# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ទីឃនិកាយ  មជ្ឈិមបណ្ណាសក
# ចតុត្ថភាគ
# ២៣



ផ្សព្វផ្សាយដោយសម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

## MAJJHIMANIKĀYA

## MAJJHIMAPAṆṆĀSAKA

## CATUTTHABHĀGA

## 23

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammayutt Sangkat Chatumuk Khan Daun Penh P.Penh

Printed and donated for free distribution by

**The Corporate Body of the Buddha Educational Foundation**

11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website:http://www.budaedu.org

**This book is strictly for free distribution, it is not for sale.**

**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# សេចក្តីណែនាំក្នុងការអាន

១ ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរៈ **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស្ស** គឺ **តស្ស** ។

២ ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (ជួន-ណាត) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣ ចំពោះ **សន្ទឹកច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

# មជ្ឈិមនិកាយ  មជ្ឈិមបណ្ណាសក

# ចតុត្ថភាគ

# ២៣

# ព. ស. ២៥០៤

# សុត្តន្តបិដកេ មជ្ឈិមនិកាយស្ស

# មជ្ឈិមបណ្ណាសកំ

# ចតុត្ថោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## គហបតិវគ្គោ

## បឋមំ កន្ទរកសុត្តំ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ចម្បាយំ វិហរតិ គគ្គរាយ ពោក្ខរណិយា តីរេ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ អថខោ បេស្សោ ច ហត្ថារោហបុត្តោ កន្ទរកោ ច បរិព្វាជកោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា បេស្សោ ហត្ថារោហបុត្តោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ កន្ទរកោ បន បរិព្វាជកោ ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ កន្ទរកោ បរិព្វាជកោ

# សុត្តន្តបិដក មជ្ឈិមនិកាយ

# មជ្ឈិមបណ្ណាសកៈ

# ចតុត្ថភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

# គហបតិវគ្គ

## កន្ទរកសូត្រ ទី ១

*[១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតឆ្នេរស្រះគគ្គរា ក្បែរក្រុងចម្បា ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ។ សម័យនោះឯង បេស្សហត្ថារោហបុត្រ[១] និងកន្ទរកបរិព្វាជក នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបបេស្សហត្ថារោហបុត្រ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ឯកន្ទរកបរិព្វាជក និយាយរាក់ទាក់ ជាមួយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ និងពាក្យដែលគួររលឹកហើយ ឋិតនៅក្នុងទីដ៏សមគួរ ។ លុះកន្ទរកបរិព្វាជកឋិតនៅក្នុងទីសមគួរហើយ*

១ ឈ្មោះបេស្សៈ ជាកូនទ្រម័កដំរី ។ អដ្ឋកថា ។

២



តុណ្ហីភូតំ តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា ភគវន្តំ ឯតទវោច អច្ឆរិយំ ភោ គោតម អព្ភូតំ ភោ គោតម យាវញ្ចិទំ ភោតា គោតមេន សម្មា ភិក្ខុសង្ឃោ បដិបាទិតោ យេបិ តេ ភោ គោតម អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេបិ ភគវន្តោ ឯតបរមំយេវ សម្មា ភិក្ខុសង្ឃំ បដិបា-ទេសុំ សេយ្យថាបិ ឯតរហិ ភោតា គោតមេន សម្មា ភិក្ខុសង្ឃោ បដិបាទិតោ យេបិ តេ ភោ គោតម ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មា-សម្ពុទ្ធា តេបិ ភគវន្តោ ឯតបរមំយេវ សម្មា ភិក្ខុសង្ឃំ បដិបាទេស្សន្តិ សេយ្យថាបិ ឯតរហិ ភោតា គោតមេន សម្មា ភិក្ខុសង្ឃោ បដិបាទិតោតិ ។

ក្រឡេកមៀងមើលភិក្ខុសង្ឃ ដែលគង់នៅស្ងៀមស្ងាត់ ហើយក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ ព្រោះព្រះគោតមដ៏ចម្រើន បានប្រដៅភិក្ខុសង្ឃមានប្រមាណប៉ុណ្ណោះ ឲ្យប្រតិបត្តិដោយល្អ បពិត្រព្រះគោតមដ៏ចម្រើន ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា មានហើយក្នុងអតីតកាល តើព្រះអរហន្តសម្មាសម្ពុទ្ធ មានព្រះភាគទាំង-ឡាយនោះ ប្រដៅភិក្ខុសង្ឃដោយល្អ អស់កំណត់ត្រឹមប៉ុណ្ណោះ ដូចជាភិក្ខុសង្ឃដែលព្រះគោតមដ៏ចម្រើន ប្រដៅដោយល្អ ក្នុងកាលឥឡូវនេះដែរឬ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត ព្រះអរហន្តសម្មាសម្ពុទ្ធ ទាំង-ឡាយណា នឹងមានក្នុងអនាគតកាល តើព្រះអរហន្តសម្មាសម្ពុទ្ធ មានព្រះភាគទាំងឡាយនោះ នឹងប្រដៅភិក្ខុសង្ឃដោយល្អ អស់កំណត់ត្រឹមប៉ុណ្ណោះ ដូចជាភិក្ខុសង្ឃដែលព្រះគោតមដ៏ចម្រើន ប្រដៅដោយល្អក្នុងកាលឥឡូវនេះដែរឬ ។

គហបតិវគ្គស្ស  កន្ទរកសុត្តេ  សម្មាបដិបាទនំ

[២] ឯវមេតំ កន្ទរក ឯវមេតំ កន្ទរក យេបិ តេ កន្ទរក អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មា-សម្ពុទ្ធា តេបិ ភគវន្តោ ឯតបរមំយេវ សម្មា ភិក្ខុ-សង្ឃំ បដិបាទេសុំ សេយ្យថាបិ ឯតរហិ មយា សម្មា ភិក្ខុសង្ឃោ បដិបាទិតោ យេបិ តេ កន្ទរក ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេបិ ភគវន្តោ ឯតបរមំយេវ សម្មា ភិក្ខុសង្ឃំ បដិបាទេស្សន្តិ សេយ្យថាបិ ឯតរហិ មយា សម្មា ភិក្ខុសង្ឃោ បដិបាទិតោ សន្តិ ហិ កន្ទរក ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អរហន្តោ ខីណាសវា វុសិតវន្តោ កត-ករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណ-ភវសញ្ញោជនា សម្មទញ្ញា វិមុត្តា សន្តិ បន កន្ទរក ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ សេខា សន្តតសីលា សន្តតវុត្តិនោ និបកា និបកវុត្តិនោ

គហបតិវគ្គ កន្ទរកសូត្រ ការទ្រង់ប្រដៅដោយល្អ

[២] ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលកន្ទរកៈ ដំណើរនុ៎ះយ៉ាងនេះហើយ ម្នាលកន្ទរកៈ ដំណើរនោះយ៉ាងនេះហើយ ម្នាលកន្ទរកៈ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា មានហើយក្នុងអតីតកាល ព្រះអរហន្តសម្មាសម្ពុទ្ធ មានព្រះភាគទាំងឡាយនោះ ក៏បានប្រដៅភិក្ខុសង្ឃដោយល្អ អស់កំណត់ត្រឹមប៉ុណ្ណោះឯង ដូចជាភិក្ខុសង្ឃ ដែលតថាគតប្រដៅដោយល្អ ក្នុងកាលឥឡូវនេះដែរ ម្នាលកន្ទរកៈ ព្រះអរហន្ត-សម្មាសម្ពុទ្ធទាំងឡាយណា នឹងមានក្នុងអនាគតកាល ព្រះអរហន្តសម្មា-សម្ពុទ្ធ មានព្រះភាគទាំងឡាយនោះ ក៏នឹងប្រដៅភិក្ខុសង្ឃដោយល្អ អស់កំណត់ត្រឹមប៉ុណ្ណោះឯង ដូចជាភិក្ខុសង្ឃ ដែលតថាគតប្រដៅដោយល្អ ក្នុងកាលឥឡូវនេះដែរ ម្នាលកន្ទរកៈ ព្រោះក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុខ្លះជាអរហន្តខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយៈរួចហើយ បានធ្វើសោឡសកិច្ចរួចស្រេច បានដាក់ភារៈចុះហើយ ធ្វើប្រយោជន៍របស់ខ្លួនឲ្យស្រេចហើយ អស់សំយោជនៈក្នុងភពហើយ មានចិត្តផុតស្រឡះហើយ ព្រោះត្រាស់ដឹងដោយប្រពៃ ម្នាលកន្ទរកៈ មួយទៀត ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុខ្លះ ជាសេក្ខបុគ្គល រក្សាសីលជាប់ជានិច្ច ប្រព្រឹត្តនៅក្នុងសីលជាប់ជានិច្ច មានបញ្ញាខ្ជាប់ខ្ជួន ប្រព្រឹត្តនៅក្នុងបញ្ញាខ្ជាប់ខ្ជួន ពួក

តេ ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តា វិហរន្តិ កតមេសុ ចតូសុ ឥធ កន្ទរក ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សន្តិ ។

[៣] ឯវំ វុត្តេ បេស្សោ ហត្ថារោហបុត្តោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុប្បញ្ញត្តា ចិមេ ចត្តារោ សតិប្បដ្ឋានា សត្តានំ វិសុទ្ធិយា សោក-

ភិក្ខុទាំងនោះតម្កល់ចិត្តស៊ប់ ក្នុងសតិប្បដ្ឋាន ៤ ឯសតិប្បដ្ឋាន ៤ នោះ តើដូចម្តេចខ្លះ ម្នាលកន្ទរក: ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយដោយប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈនិងសតិ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកគឺកាយ ពិចារណានូវវេទនាក្នុងវេទនា ដោយប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈនិងស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ពិចារណានូវចិត្តក្នុងចិត្ត ដោយប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈនិងស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ពិចារណានូវធម៌ក្នុងធម៌ដោយប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈនិងស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ។

[៣] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ បេស្សហត្ថារោហបុត្រ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ ព្រោះសតិប្បដ្ឋានទាំង ៤ ដែលព្រះអង្គទ្រង់បញ្ញត្តហើយដោយល្អនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធ ដល់ពួកសត្វ ដើម្បីកន្លងបង់នូវសេចក្តីសោក

៤



បរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ មយម្បិ ហិ ភន្តេ គិហី ឱទាតវសនា កាលេន កាលំ ឥមេសុ ចតូសុ សតិប្បដ្ឋានេសុ សុប្បតិដ្ឋិតចិត្តា វិហរាម ឥធ មយំ ភន្តេ កាយេ កាយានុបស្សិនោ[១] វិហរាម អាតាបិនោ សម្បជានា សតិមន្តោ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សិនោ[២] វិហរាម អាតាបិនោ សម្បជានា សតិមន្តោ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ចិត្តេ ចិត្តានុបស្សិនោ[៣] វិហរាម អាតាបិនោ សម្បជានា សតិមន្តោ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ធម្មេសុ ធម្មានុបស្សិនោ[៤] វិហរាម អាតាបិនោ សម្បជានា សតិមន្តោ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវញ្ចិទំ ភន្តេ ភគវា ឯវំ មនុស្សគហនេ

---

១ ឱ. កាយានុបស្សី ។ ២ ឱ. វេទនានុបស្សី ។ ៣ ឱ. ចិត្តានុបស្សី ។ ៤ ឱ. ធម្មានុបស្សី ។

ខ្សឹកខ្សួល ដើម្បីធ្វើទុក្ខនិងទោមនស្សឲ្យអស់ទៅ ដើម្បីបានអរិយមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វានជាប្រាកដ បពិត្រព្រះអង្គដ៏ចម្រើន ឯពួកខ្ញុំព្រះអង្គ ជាគ្រហស្ថស្លៀកពាក់ស តែងមានចិត្តតាំងល្អក្នុងសតិ-ប្បដ្ឋានទាំង ៤ នេះ មួយដងមួយកាល បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ ជាអ្នកពិចារណានូវកាយក្នុងកាយនេះ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈនិងស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោ-មនស្សក្នុងលោក ពួកខ្ញុំព្រះអង្គតែងពិចារណានូវវេទនាក្នុងវេទនា មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈនិងស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ពួកខ្ញុំព្រះអង្គ តែងពិចារណានូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈនិងស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ពួកខ្ញុំព្រះអង្គ តែងពិចារណានូវធម៌ក្នុងធម៌ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈនិងស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាកាលបើមនុស្សមានចិត្តសាំញ៉ាំយ៉ាងនេះ

ឯវំ មនុស្សកសដេ ឯវំ មនុស្សសាឋេយ្យេ វត្តមានេ សត្តានំ ហិតាហិតំ ជានាតិ គហនញ្ហេតំ ភន្តេ យទិទំ មនុស្សា ឧត្តានកញ្ហេតំ ភន្តេ យទិទំ បសវោ អហញ្ហិ ភន្តេ បហោមិ ហត្ថិទម្មំ សារេតុំ យាវតកេន អន្តរេន ចម្បំ គតាគតំ ករិស្សតិ សព្វានិ តានិ សាឋេយ្យានិ កូដេយ្យានិ វង្កេយ្យានិ ជិម្ហេយ្យានិ បាតុករិស្សតិ អម្ហាកំ បន ភន្តេ ទា-សាតិ វា បេស្សាតិ វា កម្មករាតិ វា អញ្ញថា ច កាយេន សមុទាចរន្តិ អញ្ញថា ច វាចាយ អញ្ញថា ច នេសំ ចិត្តំ ហោតិ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវញ្ចិទំ ភន្តេ ភគវា ឯវំ មនុស្សគហនេ ឯវំ មនុស្សកសដេ ឯវំ មនុស្សសាឋេយ្យេ វត្តមានេ

កាលបើមនុស្សមានចិត្តស្រកាក មិនបរិសុទ្ធយ៉ាងនេះ កាលបើមនុស្សមានកិច្ចកល ប្រព្រឹត្តទៅយ៉ាងនេះ ព្រះមានព្រះភាគ គង់ជ្រាបនូវសេចក្តីប្រតិបត្តិដែលជាប្រយោជន៍ និងមិនមែនជាប្រយោជន៍ របស់សត្វទាំងឡាយបានប្រាកដ បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សមានចិត្តសាំញ៉ាំ បពិត្រព្រះអង្គដ៏ចម្រើន ពួកសត្វចិញ្ចឹម មានចិត្តឲ្យងាយយល់ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខាងខ្ញុំព្រះអង្គអាចទូន្មានដំរី ដែលល្មមទូន្មានបាន ក្នុងខណៈដែលទូន្មានដំរីមួយរំពេចនោះ នឹងដើរទៅដើរមកកាន់នគរចម្បាបាន (តែលុះយូរទៅ) ដំរីនឹងធ្វើកិច្ចកលគ្រប់យ៉ាង គឺក្រអើតក្រអោង កោងកាច វៀចវេរ គ្រលែងខ្លួនឲ្យប្រាកដឡើង បពិត្រព្រះអង្គដ៏ចម្រើន ចំណែកពួកជនជាខ្ញុំកំដរក្តី អ្នកបម្រើក្តី អ្នកស៊ីឈ្នួលក្តី របស់ខ្ញុំព្រះអង្គ តែងប្រព្រឹត្តទៅដោយកាយផ្សេង ដោយវាចាផ្សេង ទាំងចិត្តរបស់វាផ្សេង បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាកាលបើមនុស្សមានចិត្តសាំញ៉ាំយ៉ាងនេះ កាលបើមនុស្សមានចិត្តស្រកាក មិនបរិសុទ្ធយ៉ាងនេះ កាលបើមនុស្ស មានកិច្ចកល ប្រព្រឹត្តទៅ

### គហបតិវគ្គស្ស កន្ទរកសុត្តេ ចត្តារោ បុគ្គលា

ហិតាហិតំ ជានាតិ គហនញ្ហេតំ ភន្តេ យទិទំ មនុស្សា ឧត្តានកញ្ហេតំ ភន្តេ យទិទំ បសវោតិ ។

[៤] ឯវមេតំ បេស្ស ឯវមេតំ បេស្ស គហនញ្ហេតំ បេស្ស យទិទំ មនុស្សា ឧត្តានកញ្ហេតំ បេស្ស យទិទំ បសវោ ចត្តារោមេ បេស្ស បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ កតមេ ចត្តារោ ឥធ បេស្ស ឯកច្ចោ បុគ្គលោ អត្តន្តបោ ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ ឥធ បន បេស្ស ឯកច្ចោ បុគ្គលោ បរន្តបោ ហោតិ បរបរិតាបនានុយោគមនុយុត្តោ ឥធ បេស្ស ឯកច្ចោ បុគ្គលោ អត្តន្តបោ ច ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ ឥធ បន បេស្ស ឯកច្ចោ បុគ្គលោ

យ៉ាងនេះ ព្រះមានព្រះភាគ គង់ជ្រាបនូវសេចក្តីប្រតិបត្តិ ជាប្រយោជន៍ និងមិនជាប្រយោជន៍ (របស់សត្វទាំងនោះ) ជាប្រាកដ បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សមានចិត្តសាំញ៉ាំ បពិត្រព្រះអង្គដ៏ចម្រើន ពួកសត្វចិញ្ចឹម មានចិត្តងាយយល់ ។

[៤] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលបេស្ស: ដំណើរនុ៎ះយ៉ាងនេះហើយ ម្នាលបេស្ស: ដំណើរនុ៎ះយ៉ាងនេះហើយ ម្នាលបេស្ស: ពួកមនុស្សមានចិត្តសាំញ៉ាំ ម្នាលបេស្ស: ពួកសត្វចិញ្ចឹមមានចិត្តឲ្យងាយយល់ ម្នាលបេស្ស: បុគ្គល ៤ ពួកនេះ តែងមានក្នុងលោក បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ម្នាលបេស្ស: ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាអ្នកដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ១ ម្នាលបេស្ស: ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាអ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ ១ ម្នាលបេស្ស: ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាអ្នកដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯងផង ជាអ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃផង ១ ម្នាលបេស្ស: ក្នុងលោកនេះ បុគ្គលពួកខ្លះ

នេវត្តន្តបោ ហោតិ នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ឥមេសំ បេស្ស ចតុន្នំ បុគ្គលានំ កតមោ តេ បុគ្គលោ ចិត្តំ អារាធេតីតិ ។

[៤] យ្វាយំ ភន្តេ បុគ្គលោ អត្តន្តបោ អត្តបរិតាបនានុយោគមនុយុត្តោ អយំ មេ បុគ្គលោ ចិត្តំ នារាធេតិ យោចាយំ ភន្តេ បុគ្គលោ បរន្តបោ បរបរិតាបនានុយោគមនុយុត្តោ អយម្បិ មេ បុគ្គលោ ចិត្តំ នារាធេតិ យោចាយំ ភន្តេ បុគ្គលោ អត្តន្តបោ ច អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ អយម្បិ មេ បុគ្គលោ ចិត្តំ នារាធេតិ យោ ច ខោ អយំ ភន្តេ បុគ្គលោ នេវត្តន្តបោ នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ

ជាអ្នកមិនដុតកម្តៅខ្លួនឯង មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ជាអ្នកមិនដុតកម្តៅអ្នកដទៃ មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលជាអ្នកមិនដុតកម្តៅខ្លួនឯង ទាំងមិនដុតកម្តៅអ្នកដទៃនោះ ជាអ្នកអស់សេចក្តីស្រេកឃ្លាន ក្នុងបច្ចុប្បន្ននេះ ជាអ្នករលត់ទុក្ខ មានសេចក្តីត្រជាក់ ទទួលនូវសេចក្តីសុខ រមែងមានខ្លួនដ៏ប្រសើរ ១ ម្នាលបេស្សៈ បណ្តាបុគ្គលទាំង ៤ ពួកនេះ តើបុគ្គលពួកណា ធ្វើចិត្តអ្នកឲ្យត្រេកអរបាន ។

[៥] បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង បុគ្គលនេះ មិនធ្វើចិត្តខ្ញុំព្រះអង្គឲ្យត្រេកអរទេ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលនេះ ក៏ធ្វើចិត្តរបស់ខ្ញុំព្រះអង្គ ឲ្យត្រេកអរមិនបានដែរ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯងផង ជាអ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃផង បុគ្គលនេះ ក៏ធ្វើចិត្តរបស់ខ្ញុំព្រះអង្គ ឲ្យត្រេកអរមិនបានដែរ បពិត្រព្រះអង្គដ៏ចម្រើន លុះតែបុគ្គលណា មិនដុតកម្តៅខ្លួនឯង មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ជាអ្នកមិនដុតកម្តៅអ្នកដទៃ

ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ អយំ មេ បុគ្គលោ ចិត្តំ អារាធេតីតិ ។ កស្មា បន តេ បេស្ស ឥមេ តយោ បុគ្គលា ចិត្តំ នារាធេន្តីតិ ។

[៦] យ្វាយំ ភន្តេ បុគ្គលោ អត្តន្តបោ អត្តបរិតាបនានុយោគមនុយុត្តោ សោ អត្តានំ សុខកាមំ ទុក្ខប្បដិក្កូលំ អាតាបេតិ បរិតាបេតិ ឥមិនា មេ អយំ បុគ្គលោ ចិត្តំ នារាធេតិ យោចាយំ ភន្តេ បុគ្គលោ បរន្តបោ បរបរិតាបនានុយោគមនុយុត្តោ សោ បរំ សុខកាមំ ទុក្ខប្បដិក្កូលំ អាតាបេតិ បរិតាបេតិ ឥមិនា មេ អយំ បុគ្គលោ ចិត្តំ នារាធេតិ យោចាយំ ភន្តេ បុគ្គលោ អត្តន្តបោ ច

មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលជាអ្នកមិនដុតកម្តៅខ្លួនឯង ទាំងមិនដុតកម្តៅអ្នកដទៃនោះ ជាអ្នកអស់សេចក្តីស្រេកឃ្លាន ក្នុងបច្ចុប្បន្ននេះ ជាអ្នករលត់ទុក្ខ មានសេចក្តីត្រជាក់ ទទួលសេចក្តីសុខ ជាអ្នកមានខ្លួនប្រសើរ បុគ្គលនេះ ទើបធ្វើចិត្តរបស់ខ្ញុំព្រះអង្គឲ្យត្រេកអរបាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលបេស្សៈ ចុះបុគ្គល ៣ ពួកនេះ ធ្វើចិត្តរបស់អ្នក ឲ្យត្រេកអរមិនបាន តើដោយហេតុអ្វី ។

[៦] បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង បុគ្គលនោះឈ្មោះថាធ្វើខ្លួនឯងដែលប្រាថ្នាសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខ ឲ្យក្តៅរោលរាលអន្ទះ-អន្ទែង ដោយហេតុនេះឯង បានជាបុគ្គលនេះ ធ្វើចិត្តរបស់ខ្ញុំព្រះអង្គឲ្យត្រេកអរមិនបាន បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលនោះឈ្មោះថាធ្វើអ្នកដទៃដែលប្រាថ្នាសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខឲ្យក្តៅរោលរាលអន្ទះ-អន្ទែង ដោយហេតុនេះឯង បានជាបុគ្គលនេះ ធ្វើចិត្តរបស់ខ្ញុំព្រះអង្គឲ្យត្រេកអរមិនបាន បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅខ្លួនឯង

អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរ-
បរិតាបនានុយោគមនុយុត្តោ សោ អត្តានញ្ច បរញ្ច
សុខកាមំ ទុក្ខប្បដិក្កូលំ អាតាបេតិ បរិតាបេតិ
ឥមិនា មេ អយំ បុគ្គលោ ចិត្តំ នារាធេតិ យោ
ច ខោ អយំ បុគ្គលោ នេវត្តន្តបោ នាត្តបរិ-
តាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតា-
បនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ
ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្ប-
ដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ឥមិនា មេ
អយំ បុគ្គលោ ចិត្តំ អារាធេតិ ហន្ទ ចទានិ
មយំ ភន្តេ គច្ឆាម ពហុកិច្ចា មយំ ពហុករណី-
យាតិ ។ យស្សទានិ ត្វំ បេស្ស កាលំ មញ្ញសី-
តិ ។ អថខោ បេស្សោ ហត្ថារោហបុត្តោ ភគវតោ
ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា
ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯងផង ជាអ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃផង បុគ្គលនោះឈ្មោះថាធ្វើខ្លួនឯងនិងអ្នកដទៃ ដែលប្រាថ្នាសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខឲ្យក្តៅពោលពាលអន្ទះអន្ទែង ដោយហេតុនេះឯង បានជាបុគ្គលនេះធ្វើចិត្តរបស់ខ្ញុំព្រះអង្គឲ្យត្រេកអរមិនបាន បពិត្រព្រះអង្គដ៏ចម្រើន លុះតែបុគ្គលណា មិនដុតកម្តៅខ្លួនឯង មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ជាអ្នកមិនដុតកម្តៅអ្នកដទៃ មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលជាអ្នកមិនដុតកម្តៅខ្លួនឯង មិនដុតកម្តៅអ្នកដទៃនោះ ជាអ្នកអស់សេចក្តីស្រេកឃ្លានក្នុងបច្ចុប្បន្ន ជាអ្នករលត់ទុក្ខ មានសេចក្តីត្រជាក់ ទទួលសេចក្តីសុខ ជាអ្នកមានខ្លួនប្រសើរ បុគ្គលនេះទើបធ្វើចិត្តរបស់ខ្ញុំព្រះអង្គ ឲ្យជ្រះថ្លា ឲ្យត្រេកអរបាន ដោយហេតុនេះឯង បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះខ្ញុំព្រះអង្គនឹងលាទៅ ព្រោះខ្ញុំព្រះអង្គមានកិច្ចច្រើន មានអំពើដែលត្រូវធ្វើច្រើន ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលបេស្សៈ អ្នកចូរដឹងកាលនៃដំណើរទៅរបស់អ្នក ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ បេស្សហត្ថារោហបុត្រ ត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ក្រោកចាកអាសនៈ រួចថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏ដើរចេញទៅ ។

១១

គហបតិវគ្គស្ស កន្ទរកសុត្តេ បេស្សហត្ថារោហបុត្តប្បសំសា

[៧] អថខោ ភគវា អចិរប្បក្កន្តេ បេស្សេ ហត្ថារោហបុត្តេ ភិក្ខូ អាមន្តេសិ បណ្ឌិតោ ភិក្ខវេ បេស្សោ ហត្ថារោហបុត្តោ មហាបញ្ញោ ភិក្ខវេ បេស្សោ ហត្ថារោហបុត្តោ សចេ ភិក្ខវេ បេស្សោ ហត្ថារោហបុត្តោ មុហុត្តំ និសីទេយ្យ យាវស្សាហំ ឥមេ ចត្តារោ បុគ្គលេ វិត្ថារេន វិភជិស្សាមិ មហតា អត្ថេន សំយុត្តោ អភវិស្ស អបិច ភិក្ខវេ ឯត្តាវតាបិ បេស្សោ ហត្ថារោហបុត្តោ មហតា អត្ថេន សំយុត្តោតិ ។ ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា ឥមេ ចត្តារោ បុគ្គលេ វិត្ថារេន វិភជេយ្យ វិត្ថារេន ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

គហបតិវគ្គ កន្ទរកសូត្រ ការទ្រង់សរសើរពេស្សហត្ថារោហបុត្រ

[៧] កាលដែលពេស្សហត្ថារោហបុត្រ ចេញទៅមិនទាន់បានយូរប៉ុន្មាន ខាងក្រោយនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ទៅនឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ពេស្សហត្ថារោហបុត្រ ជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ ពេស្សហត្ថារោហបុត្រ ជាអ្នកមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពេស្សហត្ថារោហបុត្រ អង្គុយនៅមួយស្របក់ទៀត ទម្រាំតថាគតនឹងចែកនូវបុគ្គលទាំង ៤ ពួកនេះដោយពិស្តារសិន គាត់មុខជានឹងបានសម្រេចប្រយោជន៍ច្រើន (ដល់សោតាបត្តិផល) ម្នាលភិក្ខុទាំង-ឡាយ តែបើទុកជាដូច្នោះ ពេស្សហត្ថារោហបុត្រ ក៏គង់តែបានប្រកបដោយប្រយោជន៍[១]ច្រើន ត្រឹមហេតុប៉ុណ្ណោះដែរ ។ ពួកភិក្ខុក្រាបបង្គំទូលថា ព្រះមានព្រះភាគ គប្បីចែកបុគ្គល ៤ ពួកនេះ ដោយសេចក្តីពិស្តារ ដោយភាសិតណា បពិត្រព្រះមានព្រះភាគ នេះជាកាលគួរដល់ភាសិតនុ៎ះ បពិត្រព្រះសុគត នេះជាកាលគួរដល់ភាសិតនុ៎ះ ពួកភិក្ខុបើបានស្តាប់ភាសិត របស់ព្រះមានព្រះភាគដោយពិស្តារហើយ នឹងចងចាំបាន ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរប្រុងស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែងឥឡូវនេះ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ករុណា ព្រះអង្គ ។

---

១ គឺបានសេចក្តីជ្រះថ្លាក្នុងភិក្ខុសង្ឃផង កើតសេចក្តីយល់ជាថ្មីទៀតក្នុងការចម្រើនសតិ-ប្បដ្ឋានផង ។ អដ្ឋកថា ។

[៨] ភគវា ឯតទវោច កតមោ ច ភិក្ខវេ បុគ្គលោ អត្តន្តបោ អត្តបរិតាបនានុយោគមនុយុត្តោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អចេលកោ ហោតិ មុត្តាចារោ ហត្ថាវលេខនោ[១] ន ឯហិភទន្តិកោ ន តិដ្ឋភទន្តិកោ នាភិហតំ ន ឧទិស្ស កតំ ន និមន្តនំ សាទិយតិ សោ ន កុម្ភិមុខា បដិគ្គណ្ហាតិ ន កឡោ-បិមុខា បដិគ្គណ្ហាតិ ន ឯឡកមន្តរំ ន ទណ្ឌមន្តរំ ន មុសលមន្តរំ ន ទ្វិន្នំ ភុញ្ជមានានំ ន គព្ភិនិយា ន បាយមានាយ ន បុរិសន្តរគតាយ ន សង្កិត្តីសុ ន យត្ថ សា ឧបដ្ឋិតោ ហោតិ ន យត្ថ មក្ខិកា សណ្ឌ-សណ្ឌចារិនី ន មច្ឆំ ន មំសំ ន សុរំ ន មេរយំ ន ថុសោទកំ បិវតិ ។ សោ ឯកាគារិកោ វា ហោតិ

១ ឱ. ម. ហត្ថាបលេខនោ ។

[៨] ព្រះមានព្រះភាគ ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាអ្នកមានកាយអាក្រាត លះបង់មារយាទល្អ ជាអ្នកប្រព្រឹត្តហត្ថាវលេខនៈ ជាអ្នកមិនទទួលភត្តដែលគេនិមន្តថា សូមលោកដំចម្រើនចូរមក ជាអ្នកមិនទទួលភត្តដែលគេនិមន្តថា សូមលោកដំចម្រើនរង់ចាំសិន មិនត្រេកអរនឹងភិក្ខាដែលគេនាំមកចាំមុន មិនត្រេកអរនឹងភិក្ខាដែលគេធ្វើចំពោះខ្លួន មិនត្រេកអរនឹងការនិមន្ត បុគ្គលនោះ មិនទទួលភិក្ខាអំពីមាត់ឆ្នាំង មិនទទួលភិក្ខាអំពីមាត់កូនល្អី មិនទទួលភិក្ខាក្នុងចន្លោះធរណីទ្វារ មិនទទួលភិក្ខាក្នុងចន្លោះកំណាត់ឈើ មិនទទួលភិក្ខាក្នុងចន្លោះអង្រែ មិនទទួលភិក្ខារបស់ជនពីរនាក់ ដែលកំពុងបរិភោគ មិនទទួលភិក្ខារបស់ស្ត្រីមានគភ៌ មិនទទួលភិក្ខារបស់ស្រី ដែលកំពុងបំបៅកូន មិនទទួលភិក្ខារបស់ស្រី ដែលកំពុងនៅក្នុងចន្លោះបុរស មិនទទួលភិក្ខាដែលគេអង្គាសគ្នាធ្វើ មិនទទួលភិក្ខាក្នុងទីដែលមានសុនខនៅចាំ មិនទទួលភិក្ខាដែលរុយរោម មិនបរិភោគត្រី មិនបរិភោគសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំត្រាំ ។ បុគ្គលនោះទទួលភិក្ខាចំពោះតែក្នុងផ្ទះមួយ

ឯកាលោបិកោ ទ្វាគារិកោ វា ហោតិ ទ្វាលោបិកោ ។ បេ ។ សត្តាគារិកោ វា ហោតិ សត្តាលោបិកោ ឯកិស្សាបិ ទត្តិយា យាបេតិ ទ្វីហិបិ ទត្តីហិ យាបេតិ ។ បេ ។ សត្តហិបិ ទត្តីហិ យាបេតិ ឯកាហិកម្បិ[១] អាហារំ អាហារេតិ ទ្វីហិកម្បិ អាហារំ អាហារេតិ ។ បេ ។ សត្តាហិកម្បិ អាហារំ អាហារេតិ ឥតិ ឯវរូបម្បិ[២] អឌ្ឍមាសិកំ[៣] បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតិ ។ សោ សាកភក្ខោ វា ហោតិ សាមាកភក្ខោ វា ហោតិ នីវារភក្ខោ វា ហោតិ ទទ្ទុលភក្ខោ វា ហោតិ ហដភក្ខោ វា ហោតិ កណភក្ខោ វា ហោតិ អាចាមភក្ខោ វា ហោតិ បិញ្ញាកភក្ខោ វា ហោតិ តិណភក្ខោ វា ហោតិ គោមយភក្ខោ វា ហោតិ វនមូលផលាហារោ វា យាបេតិ បវត្តផលភោជី ។ សោ សាណានិបិ ធារេតិ មសាណានិបិ ធារេតិ ឆវទុស្សានិបិ ធារេតិ បំសុកូលានិបិ ធារេតិ តិរីដានិបិ ធារេតិ

---

១ ម. ឯកាហិកំបិ ។ ២ ឱ. ឯវរូបំ ។ ម. ឯវរូបំបិ ។ ៣ ឱ. អទ្ធមាសិកម្បិ ។ ម. អទ្ធមាសិកំ ។

ឬទទួលបាយតែមួយពំនូត ទទួលភិក្ខាចំពោះតែក្នុងផ្ទះពីរ ឬទទួលបាយតែពីរពំនូត ។ បេ ។ ទទួលភិក្ខាចំពោះតែក្នុងផ្ទះ ៧ ឬទទួលបាយតែ ៧ ពំនូត ចិញ្ចឹមអត្តភាពដោយភិក្ខាក្នុងភាជន៍តូចមួយក៏មាន ចិញ្ចឹមអត្តភាពដោយភិក្ខាក្នុងភាជន៍ពីរក៏មាន ។ បេ ។ ចិញ្ចឹមអត្តភាពដោយភិក្ខាក្នុងភាជន៍ ៧ ក៏មាន បរិភោគអាហាររំលង ១ ថ្ងៃក៏មាន បរិភោគអាហាររំលងពីរថ្ងៃក៏មាន ។ បេ ។ បរិភោគអាហាររំលង ៧ ថ្ងៃក៏មាន ប្រកបរឿយ ៗ នូវព្យាយាមក្នុងកិរិយាបរិភោគនូវភត្ត ដោយការផ្លាស់ប្តូរគ្នាកន្លះខែដូច្នេះឯង ។ បុគ្គលនោះបរិភោគបន្លែស្រស់ក៏មាន បរិភោគស្កួយក៏មាន បរិភោគគ្រាប់ស្មៅគែលលកក៏មាន បរិភោគចំនៀរស្បែកក៏មាន បរិភោគសារាយក៏មាន បរិភោគកុណ្ឌកក៏មាន បរិភោគបាយក្តាំងក៏មាន បរិភោគម្សៅក៏មាន បរិភោគស្មៅក៏មាន បរិភោគអាចម៍គោក៏មាន បរិភោគមើមនិងផ្លែក្នុងព្រៃក៏មាន បរិភោគផ្លែដែលជ្រុះចុះឯងក៏មាន ។ បុគ្គលនោះប្រើប្រាស់សំពត់ ដែលត្បាញដោយសំបកធ្មៃក៏មាន ប្រើប្រាស់សំពត់ដែលត្បាញលាយគ្នាក៏មាន ប្រើប្រាស់សំពត់ដែលគេរុំសពក៏មាន ប្រើប្រាស់សំពត់បង្សុកូលក៏មាន ប្រើប្រាស់សំពត់សម្បកឈើ

អជិនានិបិ ធារេតិ អជិនក្ខិបម្បិ ធារេតិ កុសចីរម្បិ ធារេតិ វាកចីរម្បិ ធារេតិ ផលកចីរម្បិ ធារេតិ កេសកម្ពលម្បិ ធារេតិ វាលកម្ពលម្បិ ធារេតិ ឧលូកបក្ខម្បិ ធារេតិ កេសមស្សុលោចកោបិ ហោតិ កេសមស្សុលោចនានុយោគមនុយុត្តោ ឧព្ភដ្ឋកោបិ ហោតិ អាសនប្បដិក្ខិត្តោ ឧក្កុដិកោបិ ហោតិ ឧក្កុដិកប្បធានមនុយុត្តោ កណ្ដកាបស្សយិកោបិ ហោតិ កណ្ដកាបស្សយេ សេយ្យំ កប្បេតិ សាយតតិយកម្បិ ឧទកោរោហនានុយោគមនុយុត្តោ វិហរតិ ឥតិ ឯវរូបំ អនេកវិហិតំ កាយស្ស អាតាបនបរិតាបនានុយោគមនុយុត្តោ វិហរតិ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អត្តន្តបោ អត្តបរិតាបនា-នុយោគមនុយុត្តោ ។

[៩] កតមោ ច ភិក្ខវេ បុគ្គលោ បរន្តបោ បរបរិតាបនានុយោគមនុយុត្តោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឱរព្ភិកោ(១) ហោតិ សូករិកោ សាកុ-ណិកោ(២) មាគវិកោ លុទ្ទោ មច្ឆឃាតកោ ចោរោ

១ ម. ឱរម្ភិកោ ។ ២ ម. សាកុន្តិកោ ។ សាកុណីកោ ។

ក៏មាន ប្រើប្រាស់ស្បែកខ្លាក៏មាន ប្រើប្រាស់ស្បែកខ្លាទាំងក្រចក ក៏មាន ប្រើប្រាស់ស្បូវក្រង់ក៏មាន ប្រើប្រាស់សំពត់ដែលត្បាញ ដោយសំបកក្រចៅក៏មាន ប្រើប្រាស់សំពត់ដែលត្បាញ ដោយសំបកផ្លៃឈើក៏មាន ប្រើប្រាស់សំពត់កម្ពលដែលត្បាញដោយសក់ក៏មាន ប្រើប្រាស់សំពត់កម្ពលត្បាញដោយរោមសត្វក៏មាន ប្រើប្រាស់សំពត់ដែលត្បាញដោយស្លាបមៀមក៏មាន ជាអ្នកទុកសក់និងពុកមាត់ ពុកចង្កា ប្រកបព្យាយាមក្នុងការទុកសក់ និងពុកមាត់ ពុកចង្កាក៏មាន ជាអ្នកប្រព្រឹត្តឈរ ហាមនូវការអង្គុយក៏មាន ជាអ្នកអង្គុយច្រហោង ប្រកបព្យាយាមអង្គុយច្រហោងក៏មាន ជាអ្នកដេកលើបន្លា សម្រេចនូវការដេកលើបន្លាក៏មាន ប្រកបព្យាយាមក្នុងការចុះត្រាំទឹក ក្នុង ១ ថ្ងៃ ៣ ដងក៏មាន ខ្វល់ខ្វាយព្យាយាម ដើម្បីធ្វើឲ្យក្ដៅពោលរាលច្រើនប្រការ មានសភាពយ៉ាងនេះដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះតថាគតហៅថា អ្នកដុតកម្ដៅខ្លួនឯង ប្រកបសេចក្ដីព្យាយាម ដើម្បីដុតកម្ដៅខ្លួនឯង ។

[៩] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលដុតកម្ដៅអ្នកដទៃ ប្រកបសេចក្ដីព្យាយាម ដើម្បីដុតកម្ដៅអ្នកដទៃ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់សត្វស្លាប សម្លាប់ម្រឹគ ជាអ្នកនេសាទត្រី ជាចោរ

ចោរឃាតកោ ពន្ធនាគារិកោ យេ វា បនញ្ញេបិ កេចិ កុរូរកម្មន្តា អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ បរន្តបោ បរ-បរិតាបនានុយោគមនុយុត្តោ ។

[១០] កតមោ ច ភិក្ខវេ បុគ្គលោ អត្តន្តបោ ច អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតា-បនានុយោគមនុយុត្តោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ រាជា វា ហោតិ ខត្តិយោ មុទ្ធាវសិត្តោ ព្រាហ្មណោ វា មហាសាលោ សោ បុរត្ថិមេន នគរស្ស នវំ សន្ថាគារំ ការាបេត្វា កេសមស្សុំ ឱតារេត្វា ខរា-ជិនំ[១] និវាសេត្វា សប្បិតេលេន កាយំ អព្ភញ្ជិត្វា មិគ-វិសាណេន បិដ្ឋឹ កណ្ឌុវមានោ នវំ[២] សន្ថាគារំ បវិសតិ សទ្ធឹ មហេសិយា ព្រាហ្មណេន ច បុរោហិតេន សោ

១ ខុរាជិនន្តិបិ បាឋោ ។ ២ ឱ. ម. នវន្តិ ន ទិស្សតិ ។

ជាអ្នកពិឃាតចោរ ជាអ្នកគ្រប់គ្រង់គុក ពុំនោះសោត ពួកជនណាមួយក្រៅពីនេះ ជាអ្នកមានអំពើអាក្រក់ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ តថាគតហៅថា អ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ ។

[១០] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គល ដែលដុតកម្តៅខ្លួនឯងប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯងផង ជាអ្នកដុតកម្តៅបុគ្គលដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាស្តេច ជាក្សត្រដែលបានមុទ្ធាភិសេកក្តី ជាព្រាហ្មណមហាសាលក្តី ស្តេចនោះឲ្យគេសង់សន្ថាគារសាលាថ្មី ១ ក្នុងទិសខាងកើតនៃព្រះនគរ ហើយកោរសក់និងពុកមាត់ពុកចង្កា ស្លៀកពាក់ស្បែកខ្លាទាំងក្រចក លាបកាយដោយទឹកដោះថ្លានិងប្រេង ហើយអេះខ្នងដោយស្នែងម្រឹគ ចូលទៅកាន់សន្ថាគារសាលាជាមួយនឹងមហេសីផង ព្រាហ្មណបុរោហិតផង ស្តេចនោះ

តត្ថ អនន្តរហិតាយ ភូមិយា ហរិតុបលិត្តាយ(១) សេយ្យំ កប្បេតិ សោ(២) ឯកិស្សា គាវិយា សរូបវច្ឆាយ យំ ឯកស្មឹ ថនេ ខីរំ ហោតិ តេន រាជា យាបេតិ យំ ទុតិយស្មឹ ថនេ ខីរំ ហោតិ តេន មហេសី យាបេតិ យំ តតិយស្មឹ ថនេ ខីរំ ហោតិ តេន ព្រាហ្មណោ បុរោហិតោ យាបេតិ យំ ចតុត្ថស្មឹ ថនេ ខីរំ ហោតិ តេន អគ្គឹ ជុហតិ(៣) អវសេសេន វច្ឆកោ យាបេតិ សោ ឯវមាហ ឯត្តកា ឧសភា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា វច្ឆតរា ហញ្ញន្តុ យញ្ញ-ត្ថាយ ឯត្តិកា វច្ឆតរិយោ ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា អជា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា ឧរព្ភា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា អស្សា ហញ្ញន្តុ យញ្ញត្ថាយ(៤) ឯត្តកា រុក្ខា ឆិជ្ជន្តុ យូបត្ថាយ ឯត្តកា ទព្ភា លុយន្តុ បរិសត្ថាយាតិ(៥) យេបិស្ស តេ ហោន្តិ ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា

---

១ ឱ. ហរិតុបត្តាយ ។ ២ ឱ. ម. សោតិ ន ទិស្សតិ ។ ៣ ឱ. ម. ជុហន្តិ ។ ៤ ឱ. ឯត្តកា អស្សា ហញ្ញន្តុ យញ្ញត្ថាយាតិ ន ទិស្សតិ ។ ៥ ឱ. ពរិហិសត្ថាយាតិ ។ ម. បរិហឹសត្ថាយាតិ ។

សម្រេចទីក្រឡាព្រះបន្ទំលើផែនដី ដែលប្រកបដោយវត្ថុ មានពណ៌ខៀវ ដែលមិនស្អាតក្នុងរោងនោះ ស្តេចនោះសោយទឹកដោះស្រស់ចំពោះដោះមួយ របស់មេគោមួយ ដែលមានកូនមានរូបស្រដៀងនឹងមេ មហេសីសោយទឹកដោះស្រស់ចំពោះដោះទី ២ ព្រាហ្មណបុរោហិត ផឹកទឹកដោះស្រស់ចំពោះដោះទី ៣ បូជាភ្លើងដោយទឹកដោះស្រស់ចំពោះដោះទី ៤ ឯទឹកដោះសេសសល់ពីនោះ ទើបឲ្យកូនគោបៅ ស្តេចនោះទ្រង់ត្រាស់បង្គាប់យ៉ាងនេះថា ចូរអ្នកទាំងឡាយសម្លាប់គោឧសភ ប្រមាណប៉ុណ្ណោះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរសម្លាប់កូនគោឈ្មោលតូច ប្រមាណប៉ុណ្ណោះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរសម្លាប់កូនគោញីតូចប្រមាណប៉ុណ្ណោះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរសម្លាប់ពពែប្រមាណប៉ុណ្ណោះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរសម្លាប់ចៀមប្រមាណប៉ុណ្ណោះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរសម្លាប់សេះប្រមាណប៉ុណ្ណោះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរកាប់ឈើប្រមាណប៉ុណ្ណោះ ដើម្បីធ្វើប្រាសាទ ចូរអារកាត់គ្រឿងឈើប្រមាណប៉ុណ្ណោះ ដើម្បីធ្វើរបងនិងកម្រាលដូច្នេះ ពួកជនណាជាខ្ញុំកំដរក្តី ជាអ្នកបម្រើក្តី ជាអ្នកធ្វើការស៊ីឈ្នួលក្តី របស់ស្តេចនោះ

តេបិ ទណ្ឌតជ្ជិតា ភយតជ្ជិតា អស្សុមុខា រុទមានា បរិកម្មានិ ករោន្តិ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អត្តន្តបោ ច អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ ។

[១១] កតមោ ច ភិក្ខវេ បុគ្គលោ នេវត្តន្តបោ[១] នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ។ ឥធ ភិក្ខវេ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា

---

១ ម. នេវត្តន្តបោ ច ។

ពួកជនទាំងនោះឯង កាលបើត្រូវអាជ្ញាគម្រាមហើយ ត្រូវភ័យគម្រាមហើយ ក៏មានមុខទទឹកដោយទឹកភ្នែកទ្រហោយំធ្វើនូវការបន់ស្រន់បួងសួង (កុំឲ្យស្លាប់) ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ តថាគតហៅថា អ្នកដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯងផង ជាអ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃផង ។

[១១] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គល ដែលមិនដុតកម្តៅខ្លួនឯង មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ជាអ្នកមិនដុតកម្តៅអ្នកដទៃ មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលនោះ ឈ្មោះថា អ្នកមិនដុតកម្តៅខ្លួនឯង មិនដុតកម្តៅអ្នកដទៃ ជាអ្នកអស់សេចក្តីស្រេកឃ្លាន ក្នុងបច្ចុប្បន្ននេះ ជាអ្នករលត់ទុក្ខ មានសេចក្តីត្រជាក់ ទទួលសេចក្តីសុខ ជាអ្នកប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត កើតឡើងក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អទៅកាន់ព្រះនិព្វាន ដឹងច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ជាសារថីអ្នកទូន្មានបុរស ដែលគួរទូន្មានបាន ជាគ្រូ

ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ តំ ធម្មំ សុណាតិ គហបតិ វា គហបតិបុត្តោ វា អញ្ញតរស្មឹ វា កុលេ បច្ចាជាតោ សោ តំ ធម្មំ សុត្វា តថាគតេ សទ្ធំ បដិលភតិ សោ តេន សទ្ធាបដិលាភេន សមន្នាគតោ ឥតិ បដិសញ្ចិក្ខតិ សម្ពាធោ ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ អបរេន សមយេន អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្តំ បហាយ

នៃទេវតានិងមនុស្សទាំងឡាយ បានត្រាស់ដឹងសច្ចធម៌ លែងត្រឡប់មកកាន់ភពថ្មីទៀត ព្រះតថាគតនោះ បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញារបស់ខ្លួន នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ព្រះតថាគតនោះ សំដែងធម៌ មានលំអបទដើម បទកណ្តាលនិងបទចុង ព្រះតថាគត ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ។ គហបតី ឬកូននៃគហបតី ឬជនអ្នកកើតក្នុងត្រកូលណាមួយ ក្នុងកាលជាខាងក្រោយ រមែងបានស្តាប់ធម៌នោះ លុះគេស្តាប់ធម៌នោះហើយ ក៏បាននូវសទ្ធាក្នុងព្រះតថាគត លុះគេប្រកបដោយសទ្ធានោះ រមែងពិចារណាដូច្នេះថា ឃរាវាស ចង្អៀតណាស់ ជាផ្លូវនៃធូលី បព្វជ្ជាទើបមានឱកាសល្អ កាលបើអាត្មាអញនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ ក៏មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌តែមួយយ៉ាង ឲ្យបរិសុទ្ធតែមួយយ៉ាង ដូចជាស័ង្ខ ដែលគេខាត់ហើយនោះទេ បើដូច្នោះគួរតែអាត្មាអញកោរសក់និងពុកមាត់ ពុកចង្កា រួចស្លៀកដណ្តប់សំពត់ជ្រលក់ទឹកចត់ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ លុះសម័យខាងក្រោយមក ជននោះក៏លះគំនរទ្រព្យតិចក្តី លះគំនរទ្រព្យច្រើនក្តី លះបង់ញាតិវង្សតិចក្តី

មហន្តំ វា ញាតិបរិវដ្ដំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ។

[១២] សោ ឯវំ បព្វជិតោ សមានោ ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ ទិន្នាទាយី ទិន្នបាដិកង្ខី អថេនេន សុចិភូតេន អត្តនា វិហរតិ អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ អារាចារី[១] វិរតោ មេថុនា គាមធម្មា មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ

លះបង់ញាតិវង្សច្រើនក្តី ហើយកោរសក់និងពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់ជ្រលក់ទឹកចត់ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។

[១២] លុះជននោះបួសយ៉ាងនេះហើយ ដល់ព្រមដោយសិក្ខានិងសាជីវៈសម្រាប់ភិក្ខុទាំងឡាយ ហើយលះបាណាតិបាត ជាអ្នកវៀរចាកបាណាតិបាត ដាក់ចុះនូវអាជ្ញា ដាក់ចុះនូវគ្រឿងសស្ត្រា មានសេចក្តីអៀនខ្មាស ប្រកបដោយសេចក្តីអាណិតអាសូរ ជាអ្នកមានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ជាអ្នកលះអទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែទ្រព្យដែលគេឲ្យ ប្រាថ្នាតែទ្រព្យ ដែលគេឲ្យ មានខ្លួនស្អាត មិនមែនជាអ្នកលួច ជាអ្នកលះអព្រហ្មចរិយធម៌ ប្រព្រឹត្តព្រហ្មចរិយធម៌ ប្រព្រឹត្តឆ្ងាយ វៀរចាកមេថុន ជាធម៌សម្រាប់អ្នកស្រុក ជាអ្នកលះមុសាវាទ វៀរចាកមុសាវាទ ពោលតែពាក្យពិត តតែពាក្យពិត មានសំដីខ្ជាប់ខ្ជួន គួរឲ្យអ្នកផងជឿបាន មិនពោលពាក្យឲ្យខុសចំពោះសត្វលោក ជាអ្នកលះបិសុណាវាចា វៀរចាកបិសុណាវាចា ឮអំពីទីនេះ មិននាំយកទៅប្រាប់ទីនោះ ដើម្បីបំបែកពួកជននេះ ឬឮក្នុងទីឯណោះ មិននាំមកប្រាប់ដល់ពួកជននេះ ដើម្បីបំបែកពួកជនឯណោះ

ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្ប-
ទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គក-
រណឹ វាចំ ភាសិតា ហោតិ ផរុសំ បហាយ ផរុសាយ
វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា
កណ្ណសុខា បេមនីយា ហទយង្គមា ចោរី ពហុជន-
កន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ
សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ
កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធា-
នវតឹ វាចំ ភាសិតា កាលេន សាបទេសំ បរិយន្ត-
វតឹ អត្ថសញ្ហិតំ ។ សោ វីជគាមភូតគាមសមារម្ភា[១]
បដិវិរតោ ហោតិ ឯកភត្តិកោ ហោតិ រត្តូបរតោ វិរតោ
វិកាលភោជនា នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ
ហោតិ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា
បដិវិរតោ ហោតិ ឧច្ចាសយនមហាសយនា បដិវិរតោ
ហោតិ ជាតរូបរជតប្បដិគ្គហណា បដិវិរតោ ហោតិ

១ ឱ. ម. ពីជគាមភូតគាមសមារម្ភោ ។

ជាអ្នកពោលពាក្យផ្សះផ្សាជន ដែលបែកគ្នាហើយ ឬជួយជ្រោមជ្រែងជន ដែលព្រមព្រៀងគ្នាស្រាប់ហើយ មានសេចក្តីព្រមព្រៀង ជាទីត្រេកអរ ត្រេកអរក្នុងសេចក្តីព្រមព្រៀង ពេញចិត្តក្នុងសេចក្តីព្រមព្រៀង ពោល តែសំដីដែលជាទីធ្វើនូវសេចក្តីព្រមព្រៀង ជាអ្នកលះផរុសវាចា វៀរចាក ផរុសវាចា វាចាណាមិនមានទោស សុខដល់ត្រចៀក គួរជាទីស្រឡាញ់ គួរយកទុក ក្នុងហឫទ័យ ជាពាក្យរបស់អ្នកក្រុង ជាទីប្រាថ្នារបស់ជន ច្រើន ជាទីគាប់ចិត្តរបស់ជនច្រើន ក៏ពោលតែវាចា មានសភាពដូច្នោះ ជាអ្នកលះសម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ ពោលតែក្នុងកាល ដែលគួរ ពោលតែពាក្យដែលពិតប្រាកដ ពោលតែអត្ថ ពោលតែធម៌ ពោលតែវិន័យ ពោលតែវាចាដែលគួរតម្កល់ទុក ក្នុងហឫទ័យ ជាវាចា មានគ្រឿងអាងតាមកាលគួរ មានកំណត់ ប្រកបដោយប្រយោជន៍ ។ ភិក្ខុនោះ វៀរចាកការផ្តាច់ផ្តិលពីជគាមនិងភូតគាម ជាអ្នកបរិភោគកត្តតែ មួយពេល វៀរចាកការបរិភោគក្នុងវេលាពត្រី វៀរចាកការបរិភោគក្នុងកាល ខុស វៀរចាកការរាំ ច្រៀង ប្រគំ និងការមើលល្បែងផ្សេង ៗ វៀរចាក ការទ្រទ្រង់ប្រដាប់តាក់តែងនិងការស្អិតស្អាង (រាងកាយ) ដោយផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបផ្សេង ៗ វៀរចាកការដេក ឬអង្គុយលើ អាសនៈដ៏ខ្ពស់ និងអាសនៈដ៏ប្រសើរ វៀរចាកការទទួលមាសនិងប្រាក់

អាមកធញ្ញប្បដិគ្គហណា បដិវិរតោ ហោតិ អាមកមំសប្បដិគ្គហណា បដិវិរតោ ហោតិ ឥត្ថីកុមារិកាបដិគ្គហណា បដិវិរតោ ហោតិ ទាសីទាសប្បដិគ្គហណា បដិវិរតោ ហោតិ អជេឡកប្បដិគ្គហណា បដិវិរតោ ហោតិ កុក្កុដសូករប្បដិគ្គហណា បដិវិរតោ ហោតិ ហត្ថិគវាស្សវឡវប្បដិគ្គហណា បដិវិរតោ ហោតិ ខេត្តវត្ថុប្បដិគ្គហណា បដិវិរតោ ហោតិ ទូតេយ្យប្បហីណគមនានុយោគា បដិវិរតោ ហោតិ កយវិក្កយា បដិវិរតោ ហោតិ តុលាកូដកំសកូដមានកូដា បដិវិរតោ ហោតិ ឧក្កោដនវញ្ចននិកតិសាចិយោគា បដិវិរតោ ហោតិ ឆេទនវធពន្ធនវិបរាមោសអាលោបសហសាការា បដិវិរតោ ហោតិ ។ សោ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ សេយ្យថាបិ នាម បក្ខី សកុណោ យេន យេនេវ ឌេតិ សបត្តភារោវ ឌេតិ ឯវមេវ ភិក្ខុ សន្តុដ្ឋោ ហោតិ

*វៀរចាកការទទួលស្រូវស្រស់ វៀរចាកការទទួលសាច់ឆៅ វៀរចាកការទទួលស្ត្រីនិងក្មេងស្រី វៀរចាកការទទួលខ្ញុំស្រីនិងខ្ញុំប្រុស វៀរចាកការទទួលពពែនិងចៀម វៀរចាកការទទួលមាន់និងជ្រូក វៀរចាកការទទួលដំរី គោ សេះឈ្មោលនិងសេះញី វៀរចាកការទទួលស្រែនិងចម្ការ វៀរចាកការប្រកបក្នុងកិច្ចជាទូតនិងការនាំសំបុត្រទៅមក វៀរចាកការលក់ដូរ វៀរចាកការបោកដោយជញ្ជីង ឆបោកដោយភាជន៍មាស ទាំងឆបោកដោយរង្វាស់រង្វាល់ វៀរចាកការសើរើ[១] បញ្ឆោតបន្ទំ កោងកាច វៀរចាកការកាប់សម្លាប់ ចងបំភាន់ ប្លន់ កំហែង ។ បុគ្គលនោះជាអ្នកសន្តោសដោយចីវរសម្រាប់រក្សាកាយ ដោយបិណ្ឌបាតសម្រាប់រក្សាផ្ទៃ ត្រាច់ទៅក្នុងទីណា ៗ ក៏កាន់យក (ត្រឹមតែគ្រឿងបរិក្ខារ) ប៉ុណ្ណោះទៅ ។ សត្វបក្សីហើរទៅក្នុងទីណា ៗ ក៏ទៅត្រឹមតែស្លាបរបស់ខ្លួនប៉ុណ្ណោះ យ៉ាងណាមិញ ភិក្ខុជាអ្នកសន្តោសដោយ*

---

១ ចូរមើល ក្នុងចូឡហត្ថិបទោបមសូត្រឯណោះចុះ ។

កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌ-
បាតេន យេន យេនេវ បក្កមតិ សមាទាយេវ
បក្កមតិ ។ សោ ឥមិនា អរិយេន សីលក្ខន្ធេន
សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិសំវេទេតិ ។
សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ
នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំ-
វុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា
ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ
រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោ-
តេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា...
ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ
ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី
ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ
អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុ-
សលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ
រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។
សោ ឥមិនា អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ

ចីវរសម្រាប់រក្សាកាយ ដោយបិណ្ឌបាតសម្រាប់រក្សាផ្ទៃ ត្រាច់ទៅក្នុងទីណា ៗ ក៏កាន់យក (ត្រឹមតែគ្រឿងបរិក្ខារ) ប៉ុណ្ណោះទៅ ក៏យ៉ាងនោះដែរ ។ ភិក្ខុនោះប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះ ហើយបានទទួលនូវសេចក្តីសុខ ដែលមិនមានទោសក្នុងសន្តាន ។ ភិក្ខុនោះឃើញរូបដោយភ្នែក ក៏មិនក្តួចកាន់និមិត្ត មិនក្តួចកាន់អនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ ដ៏លាមក គប្បីជាប់តាមបុគ្គល ដែលមិនសង្រួមនូវចក្ខុន្ទ្រិយ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា លោកក៏ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ពាល់ត្រូវផ្សព្វដោយកាយ... ដឹងធម្មារម្មណ៍ដោយចិត្ត ក៏មិនក្តួចកាន់និមិត្ត ទាំងមិនក្តួចកាន់អនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ ដ៏លាមក គប្បីជាប់តាមនូវបុគ្គលនុ៎ះដែលមិនសង្រួមមនិន្ទ្រិយ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា លោកក៏ប្រតិបត្តិ ដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ ។ ភិក្ខុនោះប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះ

អជ្ឈត្តំ អព្យាសេកសុខំ បដិសំវេទេតិ ។ សោ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។

[១៣] សោ ឥមិនា ច អរិយេន សីលក្ខន្ធេន សមន្នាគតោ ឥមិនា ច អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ ឥមិនា ច អរិយេន សតិសម្បជញ្ញេន សមន្នាគតោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។

តែងទទួលសេចក្តីសុខ ឥតសៅហ្មងខាងក្នុងសន្តាន ។ ភិក្ខុនោះជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលឈានទៅមុខ និងឈានថយក្រោយ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលក្រឡេកមើលទៅមុខ ឬក្រ-ឡេកមើលទៅទិសផ្សេង ៗ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលបត់អវយវៈចូលនិងលាចេញ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលប្រើប្រាស់សង្ឃាដីបាត្រនិងចីវរ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលស៊ី ផឹក ទំពា ទទួលរស ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលធ្វើឧច្ចារៈនិងបស្សាវៈ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ រលឹក និយាយស្តី នៅស្ងៀម ។

[១៣] ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបដោយឥន្ទ្រិយសំវរៈ ដ៏ប្រសើរនេះផង ប្រកបដោយសតិនិងសម្បជញ្ញៈដ៏ប្រសើរនេះផង គប់រកនូវសេនាសនៈស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ច្រកភ្នំ គុហាលើភ្នំ ព្រៃស្មសាន ព្រៃស្រោង ទីវាល គំនរចំបើង ។ ភិក្ខុនោះត្រឡប់មកពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្តហើយ ក៏អង្គុយផ្គត់ភ្នែនតាំងកាយឲ្យត្រង់ តម្កល់សតិឆ្ពោះមុខទៅរកកម្មដ្ឋាន ។

សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ព្យាបាទប្បទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទប្បទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។

[១៤] សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ

ភិក្ខុនោះ លះអភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា ជាអ្នកលះសេចក្តីប្រទូស្ត ព្រោះព្យាបាទ មានចិត្តប្រាសចាកព្យាបាទ ជាអ្នកអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ជម្រះចិត្តឲ្យស្អាតចាកសេចក្តីប្រទូស្ត ព្រោះព្យាបាទ ជាអ្នកលះថីនមិទ្ធៈ ប្រាសចាកថីនមិទ្ធៈ សំគាល់នូវអាលោកកសិណ មានសតិនិងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ ជាអ្នកលះឧទ្ធច្ចកុក្កុច្ចៈ មិនរាយមាយ មានចិត្តស្ងប់ស្ងាត់ខាងក្នុងសន្តាន ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ ជាអ្នកលះវិចិកិច្ឆា ឆ្លងផុតចាកវិចិកិច្ឆា មិនមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

[១៤] ភិក្ខុនោះ លុះលះនីវរណៈទាំង ៥ ដែលជាឧបក្កិលេសរបស់ចិត្ត ដែលធ្វើបញ្ញាឲ្យមានកម្លាំងថយនេះរួចហើយ លោកក៏ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិសុខដែលកើតអំពីវិវេក ព្រោះ

វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោម-នស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិចារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

[១៨] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ[១] បុព្វេនិវាសានុស្ស-តិញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ

---

១ ឱ. អនេជ្ជប្បត្តេ ។

រម្ងាប់វិតក្កៈ និងវិចារៈរួចហើយ ចូលកាន់ទុតិយជ្ឈាន ជាទីផូរផង់ខាង ក្នុងសន្ដាន មានភាវៈនៃចិត្តដ៏ប្រសើរ មិនមានវិតក្កៈ វិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ ព្រោះលះបង់បីតិចេញហើយ ជាបុគ្គល ព្រងើយផង មានសតិនិងសម្បជញ្ញៈផង ទទួលសេចក្ដីសុខដោយនាម-កាយផង ចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយតែងសរសើរ ថា បុគ្គលដែលបានតតិយជ្ឈានហើយ តែងមានចិត្តព្រងើយ ជាអ្នកមាន ស្មារតីនៅជាសុខ ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះរលត់ នូវសោមនស្សនិងទោមនស្សអំពីកាលមុនផង លោកក៏ចូលកាន់ចតុត្ថជ្ឈាន ឥតទុក្ខ ឥតសុខ មានសតិដែលកើតអំពីឧបេក្ខា ។

[១៥] កាលដែលចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ រកបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះក៏រលឹកឃើញជាតិដែលខ្លួនធ្លាប់ អាស្រ័យនៅក្នុងកាលមុន ជាច្រើនជាតិ គឺរលឹកឃើញបាន ១ ជាតិ

ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ[១] តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។

[១៦] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ

១ ឱ. ឧប្បាទឹ ។

២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១០០០ ជាតិ មួយសែនជាតិក៏បានខ្លះ រលឹកឃើញបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្ត-វិវដ្តកប្បក៏បាន ដូច្នេះថា អាត្មាអញនៅក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណ:យ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណ:យ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ។ ភិក្ខុនោះ រលឹកឃើញជាតិដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុនបានច្រើនជាតិ ព្រមទាំងអាការទាំងឧទ្ទេស ។

[១៦] កាលដែលចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ភ្លន់ គួរ

២៧

គហបតិវគ្គស្ស កន្ទរកសុត្តេ ចុតូបបាតញ្ញាណំ

កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបា-
តញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ ទិព្វេន
ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ
បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ
សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ
សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយ-
ទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា
មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទ-
កា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ
កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ
វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ
សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន
សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយា-
នំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្ម-
សមាទានា តេ កាយស្ស ភេទា បរម្មរណា

ដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅ ដើម្បីញាណជាគ្រឿងដឹងនូវចុតិនិងបដិសន្ធិ របស់សត្វទាំងឡាយ ភិក្ខុនោះ ក៏ឃើញសត្វទាំងឡាយ ដែលច្យុតចាប់បដិសន្ធិ មានភាវៈទាបថោកនិងឧត្តម មានវណ្ណៈល្អនិងវណ្ណៈអាក្រក់ ទៅកាន់សុគតិនិងទុគ្គតិ ដោយចក្ខុដ៏ជាទិព្វ ដ៏បរិសុទ្ធក្រៃលែងជាងចក្ខុរបស់មនុស្សសាម័ញ្ញ ក៏ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រ-កបដោយមនោទុច្ចរិត ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ និយាយតិះដៀលព្រះអរិយបុគ្គលទាំងឡាយ សត្វទាំងនោះ លុះរំលាយខ័ន្ធបន្ទាប់អំពីមរណៈក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ចំណែកឯសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសម្មាទិដ្ឋិ ប្រកាន់មាំនូវកម្មជាសម្មាទិដ្ឋិ មិនតិះដៀលពួកព្រះអរិយបុគ្គល សត្វទាំងនោះ លុះដល់រំលាយខន្ធបន្ទាប់អំពីមរណៈ

សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។

[១៧] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញា-ណាយ ចិត្តំ អភិនិន្នាមេតិ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខ-និរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថា-ភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ

ក៏ទៅកើតឯឋានសុគតិ សួគ៌ ទេវលោក ។ ភិក្ខុនោះ ឃើញសត្វទាំងឡាយ ដែលច្យុតដែលចាប់បដិសន្ធិ មានភាវៈទាបថោកនិងឧត្តម មានវណ្ណៈល្អនិងវណ្ណៈអាក្រក់ ទៅកាន់សុគតិនិងទុគ្គតិ ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។

[១៧] កាលដែលចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅរកអាសវក្ខយញ្ញាណ លោកក៏ដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសេចក្ដីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្ដីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា ធម៌ប៉ុណ្ណេះជាអាសវៈ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងប្រាកដតាមពិតថា នេះជាសេចក្ដីរលត់អាសវៈ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្ដីរលត់អាសវៈ ។ កាលដែលភិក្ខុនោះ ដឹងយ៉ាងនេះ ពិចារណាឃើញយ៉ាងនេះ ចិត្តក៏ផុតចាកកាមាសវៈផង ផុតចាកភវាសវៈ

២៩

គហបតិវគ្គស្ស កន្ទរកសុត្តេ អាសវក្ខយញ្ញាណំ

អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ នេវត្តន្តបោ នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

កន្ទរកសុត្តំ បឋមំ និដ្ឋិតំ[១] ។

១ ឱ. ម. និដ្ឋិតន្តិ សព្វត្ថ ន ទិស្សតិ ។

ផង ផុតចាកអវិជ្ជាសវៈផង កាលបើចិត្ត ផុតស្រឡះហើយ ញាណ ក៏កើតប្រាកដថា អាត្មាអញផុតស្រឡះចាកអាសវៈហើយ ដឹងច្បាស់ថា កំណើតរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្ត គ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញក៏បានធ្វើស្រេចហើយ កិច្ច ដទៃក្រៅពីសោឡសកិច្ច តទៅទៀតមិនមានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះឯង ដែលតថាគតហៅថា អ្នកមិនដុតកម្តៅខ្លួនឯង មិនប្រកប សេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ជាអ្នកមិនដុតកម្តៅអ្នកដទៃ មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលដែលមិនដុត កម្តៅខ្លួនឯង មិនដុតកម្តៅអ្នកដទៃនោះ ជាអ្នកអស់សេចក្តីស្រេកឃ្លាន ក្នុងបច្ចុប្បន្ននេះ ជាអ្នករលត់ទុក្ខ មានសេចក្តីត្រជាក់ ទទួលសេចក្តី សុខ ជាអ្នកប្រសើរ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះ ចប់ហើយ ភិក្ខុទាំងនោះ មានចិត្តត្រេកអរ រីករាយចំពោះភាសិត របស់ ព្រះមានព្រះភាគ ។

ចប់ កន្ទរកសូត្រ ទី ១ ។

# ទុតិយំ អដ្ឋកនាគរសុត្តំ

[១៨] ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា អានន្ទោ វេសាលិយំ វិហរតិ វេឡុវគ្គាមកេ ។ តេន ខោ បន សមយេន ទសមោ គហបតិ អដ្ឋកនាគរោ បាដលិបុត្តំ អនុប្បត្តោ ហោតិ កេនចិទេវ ករណីយេន ។ អថខោ ទសមោ គហបតិ អដ្ឋកនាគរោ យេន កុក្កុដារាមោ យេន អញ្ញតរោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ទសមោ គហបតិ អដ្ឋកនាគរោ តំ ភិក្ខុំ ឯតទវោច កហំ នុ ខោ ភន្តេ អាយស្មា អានន្ទោ ឯតរហិ វិហរតិ ទស្សនកាមា ហិ មយំ តំ អានន្ទន្តិ ។ ឯសោ គហបតិ អាយស្មា អានន្ទោ វេសាលិយំ វិហរតិ វេឡុវគ្គាមកេតិ ។

# អដ្ឋកនាគរសូត្រ ទី ២

[១៨] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះអានន្ទមានអាយុ គង់នៅក្នុងវេឡុវគ្រាម ជិតក្រុងវេសាលី ។ សម័យនោះឯង ទសមគហបតីអ្នកក្រុងអដ្ឋកៈ បានទៅដល់ក្រុងបាតលិបុត្ត ដោយកិច្ចការនីមួយ ។ គ្រានោះ ទសមគហបតីអ្នកក្រុងអដ្ឋកៈ ចូលទៅរកភិក្ខុ ១ រូប ដែលនៅក្នុងកុក្កុដារាម លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំភិក្ខុនោះ ហើយអង្គុយក្នុងទីសមគួរ ។ លុះទសមគហបតី អ្នកក្រុងអដ្ឋកៈ អង្គុយក្នុងទីសមគួរហើយ បានសួរភិក្ខុនោះ យ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ ព្រះអានន្ទមានអាយុ គង់នៅក្នុងទីណា ព្រោះយើងខ្ញុំចង់ឃើញព្រះអានន្ទនោះ ។ ភិក្ខុនោះប្រាប់ថា ម្នាលគហបតី ព្រះអានន្ទមានអាយុនុ៎ះ លោកគង់នៅក្នុងវេឡុវគ្រាម ជិតក្រុងវេសាលី ។

អថខោ ទសមោ គហបតិ អដ្ឋកនាគរោ បាដលិបុត្តេ តំ ករណីយំ តីរេត្វា យេន វេសាលី យេន វេឡុវគាមកោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[១៩] ឯកមន្តំ និសិន្នោ ខោ ទសមោ គហបតិ អដ្ឋកនាគរោ អាយស្មន្តំ អានន្ទំ ឯតទវោច អត្ថិ នុ ខោ ភន្តេ អានន្ទ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯកធម្មោ អក្ខាតោ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តញ្ចេវ[១] ចិត្តំ វិមុច្ចតិ អបរិក្ខីណា ច[២] អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច[៣] អនុត្តរំ យោគក្ខេមំ អនុបាបុណាតីតិ ។ អត្ថិ ខោ គហបតិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯកធម្មោ អក្ខាតោ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តញ្ចេវ ចិត្តំ វិមុច្ចតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច

១ ឱ. អវិមុត្តំ វា ។ ២ ឱ. វា ។ ៣ ឱ. អននុប្បត្តំ វា ។

ទើបទសមគហបតី អ្នកក្រុងអដ្ឋកៈ ត្រួតត្រាកិច្ចការដែលខ្លួនត្រូវធ្វើក្នុងក្រុងបាតលិបុត្តនោះរួចហើយ ក៏ចូលទៅរកព្រះអានន្ទមានអាយុ ក្នុងវេឡុវគ្រាម ទៀបក្រុងវេសាលីនោះ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះអានន្ទមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។

[១៩] លុះទសមគហបតី អ្នកក្រុងអដ្ឋកៈ អង្គុយក្នុងទីសមគួរហើយ ទើបទូលសួរព្រះអានន្ទមានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ភិក្ខុជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ចិត្តដែលមិនទាន់រួចស្រឡះ (ចាកអាសវៈ) ក៏រួចស្រឡះបានផង អាសវធម៌ទាំងឡាយ ដែលមិនទាន់អស់ទៅ ក៏អស់រលីងបានផង ទាំងបានដល់ធម៌ក្សេម ចាកយោគៈដ៏ប្រសើរ ដែលខ្លួនមិនទាន់បានដល់ផង ព្រោះធម៌ឯកណា ធម៌ឯកនោះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គបានសំដែងហើយ តើមានដែរឬ ។ ព្រះអានន្ទត្ថេរ តបថា ម្នាលគហបតី ភិក្ខុជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ចិត្តដែលមិនទាន់រួចស្រឡះ ក៏រួចស្រឡះបានផង អាសវធម៌ទាំងឡាយដែលមិនទាន់អស់ទៅ ក៏អស់រលីងបានផង ទាំងបានដល់

អនុត្តរំ យោគក្ខេមំ អនុបាបុណាតីតិ ។ កតមោ
បន ភន្តេ អានន្ទ តេន ភគវតា ជានតា បស្សតា
អរហតា សម្មាសម្ពុទ្ធេន ឯកធម្មោ អក្ខាតោ យត្ថ
ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហ-
រតោ អវិមុត្តញ្ចេវ ចិត្តំ វិមុច្ចតិ អបរិក្ខីណា ច អាសវា
បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ
អនុបាបុណាតីតិ ។

[២០] ឥធ គហបតិ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច
អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ
បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ
ឥតិ បដិសញ្ចិក្ខតិ ឥទម្បិ ខោ បឋមំ ឈានំ
អភិសង្ខតំ អភិសញ្ចេតយិតំ យំ ខោ បន កិញ្ចិ
អភិសង្ខតំ អភិសញ្ចេតយិតំ តទនិច្ចំ និរោធធម្មន្តិ
បជានាតិ សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុ-

នូវធម៌ក្សេមចាកយោគៈដ៏ប្រសើរ ដែលខ្លួនមិនទាន់បានដល់ផង ព្រោះធម៌ឯកណា ធម៌ឯកនោះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គបានសំដែងហើយ រមែងបានប្រាកដ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ភិក្ខុជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ចិត្តដែលមិនទាន់រួចស្រឡះ ក៏រួចស្រឡះបានផង អាសវធម៌ទាំងឡាយដែលមិនទាន់អស់ទៅ ក៏អស់រលីងបានផង ទាំងបានដល់ធម៌ក្សេមចាកយោគៈដ៏ប្រសើរ ដែលខ្លួនមិនទាន់បានដល់ផង ព្រោះធម៌ឯកណា ធម៌ឯកនោះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គបានសំដែងហើយ តើដូចម្ដេចខ្លះ ។

[២០] ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈដែលកើតអំពីវិវេក ភិក្ខុនោះពិចារណាដឹងច្បាស់ដូច្នេះថា បឋមជ្ឈាននេះឯង អាត្មាអញ បានតាក់តែងហើយ បានបង្កើតហើយ ក៏បឋមជ្ឈានតិចតួច ដែលអាត្មាអញ បានតាក់តែង បានបង្កើតហើយនោះ ជាធម្មជាតមិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះ ក៏ឋិតនៅក្នុងធម៌នោះ ហើយក៏ដល់នូវការអស់ទៅនៃអាសវៈ បើ

ឈាតិ ដោ ចេ អាសវានំ ខយំ ចាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាតិយានំ សញ្ញោជនានំ បរិក្ខយា ឱបចាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា អយម្បិ ខោ គហបតិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯក-ធម្មោ អក្ខាតោ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ អវិមុត្តញ្ចេវ ចិត្តំ វិមុច្ចតិ អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុចាបុណាតិ ។ បុន ចបរំ គហបតិ ភិក្ខុ វិតក្កវិចារានំ វូបស-មា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ ឥតិ បដិសញ្ចិក្ខតិ ឥទម្បិ ខោ ទុតិយំ ឈានំ អភិសង្ខតំ អភិសញ្ចេតយិតំ ។ បេ ។ អនុត្តរំ យោគក្ខេមំ អនុចាបុណាតិ ។ បុន ចបរំ គហ-បតិ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ ឥតិ បដិសញ្ចិក្ខតិ

មិនទាន់ដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់នឹងទៅកើតជាឱបបាតិកៈ ព្រោះការអស់ទៅនៃសំយោជនធម៌ទាំង ៥ ប្រការ ជាចំណែកខាងក្រោម ដោយសេចក្តីត្រេកអរក្នុងធម៌នោះ និងសេចក្តីរីករាយក្នុងធម៌នោះ ហើយនឹងបរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់មក អំពីព្រហ្មលោកនោះវិញឡើយ ម្នាលគហបតី ភិក្ខុជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ចិត្តដែលមិនទាន់រួចស្រឡះ ក៏រួចស្រឡះបានផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏អស់រលីងបានផង ទាំងដល់នូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ដែលខ្លួនមិនទាន់បានដល់ផង ព្រោះធម៌ឯកណា នេះឯងជាធម៌ឯក ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គបានសំដែងហើយ ។ ម្នាលគហបតី មួយទៀត ភិក្ខុព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ក៏ចូលកាន់ទុតិយជ្ឈាន ទើបភិក្ខុនោះពិចារណា ដឹងច្បាស់ដូច្នេះថា ទុតិយជ្ឈាននេះឯង អាត្មាអញ បានតាក់តែងហើយ បានបង្កើតហើយ ។ បេ ។ ទាំងដល់ធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលគហបតី មួយទៀត ភិក្ខុព្រោះប្រាសចាកបីតិ ។ បេ ។ ចូលកាន់តតិយជ្ឈាន ទើបភិក្ខុនោះពិចារណា

ឥទម្បិ ខោ តតិយំ ឈានំ អភិសង្ខតំ អភិសញ្ចេតយិតំ ។ បេ ។ អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ ។ បុន ចបរំ គហបតិ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ ឥតិ បដិសញ្ចិក្ខតិ ឥទម្បិ ខោ ចតុត្ថំ ឈានំ អភិសង្ខតំ អភិសញ្ចេតយិតំ ។ បេ ។ អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ ។

[២១] បុន ចបរំ គហបតិ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ សោ ឥតិ បដិសញ្ចិក្ខតិ អយម្បិ ខោ មេត្តា ចេតោវិមុត្តិ អភិសង្ខតា អភិសញ្ចេតយិតា យំ ខោ បន កិញ្ចិ អភិសង្ខតំ អភិសញ្ចេតយិតំ តទនិច្ចំ និរោធធម្មន្តិ បជានាតិ សោ តត្ថ ឋិតោ ។ បេ ។

ដឹងច្បាស់ដូច្នេះថា តតិយជ្ឈាននេះឯង អាត្មាអញ បានតាក់តែង ហើយ បានបង្កើតហើយ ។ បេ ។ ទាំងដល់នូវធម៌ដ៏ក្សេម ចាកយោគ: ដ៏ប្រសើរ ។ ម្នាលគហបតី មួយទៀត ភិក្ខុព្រោះលះបង់សុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ទើបភិក្ខុនោះពិចារណាដឹងច្បាស់ដូច្នេះថា ចតុត្ថជ្ឈាននេះឯង អាត្មាអញ បានតាក់តែងហើយ បានបង្កើតហើយ ។ បេ ។ ទាំងដល់នូវធម៌ដ៏ក្សេមចាកយោគ:ដ៏ប្រសើរ ។

[២១] ម្នាលគហបតី មួយទៀត ភិក្ខុមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទាំងមានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទិសទាំងពួង ដោយប្រការដូច្នេះ ទើបភិក្ខុនោះពិចារណា ដឹងច្បាស់ដូច្នេះថា មេត្តាចេតោវិមុត្តិនេះឯង អាត្មាអញ បានតាក់តែងហើយ បានបង្កើតហើយ ប៉ុន្តែធម្មជាតតិចតួចណា ដែលតាក់តែងហើយ បានបង្កើតហើយ ធម្មជាតទាំងនោះ ជារបស់មិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះក៏ឋិតនៅក្នុងធម៌នោះ ។ បេ ។

៣៤

គហបតិវគ្គស្ស អដ្ឋកនាគរសុត្តេ អប្បមញ្ញាភាវនា

អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ ។ បុន ចបរំ គហបតិ ភិក្ខុ ករុណាសហគតេន ចេតសា ។ បេ ។ មុទិតាសហគតេន ចេតសា... ឧបេក្ខា-សហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ សោ ឥតិ បដិសញ្ចិក្ខតិ អយម្បិ ខោ ឧបេក្ខាចេតោវិមុត្តិ អភិសង្ខតា អភិសញ្ចេត-យិតា យំ ខោ បន កិញ្ចិ អភិសង្ខតំ អភិសញ្ចេត-យិតំ តទនិច្ចំ និរោធធម្មន្តិ បជានាតិ សោ តត្ថ ឋិតោ ។ បេ ។ អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ ។

ទាំងដល់ធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលគហបតី មួយទៀត ភិក្ខុមានចិត្តប្រកបដោយករុណា ។ បេ ។ មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទាំងមានចិត្តប្រកបដោយឧបេក្ខា ដ៏ធំទូលាយប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយយកខ្លួនឯងទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទិសទាំងពួង ដោយប្រការដូច្នេះ ទើបភិក្ខុនោះពិចារណា ដឹងច្បាស់ដូច្នេះថា ឧបេក្ខាចេតោ-វិមុត្តិនេះឯង អាត្មាអញបានតាក់តែងហើយបានបង្កើតហើយ ប៉ុន្តែធម្មជាតតិចតួចណា ដែលអាត្មាអញតាក់តែងហើយបានបង្កើតហើយ ធម្មជាតនោះឯង ជារបស់មិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះក៏បិតនៅក្នុងធម៌នោះ ។ បេ ។ ទាំងដល់ធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។

[២២] បុន ចបរំ គហបតិ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា ឯានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ សោ ឥតិ បដិសញ្ចិក្ខតិ អយម្បិ ខោ អាកាសានញ្ចាយតន-សមាបត្តិ អភិសង្ខតា អភិសញ្ចេតយិតា យំ ខោ បន កិញ្ចិ អភិសង្ខតំ អភិសញ្ចេតយិតំ តទនិច្ចំ និរោធធម្មន្តិ បជានាតិ សោ តត្ថ ឋិតោ ។ បេ ។ អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ ។ បុន ចបរំ គហបតិ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សម-តិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧប-សម្បជ្ជ វិហរតិ សោ ឥតិ បដិសញ្ចិក្ខតិ អយម្បិ ខោ វិញ្ញាណញ្ចាយតនសមាបត្តិ អភិសង្ខតា អភិសញ្ចេត-យិតា យំ ខោ បន កិញ្ចិ អភិសង្ខតំ អភិសញ្ចេត-យិតំ តទនិច្ចំ និរោធធម្មន្តិ បជានាតិ សោ តត្ថ ឋិតោ ។ បេ ។ អនុត្តរំ យោគក្ខេមំ អនុបាបុណាតិ ។

[២២] ម្នាលគហបតី មួយទៀត ភិក្ខុព្រោះកន្លងនូវពួករូបសញ្ញា ដោយអាការសព្វគ្រប់ រលត់នូវបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ហើយក៏ចូលអាកាសានញ្ចាយតនសមាបត្តិ ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ ទើបភិក្ខុនោះពិចារណា ដឹងច្បាស់ដូច្នេះថា អាកាសានញ្ចាយតនសមាបត្តិនេះឯង អាត្មាអញបានតាក់តែង បានបង្កើតហើយ ប៉ុន្តែធម្មជាតតិចតួចណាដែលតាក់តែងហើយ បានបង្កើតហើយ ធម្មជាតនោះឯង ជារបស់មិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះក៏ឋិតនៅ ក្នុងធម៌នោះ ។ បេ ។ ទាំងដល់នូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលគហបតី មួយទៀត ភិក្ខុកន្លងនូវអាកាសានញ្ចាយតនសមាបត្តិ ដោយអាការសព្វគ្រប់ ហើយក៏ចូលវិញ្ញាណញ្ចាយតនសមាបត្តិ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ភិក្ខុនោះពិចារណា ដឹងច្បាស់ដូច្នេះថា វិញ្ញាណញ្ចាយតនសមាបត្តិនេះឯង អាត្មាអញ បានតាក់តែងហើយ បានបង្កើតហើយ ប៉ុន្តែធម្មជាតតិចតួចណា ដែលតាក់តែងហើយ បានបង្កើតហើយ ធម្មជាតនោះឯង ជារបស់មិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះក៏ឋិតនៅក្នុងធម៌នោះ ។ បេ ។ ទាំងដល់នូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។

គហបតិវគ្គស្ស អដ្ឋកនាគរសុត្តេ ចត្វារូបជ្ឈានំ

បុន ចបរំ គហបតិ ភិក្ខុ សព្វសោ វិញ្ញាណញ្ចា-
យតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញា-
យតនំ ឧបសម្បជ្ជ វិហរតិ សោ ឥតិ បដិ-
សញ្ចិក្ខតិ អយម្បិ ខោ អាកិញ្ចញ្ញាយតនសមា-
បត្តិ អភិសង្ខតា អភិសញ្ចេតយិតា យំ ខោ បន
កិញ្ចិ អភិសង្ខតំ អភិសញ្ចេតយិតំ តទនិច្ចំ និរោធ-
ធម្មន្តិ បជានាតិ សោ តត្ថ ឋិតោ អាសវានំ ខយំ
បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ
តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ
ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ
ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា
អយំ ខោ គហបតិ តេន ភគវតា ជានតា
បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯកធម្មោ អក្ខា-
តោ យត្ថ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ
បហិតត្តស្ស វិហរតោ អវិមុត្តញ្ចេវ ចិត្តំ វិមុច្ចតិ

គហបតិវគ្គ អដ្ឋកនាគរសូត្រ អរូបជ្ឈាន ៤

ម្នាលគហបតី មួយវិញទៀត ភិក្ខុកន្លងវិញ្ញាណញ្ចាយតនសមាបត្តិ ដោយអាការសព្វគ្រប់ ហើយក៏ចូលអាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា របស់បន្តិចបន្តួចមិនមានដូច្នេះ ទើបភិក្ខុនោះពិចារណាដឹងច្បាស់ដូច្នេះថា អាកិញ្ចញ្ញាយតនសមាបត្តិនេះឯង អាត្មាអញបានតាក់តែងហើយ បានបង្កើតហើយ ប៉ុន្តែធម្មជាតតិចតួចណា ដែលអាត្មាអញតាក់តែងហើយ បានបង្កើតហើយ ធម្មជាតនោះឯង ជារបស់មិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះក៏ឋិតនៅក្នុងធម៌នោះ ហើយក៏បានដល់នូវការអស់ទៅនៃអាសវៈ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់ទៅកើតជាឱបបាតិកៈ ព្រោះអស់ទៅនៃសំយោជនធម៌ទាំង ៥ ប្រការ ជាចំណែកខាងក្រោម ដោយសេចក្តីត្រេកអរ ក្នុងធម៌នោះ និងសេចក្តីរីករាយ ក្នុងធម៌នោះ ហើយបរិនិព្វានក្នុងជាន់សុទ្ធាវាសនោះ មានសភាពមិនត្រឡប់ ចាកព្រហ្មលោកនោះជាធម្មតា ម្នាលគហបតី ភិក្ខុជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ចិត្តដែលមិនទាន់រួចស្រឡះ ក៏រួចស្រឡះបានផង

អបរិក្ខីណា ច អាសវា បរិក្ខយំ គច្ឆន្តិ អននុប្បត្តញ្ច អនុត្តរំ យោគក្ខេមំ អនុចាបុណាតីតិ ។

[២៣] ឯវំ វុត្តេ ទសមោ គហបតិ អដ្ឋកនាគរោ អាយស្មន្តំ អានន្ទំ ឯតទវោច សេយ្យថាបិ ភន្តេ អានន្ទ បុរិសោ ឯកំ និធិមុខំ គវេសន្តោ សកិទេវ ឯកាទស និធិមុខានិ អធិគច្ឆេយ្យ ឯវមេវ ខោ អហំ ភន្តេ ឯកំ អមតទ្វារំ គវេសន្តោ សកិទេវ ឯកាទស អមតទ្វារានិ អលត្ថំ សវនាយ សេយ្យថាបិ ភន្តេ បុរិសស្ស អគារំ ឯកាទសទ្វារំ សោ តស្មឹ អគារេ អាទិត្តេ ឯកមេកេនបិ ទ្វារេន សក្កុណេយ្យ អត្តានំ សោត្ថឹ កាតុំ ឯវមេវ ខោ អហំ ភន្តេ ឥមេសំ ឯកាទសន្នំ អមតទ្វារានំ ឯកមេកេនបិ អមតទ្វារេន សក្ខិស្សាមិ អត្តានំ សោត្ថឹ កាតុំ

អាសវធម៌ទាំងឡាយ ដែលមិនទាន់អស់ទៅ ក៏អស់រលីងបានផង ទាំងដល់ធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ដែលមិនទាន់បានដល់ ព្រោះធម៌ឯកណា នេះឯងជាធម៌ឯក ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គបានសំដែងហើយ ។

[២៣] កាលដែលព្រះអានន្ទត្ថេរ សំដែងយ៉ាងនេះហើយ ទសមគហបតិ អ្នកក្រុងអដ្ឋកៈ បាននិយាយនឹងព្រះអានន្ទមានអាយុយ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន បុរសកាលស្វែងរកកំណប់តែ ១ ស្រាប់តែបានកំណប់ទាំង ១១ ដោយព្យាយាមតែម្តង មានឧបមាយ៉ាងណាមិញ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណាកាលស្វែងរកទ្វារព្រះនិព្វានតែ ១ សោះ ស្រាប់តែបានទ្វារព្រះនិព្វានទាំង ១១ ដោយការស្តាប់តែម្តង ក៏មានឧបមេយ្យយ៉ាងនោះដែរ បពិត្រព្រះអានន្ទដ៏ចម្រើនមួយយ៉ាងទៀត ផ្ទះរបស់បុរសមានទ្វារ ១១ កាលភ្លើងឆេះផ្ទះនោះហើយ បុរសម្ចាស់ផ្ទះនោះ អាចនឹងធ្វើខ្លួនឲ្យមានសួស្តី ដោយទ្វារតែមួយ ៗ ក៏បាន មានឧបមាដូចម្តេចមិញ បពិត្រព្រះអានន្ទដ៏ចម្រើន បណ្តាទ្វារព្រះនិព្វានទាំង ១១ នេះ ខ្ញុំព្រះករុណានឹងអាចធ្វើខ្លួន ឲ្យមានសួស្តីដោយទ្វារព្រះនិព្វានតែមួយ ៗ បាន ក៏មានឧបមេយ្យដូច្នោះឯង បពិត្រ

គហបតិវគ្គស្ស អដ្ឋកនាគរសុត្តេ អានន្ទស្ស បូជា

ឥមេ ហិ នាម ភន្តេ អញ្ញតិត្ថិយា អាចរិយស្ស អាចរិយធនំ បរិយេសិស្សន្តិ កិមង្គំ បនាហំ អាយស្មតោ អានន្ទស្ស បូជំ ន ករិស្សាមីតិ ។ អថខោ ទសមោ គហបតិ អដ្ឋកនាគរោ បាដលិបុត្តកញ្ច វេសាលិកញ្ច ភិក្ខុសង្ឃំ សន្និបាតេត្វា[1] បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ឯកមេកញ្ច ភិក្ខុំ បច្ចេកំ ទុស្សយុគេន អច្ឆាទេសិ អាយស្មន្តំ អានន្ទំ តិចីវរេន អច្ឆាទេសិ អាយស្មតោ អានន្ទស្ស បញ្ចសតំ វិហារំ ការាបេសីតិ ។

អដ្ឋកនាគរសុត្តំ ទុតិយំ និដ្ឋិតំ ។

១ ឱ. ម. សន្និបាតាបេត្វា ។

គហបតិវគ្គ អដ្ឋកនាគរសូត្រ ការបូជាព្រះអានន្ទ

ព្រះអានន្ទដ៏ចម្រើន តាមទំនៀមពួកតិរ្ថិយទាំងនេះ (កាលបើរៀនសិល្ប-សាស្ត្រ ក្នុងសំណាក់អាចារ្យណា) តែងស្វែងរករង្វាន់អាចារ្យ ដើម្បីអាចារ្យ (នោះ) ចំណង់បើរូបខ្ញុំព្រះករុណា នឹងខានធ្វើការបូជាដល់ព្រះអានន្ទមានអាយុដូចម្តេចបាន ។ ទើបទសមគហបតិអ្នកក្រុងអដ្ឋកៈ បានប្រជុំភិក្ខុសង្ឃដែលគង់នៅ ក្នុងក្រុងបាតលិបុត្តនិងក្រុងវេសាលីហើយ អង្គាស ដោយខាទនីយៈ ភោជនីយាហារ ដ៏ឆ្ងាញ់ពីសា ដោយខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែលោកប្រកែកលែងទទួលទៀត ហើយនិមន្តភិក្ខុមួយរូប ៗ ឲ្យស្លៀកដណ្តប់ដោយសំពត់ ១ គូ ១ អង្គ រួចនិមន្តព្រះអានន្ទមានអាយុឲ្យស្លៀកដណ្តប់ដោយចីវរ ៣ ហើយកសាងទីនៅគួរដល់ថ្លៃ ៥០០ (កហាបណៈ) ប្រគេនព្រះអានន្ទមានអាយុ ។

ចប់ អដ្ឋកនាគរសូត្រ ទី ២ ។

# តតិយំ សេក្ខប្បដិបទាសុត្តំ

[២៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន កាបិលវត្ថវានំ សក្យានំ នវំ សន្ថាគារំ អចិរការិតំ ហោតិ អនជ្ឈាវុដ្ឋបុព្វំ[១] សមណេន វា ព្រាហ្មណេន វា កេនចិ វា មនុស្សភូតេន ។ អថខោ កាបិលវត្ថវា សក្យា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ កាបិលវត្ថវា សក្យា ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ កាបិលវត្ថវានំ សក្យានំ នវំ សន្ថាគារំ អចិរការិតំ ហោតិ[២] អនជ្ឈាវុដ្ឋបុព្វំ សមណេន វា ព្រាហ្មណេន វា កេនចិ វា មនុស្សភូតេន តំ ភន្តេ ភគវា បឋមំ បរិភុញ្ជតុ ភគវតា បឋមំ បរិភុត្តំ

---

១ ឱ. ម. អនជ្ឈាវុដ្ឋំ ។ ២ ឱ. ហោតីតិ ន ទិស្សតិ ។

# សេក្ខប្បដិបទាសូត្រ ទី ៣

[២៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលវត្ថុ ក្នុងដែនសក្កៈ ។ សម័យនោះឯង ពួកសក្យៈអ្នកក្រុងកបិលវត្ថុ បានកសាងសន្ថាគារសាលាថ្មីមួយ ទើបនឹងហើយថ្មី ៗ មិនទាន់មានសមណៈឬព្រាហ្មណ៍ ឬអ្នកណាមួយដែលជាជាតិមនុស្ស[១] ចូលទៅនៅអាស្រ័យនៅឡើយ ។ លំដាប់នោះ ពួកសក្យៈអ្នកក្រុងកបិលវត្ថុ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះពួកសក្យៈអ្នកក្រុងកបិលវត្ថុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកសក្យៈអ្នកក្រុងកបិលវត្ថុ បានកសាងសន្ថាគារសាលាថ្មី ១ ទើបនឹងហើយថ្មី ៗ មិនទាន់មានសមណៈ ឬព្រាហ្មណ៍ ឬអ្នកណាមួយដែលជាជាតិមនុស្ស ចូលទៅអាស្រ័យនៅឡើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ប្រើប្រាស់សន្ថាគារសាលានោះជាមុន លុះព្រះមានព្រះភាគ ទ្រង់ប្រើប្រាស់ជាមុនរួចហើយ ទើប

---

១ បានជាមិននិយាយដល់ទេវតាផង ព្រោះកន្លែងណាដែលមនុស្សទើបនឹងធ្វើថ្មី រមែងមានទេវតាចូលទៅនៅមុន ។ អដ្ឋកថា ។

បច្ឆា កាបិលវត្ថវា សក្យា បរិភុញ្ជិស្សន្តិ តទស្ស កាបិលវត្ថវានំ សក្យានំ ទីឃរត្តំ ហិតាយ សុខាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ កាបិលវត្ថវា សក្យា ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន នវំ[១] សន្ធាគារំ តេនុបសង្កមឹសុ ឧបសង្កមិត្វា សព្វសន្ថរឹ សន្ធាគារំ សន្ថរាបេត្វា[២] អាសនានិ បញ្ញាបេត្វា ឧទកមណិកំ បតិដ្ឋាបេត្វា តេលប្បទីបំ អារោបេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ កាបិលវត្ថវា សក្យា ភគវន្តំ ឯតទវោចុំ សព្វសន្ថរឹ សន្ថតំ ភន្តេ សន្ធាគារំ អាសនានិ បញ្ញត្តានិ ឧទកមណិកោ បតិដ្ឋាបិតោ តេលប្បទីបោ អារោបិតោ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។

១ ឱ. ម. នវន្តិ ន ទិស្សតិ ។ ២ ឱ. ម. សន្ថរិត្វា ។

ពួកសក្យៈអ្នកក្រុងកបិលវត្ថុ នឹងប្រើប្រាស់ជាខាងក្រោយ ការប្រើប្រាស់នោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខ យូរអង្វែងដល់ពួកសក្យៈអ្នកក្រុងកបិលវត្ថុ ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តន៍ដោយអាការស្ងៀម ។ ចំណែកខាងពួកសក្យៈអ្នកក្រុងកបិលវត្ថុដឹងថា ព្រះមានព្រះភាគទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចហើយ នាំគ្នាចូលទៅកាន់សន្ថាគារសាលាថ្មី លុះចូលទៅដល់ហើយ បាននាំគ្នាចាត់ចែងសន្ថាគារសាលាឲ្យមានកម្រាលគ្រប់អន្លើ ហើយក្រាលអាសនៈទាំងឡាយ រួចតម្កល់ក្អមទឹកទុក អុជប្រទីបប្រេងរួចហើយ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះពួកសក្យៈអ្នកក្រុងកបិលវត្ថុ ឋិតនៅក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គបានចាត់ចែងនូវសន្ថាគារសាលា ឲ្យមានកម្រាលគ្រប់អន្លើ បានក្រាលអាសនៈទាំងឡាយ បានតម្កល់ក្អមទឹកទុក និងអុជប្រទីបប្រេងទុករួចស្រេចហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សំគាល់នូវកាលនៃពុទ្ធដំណើរ ក្នុងកាលឥឡូវនេះចុះ ។

[២៨] អថខោ ភគវា និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន សន្ធាគារំ តេនុបសង្កមិ ឧបសង្កមិត្វា បាទេ បក្ខាលេត្វា សន្ធាគារំ បវិសិត្វា មជ្ឈិមថម្ភំ និស្សាយ បុរត្ថាភិមុខោ និសីទិ ។ ភិក្ខុសង្ឃោបិ ខោ បាទេ បក្ខាលេត្វា សន្ធាគារំ បវិសិត្វា បច្ឆិមំ ភិត្តឹ និស្សាយ បុរត្ថាភិមុខោ និសីទិ ភគវន្តំយេវ បុរក្ខត្វា ។ កាបិលវត្ថវាបិ ខោ សក្យា បាទេ បក្ខាលេត្វា សន្ធាគារំ បវិសិត្វា បុរត្ថិមំ ភិត្តឹ និស្សាយ បច្ឆិមាភិមុខា[១] និសីទឹសុ ភគវន្តំយេវ បុរក្ខត្វា ។ អថខោ ភគវា កាបិលវត្ថវេ សក្យេ ពហុទេវ រត្តឹ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ បដិភាតុ តំ អានន្ទ កាបិលវត្ថវានំ សក្យានំ សេក្ខោ បដិបទោ បិដ្ឋិ មេ អាគិលាយតិ តមហំ អាយមិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។

---

១ ឱ. បច្ឆាមុខា ។

[២៥] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ព្រមទាំងភិក្ខុសង្ឃ ទ្រង់និមន្តចូលទៅកាន់សន្ថាគារសាលា លុះចូលទៅដល់ហើយ ទ្រង់ឲ្យលាងព្រះបាទារួចហើយ យាងចូលទៅកាន់សន្ថាគារសាលា គង់ផ្អែកនឹងសសរកណ្ដាល បែរព្រះភក្ត្រទៅទិសខាងកើត ។ ឯភិក្ខុសង្ឃក៏ឲ្យលាងជើងរួចហើយ ចូលទៅកាន់សន្ថាគារសាលា អង្គុយផ្អែកនឹងជញ្ជាំងខាងលិច បែរមុខទៅទិសខាងកើត មានព្រះមានព្រះភាគគង់នៅខាងមុខ ។ ឯពួកសក្យៈអ្នកក្រុងកបិលវត្ថុ ក៏លាងជើងរួចហើយ ចូលទៅកាន់សន្ថាគារសាលា អង្គុយផ្អែកនឹងជញ្ជាំងខាងកើត បែរមុខទៅទិសខាងលិច មានព្រះមានព្រះភាគគង់នៅខាងមុខ ។ លំដាប់នោះ ព្រះមានព្រះភាគ ពន្យល់ណែនាំពួកសក្យៈអ្នកក្រុងកបិលវត្ថុ ឲ្យយល់ប្រយោជន៍ (ក្នុងបច្ចុប្បន្ននិងបរលោក) ឲ្យជឿជាក់ (ក្នុងកុសលធម៌) ឲ្យខ្មីឃ្មាតសង្វាត ឲ្យរីករាយ ដោយធម្មីកថា ច្រើនរាត្រី (ពេញមួយយប់) ហើយត្រាស់ទៅនឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកសំដែងសេក្ខប្បដិបទា ដល់ពួកសក្យៈអ្នកក្រុងកបិលវត្ថុចុះ ដ្បិតតថាគតពោយខ្នងណាស់ តថាគតនឹងសម្រាកខ្នងបន្តិច ។ ព្រះអានន្ទមានអាយុ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

អថខោ ភគវា ចតុក្កុណ្ឌំ សង្ឃាដឹ បញ្ញាបេត្វា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ បាទេន បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា ។

[២៦] អថខោ អាយស្មា អានន្ទោ មហានាមំ សក្កំ អាមន្តេសិ ឥធ មហានាម អរិយសាវកោ សីលសម្បន្នោ ហោតិ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ភោជនេ មត្តញ្ញូ ហោតិ ជាគរិយមនុយុត្តោ ហោតិ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។

[២៧] កថញ្ច មហានាម អរិយសាវកោ សីលសម្បន្នោ ហោតិ ។ ឥធ មហានាម អរិយសាវកោ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ឯវំ ខោ មហានាម អរិយសាវកោ សីលសម្បន្នោ ហោតិ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ក្រាលសង្ឃាដីឲ្យជា ៤ ជាន់ ហើយ សម្រេចនូវសីហសេយ្យាផ្ទៀងខាងស្តាំ គង់ព្រះបាទដោយព្រះបាទ មានសតិនិងសម្បជញ្ញៈ កំណត់ទុកក្នុងហឫទ័យ នូវឧដ្ឋានសញ្ញា គឺសេចក្តីសំគាល់នូវការក្រោកឡើងវិញ ។

[២៦] គ្រានោះ ព្រះអានន្ទមានអាយុ សំដែងចំពោះមហានាមសក្យៈថា បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសីល ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកស្គាល់ប្រមាណក្នុងភោជន ជាអ្នកប្រកបនូវការភ្ញាក់រឭក ជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការ ជាអ្នកបានដូចប្រាថ្នានូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាហេតុនៃកិរិយានៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយ ។

[២៧] បពិត្រមហានាម ចុះអរិយសាវ័កជាអ្នកបរិបូណ៌ដោយសីល តើដូចម្តេច ។ បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមល្អក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ បពិត្រមហានាម អរិយសាវ័កដែលជាអ្នកបរិបូណ៌ដោយសីល យ៉ាងនេះឯង ។

[២៨] កថញ្ច មហានាម អរិយសាវកោ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។ ឥធ មហានាម អរិយសាវកោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ឯវំ ខោ មហានាម អរិយសាវកោ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។

[២៨] បពិត្រមហានាម ចុះអរិយសាវ័កជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ឃើញរូបារម្មណ៍ដោយចក្ខុ មិនក្តួចកាន់និមិត្ត មិនក្តួចកាន់អនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្សជាអកុសលដ៏លាមក គប្បីជាប់តាមបុគ្គល ដែលមិនសង្រួមនូវចក្ខុន្ទ្រិយ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា លោកប្រតិបត្តិ ដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ.... ដឹងធម្មារម្មណ៍ដោយចិត្ត ហើយជាអ្នកមិនក្តួចកាន់និមិត្ត មិនក្តួចកាន់អនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្សជាអកុសលដ៏លាមក គប្បីជាប់តាមបុគ្គល ដែលមិនសង្រួមនូវមនិន្ទ្រិយ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា លោកប្រតិបត្តិ ដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ បពិត្រមហានាម អរិយសាវ័កដែលជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ យ៉ាងនេះឯង ។

គហបតិវគ្គស្ស សេក្ខប្បដិបទាសុត្តេ ភោជនេ មត្តញ្ញុតា

[២៩] កថញ្ច មហានាម អរិយស្សាវកោ ភោជនេ មត្តញ្ញូ ហោតិ ។ ឥធ មហានាម អរិយស្សាវកោ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ឯវំ ខោ មហានាម អរិយស្សាវកោ ភោជនេ មត្តញ្ញូ ហោតិ ។

គហបតិវគ្គ សេក្ខប្បដិបទាសូត្រ ការស្គាល់ប្រមាណក្នុងភោជន

[២៩] បពិត្រមហានាម ចុះអរិយសាវ័ក ជាអ្នកស្គាល់ប្រមាណក្នុងភោជន តើដូចម្តេច ។ បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ពិចារណាដោយឧបាយ ទើបបរិភោគអាហារដោយគិតថា អាត្មាអញបរិភោគអាហារ ដើម្បីលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីស្រវឹងក៏ទេ ដើម្បីប្រដាប់តាក់តែងរាងកាយក៏ទេ ដើម្បីធ្វើឲ្យផូរផង់ពណ៌សម្បុរក៏ទេ (បរិភោគ) ដើម្បីនឹងឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់សេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយធម៌ អាត្មាអញនឹងកម្ចាត់បង់វេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោសមានមិនប្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អាត្មាអញដោយបានបរិភោគអាហារនេះ បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ដែលជាអ្នកស្គាល់ប្រមាណក្នុងភោជន យ៉ាងនេះឯង ។

[៣០] កថញ្ច មហានាម អរិយសាវកោ ជាគរិយមនុយុត្តោ ហោតិ ។ ឥធ មហានាម អរិយសាវកោ ទិវសំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេតិ បាទេ បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ ឯវំ ខោ មហានាម អរិយសាវកោ ជាគរិយមនុយុត្តោ ហោតិ ។

[៣១] កថញ្ច មហានាម អរិយសាវកោ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ ។ ឥធ មហានាម អរិយសាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ

[៣០] បពិត្រមហានាម ចុះអរិយសាវ័កជាអ្នកប្រកបនូវសេចក្តីភ្ញាក់រឭក តើដូចម្តេច ។ បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ បើក្នុងវេលាថ្ងៃ (លោក) រមែងជម្រះចិត្តចាកនីវរណធម៌ទាំងឡាយដោយការចង្រ្កមនិងអង្គុយ បើវេលារាត្រីបឋមយាម (លោក) រមែងជម្រះចិត្តចាកនីវរណធម៌ទាំងឡាយ ដោយការចង្រ្កមនិងអង្គុយ លុះដល់វេលារាត្រីមជ្ឈិមយាម លោករមែងសម្រេចសីហសេយ្យាផ្អៀងខាងស្តាំ យកជើងគងលើជើង មានសតិនិងសម្បជញ្ញៈ ធ្វើមនសិការៈនូវឧដ្ឋានសញ្ញា លុះដល់វេលារាត្រីមច្ឆិមយាម (លោក) រមែងក្រោកឡើងហើយជម្រះចិត្ត ចាកនីវរណធម៌ទាំងឡាយ ដោយការចង្រ្កមនិងអង្គុយ បពិត្រមហានាម អរិយសាវ័កដែលជាអ្នកប្រកបនូវការភ្ញាក់រឭក យ៉ាងនេះឯង ។

[៣១] បពិត្រមហានាម ចុះអរិយសាវ័កជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការ តើដូចម្តេច ។ បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានសទ្ធា រមែងជឿចំពោះពោធិញ្ញាណរបស់ព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវលោក

គហបតិវគ្គស្ស សេក្ខប្បដិបទាសុត្តេ សត្ត សទ្ធម្មា

អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ហិរិមា ហោតិ ហិរិយតិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ហិរិយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឱត្តាបី ហោតិ ឱត្តបតិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ឱត្តបតិ បាបកានំ អកុសលានំ ធម្មានំ សមា-បត្តិយា ពហុស្សុតោ ហោតិ សុតធរោ សុតសន្និ-ចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេ-កល្យាណា បរិយោសានកល្យាណា សាត្ថា សព្យញ្ជ-នា កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា អារទ្ធវីរិ-យោ ហោតិ[១] អកុសលានំ ធម្មានំ បហានាយ កុស-លានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ សតិមា ហោតិ

១ ឱ. ម. វិហរតិ ។

គហបតិវគ្គ សេក្ខប្បដិបទាសូត្រ ព្រះសទ្ធម្ម ៧ ប្រការ

ព្រះអង្គប្រសើរបំផុត ដោយសីលាទិគុណ ព្រះអង្គជាសារថីទូន្មានបុរស ព្រះអង្គជាសាស្តារបស់ពួកទេវតានិងមនុស្ស ព្រះអង្គត្រាស់ដឹងសច្ចធម៌ ព្រះអង្គបំបាត់បង់ត្រៃភព ដូច្នេះ១ ជាអ្នកមានសេចក្តីខ្មាស រមែងអៀនខ្មាសចំពោះកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត រមែងអៀនខ្មាសចំពោះការជួបប្រសព្វអកុសលធម៌ដ៏លាមក១ ជាអ្នកមានសេចក្តីតក់ស្លុត រមែងតក់ស្លុតចំពោះកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត រមែងតក់ស្លុត ចំពោះការជួបប្រសព្វអកុសលធម៌ដ៏លាមក១ ជាពហុស្សូត ទ្រទ្រង់នូវចំណេះ សន្សំទុកនូវចំណេះ ធម៌ទាំងឡាយណាមានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកបដោយអត្ថនិងព្យញ្ជនៈ រមែងប្រកាសព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំង-ឡាយមានសភាពដូច្នោះ លោកបានស្តាប់មកច្រើន បានទ្រទ្រង់ទុក បានចាំស្ទាត់រត់មាត់ បានចូលចិត្តច្បាស់លាស់ បានយល់ច្បាស់ដោយទិដ្ឋិគឺបញ្ញា១ ជាអ្នកផ្តួចផ្តើមសេចក្តីព្យាយាម ដើម្បីលះអកុសល-ធម៌ ដើម្បីបំពេញកុសលធម៌ ជាអ្នកមានកម្លាំងព្យាយាម ខ្មីឃ្មាតមុតមាំ មិនដាក់ធុរៈចោល ចំពោះកុសលធម៌ទាំងឡាយ១ ជាអ្នកមានសតិ

បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ[១] អរិយាយ និព្វេធិកាយ សម្មា ទុក្ខក្ខយគាមិនិយា ឯវំ ខោ មហានាម អរិយសាវកោ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ ។

[៣២] កថញ្ច មហានាម អរិយសាវកោ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ ឥធ មហានាម អរិយសាវកោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច

១ ម. សមន្នាគតោ ហោតិ ។

ប្រកបព្រមដោយសតិនិងបញ្ញាដ៏ឧត្តម ជាអ្នកនឹករលឹកចាំបាននូវអំពើដែលខ្លួនធ្វើយូរហើយ និងសំដីដែលខ្លួននិយាយយូរហើយ ១ ជាអ្នកមានប្រាជ្ញា រមែងប្រកបដោយប្រាជ្ញាជាគ្រឿងដឹងច្បាស់ នូវការកើតឡើង និងសូន្យទៅ (នៃខន្ធ ៥) និងបញ្ញាសម្រាប់ទម្លាយបង់នូវគំនរលោភៈ ទោសៈ មោហៈ ដ៏ប្រសើរ ទាំងជាគ្រឿងដឹង នូវការអស់ទៅនៃកងទុក្ខដោយប្រពៃ១ បពិត្រមហានាម អរិយសាវ័កដែលជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការ យ៉ាងនេះឯង ។

[៣២] បពិត្រមហានាម ចុះអរិយសាវ័កជាអ្នកបានដូចប្រាថ្នានូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ថ្លៃថ្លា ជាហេតុនៃការនៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយតើដូចម្តេច ។ បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈដែលកើតអំពីវិវេក ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ក៏ចូលកាន់ទុតិយជ្ឈាន ជាទីផូរផង់ប្រព្រឹត្តទៅក្នុងសន្តាន មានភាវៈនៃចិត្តដ៏ប្រសើរ គ្មានវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ ព្រោះលះបង់បីតិចេញ ជាបុគ្គលព្រងើយផង មានសតិ

សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឯវំ ខោ មហានាម អរិយសាវកោ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។

[៣៣] យតោ ខោ មហានាម អរិយសាវកោ ឯវំ សីលសម្បន្នោ ហោតិ ឯវំ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ឯវំ ភោជនេ មត្តញ្ញូ ហោតិ ឯវំ ជាគរិយមនុយុត្តោ ហោតិ ឯវំ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ ឯវំ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អយំ វុច្ចតិ មហានាម អរិយសាវកោ

និងសម្បជញ្ញៈផង ទទួលសេចក្ដីសុខដោយនាមកាយផង ចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយសរសើរថា បុគ្គលដែលបានតតិយជ្ឈានហើយតែងមានចិត្តព្រងើយ ជាអ្នកមានស្មារតី មានប្រក្រតីនៅជាសុខ ព្រោះលះបង់សេចក្ដីសុខផង លះបង់សេចក្ដីទុក្ខផង ព្រោះរលត់សោមនស្សនិងទោមនស្សអំពីមុនផង លោកក៏បានចូលកាន់ចតុត្ថជ្ឈាន ឥតទុក្ខឥតសុខ មានសតិ ដែលកើតអំពីឧបេក្ខាដ៏បរិសុទ្ធ ។ បពិត្រមហានាម អរិយសាវ័កជាអ្នកបានដូចប្រាថ្នានូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ថ្លៃថ្លា ជាហេតុនៃការនៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយ យ៉ាងនេះឯង ។

[៣៣] បពិត្រមហានាម កាលណាអរិយសាវ័កជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះ ជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយយ៉ាងនេះ ជាអ្នកស្គាល់ប្រមាណក្នុងភោជនយ៉ាងនេះ ជាអ្នកប្រកបដោយការភ្ញាក់រឭកយ៉ាងនេះ ជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការយ៉ាងនេះ ជាអ្នកបានដូចប្រាថ្នានូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ថ្លៃថ្លា ជាហេតុនៃការនៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយយ៉ាងនេះ បពិត្រមហានាម អរិយសាវ័កនេះ ព្រះបរមគ្រូ

សេក្ខោ បដិបទោ អបុច្ចណ្ឌតាយ សមាបន្នោ ភព្វោ អភិនិព្ភិទាយ ភព្វោ សម្ពោធាយ ភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ ។ សេយ្យថាបិ មហានាម កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា តានស្សុ កុក្កុដិយា សម្មា អធិសយិតានិ សម្មា បរិសេទិតានិ សម្មា បរិភាវិតានិ កិញ្ចាបិ តស្សា កុក្កុដិយា ន ឯវំ ឥច្ឆា ឧប្បជ្ជេយ្យ អហោ វតិមេ[១] កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជេយ្យុន្តិ[២] ឯវមេវ ខោ មហានាម យតោ អរិយសាវកោ ឯវំ សីលសម្បន្នោ ហោតិ ឯវំ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ឯវំ ភោជនេ មត្តញ្ញូ ហោតិ ឯវំ ជាគរិយមនុយុត្តោ ហោតិ ឯវំ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ

---

១ ឱ. វតមេ ។ ២ ឱ. ម. ឥតោ បរំ អថខោ ភព្វា វ តេ កុក្កុដបោតកា បាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជិតុន្តិ ទិស្សន្តិ ។

សំដែងថា អ្នកមានសេចក្តីប្រតិបត្តិជាសេក្ខៈ ប្រកបដោយសេចក្តីប្រតិបត្តិដូចជាពងមាន់មិនស្អុយ ជាបុគ្គលគួរដើម្បីបែកធ្លាយនូវញាណ គួរត្រាស់ដឹង គួរបាននូវព្រះនិព្វាន ជាដែនក្សេមចាកយោគៈដ៏ប្រសើរ ។ បពិត្រមហានាម ប្រៀបដូចពងមាន់ ៨ ក្តី ១០ ក្តី ១២ ក្តី ពងមាន់ទាំងនោះមេមាន់បានក្រាបល្អហើយ ធ្វើឲ្យកក់ក្តៅដោយប្រពៃហើយ អប់រំកម្តៅដោយល្អហើយ ចំណែកខាងមេមាន់នោះ មិនមានបំណងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ កូនមាន់ទាំងនេះគប្បីទម្លាយសម្បកពង ដោយចុងក្រចកឬដោយចុងចំពុះ ហើយញាស់ចេញមកដោយសួស្តីដូច្នេះទេ មានឧបមាយ៉ាងណាមិញ បពិត្រមហានាម កាលណាបើអរិយាសាវ័កជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះ ជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយយ៉ាងនេះ ជាអ្នកស្គាល់ប្រមាណក្នុងភោជនយ៉ាងនេះ ជាអ្នកប្រកបការភ្ញាក់រលឹកយ៉ាងនេះ ជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការយ៉ាងនេះ

៤១



ឯវំ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខ-វិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អយំ វុច្ចតិ មហានាម អរិយស្សាវកោ សេក្ខោ បដិបទោ អបុច្ចណ្ឌតាយ សមាបន្នោ ភព្វោ អភិនិព្ភិទាយ ភព្វោ សម្ពោធាយ ភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ ។ ស ខោ សោ មហានាម អរិយស្សាវកោ ឥមំយេវ អនុត្តរំ ឧបេក្ខា-សតិចារិសុទ្ធឹ អាគម្ម អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេ-និវាសំ អនុស្សរតិ អយមស្ស បឋមាភិនិព្ភិទា ហោតិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហា ។ ស ខោ សោ មហានាម អរិយស្សាវកោ ឥមំយេវ អនុត្តរំ ឧបេក្ខា-សតិចារិសុទ្ធឹ អាគម្ម ទិព្វេន ចក្ខុនា វិសុទ្ធេន

ជាអ្នកបានដូចសេចក្ដីប៉ុនប៉ងនូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ថ្លៃថ្លា ជាហេតុនៃការនៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយយ៉ាងនេះ បពិត្រមហានាម អរិយសាវ័កនេះ ព្រះបរមសាស្ដាចារ្យសំដែងថា អ្នកមានសេចក្ដីប្រតិបត្តិជាសេក្ខៈ ប្រកបដោយសេចក្ដីប្រតិបត្តិដូចជាពងមាន់មិនស្អុយ ជាបុគ្គលគួរដើម្បីបែកធ្លាយនូវញាណគួរត្រាស់ដឹង គួរបាននូវព្រះនិព្វានជាដែនក្សេមចាកយោគៈដ៏ប្រសើរ ក៏មានឧបមេយ្យយ៉ាងនេះដែរ ។ បពិត្រមហានាម អរិយសាវ័កនោះឯង អាស្រ័យសតិដ៏បរិសុទ្ធដោយឧបេក្ខាដ៏ប្រសើរនេះឯង ទើបរលឹកបាននូវជាតិដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុន បានច្រើនជាតិ គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកបាននូវជាតិដែលខ្លួនធ្លាប់អាស្រ័យនៅអំពីមុនបានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះឯង នេះឈ្មោះថាការបែកធ្លាយនៃប្រាជ្ញាទី ១ គឺបុព្វេនិវាសញ្ញាណរបស់អរិយសាវ័កនោះ ដូចពងមាន់ដែលញាស់ចេញចាកសម្បកពង ។ បពិត្រមហានាម អរិយសាវ័កនេះឯង អាស្រ័យសតិដ៏បរិសុទ្ធដោយឧបេក្ខាដ៏ប្រសើរនេះឯង ទើបលោកមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ

អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ អយមស្ស ទុតិយាភិនិព្ភិទា ហោតិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហា ។ ស ខោ សោ មហានាម អរិយសាវកោ ឥមំយេវ អនុត្តរំ ឧបេក្ខាសតិបារិសុទ្ធឹ អាគម្ម អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ អយមស្ស តតិយាភិនិព្ភិទា ហោតិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហា ។

[៣៤] យម្បិ[១] មហានាម អរិយសាវកោ សីលសម្បន្នោ ហោតិ ឥទម្បិស្ស ហោតិ ចរណស្មឹ យម្បិ[២] មហានាម អរិយសាវកោ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ឥទម្បិស្ស ហោតិ ចរណស្មឹ យម្បិ[៣] មហានាម អរិយសាវកោ ភោជនេ មត្តញ្ញូ ហោតិ ឥទម្បិស្ស ហោតិ ចរណស្មឹ យម្បិ[៤] មហានាម អរិយសាវកោ ជាគរិយមនុយុត្តោ ហោតិ ឥទម្បិស្ស ហោតិ

១-២-៣-៤ ម. យម្បិ ខោ ។

កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម នេះឈ្មោះថាការបែកធ្លាយនៃប្រាជ្ញាទី ២ គឺទិព្វចក្ខុវិញ្ញាណរបស់អរិយសាវ័កនោះ ដូចកូនមាន់ដែលញាស់ចេញចាកសម្បកពង ។ បពិត្រមហានាម អរិយសាវ័កនោះឯង អាស្រ័យសតិដ៏បរិសុទ្ធដោយឧបេក្ខាដ៏ប្រសើរនេះឯង ទើបធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវធម៌ទាំងឡាយ ដោយប្រាជ្ញារបស់ខ្លួនក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅដោយឥរិយាបថ នេះឈ្មោះថាការបែកធ្លាយនៃប្រាជ្ញាទី ៣ គឺអាសវក្ខយញ្ញាណរបស់អរិយសាវ័កនោះ ដូចកូនមាន់ដែលញាស់ចេញចាកសម្បកពង ។

[៣៤] បពិត្រមហានាម ត្រង់អរិយសាវ័កលោកបានបរិបូណ៌ដោយសីល នេះឯងជាចរណៈរបស់អរិយសាវ័កនោះ បពិត្រមហានាម ត្រង់អរិយសាវ័ក បានគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ នេះឯងជាចរណៈរបស់អរិយសាវ័កនោះ បពិត្រមហានាម ត្រង់អរិយសាវ័កស្គាល់ប្រមាណក្នុងភោជន នេះឯងជាចរណៈរបស់អរិយសាវ័កនោះ បពិត្រមហានាម ត្រង់អរិយសាវ័ក ប្រកបការភ្ញាក់រលឹក នេះឯងជា

ចរណស្មឹ យម្បិ[១] មហានាម អរិយសាវកោ សត្តហិ សទ្ធម្មេហិ សមន្នាគតោ ហោតិ ឥទម្បិស្ស ហោតិ ចរណស្មឹ យម្បិ[២] មហានាម អរិយសាវកោ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ឥទម្បិស្ស ហោតិ ចរណស្មឹ យញ្ច ខោ មហានាម អរិយសាវកោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ឥទម្បិស្ស ហោតិ វិជ្ជាយ យម្បិ មហានាម អរិយសាវកោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ឥទម្បិស្ស ហោតិ វិជ្ជាយ

---

១-២ ម. យម្បិ ខោ ។

ចរណៈរបស់អរិយសាវ័កនោះ បពិត្រមហានាម ត្រង់អរិយសាវ័កបានប្រកប ដោយសប្បុរិសធម៌ទាំង ៧ ប្រការ នេះឯងជាចរណៈរបស់អរិយសាវ័កនោះ បពិត្រមហានាម ត្រង់អរិយសាវ័កបានដូចសេចក្ដីប៉ុនប៉ង នូវឈានទាំង ៤ ប្រការ ដែលអាស្រ័យចិត្តដ៏ថ្លៃថ្លាជាហេតុនៃការនៅជាសុខក្នុងបច្ចុប្បន្ន បានដោយមិនលំបាក បានដោយងាយ នេះឯងជាចរណៈ របស់អរិយសាវ័កនោះ បពិត្រមហានាម ត្រង់អរិយសាវ័ក បានរលឹកឃើញជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅអំពីមុន បានច្រើនជាតិ គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលអំពីមុន បានច្រើនជាតិព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ នេះឯងជាវិជ្ជារបស់អរិយ-សាវ័កនោះ បពិត្រមហានាម ត្រង់អរិយសាវ័កមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងនូវចក្ខុរបស់មនុស្សធម្មតា ។ បេ ។ លោកដឹងច្បាស់នូវសត្វទាំង-ឡាយ ដែលអន្ទោលទៅតាមកម្ម នេះឯងជាវិជ្ជារបស់អរិយសាវ័កនោះ

យម្បិ មហានាម អរិយសាវកោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥទម្បិស្ស ហោតិ វិជ្ជាយ អយំ វុច្ចតិ មហានាម អរិយសាវកោ វិជ្ជាសម្បន្នោ ឥតិបិ ចរណសម្បន្នោ ឥតិបិ វិជ្ជាច-រណសម្បន្នោ ឥតិបិ ។ ព្រហ្មុនាបេសា[១] មហានាម សនង្កុមារេន គាថា ភាសិតា

> ខត្តិយោ សេដ្ឋោ ជនេតស្មឹ
> យេ គោត្តប្បដិសារិនោ
> វិជ្ជាចរណសម្បន្នោ
> សោ សេដ្ឋោ ទេវមានុសេតិ ។

[៣៥] សា ខោ បនេសា មហានាម ព្រហ្មុនា សនង្កុមារេន គាថា សុគីតា ន ទុគ្គីតា សុភាសិតា ន[២] ទុព្ភាសិតា អត្ថសញ្ហិតា នោ អនត្ថសញ្ហិតា អនុមតា ភគវតាតិ ។ អថខោ ភគវា ឧដ្ឋហិត្វា

---
១ ម. ព្រហ្មុនា ខោ បនេសា ។ ២ ម. នោ ។

បពិត្រមហានាម ត្រង់អរិយសាវ័កធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិនិង បញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវធម៌ទាំងឡាយ ដោយប្រាជ្ញានៃខ្លួនក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តដោយឥរិយាបថ នេះឯងជាវិជ្ជារបស់អរិយសាវ័កនោះ បពិត្រមហានាម អរិយសាវ័កនេះ ព្រះបរមគ្រូទ្រង់សំដែងថា ជាអ្នកបរិបូណ៌ដោយវិជ្ជាដូច្នេះក៏បាន បរិបូណ៌ ដោយចរណៈដូច្នេះក៏បាន បរិបូណ៌ដោយវិជ្ជានិងចរណៈដូច្នេះក៏បាន ។ បពិត្រមហានាម ទាំងព្រហ្មឈ្មោះសនង្កុមារ ក៏បានពោលគាថានេះថា

ក្សត្រប្រសើរបំផុត ក្នុងពួកជនដែលប្រកាន់គោត្រ អ្នកណា
បរិបូណ៌ដោយវិជ្ជានិងចរណៈ អ្នកនោះឈ្មោះថាប្រសើរបំផុត
ក្នុងពួកទេវតានិងមនុស្ស ។

[៣៥] បពិត្រមហានាម គាថានេះឯង ព្រហ្មឈ្មោះ សនង្កុមារ ច្រៀងពីរោះហើយ មិនមែនច្រៀងមិនពីរោះទេ ពោល ពីរោះហើយ មិនមែនពោលមិនពីរោះទេ ជាគាថាប្រកបដោយ ប្រយោជន៍ មិនមែនឥតប្រយោជន៍ទេ ទាំងព្រះមានព្រះភាគ ក៏ទ្រង់យល់ ព្រមហើយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ក្រោកឡើង

៤៤

គហបតិវគ្គស្ស សេក្ខប្បដិបទាសុត្តេ អានន្ទប្បសំសា

អាយស្មន្តំ អានន្ទំ អាមន្តេសិ សាធុ សាធុ អានន្ទ សាធុ ខោ ត្វំ អានន្ទ កាបិលវត្ថវានំ សក្យានំ សេក្ខប្បដិបទំ[១] អភាសីតិ ។ ឥទមវោច អាយស្មា អានន្ទោ សមនុញ្ញោ សត្ថា អហោសិ អត្តមនា កាបិលវត្ថវា សក្យា អាយស្មតោ អានន្ទស្ស ភាសិតំ អភិនន្ទុន្តិ ។

សេក្ខប្បដិបទាសុត្តំ តតិយំ និដ្ឋិតំ ។

១ ឱ. សេក្ខំ បាដិបទំ ។

ហើយត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ពីរោះណាស់ ។ ម្នាលអានន្ទ អ្នកសំដែងសេក្ខប្បដិបទា ដល់ពួកសក្យៈ អ្នកក្រុងកបិលវត្ថុ ពេញហៅពីរោះ ។ លុះព្រះអានន្ទមានអាយុ បានសំដែងសេចក្តីនេះចប់ហើយ ព្រះបរមគ្រូ ក៏មានហឫទ័យត្រេកអរ ពួកសក្យៈ អ្នកក្រុងកបិលវត្ថុ ក៏មានចិត្តរីករាយ ត្រេកអរហើយ ចំពោះភាសិតនៃព្រះអានន្ទមានអាយុ ។

ចប់ សេក្ខប្បដិបទាសូត្រ ទី ៣ ។

# ចតុត្ថំ បោតលិយសុត្តំ

[៣៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អង្គុត្តរាបេសុ វិហរតិ អាបណំ នាម អង្គុត្តរាបានំ និគមោ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ អាបណំ បិណ្ឌាយ បាវិសិ ។ អាបណេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន អញ្ញតរោ វនសណ្ឌោ តេនុបសង្កមិ ឧបសង្កមិត្វា ទិវាវិហារាយ តំ វនសណ្ឌំ អជ្ឈោគហេត្វា[១] អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ[២] និសីទិ ។ បោតលិយោបិ ខោ គហបតិ សម្បន្ននិវាសនបាវុរណោ[៣] ឆត្តុបាហនាហិ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ យេន សោ វនសណ្ឌោ តេនុបសង្កមិ ឧបសង្កមិត្វា តំ វនសណ្ឌំ អជ្ឈោគហេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។

---

១ ឱ. ម. អជ្ឈោគាហិត្វា ។ ២ ឱ. ទិវាវិហារន្តិ ន ទិស្សតិ ។ ៣ ឱ. សម្បន្ននិវាសបាវុរណោ ។ ម. សម្បន្ននិវាសនបាវុរណោ ។

# បោតលិយសូត្រ ទី ៤

[៣៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអាបណនិគម របស់ពួកអង្គុត្តរាបជន ក្នុងអង្គុត្តរាបជនបទ[១] ។ ក្នុងកាលនោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់ដោយបាត្រនិងចីវរ ហើយទ្រង់ចូលទៅកាន់អាបណនិគម ដើម្បីបិណ្ឌបាត ក្នុងវេលាបុព្វណ្ហសម័យ ។ លុះទ្រង់ពុទ្ធដំណើរទៅដើម្បីបិណ្ឌបាត ក្នុងអាបណនិគម ហើយត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាបច្ឆាភត្តហើយ ទ្រង់យាងសំដៅទៅរកដងព្រៃមួយ លុះយាងទៅដល់ហើយ ក៏ទ្រង់ចូលទៅកាន់ដងព្រៃនោះ ដើម្បីសម្រាកព្រះអង្គក្នុងវេលាថ្ងៃ ទ្រង់គង់សម្រាកព្រះអង្គក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។ ទើបបោតលិយគហបតី ស្លៀកដណ្តប់សំពត់សមគួរ ប្រដាប់ឆត្រនិងស្បែកជើង ដើរត្រាច់ទៅរឿយ ៗ ដើម្បីសម្រួលស្មង ហើយដើរសំដៅទៅដងព្រៃនោះ លុះដើរទៅដល់ហើយ ក៏ចូលទៅកាន់ដងព្រៃនោះ ហើយចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏ឋិតនៅក្នុងទីសមគួរ ។

---

១ អដ្ឋកថា ថា អង្គុត្តរាបជនបទនោះ គឺអង្គជនបទនោះឯង តែបានជាហៅថា ឧត្តរាបៈ ដូច្នេះ ព្រោះនិគមនោះ នៅជិតទឹកទន្លេមហី ដែលបត់ទៅខាងជើង ។

គហបតិវគ្គស្ស បោតលិយសុត្តេ គហបតិវាទេន សមុទាចរណំ

[៣៧] ឯកមន្តំ ឋិតំ ខោ បោតលិយំ គហបតឹ ភគវា ឯតទវោច សំវិជ្ជន្តិ[១] ខោ គហបតិ អាសនានិ សចេ អាកង្ខសិ និសីទាតិ ។ ឯវំ វុត្តេ បោតលិយោ គហបតិ គហបតិវាទេន មំ សមណោ គោតមោ សមុទាចរតីតិ កុបិតោ អនត្តមនោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ភគវា បោតលិយំ គហបតឹ ឯតទវោច សំវិជ្ជន្តិ[២] ខោ គហបតិ អាសនានិ សចេ អាកង្ខសិ និសីទាតិ ។ ទុតិយម្បិ ខោ បោតលិយោ គហបតិ គហបតិវាទេន មំ សមណោ គោតមោ សមុទាចរតីតិ កុបិតោ អនត្តមនោ តុណ្ហី អហោសិ ។ តតិយម្បិ ខោ ភគវា បោតលិយំ គហបតឹ ឯតទវោច សំវិជ្ជន្តិ ខោ គហបតិ អាសនានិ សចេ អាកង្ខសិ និសីទាតិ ។ ឯវំ វុត្តេ បោតលិយោ គហបតិ គហបតិវាទេន មំ សមណោ គោតមោ សមុទាចរតីតិ កុបិតោ អនត្តមនោ ភគវន្តំ ឯតទវោច តយិទំ ភោ គោតម នច្ឆន្នំ តយិទំ នប្បតិរូបំ យំ មំ ត្វំ គហបតិវាទេន សមុទាចរសីតិ ។

---
១-២ ឱ. សំវជ្ជន្តេ ។

គហបតិវគ្គ បោតលិយសូត្រ ការទ្រង់ត្រាស់ហៅដោយពាក្យថាគហបតី

[៣៧] លុះបោតលិយគហបតីឋិតនៅក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកាដូច្នេះថា ម្នាលគហបតី អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការចូរអង្គុយចុះ ។ កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ បោតលិយគហបតី ក៏នៅស្ងៀមដោយខឹងអន់ចិត្តថា ព្រះសមណគោតមហ៊ានហៅអញ ដោយពាក្យថា គហ-បតី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងបោតលិយគហបតី ជាគម្រប់ពីរដងទៀតដូច្នេះថា ម្នាលគហបតី អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការចូរអង្គុយចុះ ។ បោតលិយគហបតី ក៏នៅស្ងៀមជាគម្រប់ពីរដងដោយខឹងអន់ចិត្តថា ព្រះសមណគោតមហ៊ានហៅអញ ដោយពាក្យថា គហ-បតី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងបោតលិយគហបតីជាគម្រប់បីដងទៀតដូច្នេះថា ម្នាលគហបតី អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការចូរអង្គុយចុះ ។ កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ បោតលិយគហបតី ក៏ខឹងអន់ចិត្តថា ព្រះសមណគោតមហ៊ានហៅអញដោយពាក្យថា គហបតី ហើយក៏ពោលពាក្យដូច្នេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គហៅខ្ញុំដោយពាក្យថាគហបតីណា ពាក្យនុ៎ះមិនសមគួរឡើយ ពាក្យនុ៎ះមិនសុភាពឡើយ ។

តេ ហិ[១] តេ គហបតិ អាការា តេ លិង្គា តេ និមិត្តា យថាតំ គហបតិស្សាតិ ។ តថា ហិ បន មេ ភោ គោតម សព្វេ កម្មន្តា បដិក្ខិត្តា សព្វេ វោហារា សមុច្ឆិន្នាតិ ។ យថាកថំ បន តេ គហបតិ សព្វេ កម្មន្តា បដិក្ខិត្តា សព្វេ វោហារា សមុច្ឆិន្នាតិ ។ ឥធ មេ ភោ គោតម យំ អហោសិ ធនំ វា ធញ្ញំ វា រជតំ វា ជាតរូបំ វា សព្វន្តំ បុត្តានំ ទាយជ្ជំ និយ្យាតំ តត្ថាហំ អនោវាទី អនុបវាទី ឃាសច្ឆាទនបរមោ វិហរាមិ ឯវញ្ច[២] មេ ភោ គោតម សព្វេ កម្មន្តា បដិក្ខិត្តា សព្វេ វោហារា សមុច្ឆិន្នាតិ ។ អញ្ញថា ខោ ត្វំ គហបតិ វោហារសមុច្ឆេទំ វទេសិ[៣] អញ្ញថា ច បន អរិយស្ស វិនយេ វោហារសមុច្ឆេទោ ហោតីតិ ។ យថាកថំ បន ភន្តេ អរិយស្ស វិនយេ វោហារសមុច្ឆេទោ ហោតិ

---

១ ម. តេន ហិ ។ ២ ឱ. ឯវំ ខោ ។ ម. ឯវំ ។ ៣ ឱ. វទសិ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតី អាការ ភេទ និងនិមិត្ត របស់អ្នកនៅប្រាកដជារបស់គហបតីនៅឡើយទេតើ ។ បោតលិយគហបតីតបថា បពិត្រព្រះគោតមដ៏ចម្រើន ដូច្នោះមែនហើយ តែថាការងារគ្រប់ចំពូកខ្ញុំព្រះអង្គឈប់លែងធ្វើហើយ ជំនួញទាំងអស់ ខ្ញុំព្រះអង្គកាត់ចោលហើយ ។ ព្រះមានព្រះភាគទ្រង់សួរថា ម្នាលគហបតី ការងារគ្រប់ចំពូកដែលអ្នកឈប់លែងធ្វើហើយ ជំនួញទាំងអស់ដែលអ្នកកាត់ចោលហើយ តើដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន មត៌កណាគឺទ្រព្យសម្បត្តិ ស្រូវ អង្ករ ឬប្រាក់មាសដែលមានក្នុងលោកនេះ មត៌កទាំងអស់នោះ ខ្ញុំព្រះអង្គប្រគល់ឲ្យកូនអស់ហើយ ខ្ញុំព្រះអង្គលែងទូន្មានដាស់តឿនលែងឃាត់ខាំងក្នុងការងារទាំងនោះហើយ នៅមានតែគ្រឿងស៊ីនិងគ្រឿងស្លៀកដណ្តប់ប៉ុណ្ណោះ បពិត្រព្រះគោតមដ៏ចម្រើន ការងារគ្រប់ចំពូកខ្ញុំព្រះអង្គឈប់លែងធ្វើហើយ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គកាត់ចោលហើយយ៉ាងនេះឯង ។ ម្នាលគហបតី អ្នកពោលផ្តាច់បង់ជំនួញដោយចំណែកផ្សេង ការផ្តាច់បង់ជំនួញក្នុងវិន័យ របស់ព្រះអរិយៈដោយចំណែកផ្សេង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការផ្តាច់បង់ជំនួញក្នុងវិន័យ

គហបតិវគ្គស្ស បោតលិយសុត្តេ បឋមធម្មោ

សាធុ មេ ភន្តេ ភគវា តថា ធម្មំ ទេសេតុ យថា អរិយស្ស វិនយេ វោហារសមុច្ឆេទោ ហោតីតិ ។ តេនហិ គហបតិ សុណាហិ[១] សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ បោតលិយោ គហបតិ ភគវតោ បច្ចស្សោសិ ។

[៣៨] ភគវា ឯតទវោច អដ្ឋ ខោ ឥមេ គហបតិ ធម្មា អរិយស្ស វិនយេ វោហារសមុច្ឆេទាយ សំវត្តន្តិ កតមេ អដ្ឋ អបាណាតិបាតំ និស្សាយ បាណាតិបាតោ បហាតព្វោ ទិន្នាទានំ និស្សាយ អទិន្នាទានំ បហាតព្វំ សច្ចំ វាចំ និស្សាយ មុសាវាទោ បហាតព្វោ អបិសុណំ វាចំ និស្សាយ បិសុណា វាចា បហាតព្វា អគិទ្ធិលោភំ និស្សាយ គិទ្ធិលោភោ បហាតព្វោ អនិន្ទារោសំ និស្សាយ និន្ទារោសោ បហាតព្វោ

---

១ ម. សុណោហិ ។

របស់ព្រះអរិយៈ តើដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ការផ្តាច់បង់ជំនួញ ក្នុងវិន័យ របស់ព្រះអរិយៈ យ៉ាងណា សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ដល់ខ្ញុំព្រះអង្គយ៉ាងនោះឲ្យទាន ។ ម្នាលគហបតី បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែង ។ បោតលិយគហបតី ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[៣៨] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី ធម៌ ៨ ប្រការនេះឯង រមែងប្រព្រឹត្តទៅដើម្បីផ្តាច់បង់ជំនួញ ក្នុងវិន័យ របស់ព្រះអរិយៈ ធម៌ ៨ ប្រការ តើដូចម្តេច បុគ្គលព្រោះអាស្រ័យ ការមិនសម្លាប់សត្វ ទើបលះបង់ការសម្លាប់សត្វចេញបាន ព្រោះអាស្រ័យការកាន់យកតែទ្រព្យដែលគេឲ្យ ទើបលះបង់ការកាន់យកទ្រព្យដែលគេមិនឲ្យ ចេញបាន ព្រោះអាស្រ័យពាក្យមិនញុះញង់ ទើបលះបង់ពាក្យញុះញង់ចេញបាន ព្រោះអាស្រ័យសេចក្តីមិនលោភលន់ ទើបលះបង់សេចក្តីលោភលន់ចេញបាន ព្រោះអាស្រ័យសេចក្តីមិនគ្នាន់ក្នាញ់ គឺមិននិន្ទា ទើបលះបង់សេចក្តីគ្នាន់ក្នាញ់ គឺនិន្ទាចេញបាន

អកោធុបាយាសំ និស្សាយ កោធុបាយាសោ បហាតព្វោ អនតិមានំ និស្សាយ អតិមានោ បហាតព្វោ ឥមេ ខោ គហបតិ អដ្ឋ ធម្មា សង្ខិត្តេន វុត្តា វិត្ថារេន អវិភត្តា អរិយស្ស វិនយេ វោហារសមុច្ឆេទាយ សំវត្តន្តីតិ ។ យេមេ បន[១] ភន្តេ ភគវតា អដ្ឋ ធម្មា សង្ខិត្តេន វុត្តា វិត្ថារេន អវិភត្តា អរិយស្ស វិនយេ វោហារសមុច្ឆេទាយ សំវត្តន្តិ សាធុ មេ ភន្តេ ភគវា ឥមេ អដ្ឋ ធម្មេ វិត្ថារេន[២] វិភជតុ អនុកម្បំ ឧបាទាយាតិ ។ តេនហិ គហបតិ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ បោតលិយោ គហបតិ ភគវតោ បច្ចស្សោសិ ។

[៣៩] ភគវា ឯតទវោច អបាណាតិបាតំ និស្សាយ បាណាតិបាតោ បហាតព្វោតិ ឥតិ ខោ បនេតំ វុត្តំ

១ ឱ. បនសទ្ទោ ន ទិស្សតិ ។ ២ ម. វិត្ថារេត្វា ។

ព្រោះអាស្រ័យសេចក្តីមិនចង្អៀតចង្អល់ចិត្ត គឺមិនក្រោធ ទើបលះបង់សេចក្តីចង្អៀតចង្អល់ចិត្ត គឺសេចក្តីក្រោធចេញបាន ព្រោះអាស្រ័យសេចក្តីមិនមើលងាយគេ ទើបលះបង់សេចក្តីមើលងាយគេ ចេញបាន ម្នាលគហបតី ធម៌ទាំង ៨ ប្រការនេះឯង តថាគតពោលហើយដោយបំប្រួញមិនទាន់ចែកដោយពិស្តារ រមែងប្រព្រឹត្តទៅដើម្បីផ្តាច់បង់ជំនួញក្នុងវិន័យ របស់ព្រះអរិយៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ក៏ធម៌ទាំង ៨ ប្រការណា ដែលព្រះមានព្រះភាគសំដែងហើយ ដោយបំប្រួញមិនទាន់ចែកដោយពិស្តារ រមែងប្រព្រឹត្តទៅដើម្បីផ្តាច់បង់ជំនួញ ក្នុងវិន័យរបស់ព្រះអរិយៈ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគអាស្រ័យសេចក្តីអនុគ្រោះ ចែកនូវធម៌ ៨ ប្រការនេះ ដោយពិស្តារ ដល់ខ្ញុំព្រះអង្គឲ្យទាន ។ ម្នាលគហបតី បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែងឲ្យស្តាប់ ។ បោតលិយគហបតីទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[៣៩] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ត្រង់ពាក្យថា បុគ្គល ព្រោះអាស្រ័យការមិនសម្លាប់សត្វ ទើបលះបង់ការសម្លាប់សត្វចេញបាន ដូច្នេះនេះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ

គហបតិវគ្គស្ស បោតលិយសុត្តេ បឋមធម្មោ

កិញ្ចេតំ បដិច្ច វុត្តំ ឥទំ គហបតិ អរិយស្ស វោហារោ ឥតិ បដិសញ្ចិក្ខតិ យេសំ ខោ អហំ សញ្ញោជនានំ ហេតុ បាណាតិបាតី អស្សំ តេសាហំ សញ្ញោជនានំ បហានាយ សមុច្ឆេទាយ បដិបន្នោ អហញ្ចេវ ខោ បន បាណាតិបាតី អស្សំ អត្តាបិ មំ ឧបវទេយ្យ បាណាតិបាតបច្ចយា អនុវិច្ច វិញ្ញូ[1] គរហេយ្យុំ បាណាតិបាតបច្ចយា កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា បាណាតិបាតបច្ចយា ឯតទេវ ខោ បន សញ្ញោជនំ ឯតំ នីវរណំ យទិទំ បាណាតិបាតោ យេ ច បាណាតិបាតបច្ចយា ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា បាណាតិបាតា បដិវិរតស្ស ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ អបាណាតិបាតំ និស្សាយ បាណាតិបាតោ បហាតព្វោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

១ ម. អនុវិច្ចាបិ មំ វិញ្ញូ ។

ក៏ពាក្យនេះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាល គហបតី ព្រះអរិយសាវ័កក្នុងសាសនានេះ តែងពិចារណាដូច្នេះថា អាត្មាអញ ជាអ្នកសម្លាប់សត្វ ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មាអញ បានប្រតិបត្តិដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈទាំងនោះចេញហើយ មួយវិញទៀត បើអាត្មាអញ ជាអ្នកសម្លាប់សត្វហើយ សូម្បីខ្លួនឯងក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុសម្លាប់សត្វ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយ ៗ ក៏គប្បីតិះដៀលបាន ព្រោះហេតុតែសម្លាប់សត្វ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុសម្លាប់សត្វ ធម្មជាតនេះឈ្មោះថា សំយោជនៈ ធម្មជាតនេះឈ្មោះថា នីវរណៈ គឺការសម្លាប់សត្វហ្នឹងឯង មួយយ៉ាងទៀត អាសវៈទាំងឡាយណា មានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុតែការសម្លាប់សត្វ អាសវៈដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលវៀរចាកការសម្លាប់សត្វយ៉ាងនេះ ពាក្យណាដែលតថាគត ពោលហើយថា ព្រោះអាស្រ័យការមិនសម្លាប់សត្វ ទើបលះបង់ការសម្លាប់សត្វចេញ ដូច្នេះ ពាក្យនេះ តថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[៤០] ជិឃ្ឃាធានំ និស្សាយ អជិឃ្ឃាធានំ បហាតព្វន្តិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ឥធ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យេសំ ខោ អហំ សញ្ញោជនានំ ហេតុ អជិឃ្ឃាធាយី អស្សំ តេសាហំ សញ្ញោជនានំ បហានាយ សមុច្ឆេទាយ បដិបន្នោ អហញ្ចេវ ខោ បន អជិឃ្ឃាធាយី អស្សំ អត្តាបិ មំ ឧបវទេយ្យ អជិឃ្ឃាធានប្បច្ចយា អនុវិច្ច វិញ្ញូ គរហេយ្យុំ អជិឃ្ឃាធានប្បច្ចយា កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា អជិឃ្ឃាធានប្បច្ចយា ឯតទេវ ខោ បន សញ្ញោជនំ ឯតំ នីវរណំ យទិទំ អជិឃ្ឃាធានំ យេ ច អជិឃ្ឃាធានប្បច្ចយា ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា អជិឃ្ឃាធានា បដិវិរតស្ស ឯវំស តេ អាសវា

[៤០] ត្រង់ពាក្យថា បុគ្គលព្រោះអាស្រ័យការកាន់យកតែទ្រព្យដែលគេឲ្យ ទើបលះបង់ការកាន់យកទ្រព្យ ដែលគេមិនឲ្យ ដូច្នេះនេះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ ក៏ពាក្យនេះដែលតថា-គតពោលហើយព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ តែងពិចារណាដូច្នេះថា អាត្មាអញ កាន់យកទ្រព្យដែលគេមិនបានឲ្យ ព្រោះហេតុសំយោជនៈណា អាត្មាអញ បានប្រតិបត្តិដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈចេញហើយ មួយវិញទៀត បើអាត្មាអញ ជាអ្នកកាន់យកទ្រព្យ ដែលគេមិនបានឲ្យហើយ សូម្បីខ្លួនឯងគប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយ ៗ ហើយ ក៏គប្បីតិះដៀលបានព្រោះហេតុតែកាន់យកទ្រព្យ ដែលគេមិនបានឲ្យ លុះទម្លាយរាងកាយខាងមុខអំពីមរណៈទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុតែកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ធម្មជាតនេះ ឈ្មោះថាសំយោជនៈ ធម្ម-ជាតនេះឈ្មោះថានីវរណៈ គឺការកាន់យកទ្រព្យ ដែលគេមិនបានឲ្យហ្នឹងឯង មួយយ៉ាងទៀត អាសវៈទាំងឡាយណា មានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយគប្បីកើតឡើង ព្រោះហេតុកាន់យកទ្រព្យ ដែលគេមិនបានឲ្យ អាសវៈដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយទាំងនោះ

វិឃាតបរិឡាហា ន ហោន្តិ ទិន្នាទានំ និស្សាយ អទិន្នាទានំ បហាតព្វន្តិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[៤១] សច្ចំ វាចំ និស្សាយ មុសាវាទោ បហា-តព្វោតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ឥធ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យេ-សំ ខោ អហំ សញ្ញោជនានំ ហេតុ មុសាវាទី អស្សំ តេសាហំ សញ្ញោជនានំ បហានាយ សមុច្ឆេទាយ បដិបន្នោ អហញ្ចេវ ខោ បន មុសាវាទី អស្សំ អត្តាបិ មំ ឧបវទេយ្យ មុសាវាទបច្ចយា អនុវិច្ច វិញ្ញូ គរហេយ្យុំ មុសាវាទបច្ចយា កាយស្ស ភេទា បរម្មរណា ទុគ្គតិ ចាដិកង្ខា មុសាវាទបច្ចយា

មិនមានដល់បុគ្គលនោះ ដែលវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យយ៉ាងនេះ ពាក្យណាដែលតថាគត ពោលហើយថា បុគ្គលគួរអាស្រ័យការកាន់យកតែទ្រព្យដែលគេឲ្យ ទើបលះបង់ការកាន់យកទ្រព្យដែលគេមិនបានឲ្យចេញដូច្នេះ ពាក្យនេះតថាគត បានពោលហើយព្រោះអាស្រ័យហេតុនុ៎ះឯង ។

[៤១] ត្រង់ពាក្យថា បុគ្គលគួរអាស្រ័យពាក្យពិត ទើបលះបង់ការកុហកចេញដូច្នេះនេះ តថាគតបានពោលហើយ ដោយប្រការដូច្នេះក៏ពាក្យនេះឯង ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ តែងពិចារណាដូច្នេះថា អាត្មាអញពោលពាក្យកុហក ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មាអញបានប្រតិបត្តិ ដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈ ទាំងនោះចេញហើយ មួយវិញទៀត បើអាត្មាអញ ជាអ្នកពោលពាក្យកុហកហើយសូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុពោលពាក្យកុហកទាំងអ្នកប្រាជ្ញ ដែលបានពិចារណារឿយ ៗ ហើយ ក៏គប្បីតិះដៀលបានព្រោះហេតុពោលពាក្យកុហក លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុពោលពាក្យកុហក

ឯតទេវ ខោ បន សញ្ញោជនំ ឯតំ នីវរណំ យទិទំ មុសាវាទោ យេ ច មុសាវាទប្បច្ចយា ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា មុសាវាទា បដិវិរតស្ស ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ សច្ចំ វាចំ និស្សាយ មុសាវាទោ បហាតព្វោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[៤២] អបិសុណំ វាចំ និស្សាយ បិសុណា វាចា បហាតព្វាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ឥធ គហបតិ អរិយសាវកោ ឥតិ បដិ-សញ្ចិក្ខតិ យេសំ ខោ អហំ សញ្ញោជនានំ ហេតុ បិសុណាវាចោ អស្សំ តេសាហំ សញ្ញោជនានំ បហានាយ សមុច្ឆេទាយ បដិបន្នោ អហញ្ចេវ ខោ បន បិសុណាវាចោ អស្សំ អត្តាបិ មំ ឧបវទេយ្យ

ធម្មជាតនុ៎ះហៅថា សំយោជនៈ ធម្មជាតនុ៎ះ ហៅថា នីវរណៈ គឺពាក្យកុហកហ្នឹងឯង មួយយ៉ាងទៀត អាសវៈទាំងឡាយណា មានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុពោលពាក្យកុហក អាសវៈដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះមិនមាន ដល់បុគ្គលនោះ ដែលវៀរចាកពាក្យកុហកយ៉ាងនេះ ពាក្យណា ដែលតថាគត ពោលហើយថា បុគ្គលព្រោះអាស្រ័យពាក្យពិតទើបលះបង់ការពោលពាក្យកុហកចេញ ដូច្នេះ ពាក្យនេះតថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[៤២] ត្រង់ពាក្យថា ព្រោះអាស្រ័យពាក្យមិនញុះញង់ ទើបលះបង់ពាក្យញុះញង់ចេញដូច្នេះនេះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ ក៏ពាក្យនេះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ តែងពិចារណាដូច្នេះថា អាត្មាអញ ជាអ្នកមានពាក្យញុះញង់ ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មាអញ បានប្រតិបត្តិ ដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈទាំងនោះចេញហើយ មួយយ៉ាងទៀត បើអាត្មាអញ និយាយពាក្យញុះញង់ហើយ សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះ

បិសុណាវាចប្បច្ចយា អនុវិច្ច វិញ្ញូ គរហេយ្យុំ បិសុណា-
វាចប្បច្ចយា កាយស្ស ភេទា បរម្មរណា ទុគ្គតិ
បាដិកង្ខា បិសុណាវាចប្បច្ចយា ឯតទេវ ខោ បន
សញ្ញោជនំ ឯតំ នីវរណំ យទិទំ បិសុណាវាចា យេ
ច បិសុណាវាចប្បច្ចយា ឧប្បជ្ជេយ្យុំ អាសវា វិឃាត-
បរិឡាហា បិសុណាយ វាចាយ បដិវិរតស្ស ឯវំស
តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ អបិសុណំ
វាចំ និស្សាយ បិសុណា វាចា បហាតព្វាតិ ឥតិ
យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[៤៣] អគិទ្ធិលោភំ និស្សាយ គិទ្ធិលោភោ
បហាតព្វោតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ
បដិច្ច វុត្តំ ឥធ គហបតិ អរិយសាវកោ

ហេតុពាក្យញុះញង់ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយ ៗ ហើយ ក៏គប្បីតិះដៀលបាន ព្រោះហេតុពាក្យញុះញង់ លុះទម្លាយរាងកាយខាងមុខបន្ទាប់ អំពីមរណៈទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុពាក្យញុះ-ញង់ ធម្មជាតនុ៎ះហៅថា សំយោជនៈ ធម្មជាតនុ៎ះហៅថា នីវរណៈ គឺពាក្យញុះញង់ហ្នឹងឯង មួយយ៉ាងទៀត អាសវៈទាំងឡាយណា មានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុពាក្យញុះញង់ អាសវៈដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះ មិនមាន ដល់បុគ្គលនោះ ដែលវៀរចាកពាក្យញុះញង់យ៉ាងនេះ ពាក្យណាដែលតថាគតពោលហើយថា ព្រោះអាស្រ័យពាក្យមិនញុះញង់ ទើបលះបង់ពាក្យញុះញង់ចេញដូច្នេះ ពាក្យនេះតថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនោះឯង ។

[៤៣] ត្រង់ពាក្យថា ព្រោះអាស្រ័យសេចក្តីមិនលោភលន់ ទើបលះបង់សេចក្តីលោភលន់ចេញដូច្នេះនេះ តថាគតបានពោលហើយដោយប្រការដូច្នេះ ក៏ពាក្យនេះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ រមែង

៦៦



ឥតិ បដិសញ្ចិក្ខតិ យេសំ ខោ អហំ សញ្ញោជនានំ
ហេតុ គិទ្ធិលោភី អស្សំ តេសាហំ សញ្ញោជនានំ
បហានាយ សមុច្ឆេទាយ បដិបន្នោ អហញ្ចេវ ខោ
បន គិទ្ធិលោភី អស្សំ អត្តាបិ មំ ឧបវទេយ្យ គិទ្ធិ-
លោភប្បច្ចយា អនុវិច្ច វិញ្ញូ គរហេយ្យុំ គិទ្ធិលោ-
ភប្បច្ចយា កាយស្ស ភេទា បរម្មរណា ទុគ្គតិ
បាដិកង្ខា គិទ្ធិលោភប្បច្ចយា ឯតទេវ ខោ បន
សញ្ញោជនំ ឯតំ នីវរណំ យទិទំ គិទ្ធិលោភោ យេ
ច គិទ្ធិលោភប្បច្ចយា ឧប្បជ្ជេយ្យុំ អាសវា វិឃាត-
បរិឡាហា អគិទ្ធិលោភិស្ស ឯវំស តេ អាសវា
វិឃាតបរិឡាហា ន ហោន្តិ អគិទ្ធិលោភំ និស្សាយ
គិទ្ធិលោភោ បហាតព្វោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ
បដិច្ច វុត្តំ ។

ពិចារណាដូច្នេះថា អាត្មាអញ ជាអ្នកមានសេចក្តីលោភលន់ ព្រោះសំយោជនៈទាំងឡាយណា អាត្មាអញ បានប្រតិបត្តិ ដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈនោះចេញហើយ មួយយ៉ាងទៀត បើអាត្មាអញ ជាអ្នកមានសេចក្តីលោភលន់ហើយ សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុសេចក្តីលោភលន់ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយ ៗ ហើយ ក៏គប្បីតិះដៀលបាន ព្រោះហេតុសេចក្តីលោភលន់ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុសេចក្តីលោភលន់ ធម្មជាតនុ៎ះហៅថា សំយោជនៈ ធម្មជាតនុ៎ះហៅថា នីវរណៈ គឺសេចក្តីលោភលន់ហ្នឹងឯង មួយយ៉ាងទៀត អាសវៈទាំងឡាយណា ដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុសេចក្តីលោភលន់ អាសវៈដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលមិនមានសេចក្តីលោភលន់បានយ៉ាងនេះ ពាក្យណា ដែលតថាគតពោលហើយថា ព្រោះអាស្រ័យសេចក្តីមិនលោភលន់ ទើបលះសេចក្តីលោភលន់ចេញដូច្នេះ ពាក្យនេះតថាគត បានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

គហបតិវគ្គស្ស បោតលិយសុត្តេ ឆដ្ឋធម្មោ

[៤៤] អនិដ្ឋាពេសំ និស្សាយ និដ្ឋាពេសោ
បហាតព្វោតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច
វុត្តំ ឥធ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិ-
ក្ខតិ យេសំ ខោ អហំ សញ្ញោជនានំ ហេតុ
និដ្ឋាពេសី អស្សំ តេសាហំ សញ្ញោជនានំ បហា-
នាយ សមុច្ឆេទាយ បដិបន្នោ អហាញ្ចេវ ខោ បន
និដ្ឋាពេសី អស្សំ អត្តាបិ មំ ឧបវទេយ្យ និដ្ឋាពេ-
សប្បច្ចយា អនុវិច្ច វិញ្ញូ គរហេយ្យុំ និដ្ឋាពេសប្បច្ចយា
កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា និដ្ឋា-
ពេសប្បច្ចយា ឯតទេវ ខោ បន សញ្ញោជនំ ឯតំ
នីវរណំ យទិទំ និដ្ឋាពេសោ យេ ច និដ្ឋាពេសប្បច្ច-
យា ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា អនិដ្ឋាពេ-
សិស្ស ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ

គហបតិវគ្គ បោតលិយសូត្រ ធម៌ ទី ៦

[៤៤] ត្រង់ពាក្យថា ព្រោះអាស្រ័យសេចក្តីមិនគ្នាន់ក្នាញ់ គឺមិននិន្ទា ទើបលះបង់សេចក្តីគ្នាន់ក្នាញ់ គឺនិន្ទាចេញដូច្នេះនេះ តថាគតបានពោលហើយដោយប្រការដូច្នេះ ក៏ពាក្យនេះដែលតថាគតពោលហើយព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ រមែងពិចារណាដូច្នេះថា អាត្មាអញ ជាអ្នកមានសេចក្តីគ្នាន់ក្នាញ់គឺនិន្ទា ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មាអញ បានប្រតិបត្តិដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈទាំងនោះចេញហើយ មួយយ៉ាងទៀត បើអាត្មាអញ ជាអ្នកមានសេចក្តីគ្នាន់ក្នាញ់គឺនិន្ទាហើយ សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុសេចក្តីគ្នាន់ក្នាញ់គឺនិន្ទា ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយ ៗ ហើយ ក៏គប្បីតិះដៀលបាន ព្រោះហេតុសេចក្តីគ្នាន់ក្នាញ់គឺនិន្ទា លុះទម្លាយរាងកាយខាងមុខ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុសេចក្តីគ្នាន់ក្នាញ់គឺនិន្ទា ធម្មជាតនុ៎ះហៅថាសំយោជនៈ ធម្មជាតនុ៎ះហៅថានីវរណៈ គឺសេចក្តីគ្នាន់ក្នាញ់គឺនិន្ទាហ្នឹងឯង មួយយ៉ាងទៀត អាសវៈទាំងឡាយណា ដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុសេចក្តីគ្នាន់ក្នាញ់គឺនិន្ទា អាសវៈដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តី

អនិន្ទារោសំ និស្សាយ និន្ទារោសោ បហាតព្វោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[៤៩] អក្កោធុបាយាសំ និស្សាយ កោធុបាយាសោ បហាតព្វោតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ឥធ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យេសំ ខោ អហំ សញ្ញោជនានំ ហេតុ កោធុបាយាសី អស្សំ តេសាហំ សញ្ញោជនានំ បហានាយ សមុច្ឆេទាយ បដិបន្នោ អហញ្ចេវ ខោ បន កោធុបាយាសី អស្សំ អត្តាបិ មំ ឧបវទេយ្យ កោធុបាយាសបច្ចយា អនុវិច្ច វិញ្ញូ គរហេយ្យុំ កោធុបាយាសបច្ចយា កាយស្ស ភេទា បរម្ម-

គ្នាន់ក្នាញ់ គឺមិននិន្ទាយ៉ាងនេះ ពាក្យណា ដែលតថាគតពោលហើយថា ព្រោះអាស្រ័យសេចក្តីគ្នាន់ក្នាញ់ គឺមិននិន្ទា ទើបលះបង់សេចក្តីគ្នាន់ក្នាញ់ គឺនិន្ទាចេញដូច្នេះ ពាក្យនេះតថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[៤៥] ត្រង់ពាក្យថា ព្រោះអាស្រ័យសេចក្តីមិនចង្អៀតចង្អល់ គឺមិនក្រោធ ទើបលះបង់សេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធចេញ ដូច្នេះនេះ តថាគតពោលហើយ ដោយប្រការដូច្នេះ ក៏ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ រមែងពិចារណាដូច្នេះថា អាត្មាអញ ជាអ្នកមានសេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធ ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មាអញបានប្រតិបត្តិ ដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈទាំងនោះចេញហើយ មួយយ៉ាងទៀត បើអាត្មាអញ ជាអ្នកមានសេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធហើយ សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះសេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយ ៗ ហើយ ក៏គប្បីតិះដៀលបាន ព្រោះសេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធ លុះទម្លាយរាងកាយ ខាងមុខ

វណា ទុក្កតិ ចាជិកង្ខា កោធុបាយាសប្បច្ចយា ឯតទេវ ខោ បន សញ្ញោជនំ ឯតំ នីវរណំ យទិទំ កោធុបាយាសោ យេ ច កោធុបាយាសប្បច្ចយា ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា អកោធុបា-យាសិស្ស ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ អកោធុបាយាសំ និស្សាយ កោធុបាយាសោ បហាតព្វោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[៤៦] អនតិមានំ និស្សាយ អតិមានោ បហា-តព្វោតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ឥធ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ

គហបតិវគ្គ  បោតលិយសូត្រ  ទី  ៨

បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុសេចក្ដីចង្អៀតចង្អល់ គឺសេចក្ដីក្រោធ ធម្មជាតនុ៎ះហៅថា សំយោជនៈ ធម្មជាតនុ៎ះហៅថា នីវរណៈ គឺសេចក្ដីចង្អៀតចង្អល់ គឺសេចក្ដីក្រោធហ្នឹងឯងមួយយ៉ាងទៀត អាសវៈទាំងឡាយណា ដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុសេចក្ដីចង្អៀតចង្អល់ គឺសេចក្ដីក្រោធ អាសវៈដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលជាអ្នកមិនមានសេចក្ដីចង្អៀតចង្អល់ គឺសេចក្ដីក្រោធយ៉ាងនេះ ពាក្យណាដែលតថាគតពោលហើយថា ព្រោះអាស្រ័យសេចក្ដីចង្អៀតចង្អល់ គឺសេចក្ដីមិនក្រោធ ហើយលះបង់សេចក្ដីចង្អៀតចង្អល់ គឺសេចក្ដីក្រោធចេញដូច្នេះ ពាក្យនេះតថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[៤៦] ត្រង់ពាក្យថា ព្រោះអាស្រ័យសេចក្ដីមិនមើលងាយគេទើបលះបង់សេចក្ដីមើលងាយដូច្នេះនេះ តថាគតបានពោលហើយដោយប្រការដូច្នេះ ក៏ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ រមែងពិចារណា

យេសំ ខោ អហំ សញ្ញោជនានំ ហេតុ អតិមានី អស្សំ តេសាហំ សញ្ញោជនានំ បហានាយ សមុច្ឆេ-ទាយ បដិបន្នោ អហញ្ចេវ ខោ បន អតិមានី អស្សំ អត្តាបិ មំ ឧបវទេយ្យ អតិមានប្បច្ចយា អនុវិច្ច វិញ្ញូ គរហេយ្យុំ អតិមានប្បច្ចយា កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា អតិមានប្បច្ចយា ឯតេវ ខោ បន សញ្ញោជនំ ឯតំ នីវរណំ យទិទំ អតិមានោ យេ ច អតិមានប្បច្ចយា ឧប្បជ្ជេយ្យុំ អាសវា វិឃា-តបរិឡាហា អនតិមានិស្ស ឯវំស តេ អាសវា វិឃា-តបរិឡាហា ន ហោន្តិ អនតិមានំ និស្សាយ អតិមា-នោ បហាតព្វោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥមេ ខោ គហបតិ អដ្ឋ ធម្មា

ដូច្នេះថា អាត្មាអញ ជាអ្នកមានសេចក្តីមើលងាយគេ ព្រោះហេតុសំយោ-ជនៈទាំងឡាយណា អាត្មាអញបានប្រតិបត្តិ ដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈទាំងនោះចេញហើយ មួយយ៉ាងទៀត បើអាត្មាអញជាអ្នកមានសេចក្តីមើលងាយគេហើយ សូម្បីខ្លួនឯងក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុសេចក្តីមើលងាយ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយ ៗ ហើយ គប្បីតិះដៀលបាន ព្រោះហេតុសេចក្តីមើលងាយគេ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដព្រោះហេតុសេចក្តីមើលងាយ ធម្មជាតនុ៎ះហៅថា សំយោជនៈ ធម្មជាតនុ៎ះហៅថា នីវរណៈ គឺសេចក្តីមើលងាយហ្នឹងឯង មួយយ៉ាងទៀត អាសវៈទាំងឡាយណា ដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុសេចក្តីមើលងាយគេ អាសវៈដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីមើលងាយ យ៉ាងនេះ ពាក្យណា ដែលតថាគតពោលហើយថា ព្រោះអាស្រ័យសេចក្តីមិនមើលងាយគេ ទើបលះបង់សេចក្តីមើលងាយគេចេញដូច្នេះ ពាក្យនេះតថាគត បានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។ ម្នាលគហបតី ធម៌ទាំង ៨

គហបតិវគ្គស្ស បោតលិយសុត្តេ អដ្ឋិកង្កលូបមា

សង្ខិត្តេន វុត្តា វិត្ថារេន អវិភត្តា យេ អរិយស្ស វិនយេ បហានាយ វោហារសមុច្ឆេទាយ សំវត្តន្តិ ន តេ៎វ តាវ គហបតិ អរិយស្ស វិនយេ សព្វេន សព្វំ សព្វថា សព្វំ វោហារស្ស សមុច្ឆេទោ ហោតីតិ ។ យថាកថំ បន ភន្តេ អរិយស្ស វិនយេ សព្វេន សព្វំ សព្វថា សព្វំ វោហារសមុច្ឆេទោ ហោតិ សាធុ មេ ភន្តេ ភគវា តថា ធម្មំ ទេសេតុ យថា អរិយស្ស វិនយេ សព្វេន សព្វំ សព្វថា សព្វំ វោហារស្ស សមុច្ឆេទោ ហោតីតិ ។ តេនហិ គហ-បតិ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សា-មីតិ ។ ឯវំ ភន្តេតិ ខោ បោតលិយោ គហបតិ ភគវតោ បច្ចស្សោសិ ។

[៤៧] ភគវា ឯតទវោច សេយ្យថាបិ គហបតិ កុក្កុរោ ជិឃច្ឆាទុព្វល្យបរេតោ គោឃាតកសូនំ បច្ចុបដ្ឋិតោ អស្ស តមេនំ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា អដ្ឋិកង្កលំ សុនិក្កន្តំ និក្កន្តំ និម្មំសំ លោហិតមក្ខិតំ ឧបច្ឆុភេយ្យ[១]

១ ឧបច្ឆុភេយ្យាតិបិ ឧបច្ឆុម្ភេយ្យាតិបិ ឧបត្ថម្ភេយ្យាតិបិ បាឋោ ទិស្សតិ ។ ឧបច្ឆុម្ភេយ្យាតិ ឥទដ្ឋកថា ។

ណា តែងប្រព្រឹត្តទៅ ដើម្បីលះបង់ ដើម្បីផ្តាច់បង់ជំនួញ ក្នុងអរិយវិន័យ ធម៌ទាំង ៨ នេះឯង តថាគតពោលហើយ ដោយបំប្រួញ មិនបានចែក ដោយពិស្តារទេ ម្នាលគហបតី ការផ្តាច់បង់ជំនួញ សព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យ មិនមានត្រឹមប៉ុណ្ណោះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការផ្តាច់បង់ជំនួញ សព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យនោះ តើដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ការផ្តាច់បង់ជំនួញ សព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យ យ៉ាងណា សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌យ៉ាងនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ។ ម្នាលគហបតី បើដូច្នោះ អ្នកចូរស្តាប់ ចូរយកចិត្តទុកដាក់ដោយប្រពៃចុះ តថាគតនឹងសំដែងឲ្យស្តាប់ ។ បោតលិយគហបតី ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[៤៧] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី ដូចសុនខដែលអស់កម្លាំង ព្រោះសេចក្តីឃ្លានគ្របសង្កត់ ក៏ដើរចូលទៅកាន់ទីសម្រាប់អារសាច់លក់ របស់គោឃាតកៈ ឯគោឃាតកៈក្តី កូនឈ្នួលរបស់គោឃាតកៈក្តី ដែលឈ្លាស យករាងឆ្អឹងដែលពន្ធះសាច់ចេញស្អាត ឥតមានសាច់ គ្រាន់តែប្រឡាក់ដោយឈាម បោះទៅឲ្យឆ្កែនោះ

តំ កឹ មញ្ញសិ គហបតិ អបិ នុ សោ កុក្កុរោ អមុំ អដ្ឋិកង្កលំ សុនិកន្តំ និកន្តំ និម្មំសំ លោហិតមក្ខិតំ បលេហន្តោ[១] ជិឃច្ឆាទុព្វល្យំ បដិវិនេយ្យាតិ ។ នោ ហេតំ ភន្តេ តំ កិស្ស ហេតុ អទុំ ហិ ភន្តេ អដ្ឋិកង្កលំ សុនិកន្តំ និកន្តំ និម្មំសំ លោហិតមក្ខិតំ យាវទេវ ច បន សោ កុក្កុរោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ អដ្ឋិកង្កលូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា យាយំ ឧបេក្ខា នានត្តា នានត្តសិតា តំ អភិនិវជ្ជេត្វា យាយំ ឧបេក្ខា ឯកត្តា ឯកត្តសិតា យត្ថ សព្វសោ លោកាមិសុបាទានា អបរិសេសា និរុជ្ឈន្តិ តមេវ ឧបេក្ខំ ភាវេតិ ។

១ ឱ. បលិខាទន្តោ ។

ម្នាលគហបតី អ្នកសំគាល់សេចក្ដីនោះថាដូចម្ដេច ឆ្កែនោះកាលអង្អៀម នូវរាងឆ្អឹងឯណោះ ដែលគេពន្លះសាច់ស្អាត ឥតមានសាច់ គ្រាន់តែប្រឡាក់ដោយឈាម នឹងបន្ទោបង់សេចក្ដីអស់កម្លាំង ព្រោះការឃ្លានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ការបន្ទោបង់សេចក្ដីអស់កម្លាំង ព្រោះការឃ្លាននុ៎ះមិនបានទេ ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថារាងឆ្អឹងឯណោះ ដែលគេពន្លះសាច់ចេញស្អាត ឥតមានសាច់ គ្រាន់តែប្រឡាក់ដោយឈាម ឯសុនខនោះ ជាសត្វគ្រាន់តែមានចំណែក នៃសេចក្ដីលំបាកកាយ លំបាកចិត្ត ប៉ុណ្ណោះឯង ។ ម្នាលគហបតី អរិយសាវ័ក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សំដែងហើយថា កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយសាវ័ក ឃើញសេចក្ដីនេះ តាមពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ ក៏លះបង់ឧបេក្ខា (ក្នុងបញ្ចកាមគុណ) ដែលមានសភាពផ្សេងគ្នា អាស្រ័យអារម្មណ៍ មានសភាពផ្សេងគ្នា ហើយចម្រើនឧបេក្ខា[១] ដែលមានសភាពតែមួយ អាស្រ័យអារម្មណ៍មានសភាពតែមួយ នឹងឧបេក្ខា[២] ជាទីរលត់នៃឧបាទានជាលោកាមិសៈ មិនមានសេសសល់ ដោយប្រការទាំងពួង ។

១-២ បានដល់ឧបេក្ខាក្នុងចតុត្ថជ្ឈាន ។

គហបតិវគ្គស្ស បោតលិយសុត្តេ មំសបេសូបមា

[៤៨] សេយ្យថាបិ គហបតិ គិជ្ឈោ វា កង្ខោ វា(១) កុលលោ វា មំសបេសិមាទាយ(២) ឧឌ្ឌយេយ្យ(៣) តមេនំ គិជ្ឈាបិ កង្ខាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតច្ឆេយ្យុំ វិភជេយ្យុំ តំ កឹ មញ្ញសិ គហបតិ សចេ សោ គិជ្ឈោ វា កង្ខោ វា កុ-លលោ វា តំ មំសបេសឹ ន ខិប្បមេវ បដិនិស្ស-ជ្ជេយ្យ សោ តតោនិទានំ មរណំ វា និគ្គច្ឆេយ្យ(៤) មរណមត្តំ វា ទុក្ខន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិ-ក្ខតិ មំសបេសូបមា កាមា វុត្តា ភគវតា ពហុ-ទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា យាយំ ឧបេក្ខា នានត្តា នានត្តសិតា តំ អភិនិវជ្ជេត្វា យាយំ ឧបេក្ខា ឯកត្តា ឯកត្តសិតា យត្ថ សព្វសោ លោកាមិសុបាទានា អបរិសេសា និរុជ្ឈន្តិ តមេវ ឧបេក្ខំ ភាវេតិ ។

---

១ ឱ. ម. កង្កោ វា ។ ២ ឱ. ម. មំសបេសឹ អាទាយ ។ ៣ ម. ឧឌ្ឌិយេយ្យ ។ ៤ ឱ. ម. និគច្ឆេយ្យ ។

គហបតិវគ្គ បោតលិយសូត្រ សេចក្តីឧបមាដោយដុំសាច់

[៤៨] ម្នាលគហបតី ដូចជាសត្វត្មាត ខ្លែងក្រហម ឬខ្លែងខ្មៅ ពាំនាំដុំសាច់ហើរទៅ មានពួកត្មាតខ្លះ ពួកខ្លែងក្រហមខ្លះ ពួកខ្លែងខ្មៅខ្លះ នាំគ្នាហើរដេញតាមសត្វត្មាតជាដើមនោះ ចឹកជញ្ជែងដណ្តើមយក ម្នាលគហបតី អ្នកសំគាល់សេចក្តីនោះថាដូចម្តេច បើសត្វត្មាត ខ្លែងក្រហមឬខ្លែងខ្មៅនោះ មិនលះចោលដុំសាច់នោះ ដោយឆាប់ទេ ក៏ត្មាតជាដើមនោះ នឹងដល់សេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ព្រោះដុំសាច់នោះជាហេតុ មែនឬទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលគហបតី អរិយសាវ័ក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុំសាច់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយសាវ័ក ឃើញសេចក្តីនេះ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ ក៏លះបង់នូវឧបេក្ខា ដែលមានសភាពផ្សេងគ្នា អាស្រ័យអារម្មណ៍មានសភាពផ្សេងគ្នា ចម្រើនឧបេក្ខា ដែលមានសភាពតែមួយ អាស្រ័យអារម្មណ៍ មានសភាពតែមួយ នឹងឧបេក្ខាជាទីរលត់ នៃឧបាទានជាលោកាមិសៈ មិនមានសេសសល់ ដោយប្រការទាំងពួង ។

[៤៩] សេយ្យថាបិ គហបតិ បុរិសោ អាទិត្តំ តិណុក្កំ អាទាយ បដិវាតំ គច្ឆេយ្យ តំ កឹ មញ្ញសិ គហបតិ សចេ សោ បុរិសោ តំ អាទិត្តំ តិណុក្កំ ន ខិប្បមេវ បដិនិស្សជ្ជេយ្យ តស្ស សា អាទិត្តា តិណុក្កា ហត្ថំ វា ឌហេយ្យ(១) ពាហុំ វា ឌហេយ្យ អញ្ញតរំ វា អញ្ញតរំ វា អង្គប្បច្ចង្គំ វា(២) ឌហេយ្យ សោ តតោនិទានំ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ តិណុក្កូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវមេតំ យថាភូតំ សម្ម-ប្បញ្ញាយ ទិស្វា ។ បេ ។ តមេវ ឧបេក្ខំ ភាវេតិ ។

[៥០] សេយ្យថាបិ គហបតិ អង្គារកាសុសាធិក-បោរិសា បូរា អង្គារានំ វីតច្ចិកានំ វីតធូមានំ អថ បុរិសោ អាគច្ឆេយ្យ ជីវិតុកាមោ អមរិតុកាមោ សុខ-កាមោ ទុក្ខប្បដិក្កូលោ តមេនំ ទ្វេ ពលវន្តោ បុរិសា នានាពាហាសុ គហេត្វា អង្គារកាសុំ ឧបកឌ្ឍេយ្យុំ

១ ឱ. ម. ទហេយ្យ ។ ២ ឱ. អញ្ញតរំ វា អង្គប្បច្ចង្គំ ។

[៤៩] ម្នាលគហបតី ដូចជាបុរសកាន់គប់ស្មៅ ដែលភ្លើងឆេះដើរច្រាសខ្យល់ ម្នាលគហបតី អ្នកសំគាល់សេចក្តីនោះថាដូចម្តេច បើបុរសនោះ មិនលះចោលគប់ស្មៅ ដែលភ្លើងឆេះនោះ ដោយឆាប់ទេ គប់ស្មៅដែលភ្លើងឆេះនោះ នឹងពោលពាលដៃឬកំភួនដៃ ឬពោលពាលអវយវៈតូចធំនីមួយ បុរសនោះនឹងដល់សេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះគប់ស្មៅដែលភ្លើងឆេះនោះជាហេតុមែនឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតី អរិយសាវ័ក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ស្មៅ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយសាវ័កឃើញសេចក្តីនេះ តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះ ។ បេ ។ ក៏ចម្រើនឧបេក្ខានោះឯង ។

[៥០] ម្នាលគហបតី ដូចជារណ្តៅរងើកភ្លើង មានជម្រៅមួយជំហរបុរស ដ៏ពេញដោយរងើកភ្លើង ឥតមានអណ្តាត ឥតមានផ្សែង កាលនោះ មានបុរសម្នាក់មានប្រាថ្នាដើម្បីរស់នៅ មិនប្រាថ្នាដើម្បីស្លាប់ ប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ ដើរមក (កាន់រណ្តៅនោះ) មានបុរសខ្លាំងពូកែពីរនាក់ចាប់បុរសនោះ ត្រង់កំភួនដៃម្ខាងម្នាក់ ទាញទម្លាក់

តំ កឹ មញ្ញសិ គហបតិ អបិ នុ សោ បុរិសោ ឥតិ ចីតិ ចេវ កាយំ សន្ធាមេយ្យាតិ(១) ។ នោ ហេតំ ភន្តេ(២) តំ កិស្ស ហេតុ វិទិតំ ហិ ភន្តេ តស្ស បុរិសស្ស ឥមញ្ច(៣) អហំ អង្គារកាសុំ បបតិស្សាមិ តតោនិទានំ មរណំ វា និគ្គច្ឆិស្សាមិ(៤) មរណមត្តំ វា ទុក្ខន្តិ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ អង្គារកាសូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា អាទី-នវោ ឯត្ថ ភិយ្យោតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា ។ បេ ។ តមេវ ឧបេក្ខំ ភាវេតិ ។

[៤១] សេយ្យថាបិ គហបតិ បុរិសោ សុបិនកំ បស្សេយ្យ អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណិរាមណេយ្យកំ សោ បដិពុទ្ធោ ន កិញ្ចិ បស្សេយ្យ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ សុបិនកូបមា កាមា វុត្តា ភគវតា ពហុទុក្ខា

១ ម. បនាមេយ្យាតិ ។ ២ ឱ. ម. ឯវំ ភន្តេ ។ ៣ ឱ. ឥមញ្ចេ ។ ៤ ឱ. និគច្ឆាមិ ។

ទៅក្នុងរណ្តៅ  ម្នាលគហបតី  អ្នកសំគាល់សេចក្តីនោះ  ថាដូចម្តេច តើបុរសនោះគួរបង្អោនកាយ (ទៅកាន់រណ្តៅ) នោះដូច្នេះខ្លះ ដូច្នោះខ្លះ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះ មិនគួរបង្អោនកាយ ទៅឡើយ ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះ បុរសនោះដឹងច្បាស់ថា បើអាត្មាអញ នឹងធ្លាក់រណ្តៅរងើកភ្លើងនេះ អាត្មា អញ នឹងដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតស្លាប់ ព្រោះរណ្តៅរងើក ភ្លើងនោះជាហេតុ ។ ម្នាលគហបតី អរិយសាវ័ក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា កាមទាំងឡាយមានឧបមាដោយ រណ្តៅរងើកភ្លើង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោស មានច្រើនប្រការ ក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយសាវ័កឃើញ សេចក្តីនេះតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ ។ បេ ។ ក៏ចម្រើន ឧបេក្ខានោះឯង ។

[៤១] ម្នាលគហបតី ដូចជាបុរស យល់សប្តិឃើញអារាមជាទី សប្បាយ ព្រៃជាទីសប្បាយ ផែនដីជាទីសប្បាយ និងស្រះបោក្ខរណី ជាទីសប្បាយ លុះបុរសនោះ ភ្ញាក់ឡើង មិនឃើញអ្វីមួយឡើយ ម្នាល គហបតី អរិយសាវ័ក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំ-ដែងហើយថា កាមទាំងឡាយមានឧបមាដោយយល់សប្តិ មានទុក្ខច្រើន

ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ។ បេ ។ តមេវ ឧបេក្ខំ ភាវេតិ ។

[៤២] សេយ្យថាបិ គហបតិ បុរិសោ យាចិតកំ ភោគំ យាចិត្វា យានំ ឱរោបេយ្យ[១] បវរមណិ-កុណ្ឌលំ សោ តេហិ យាចិតកេហិ ភោគេហិ បុរក្ខតោ បរិវុតោ អន្តរាបណំ បដិបជ្ជេយ្យ តមេនំ ជនោ ទិស្វា ឯវំ វទេយ្យ ភោគី វត ភោ បុរិសោ ឯវំ កិរ ភោគិនោ ភោគានិ ភុញ្ជន្តីតិ តមេនំ សាមិកា យត្ថ យត្ថេវ បស្សេយ្យុំ តត្ថ តត្ថេវ សាមិកា[២] សានិ ហរេយ្យុំ តំ កឹ មញ្ញសិ គហបតិ អលំ នុ ខោ តស្ស បុរិសស្ស អញ្ញថត្តាយាតិ ។ នោ ហេតំ ភន្តេ[៣] តំ កិស្ស ហេតុ សាមិនោ ហិ ភន្តេ សានិ ហរន្តីតិ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ

១ ឱ. យានំ បោរោសេយ្យំ ។ ម. យានំ វា បោរោសេយ្យំ ។ ២ ឱ. សាមិកាតិ ន ទិស្សតិ ។ ៣ ឱ. ម. ឯវំ ភន្តេ ។

មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការ ក្នុងកាមទាំងនេះ យ៉ាងនេះឯង ។ បេ ។ ក៏ចម្រើនឧបេក្ខានោះឯង ។

[៩២] ម្នាលគហបតី ដូចជាបុរស ខ្ចីទ្រព្យគេជារបស់បណ្តោះអាសន្ន គឺកែវមណីនិងកុណ្ឌល (គ្រឿងប្រដាប់ត្រចៀក) ដ៏ប្រសើរ ហើយឡើងកាន់យាន បុរសនោះបានប្រដាប់តាក់តែង ដោយទ្រព្យជារបស់ខ្ចីគេបណ្តោះអាសន្នទាំងនោះ ដើរទៅកាន់រានផ្សារ អ្នកផងបានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា អើហ្ន៎ បុរសនេះ មានភោគសម្បត្តិច្រើនណាស់ បានឮថាពួកជនអ្នកមានភោគសម្បត្តិ រមែងបរិភោគសម្បត្តិយ៉ាងហ្នឹងតើ បើពួកជនជាម្ចាស់គប្បីឃើញបុរសនោះក្នុងទីណា ៗ ក៏គប្បីយកទ្រព្យ ដែលជារបស់ខ្លួនក្នុងទីនោះទៅ ម្នាលគហបតី អ្នកសំគាល់សេចក្តីនោះ ថាដូចម្តេច បុរសនោះគួរអោក់អន់ចិត្តឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះមិនគួរអោក់អន់ចិត្តទេ ដំណើរនោះ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះពួកជនជាម្ចាស់ទ្រព្យ នាំយកទ្រព្យ ដែលជារបស់ខ្លួនទៅ ។ ម្នាលគហបតី អរិយសាវ័កតែង

ឥតិ បដិសញ្ចិក្ខតិ យាចិតកូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូចាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ។ បេ ។ តមេវ ឧបេក្ខំ ភាវេតិ ។

[៤៣] សេយ្យថាបិ គហបតិ គាមស្ស វា និគមស្ស វា អវិទូរេ តិព្វោ វនសណ្ឌោ តត្រស្ស រុក្ខោ សម្បន្នផលោ ច ឧប្បន្នផលោ ច ន ចាស្ស កានិចិ ផលានិ ភូមិយំ បតិតានិ អថ បុរិសោ អាគច្ឆេយ្យ ផលត្ថិកោ ផលគវេសី ផលបរិយេសនំ ចរមានោ សោ តំ វនសណ្ឌំ អជ្ឈោគាហេត្វា តំ រុក្ខំ បស្សេយ្យ សម្បន្នផលញ្ច ឧប្បន្នផលញ្ច តស្ស ឯវមស្ស អយំ ខោ រុក្ខោ សម្បន្នផលោ ច ឧប្បន្នផលោ ច នត្ថិ ច កានិចិ ផលានិ ភូមិយំ បតិតានិ ជានាមិ ខោ បនាហំ រុក្ខំ អភិរុយ្ហិតុំ[១] យន្នូនាហំ ឥមំ រុក្ខំ អភិរុយ្ហិត្វា[២] យាវទត្ថញ្ច ខាទេយ្យំ ឧច្ឆង្គញ្ច បូរេយ្យន្តិ សោ តំ រុក្ខំ អភិរុយ្ហិត្វា[៣] យាវទត្ថញ្ច ខាទេយ្យ

១ ឱ. ម. អារោហិតុំ ។ ២-៣ ឱ. អារោហិត្វា ។

ពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា កាមទាំង-ឡាយ មានឧបមាដោយរបស់ខ្ចីគេ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការ ក្នុងកាមទាំងនេះ យ៉ាងនេះឯង ។ បេ ។ ក៏ចម្រើនឧបេក្ខានោះឯង ។

[៥៣] ម្នាលគហបតី ដូចជាដងព្រៃស្តុក នៅជិតស្រុកឬនិគម មានដើមឈើក្នុងព្រៃនោះ ជាឈើមានផ្លែផ្អែមផង មានផ្លែដ៏ច្រើនផង សូម្បីផ្លែណាមួយ ក៏មិនជ្រុះចុះលើផែនដីឡើយ ទើបមានបុរសម្នាក់ជាអ្នកត្រូវការដោយផ្លែ ស្វែងរកផ្លែ ត្រាច់ទៅស្វែងរកផ្លែ ក៏ដើរមកដល់ បុរសនោះ ដើរចូលទៅកាន់ដងព្រៃនោះ ឃើញដើមឈើនោះ មានផ្លែផ្អែមផង មានផ្លែច្រើនផង ទើបបុរសនោះ គិតយ៉ាងនេះថា ឈើនេះឯងមានផ្លែផ្អែមផង មានផ្លែច្រើនផង សូម្បីផ្លែណាមួយ ក៏មិនជ្រុះចុះលើផែនដីឡើយ ឯអាត្មាអញ ក៏ចេះឡើងឈើដែរ បើដូច្នោះមានតែអាត្មាអញឡើងកាន់ដើមឈើនេះ ហើយទំពាស៊ីត្រាតែឆ្អែតផង ដក់ថ្នក់ផង លុះបុរសនោះគិតហើយ ក៏ឡើងកាន់ដើមឈើនោះ ទំពាស៊ីត្រាតែឆ្អែតផង

ឧច្ឆង្គញ្ច បូរេយ្យ អថ ទុតិយោ បុរិសោ អាគច្ឆេយ្យ ផលត្ថិកោ ផលគវេសី ផលបរិយេសនំ ចរមានោ តិណ្ហំ កុធារឹ(១) អាទាយ សោ តំ វនសណ្ឌំ អជ្ឈោ-គហេត្វា តំ រុក្ខំ បស្សេយ្យ សម្បន្នផលញ្ច ឧប្បន្ន-ផលញ្ច តស្ស ឯវមស្ស អយំ រុក្ខោ សម្បន្នផលោ ច ឧប្បន្នផលោ ច នត្ថិ ច កានិចិ ផលានិ ភូមិយំ បតិតានិ ន ខោ បនាហំ ជានាមិ រុក្ខំ អភិរុយ្ហិតុំ យន្នូនាហំ ឥមំ រុក្ខំ មូលតោ ឆេត្វា យាវទត្ថញ្ច ខាទេយ្យំ ឧច្ឆង្គញ្ច បូរេយ្យន្តិ សោ តំ រុក្ខំ មូលតោ ឆិន្ទេយ្យ តំ កឹ មញ្ញសិ គហបតិ អមុកោ សោ(២) បុរិសោ បឋមំ រុក្ខំ អារុឡ្ហោ សចេ ខោ សោ ន ខិប្បមេវ ឱរោហេយ្យ តស្ស សោ រុក្ខោ បបតន្តោ ហត្ថំ វា ភញ្ជេយ្យ បាទំ វា ភញ្ជេយ្យ អញ្ញតរំ វា អង្គប្បច្ចង្គំ ភញ្ជេយ្យ សោ តតោនិទានំ មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ គហបតិ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ

១ ឱ. កុឋារឹ ។ ម. កុទារឹ ។ ២ ឱ. អសុ យោ សោ ។

ដក់ថ្នក់ផង កាលនោះមានបុរសជាគម្រប់ពីរ ជាអ្នកត្រូវការដោយផ្លៃ ស្វែង រកផ្លៃ ត្រាច់ទៅស្វែងរកផ្លៃ ក៏កាន់យកដឹងដ៏មុតដើរមកដល់ បុរសនោះ ចូលទៅកាន់ដងព្រៃនោះ ហើយឃើញដើមឈើនោះ មានផ្លៃផ្អែមផង មានផ្លៃច្រើនផង ទើបបុរសនោះ គិតយ៉ាងនេះថា ឈើនេះឯង មាន ផ្លៃផ្អែមផង មានផ្លៃច្រើនផង សូម្បីផ្លៃណាមួយ មិនជ្រុះចុះលើផែនដី ឡើយ ឯអាត្មាអញ ក៏មិនចេះឡើងដើមឈើឡើយ បើដូច្នោះមានតែអាត្មា អញ កាប់ដើមឈើនេះត្រង់គល់ ហើយទំពាស៊ីត្រាតែឆ្អែតផង ដក់ថ្នក់ផង លុះបុរសនោះគិតហើយ ក៏កាប់ដើមឈើនោះត្រង់គល់ ម្នាលគហបតី អ្នកសំគាល់សេចក្តីនោះ ថាដូម្តេច បុរសដែលឡើងដើមឈើមុនគេ នោះ បើមិនចុះមកដោយរហ័សទេ កាលដែលដើមឈើនោះរលំចុះ គប្បី បាក់ដៃ បាក់ជើង បំបាក់អវយវៈតូចធំណាមួយ របស់បុរសនោះ បុរស នោះគប្បីដល់សេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះផ្លៃឈើ នោះជាហេតុ មែនឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតី អរិយ-សាវ័កតែងពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា

វុត្តាជលូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហូ-បាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ឯវមេតំ យថា-ភូតំ សម្មប្បញ្ញាយ ទិស្វា យាយំ ឧបេក្ខា នានត្តា នានត្តសិតា តំ អភិនិវជ្ជេត្វា យាយំ ឧបេក្ខា ឯកត្តា ឯកត្តសិតា យត្ថ សព្វសោ លោកាមិសុបាទានា អបរិសេសា និរុជ្ឈន្តិ តមេវ ឧបេក្ខំ ភាវេតិ ។

[៥៤] ស ខោ សោ គហបតិ អរិយសាវកោ ឥមមេវ[១] អនុត្តរំ ឧបេក្ខាសតិបារិសុទ្ធឹ អាគម្ម អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុ-ស្សរតិ ។ ស ខោ សោ គហបតិ អរិយសាវកោ ឥមមេវ[២] អនុត្តរំ ឧបេក្ខាសតិបារិសុទ្ធឹ អាគម្ម ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧប្បជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជា-នាតិ ។ ស ខោ សោ គហបតិ អរិយសាវកោ ឥមំ-

១-២ ឱ. ម. ឥមំយេវ ។

កាមទាំងឡាយ មានឧបមាដោយផ្លែឈើ មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយសាវ័កឃើញសេចក្ដីនេះតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ ក៏លះបង់ឧបេក្ខា ដែលមានសភាពផ្សេងគ្នា អាស្រ័យអារម្មណ៍មានសភាពផ្សេងគ្នា ហើយចម្រើនឧបេក្ខា ដែលមានសភាពតែមួយ អាស្រ័យអារម្មណ៍មានសភាពតែមួយ នឹងឧបេក្ខាជាទីរលត់ទៅនៃឧបាទានជាលោកាមិស: មិនមានសេសសល់ ដោយប្រការទាំងពួង ។

[៥៤] ម្នាលគហបតី អរិយសាវ័កនោះឯង អាស្រ័យសេចក្ដីបរិសុទ្ធនៃសតិ ដែលកើតអំពីឧបេក្ខាដ៏ប្រសើរនេះឯង ហើយរលឹកនូវបុព្វេនិវាសច្រើនប្រការ គឺ រលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ ម្នាលគហបតី អរិយសាវ័កនោះឯង អាស្រ័យសេចក្ដីបរិសុទ្ធនៃសតិ ដែលកើតអពីឧបេក្ខាដ៏ប្រសើរនេះឯង ហើយឃើញពួកសត្វដែលច្យុត កើតឡើង ជាសត្វថោកទាប ឧត្ដម មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។ បេ ។ ក៏ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្ម ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សសាម័ញ្ញ ។ ម្នាលគហបតី អរិយសាវ័កនោះឯង អាស្រ័យ

យេវ អនុត្តរំ ឧបេក្ខាសតិបារិសុទ្ធឹ អាគម្ម អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។

[៤៤] ឯត្តាវតា ខោ គហបតិ អរិយស្ស វិនយេ សព្វេន សព្វំ សព្វថា សព្វំ វោហារសមុច្ឆេទោ ហោតិ តំ កឹ មញ្ញសិ គហបតិ យថា អរិយស្ស វិនយេ សព្វេន សព្វំ សព្វថា សព្វំ វោហារសមុច្ឆេទោ ហោតិ អបិ នុ ត្វំ ឯវរូបំ វោហារសមុច្ឆេទំ អត្តនិ សម-នុបស្សីតិ ។ កោ ចាហំ ភន្តេ យោ[១] ច អរិយស្ស វិនយេ សព្វេន សព្វំ សព្វថា សព្វំ វោហារសមុច្ឆេទោ អារកាហំ ភន្តេ អរិយស្ស វិនយេ សព្វេន សព្វំ សព្វថា ភន្តេ វោហារសមុច្ឆេទា មយំ ហិ ភន្តេ បុព្វេ អញ្ញតិត្ថិយេ បរិព្វាជកេ អនាជានីយេវ សមានេ អាជានីយាតិ អមញ្ញិម្ហ អនាជានីយេវ សមានេ អាជា-នីយភោជនំ ភោជិម្ហ អនាជានីយេវ សមានេ អាជា-

១ ឱ. ម. កោ ។

នូវសេចក្តីបរិសុទ្ធនៃសតិ ដែលកើតអំពីឧបេក្ខាដ៏ប្រសើរនេះឯង ហើយធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នឹងបានដល់ចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។

[៤៥] ម្នាលគហបតី ការផ្តាច់បង់ជំនួញ ដោយសព្វគ្រប់ដោយប្រការទាំងពួង ក្នុងអរិយវិន័យ តែងមានដោយហេតុមានប្រមាណប៉ុណ្ណោះ ម្នាលគហបតី អ្នកសំគាល់សេចក្តីនោះ ដូចម្តេច ការផ្តាច់បង់ជំនួញដោយសព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យ ដោយសភាពយ៉ាងណា អ្នកបានឃើញការផ្តាច់បង់ជំនួញ មានសភាពយ៉ាងនោះក្នុងខ្លួនដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គណាក្តី ការផ្តាច់បង់ជំនួញដោយសព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យណាក្តី បពិត្រព្រះអង្គដ៏ចម្រើន បណ្តាសភាវៈទាំងពីរនោះ ខ្ញុំព្រះអង្គឆ្ងាយចាកការផ្តាច់បង់ជំនួញដោយសព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា កាលពីដើមខ្ញុំព្រះអង្គបានសំគាល់នូវពួកបរិព្វាជក មានលទ្ធិផ្សេង ដែលមិនមែនជាបុរសអាជានេយ្យពិតថាជាបុរសអាជានេយ្យ ញុំាងបុគ្គលដែលមិនមែនជាបុរសអាជានេយ្យពិតឲ្យបរិភោគភោជន សំរាប់បុរសអាជានេយ្យ តាំងបុគ្គលដែលមិនមែនជា

គហបតិវគ្គស្ស បោតលិយសុត្តេ អាជានីយានាជានីយតា

នីយដ្ឋានេ បឋិម្ហ ភិក្ខូ បន មយំ ភន្តេ អាជានីយេវ សមានេ អជាជានីយាតិ អមញ្ញិម្ហ អាជានីយេវ សមានេ អជាជានីយភោជនំ ភោជិម្ហ អាជានីយេវ សមានេ អជាជានីយដ្ឋានេ បឋិម្ហ ឥជានិ បន មយំ ភន្តេ អញ្ញតិត្ថិយេ បរិព្វាជកេ អជាជានីយេវ សមានេ អជាជានីយាតិ ជានិស្សាម អជាជានីយេវ សមានេ អជាជានីយភោជនំ ភោជិស្សាម អជាជានីយេវ ស-មានេ អជាជានីយដ្ឋានេ បបេស្សាម ភិក្ខូ បន មយំ ភន្តេ អាជានីយេវ សមានេ អាជានីយាតិ ជានិស្សាម អាជានីយេវ សមានេ អាជានីយភោជនំ ភោជិស្សាម អាជានីយេវ សមានេ អាជានីយដ្ឋានេ បបេស្សាម អជនេសិ វត មេ ភន្តេ ភគវា សមណេសុ សម-ណាបេមំ សមណេសុ សមណាបសាទំ សមណេសុ

បុរសអាជានេយ្យពិត ឲ្យតាំងនៅក្នុងទីជាបុរសអាជានេយ្យ បពិត្រព្រះអង្គដ៏ចម្រើន មួយយ៉ាងទៀត ខ្ញុំព្រះអង្គ បានសំគាល់ភិក្ខុទាំងឡាយដែលជាបុរសអាជានេយ្យពិត ថាមិនមែនជាបុរសអាជានេយ្យវិញ ញ៉ាំងភិក្ខុដែលជាបុរសអាជានេយ្យពិត ឲ្យបរិភោគភោជន សំរាប់បុរសមិនមែនជាអាជានេយ្យវិញ តាំងភិក្ខុដែលជាបុរសអាជានេយ្យពិត ក្នុងទីនៃបុរសមិនមែនជាអាជានេយ្យ បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះ ខ្ញុំព្រះអង្គស្គាល់ពួកបរិព្វាជក មានលទ្ធិផ្សេង ដែលមិនមែនជាបុរសអាជា-នេយ្យពិត ថាមិនមែនជាបុរសអាជានេយ្យ នឹងញ៉ាំងបុគ្គលដែលមិនមែនជាបុរសអាជានេយ្យពិត ឲ្យបរិភោគភោជន សំរាប់បុរសមិនមែនជាអាជានេយ្យ នឹងតាំងបុគ្គលដែលមិនមែនជាបុរសអាជានេយ្យពិត ក្នុងទីនៃបុគ្គលមិនមែនជាបុរសអាជានេយ្យ បពិត្រព្រះអង្គដ៏ចម្រើន មួយយ៉ាងទៀត ខ្ញុំព្រះអង្គស្គាល់ភិក្ខុទាំងឡាយ ដែលជាបុរសអាជានេយ្យពិត ថាជាបុរសអាជានេយ្យ នឹងញ៉ាំងភិក្ខុដែលជាបុរសអាជានេយ្យពិត ឲ្យបរិភោគភោជន សំរាប់បុរសអាជានេយ្យ នឹងតាំងភិក្ខុដែលជាបុរសអាជានេយ្យ ក្នុងទីនៃបុរសអាជានេយ្យ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់បានធ្វើសេចក្តីស្រឡាញ់ចំពោះពួកសមណៈ សេចក្តីជ្រះថ្លា

សមណាគារវំ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យ-
ថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា
វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា
តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ
ឯវមេវ[១] ភគវតា អនេកបរិយាយេន ធម្មោ បកា-
សិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ
ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ
អជ្ជតគ្គេ បាណុបេតំ សរណាគតន្តិ ។

បោតលិយសុត្តំ ចតុត្ថំ និដ្ឋិតំ[២] ។

---

១ ឱ. ឯវមេវ ។ ម. ឯវមេវ ខោ ។ ២ ឱ. ម. និដ្ឋិតន្តិ សព្វត្ថ ន ទិស្សតិ ។

ចំពោះពួកសមណៈ សេចក្ដីគោរពចំពោះពួកសមណៈ ឲ្យកើតដល់ខ្ញុំព្រះអង្គហើយហ្ន៎ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសំដែងហើយដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) ដូចជាបុរសចាប់បើករបស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ឬដូចជាបុរសបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ឬក៏ដូចជាបុរសប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះដូចជាគេកាន់ប្រទីបទ្រោលបំភ្លឺ ក្នុងទីងងឹតដោយគិតថា មនុស្សអ្នកមានចក្ខុមើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង ទីរលឹក សូមព្រះមានព្រះភាគ ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសកដល់សរណៈ ស្មើដោយជីវិត ក្នុងថ្ងៃនេះជាដើម ។

ចប់ បោតលិយសូត្រ ទី ៤ ។

# បញ្ចមំ ជីវកសុត្តំ

[៥៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ ជីវកស្ស កោមារភច្ចស្ស អម្ព-វនេ ។ អថខោ ជីវកោ កោមារភច្ចោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជីវកោ កោមារភច្ចោ ភគវន្តំ ឯតទវោច សុតមេតំ ភន្តេ សមណំ គោតមំ ឧទ្ទិស្ស ចាណំ អារភន្តិ តំ សមណោ គោតមោ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជតិ បដិច្ច កម្មន្តិ យេ តេ ភន្តេ ឯវមាហំសុ សមណំ គោតមំ ឧទ្ទិស្ស ចាណំ អារភន្តិ តំ សមណោ គោតមោ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជតិ បដិច្ច កម្មន្តិ កច្ចិ តេ ភន្តេ ភគវតោ វុត្តវាទិនោ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខន្តិ

# ជីវកសូត្រ ទី ៥

[៩៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអម្ពវ័ន របស់ជីវកកោមារភច្ច ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ជីវកកោមារភច្ច ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះជីវកកោមារភច្ច អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឮមកដូច្នេះថា ពួកជនតែងសម្លាប់សត្វ ចំពោះព្រះសមណគោតម ព្រះសមណគោតម បើទុកជាជ្រាបហេតុនោះហើយ ក៏រមែងសោយសាច់ ដែលគេធ្វើចំពោះ គឺសាច់ដែលគេធ្វើអាស្រ័យនូវខ្លួន បពិត្រព្រះអង្គដ៏ចម្រើន ពួកជនណា ពោលយ៉ាងនេះថា ពួកជនតែងសម្លាប់សត្វ ចំពោះព្រះសមណគោតម ព្រះសមណគោតម បើទុកជាជ្រាបហេតុនោះហើយក៏រមែងសោយសាច់ ដែលគេធ្វើចំពោះ គឺសាច់ដែលគេធ្វើអាស្រ័យនូវខ្លួន បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងនោះនិយាយត្រូវតាមពាក្យ ដែលគេពោលចំពោះព្រះមានព្រះភាគ មិនមែននិយាយបង្កាច់ព្រះមានព្រះភាគ

ធម្មស្ស ចានុធម្មំ ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហដ្ឋានំ[1] អាគច្ឆតីតិ ។

[៤៧] យេ តេ ជីវក ឯវមាហំសុ សមណំ គោតមំ ឧទ្ទិស្ស បាណំ អារភន្តិ តំ សមណោ គោតមោ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជតិ បដិច្ចកម្មន្តិ ន មេ តេ វុត្តវាទិនោ អព្ភាចិក្ខន្តិ ច មំ តេ អសតា អភូតេន[2] តីហិ ខោ អហំ ជីវក ឋានេហិ មំសំ អបរិភោគន្តិ វទាមិ ទិដ្ឋំ សុតំ បរិសង្កិតំ ឥមេហិ ខោ អហំ ជីវក តីហិ ឋានេហិ មំសំ អបរិភោគន្តិ វទាមិ តីហិ ខោ អហំ ជីវក ឋានេហិ មំសំ បរិភោគន្តិ វទាមិ អទិដ្ឋំ អសុតំ អបរិសង្កិតំ ឥមេហិ ខោ អហំ ជីវក តីហិ ឋានេហិ មំសំ បរិភោគន្តិ វទាមិ ។

---

១ ឱ. គារយ្ហំ ឋានន្តិ ទិស្សតិ ។ ២ ឱ. អព្ភាចិក្ខន្តិ ច បន មន្តេ អសតា អភូតេន ។ ម. អសតា អភូតេន អព្ភាចិក្ខន្តិ ។

ដោយពាក្យមិនពិតផង និយាយនូវហេតុសមគួរដល់ហេតុផងឬទេ មួយយ៉ាងទៀត វាទៈនិងអនុវាទៈបន្តិចបន្តួចរបស់ព្រះអង្គ ដែលប្រកបដោយហេតុ មិនបានដល់នូវហេតុ ដែលគួរតិះដៀលឬទេ ។

[៥៧] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលជីវកៈ ពួកជនណានិយាយយ៉ាងនេះថា ពួកជនសម្លាប់សត្វ ចំពោះព្រះសមណគោតម ព្រះសមណគោតម បើទុកជាជ្រាបហេតុនោះហើយ ក៏រមែងសោយសាច់ដែលគេធ្វើចំពោះ គឺសាច់ដែលគេធ្វើអាស្រ័យនូវខ្លួន ពួកជននោះមិនមែននិយាយត្រូវតាមពាក្យ ដែលគេពោលចំពោះតថាគតឡើយ ពួកជននោះនិយាយបង្កាច់តថាគត ដោយពាក្យមិនមែន មិនពិត ម្នាលជីវកៈ តថាគតពោលនូវសាច់ដែលមិនគួរបរិភោគ ដោយហេតុទាំង ៣ គឺឃើញ ឮ រង្កៀស ម្នាលជីវកៈ តថាគតពោលនូវសាច់ដែលមិនគួរបរិភោគ ដោយហេតុទាំង ៣ នេះឯង ម្នាលជីវកៈ តថាគតពោលនូវសាច់ដែលគួរបរិភោគ ដោយហេតុទាំង ៣ គឺមិនឃើញ មិនឮ មិនរង្កៀស ម្នាលជីវកៈ តថាគតពោលនូវសាច់ដែលគួរបរិភោគ ដោយហេតុទាំង ៣ នេះឯង ។

## គហបតិវគ្គស្ស ជីវកសុត្តេ មេត្តាភាវនា

[៤៨] ឥធ ជីវក ភិក្ខុ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ ។ សោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ តមេនំ គហបតិ វា គហបតិបុត្តោ វា ឧបសង្កមិត្វា ស្វាតនាយ ភត្តេន និមន្តេតិ អាកង្ខមានោ ជីវក ភិក្ខុ អធិវាសេតិ ។ សោ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តស្ស គហបតិស្ស វា គហបតិបុត្តស្ស វា និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទតិ ។ តមេនំ សោ គហបតិ វា គហបតិបុត្តោ វា បណីតេន បិណ្ឌបាតេន បរិវិសតិ ។ តស្ស ន ឯវំ ហោតិ សាធុ វត មាយំ គហបតិ វា គហបតិបុត្តោ វា បណីតេន បិណ្ឌបាតេន បរិវិសតិ

គហបតិវគ្គ ជីវកសូត្រ ការចម្រើនមេត្តាព្រហ្មវិហារ

[៥៨] ម្នាលជីវកៈ ភិក្ខុក្នុងសាសនានេះ ចូលទៅនៅអាស្រ័យនឹងស្រុកឬនិគមណាមួយ ។ ភិក្ខុនោះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តាជាចិត្តទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានវេរា មិនមានព្យាបាទ ផ្សាយទៅកាន់ទិសទាំងពួង ដោយអាការ[១] ទាំងពួង ។ គហបតីឬគហបតិបុត្ត ចូលទៅរកភិក្ខុនោះ ហើយនិមន្តដោយភត្តដើម្បីឆាន់ក្នុងថ្ងៃស្អែក ម្នាលជីវកៈ កាលបើភិក្ខុមានប្រាថ្នា ក៏ទទួលនិមន្ត ។ លុះកន្លងរាត្រីនោះទៅ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងវេលាព្រឹក ក៏ចូលទៅកាន់ផ្ទះនៃគហបតីឬគហបតិបុត្តនោះ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈ ដែលគេក្រាលហើយ ។ ឯគហបតីឬគហបតិបុត្តនោះ ក៏អង្គាសភិក្ខុនោះ ដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់ ។ ភិក្ខុនោះមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា គហបតីឬគហបតិបុត្តនេះអង្គាសអាត្មាអញ ដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់ ដោយប្រពៃណាស់ហ្ន៎

---

១ ដោយសភាពនៃចិត្តដែលប្រព្រឹត្តទៅក្នុងសត្វទាំងពួង ដែលផ្សេងគ្នាមានសត្វថោកទាប យ៉ាងកណ្តាលនិងឧក្រិដ្ឋ សត្វជាមិត្ត ជាសត្រូវ និងយ៉ាងកណ្តាលជាដើម ។

អហោ វត មាយំ គហបតិ វា គហបតិបុត្តោ វា អាយតិម្បិ ឯវរូបេន បណីតេន បិណ្ឌបាតេន បរិវិសេយ្យាតិ ឯវម្បិស្ស ន ហោតិ ។ សោ តំ បិណ្ឌបាតំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ[១] អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ ។ តំ កឹ មញ្ញសិ ជីវក អបិ នុ សោ ភិក្ខុ តស្មឹ សមយេ អត្តព្យាពាធាយ វា ចេតេតិ បរព្យាពាធាយ វា ចេ-តេតិ ឧភយព្យាពាធាយ វា ចេតេតីតិ ។ នោ ហេតំ ភន្តេ ។ ននុ សោ ជីវក ភិក្ខុ តស្មឹ សមយេ អនវជ្ជំយេវ អាហារំ អាហារេតីតិ ។ ឯវំ ភន្តេ សុតំ មេតំ ភន្តេ ព្រហ្មា មេត្តាវិហារីតិ តម្មេ ឥទំ ភន្តេ ភគវា សក្ខិ ទិដ្ឋោ ភគវា ហិ ភន្តេ មេត្តាវិហារីតិ ។ យេន ខោ ជីវក រាគេន យេន ទោសេន យេន មោ-ហេន ព្យាបាទវា អស្ស សោ រាគោ សោ ទោសោ សោ មោហោ តថាគតស្ស បហីនោ ឧច្ឆិន្នមូលោ

១ ឱ. អនជ្ឈោបន្នោ ។

ធ្វើម្ដេចហ្ន៎ គហបតីឬគហបតិបុត្តនេះ គប្បីអង្គាសអាត្មាអញ ដោយបិណ្ឌ-បាតដ៏ផ្ចិតផ្ចង់ មានសភាពយ៉ាងនេះតទៅទៀត ភិក្ខុនោះ មិនមានសេចក្ដីត្រិះរិះយ៉ាងនេះសោះ ។ ភិក្ខុនោះ មិនផ្ដេកផ្ដួល មិនជ្រុលជ្រប់ មិនល្មោភ តែងឃើញទោស មានបញ្ញាជាគ្រឿងរលាស់ចេញចាកទុក្ខ បរិភោគបិណ្ឌបាតនោះ ។ ម្នាលជីវក: អ្នកសំគាល់ហេតុនោះ ថាដូចម្ដេច តើភិក្ខុនោះ គិតដើម្បីបៀតបៀនខ្លួន ឬគិតដើម្បីបៀតបៀនអ្នកដទៃ ឬគិតដើម្បីបៀតបៀនអ្នកទាំងពីរ ក្នុងសម័យនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលជីវក: ភិក្ខុនោះ ឈ្មោះថា ឆាន់អាហារ ដែលមិនមានទោស ក្នុងសម័យនោះមែនឬទេ ។ ព្រះករុណាព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគ្រាន់តែឮមកយ៉ាងនេះថា ព្រហ្មមានកិរិយានៅដោយមេត្តា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនោះជាពាក្យរបស់ខ្ញុំព្រះអង្គ ឥឡូវនេះ ខ្ញុំព្រះអង្គបានឃើញព្រះមានព្រះភាគច្បាស់នឹងភ្នែករបស់ខ្លួនហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ មានកិរិយានៅដោយមេត្តាពិត ។ ម្នាលជីវក: បុគ្គលមានព្យាបាទ ដោយរាគ:ទោស:មោហ:ណា រាគ:ទោស:មោហ:នោះ តថាគតបានលះបង់ហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បាន

## ៨៧

### គហបតិវគ្គស្ស ជីវកសុត្តេ ករុណាទិភាវនា

តាលាវត្ថុកតោ អនភាវង្កតោ[១] អាយតឹ អនុប្បាទធម្មោ សចេ ខោ តេ ជីវក ឥទំ សន្ធាយ ភាសិតំ អនុជានាមិ តេ ឯតន្តិ ។ ឯតទេវ ខោ បន មេ ភន្តេ សន្ធាយ ភាសិតន្តិ[២] ។

[៤៩] ឥធ ជីវក ភិក្ខុ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ ។ សោ ករុណាសហគតេន ចេតសា ។ បេ ។ មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ តមេនំ គហបតិ វា គហបតិបុត្តោ វា ឧបសង្កមិត្វា ស្វាតនាយ ភត្តេន និមន្តេតិ អាកង្ខមានោ[៣] ជីវក ភិក្ខុ អធិវាសេតិ ។ សោ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ

---

១ ឱ. អនភាវគតោ ។ ២ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។ ៣ ឱ. ម. អាកង្ខមានោ វ ។

ធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការសាបសូន្យ មានសភាវៈកើតឡើងតទៅ ម្នាលជីវកៈ បើអ្នកនិយាយអាស្រ័យហេតុនេះ តថាគតក៏យល់ព្រមនូវពាក្យនេះ របស់អ្នកដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនិយាយអាស្រ័យហេតុហ្នឹងឯង ។

[៥៩] ម្នាលជីវកៈ ភិក្ខុក្នុងសាសនានេះ ចូលទៅនៅអាស្រ័យនឹងស្រុក ឬនិគមណាមួយ ។ ភិក្ខុនោះមានចិត្តប្រកបដោយករុណា ។ បេ ។ មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោមនិងទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានវេរា មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង ។ គហបតីឬគហបតិបុត្ត ក៏ចូលទៅរកភិក្ខុនោះ ហើយនិមន្តដោយភត្តដើម្បីឆាន់ក្នុងថ្ងៃស្អែក ម្នាលជីវកៈ កាលបើភិក្ខុមានប្រាថ្នា ក៏ទទួលនិមន្ត ។ លុះកន្លងរាត្រីនោះទៅ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រ

យេន តស្ស គហបតិស្ស វា គហបតិបុត្តស្ស វា និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អា-សនេ និសីទតិ ។ តមេនំ សោ គហបតិ វា គហបតិបុត្តោ វា បណីតេន បិណ្ឌបាតេន បរិវិសតិ ។ តស្ស ន ឯវំ ហោតិ សាធុ វត មាយំ គហបតិ វា គហបតិបុត្តោ វា បណីតេន បិណ្ឌបាតេន បរិវិសតិ អហោ វត មាយំ គហបតិ វា គហបតិបុត្តោ វា អាយតិម្បិ ឯវរូបេន បណីតេន បិណ្ឌបាតេន បរិវិសេយ្យាតិ ឯវម្បិស្ស ន ហោតិ ។ សោ តំ បិណ្ឌបាតំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អា-ទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតិ ។ តំ កឹ មញ្ញសិ ជីវក អបិ នុ សោ ភិក្ខុ តស្មឹ សមយេ អត្តព្យាពាធាយ វា ចេតេតិ បរព្យាពាធាយ វា ចេតេតិ ឧភយព្យាពាធាយ វា ចេតេតីតិ ។ នោ ហេតំ ភន្តេ ។ ននុ សោ ជីវក ភិក្ខុ តស្មឹ សមយេ តំ អនវជ្ជំ-យេវ អាហារំ អាហារេតីតិ ។ ឯវំ ភន្តេ សុតំ មេតំ ភន្តេ ព្រហ្មា ឧបេក្ខាវិហារីតិ តម្មេ ឥទំ ភន្តេ

និងចីវរក្នុងវេលាព្រឹក ក៏ចូលទៅកាន់ផ្ទះគហបតីឬគហបតិបុត្តនោះ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈ ដែលគេក្រាលហើយ ។ ឯគហបតីឬគហបតិបុត្តនោះ ក៏អង្គាសភិក្ខុនោះ ដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់ ។ ភិក្ខុនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា គហបតីឬគហបតិបុត្តនេះ អង្គាសអាត្មាអញ ដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់ ដោយប្រពៃណាស់ហ្ន៎ ធ្វើម្តេចហ្ន៎ គហបតីឬគហបតិបុត្តនេះ គប្បីអង្គាសអាត្មាអញ ដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់ មានសភាពយ៉ាងនេះ តទៅទៀត ភិក្ខុនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះសោះ ។ ភិក្ខុនោះ មិនផ្តេកផ្តួល មិនជ្រុលជ្រប់ មិនល្មោភ តែងឃើញទោស មានបញ្ញាជាគ្រឿងរលាស់ចេញចាកទុក្ខ បរិភោគបិណ្ឌបាតនោះ ។ ម្នាលជីវកៈ អ្នកសំគាល់ហេតុនោះថាដូចម្តេច តើភិក្ខុនោះ គិតដើម្បីបៀតបៀនខ្លួនឯង ឬគិតដើម្បីបៀតបៀនអ្នកដទៃ ឬក៏គិតដើម្បីបៀតបៀនអ្នកទាំងពីរ ក្នុងសម័យនោះ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលជីវកៈ ភិក្ខុនោះឈ្មោះថា ឆាន់អាហារដែលមិនមានទោសនោះ ក្នុងសម័យនោះមែនឬទេ ។ ព្រះករុណាព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគ្រាន់តែឮមក យ៉ាងនេះថា ព្រហ្មមានកិរិយានៅ ដោយឧបេក្ខា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនោះ ជាពាក្យរបស់ខ្ញុំព្រះអង្គ

ភគវា សក្ខិ ទិដ្ឋោ ភគវា ហិ ភន្តេ ឧបេក្ខាវិហារីតិ ។ យេន ខោ ជីវក រាគេន យេន ទោសេន យេន មោហេន វិហេសវា(១) អស្ស អរតិវា អស្ស បដិឃវា(២) អស្ស សោ រាគោ សោ ទោសោ សោ មោហោ តថាគតស្ស បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ សចេ ខោ តេ ជីវក ឥទំ សន្ធាយ ភាសិតំ អនុជានាមិ តេ ឯតន្តិ ។ ឯតទេវ ខោ បន មេ ភន្តេ សន្ធាយ ភាសិតន្តិ ។

[៦០] យោ ខោ ជីវក តថាគតំ វា តថាគតស្សាវកំ វា ឧទ្ទិស្ស បាណំ អារភតិ សោ បញ្ចហិ ឋានេហិ ពហុំ អបុញ្ញំ បសវតិ យម្បិ សោ គហបតិ(៣) ឯវមាហ គច្ឆថ អមុកំ នាម បាណំ អានេថាតិ ឥមិនា បឋមេន ឋានេន ពហុំ អបុញ្ញំ បសវតិ យម្បិ សោ បាណោ គលប្បវេឋកេន អានីយមានោ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ឥមិនា ទុតិយេន ឋានេន ពហុំ អបុញ្ញំ បសវតិ យម្បិ សោ ឯវមាហ គច្ឆថ

១ ឱ. ម. វិហេសាវា ។ ២ ម. បដិឃោវា ។ ៣ ឱ. គហបតីតិ ន ទិស្សតិ ។

ឥឡូវនេះ ខ្ញុំព្រះអង្គបានឃើញព្រះមានព្រះភាគ ច្បាស់នឹងភ្នែករបស់ខ្លួនហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាព្រះមានព្រះភាគ មានកិរិយានៅដោយឧបេក្ខាពិត ។ ម្នាលជីវកៈ បុគ្គលមានសេចក្តីបៀតបៀន សេចក្តីអផ្សុកនិងសេចក្តីចង្អៀតចង្អល់ ដោយរាគៈទោសៈមោហៈណា រាគៈទោសៈ និងមោហៈនោះ តថាគតបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោតជាសភាវៈដល់នូវការសាបសូន្យ មានសភាពមិនកើតឡើងតទៅ ម្នាលជីវកៈ បើអ្នកនិយាយអាស្រ័យហេតុនេះ តថាគតក៏យល់ព្រមនូវពាក្យនេះរបស់អ្នកដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនិយាយអាស្រ័យហេតុហ្នឹងឯង ។

[៦០] ម្នាលជីវកៈ បុគ្គលណាសម្លាប់សត្វ ចំពោះតថាគតឬសាវ័ករបស់តថាគត បុគ្គលនោះតែងទទួលបាបច្រើន ដោយឋានៈ ៥ យ៉ាង បុគ្គលនោះនិយាយយ៉ាងនេះថា អ្នកទាំងឡាយចូរទៅនាំយកសត្វឯណោះមកដោយឋានៈណា តែងទទួលនូវបាបច្រើន ដោយឋានៈនេះជាបឋម សត្វនោះកាលដែលគេយកខ្សែទាក់កដឹកយកមក ក៏ទទួលទុក្ខទោមនស្សដោយឋានៈណា បុគ្គលនោះតែងទទួលបាបច្រើន ដោយឋានៈនេះជាគម្រប់ពីរ បុគ្គលនោះនិយាយយ៉ាងនេះថា អ្នកទាំងឡាយចូរទៅ

ឥមំ បាណំ អារភថាតិ ឥមិនា តតិយេន ឋានេន ពហុំ អបុញ្ញំ បសវតិ យម្បិ សោ បាណោ អារភិយ-មានោ ទុក្ខទោមនស្សំ បដិសំវេទេតិ ឥមិនា ចតុត្ថេន ឋានេន ពហុំ អបុញ្ញំ បសវតិ យម្បិ សោ តថាគតំ វា តថាគតសាវកំ វា អកប្បិយេន អាសាទេតិ ឥមិនា បញ្ចមេន ឋានេន ពហុំ អបុញ្ញំ បសវតិ យោ ខោ ជីវក តថាគតំ វា តថាគតសាវកំ វា ឧទ្ទិស្ស បាណំ អារភតិ សោ ឥមេហិ បញ្ចហិ ឋានេហិ ពហុំ អបុញ្ញំ បសវតីតិ ។

[៦១] ឯវំ វុត្តេ ជីវកោ កោមារភច្ចោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ កប្បិយំ វត ភន្តេ ភិក្ខូ អាហារំ អាហារេន្តិ អនវជ្ជំ វត ភន្តេ ភិក្ខូ អាហារំ អាហារេន្តិ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ

សម្លាប់សត្វនេះដោយឋានៈណា បុគ្គលនោះតែងសោយ នូវបាបច្រើន ដោយឋានៈនេះជាគម្រប់ ៣ សត្វនោះកាលដែលគេកំពុងសម្លាប់ក៏ទទួល នូវទុក្ខ ទោមនស្ស ដោយឋានៈណា បុគ្គលតែងទទួលបាបច្រើន ដោយឋានៈនេះជាគម្រប់ ៤ បុគ្គលនោះធ្វើឲ្យគេតិះដៀលតថាគត ឬសាវ័ករបស់តថាគត ដោយអកប្បិយមំសៈ (សាច់មិនសមគួរ) ដោយឋានៈណា បុគ្គលនោះតែងទទួលបាបច្រើន ដោយឋានៈនេះជាគម្រប់ ៥ ម្នាលជីវកៈ បុគ្គលណាសម្លាប់សត្វចំពោះតថាគត ឬសាវ័ករបស់តថាគត បុគ្គលនោះតែងទទួលបាបច្រើន ដោយឋានៈទាំង ៥ យ៉ាងនេះឯង ។

[៦១] លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ទើបជីវកកោមារភច្ចក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុឆាន់តែអាហារជាកប្បិយៈហ្ន៎ បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុឆាន់តែអាហារ ដែលមិនមានទោសហ្ន៎ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់

គហបតិវគ្គស្ស ជីវកសុត្តេ បាណុបេតសរណាគតតា

សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិ-តោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណាង្គតន្តិ ។

ជីវកសុត្តំ បញ្ចមំ និដ្ឋិតំ ។

ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) ដូចជាបុរសចាប់បើករបស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ឬដូចជាបុរសបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះដូចជាបុរសប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាបុរសកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សមានចក្ខុមើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់សរណៈ ស្មើដោយជីវិតក្នុងថ្ងៃនេះជាដើម ។

ចប់ ជីវកសូត្រ ទី ៥ ។

# ឆដ្ឋំ ឧបាលិវាទសុត្តំ

[៦២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា នាឡន្ទាយំ វិហរតិ បាវារិកម្ពវនេ ។ តេន ខោ បន សមយេន និគណ្ឋោ[១] នាដបុត្តោ នាឡន្ទាយំ បដិវសតិ មហតិយា និគណ្ឋបរិសាយ សទ្ធឹ ។ អថខោ ទីឃតបស្សី និគណ្ឋោ នាឡន្ទាយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន បាវារិកម្ពវនំ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ ទីឃតបស្សឹ និគណ្ឋំ ភគវា ឯតទវោច សំវិជ្ជន្តិ ខោ[២] ទីឃតបស្សិ អាសនានិ សចេ អាកង្ខសិ និសីទាតិ ។ ឯវំ វុត្តេ ទីឃតបស្សី និគណ្ឋោ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។

---

១ និគ្គន្ថោតិបិ សំយោគោ ទដ្ឋព្វោ ។ ២ ឱ. សំវិជ្ជន្តេ ខោតិ ទិស្សតិ ។

# ឧបាលិវាទសូត្រ ទី ៦

[៦២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងបាវារិកម្ពវ័ន[១] ជិតស្រុកនាលន្ទា ។ សម័យនោះឯង និគន្ថនាដបុត្តនៅអាស្រ័យ ក្នុងស្រុកនាលន្ទា ជាមួយនឹងនិគន្ថបរិសទ្យជាច្រើន ។ គ្រានោះ និគ្រន្ថឈ្មោះទីឃតបស្សី ត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងស្រុកនាលន្ទា លុះត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាបច្ឆាភត្តហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងបាវារិកម្ពវ័ននោះ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏ឋិតនៅក្នុងទីសមគួរ ។ លុះទីឃតបស្សីនិគ្រន្ថឋិតនៅ ក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា នែទីឃតបស្សី អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការចូរអង្គុយចុះ ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ទើបទីឃតបស្សីនិគ្រន្ថ កាន់យកអាសនៈទាបមួយ អង្គុយក្នុងទីសមគួរ ។

---

១ ជាឈ្មោះវត្តព្រៃស្វាយរបស់បាវារិកសេដ្ឋី ។ បានឮមកថា សេដ្ឋីនោះបានស្តាប់ធម៌ទេសនារបស់ព្រះមានព្រះភាគ មានសេចក្តីជ្រះថ្លាបានកសាងវត្ត ប្រដាប់ដោយសេនាសនៈផ្សេង ៗ មានកុដិគូហា និងមណ្ឌបជាដើមក្នុងឱទ្យាននោះ ថ្វាយព្រះមានព្រះភាគ ។ បានជាវត្តនោះឈ្មោះថា វត្តបាវារិកម្ពវ័ន ដូចជាវត្តជីវកម្ពវ័នដូច្នោះដែរ ។ អដ្ឋកថា ។

គហបតិវគ្គស្ស ឧបាលិវាទសុត្តេ តីណិ ទណ្ឌានិ

[៦៣] ឯកមន្តំ និសិន្នំ ខោ ទីឃតបស្សឹ និគន្ថំ ភគវា ឯតទវោច កតិ បន តបស្សិ និគន្ថោ នាដបុត្តោ កម្មានិ បញ្ញាបេតិ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយាតិ ។ ន ខោ អាវុសោ គោតម អាចិណ្ណំ និគន្ថស្ស នាដបុត្តស្ស កម្មំ កម្មន្តិ បញ្ញាបេតុំ ទណ្ឌំ ទណ្ឌន្តិ ខោ អាវុសោ គោតម អាចិណ្ណំ និគន្ថស្ស នាដបុត្តស្ស បញ្ញាបេតុន្តិ ។ កតិ បន តបស្សិ និគន្ថោ នាដបុត្តោ ទណ្ឌានិ បញ្ញាបេតិ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយាតិ ។ តីណិ[១] អាវុសោ គោតម និគន្ថោ នាដបុត្តោ ទណ្ឌានិ បញ្ញាបេតិ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា សេយ្យថីទំ កាយទណ្ឌំ វចីទណ្ឌំ មនោទណ្ឌន្តិ ។ កឹ បន តបស្សិ អញ្ញទេវ កាយទណ្ឌំ អញ្ញំ វចីទណ្ឌំ អញ្ញំ មនោទណ្ឌន្តិ ។ អញ្ញទេវ អាវុសោ គោតម កាយទណ្ឌំ អញ្ញំ វចីទណ្ឌំ អញ្ញំ មនោទណ្ឌន្តិ ។ ឥមេសំ បន តបស្សិ តិណ្ណំ ទណ្ឌានំ

---

១ ឱ. តីណិ ខោ ។

គហបតិវគ្គ ឧបាលិវាទសូត្រ ទណ្ឌៈ ៣ យ៉ាង

[៦៣] លុះទីឃតបស្សីនិគ្រន្ថអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលតបស្សី ចុះនិគន្ថនាដបុត្តបញ្ញត្តកម្ម ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមានប៉ុន្មាន ។ ទីឃតបស្សីតបថា អាវុសោគោតម និគន្ថនាដបុត្តមិនធ្លាប់បញ្ញត្តនូវកម្ម ថាកម្មដូច្នេះឡើយ អាវុសោគោតម និគន្ថនាដបុត្តធ្លាប់បញ្ញត្តនូវទណ្ឌៈ ថាទណ្ឌៈ ប៉ុណ្ណោះឯង ។ ម្នាលតបស្សី ចុះនិគន្ថនាដបុត្ត តែងបញ្ញត្តនូវទណ្ឌៈប៉ុន្មានយ៉ាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមានប៉ុន្មាន ។ អាវុសោគោតម និគន្ថនាដបុត្ត តែងបញ្ញត្តនូវទណ្ឌៈក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមាន ៣ យ៉ាង គឺ កាយទណ្ឌៈ ១ វចីទណ្ឌៈ ១ មនោទណ្ឌៈ ១ ។ ម្នាលតបស្សី ចុះកាយទណ្ឌៈផ្សេង វចីទណ្ឌៈផ្សេង មនោទណ្ឌៈផ្សេង ឬក៏ដូចគ្នា ។ អាវុសោគោតម កាយទណ្ឌៈផ្សេង វចីទណ្ឌៈផ្សេង មនោ-ទណ្ឌៈផ្សេង មិនដូចគ្នាទេ ។ ម្នាលតបស្សី បណ្តាទណ្ឌៈទាំង ៣ នេះ

ឯវំ បដិវិភត្តានំ ឯវំ បដិវិសិដ្ឋានំ កតមំ ទណ្ឌំ និគណ្ឋោ នាដបុត្តោ មហាសាវជ្ជតរំ បញ្ញាបេតិ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា យទិ វា កាយទណ្ឌំ យទិ វា វចីទណ្ឌំ យទិ វា មនោទណ្ឌន្តិ ។ ឥមេសំ ខោ អាវុសោ គោតម តិណ្ណំ ទណ្ឌានំ ឯវំ បដិវិភត្តានំ ឯវំ បដិវិសិដ្ឋានំ កាយទណ្ឌំ និគណ្ឋោ នាដបុត្តោ មហាសាវជ្ជតរំ បញ្ញាបេតិ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា នោ តថា វចីទណ្ឌំ នោ តថា មនោទណ្ឌន្តិ ។ កាយទណ្ឌន្តិ តបស្សិ វទេសិ ។ កាយទណ្ឌន្តិ អាវុសោ គោតម វទាមិ ។ កាយទណ្ឌន្តិ តបស្សិ វទេសិ ។ កាយទណ្ឌន្តិ អាវុសោ គោតម វទាមិ ។ កាយទណ្ឌន្តិ តបស្សិ វទេសិ ។ កាយទណ្ឌន្តិ អាវុសោ គោតម វទាមីតិ ។ ឥតិហ ភគវា ទីឃតបស្សឹ និគណ្ឋំ ឥមស្មឹ កថាវត្ថុស្មឹ យាវតតិយកំ បតិដ្ឋាបេសិ ។

ដែលអ្នកចែកហើយយ៉ាងនេះ ញែកហើយយ៉ាងនេះ និគន្ថនាដបុត្ត តែង បញ្ញត្តនូវទណ្ឌៈណា ដែលមានទោសធំជាងគេ ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម កាយទណ្ឌ: ឬវចីទណ្ឌ: ឬមនោទណ្ឌ: ។ អាវុសោគោតម បណ្តាទណ្ឌ:ទាំង ៣ នេះ ដែលខ្ញុំព្រះអង្គចែកហើយ យ៉ាងនេះ ញែកហើយយ៉ាងនេះ និគន្ថនាដបុត្ត តែងបញ្ញត្តនូវកាយទណ្ឌ: ថាមានទោសធំជាងគេ ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃ បាបកម្ម មិនបញ្ញត្តនូវវចីទណ្ឌ: និងមនោទណ្ឌ: ថាមានទោសធំដូច្នោះ ទេ ។ ម្នាលតបស្សី អ្នកនិយាយថា កាយទណ្ឌដូច្នេះឬ ។ អាវុសោ គោតម ខ្ញុំព្រះអង្គនិយាយថា កាយទណ្ឌ: ដូច្នេះ ។ ម្នាលតបស្សី អ្នកនិយាយថា កាយទណ្ឌ: ដូច្នេះឬ ។ អាវុសោគោតម ខ្ញុំព្រះអង្គ និយាយថា កាយទណ្ឌ: ដូច្នេះ ។ ម្នាលតបស្សី អ្នកនិយាយថា កាយ-ទណ្ឌ: ដូច្នេះឬ ។ អាវុសោគោតម ខ្ញុំព្រះអង្គនិយាយថា កាយទណ្ឌ: ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ញុំាងទីឃតបស្សីនិគ្រន្ថឲ្យឋិតនៅនឹង ក្នុងកថាវត្ថុនេះ ជាគម្រប់ ៣ ដង ដោយប្រការដូច្នេះ ។

[៦៤] ឯវំ វុត្តេ ទីឃតបស្សី និគណ្ឋោ ភគវន្តំ ឯតទវោច តុំ បនាវុសោ គោតម កតិ ទណ្ឌានិ បញ្ញាបេសិ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយាតិ ។ ន ខោ តបស្សិ អាចិណ្ណំ តថាគតស្ស ទណ្ឌំ ទណ្ឌន្តិ បញ្ញាបេតុំ កម្មំ កម្មន្តិ ខោ តបស្សិ អាចិណ្ណំ តថាគតស្ស បញ្ញាបេតុន្តិ ។ តុំ បនាវុសោ គោតម កតិ កម្មានិ បញ្ញាបេសិ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយាតិ ។ តីណិ ខោ អហំ តបស្សិ កម្មានិ បញ្ញាបេមិ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា សេយ្យថីទំ កាយកម្មំ វចីកម្មំ មនោកម្មន្តិ ។ កឹ បនាវុសោ គោតម អញ្ញទេវ កាយកម្មំ អញ្ញំ វចីកម្មំ អញ្ញំ មនោកម្មន្តិ ។ អញ្ញទេវ តបស្សិ កាយកម្មំ អញ្ញំ វចីកម្មំ អញ្ញំ មនោកម្មន្តិ ។ ឥមេសំ បនាវុសោ គោតម តិណ្ណំ កម្មានំ ឯវំ បដិវិភត្តានំ ឯវំ បដិវិសិដ្ឋានំ កតមំ កម្មំ មហាសាវជ្ជតរំ បញ្ញាបេសិ

គហបតិវគ្គ ឧបាលិវាទសូត្រ កម្ម ៣ យ៉ាង

[៦៤] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ទីឃតបស្សីនិគ្រន្ថ ក៏និយាយពាក្យនេះនឹងព្រះមានព្រះភាគថា អាវុសោគោតម ព្រះអង្គទ្រង់បញ្ញត្តទណ្ឌៈ ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមានប៉ុន្មាន ។ ម្នាលតបស្សី តថាគតមិនធ្លាប់បញ្ញត្តនូវទណ្ឌៈ ថាទណ្ឌៈដូច្នេះទេ ម្នាលតបស្សី តថាគតធ្លាប់បញ្ញត្តតែកម្ម ថាកម្មប៉ុណ្ណោះឯង ។ អាវុសោគោតម ចុះព្រះអង្គទ្រង់បញ្ញត្តកម្មមានប៉ុន្មាន ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមានប៉ុន្មាន ។ ម្នាលតបស្សី តថាគតបញ្ញត្តនូវកម្ម ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមាន ៣ យ៉ាងគឺ កាយកម្ម ១ វចីកម្ម ១ មនោកម្ម ១ ។ អាវុសោគោតម ចុះកាយកម្មផ្សេង វចីកម្មផ្សេង មនោកម្មផ្សេងឬអ្វី ។ ម្នាលតបស្សី កាយកម្មផ្សេង វចីកម្មផ្សេង មនោកម្មផ្សេង ។ អាវុសោគោតម បណ្ដាកម្មទាំង ៣ នេះ ដែលព្រះអង្គចែកហើយយ៉ាងនេះ ញែកហើយយ៉ាងនេះ ព្រះអង្គទ្រង់បញ្ញត្តកម្មណា ថាមានទោសធំជាងគេ

បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា យទិ វា កាយកម្មំ យទិ វា វចីកម្មំ យទិ វា មនោកម្មន្តិ ។ ឥមេសំ ខោ អហំ តបស្សិ តិណ្ណំ កម្មានំ ឯវំ បដិវិភត្តានំ ឯវំ បដិវិសិដ្ឋានំ មនោកម្មំ មហាសាវជ្ជតរំ បញ្ញាបេមិ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា នោ តថា កាយកម្មំ នោ តថា វចីកម្មន្តិ ។ មនោកម្មន្តិ អាវុសោ គោតម វទេសិ ។ មនោកម្មន្តិ តបស្សិ វទាមិ ។ បេ ។ មនោកម្មន្តិ អាវុសោ គោតម វទេសិ ។ មនោកម្មន្តិ តបស្សិ វទាមីតិ ។ ឥតិហ ទីឃតបស្សី និគណ្ឋោ ភគវន្តំ ឥមស្មឹ កថាវត្ថុស្មឹ យាវតតិយកំ បតិដ្ឋាបេត្វា ឧដ្ឋាយាសនា យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ។

[៦៤] តេន ខោ បន សមយេន និគណ្ឋោ នាដបុត្តោ មហតិយា គិហិបរិសាយ សទ្ធឹ និសិន្នោ ហោតិ ពាលកិនិយា ឧបាលិប្បមុខាយ[១] ។

១ ឱ. ម. ពាលកិរិយា បរិសាយ ឧបាលិបមុខាយាតិ ទិស្សតិ ។

ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម តើកាយកម្ម ឬវចីកម្ម ឬក៏មនោកម្ម ។ ម្នាលតបស្សី បណ្តាកម្មទាំង ៣ នេះ ដែលតថាគតចែក ហើយយ៉ាងនេះ ញែកហើយយ៉ាងនេះ តថាគតបញ្ញត្តមនោកម្ម ថាមាន ទោសធំជាងគេ ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម មិនបញ្ញត្តកាយកម្មនិងវចីកម្ម ថាមានទោសធំទេ ។ អាវុសោគោតម ព្រះអង្គថា មនោកម្មឬ ។ ម្នាលតបស្សី តថាគតថាមនោកម្ម ។ បេ ។ អាវុសោគោតម ព្រះអង្គថាមនោកម្មឬ ។ ម្នាលតបស្សី តថាគតថាមនោកម្ម ។ ទីឃតបស្សីនិគ្រន្ថ ញុំាងព្រះមានព្រះភាគ ឲ្យឋិតនៅក្នុងកថាវត្ថុនេះដរាប ៣ ដង ដោយប្រការដូច្នេះ ហើយក្រោក ចាកអាសនៈចូលទៅរកនិគន្ថនាដបុត្ត ។

[៦៥] សម័យនោះឯង និគន្ថនាដបុត្តកំពុងអង្គុយជាមួយនឹងគិហិបរិ-ស័ទជាច្រើន អ្នកនៅក្នុងស្រុកពាលកៈ មានឧបាលិគហបតីជាប្រធាន ។

៩៧



អទ្ទសា ខោ និគណ្ឋោ នាដបុត្តោ ទីឃតបស្សឹ និគណ្ឋំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន ទីឃតបស្សឹ និគណ្ឋំ ឯតទវោច ហន្ទ កុតោ នុ ត្វំ តបស្សិ អាគច្ឆសិ ទិវាទិវស្សាតិ ។ ឥតោ ហិ ខោ អហំ ភន្តេ អាគច្ឆាមិ សមណស្ស គោតមស្ស សន្តិកាតិ ។ អហុ បន តេ តបស្សិ សមណេន គោតមេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ អហុ ខោ មេ ភន្តេ សមណេន គោតមេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ យថាកថំ បន តេ តបស្សិ អហុ សមណេន គោតមេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ អថខោ ទីឃតបស្សី និគណ្ឋោ យាវតកោ អហោសិ ភគវតា សទ្ធឹ កថាសល្លាបោ តំ សព្វំ និគណ្ឋស្ស នាដបុត្តស្ស អារោចេសិ ។ ឯវំ វុត្តេ និគណ្ឋោ នាដបុត្តោ ទីឃតបស្សឹ និគណ្ឋំ ឯតទវោច សាធុ សាធុ តបស្សិ យថា តំ សុតវតា សាវកេន សម្មទេវ សត្ថុ សាសនំ អាជានន្តេន

និគន្ថនាដបុត្ត បានឃើញតបស្សីនិគ្រន្ថ ដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងទីឃតបស្សីនិគ្រន្ថ ដោយពាក្យដូច្នេះថា តបស្សី ចុះអ្នកឯងទើបមកពីណាទាំងថ្ងៃម្ល៉េះ[១] ។ ទីឃតបស្សីតបថា បពិត្រលោកដ៏ចម្រើន ខ្ញុំមកអំពីសំណាក់ព្រះសមណគោតមឯណោះ ។ និគន្ថនាដបុត្តសួរថា នែតបស្សី ចុះអ្នកមានកថាសល្លាបៈបន្តិចបន្តួច[២] ជាមួយនឹងព្រះសមណគោតមដែរឬ ។ បពិត្រលោកដ៏ចម្រើន ខ្ញុំមានកថាសល្លាបៈបន្តិចបន្តួចជាមួយនឹងព្រះសមណគោតមដែរ ។ នែតបស្សី អ្នកមានកថាសល្លាបៈបន្តិចបន្តួច ជាមួយនឹងព្រះសមណគោតមតើដូចម្តេច ។ ទើបទីឃតបស្សីនិគ្រន្ថ ក៏រៀបរាប់កថាសល្លាបៈ ជាមួយនឹងព្រះមានព្រះភាគទាំងអស់ដល់និគន្ថនាដបុត្ត ។ កាលបើទីឃតបស្សីនិគ្រន្ថនិយាយយ៉ាងនេះហើយ និគន្ថនាដបុត្តនិយាយនឹងទីឃតបស្សីនិគ្រន្ថដូច្នេះថា នែតបស្សី ពីរោះណាស់ ៗ សាវ័កដែលជាអ្នកចេះដឹង អាចដឹងច្បាស់សាសនារបស់

---

១ ហួសវេលាថ្ងៃត្រង់ទៅ ។ ២ ការនិយាយដោយសំដី ។

ឯវមេវ ទីឃតបស្សិនា និគណ្ឋេន សមណស្ស គោតមស្ស ព្យាកតំ កិញ្ហិ សោភតិ ឆវោ មនោទណ្ឌោ ឥមស្ស ឯវំ ឱឡារិកស្ស កាយទណ្ឌស្ស ឧបនិធាយ អថខោ កាយទណ្ឌោវ មហាសាវជ្ជតរោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា នោ តថា វចីទណ្ឌោ នោ តថា មនោទណ្ឌោតិ ។

[៦៦] ឯវំ វុត្តេ ឧបាលិ គហបតិ និគណ្ឋំ នាដបុត្តំ ឯតទវោច សាធុ សាធុ ភន្តេ ទីឃតបស្សី យថា តំ សុតវតា សាវកេន សម្មទេវ សត្ថុ សាសនំ អាជានន្តេន ឯវមេវ ភទន្តេន ទីឃតបស្សិនា[១] សមណស្ស គោតមស្ស ព្យាកតំ កិញ្ហិ សោភតិ ឆវោ មនោទណ្ឌោ ឥមស្ស ឯវំ ឱឡារិកស្ស កាយទណ្ឌស្ស ឧបនិធាយ អថខោ កាយទណ្ឌោវ មហាសាវជ្ជតរោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា នោ តថា វចីទណ្ឌោ នោ តថា មនោទណ្ឌោ

១ ឱ. តបស្សិនា ។

គ្រូដោយប្រពៃ ហើយព្យាករពាក្យនោះយ៉ាងណា ទីឃតបស្សីនិគ្រន្ថ បានព្យាករ ចំពោះព្រះសមណគោតម ក៏យ៉ាងនោះឯង ក៏មនោទណ្ឌៈ ជាសភាវៈថោកថយ យកមកប្រៀបធៀបនឹងកាយទណ្ឌៈ ដ៏ថ្លៃថ្លានេះឲ្យវិសេសវិសាលជាងយ៉ាងនេះដូចម្តេចបាន គឺកាយទណ្ឌៈហ្នឹងឯងជារបស់មានទោសធំជាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈ និងមនោទណ្ឌៈ នឹងមានទោសធំដូច្នោះក៏ទេ ។

[៦៦] កាលបើនិគន្ថនាដបុត្តនិយាយយ៉ាងនេះហើយ ទើបឧបាលិគហបតីនិយាយនឹងនិគន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន ទីឃតបស្សីនិយាយពាក្យនេះពីរោះណាស់ ៗ សាវ័កដែលជាអ្នកចេះដឹង អាចដឹងច្បាស់នូវសាសនារបស់គ្រូដោយប្រពៃ ហើយព្យាករពាក្យនោះយ៉ាងណា ទីឃតបស្សីដ៏ចម្រើន បានព្យាករចំពោះព្រះសមណគោតមយ៉ាងនោះឯង ក៏មនោទណ្ឌៈជារបស់ថោកថយ យកមកប្រៀបធៀបនឹងកាយទណ្ឌៈដ៏ថ្លៃថ្លានេះ ឲ្យវិសេសវិសាលជាងយ៉ាងនេះ ដូចម្តេចបាន គឺកាយទណ្ឌៈហ្នឹងឯង ជាសភាវៈមានទោសធំជាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈ និងមនោទណ្ឌៈ នឹងមានទោសធំដូច្នោះក៏ទេ

៩៩

គហបតិវគ្គស្ស ឧបាលិវាទសុត្តេ វាទារោបនកាមតា

ហន្ទ ចាហំ ភន្តេ គច្ឆាមិ សមណស្ស គោតមស្ស ឥមស្មឹ កថាវត្ថុស្មឹ វាទំ អារោបេស្សាមិ សចេ មេ សម-ណោ គោតមោ តថា បតិដ្ឋហិស្សតិ យថា ភទន្តេន តបស្សិនា បតិដ្ឋាបិតំ សេយ្យថាបិ នាម ពលវា បុរិសោ ទីឃលោមិកំ ឯឡកំ លោមេសុ គហេត្វា អាកឌ្ឍេយ្យ បរិកឌ្ឍេយ្យ សម្បរិកឌ្ឍេយ្យ ឯវមេវាហំ សមណំ គោតមំ វាទេន វាទំ អាកឌ្ឍិស្សាមិ បរិកឌ្ឍិស្សាមិ សម្បរិកឌ្ឍិស្សាមិ សេយ្យថាបិ នាម ពលវា បុរិសោ(១) សោណ្ឌិកាកម្មការោ មហន្តំ សោណ្ឌិកាកិលញ្ជំ គម្ភីរេ ឧទករហទេ បក្ខិបិត្វា កណ្ណេ គហេត្វា អាកឌ្ឍេយ្យ បរិកឌ្ឍេយ្យ សម្បរិកឌ្ឍេយ្យ ឯវមេវាហំ សមណំ គោតមំ វាទេន វាទំ អាកឌ្ឍិស្សាមិ បរិកឌ្ឍិស្សាមិ សម្បរិកឌ្ឍិស្សាមិ សេយ្យថាបិ នាម ពលវា បុរិសោ(២) សោណ្ឌិកាធុត្តោ ថាលំ(៣) កណ្ណេ គហេត្វា ឱធុនេយ្យ និទ្ធុនេយ្យ និប្ផោដេយ្យ(៤) ឯវមេវាហំ

១-២ ឱ. ម. បុរិសោតិ ន ទិស្សតិ ។ ៣ ឱ. វាលំ ។ ៤ ឱ. និប្ផាទេយ្យ ។ ម. និប្ផោឌេយ្យ ។

បពិត្រលោកដ៏ចម្រើន ណ្ហើយចុះ ខ្ញុំនឹងទៅលើកឡើងនូវវាទៈ របស់ព្រះសមណគោតម ក្នុងកថាវត្ថុនេះ បើសមណគោតម នឹងតាំងពាក្យឲ្យនៅនឹងដូចដែលចំពោះខ្ញុំ ដូចកាលដែលតបស្សីដ៏ចម្រើនឲ្យតាំងនៅដូច្នោះ ខ្ញុំនឹងទាញកន្ត្រាក់គ្រវាត់គ្រវែង នូវវាទៈដោយវាទៈចំពោះសមណគោតម ដូចជាបុរសអ្នកមានកម្លាំង ចាប់សត្វចៀមដែលមានរោមវែង ត្រង់រោម ហើយទាញកន្ត្រាក់គ្រវាត់គ្រវែង ដូច្នោះឯង ពុំនោះខ្ញុំនឹងទាញកន្ត្រាក់គ្រវាត់គ្រវែង នូវវាទៈដោយវាទៈចំពោះសមណគោតម ដូចជាបុរសអ្នកមានកម្លាំង ជាអ្នកធ្វើការងារក្នុងផ្ទះសុរា ដាក់ចុះកន្ទេលសម្រាប់ដាក់នូវម្សៅក្នុងផ្ទះធ្វើសុរាក្នុងអន្លង់ទឹកជ្រៅ ហើយចាប់ត្រង់ជាយទាញកន្ត្រាក់គ្រវាត់គ្រវែងដូច្នោះឯង ពុំនោះខ្ញុំនឹងផ្កាប់ចុះផ្ងារឡើង បោះចោលនូវវាទៈដោយវាទៈចំពោះសមណគោតម ដូចជាបុរសមានកម្លាំង ជាអ្នកលេងសុរាចាប់ថាសត្រង់កណ្ដាប់មាត់ ផ្កាប់ចុះផ្ងារឡើង បោះចោលដូច្នោះឯង

សមណំ គោតមំ វាទេន វាទំ ឱធុនិស្សាមិ និទ្ធុនិស្សាមិ និប្ផោថេស្សាមិ[១] សេយ្យថាបិ នាម កុញ្ជរោ សដ្ឋិហាយនោ គម្ភីរំ បោក្ខរណឹ ឱគាហេត្វា សាណធោវិកំ[២] នាម កីឡិតជាតំ កីឡតិ ឯវមេវាហំ សមណំ គោតមំ សាណធោវិកំ[៣] មញ្ញេ កីឡិតជាតំ កីឡិស្សាមិ ហន្ទ ចាហំ ភន្តេ គច្ឆាមិ សមណស្ស គោតមស្ស ឥមស្មឹ កថាវត្ថុស្មឹ វាទំ អារោបេស្សាមីតិ ។ គច្ឆ ត្វំ គហបតិ សមណស្ស គោតមស្ស ឥមស្មឹ កថាវត្ថុស្មឹ វាទំ អារោបេហិ អហំ វា គហបតិ សមណស្ស គោតមស្ស វាទំ អារោបេយ្យំ ទីឃតបស្សី វា និគណ្ឋោ ត្វំ វាតិ ។

[៦៧] ឯវំ វុត្តេ ទីឃតបស្សី និគណ្ឋោ និគណ្ឋំ នាដបុត្តំ ឯតទវោច ន ខោ មេ តំ ភន្តេ រុច្ចតិ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស វាទំ អារោបេយ្យ សមណោ ហិ ភន្តេ គោតមោ មាយាវី អាវដ្ដនឹ មាយំ ជានាតិ

១ ឱ. និប្ផោទេស្សាមិ ។ ម. និប្ផោឌេស្សាមិ ។ ២-៣ ឱ. ម. សាណធោវីកំ ។

ពុំនោះសោត ខ្ញុំនឹងលេងនូវព្រះសមណគោតម ដូចគេលេងល្បែងលាងសម្បកធ្មៃ ដូចជាដំរីដែលមានអាយុ ៦០ ឆ្នាំ ចុះកាន់ស្រះដ៏ជ្រៅ ហើយលេងល្បែងលាងសម្បកធ្មៃ ដូច្នោះឯង បពិត្រលោកដ៏ចម្រើន ណ្ហើយចុះខ្ញុំនឹងទៅលើកឡើងនូវវាទៈ របស់ព្រះសមណគោតម ក្នុងកថាវត្ថុនេះ ។ ម្នាលគហបតី អ្នកចូរទៅលើកឡើងនូវវាទៈរបស់ព្រះសមណគោតមក្នុងកថាវត្ថុនេះ ម្នាលគហបតី ឬអាត្មាគប្បីលើកឡើងនូវវាទៈរបស់សមណគោតមក៏បាន ទីឃតបស្សីនិគ្រន្ថក៏បាន អ្នកឯងក៏បានដែរ ។

[៦៧] កាលបើនិគន្ថនាដបុត្ត និយាយយ៉ាងនេះហើយ ទើបទីឃតបស្សីនិគ្រន្ថនិយាយនឹងនិគន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតីគប្បីលើកឡើងនូវវាទៈ របស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនពេញចិត្តខ្ញុំឡើយ បពិត្រលោកដ៏ចម្រើន ព្រោះថា ព្រះសមណគោតមជាអ្នកមានកិច្ចកល តែងដឹងនូវកិច្ចកលសម្រាប់

យាយ អញ្ញតិត្ថិយានំ សាវកេ អាវដ្ដេតីតិ ។ អដ្ឋានំ ខោ ឯតំ តបស្សិ អនវកាសោ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគច្ឆេយ្យ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ សមណោ គោតមោ ឧបាលិស្ស គហបតិស្ស សាវកត្តំ ឧបគច្ឆេយ្យ គច្ឆ ត្វំ គហបតិ សមណស្ស គោតមស្ស ឥមស្មឹ កថាវត្ថុស្មឹ វាទំ អារោបេហិ អហំ វា[១] គហបតិ សមណស្ស គោតមស្ស វាទំ អារោបេយ្យំ ទីឃតបស្សី វា និគណ្ឋោ ត្វំ វាតិ ។ ទុតិយម្បិ ខោ ទីឃតបស្សី និគណ្ឋោ និគណ្ឋំ នាដបុត្តំ ឯតទវោច ន ខោ មេ តំ ភន្តេ រុច្ចតិ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស វាទំ អារោបេយ្យ សមណោ ហិ ភន្តេ គោតមោ មាយាវី អាវដ្ដនឹ មាយំ ជានាតិ យាយ អញ្ញតិត្ថិយានំ សាវកេ អាវដ្ដេតីតិ ។ អដ្ឋានំ ខោ ឯតំ តបស្សិ អនវកាសោ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគច្ឆេយ្យ

---

១ ឱ. ម. វាហិ ។

លោកប្រាស់ តែងលោកប្រាស់នូវពួកសាវ័ក របស់អន្យតិរ្ថិយ ។ និគន្ថ-នាដបុត្តនិយាយថា ម្នាលតបស្សី ឧបាលិគហបតីគប្បីចុះចូលជាសាវ័ករបស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំងមិនមែនជាឱកាសឡើយ ឯព្រះសមណគោតមគប្បីចុះចូលជាសាវ័ករបស់ឧបាលិគហបតី ដោយហេតុណា ហេតុនោះទើបជាទីតាំងមានមែន ម្នាលគហបតី អ្នកចូរទៅលើកឡើងនូវវាទៈ របស់ព្រះសមណ-គោតម ក្នុងកថាវត្ថុនោះចុះ ម្នាលគហបតី ឬអាត្មាគប្បីលើកឡើងនូវវាទៈ របស់ព្រះសមណគោតមក៏បាន ទីឃតបស្សីនិគ្រន្ថក៏បាន អ្នកឯងក៏បាន ។ ទីឃតបស្សីនិគ្រន្ថនិយាយនឹងនិគន្ថនាដបុត្តដូច្នេះ ជាគម្រប់ពីរដងទៀតថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតីគប្បីលើកឡើងនូវវាទៈរបស់ព្រះសមណគោតម ដោយហេតុណា ហេតុនោះមិនពេញចិត្តខ្ញុំទេ បពិត្រលោកដ៏ចម្រើន ព្រោះថាព្រះសមណគោតម ជាអ្នកមានកិច្ចកល តែងដឹងនូវកិច្ចកលសម្រាប់លោកប្រាស់ តែងលោកប្រាស់នូវពួកសាវ័កអន្យតិរ្ថិយ ។ ម្នាលតបស្សី ឧបាលិគហបតីគប្បីចុះចូលជាសាវ័ករបស់សមណគោតម ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង

ហន្ទញ្ច ខោ ឯតំ វិជ្ជតិ យំ សមណោ គោតមោ ឧបាលិស្ស គហបតិស្ស សាវកត្តំ ឧបគច្ឆេយ្យ គច្ឆ ត្វំ គហបតិ សមណស្ស គោតមស្ស ឥមស្មឹ កថាវត្ថុស្មឹ វាទំ អារោបេហិ អហំ វា[១] គហបតិ សមណស្ស គោតមស្ស វាទំ អារោបេយ្យំ ទីឃតបស្សី វា និគណ្ឋោ ត្វំ វាតិ ។ តតិយម្បិ ខោ ទីឃតបស្សី និគណ្ឋោ និគណ្ឋំ នាដបុត្តំ ឯតទវោច ន ខោ មេ តំ ភន្តេ រុច្ចតិ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស វាទំ អារោបេយ្យ សមណោ ហិ ភន្តេ គោតមោ មាយាវី អាវដ្ដនឹ មាយំ ជានាតិ យាយ អញ្ញតិត្ថិយានំ សាវកេ អាវដ្ដេតីតិ ។ អដ្ឋានំ ខោ ឯតំ តបស្សិ អនវកាសោ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគច្ឆេយ្យ ហន្ទញ្ច ខោ ឯតំ វិជ្ជតិ យំ សមណោ គោតមោ ឧបាលិស្ស គហបតិស្ស សាវកត្តំ ឧបគច្ឆេយ្យ គច្ឆ ត្វំ គហបតិ សមណស្ស គោតមស្ស ឥមស្មឹ កថាវត្ថុស្មឹ វាទំ អារោបេហិ អហំ វា[២] គហបតិ

១ ឱ. ម. វា ហិ ។ ២ ឱ. ម. វា ហិ ។

មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលជាសាវ័ក របស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះ ទើបជាទីតាំង មានមែន ម្នាលគហបតី អ្នកចូរទៅលើកឡើងនូវវាទៈ របស់ព្រះ សមណគោតម ក្នុងកថាវត្ថុនេះចុះ ម្នាលគហបតី ឬអាត្មាគប្បីលើក ឡើងនូវវាទៈ របស់ព្រះសមណគោតមក៏បាន ទីឃតបស្សីនិគ្រន្ថក៏បាន អ្នកឯងក៏បាន ។ ទីឃតបស្សីនិគ្រន្ថ និយាយនឹងនិគន្ថនាដបុត្តដូច្នេះជា គម្រប់ ៣ ដងទៀតថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតីគប្បីលើក ឡើងនូវវាទៈ របស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះ មិនពេញចិត្តខ្ញុំទេ បពិត្រលោកដ៏ចម្រើន ព្រោះថាព្រះសមណគោតមជា អ្នកមានកិច្ចកល តែងដឹងនូវកិច្ចកលសម្រាប់បោកប្រាស់ តែងបោកប្រាស់ នូវពួកសាវ័ករបស់អន្យតិរ្ថិយ ។ ម្នាលតបស្សី ឧបាលិគហបតី គប្បី ចុះចូលជាសាវ័ក របស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះ មិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បី ចុះចូលជាសាវ័ករបស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះ ទើបជាទីតាំងមានមែន ម្នាលគហបតី អ្នកចូរទៅលើកឡើងនូវវាទៈ របស់ព្រះសមណគោតម ក្នុងកថាវត្ថុនេះចុះ ម្នាលគហបតី ឬអាត្មា

សមណស្ស គោតមស្ស វាទំ អារោបេយ្យំ ទីឃតបស្សី វា និគណ្ឋោ ត្វំ វាតិ ។

[៦៨] ឯវំ ភន្តេតិ ខោ ឧបាលិ គហបតិ និគណ្ឋស្ស នាដបុត្តស្ស បដិស្សុត្វា ឧដ្ឋាយាសនា និគណ្ឋំ នាដបុត្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន ចាវារិកម្ពវនំ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧបាលិ គហបតិ ភគវន្តំ ឯតទវោច អាគមា នុ ខ្វិធ ភន្តេ ទីឃតបស្សី និគណ្ឋោតិ ។ អហុ បន[1] តេ ភន្តេ ទីឃតបស្សិនា និគណ្ឋេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ អហុ ខោ មេ គហបតិ ទីឃតបស្សិនា និគណ្ឋេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ យថាកថំ បន តេ ភន្តេ

១ ម. អហុ ខោ បន ។

គប្បីលើកឡើងនូវវាទៈ របស់ព្រះសមណគោតម ក៏បាន ទីឃតបស្សិនិគ្រន្ថក៏បាន អ្នកឯងក៏បាន ។

[៦៨] ឧបាលិគហបតី ទទួលពាក្យរបស់និគន្ថនាដបុត្តថា អើ លោកម្ចាស់ ហើយក្រោកចាកទីអង្គុយ សំពះនិគន្ថនាដបុត្តធ្វើប្រទក្សិណ ហើយចូលទៅរកព្រះមានព្រះភាគ ក្នុងបាវារិកម្ពវ័ន លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះឧបាលិគហបតី អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទីឃតបស្សីនិគ្រន្ថ បានមកក្នុងទីនេះឬទេ ។ ម្នាលគហបតី ទីឃតបស្សីនិគ្រន្ថ បានមកក្នុងទីនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គមានកថាសល្លាបៈបន្តិចបន្តួច ជាមួយនឹងទីឃតបស្សីនិគ្រន្ថដែរឬ ។ ម្នាលគហបតី តថាគតមានកថាសល្លាបៈបន្តិចបន្តួច ជាមួយនឹងទីឃតបស្សីនិគ្រន្ថដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន

អហុ ទីឃតបស្សិនា និគណ្ឋេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ អថខោ ភគវា យាវតកោ អហោសិ ទីឃតបស្សិនា និគណ្ឋេន សទ្ធឹ កថាសល្លាបោ តំ សព្វំ ឧបាលិស្ស គហបតិស្ស អារោចេសីតិ[១] ។ ឯវំ វុត្តេ ឧបាលិ គហបតិ ភគវន្តំ ឯតទវោច សាធុ សាធុ ភន្តេ ទីឃតបស្សី យថា តំ សុតវតា សាវកេន សម្មទេវ សត្ថុ សាសនំ អាជានន្តេន ឯវមេវ ទីឃតបស្សិនា និគណ្ឋេន ភគវតោ ព្យាកតំ កិញ្ហិ សោភតិ ឆវោ មនោទណ្ឌោ ឥមស្ស ឯវំ ឱឡារិកស្ស កាយទណ្ឌស្ស ឧបនិធាយ អថខោ កាយទណ្ឌោវ មហាសាវជ្ជតរោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា នោ តថា វចីទណ្ឌោ នោ តថា មនោទណ្ឌោតិ ។ សចេ ខោ ត្វំ គហបតិ សច្ចេ បតិដ្ឋាយ មន្តេយ្យាសិ សិយា នោ ឯត្ថ កថាសល្លាបោតិ ។ សច្ចេ អហំ ភន្តេ បតិដ្ឋាយ មន្តេស្សាមិ ហោតុ នោ ឯត្ថ កថាសល្លាបោតិ ។

១ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។

ចុះព្រះអង្គមានកថាសល្លាបៈបន្តិចបន្តួច ជាមួយនឹងទីឃតបស្សីនិគ្រន្ថ ដូចម្តេច ។ ទើបព្រះមានព្រះភាគ ទ្រង់រៀបរាប់កថាសល្លាបៈ ជាមួយនឹងទីឃតបស្សីនិគ្រន្ថទាំងអស់នោះ ប្រាប់ដល់ឧបាលិគហបតី ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ទើបឧបាលិគហបតីក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ទីឃតបស្សីនិគ្រន្ថ និយាយពាក្យនេះពីរោះណាស់ ៗ សាវ័កដែលជាអ្នកចេះដឹងអាចដឹងច្បាស់នូវសាសនា របស់គ្រូដោយប្រពៃ ហើយព្យាករពាក្យនោះ យ៉ាងណា ទីឃតបស្សីនិគ្រន្ថ ព្យាករ ចំពោះព្រះមានព្រះភាគយ៉ាងនោះដែរ មនោទណ្ឌៈជាសភាវៈថោកថយ យកមកប្រៀបធៀបនឹងកាយទណ្ឌៈដ៏ថ្លៃថ្លានេះ ឲ្យវិសេសវិសាលជាងយ៉ាងនេះ ដូចម្តេចបាន គឺកាយទណ្ឌៈហ្នឹងឯងជាសភាវៈមានទោសធំជាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈនិងមនោទណ្ឌៈនឹងមានទោសធំដូច្នោះក៏ទេ ។ ម្នាលគហបតី បើអ្នកឯងគប្បីឋិតនៅក្នុងពាក្យសច្ចៈហើយប្រឹក្សាគ្នា កថាសល្លាបៈរបស់យើង គប្បីមានក្នុងហេតុនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឋិតនៅក្នុងពាក្យសច្ចៈ ប្រឹក្សាគ្នា កថាសល្លាបៈរបស់យើង ចូរមានក្នុងដំណើរនេះ ។

[៦៩] តំ កឹ មញ្ញសិ គហបតិ ឥធស្ស និគណ្ឋោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សីតោទក-ប្បដិក្ខិត្តោ ឧណ្ហោទកប្បដិសេវី សោ សីតោទកំ អលភមានោ កាលំ ករេយ្យ ឥមស្ស បន គហបតិ និគណ្ឋោ នាដបុត្តោ កត្ថុបបត្តឹ[១] បញ្ញាបេតីតិ ។ អត្ថិ ភន្តេ មនោសត្តា នាម ទេវា តត្ថ សោ ឧប្បជ្ជតិ តំ កិស្ស ហេតុ អសុ[២] ហិ ភន្តេ មនោបដិពទ្ធោ កាលំ ករោតីតិ ។ គហបតិ គហបតិ មនសិករោហិ[៣] មនសិករិត្វា ខោ ត្វំ[៤] គហបតិ ព្យាករោហិ ន ខោ តេ សន្ធិយតិ បុរិមេន វា បច្ឆិមំ បច្ឆិមេន វា បុរិមំ ភាសិតា ខោ បន តេ គហបតិ ឯសា វាចា សច្ចេ អហំ ភន្តេ បតិដ្ឋាយ មន្តេស្សាមិ ហោតុ នោ ឯត្ថ កថាសល្លាបោតិ ។ កិញ្ចាបិ ភន្តេ ភគវា ឯវមាហ

---

១ ឱ. កត្ថូបបត្តឹ ។ ២ ម. អមុ ។ ៣ ឱ. មនសិករោហីតិ ន ទិស្សតិ ។ ៤ ឱ. ត្វន្តិ នត្ថិ ។

[៦៩] ម្នាលគហបតី អ្នកសំគាល់នូវហេតុនោះ ថាដូចម្តេច និគ្រន្ថក្នុងលោកនេះ មានអាពាធ មានទុក្ខ មានជំងឺធ្ងន់ ហាមបង់ទឹកត្រជាក់[១] ប្រើប្រាស់តែទឹកក្តៅ កាលបើនិគ្រន្ថនោះ មិនបានទឹកត្រជាក់ ក៏ធ្វើមរណកាលទៅ ម្នាលគហបតី និគន្ថនាដបុត្ត បញ្ញត្តនូវកំណើតរបស់និគ្រន្ថនេះ ក្នុងភពណា ។ បពិត្រព្រះអង្គដ៏ចម្រើន មានពួកទេវតាឈ្មោះមនោសត្ត[២] ឯនិគ្រន្ថនោះក៏ទៅកើតក្នុងពួកទេវតានោះ សេចក្តីនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថានិគ្រន្ថនោះ ជាអ្នកជាប់ចំពាក់ក្នុងចិត្តធ្វើមរណកាលទៅ ។ ម្នាលគហបតី គហបតី អ្នកចូរធ្វើទុកក្នុងចិត្តចុះ ម្នាលគហបតី លុះអ្នកធ្វើទុកក្នុងចិត្ត ព្យាករចុះ (តែថា) ពាក្យចុងរបស់អ្នកមិនតគ្នានឹងពាក្យដើម ឬពាក្យដើមមិនតគ្នានឹងពាក្យចុងសោះឡើយ ម្នាលគហបតី ពាក្យនេះដែលអ្នកនិយាយហើយ ជាពិតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឋិតនៅ ក្នុងពាក្យសច្ចៈ ហើយប្រឹក្សាគ្នា កថាសល្លាបៈរបស់យើង ចូរមានក្នុងដំណើរនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះក៏ពិតមែន

---

១ និគ្រន្ថឃាត់បង់ទឹកត្រជាក់ ព្រោះសំគាល់ថាជាសត្វ អដ្ឋកថា ។ ២ ទេវតាជាប់នៅក្នុងចិត្ត ។

អថខោ កាយឧណ្ហោ វ មហាសាវជ្ជតរោ ចាបស្ស កម្មស្ស កិរិយាយ ចាបស្ស កម្មស្ស បវត្តិយា នោ តថា វចីឧណ្ហោ នោ តថា មនោឧណ្ហោតិ ។

[៧០] តំ កឹ មញ្ញសិ គហបតិ ឥធស្ស និគណ្ឋោ ចាតុយាមសំវរសំវុតោ សព្វភារិភារិតោ សព្វ-ភារិយុត្តោ សព្វភារិធុតោ សព្វភារិផុដ្ឋោ[១] សោ អភិក្កមន្តោ បដិក្កមន្តោ ពហុ ខុទ្ទកេ ចាណេ សង្ឃាដំ[២] អាចាទេតិ ឥមស្ស បន គហបតិ និគណ្ឋោ នាដបុត្តោ កឹ[៣] វិចាកំ បញ្ញាបេតីតិ ។ អសញ្ចេតនិកំ ភន្តេ និគណ្ឋោ នាដបុត្តោ នោ មហាសា-វជ្ជំ បញ្ញាបេតីតិ ។ សចេ បន គហបតិ ចេតេតីតិ ។

១ ឱ. ម. សព្វភារិផុដោ ។ ២ ឱ. ម. សង្ឃាតំ ។ ៣ ឱ. ម. កំ ។

តែថាកាយទណ្ឌៈហ្នឹងឯង មានទោសធំជាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈនិងមនោទណ្ឌៈ នឹងមានទោសធំដូច្នោះក៏ទេ ។

[៧០] ម្នាលគហបតី អ្នកសំគាល់ហេតុនោះថាដូចម្ដេច និគ្រន្ថក្នុងលោកនេះ សង្រួម ដោយការសង្រួម ៤ ចំណែក[១] ហាមឃាត់ដោយការហាមឃាត់បាបទាំងអស់ ប្រកបដោយការហាមឃាត់បាបទាំងអស់ ជាអ្នកកម្ចាត់បាប ដោយការហាមបាបទាំងអស់ ជាអ្នកប៉ះពាល់ ដោយការហាមឃាត់បាបទាំងអស់ និគ្រន្ថនោះកាលដែលដើរឈានទៅមុខឈានថយ ក៏ញុាំងសត្វតូច ៗ ជាច្រើន ឲ្យដល់នូវសេចក្តីវិនាស ម្នាលគហបតី និគន្ថនាដបុត្ត បញ្ញត្តនូវវិបាកនៃកម្មនេះដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន និគន្ថនាដបុត្ត មិនបញ្ញត្តនូវកម្មដែលមិនមានចេតនាថាមានទោសធំទេ ។ ម្នាលគហបតី ចុះបើបុគ្គលមានចេតនាវិញ ។

១ គឺមិនសម្លាប់ដោយខ្លួនឯង មិនប្រើគេឲ្យសម្លាប់ មិនត្រេកអរនឹងអ្នកសម្លាប់ ១ មិនលួចដោយខ្លួនឯង មិនប្រើគេឲ្យលួច មិនត្រេកអរនឹងអ្នកលួច ១ មិននិយាយកុហកដោយខ្លួនឯង មិនប្រើគេឲ្យនិយាយកុហក មិនត្រេកអរនឹងអ្នកនិយាយកុហក ១ មិនប្រាថ្នាបញ្ចកាមគុណដោយខ្លួនឯង មិនប្រើគេឲ្យប្រាថ្នាបញ្ចកាមគុណ មិនត្រេកអរនឹងអ្នកប្រាថ្នាបញ្ចកាមគុណ ១ ។ រួមជាចំណែក ៤ ។ អដ្ឋកថា ។

គហបតិវគ្គស្ស ឧបាលិវាទសុត្តេ បដិបុច្ឆិតប្បញ្ហា

មហាសាវជ្ជំ ភន្តេ ហោតីតិ ។ ចេតនំ បន គហបតិ និគណ្ឋោ នាដបុត្តោ កិស្មឹ បញ្ញាបេតីតិ ។ មនោទណ្ឌស្មឹ បន ភន្តេតិ ។ គហបតិ គហបតិ មនសិករោហិ មនសិករិត្វា ខោ គហបតិ ព្យាករោហិ ន ខោ តេ សន្ធិយតិ បុរិមេន វា បច្ឆិមំ បច្ឆិមេន វា បុរិមំ ភាសិតា ខោ បន តេ គហបតិ ឯសា វាចា សច្ចេ អហំ ភន្តេ បតិដ្ឋាយ មន្តេស្សាមិ ហោតុ ន ឯត្ថ កថាសល្លាបោតិ ។ កិញ្ចាបិ ភន្តេ ភគវា ឯវមាហ អថខោ កាយ-ទណ្ឌោ វ មហាសាវជ្ជតរោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា នោ តថា វចីទណ្ឌោ នោ តថា មនោទណ្ឌោតិ ។ តំ កឹ មញ្ញសិ គហបតិ អយំ នាឡន្ទា ឥទ្ធា ចេវ ផីតា ច ពហុជនា អាកិណ្ណមនុស្សាតិ ។ ឯវំ ភន្តេ អយំ នាឡន្ទា ឥទ្ធា ចេវ ផីតា ច ពហុជនា អាកិណ្ណមនុស្សាតិ ។ តំ កឹ មញ្ញសិ គហបតិ ឥធ បុរិសោ អាគច្ឆេយ្យ ឧក្ខិត្តាសិកោ សោ

បពិត្រព្រះអង្គដ៏ចម្រើន កម្មនោះមានទោសធំ ។ ម្នាលគហបតី ចុះនិគន្ថ-នាដបុត្ត បញ្ញត្តនូវចេតនាក្នុងចំណែកណា ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងមនោទណ្ឌៈ ។ ម្នាលគហបតី អ្នកចូរធ្វើទុកក្នុងចិត្តចុះ ម្នាលគហបតី លុះអ្នកធ្វើទុកក្នុងចិត្តហើយ ចូរព្យាករចុះ (តែថា) ពាក្យចុងរបស់អ្នកមិនតគ្នានឹងពាក្យដើម ឬពាក្យដើមមិនតគ្នានឹងពាក្យចុងសោះឡើយ ម្នាលគហ-បតី ពាក្យនេះដែលអ្នកនិយាយជាពិតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឋិតនៅក្នុងពាក្យសច្ចៈប្រឹក្សាគ្នា កថាសល្លាបៈរបស់យើងចូរមានក្នុងដំណើរនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះក៏ពិតមែនហើយ តែថាកាយទណ្ឌៈហ្នឹងឯង នៅតែមានទោសធំជាង់ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈនិងមនោទណ្ឌៈនឹងមានទោសធំដូច្នោះក៏ទេ ។ ម្នាលគហបតី អ្នកសំគាល់នូវហេតុនោះថាដូចម្តេច ស្រុកនាលន្ទានេះស្តុកស្តម្ភមាំមួនផង ទូលាយផង មានជនច្រើន មានមនុស្សកុះករផង មែនឬទេ ។ ព្រះករុណាព្រះអង្គ ស្រុកនាលន្ទានេះស្តុកស្តម្ភមាំមួនផង ទូលាយផង មានជនច្រើន មានមនុស្សកុះករផងមែន ។ ម្នាលគហបតី អ្នកសំគាល់នូវហេតុនោះថាដូចម្តេច មានបុរសម្នាក់ ផ្គាដាវដើរមកក្នុងស្រុកនាលន្ទានេះ បុរសនោះ

ឯវំ វទេយ្យ អហំ យាវតិកា ឥមិស្សា នាឡន្ទាយ បាណា តេ ឯកេន ខណេន ឯកេន មុហុត្តេន ឯកមំសខលំ ឯកមំសបុញ្ជំ ករិស្សាមីតិ ។ តំ កឹ មញ្ញសិ គហបតិ បហោតិ នុ ខោ សោ បុរិសោ យាវតិកា ឥមិស្សា នាឡន្ទាយ បាណា តេ ឯកេន ខណេន ឯកេន មុហុត្តេន ឯកមំសខលំ ឯកមំសបុញ្ជំ កាតុន្តិ ។ ទសបិ ភន្តេ បុរិសា វីសម្បិ ភន្តេ[១] បុរិសា តឹសម្បិ ភន្តេ[២] បុរិសា ចត្តាឡីសម្បិ ភន្តេ[៣] បុរិសា បញ្ញាសម្បិ ភន្តេ[៤] បុរិសា នប្បហោន្តិ យាវតិកា ឥមិស្សា នាឡន្ទាយ បាណា តេ ឯកេន ខណេន ឯកេន មុហុត្តេន ឯកមំសខលំ ឯកមំសបុញ្ជំ កាតុំ កិញ្ហិ សោភតិ ឯកោ ឆវោ បុរិសោតិ ។ តំ កឹ មញ្ញសិ គហបតិ ឥធាគច្ឆេយ្យ សមណោ វា ព្រាហ្មណោ វា ឥទ្ធិមា ចេតោវសិប្បត្តោ សោ ឯវំ វទេយ្យ អហំ ឥមំ នាឡន្ទំ ឯកេន មនោបទោសេន ភស្មំ ករិស្សាមីតិ ។

---

១- ២- ៣- ៤- ឱ. ឥមេ ភន្តេតិ សទ្ទា ន ទិស្សន្តិ ។

និយាយយ៉ាងនេះថា សត្វទាំងឡាយក្នុងស្រុកនាលន្ទានេះមានចំនួនប៉ុន្មាន អាត្មាអញនឹងធ្វើសត្វទាំងនោះ ឲ្យជាលាននៃសាច់តែមួយ ឲ្យជាគំនរនៃសាច់តែមួយ តែមួយរំពេច តែមួយស្របក់ប៉ុណ្ណោះ ។ ម្នាលគហបតី អ្នកសំគាល់ហេតុនោះថា ដូចម្តេច បុរសនោះអាចនឹងធ្វើសត្វទាំងឡាយក្នុងក្រុងនាលន្ទានេះ មានចំនួនប៉ុន្មាននោះ ឲ្យជាលាននៃសាច់តែមួយ ឲ្យជាគំនរនៃសាច់តែមួយ តែមួយរំពេច តែមួយស្របក់ប៉ុណ្ណោះបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០ នាក់ក្តី បុរស ៥០ នាក់ក្តី ក៏មិនអាចនឹងធ្វើសត្វ ក្នុងស្រុកនាលន្ទានេះ ទាំងអម្បាលម៉ាននោះ ឲ្យជាលាននៃសាច់តែមួយ ឲ្យជាគំនរនៃសាច់តែមួយ តែមួយរំពេច តែមួយស្របក់បានឡើយ ចំណង់បើបុរសកម្សោយតែម្នាក់ នឹងអាចធ្វើឲ្យវិសេសវិសាល ដូចម្តេចបាន ។ ម្នាលគហបតី អ្នកសំគាល់ហេតុនោះថា ដូចម្តេច បុគ្គលជាសមណៈ ឬព្រាហ្មណ៍ ជាអ្នកមានឫទ្ធិ ដល់នូវសេចក្តីស្ទាត់ជំនាញ ក្នុងចិត្ត ដើរមកក្នុងស្រុកនាលន្ទានេះ បុគ្គលនោះ និយាយយ៉ាងនេះថា អញនឹងធ្វើស្រុកនាលន្ទានេះ ឲ្យទៅជាផេះ ដោយចិត្តប្រទូស្តតែម្តង ។

តំ កឹំ មញ្ញសិ គហបតិ បហោតិ នុ ខោ សោ សមណោ វា ព្រាហ្មណោ វា ឥទ្ធិមា ចេតោវសិប្បត្តោ ឥមំ នាឡន្ទំ ឯកេន មនោបទោសេន ភស្មំ កាតុន្តិ ។ ទសបិ ភន្តេ នាឡន្ទា វីសម្បិ ភន្តេ នាឡន្ទា តឹសម្បិ ភន្តេ នាឡន្ទា ចត្តាឡីសម្បិ ភន្តេ នាឡន្ទា បញ្ញាសម្បិ ភន្តេ នាឡន្ទា បហោតិ សោ សមណោ វា ព្រាហ្មណោ វា ឥទ្ធិមា ចេតោវសិប្បត្តោ ឥមំ នាឡន្ទំ ឯកេន មនោបទោសេន ភស្មំ កាតុំ កិញ្ហិ សោភតិ ឯកា ឆវា នាឡន្ទាតិ ។ គហបតិ គហបតិ[១] មនសិករោហិ មនសិករិត្វា ខោ ត្វំ គហបតិ ព្យាករោហិ ន ខោ តេ សន្ធិយតិ បុរិមេន វា បច្ឆិមំ បច្ឆិមេន វា បុរិមំ ភាសិតា ខោ បន តេ គហបតិ ឯសា វាចា សច្ចេ អហំ ភន្តេ បតិដ្ឋាយ មន្តេស្សាមិ ហោតុ នោ ឯត្ថ កថាសល្លាបោតិ ។ កិញ្ចាបិ ភន្តេ ភគវា ឯវមាហ អថខោ កាយទណ្ឌោ វ មហាសាវជ្ជតរោ បាបស្ស កម្មស្ស កិរិយាយ បាបស្ស កម្មស្ស បវត្តិយា

១ ម. តេនហិ គហបតិ ។

ម្នាលគហបតី អ្នកសំគាល់ហេតុនោះថា ដូចម្តេច បុគ្គលជាសមណៈ ឬព្រាហ្មណ៍ជាអ្នកមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញក្នុងចិត្តនោះ អាចនឹងធ្វើស្រុកនាលន្ទានេះ ឲ្យទៅជាផេះ ដោយចិត្តប្រទូស្តតែម្តងបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ស្រុកនាលន្ទា ១០ ក្តី ស្រុកនាលន្ទា ២០ ក្តី ស្រុកនាលន្ទា ៣០ ក្តី ស្រុកនាលន្ទា ៤០ ក្តី ស្រុកនាលន្ទា ៥០ ក្តី ក៏បុគ្គលជាសមណៈឬព្រាហ្មណ៍ជាអ្នកមានឫទ្ធិ ដល់នូវសេចក្តីស្ទាត់ក្នុងចិត្តនោះ អាចដើម្បីធ្វើស្រុកនាលន្ទានេះ ឲ្យទៅជាផេះ ដោយចិត្តប្រទូស្តតែម្តងបាន ដ្បិតស្រុកនាលន្ទាតូចមួយនឹងអាចទប់ទល់ដូចម្តេចបាន ។ ម្នាលគហបតី ៗ អ្នកចូរធ្វើទុកក្នុងចិត្តចុះ ម្នាលគហបតី លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ព្យាករចុះ ពាក្យចុងរបស់អ្នកមិនតគ្នានឹងពាក្យដើម ឬពាក្យដើមមិនតគ្នានឹងពាក្យចុងសោះឡើយ ម្នាលគហបតី វាចានេះអ្នកបាននិយាយរួចហើយថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងតាំងនៅក្នុងពាក្យសច្ចៈ ហើយប្រឹក្សាគ្នា កថាសល្លាបៈរបស់យើង សូមមានក្នុងដំណើរនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះពិតមែនហើយ តែថា កាយទណ្ឌៈហ្នឹងឯង ក៏នៅតែមានទោសធំជាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម

នោ តថា វចីទណ្ឌោ នោ តថា មនោទណ្ឌោតិ ។ តំ កឹ មញ្ញសិ គហបតិ សុតន្តេ ទណ្ឌកីរញ្ញំ[១] កាលិង្គារញ្ញំ មេជ្ឈារញ្ញំ[២] មាតង្គារញ្ញំ អរញ្ញំ អរញ្ញភូតន្តិ ។ ឯវំ ភន្តេ សុតំ មេ ទណ្ឌកីរញ្ញំ កាលិង្គារញ្ញំ មេជ្ឈារញ្ញំ មាតង្គារញ្ញំ អរញ្ញំ អរញ្ញភូតន្តិ ។ តំ កឹ មញ្ញសិ គហបតិ កិន្តិ តេ សុតំ កេន តំ ទណ្ឌកីរញ្ញំ កាលិង្គារញ្ញំ មេជ្ឈារញ្ញំ មាតង្គារញ្ញំ អរញ្ញំ អរញ្ញភូតន្តិ ។ សុតំ មេតំ ភន្តេ ឥសីនំ មនោបទោសេន តំ ទណ្ឌកីរញ្ញំ កាលិង្គារញ្ញំ មេជ្ឈារញ្ញំ មាតង្គារញ្ញំ អរញ្ញំ អរញ្ញភូតន្តិ ។ គហបតិ គហបតិ មនសិករោហិ មនសិករិត្វា ខោ ត្វំ គហបតិ ព្យាករោហិ ន ខោ តេ សន្ធិយតិ បុរិមេន វា បច្ឆិមំ បច្ឆិមេន វា បុរិមំ ភាសិតា ខោ បន តេ គហបតិ ឯសា វាចា សច្ចេ អហំ ភន្តេ បតិដ្ឋាយ មន្តេស្សាមិ ហោតុ នោ ឯត្ថ កថាសល្លាបោតិ ។

១ ឱ. ទណ្ឌការញ្ញំ ។ ២ ម. មជ្ឈារញ្ញំ ។

*ឯវចីទណ្ឌៈ និងមនោទណ្ឌៈ នឹងមានទោសដូច្នោះក៏ទេ ។ ម្នាលគហបតី អ្នកសំគាល់ហេតុនោះថា ដូចម្តេច អ្នកបានឮថា ព្រៃទណ្ឌកី[១] ព្រៃកាលិង្គៈ[២] ព្រៃមេជ្ឈា[៣] និងព្រៃមាតង្គៈ[៤] ជាព្រៃទទេ ជាព្រៃសុទ្ធឬទេ ។ ព្រះករុណាព្រះអង្គ ខ្ញុំព្រះអង្គបានឮថាព្រៃទណ្ឌកី ព្រៃកាលិង្គៈ ព្រៃមេជ្ឈានិងព្រៃមាតង្គៈ ជាព្រៃទទេ ជាព្រៃសុទ្ធ ។ ម្នាលគហបតី អ្នកសំគាល់ហេតុនោះ ថាដូចម្តេច អ្នកបានឮដូចម្តេច ព្រៃទណ្ឌកី ព្រៃកាលិង្គៈ ព្រៃមេជ្ឈានិងព្រៃមាតង្គៈនោះ ជាព្រៃទទេ ជាព្រៃសុទ្ធ ដោយហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គឮមកថា ព្រៃទណ្ឌកី ព្រៃកាលិង្គៈ ព្រៃមេជ្ឈានិងព្រៃមាតង្គៈនោះ ជាព្រៃទទេ ជាព្រៃសុទ្ធ ព្រោះចិត្តប្រទូស្តនឹងឥសី ។ ម្នាលគហបតី អ្នកចូរធ្វើទុកក្នុងចិត្តចុះ ម្នាលគហបតី លុះអ្នកធ្វើទុកក្នុងចិត្តហើយ ចូរព្យាករចុះ ពាក្យចុងរបស់អ្នក មិនតគ្នានឹងពាក្យដើម ពាក្យដើមមិនតគ្នានឹងពាក្យចុងសោះឡើយ ម្នាលគហបតី វាចានេះអ្នកបាននិយាយរួចហើយថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងតាំងនៅក្នុងពាក្យសច្ចៈប្រឹក្សាគ្នា កថាសល្លាបៈរបស់យើង ចូរមានក្នុងដំណើរនេះ ។*

---

១-២-៣-៤ អំពីដើមថាឈ្មោះដែន ទណ្ឌកី កាលិង្គៈ មេជ្ឈៈ និងមាតង្គៈ តែមនុស្សក្នុងដែនទាំងនោះស្លាប់វិនាសអស់ទៅ ព្រោះធ្វើចិត្តប្រទូស្តនឹងពួកឥសី ដែនទាំងនោះក៏ក្លាយទៅជាព្រៃ គេហៅថា ព្រៃទណ្ឌកី កាលិង្គៈ មេជ្ឈៈ និងមាតង្គៈដូច្នេះវិញ ។ អដ្ឋកថា ។

គហបតិវគ្គស្ស ឧបាលិវាទសុត្តេ បាណុបេតសរណគតតា

[៧១] បុរិមេនាហំ(១) ភន្តេ ឱបម្មេន ភគវតោ អត្តមនោ អភិរទ្ធោ អបិចាហំ ឥមានិ ភគវតោ វិចិត្តានិ បញ្ហាបដិភាណានិ(២) សោតុកាមោ ឯវាហំ ភគវន្តំ បច្ចនីកាតព្វំ អមញ្ញិស្សំ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ(៣) ។

---

១ ឱ. បុរិមេនេវាហន្តិ ទិស្សតិ ។ ២ ឱ. ម. វិចិត្រានិ បញ្ហបដិភានានិ ។ ៣ ឱ. បាណុបេតំ សរណគតន្តិ ។

គហបតិវគ្គ ឧបាលិវាទសូត្រ ការដល់នូវសរណៈស្មើដោយជីវិត

[៧១] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រេកអររីករាយ ដោយពាក្យឧបមាខាងដើម របស់ព្រះមានព្រះភាគ តែថាខ្ញុំព្រះអង្គមានប្រាថ្នានឹងស្តាប់ នូវបញ្ហាព្យាករណ៍ដ៏វិចិត្តនេះ របស់ព្រះមានព្រះភាគ កាលពីដើមខ្ញុំព្រះអង្គបានសំគាល់ នូវព្រះមានព្រះភាគ ថាជាបុគ្គលគួរធ្វើឲ្យជាសត្រូវយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគសំដែងហើយ ដោយអនេកបរិយាយ ភ្លឺច្បាស់ណាស់ ដូចជាបុរសបើករបស់ ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ឬក៏ដូចជាបុរសបើកបង្ហាញរបស់ ដែលលាក់បិទបាំង ពុំនោះដូចជាបុរសប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោតដូចជាមនុស្សកាន់ប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សមានចក្ខុតែងមើលរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរណគមន៍ស្មើដោយជីវិតក្នុងថ្ងៃនេះជាដើម ។

[៧២] អនុវិច្ចការំ ខោ គហបតិ ករោហិ អនុវិច្ចការោ តុម្ហាទិសានំ ញាតមនុស្សានំ សាធុ ហោតីតិ ។ ឥមិនាបាហំ ភន្តេ ភគវតោ ភិយ្យោសោមត្តាយ អត្តមនោ អភិរទ្ធោ យំ មំ ភគវា ឯវមាហ អនុវិច្ចការំ ខោ គហបតិ ករោហិ អនុវិច្ចការោ តុម្ហាទិសានំ ញាតមនុស្សានំ សាធុ ហោតីតិ មំ ហិ ភន្តេ អញ្ញតិត្ថិយា សាវកំ លភិត្វា កេវលកប្បំ នាឡន្ទំ បដាកំ បរិហរេយ្យុំ ឧបាលិ អម្ហាកំ គហបតិ សាវកត្តំ ឧបគតោតិ[១] អថ ច បន មំ ភគវា ឯវមាហ អនុវិច្ចការំ ខោ គហបតិ ករោហិ អនុវិច្ចការោ ហិ[២] តុម្ហាទិសានំ ញាតមនុស្សានំ សាធុ ហោតីតិ ឯសាហំ ភន្តេ ទុតិយម្បិ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

---

១ ឱ. សាវកត្តូបគតោតិ ។ ២ ឱ. ម. ហិ សទ្ទោ នត្ថិ ។

[៧២] ម្នាលគហបតី អ្នកចូរធ្វើនូវការពិចារណារឿយ ៗ ចុះ ការពិចារណារឿយ ៗ របស់មនុស្ស ដែលគេស្គាល់ ប្រាកដដូចជាខ្លួនអ្នក ជាការប្រពៃពេក ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះ នឹងខ្ញុំព្រះអង្គថា ម្នាលគហបតី អ្នកចូរធ្វើនូវការពិចារណារឿយ ៗ ចុះ ការពិចារណារឿយ ៗ របស់មនុស្ស ដែលគេស្គាល់ប្រាកដដូចជាខ្លួនអ្នក ជាការប្រពៃពេកដូច្នេះ ដោយពាក្យណា ខ្ញុំព្រះអង្គមានចិត្តត្រេកអរ រីករាយហួសប្រមាណ ដោយពាក្យនេះ របស់ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន បើពួកអន្យតិរ្ថិយបានខ្ញុំព្រះអង្គជាសាវ័កហើយ គប្បីលើកឡើងនូវទង់សំពត់ ក្នុងស្រុកនាលន្ទាទាំងអស់ដោយអំណរថា ឧបាលិគហបតីចុះចូលមកជាសាវ័ករបស់ពួកយើងហើយ សមដូចព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះនឹងខ្ញុំព្រះអង្គថា ម្នាលគហបតី អ្នកចូរធ្វើនូវការពិចារណារឿយ ៗ ចុះ ដ្បិតការពិចារណារឿយ ៗ របស់មនុស្សដែលគេស្គាល់ប្រាកដ ដូចជាខ្លួនអ្នក ជាការប្រពៃពេក បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ជាគម្រប់ពីរដងផង សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសកអ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ក្នុងថ្ងៃនេះជាដើម ។

១១៣

គហបតិវគ្គស្ស ឧបាលិវាទសុត្តេ មហប្ផលាមហប្ផលតា

[៧៣] ទីឃរត្តំ ខោ តេ គហបតិ និគណ្ឋានំ ឱបានភូតំ កុលំ យេន តេសំ ឧបគតានំ បិណ្ឌកំ ទាតព្វំ មញ្ញេយ្យាសីតិ ។ ឥមិនាបាហំ ភន្តេ ភគវតោ ភិយ្យោសោ មត្តាយ អត្តមនោ អភិរទ្ធោ យំ មំ ភគវា ឯវមាហ ទីឃរត្តំ ខោ តេ គហបតិ និគណ្ឋានំ ឱបានភូតំ កុលំ យេន តេសំ ឧបគតានំ បិណ្ឌកំ ទាតព្វំ មញ្ញេយ្យាសីតិ សុតំ មេតំ ភន្តេ សមណោ គោតមោ ឯវមាហ មយ្ហមេវ ទានំ ទាតព្វំ នាញ្ញេសំ ទានំ ទាតព្វំ មយ្ហមេវ សាវកានំ ទានំ ទាតព្វំ នាញ្ញេសំ សាវកានំ ទានំ ទាតព្វំ មយ្ហមេវ ទិន្នំ មហប្ផលំ នាញ្ញេសំ ទិន្នំ មហប្ផលំ មយ្ហមេវ សាវកានំ ទិន្នំ មហប្ផលំ នាញ្ញេសំ សាវកានំ ទិន្នំ មហប្ផលន្តិ អថ ច បន មំ ភគវា

[៧៣] ម្នាលគហបតី អ្នកសំគាល់បិណ្ឌបាត ថាជារបស់គួរឲ្យដល់ពួកនិគ្រន្ថនោះ ដែលចូលមកក្នុងត្រកូលណា ត្រកូលនោះរបស់អ្នកតាំងនៅ ដូចជាអណ្តូងនៃពួកនិគ្រន្ថ ជាយូរអង្វែងមកហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះ នឹងខ្ញុំព្រះអង្គថា ម្នាលគហបតី អ្នកសំគាល់នូវបិណ្ឌបាត ថាជារបស់គួរឲ្យដល់ពួកនិគ្រន្ថនោះ ដែលចូលមកក្នុងត្រកូលណា ត្រកូលនោះរបស់អ្នកតាំងនៅ ដូចជាអណ្តូងនៃពួកនិគ្រន្ថ ជាយូរមកហើយ ដោយពាក្យណា ខ្ញុំព្រះអង្គមានចិត្តត្រេកអរ រីករាយហួសប្រមាណ ដោយពាក្យនេះ របស់ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឮពាក្យដូច្នេះថា ព្រះសមណគោតមសំដែងយ៉ាងនេះថា បុគ្គលគួរតែឲ្យទានដល់តថាគត មិនគួរឲ្យទានដល់ពួកជនដទៃឡើយ គួរតែឲ្យទានដល់ពួកសាវ័ករបស់តថាគត មិនគួរឲ្យទានដល់ពួកសាវ័ករបស់គ្រូដទៃឡើយ ទានដែលបុគ្គលឲ្យហើយដល់តថាគត ទើបមានផលច្រើន ទានដែលបុគ្គលឲ្យហើយដល់គ្រូដទៃ មិនមានផលច្រើនទេ ទានដែលបុគ្គលឲ្យដល់ពួកសាវ័ករបស់តថាគត ទើបមានផលច្រើន ទានដែលបុគ្គលឲ្យដល់ពួកសាវ័ករបស់គ្រូដទៃ មិនមានផលច្រើនទេ ក៏ប៉ុន្តែព្រះមានព្រះភាគ

និគន្ថេសុបិ ទានេ សមាទបេតិ អបិច ភន្តេ មយមេត្ថ កាលំ ជានិស្សាម ឯសាហំ ភន្តេ តតិយម្បិ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

[៧៤] អថខោ ភគវា ឧបាលិស្ស គហបតិស្ស អនុបុព្វិកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា ភគវា អញ្ញាសិ ឧបាលឹ គហបតឹ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ ឧបាលិស្ស គហបតិស្ស តស្មឹយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ

ទ្រង់ណែនាំខ្ញុំព្រះអង្គឲ្យធ្វើទានដល់ពួកនិគ្រន្ថដែរ បពិត្រព្រះអង្គដ៏ចម្រើន មួយយ៉ាងទៀត យើងនឹងដឹងនូវកាលគួរក្នុងដំណើរនេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ជាគម្រប់ ៣ ដងផង សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសកអ្នកដល់នូវសរណគមន៍ ស្មើដោយជីវិត ក្នុងថ្ងៃនេះជាដើម ។

[៧៤] គ្រានោះ ព្រះមានព្រះភាគ ទ្រង់សំដែងនូវអនុបុព្វីកថា គឺទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា និងទោសនៃកាមទាំង-ឡាយ ជាទោសដ៏លាមកសៅហ្មង និងអានិសង្សក្នុងការចេញចាកកាម ដល់ឧបាលិគហបតី ។ កាលដែលព្រះមានព្រះភាគ ទ្រង់ជ្រាបនូវឧបាលិគហបតីថា មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តខ្ពស់ឡើង មានចិត្តជ្រះថ្លា ក៏ព្រះអង្គទ្រង់សំដែងធម៌ទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែង ដោយព្រះអង្គឯង គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ។ ធម្មតាសំពត់ស្អាត ប្រាសចាកវត្ថុមានពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយល្អបាន មានឧបមាដូចម្តេចមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់ឧបាលិគហបតី ក្នុងកន្លែងអង្គុយ

យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ អថខោ ឧបាលិ គហបតិ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុ សាសនេ ភគវន្តំ ឯតទវោច ហន្ទ ចទានិ មយំ ភន្តេ គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ គហបតិ កាលំ មញ្ញសីតិ ។

[៧៨] អថខោ ឧបាលិ គហបតិ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន សកំ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា ទោវារិកំ អាមន្តេសិ អជ្ជតគ្គេ សម្ម ទោវារិក អាវរាមិ ទ្វារំ និគណ្ឋានំ និគណ្ឋីនំ អនាវដំ ទ្វារំ ភគវតោ សាវកានំ[១] ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ សចេ កោចិ និគណ្ឋោ អាគច្ឆតិ

១ ឱ. ម. សាវកានន្តិ ន ទិស្សតិ ។

នោះឯងថា ធម្មជាតណាទីមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ ក៏រលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។ គ្រានោះ ឧបាលិគហបតី បានឃើញអរិយសច្ចធម៌ហើយ បានដល់នូវអរិយសច្ចធម៌ហើយ បានដឹងច្បាស់នូវអរិយសច្ចធម៌ហើយ បានឈានចុះកាន់អរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្ដីសង្ស័យ មិនមានជឿងឆ្ងល់ ដល់នូវសេចក្ដីក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនា របស់ព្រះសាស្ដា ទើបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ណ្ហើយចុះ ខ្ញុំព្រះអង្គនឹងទៅក្នុងកាលឥឡូវនេះ ព្រោះខ្ញុំព្រះអង្គមានកិច្ចច្រើន មានការងារច្រើន ។ ម្នាលគហបតី អ្នកសំគាល់នូវកាលដ៏សមគួរនឹងទៅឥឡូវនេះចុះ ។

[៧៥] គ្រានោះ ឧបាលិគហបតី ក៏ត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ហើយធ្វើប្រទក្សិណ ដើរចូលទៅកាន់លំនៅរបស់ខ្លួន លុះចូលទៅដល់ហើយ ក៏ហៅអ្នករក្សាទ្វារមកប្រាប់ថា ម្នាលអ្នករក្សាទ្វារជាសំឡាញ់ ពីថ្ងៃនេះជាដើមរៀងទៅ ខ្ញុំបិទទ្វារចំពោះពួកនិគ្រន្ថប្រុសនិងពួកនិគ្រន្ថស្រី មិនបានបិទទ្វាររបស់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាជាសាវ័ក របស់ព្រះមានព្រះភាគ បើមាននិគ្រន្ថណាមួយ មកដល់

តមេនំ ត្វំ ឯវំ វទេយ្យាសិ តិដ្ឋ ភន្តេ មា បាវិសិ អជ្ជតគ្គេ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគតោ អាវដំ ទ្វារំ និគណ្ឋានំ និគណ្ឋីនំ អនាវដំ ទ្វារំ ភគវតោ សាវកានំ[១] ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ សចេ តេ[២] ភន្តេ បិណ្ឌកេន អត្ថោ ឯត្ថេវ តិដ្ឋ ឯត្ថេវ[៣] តេ[៤] អាហរិស្សន្តីតិ ។ ឯវំ ភន្តេតិ ខោ ទោវារិកោ ឧបាលិស្ស គហបតិស្ស បច្ចស្សោសិ ។

[៧៦] អស្សោសិ ខោ ទីឃតបស្សី និគណ្ឋោ ឧបាលិ កិរ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧប-គតោតិ ។ អថខោ ទីឃតបស្សី និគណ្ឋោ យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា និគណ្ឋំ នាដបុត្តំ ឯតទវោច សុតំ មេតំ ភន្តេ ឧបាលិ កិរ គហបតិ

---

១ ឱ. ម. សាវកានន្តិ ន ទិស្សតិ ។ ២ ម. វោ ។ ៣ ឱ. តិដ្ឋេត្ថេវ ។ ៤ ម. វោ ។

អ្នកគប្បីនិយាយយ៉ាងនេះនឹងគេថា បពិត្រលោកដ៏ចម្រើន លោកចូរឈប់សិន កុំចូលទៅឡើយ ពីថ្ងៃនេះជាដើមរៀងទៅ ឧបាលិគហបតីចុះចូលជាសាវ័ក របស់ព្រះសមណគោតមហើយ បិទទ្វារចំពោះពួកនិគ្រន្ថប្រុស និងពួកនិគ្រន្ថស្រីហើយ ប៉ុន្តែមិនបិទទ្វារចំពោះពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាសាវ័ក របស់ព្រះមានព្រះភាគ បពិត្រលោកដ៏ចម្រើន បើលោកត្រូវការដោយបិណ្ឌបាត្រ សូមឈប់នៅទីនេះសិនចុះ ពួកជននឹងនាំមកឲ្យលោក ត្រឹមទីនេះឯង ។ អ្នករក្សាទ្វារក៏ទទួលពាក្យរបស់ឧបាលិគហបតី ដោយពាក្យថា បាទ អ្នកដ៏ចម្រើន ។

[៧៦] ទីឃតបស្សីនិគ្រន្ថ បានឮដំណឹងថា ឧបាលិគហបតីចុះចូលជាសាវ័ក របស់ព្រះសមណគោតមហើយ ។ ទើបទីឃតបស្សីនិគ្រន្ថចូលទៅរកនិគន្ថនាដបុត្ត លុះចូលទៅដល់ហើយ និយាយនឹងនិគន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំបានឮដំណឹងដូច្នេះថា ឧបាលិគហបតី

សមណស្ស គោតមស្ស សាវកត្តំ ឧបគតោតិ ។ អដ្ឋានំ ខោ ឯតំ តបស្សិ អនវកាសោ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគច្ឆេយ្យ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ សមណោ គោតមោ ឧបាលិស្ស គហបតិស្ស សាវកត្តំ ឧបគច្ឆេយ្យាតិ ។ ទុតិយម្បិ ខោ ទីឃតបស្សី និគណ្ឋោ និគណ្ឋំ នាដបុត្តំ ឯតទវោច សុតំ មេតំ ភន្តេ ឧបាលិ កិរ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគតោតិ ។ អដ្ឋានំ ខោ ឯតំ តបស្សិ អនវកាសោ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគច្ឆេយ្យ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ សមណោ គោតមោ ឧបាលិស្ស គហបតិស្ស សាវកត្តំ ឧបគច្ឆេយ្យាតិ ។ តតិយម្បិ ខោ ទីឃតបស្សី និគណ្ឋោ និគណ្ឋំ នាដបុត្តំ ឯតទវោច សុតំ មេតំ ភន្តេ ឧបាលិ កិរ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគតោតិ ។ អដ្ឋានំ ខោ ឯតំ តបស្សិ អនវកាសោ យំ ឧបាលិ គហបតិ

ចុះចូលទៅជាសាវ័ក របស់ព្រះសមណគោតមហើយ ។ និគន្ថនាដបុត្ត តបថា នែតបស្សី ឧបាលិគហបតី គប្បីចុះចូលទៅជាសាវ័កនៃព្រះសមណ-គោតមដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលមកជាសាវ័ក របស់ឧបាលិ-គហបតីដោយហេតុណា ហេតុនុ៎ះទើបជាទីតាំងមានមែន ។ ទីឃតបស្សីនិគ្រន្ថ ក៏និយាយនឹងនិគន្ថនាដបុត្តជាគម្រប់ពីរដងដូច្នេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំបានឮដំណឹងដូច្នេះថា ឧបាលិគហបតី ចុះចូលទៅជាសាវ័ករបស់ព្រះសមណគោតមហើយ ។ និគន្ថនាដបុត្តតបថា នែតបស្សី ឧបាលិគហបតី គប្បីចុះចូលទៅជាសាវ័ក របស់ព្រះសមណគោតមដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលមកជាសាវ័ក របស់ឧបាលិគហបតីវិញដោយហេតុណា ហេតុនុ៎ះទើបជាទីតាំងមានមែន ។ ទីឃតបស្សីនិគ្រន្ថនិយាយនឹងនិគន្ថនាដបុត្តជាគម្រប់ ៣ ដងដូច្នេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំបានឮដំណឹងដូច្នេះថា ឧបាលិគហបតី ចុះចូលទៅជាសាវ័ករបស់ព្រះសមណគោតមហើយ ។ នែតបស្សី ឧបាលិគហបតី គប្បីចុះចូលទៅ

សមណស្ស គោតមស្ស សាវកត្តំ ឧបគច្ឆេយ្យ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ សមណោ គោតមោ ឧបាលិស្ស គហបតិស្ស សាវកត្តំ ឧបគច្ឆេយ្យ[១] ហន្ទាហំ ភន្តេ គច្ឆាមិ យាវ ជានាមិ យទិ វា ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគតោ យទិ វា នោតិ ។ គច្ឆ ត្វំ តបស្សិ ជានាហិ យទិ វា ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគតោ យទិ វា នោតិ ។

[៧៧] អថ ខោ ទីឃតបស្សី និគណ្ឋោ យេន ឧបាលិស្ស គហបតិស្ស និវេសនំ តេនុបសង្កមិ ។ អទ្ទសា ខោ ទោវារិកោ ទីឃតបស្សឹ និគណ្ឋំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន ទីឃតបស្សឹ និគណ្ឋំ ឯតទវោច តិដ្ឋ ភន្តេ មា បាវិសិ អជ្ជតគ្គេ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគតោ អាវដំ ទ្វារំ និគណ្ឋានំ និគណ្ឋីនំ អនាវដំ ទ្វារំ ភគវតោ សាវកានំ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ

១ ឱ. ម. ឥតិសទ្ទោ ទិស្សតិ ។

ជាសាវ័ក របស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលមកជាសាវ័ក របស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះទើបជាទីតាំងមានមែន ។ បពិត្រលោកដ៏ចម្រើន ណ្ហើយចុះ ខ្ញុំនឹងទៅត្រាតែដឹងថា ឧបាលិគហបតី ចុះចូលទៅជាសាវ័ក របស់ព្រះសមណគោតមមែនឬក៏មិនមែនទេ ។ ម្នាលតបស្សី អ្នកចូរទៅចុះ អ្នកចូរដឹងថា ឧបាលិគហបតីចុះចូលទៅជាសាវ័ក របស់ព្រះសមណគោតមមែន ឬមិនមែនទេ ។

[៧៧] លំដាប់នោះ ទីឃតបស្សីនិគ្រន្ថ ក៏ចូលទៅកាន់ផ្ទះរបស់ឧបាលិគហបតី ។ អ្នករក្សាទ្វារបានឃើញទីឃតបស្សីនិគ្រន្ថដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងទីឃតបស្សីនិគ្រន្ថដូច្នេះថា បពិត្រលោកដ៏ចម្រើន លោកចូរឈប់សិន កុំចូលទៅឡើយ ពីថ្ងៃនេះជាដើមរៀងទៅ ឧបាលិគហបតីចុះចូលជាសាវ័ក របស់ព្រះសមណគោតមហើយ បិទទ្វារចំពោះពួកនិគ្រន្ថប្រុស និងពួកនិគ្រន្ថស្រី មិនបានបិទទ្វារដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាសាវ័ក របស់ព្រះមាន

គហបតិវគ្គស្ស ឧបាលិវាទសុត្តេ សាវកត្តុបគតតា

សចេ តេ ភន្តេ បិណ្ឌកេន អត្ថោ ឯត្ថេវ តិដ្ឋ ឯត្ថេវ តេ អាហរិស្សន្តីតិ ។ ន មេ អាវុសោ បិណ្ឌកេន អត្ថោតិ វត្វា តតោ បដិនិវត្តិត្វា យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា និគណ្ឋំ នាដបុត្តំ ឯតទវោច សច្ចំយេវ ខោ ភន្តេ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគតោ ឯតំ ខោ តេ អហំ ភន្តេ នាលត្ថំ ន ខោ មេ តំ ភន្តេ រុច្ចតិ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស វាទំ អារោបេយ្យ សមណោ ហិ ភន្តេ គោតមោ មាយាវី អាវដ្ដនឹ មាយំ ជានាតិ យាយ អញ្ញតិត្ថិយានំ សាវកេ អាវដ្ដេតីតិ អាវដ្ដោ ខោ តេ ភន្តេ ឧបាលិ គហបតិ សមណេន គោតមេន អាវដ្ដនិយា មាយាយាតិ ។ អដ្ឋានំ ខោ ឯតំ ទីឃ[១]តបស្សិ អនវកាសោ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគច្ឆេយ្យ

១ ឱ. ទីយឥតិ ន ទិស្សតិ ។

ព្រះភាគឡើយ បពិត្រលោកដ៏ចម្រើន បើលោកត្រូវការដោយបិណ្ឌបាត សូមឈប់នៅត្រឹមនេះសិនចុះ ពួកជននឹងនាំមកឲ្យលោកក្នុងទីនេះឯង ។ ទីឃតបស្សីនិយាយថា ម្នាលអាវុសោ យើងមិនត្រូវការដោយបិណ្ឌ-បាតទេ ហើយក៏ត្រឡប់មកអំពីទីនោះ ដើរចូលទៅរកនិគន្ថនាដបុត្ត លុះចូលទៅដល់ហើយ ទើបនិយាយនឹងនិគន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតីចុះចូលជាសាវ័ក របស់ព្រះសមណគោតម មែនហើយ បពិត្រលោកដ៏ចម្រើន ខ្ញុំមិនបានចួបនឹងឧបាលិគហបតីនុ៎ះ ដើម្បីលោកទេ បពិត្រលោកដ៏ចម្រើន ឧបាលិគហបតី គប្បីលើកឡើងនូវវាទៈ របស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះ ខ្ញុំមិនពេញចិត្តទេ បពិត្រលោកដ៏ចម្រើន ព្រោះថាព្រះសមណគោតមជាអ្នកមានកិច្ចកល តែងដឹងនូវកិច្ចកលសម្រាប់បោកប្រាស់ តែងបោកប្រាស់នូវសាវ័ក របស់ពួកអន្យតិត្ថិយ បពិត្រលោកដ៏ចម្រើន ព្រះសមណគោតមបោកប្រាស់នូវឧបាលិគហបតី របស់លោកដោយកិច្ចកលសម្រាប់បោកប្រាស់បានទៅហើយ ។ និគន្ថនាដបុត្តនិយាយតបថា ម្នាលទីឃតបស្សី ឧបាលិគហបតី គប្បីចុះចូលជាសាវ័ក របស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ

ហន្ទញ្ច ខោ ឯតំ វិជ្ជតិ យំ សមណោ គោតមោ ឧបាលិស្ស គហបតិស្ស សាវកត្តំ ឧបគច្ឆេយ្យាតិ ។ ទុតិយម្បិ ខោ[១] ទីឃតបស្សី និគណ្ឋោ និគណ្ឋំ នាដបុត្តំ ឯតទវោច សច្ចំ យេវ ខោ ភន្តេ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគតោ ឯតំ ខោ តេ អហំ ភន្តេ នាលត្ថំ ន ខោ មេ តំ ភន្តេ រុច្ចតិ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស វាទំ អារោបេយ្យ សមណោ ហិ ភន្តេ គោតមោ មាយាវី អាវដ្ដនឹ មាយំ ជានាតិ យាយ អញ្ញតិត្ថិយានំ សាវកេ អាវដ្ដេតីតិ អាវដ្ដោ ខោ តេ ភន្តេ ឧបាលិ គហបតិ សមណេន គោតមេន អាវដ្ដនិយា មាយាយាតិ ។ អដ្ឋានំ ខោ ឯតំ តបស្សិ អនវកាសោ យំ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគច្ឆេយ្យ ហន្ទញ្ច ខោ ឯតំ វិជ្ជតិ យំ សមណោ គោតមោ ឧបាលិស្ស គហបតិស្ស សាវកត្តំ ឧបគច្ឆេយ្យ

១ ឱ. ទុតិយម្បិ ខោ... តតិយម្បិ ខោ ទីឃតបស្សីតិ ទិស្សន្តិ ។

ឯព្រះសមណគោតម គប្បីចុះចូលជាសាវ័ក របស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះទើបជាទីតាំងមានមែន ។ ទីឃតបស្សីនិគ្រន្ថ និយាយនឹងនិគន្ថនាដបុត្ត ជាគម្រប់ពីរដង ដូច្នេះថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតី ចុះចូលជាសាវ័ក របស់ព្រះសមណគោតមមែនហើយ បពិត្រលោកដ៏ចម្រើន ខ្ញុំមិនបានចូលនឹងឧបាលិគហបតីនុ៎ះ ដើម្បីលោកទេ បពិត្រលោកដ៏ចម្រើន ឧបាលិគហបតី គប្បីលើកឡើងនូវវាទៈ របស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនពេញចិត្តខ្ញុំទេ បពិត្រលោកដ៏ចម្រើន ព្រោះថាព្រះសមណគោតម ជាអ្នកមានកិច្ចកល តែងដឹងកិច្ចកលសម្រាប់បោកប្រាស់ តែងបោកប្រាស់សាវ័ក របស់ពួកអន្យតិរ្ថិយ បពិត្រលោកដ៏ចម្រើន ព្រះសមណគោតម បោកប្រាស់នូវឧបាលិគហបតីរបស់លោក ដោយកិច្ចកលសម្រាប់បោកប្រាស់បានទៅហើយ ។ ម្នាលតបស្សី ឧបាលិគហបតីគប្បីចុះចូលជាសាវ័ក របស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលជាសាវ័ក របស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះទើបជាទីតាំងមានមែន

ហន្ទ ចាហំ តបស្សិ គច្ឆាមិ យាវ សាមំយេវ ជានាមិ យទិ វា ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគតោ យទិ វា នោតិ ។

[៧៨] អថខោ និគណ្ឋោ នាដបុត្តោ មហតិយា និគណ្ឋបរិសាយ សទ្ធឹ យេន ឧបាលិស្ស គហបតិស្ស និវេសនំ តេនុបសង្កមិ ។ អទ្ទសា ខោ ទោវារិកោ និគណ្ឋំ នាដបុត្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន និគណ្ឋំ នាដបុត្តំ ឯតទវោច តិដ្ឋ ភន្តេ មា បាវិសិ អជ្ជតគ្គេ ឧបាលិ គហបតិ សមណស្ស គោតមស្ស សាវកត្តំ ឧបគតោ អាវដំ ទ្វារំ និគណ្ឋានំ និគណ្ឋីនំ អនាវដំ ទ្វារំ ភគវតោ សាវកានំ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ សចេ តេ ភន្តេ បិណ្ឌកេន អត្ថោ ឯត្ថេវ តិដ្ឋ ឯត្ថេវ តេ អាហរិស្សន្តីតិ ។ តេនហិ សម្ម ទោវារិក យេន ឧបាលិ គហបតិ តេនុបសង្កមិ ឧបសង្កមិត្វា ឧបាលឹ គហបតឹ ឯវំ វទេហិ និគណ្ឋោ[១]

១ ឱ. ម. និគន្ថោ ភន្តេ ។

ម្នាលតបស្សី ណ្ហើយចុះ ខ្ញុំនឹងទៅត្រាតែដឹងដោយខ្លួនឯងថា ឧបាលិគហបតី ចុះចូលជាសាវ័ករបស់ព្រះសមណគោតមមែន ឬក៏មិនមែនទេ ។

[៧៨] លំដាប់នោះ និគន្ថនាដបុត្ត ជាមួយនឹងនិគន្ថបរិស័ទជាច្រើនរូប ចូលទៅកាន់ផ្ទះរបស់ឧបាលិគហបតី ។ អ្នករក្សាទ្វារបានឃើញនិគន្ថនាដបុត្តដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងនិគន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន សូមលោកឈប់សិន កុំចូលទៅឡើយ ពីថ្ងៃនេះជាដើមរៀងទៅ ឧបាលិគហបតី ចុះចូលជាសាវ័ករបស់ព្រះសមណគោតមហើយ បានបិទទ្វារចំពោះពួកនិគ្រន្ថប្រុសនិងនិគ្រន្ថស្រី មិនបានបិទទ្វារចំពោះពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាសាវ័ករបស់ព្រះមានព្រះភាគឡើយ បពិត្រលោកដ៏ចម្រើន បើលោកត្រូវការដោយបិណ្ឌបាត សូមលោកឈប់នៅត្រឹមទីនេះសិនចុះ ពួកជននឹងនាំមកឲ្យលោក ក្នុងទីនេះឯង ។ និគន្ថនាដបុត្តនិយាយថា ម្នាលអ្នករក្សាទ្វារជាសំឡាញ់ បើដូច្នោះ សូមអ្នកចូលទៅរកឧបាលិគហបតី លុះចូលទៅដល់ហើយ ក៏និយាយនឹងឧបាលិគហបតីយ៉ាងនេះថា និគន្ថ-

នាដបុត្តោ មហតិយា និគណ្ឋបរិសាយ សទ្ធឹ ពហិទ្វា-
រកោដ្ឋកេ ឋិតោ សោ តេ ឧបសង្កមតីតិ ។
ឯវំ ភន្តេតិ ខោ ទោវារិកោ និគណ្ឋស្ស នាដបុត្តស្ស
បដិស្សុត្វា យេន ឧបាលិ គហបតិ តេនុបសង្កមិ
ឧបសង្កមិត្វា ឧបាលឹ គហបតឹ ឯតទវោច និគណ្ឋោ
ភន្តេ នាដបុត្តោ មហតិយា និគណ្ឋបរិសាយ សទ្ធឹ
ពហិទ្វារកោដ្ឋកេ ឋិតោ សោ តេ ឧបសង្កមិតុ-
កាមោតិ ។ តេនហិ សម្ម ទោវារិក មជ្ឈិមាយ
ទ្វារសាលាយ អាសនានិ បញ្ញាបេហីតិ ។ ឯវំ ភន្តេតិ
ខោ ទោវារិកោ ឧបាលិស្ស គហបតិស្ស បដិស្សុត្វា
មជ្ឈិមាយ ទ្វារសាលាយ អាសនានិ បញ្ញាបេត្វា
យេន ឧបាលិ គហបតិ តេនុបសង្កមិ ឧបសង្កមិត្វា
ឧបាលឹ គហបតឹ ឯតទវោច បញ្ញត្តានិ ខោ ភន្តេ
មជ្ឈិមាយ ទ្វារសាលាយ អាសនានិ យស្សទានិ កាលំ
មញ្ញសីតិ ។ អថខោ ឧបាលិ គហបតិ យេន
មជ្ឈិមា ទ្វារសាលា តេនុបសង្កមិ ឧបសង្កមិត្វា

នាដបុត្ត ជាមួយនឹងនិគន្ថបរិស័ទជាច្រើនរូប មកឈរនៅខាងក្រៅក្លោងទ្វារ និគន្ថនាដបុត្តនោះចង់ជួបនឹងអ្នក ។ អ្នករក្សាទ្វារទទួលពាក្យរបស់និគន្ថនាដបុត្តថា អើលោកម្ចាស់ ហើយចូលទៅរកឧបាលិគហបតី លុះចូលទៅដល់ហើយ ក៏និយាយនឹងឧបាលិគហបតីដូច្នេះថា បពិត្រអ្នកដ៏ចម្រើន និគន្ថនាដបុត្តជាមួយនឹងនិគន្ថបរិស័ទជាច្រើនរូប មកឈរនៅខាងក្រៅក្លោងទ្វារ និគន្ថនាដបុត្តនោះចង់ជួបនឹងអ្នក ។ ឧបាលិគហបតីក៏និយាយថា ម្នាលអ្នករក្សាទ្វារជាសំឡាញ់ បើដូច្នោះចូរអ្នកក្រាលអាសនៈ ត្រង់ក្លោងទ្វារជាកណ្តាលចុះ ។ អ្នករក្សាទ្វារទទួលពាក្យឧបាលិគហបតីថា អើអ្នកដ៏ចម្រើន ក៏ក្រាលអាសនៈ ត្រង់ក្លោងទ្វារជាកណ្តាល ហើយត្រឡប់ចូលទៅរកឧបាលិគហបតីវិញ លុះចូលទៅដល់ហើយ ក៏និយាយប្រាប់ឧបាលិគហបតីដូច្នេះថា បពិត្រអ្នកដ៏ចម្រើន ខ្ញុំបានក្រាលអាសនៈ ត្រង់ក្លោងទ្វារជាកណ្តាលរួចហើយ សូមអ្នកសំគាល់នូវកាលដ៏សមគួរនឹងអញ្ជើញទៅឥឡូវនេះចុះ ។ ទើបឧបាលិគហបតី ដើរចូលទៅកាន់ក្លោងទ្វារជាកណ្តាល លុះចូលទៅដល់ហើយ ក៏អង្គុយ

យំ តត្ថ អាសនំ អគ្គញ្ច សេដ្ឋញ្ច ឧត្តមញ្ច បណីតញ្ច តត្ថ សាមំ[១] និសីទិត្វា ទោវារិកំ អាមន្តេសិ តេនហិ សម្ម ទោវារិក យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា និគណ្ឋំ នាដបុត្តំ ឯវំ វទេហិ ឧបាលិ ភន្តេ គហបតិ ឯវមាហ បវិស កិរ ភន្តេ សចេ អាកង្ខសីតិ ។ ឯវំ ភន្តេតិ ខោ ទោវារិកោ ឧបាលិស្ស គហបតិស្ស បដិស្សុត្វា យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា និគណ្ឋំ នាដបុត្តំ ឯតទវោច ឧបាលិ ភន្តេ គហបតិ ឯវមាហ បវិស កិរ ភន្តេ សចេ អាកង្ខសីតិ ។ អថខោ និគណ្ឋោ នាដបុត្តោ មហតិយា និគណ្ឋបរិសាយ សទ្ធឹ យេន មជ្ឈិមា ទ្វារសាលា តេនុបសង្កមិ ។

[៧៩] អថខោ ឧបាលិ គហបតិ យំសុទំ បុព្វេ[២] យតោ បស្សតិ នាដបុត្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន តតោ បច្ចុគ្គន្ត្វា យំ តត្ថ

១ ឱ. សាមន្តិ ន ទិស្សតិ ។ ២ ឱ. ម. បុព្វេវ ។

លើអាសនៈខ្ពស់ប្រសើរ ឧត្តម ថ្លៃថ្លា ដោយខ្លួនឯង ហើយប្រាប់អ្នករក្សាទ្វារថា ម្នាលអ្នករក្សាទ្វារជាសំឡាញ់ បើដូច្នោះត្រូវអ្នកចូលទៅរកនិគន្ថនាដបុត្ត លុះចូលទៅដល់ហើយ និយាយនឹងនិគន្ថនាដបុត្តយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតីបាននិយាយដូច្នេះថា បពិត្រលោកដ៏ចម្រើន បើលោកចង់ចូលទៅក៏ចូលទៅចុះ ។ អ្នករក្សាទ្វារក៏ទទួលពាក្យឧបាលិគហបតីថា អើអ្នកដ៏ចម្រើន ហើយក៏ចូលទៅរកនិគន្ថនាដបុត្ត លុះចូលទៅដល់ហើយ ក៏និយាយនឹងនិគន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតី បាននិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន បើលោកចង់ចូលទៅក៏ចូលទៅចុះ ។ លំដាប់នោះនិគន្ថនាដបុត្តព្រមទាំងនិគន្ថបរិស័ទច្រើនរូប ក៏ចូលទៅកាន់ក្លោងទ្វារជាកណ្តាល ។

[៧៩] កាលពីដើម បើឧបាលិគហបតី បានឃើញនិគន្ថនាដបុត្តមកអំពីចម្ងាយក្នុងកាលណា លុះឃើញហើយក៏ក្រោកទៅទទួលក្នុងកាលនោះ

អាសនំ អគ្គញ្ច សេដ្ឋញ្ច ឧត្តមញ្ច បណីតញ្ច តំ ឧត្តរាសង្គេន សំមជ្ជិត្វា[១] បរិគ្គហេត្វា និសីទាបេតិ សោទានិ យំ តត្ថ អាសនំ អគ្គញ្ច សេដ្ឋញ្ច ឧត្តមញ្ច បណីតញ្ច តត្ថ សាមំ និសីទិត្វា និគណ្ឋំ នាដបុត្តំ ឯតទវោច សំវិជ្ជន្តិ ខោ ភន្តេ គហបតិ អាសនានិ សចេ អាកង្ខសិ និសីទាតិ ។ ឯវំ វុត្តេ និគណ្ឋោ នាដបុត្តោ ឧបាលឹ គហបតឹ ឯតទវោច ឧម្មត្តោសិ ត្វំ គហបតិ ទត្តោសិ ត្វំ គហបតិ គច្ឆាមហំ ភន្តេ សមណស្ស គោតមស្ស វាទំ អារោបេស្សាមីតិ គន្ត្វាន មហតាសិ វាទសង្ឃាដេន បដិមុក្កោ អាគតោ សេយ្យថាបិ គហបតិ បុរិសោ អណ្ឌហារកោ គន្ត្វា ឧព្ភតេហិ អណ្ឌេហិ អាគច្ឆេយ្យ សេយ្យថា វា បន គហបតិ បុរិសោ អក្ខិកហារកោ គន្ត្វា ឧព្ភតេហិ អក្ខីហិ អាគច្ឆេយ្យ ឯវមេវ ខោ ត្វំ គហបតិ គច្ឆាមហំ ភន្តេ សមណស្ស គោតមស្ស វាទំ អារោបេស្សាមីតិ គន្ត្វា

១ ឱ. បមជ្ជិត្វា ។

ហើយយកសំពត់បង់ក ជូតសំអាតអាសនៈដ៏ខ្ពស់ប្រសើរ ឧត្តម ថ្លៃថ្លា ហើយគ្រាហ៍ឡើងទៅអង្គុយ តែពេលនេះ ឧបាលិគហបតីនោះ ត្រឡប់ទៅជាឡើងអង្គុយលើអាសនៈដ៏ខ្ពស់ប្រសើរ ឧត្តម ថ្លៃថ្លា ខ្លួនឯងវិញ ហើយក៏និយាយនឹងនិគន្ថនាដបុត្តថា នែគហបតីដ៏ចម្រើន អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការចូរអង្គុយចុះ ។ កាលបើឧបាលិគហបតីនិយាយយ៉ាងនេះហើយ និគន្ថនាដបុត្ត ក៏និយាយនឹងឧបាលិគហបតីដូច្នេះវិញថា ម្នាលគហបតី អ្នកឆ្កួតទេឬ ម្នាលគហបតី អ្នកឯងលីលាទេឬ អ្នកនិយាយថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងទៅលើកវាទៈ របស់ព្រះសមណគោតម លុះទៅហើយ ម្តេចឡើយក៏ត្រឡប់ជាពាក់ឃ្នាប គឺវាទៈដ៏ធំលើក្បាលមកវិញ ម្នាលគហបតី ដូចជាបុរសនាំអណ្ឌៈដើរទៅ ក៏ត្រឡប់នាំយកអណ្ឌៈ ដែលគេកាត់ចេញដើរមកវិញ ម្នាលគហបតី ពុំនោះសោតដូចជាបុរសនាំយកភ្នែកជាល្អដើរទៅ ត្រឡប់នាំយកភ្នែកដែលគេឆ្កៀលចេញដើរមកវិញ ម្នាលគហបតី អ្នកក៏យ៉ាងហ្នឹងដែរ និយាយថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងទៅលើកវាទៈ របស់ព្រះសមណគោតម

មហាតាសិ វាធសង្ខ្យាដេន បដិមុក្កោ អាគតោ អាវដ្ដោ ខោសិ ត្វំ គហបតិ សមណេន គោតមេន អាវដ្ដនិយា មាយាយាតិ ។

[៨០] ភទ្ទិកា ភន្តេ អាវដ្ដនី មាយា កល្យាណី ភន្តេ អាវដ្ដនី មាយា បិយា មេ ភន្តេ ញាតិសាលោ-ហិតា ឥមាយ អាវដ្ដនិយា អាវដ្ដេយ្យុំ បិយានម្បិ មេ អស្ស ញាតិសាលោហិតានំ ទីឃរត្តំ ហិតាយ សុខាយ សព្វេ ចេបិ ភន្តេ ខត្តិយា ឥមាយ អាវដ្ដនិយា អាវដ្ដេយ្យុំ សព្វេសានម្បិស្ស ខត្តិយានំ ទីឃរត្តំ ហិតាយ សុខាយ សព្វេ ចេបិ ភន្តេ ព្រាហ្មណា ។ បេ ។ វេស្សា ។ បេ ។ សុទ្ទា ឥមាយ អាវដ្ដនិ-យា អាវដ្ដេយ្យុំ សព្វេសានម្បិស្ស សុទ្ទានំ ទីឃរត្តំ ហិតាយ សុខាយ សទេវកោ ចេបិ ភន្តេ

លុះទៅដល់ហើយ ម្តេចឡើយក៏ត្រឡប់ជាពាក់ឃ្នាបគឺវាទៈ ដ៏ធំលើក្បាលដើរមកវិញ ម្នាលគហបតី អ្នកត្រូវព្រះសមណគោតមបោកប្រាស់ដោយកលជាគ្រឿងបោកប្រាស់ហើយ ។

[៨០] បពិត្រលោកដ៏ចម្រើន កលជាគ្រឿងបោកប្រាស់ស្រួលពេកណាស់ បពិត្រលោកដ៏ចម្រើន កលជាគ្រឿងបោកប្រាស់ល្អពេកណាស់ បពិត្រលោកដ៏ចម្រើន ញាតិសាលោហិតទាំងឡាយ ជាទីស្រឡាញ់របស់ខ្ញុំ គប្បីចាញ់បោកដោយកលជាគ្រឿងបោកនេះ ការចាញ់បោកនោះនឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលជាអង្វែងដល់ញាតិនិងសាលោហិត ដែលជាទីស្រឡាញ់របស់ខ្ញុំ បពិត្រលោកដ៏ចម្រើន ប្រសិនបើពួកក្សត្រទាំងអស់ គប្បីចាញ់បោកដោយកលជាគ្រឿងបោកនេះ ការចាញ់បោកនោះ នឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដើម្បីសេចក្តីសុខអស់កាលជាអង្វែង ដល់ពួកក្សត្រទាំងអស់ បពិត្រលោកដ៏ចម្រើន ប្រសិនបើពួកព្រាហ្មណ៍ទាំងអស់ ។ បេ ។ ពួកវេស្សៈ ។ បេ ។ ពួកសុទ្ទៈគប្បីចាញ់ដោយកលជាគ្រឿងបោកនេះ ការចាញ់បោកនោះ នឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលជាអង្វែង ដល់ពួកសុទ្ទៈទាំងអស់ បពិត្រលោកដ៏ចម្រើន ប្រសិនបើ

លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា ឥមាយ អាវដ្ដនិយា អាវដ្ដេយ្យ សទេវកស្សបិស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទីឃរត្តំ ហិតាយ សុខាយាតិ(១) តេនហិ ភន្តេ ឧបមំ តេ(២) ករិស្សាមិ ឧបមាយបិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ ជានន្តិ(៣) ។

[៨១] ភូតបុព្វំ ភន្តេ អញ្ញតរស្ស ព្រាហ្មណស្ស ជិណ្ណស្ស វុឌ្ឍស្ស មហល្លកស្ស ទហរា មាណវិកា បជាបតី អហោសិ គព្ភិនី ឧបវិជញ្ញា ។ អថខោ ភន្តេ សា មាណវិកា តំ ព្រាហ្មណំ ឯតទវោច គច្ឆ ត្វំ ព្រាហ្មណ អាបណា មក្កដច្ឆាបកំ កិណិត្វា អានេហិ យោ មេ កុមារកស្ស កីឡាបនកោ ភវិស្សតីតិ ។ ឯវំ វុត្តេ ភន្តេ សោ ព្រាហ្មណោ តំ មាណវិកំ ឯតទវោច អាគមេហិ តាវ ភោតិ

១ ឱ. ឥតិសទ្ទោ ន ទិស្សតិ ។ ២ ឱ. ម. ឧបមន្តេ ។ ៣ ឱ. អាជានន្តិ ។

លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វព្រម ទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្ស ដ៏សេស គប្បីចាញ់បោកដោយកលជាគ្រឿងបោកនេះ ការចាញ់បោក នោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលជា អង្វែង ដល់លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដល់ សត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និង មនុស្សដ៏សេស បពិត្រលោកដ៏ចម្រើន ណ្ហើយចុះ ខ្ញុំនឹងធ្វើសេចក្តីឧបមា ដល់លោក វិញ្ញូបុរសពួកមួយ ក្នុងលោកនេះ គង់ដឹងនូវសេចក្តីនៃភាសិត ដោយឧបមាខ្លះមិនខាន ។

[៨១] បពិត្រលោកដ៏ចម្រើន រឿងធ្លាប់មានមកហើយថា មាន ព្រាហ្មណ៍ម្នាក់ចាស់ព្រឹទ្ធា ជាធំដោយអាយុ បាននាងមាណវិកាក្រមុំ ជាប្រពន្ធ មានផ្ទៃពោះ ជិតដល់កាលនឹងប្រសូត ។ បពិត្រលោក ដ៏ចម្រើន គ្រានោះ នាងមាណវិកានោះ ក៏និយាយនឹងព្រាហ្មណ៍នោះ ដូច្នេះថា ម្នាលព្រាហ្មណ៍ អ្នកចូរទៅទិញកូនស្វាឈ្មោល ពីផ្សារ យកមក ដើម្បីឲ្យកុមាររបស់ខ្ញុំលេង ។ បពិត្រលោកដ៏ចម្រើន កាល ដែលនាងមាណវិកានិយាយយ៉ាងនេះ ព្រាហ្មណ៍នោះ ក៏និយាយដូច្នេះ នឹងនាងមាណវិកានោះថា ម្នាលនាងដ៏ចម្រើន នាងចូរបង្អង់ចាំទម្រាំនាង

១២៧



យាវ វិជាយសិ សចេ ត្វំ ភោតិ កុមារកំ វិជាយិស្សសិ តស្សា តេ អហំ អាបណា មក្កដច្ឆាបកំ កិណិត្វា អានិស្សាមិ យោ តេ កុមារកស្ស កីឡាបនកោ ភវិស្សតិ សចេ បន ត្វំ ភោតិ កុមារិកំ វិជាយិស្សសិ តស្សា តេ អហំ អាបណា មក្កដច្ឆាបិកំ កិណិត្វា អានិស្សាមិ យា តេ កុមារិកាយ កីឡាបនិកា ភវិស្សតីតិ ។ ទុតិយម្បិ ខោ ភន្តេ សា មាណវិកា តំ ព្រាហ្មណំ ឯតទវោច គច្ឆ ត្វំ ព្រាហ្មណ អាបណា មក្កដច្ឆាបកំ កិណិត្វា អានេហិ យោ មេ កុមារកស្ស កីឡាបនកោ ភវិស្សតីតិ ។ ទុតិយម្បិ ខោ ភន្តេ សោ ព្រាហ្មណោ តំ មាណវិកំ ឯតទវោច អាគមេហិ តាវ ភោតិ យាវ វិជាយសិ សចេ ត្វំ ភោតិ កុមារកំ វិជាយិស្សសិ តស្សា តេ អហំ អាបណា មក្កដច្ឆាបកំ កិណិត្វា អានិស្សាមិ យោ តេ កុមារកស្ស កីឡាបនកោ ភវិស្សតិ សចេ បន ត្វំ ភោតិ

ប្រសូតសិន ម្នាលនាងដ៏ចម្រើន បើនាងប្រសូតកុមារ សឹមអញទៅទិញកូនស្វាឈ្មោលពីផ្សារ យកមកឲ្យនាង ដើម្បីឲ្យកុមាររបស់នាងលេង ម្នាលនាងដ៏ចម្រើន តែប្រសិនបើនាងប្រសូតកុមារី អញនឹងទៅទិញកូនស្វាញីពីផ្សារយកមកឲ្យនាង ដើម្បីឲ្យកុមារីរបស់នាងលេង ។ បពិត្រលោកដ៏ចម្រើន នាងមាណវិកានោះនិយាយនឹងព្រាហ្មណ៍នោះដូច្នេះជាគម្រប់ពីរដងទៀតថា ម្នាលព្រាហ្មណ៍ អ្នកចូរទៅទិញកូនស្វាឈ្មោលពីផ្សារយកមកដើម្បីឲ្យកុមាររបស់ខ្ញុំលេង ។ បពិត្រលោកដ៏ចម្រើន ព្រាហ្មណ៍នោះ និយាយនឹងនាងមាណវិកានោះដូច្នេះ ជាគម្រប់ពីរដងទៀតថា ម្នាលនាងដ៏ចម្រើន ចូរនាងបង្អង់ចាំទម្រាំនាងប្រសូតសិន ម្នាលនាងដ៏ចម្រើន បើនាងប្រសូតកុមារ សឹមអញទៅទិញកូនស្វាឈ្មោល ពីផ្សារយកមកឲ្យនាង ដើម្បីឲ្យកុមាររបស់នាងលេង ម្នាលនាងដ៏ចម្រើន តែប្រសិនបើ

កុមារិកំ វិជាយិស្សសិ តស្សា តេ អហំ អាបណា មក្កដច្ឆាបិកំ កិណិត្វា អានិស្សាមិ យា តេ កុមារិកាយ កីឡាបនិកា ភវិស្សតីតិ ។ តតិយម្បិ ខោ ភន្តេ សា មាណវិកា តំ ព្រាហ្មណំ ឯតទវោច គច្ឆ ត្វំ ព្រាហ្មណ អាបណា មក្កដច្ឆាបកំ កិណិត្វា អានេហិ យោ មេ កុមារកស្ស កីឡាបនកោ ភវិស្សតីតិ ។ អថខោ ភន្តេ សោ ព្រាហ្មណោ តស្សា មាណវិកាយ សារត្តោ បដិពទ្ធចិត្តោ អាបណា មក្កដច្ឆាបកំ កិណិត្វា អានេត្វា តំ មាណវិកំ ឯតទវោច អយំ តេ ភោតិ មយា អាបណា មក្កដច្ឆាបកោ កិណិត្វា អានីតោ យោ តេ កុមារកស្ស កីឡាបនកោ ភវិស្សតីតិ ។ ឯវំ វុត្តេ ភន្តេ សា មាណវិកា តំ ព្រាហ្មណំ ឯត-ទវោច គច្ឆ ត្វំ ព្រាហ្មណ ឥមំ មក្កដច្ឆាបកំ អាទាយ យេន រត្តបាណី រជកបុត្តោ តេនុបសង្កម ឧបសង្កមិត្វា រត្តបាណឹ រជកបុត្តំ ឯវំ វទេហិ

នាងប្រសូតកុមារី អញនឹងទៅទិញកូនស្វាញី ពីផ្សារយកមកឲ្យនាង ដើម្បីឲ្យកុមារីរបស់នាងលេង ។ បពិត្រលោកដ៏ចម្រើន នាងមាណវិកានោះ និយាយនឹងព្រាហ្មណ៍នោះដូច្នេះ ជាគម្រប់បីដងទៀតថា ម្នាលព្រាហ្មណ៍ អ្នកចូរទៅទិញកូនស្វាឈ្មោល ពីផ្សារយកមក ដើម្បីឲ្យកុមាររបស់ខ្ញុំលេង ។ បពិត្រលោកដ៏ចម្រើន គ្រានោះ ព្រាហ្មណ៍នោះមានតម្រេក មានចិត្តប្រតិព័ទ្ធចំពោះនាងមាណវិកានោះ ក៏ទៅទិញកូនស្វាឈ្មោលពីផ្សារយកមក ហើយនិយាយដូច្នេះនឹងនាងមាណវិកានោះថា ម្នាលនាងដ៏ចម្រើន កូនស្វាឈ្មោលនេះ អញបានទៅទិញមកពីផ្សារយកមកឲ្យនាងហើយ ដើម្បីឲ្យកុមាររបស់នាងលេង ។ បពិត្រលោកដ៏ចម្រើន កាលដែលព្រាហ្មណ៍និយាយយ៉ាងនេះហើយ នាងមាណវិកានោះ ក៏និយាយដូច្នេះនឹងព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ ចូរអ្នកនាំយកកូនស្វាឈ្មោលនេះ ដើរចូលទៅរករជកបុត្រ (កូនជាងជ្រលក់) ឈ្មោះរត្តបាណិ[១] លុះចូលទៅដល់ហើយ ចូរនិយាយនឹងរត្តបាណិរជកបុត្រ

១ មានបាតដៃក្រហម ។

១២៩



ឥច្ឆាមហំ សម្ម រត្តចាណិ ឥមំ មក្កដច្ឆាបកំ បីតាវលេបនំ នាម រង្គជាតំ រជិតំ[1] អាកោដ្ដិតប្បច្ចាកោដ្ដិតំ ឧភតោភាគវិមដ្ឋន្តិ ។ អថខោ ភន្តេ សោ ព្រាហ្មណោ តស្សា មាណវិកាយ សារត្តោ បដិពទ្ធចិត្តោ[2] មក្កដច្ឆាបកំ អាទាយ យេន រត្តចាណី រជកបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា រត្តចាណឹ រជកបុត្តំ ឯតទវោច ឥច្ឆាមហំ សម្ម រត្តចាណិ ឥមំ មក្កដច្ឆាបកំ បីតាវលេបនំ នាម រង្គជាតំ រជិតំ អាកោដ្ដិតប្បច្ចាកោដ្ដិតំ ឧភតោភាគវិមដ្ឋន្តិ ។ ឯវំ វុត្តេ ភន្តេ រត្តចាណី រជកបុត្តោ តំ ព្រាហ្មណំ ឯតទវោច អយំ ខោ តេ ភន្តេ មក្កដច្ឆាបកោ រង្គក្ខមោ ហិ ខោ នោ អាកោដ្ដនក្ខមោ នោ វិមជ្ជនក្ខមោតិ ។ ឯវមេវ ខោ ភន្តេ ពាលានំ និគណ្ឋានំ វាទោ រង្គក្ខមោ ហិ ខោ ពាលានំ នោ បណ្ឌិតានំ នោ អនុយោគក្ខមោ នោ វិមជ្ជនក្ខមោ ។ អថខោ ភន្តេ សោ ព្រាហ្មណោ អបរេន សមយេន នវំ ទុស្សយុគំ អាទាយ

---

១ ឱ. រញ្ជិតំ ។ ២ ឱ.ម. បដិពទ្ធចិត្តោ តំ ។

យ៉ាងនេះថា ម្នាលវត្តបាណីជាសំឡាញ់ ខ្ញុំចង់ឲ្យអ្នកយកវត្ត[១]ជាគ្រឿងលាបមានពណ៌លឿង មកជ្រលក់ស្វាឈ្មោលនេះ បោកគក់ឲ្យសព្វ ធ្វើឲ្យមានសម្បុរស្អាតទាំងពីរខាង ។ បពិត្រលោកដ៏ចម្រើន គ្រានោះព្រាហ្មណ៍នោះ មានតម្រេកមានចិត្តប្រតិព័ទ្ធ ចំពោះនាងមាណវិកានោះ ក៏យកកូនស្វាឈ្មោល ចូលទៅរកវត្តបាណីរជកបុត្រ លុះចូលទៅដល់ហើយ ក៏និយាយដូច្នេះនឹងវត្តបាណីរជកបុត្រថា ម្នាលវត្តបាណីជាសំឡាញ់ ខ្ញុំចង់ឲ្យអ្នកយកវត្តជាគ្រឿងលាប មានពណ៌លឿងមកជ្រលក់កូនស្វាឈ្មោលនេះឲ្យសព្វ ធ្វើឲ្យមានសម្បុរស្អាតទាំងពីរខាង ។ បពិត្រលោកដ៏ចម្រើន កាលដែលព្រាហ្មណ៍និយាយយ៉ាងនេះហើយ វត្តបាណីរជកបុត្រ ក៏និយាយដូច្នេះនឹងព្រាហ្មណ៍នោះថា នែអ្នកដ៏ចម្រើន កូនស្វាឈ្មោលរបស់អ្នកនេះ គួរដល់គ្រឿងជ្រលក់ តែមិនគួរដល់ការបោកគក់ មិនគួរដល់ការដុសខាត់ឡើយ ។ បពិត្រលោកដ៏ចម្រើន វាទៈរបស់ពួកនិគ្រន្ថពាល គួរដល់គ្រឿងជ្រលក់ របស់ពួកជនពាលបាន ប៉ុន្តែមិនគួរដល់គ្រឿងជ្រលក់ របស់ពួកបណ្ឌិត ទាំងមិនគួរដល់សេចក្តីព្យាយាម មិនគួរដល់ការដុសខាត់ចិត្តឡើយយ៉ាងនោះឯង ។ បពិត្រលោកដ៏ចម្រើន គ្រានោះ ព្រាហ្មណ៍នោះ ក៏បានយកសំពត់ថ្មីមួយគូ

---

១ គ្រឿងលាបគ្រឿងជ្រលក់ ។

យេន រត្តបាណី រជកបុត្តោ តេនុបសង្កមិ ឧប-
សង្កមិត្វា រត្តបាណឹ រជកបុត្តំ ឯតទវោច ឥច្ឆាមហំ
សម្ម រត្តបាណិ ឥមំ នវំ ទុស្សយុគំ បីតាវលេបនំ
នាម រង្គជាតំ រជិតំ អាកោដ្ដិតប្បច្ចាកោដ្ដិតំ
ឧភតោភាគវិមដ្ឋន្តិ ។ ឯវំ វុត្តេ ភន្តេ រត្តបាណី
រជកបុត្តោ ព្រាហ្មណំ[១] ឯតទវោច ឥទំ
ខោ តេ ភន្តេ នវំ ទុស្សយុគំ រង្គក្ខមញ្ចេវ
អាកោដ្ដនក្ខមញ្ច វិមជ្ជនក្ខមញ្ចាតិ ។ ឯវមេវ ខោ
ភន្តេ តស្ស ភគវតោ វាទោ អរហតោ សម្មាសម្ពុទ្ធស្ស
រង្គក្ខមោ ចេវ បណ្ឌិតានំ នោ ពាលានំ
អនុយោគក្ខមោ ច វិមជ្ជនក្ខមោ ចាតិ ។
សរាជិកា ខោ តំ គហបតិ បរិសា ឯវំ ជានាតិ
ឧបាលិ គហបតិ និគណ្ឋស្ស នាដបុត្តស្ស សាវកោតិ
កស្ស តំ គហបតិ សាវកំ ធារេមាតិ ។

---

១ ឱ. ម. តំ ព្រាហ្មណំ ។

ចូលទៅរកវត្តបាណីរជកបុត្រ ក្នុងសម័យជាខាងក្រោយ លុះចូលទៅដល់ហើយ ក៏និយាយដូច្នេះនឹងវត្តបាណីរជកបុត្រថា ម្នាលវត្តបាណីជាសំឡាញ់ ខ្ញុំចង់ឲ្យអ្នកយកវត្ថុ ជាគ្រឿងលាបមានពណ៌លឿង មកជ្រលក់សំពត់ថ្មី ១ គូនេះ បោកគក់ឲ្យសព្វ ធ្វើឲ្យមានសម្បុរម៉ដ្ឋទាំងពីរខាង ។ បពិត្រលោកដ៏ចម្រើន កាលដែលព្រាហ្មណ៍និយាយយ៉ាងនេះហើយ វត្ត-បាណីរជកបុត្រ ក៏និយាយដូច្នេះនឹងព្រាហ្មណ៍នោះថា នែអ្នកដ៏ចម្រើន សំពត់ថ្មី ១ គូរបស់អ្នកនេះ គួរដល់គ្រឿងជ្រលក់ផង គួរដល់ការបោកគក់ផង គួរដល់ការដុសខាត់ផង ។ បពិត្រលោកដ៏ចម្រើន វាទៈរបស់ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ គួរដល់គ្រឿងជ្រលក់ របស់ពួកបណ្ឌិត គួរដល់សេចក្តីព្យាយាមផង គួរដល់ការដុសខាត់ផង របស់បណ្ឌិត មិនគួរដល់ពួកជនពាលទេ យ៉ាងនេះឯង ។ និគន្ថនាដបុត្តនិយាយថា ម្នាលគហបតី បរិស័ទព្រមទាំងស្តេច តែងស្គាល់អ្នកយ៉ាងនេះថា ឧបាលិគហបតីជាសាវ័ក របស់និគន្ថនាដបុត្ត ម្នាលគហបតីឥឡូវយើង នឹងចាំបានថាអ្នកជាសាវ័ក របស់បុគ្គលណា ។

គហបតិវគ្គស្ស ឧបាលិវាទសុត្តេ សាវកគុណប្បកាសនំ

[៨២] ឯវំ វុត្តេ ឧបាលិ គហបតិ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា និគណ្ឋំ នាដបុត្តំ ឯតទវោច តេនហិ ភន្តេ សុណោហិ យស្សាហំ សាវកោ ធីរស្ស វិគតមោហស្ស បភិន្នខីលស្ស វិជិតវិជយស្ស អនីឃស្ស សុសមចិត្តស្ស ពុទ្ធសីលស្ស[១] សាធុប្បញ្ញស្ស វេសមន្តរស្ស[២] វិមលស្ស ភគវតោ តស្ស សាវកោហមស្មិ អកថំកថិស្ស តុសិតស្ស វន្តលោកាមិសស្ស មុទិតស្ស កតសមណស្ស មនុជស្ស អន្តិមសរីរស្ស[៣] នរស្ស អនោបមស្ស វិរជស្ស ភគវតោ តស្ស សាវកោហមស្មិ អសំសយស្ស កុសលស្ស វេនយិកស្ស សារថិវរស្ស អនុត្តរស្ស រុចិរធម្មស្ស និក្កង្ខស្ស បភាសករស្ស[៤] មាននច្ឆិទស្ស

១ ឱ. ម. វុទ្ធសីលស្ស ។ ២ ឱ. វេស្សន្តរស្ស ។ ៣ ឱ. ម. អន្តិមសារីរស្ស ។
៤ ម. បភាសកស្ស ។

[៨២] កាលដែលនិគន្ថនាដបុត្ត ពោលយ៉ាងនេះហើយ ឧបាលិគហបតី ក៏ក្រោកចាកអាសនៈ ធ្វើសំពត់បង់កឆៀងស្មាម្ខាង ប្រណមអញ្ជលីឆ្ពោះទៅរកព្រះមានព្រះភាគ ហើយនិយាយដូច្នេះនឹងនិគន្ថនាដបុត្តថា បពិត្រលោកដ៏ចម្រើន បើដូច្នោះលោកចូរស្តាប់ ខ្ញុំជាសាវករបស់ព្រះមានព្រះភាគណា ដែលមានប្រាជ្ញាខ្ជាប់ខ្ជួន មានមោហៈទៅប្រាសហើយ មានបង្គោលបាក់បែកហើយ បានឈ្នះមារ(១)ហើយ ឥតមានសេចក្តីទុក្ខ(២) មានព្រះទ័យស្មើល្អ មានសីលដ៏ចម្រើន មានប្រាជ្ញាល្អ បានធ្ងង់នូវវិសមធម៌(៣) ប្រាសចាកមន្ទិល ខ្ញុំជាសាវករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គឥតមានសេចក្តីសង្ស័យ មានព្រះទ័យស្រស់ស្រាយ មានអាមិសៈក្នុងលោក ខ្ជាក់ចោលហើយ មានព្រះទ័យរីករាយ មានសមណធម៌ធ្វើស្រេចហើយ ជាមនុស្សមានសរីរៈតាំងនៅក្នុងទីបំផុត ជានរជាតរកបុគ្គលប្រៀបគ្មាន ប្រាសចាកធូលីគឺកិលេស ខ្ញុំជាសាវករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ឥតមានសេចក្តីសង្ស័យ ជាអ្នកឈ្លាសវៃ ព្រះអង្គជាអ្នកដឹកនាំសត្វ ជាសារថីដ៏ប្រសើរ ជាបុគ្គលប្រសើរ រកអ្នកណាស្មើគ្មាន មានធម៌ដ៏រុងរឿង ឥតមានកង្ខា ជាអ្នកធ្វើពន្លឺ ផ្តាច់បង់នូវមានះហើយ

---

១ សំដៅយកមច្ចុមារ កិលេសមារ ទេវបុត្តមារ ។ ២ សំដៅយកកិលេសទុក្ខ និងវិបាកទុក្ខ ។ ៣ សំដៅយករាគាទិក្កិលេស ។

វីរស្ស ភគវតោ តស្ស សាវកោហមស្មិ និសភស្ស អប្បមេយ្យស្ស គម្ភីរស្ស មោនប្បត្តស្ស[១] ខេមង្ករស្ស វេទស្ស[២] ធម្មដ្ឋស្ស សុសំវុតត្តស្ស[៣] សង្គាតិគស្ស មុត្តស្ស ភគវតោ តស្ស សាវកោហមស្មិ នាគស្ស បន្តសេនស្ស ខីណសញ្ញោជនស្ស មុត្តស្ស បដិមន្តកស្ស មោនស្ស[៤] បន្នធជស្ស វីតរាគស្ស ទន្តស្ស និប្បបញ្ចស្ស ភគវតោ តស្ស សាវកោហមស្មិ ឥសិសត្តមស្ស អកុហស្ស តេវិជ្ជស្ស ព្រហ្មសត្តស្ស ន្ហាតកស្ស បទកស្ស បស្សទ្ធស្ស វិទិតវេទស្ស បុរិន្ទទស្ស សក្កស្ស ភគវតោ តស្ស សាវកោហមស្មិ អរិយស្ស ភាវិតត្តស្ស

---

១ ឱ. ម. មានបត្តស្ស ។ ២ ម. ទេវស្ស ។ ៣ ឱ. ម. សំវុត្តស្ស ។ ៤ ឱ. ម. ធោនស្ស ។

មានព្យាយាម ខ្ញុំជាសាវ័ក របស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គប្រសើរ មានគុណប្រមាណមិនបាន ប្រកបដោយគុណដ៏ជ្រាលជ្រៅ ដល់នូវសេចក្តីដឹង ធ្វើនូវសេចក្តីក្សេម ប្រកបដោយប្រាជ្ញា ទ្រង់បិតនៅក្នុងធម៌ ទ្រង់សង្រួមដោយប្រពៃ ទ្រង់កន្លងបង់នូវកិលេសជាគ្រឿងជាប់នៅ ទ្រង់រួចចាកគ្រឿងសៅហ្មង ខ្ញុំជាសាវ័ក របស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គប្រសើរ ទ្រង់មានសេនាសនៈស្ងាត់ មានសំយោជនៈអស់ហើយ មានព្រះទ័យរួចស្រឡះចាកកិលេស មានប្រាជ្ញាជាគ្រឿងប្រឹក្សា ទ្រង់ប្រកបដោយសេចក្តីដឹង មានទង់គឺមានះដាក់ចុះហើយ ប្រាសចាករាគៈហើយ ទ្រង់ទូន្មានឥន្ទ្រិយហើយ មិនមានធម៌ជាគ្រឿងធ្វើសត្វឲ្យយឺតយូរ ខ្ញុំជាសាវ័ក របស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គជាឥសីទី ៧[១] មិនកុហក មានត្រៃវិជ្ជា ជាសត្វដ៏ប្រសើរ ទ្រង់លាងកិលេសអស់ហើយ ឈ្លាសវៃក្នុងបទគាថា ទ្រង់រម្ងាប់សេចក្តីក្រវល់ក្រវាយហើយ ទ្រង់មានសេចក្តីដឹងដ៏វិសេស ទ្រង់ប្រទានធម៌មុនជនទាំងពួង ជាអ្នកអង់អាច ខ្ញុំជាសាវ័ក របស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គជាព្រះអរិយៈ មានព្រះទ័យចម្រើន

---

១ បានជាហៅថា ឥសី ព្រោះព្រះអង្គស្វែងរកគុណធម៌រាប់តាំងពីព្រះពុទ្ធវិបស្សីមកជាគម្រប់ ៧ នឹងព្រះអង្គ ។

គហបតិវគ្គស្ស ឧបាលិវាទសុត្តេ សាវកត្តប្បកាសនំ

បត្តិបត្តស្ស វេយ្យាករណស្ស សតិមតោ វិបស្សិស្ស អនភិណតស្ស ដោ អបណតស្ស អានេជស្ស វសិប្បត្តស្ស ភគវតោ តស្ស សាវកោហមស្មិ សម្មគ្គ-តស្ស ឈាយិស្ស អននុគតន្តរស្ស សុទ្ធស្ស អសិតស្ស អប្បភីតស្ស(១) បវិវិត្តស្ស អគ្គប្បត្តស្ស តិណ្ណស្ស តារយន្តស្ស ភគវតោ តស្ស សាវកោហមស្មិ សន្តស្ស ភូរិប្បញ្ញស្ស មហាបញ្ញស្ស វីតលោភស្ស តថាគតស្ស សុគតស្ស អប្បដិបុគ្គលស្ស អសមស្ស វិសារទស្ស និបុណស្ស ភគវតោ តស្ស សាវកោហមស្មិ តណ្ហច្ឆិ-ទស្ស ពុទ្ធស្ស វីតធូមស្ស អនុបលិត្តស្ស អាហុនេយ្យស្ស

---

១ ឱ. អប្បហីតស្ស ។ ម. ហិតស្ស ។

ហើយ ដល់នូវគុណដែលគួរដល់ ទ្រង់សំដែងនូវសេចក្តីជាក់ច្បាស់ ទ្រង់មានព្រះស្មារតី ទ្រង់មានប្រាជ្ញាជាគ្រឿងឃើញច្បាស់ មានព្រះទ័យមិនបានទន់ទៅ មានព្រះទ័យមិនប្រព្រឹត្តទៅក្នុងកិលេស មានព្រះទ័យមិនញាប់ញ័រ ទ្រង់ដល់នូវការស្ទាត់ ខ្ញុំជាសាវ័ក របស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គជាអ្នកប្រព្រឹត្តដោយប្រពៃ ជាអ្នកមានឈាន មានព្រះសន្តានមិនប្រព្រឹត្តទៅតាមកិលេស មានព្រះទ័យស្អាត មិនជាប់ចំពាក់ ឥតមានសេចក្តីខ្លាចមានកាយនិងចិត្តស្ងាត់ហើយ ដល់នូវភាវៈជាបុគ្គលប្រសើរ ជាអ្នកច្ចងចាកលោក ជាអ្នកចម្លងសត្វ ខ្ញុំជាសាវ័ក របស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គមានព្រះទ័យស្ងប់រម្ងាប់ហើយ មានប្រាជ្ញាដូចជាផែនដី មានប្រាជ្ញាច្រើន ប្រាសចាកលោភៈហើយ ព្រះអង្គមានដំណើរដូចព្រះសម្ពុទ្ធអំពីបូរាណ ទ្រង់មានដំណើរល្អ ឥតមានបុគ្គលប្រៀប ឥតមានអ្នកណាស្មើ អ្នកក្លៀវក្លា មានប្រាជ្ញាល្អិត ខ្ញុំជាសាវ័ក របស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ទ្រង់ផ្តាច់តណ្ហាហើយ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ហើយ ទ្រង់ប្រាសចាកផ្សែង[១] ហើយ មិនប្រឡាក់ដោយតណ្ហានិងទិដ្ឋិ គួរទទួលគ្រឿងបូជា

---

១ ផ្សែងក្នុងទីនេះ សំដៅយក កោធៈ ១ តណ្ហា ១ វិតក្កៈ ១ បញ្ចកាមគុណ ១ ។

យក្ខស្ស ឧត្តមបុគ្គលស្ស អតុលស្ស មហតោ យសគ្គប្បត្តស្ស ភគវតោ តស្ស សាវកោហមស្មីតិ ។

[៨៣] កទា សញ្ញូឡ្ហា បន តេ គហបតិ ឥមេ សមណស្ស គោតមស្ស វណ្ណាតិ ។ សេយ្យថាបិ ភន្តេ នានាបុប្ផានំ មហាបុប្ផរាសិ តមេនំ ទក្ខោ មាលាការោ វា មាលាការន្តេវាសី វា វិចិត្រមាលំ[១] គន្ថេយ្យ ឯវមេវ ខោ ភន្តេ សោ ភគវា អនេកវណ្ណោ អនេកសតវណ្ណោ កោ ហិ ភន្តេ វណ្ណារហស្ស វណ្ណំ ន ករិស្សតីតិ ។ អថខោ និគណ្ឋស្ស នាដបុត្តស្ស ភគវតោ សក្ការំ អសហមានស្ស តត្ថេវ ឧណ្ហំ លោហិតំ មុខតោ ឧគ្គញ្ឆីតិ ។

ឧបាលិវាទសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

---

១ ឱ. វិចិត្រំ មាលំ ។ ម. វិចិត្តំ មាលំ ។

ព្រះអង្គជាយក្ខ[១] ជាបុគ្គលដ៏ឧត្តមឥតមានអ្នកណាថ្លឹងបាន ព្រះអង្គជាធំដល់នូវយសដ៏ប្រសើរ ខ្ញុំជាសាវ័ក របស់ព្រះមានព្រះភាគអង្គនោះ ។

[៨៣] និគន្ថនាដបុត្តពោលថា ម្នាលគហបតី ចុះគុណរបស់សមណគោតមទាំងអម្បាលនេះ អ្នកប្រមូលមកអំពីកាលណា ។ ឧបាលិគហបតីតបថា បពិត្រលោកដ៏ចម្រើន គំនរផ្កាធំនៃផ្កាផ្សេង ៗ មាលាការក្តី កូនសិស្សរបស់មាលាការក្តី ដែលជាអ្នកប៉ិនប្រសប់ ក្រងផ្កានោះឲ្យជាកម្រងដ៏វិចិត្រ មានឧបមាយ៉ាងណា បពិត្រលោកដ៏ចម្រើន ព្រះមានព្រះភាគអង្គនោះ មានគុណច្រើន មានគុណជាច្រើនរយ មានឧបមេយ្យយ៉ាងនោះ បពិត្រលោកដ៏ចម្រើន អ្នកណានឹងអាចមិនធ្វើនូវសេចក្តីសរសើរដល់ព្រះអង្គ ដែលមានគុណគួរសរសើរបាន ។ គ្រានោះឯង និគន្ថនាដបុត្តអត់ទ្រាំនឹងសក្ការៈ របស់ព្រះមានព្រះភាគមិនបានក៏ក្អួតឈាមក្តៅ ៗ ចេញពីមាត់ក្នុងទីនោះឯង ។

ចប់ ឧបាលិវាទសូត្រ ទី ៦ ។

---

១ បានជាឈ្មោះថាយក្ខ ព្រោះអាចសំដែងនូវអានុភាពបាន ឬអាចសំដែងព្រះកាយមិនឲ្យគេមើលឃើញបាន ។

# សត្តមំ កុក្កុរោវាទសុត្តំ

[៨៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោលិយេសុ វិហរតិ ហលិទ្ទវសនំ នាម កោលិយានំ និគមោ ។ អថខោ បុណ្ណោ ច កោលិយបុត្តោ គោវត្តិកោ អចេលោ ច សេនិយោ កុក្កុរវត្តិកោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា បុណ្ណោ កោលិយបុត្តោ គោវត្តិកោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ អចេលោ បន សេនិយោ កុក្កុរវត្តិកោ ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា កុក្កុរោវ បលិកុណ្ឌិត្វា[១] ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ បុណ្ណោ កោលិយបុត្តោ គោវត្តិកោ ភគវន្តំ ឯតទវោច អយំ ភន្តេ អចេលោ សេនិយោ កុក្កុរវត្តិកោ ទុក្ករការកោ ឆមាយំ និក្ខិត្តំ[២] ភោជនំ ភុញ្ជតិ តស្ស តំ កុក្កុរវត្តំ ទីឃរត្តំ សមត្តំ សមាទិន្នំ តស្ស

---

១ ឱ. បលិកុជ្ជិត្វា ។ ម. បលិគុណ្ឋិត្វា ។ ២ ឱ. ឆមានិក្ខិត្តំ ។

# កុក្កុរោវាទសូត្រ ទី ៧

[៨៤] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងនិគមឈ្មោះហលិទ្ទវសនៈ របស់អ្នកស្រុកកោលិយៈ ក្នុងកោលិយជនបទ ។ លំដាប់នោះ កោលិយបុត្រឈ្មោះបុណ្ណៈ ជាអ្នកសមាទានគោវត្ត និងអចេលឈ្មោះសេនិយៈ ជាអ្នកសមាទានកុក្កុរវត្ត បានចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបបុណ្ណកោលិយបុត្រ ជាអ្នកសមាទានគោវត្ត ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ចំណែកខាងសេនិយអចេល អ្នកសមាទានកុក្កុរវត្ត ក៏រីករាយពក់ទាក់ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយដើមហ៊ើមធ្វើដូចជាសុនខនៅក្នុងទីដ៏សមគួរ ។ ឯបុណ្ណកោលិយបុត្រជាអ្នកសមាទានគោវត្តអង្គុយនៅ ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សេនិយអចេលនេះ ជាអ្នកសមាទានកុក្កុរវត្ត ជាអ្នកធ្វើនូវអំពើដ៏កម្រ បរិភោគនូវភោជនដាក់នៅលើផែនដី សេនិយអចេលនោះបានធ្វើឲ្យពេញបរិបូណ៌ បានសមាទានកុក្កុរវត្តនោះ អស់កាលជាយូរអង្វែងមកហើយ ចុះសេនិយអចេលនោះ

កា គតិ កោ អភិសម្បរាយោតិ ។ អលំ បុណ្ណ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ ទុតិយម្បិ ខោ បុណ្ណោ កោលិយបុត្តោ គោវត្តិកោ ភគវន្តំ ឯតទវោច អយំ ភន្តេ អចេលោ សេនិយោ កុក្កុរវត្តិកោ ទុក្ករការកោ ឆមាយំ និក្ខិត្តំ ភោជនំ ភុញ្ជតិ តស្ស តំ កុក្កុរវត្តំ ទីឃរត្តំ សមត្តំ សមាទិន្នំ តស្ស កា គតិ កោ អភិសម្បរាយោតិ ។ អលំ បុណ្ណ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ តតិយម្បិ ខោ បុណ្ណោ កោលិយបុត្តោ គោវត្តិកោ ភគវន្តំ ឯតទវោច អយំ ភន្តេ អចេលោ សេនិយោ កុក្កុរវត្តិកោ ទុក្ករការកោ ឆមាយំ និក្ខិត្តំ ភោជនំ ភុញ្ជតិ តស្ស តំ កុក្កុរវត្តំ ទីឃរត្តំ សមត្តំ សមាទិន្នំ តស្ស កា គតិ កោ អភិសម្បរាយោតិ ។

មានគតិដូចម្តេច មានបរលោកដូចម្តេច ។ ព្រះអង្គត្រាស់ថា នែបុណ្ណៈ ណ្ហើយពាក្យនុ៎ះចូរលើកទុកចុះ អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ ។ បុណ្ណកោលិយបុត្រ ជាអ្នកសមាទានគោវត្ត បានក្រាបទូលព្រះមានព្រះភាគជាគម្រប់ពីរដងថា បពិត្រព្រះអង្គដ៏ចម្រើន សេនិយអចេលនេះជាអ្នកសមាទានកុក្កុរវត្ត ជាអ្នកធ្វើនូវអំពើដ៏កម្រ បរិភោគនូវភោជនដាក់នៅលើផែនដី សេនិយអចេលនោះបានធ្វើឲ្យពេញបរិបូណ៌ បានសមាទានកុក្កុរ-វត្តនោះ អស់កាលជាយូរអង្វែងមកហើយ សេនិយអចេលនោះមានគតិដូចម្តេច មានបរលោកដូចម្តេច ។ នែបុណ្ណៈ ណ្ហើយ ពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ ។ បុណ្ណកោលិយបុត្រជាអ្នកសមា-ទានគោវត្ត ក៏ក្រាបបង្គំទូលព្រះមានព្រះភាគជាគម្រប់បីដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន សេនិយអចេលនេះជាអ្នកសមាទានកុក្កុរវត្ត ជាអ្នកធ្វើនូវអំពើដ៏កម្រ បរិភោគភោជនដាក់នៅលើផែនដី សេនិយអចេលនោះបានធ្វើឲ្យពេញបរិបូណ៌ បានសមាទានកុក្កុរវត្តនោះ អស់កាលជាយូរអង្វែងមកហើយ សេនិយអចេលនោះមានគតិដូចម្តេច មានបរលោកដូចម្តេច ។

គហបតិវគ្គស្ស កុក្កុរោវាទសុត្តេ កុក្កុរវត្តិកគតិ

[៨៤] អទ្ធា ខោ តេ អហំ បុណ្ណ ន លភាមិ អលំ បុណ្ណ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ អបិច តេ អហំ ព្យាករិស្សាមិ ឥធ បុណ្ណ ឯកច្ចោ កុក្កុរវត្តំ ភាវេតិ បរិបុណ្ណំ អព្វោកិណ្ណំ កុក្កុរសីលំ ភាវេតិ បរិបុណ្ណំ អព្វោកិណ្ណំ កុក្កុរចិត្តំ ភាវេតិ បរិបុណ្ណំ អព្វោកិណ្ណំ កុក្កុរាកប្បំ ភាវេតិ បរិបុណ្ណំ អព្វោកិណ្ណំ សោ កុក្កុរវត្តំ ភាវេត្វា បរិបុណ្ណំ អព្វោកិណ្ណំ កុក្កុរសីលំ ភាវេត្វា បរិបុណ្ណំ អព្វោកិណ្ណំ កុក្កុរចិត្តំ ភាវេត្វា បរិបុណ្ណំ អព្វោកិណ្ណំ កុក្កុរាកប្បំ ភាវេត្វា បរិបុណ្ណំ អព្វោកិណ្ណំ កាយស្ស ភេទា បរម្មរណា កុក្កុរានំ សហព្យតំ ឧបបជ្ជតិ សចេ ខោ បនស្ស ឯវំ ទិដ្ឋិ ហោតិ ឥមិនាហំ សីលេន វា វត្តេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ

គហបតិវគ្គ កុក្កុរោវាទសូត្រ គតិរបស់បុគ្គលអ្នកសមាទានកុក្កុរវត្ត

[៨៥] នែបុណ្ណៈ តាមពិត តថាគតមិនចង់ប្រាប់អ្នកទេ (បានជាពោលឃាត់) ថា ម្នាលបុណ្ណៈ ណ្ហើយពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ តែថា ណ្ហើយចុះ តថាគតនឹងប្រាប់ដល់អ្នក ម្នាលបុណ្ណៈ បុគ្គលពួកមួយក្នុងលោកនេះ ចម្រើនកុក្កុរវត្ត[១] ឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរសីលឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរចិត្ត[២] ឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរាកប្បៈ[៣] ឲ្យបរិបូណ៌ ឥតមានចន្លោះ បុគ្គលនោះលុះបានចម្រើនកុក្កុរវត្តឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរសីលឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរចិត្តឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរាកប្បៈឲ្យបរិបូណ៌ ឥតមានចន្លោះហើយ ដល់ទម្លាយរាងកាយបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងសុនខទាំងឡាយ ប្រសិនបើសេនិយអចេលនោះ មានទិដ្ឋិយ៉ាងនេះថា អាត្មាអញ គង់បានជាទេវតាធំ ឬជាទេវតាណាមួយ ដោយសីលនេះផង ដោយវត្តនេះផង ដោយតបៈនេះផង ដោយព្រហ្មចរិយៈនេះផង ពុំខាន

១ កាន់យកនូវការប្រព្រឹត្តដូចជាឆ្កែ ។ ២ ចិត្តរបស់ឆ្កែឬគំនិតដែលឆ្កែតែងគិតថា អញនឹងធ្វើនូវអំពើដែលឆ្កែទាំងឡាយត្រូវធ្វើ តាំងពីថ្ងៃនេះជាដើមទៅ ។ ៣ ធ្វើនូវដំណើរដើរ ឈរ អង្គុយ ដេក ឬធ្វើនូវឧច្ចារៈនិងបស្សាវៈដូចជាឆ្កែ កាលបើឃើញជនទាំងឡាយដទៃហើយ ក៏ញេញធ្មេញបង្ហាញហើយ ធ្វើដំណើរដើរទៅ ។

សាស្ស ហោតិ មិច្ឆាទិដ្ឋិ មិច្ឆាទិដ្ឋិស្ស ខោ អហំ បុណ្ណ ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ វទាមិ និរយំ វា តិរច្ឆានយោនឹ វា ឥតិ ខោ បុណ្ណ សម្បជ្ជមានំ កុក្កុរវត្តំ កុក្កុរានំ សហព្យតំ ឧបនេតិ វិបជ្ជមានំ និរយន្តិ ។ ឯវំ វុត្តេ អចេលោ សេនិយោ កុក្កុរវត្តិកោ បរោទិ អស្សូនិ បវត្តេសិ ។

[៨៦] អថខោ ភគវា បុណ្ណំ កោលិយបុត្តំ គោវត្តិកំ ឯតទវោច ឯតំ ខោ តេ អហំ បុណ្ណ នាលត្ថំ អលំ បុណ្ណ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ នាហំ ភន្តេ ឯតំ រោទាមិ យំ មំ ភគវា ឯវមាហ អបិច មេ ឥទំ ភន្តេ កុក្កុរវត្តំ ទីឃរត្តំ សមត្តំ សមាទិន្នំ អយំ ភន្តេ បុណ្ណោ កោលិយបុត្តោ គោវត្តិកោ តស្ស តំ គោវត្តំ ទីឃរត្តំ សមត្តំ សមាទិន្នំ តស្ស កា គតិ

ទិដ្ឋិរបស់សេនិយអចេលនោះ ឈ្មោះថាមិច្ឆាទិដ្ឋិ នៃបុណ្ណៈ តថាគត ពោលថា បណ្តាគតិទាំងឡាយពីរ គតិណាមួយគឺនរកឬ ឬកំណើតនៃ តិរច្ឆាន ជារបស់បុគ្គលដែលមានចិត្តតាំងនៅក្នុងមិច្ឆាទិដ្ឋិពិត នៃបុណ្ណៈ កុក្កុរវត្ត ដែលបុគ្គលបានធ្វើឲ្យពេញ បើមិនកើតក្នុងនរក ក៏គង់ទៅកើត ជាមួយនឹងសុនខទាំងឡាយពុំលែងឡើយ ។ កាលដែលព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលយ៉ាងនេះហើយ សេនិយអចេលអ្នកសមាទានកុក្កុរវត្ត ក៏ទ្រហោយំ សម្រក់ទឹកភ្នែក ។

[៨៦] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹង បុណ្ណៈ កោលិយបុត្រអ្នកសមាទានគោវត្តយ៉ាងនេះថា នៃបុណ្ណៈ តថាគត មិនបានចង់និយាយហេតុនុ៎ះ ដល់អ្នកសោះ (បានជាពោលឃាត់ថា) នៃបុណ្ណៈ ណ្ហើយពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគត ឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនយំចំពោះព្យាករណ៍ ដែលព្រះមានព្រះភាគ សំដែងដល់ខ្ញុំព្រះអង្គយ៉ាងនេះទេ បពិត្រព្រះអង្គ ដ៏ចម្រើន បានជាខ្ញុំព្រះអង្គយំ ព្រោះខ្ញុំព្រះអង្គបានបំពេញ សមាទាន កុក្កុរវត្តនេះ អស់កាលជាយូរអង្វែងមកហើយ បពិត្រព្រះអង្គដ៏ចម្រើន ចុះ បុណ្ណកោលិយបុត្រ ជាអ្នកសមាទានគោវត្តនេះ គេបានបំពេញ សមា-ទានគោវត្តនោះ អស់កាលជាយូរអង្វែងមកហើយដែរ គេមានគតិដូចម្តេច

កោ អភិសម្បរាយោតិ ។ អលំ សេនិយ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ ទុតិយម្បិ ខោ អចេលោ សេនិយោ ។ បេ ។ តតិយម្បិ ខោ អចេលោ សេនិយោ កុក្កុរវត្តិកោ ភគវន្តំ ឯតទវោច អយំ ភន្តេ បុណ្ណោ កោលិយបុត្តោ គោវត្តិកោ តស្ស តំ គោវត្តំ ជីឃរត្តំ សមត្តំ សមាទិន្នំ តស្ស កា គតិ កោ អភិសម្បរាយោតិ ។ អទ្ធា ខោ តេ អហំ សេនិយ ន លភាមិ អលំ សេនិយ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ អបិច តេ អហំ ព្យាករិស្សាមិ ឥធ សេនិយ ឯកច្ចោ គោវត្តំ ភាវេតិ បរិបុណ្ណំ អព្វោកិណ្ណំ គោសីលំ ភាវេតិ បរិបុណ្ណំ អព្វោកិណ្ណំ គោចិត្តំ ភាវេតិ បរិបុណ្ណំ អព្វោកិណ្ណំ គវាកប្បំ ភាវេតិ បរិបុណ្ណំ អព្វោកិណ្ណំ សោ គោវត្តំ ភាវេត្វា បរិបុណ្ណំ អព្វោកិណ្ណំ គោសីលំ ភាវេត្វា បរិបុណ្ណំ អព្វោកិណ្ណំ

មានបរលោកដូចម្ដេច ។ នៃសេនិយៈ ណ្ហើយ ពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះ នឹងតថាគតឡើយ ។ សេនិយអចេលបានក្រាបទូលជាគម្រប់ពីរដងផង ។ បេ ។ សេនិយអចេលអ្នកសមាទានកុក្កុរវត្ត ក៏ក្រាបទូលព្រះមានព្រះភាគ គម្រប់ ៣ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុណ្ណកោលិយបុត្រនេះ ជាអ្នកសមាទានគោវត្ត គេបានបំពេញ បានសមាទានគោវត្តនោះ អស់កាលជាយូរអង្វែងមកហើយ គេមានគតិដូចម្ដេច មានបរលោកដូចម្ដេច ។ ម្នាលសេនិយៈ តថាគតមិនចង់ប្រាប់ដល់អ្នកសោះ (បានជាពោលឃាត់) ថា នៃសេនិយៈ ណ្ហើយ ពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ តែថាណ្ហើយចុះ តថាគតនឹងប្រាប់ដល់អ្នក ម្នាលសេនិយៈ បុគ្គលមួយពួកក្នុងលោកនេះ ចម្រើនគោវត្ត[១] ឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនគោសីល[២] ឲ្យបរិបូណ៌ ឥតចន្លោះ ចម្រើនគោចិត្ត[៣] ឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនគវាកប្បៈ[៤] ឲ្យបរិបូណ៌ ឥតមានចន្លោះ លុះបុគ្គលនោះ បានចម្រើនគោវត្តឲ្យបរិបូណ៌ ឥតមានចន្លោះ បានចម្រើនគោសីលឲ្យបរិបូណ៌ ឥតមានចន្លោះ

---

១ កាន់យកនូវការប្រព្រឹត្តដូចជាគោ ។ ២ ប្រក្រតីឬមារយាទរបស់គោ ។ ៣ ចិត្តរបស់គោ ឬគំនិតដែលគោតែងគិតយ៉ាងណា ៗ ។ ៤ ដូចគ្នានឹងកុក្កុរាកប្បៈ ប្លែកគ្នាតែសុនខញែញធ្មេញ គោត្រឡប់ទៅជាដំឡើងស្លឹកត្រចៀកអួតដល់គ្នាប៉ុណ្ណោះ ។

គោចិត្តំ ភាវេត្វា បរិបុណ្ណំ អព្វោកិណ្ណំ គវាកប្បំ ភាវេត្វា បរិបុណ្ណំ អព្វោកិណ្ណំ កាយស្ស ភេទា បរម្មរណា គុន្នំ សហព្យតំ ឧបបជ្ជតិ សចេ ខោ បនស្ស ឯវំ ទិដ្ឋិ ហោតិ ឥមិនាហំ សីលេន វា វត្តេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ សាស្ស ហោតិ មិច្ឆាទិដ្ឋិ មិច្ឆាទិដ្ឋិស្ស ខោ អហំ សេនិយ ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ វទាមិ និរយំ វា តិរច្ឆានយោនឹ វា ឥតិ ខោ សេនិយ សម្បជ្ជមានំ គោវត្តំ គុន្នំ សហព្យតំ ឧបនេតិ វិបជ្ជមានំ និរយន្តិ ។ ឯវំ វុត្តេ បុណ្ណោ កោលិយបុត្តោ គោវត្តិកោ បរោទិ អស្សូនិ បវត្តេសិ ។

បានចម្រើនគោចិត្តឲ្យបរិបូណ៌ ឥតមានចន្លោះ បានចម្រើនគវាកប្បៈ ឲ្យបរិ-បូណ៌ ឥតមានចន្លោះហើយ ដល់ទម្លាយរាងកាយបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងគោទាំងឡាយ ប្រសិនបើបុណ្ណកោលិយបុត្រនោះមានទិដ្ឋិយ៉ាងនេះថា អាត្មាអញ គង់នឹងបានជាទេវតាធំ ឬជាទេវតាណាមួយដោយសីលនេះផង ដោយវត្តនេះផង ដោយតបៈនេះផង ដោយព្រហ្មចរិយៈនេះផងមិនខាន ទិដ្ឋិរបស់បុណ្ណកោលិយបុត្រនោះ ឈ្មោះថាមិច្ឆាទិដ្ឋិ ម្នាលសេនិយៈ តថាគតពោលថា បណ្តាគតិទាំងឡាយពីរគតិណាមួយ គឺនរកឬ ឬថាកំណើតនៃតិរច្ឆាន របស់បុគ្គលដែលមានចិត្តតាំងនៅក្នុងមិច្ឆាទិដ្ឋិពិត ម្នាលសេនិយៈ គោវត្តដែលបុគ្គលបានបំពេញឲ្យបរិបូណ៌យ៉ាងនេះហើយ បើមិនកើតក្នុងនរក ក៏គង់ទៅកើតជាមួយនឹងគោទាំងឡាយមិនខានឡើយ ។ កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលយ៉ាងនេះហើយ បុណ្ណកោលិយបុត្រ ជាអ្នកសមាទានគោវត្ត ក៏ទ្រហោយំ សម្រក់ទឹកភ្នែក ។

គហបតិវគ្គស្ស កុក្កុរោវាទសុត្តេ ភគវន្តប្បសាទប្បកាសនំ

[៨៧] អថខោ ភគវា អចេលំ សេនិយំ កុក្កុរវត្តិកំ ឯតទវោច ឯតំ ខោ តេ អហំ សេនិយ នាលត្ថំ អលំ សេនិយ តិដ្ឋតេតំ មា មំ ឯតំ បុច្ឆីតិ ។ នាហំ ភន្តេ ឯតំ លភាមិ យំ មំ ភគវា ឯវមាហ អបិច មេ ឥទំ ភន្តេ គោវត្តំ ទីឃរត្តំ សមត្តំ សមាទិន្នំ ឯវំ បសន្នោ អហំ ភន្តេ ភគវតិ បហោតិ ភគវា តថា ធម្មំ ទេសេតុ យថា អហញ្ចេវិមំ គោវត្តំ បជហេយ្យំ អយញ្ច អចេលោ សេនិយោ កុក្កុរវត្តិកោ តំ កុក្កុរវត្តំ បជហេយ្យាតិ ។ តេនហិ បុណ្ណ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ បុណ្ណោ កោលិយបុត្តោ គោវត្តិកោ ភគវតោ បច្ចស្សោសិ ។

[៨៧] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងសេនិយអចេល អ្នកសមាទានកុក្កុរវត្តយ៉ាងនេះថា ម្នាលសេនិយៈ តថាគត មិនបាន (ចង់ប្រាប់) ហេតុនុ៎ះ ដល់អ្នកសោះ (បានជាពោលឃាត់) ថា នែសេនិយៈ ណ្ហើយពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនយំចំពោះព្យាករណ៍ដែលព្រះមានព្រះភាគ សំដែងដល់ខ្ញុំព្រះអង្គយ៉ាងនេះទេ បពិត្រព្រះអង្គដ៏ចម្រើន បានជាខ្ញុំព្រះអង្គយំ ព្រោះខ្ញុំព្រះអង្គបានបំពេញ បានសមាទានគោវត្តនេះ អស់កាលយូរអង្វែងមកហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្ដីជ្រះថ្លា ក្នុងព្រះមានព្រះភាគយ៉ាងនេះ សូមព្រះមានព្រះភាគ សំដែងធម៌ដែលគួរឲ្យខ្ញុំព្រះអង្គលះបង់គោវត្តនោះចេញបាន ។ ម្នាលបុណ្ណៈ បើដូច្នោះអ្នកចូរស្ដាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងឥឡូវនេះ ។ បុណ្ណកោលិយបុត្រ អ្នកសមាទានគោវត្ត ក៏ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។

[៨៨] ភគវា ឯតទវោច ចត្តារិមានិ បុណ្ណ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ កតមានិ ចត្តារិ អត្ថិ បុណ្ណ កម្មំ កណ្ហំ កណ្ហវិបាកំ អត្ថិ បុណ្ណ កម្មំ សុក្កំ សុក្កវិបាកំ អត្ថិ បុណ្ណ កម្មំ កណ្ហសុក្កំ កណ្ហសុក្កវិបាកំ អត្ថិ បុណ្ណ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ[១] កម្មក្ខយាយ សំវត្តតីតិ[២] ។ កតមញ្ច បុណ្ណ កម្មំ កណ្ហំ កណ្ហវិបាកំ ឥធ បុណ្ណ ឯកច្ចោ សព្យាបជ្ឈំ[៣] កាយសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរោតិ សោ សព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ លោកំ ឧបបជ្ជតិ

---

១ ឱ. ឥធ កម្មន្តិ បាឋោ ទិស្សតិ ។ ២ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។ ៣ ឱ. សព្យាពជ្ឈំ ។ ម. សព្យាពជ្ធំ ។

[៨៨] ព្រះមានព្រះភាគ ទ្រង់សំដែងថា ម្នាលបុណ្ណៈ កម្មទាំង-ឡាយ ៤ ប្រការនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងដោយប្រាជ្ញាខ្លួនឯង កម្មទាំងឡាយ ៤ ប្រការតើដូចម្តេច ម្នាលបុណ្ណៈ កម្ម[១] ខ្មៅ មានវិបាកខ្មៅ[២] ១ ម្នាលបុណ្ណៈ កម្មស[៣] មានវិបាកស[៤] ១ ម្នាលបុណ្ណៈ កម្មខ្មៅនិងកម្មស[៥] មានវិបាកខ្មៅនិងស[៦] ១ ម្នាលបុណ្ណៈ កម្មមិនខ្មៅមិនស[៧] មានវិបាកមិនខ្មៅមិនស តែងប្រព្រឹត្តទៅដើម្បីអស់ទៅនៃកម្ម ១ ។ ម្នាលបុណ្ណៈ ឯកម្មខ្មៅ មានវិបាកខ្មៅនោះដូចម្តេច ម្នាលបុណ្ណៈ បុគ្គលពួកមួយ ក្នុងលោកនេះ តាក់តែងនូវកាយសង្ខារប្រកបដោយព្យាបាទ តាក់តែងនូវវចីសង្ខារ ប្រកបដោយព្យាបាទ តាក់តែងនូវមនោសង្ខារ ប្រកបដោយព្យាបាទ បុគ្គលនោះ លុះបានតាក់តែងនូវកាយសង្ខារ ប្រកបដោយព្យាបាទ តាក់តែងនូវវចី-សង្ខារ ប្រកបដោយព្យាបាទ តាក់តែងនូវមនោសង្ខារ ប្រកបដោយព្យាបាទហើយ ក៏ទៅកើតក្នុងលោក ដែលប្រកបដោយព្យាបាទ

---

១ បានដល់អកុសលកម្មបថ ១០ ប្រការ ។ ២ នាំឲ្យទៅកើតក្នុងអបាយ ។ ៣ បានដល់កុសលកម្មបថ ១០ ប្រការ ។ ៤ នាំឲ្យកើតក្នុងឋានសួគ៌ ។ ៥ កម្មខ្មៅនិងសច្រឡូកច្រឡំ ។ ៦ ឲ្យផលជាសុខខ្លះជាទុក្ខខ្លះ ។ ៧ បានដល់ចេតនាកម្មដ៏សម្បយុត្តដោយមគ្គ ៤ ។

តមេនំ សព្យាបជ្ឈំ លោកំ ឧបបន្នំ សមានំ សព្យា-
បជ្ឈា ផស្សា ផុសន្តិ សោ សព្យាបជ្ឈេហិ ផស្សេហិ
ផុដ្ឋោ សមានោ សព្យាបជ្ឈំ វេទនំ វេទេតិ ឯកន្តទុក្ខំ
សេយ្យថាបិ សត្តា នេរយិកាតិ[១] ឥតិ ខោ បុណ្ណ
ភូតា ភូតស្ស ឧបបត្តិ ហោតិ យំ ករោតិ តេន
ឧបបជ្ជតិ ឧបបន្នមេតំ ផស្សា ផុសន្តិ ឯវម្បាហំ បុណ្ណ
កម្មទាយាទា សត្តាតិ វទាមិ ឥទំ វុច្ចតិ បុណ្ណ កម្មំ
កណ្ហំ កណ្ហវិបាកំ ។ កតមញ្ច បុណ្ណ កម្មំ សុក្កំ
សុក្កវិបាកំ ឥធ បុណ្ណ ឯកច្ចោ អព្យាបជ្ឈំ កាយ-
សង្ខារំ អភិសង្ខរោតិ អព្យាបជ្ឈំ វចីសង្ខារំ អភិ-
សង្ខរោតិ អព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរោតិ សោ
អព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរិត្វា អព្យាបជ្ឈំ វចី-
សង្ខារំ អភិសង្ខរិត្វា អព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខ-
រិត្វា អព្យាបជ្ឈំ លោកំ ឧបបជ្ជតិ តមេនំ អព្យាបជ្ឈំ
លោកំ ឧបបន្នំ សមានំ អព្យាបជ្ឈា ផស្សា ផុសន្តិ សោ

---

១ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។

គហបតិវគ្គ កុក្កុរោវាទសូត្រ កម្ម ៤ យ៉ាង

ផស្សៈទាំងឡាយ ប្រកបដោយព្យាបាទ តែងពាល់ត្រូវបុគ្គលដែលទៅកើតក្នុងលោកប្រកបដោយព្យាបាទនោះឯង បុគ្គលនោះ កាលដែលផស្សៈទាំងឡាយប្រកបដោយព្យាបាទពាល់ត្រូវហើយ រមែងសោយនូវវេទនាប្រកបដោយព្យាបាទ ជាទុក្ខតែមួយយ៉ាង ដូចសត្វទាំងឡាយដែលកើតក្នុងនរក ម្នាលបុណ្ណៈ កំណើតនៃសត្វរមែងកើតអំពីភូតកម្មដូច្នេះឯង បុគ្គលធ្វើកម្មណា តែងទៅកើតដោយអំណាចនៃកម្មនោះ ផស្សៈទាំងឡាយ តែងពាល់ត្រូវបុគ្គល ដែលកើតឡើងហើយនោះ ម្នាលបុណ្ណៈ យ៉ាងនេះឯងបានជាតថាគតពោលថា សត្វទាំងឡាយ មានកម្មជាមត៌ក ម្នាលបុណ្ណៈ នេះហៅថាកម្មខ្មៅ មានវិបាកខ្មៅ ។ ម្នាលបុណ្ណៈ កម្មសមានវិបាកស តើដូចម្តេច ម្នាលបុណ្ណៈ បុគ្គលពួកមួយក្នុងលោកនេះ តាក់តែងនូវកាយសង្ខារ មិនប្រកបដោយព្យាបាទ តាក់តែងនូវវចីសង្ខារ មិនប្រកបដោយព្យាបាទ តាក់តែងនូវមនោសង្ខារ មិនប្រកបដោយព្យាបាទ បុគ្គលនោះ លុះបានតាក់តែងនូវកាយសង្ខារ មិនប្រកបដោយព្យាបាទ តាក់តែងនូវវចីសង្ខារ មិនប្រកបដោយព្យាបាទ តាក់តែងនូវមនោសង្ខារ មិនប្រកបដោយព្យាបាទហើយ ក៏តែងទៅកើតក្នុងលោកមិនមានព្យាបាទឡើយ ផស្សៈទាំងឡាយ មិនមានព្យាបាទ តែងពាល់ត្រូវបុគ្គលដែលចូលទៅកើតក្នុងលោក មិនមានព្យាបាទនោះឯង បុគ្គលនោះ

អព្យាបជ្ឈេហិ ផស្សេហិ ផុដ្ឋោ សមានោ អព្យាបជ្ឈំ វេទនំ វេទេតិ ឯកន្តសុខំ សេយ្យថាបិ ទេវា សុភកិណ្ហា ឥតិ ខោ បុណ្ណ ភូតា ភូតស្ស ឧបបត្តិ ហោតិ យំ ករោតិ តេន ឧបបជ្ជតិ ឧបបន្នមេតំ ផស្សា ផុសន្តិ ឯវម្បាហំ បុណ្ណ កម្មទាយាទា សត្តាតិ វទាមិ ឥទំ វុច្ចតិ បុណ្ណ កម្មំ សុក្កំ សុក្កវិបាកំ ។ កតមញ្ច បុណ្ណ កម្មំ កណ្ហសុក្កំ កណ្ហសុក្កវិបាកំ ឥធ បុណ្ណ ឯកច្ចោ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ កាយសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ វចីសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ មនោសង្ខារំ អភិសង្ខរោតិ សោ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ កាយសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ វចីសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ មនោសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ លោកំ ឧបបជ្ជតិ

កាលដែលផស្សៈទាំងឡាយ មិនមានព្យាបាទពាល់ត្រូវហើយ រមែងទទួលនូវវេទនា ដែលមិនប្រកបដោយព្យាបាទ មានតែសេចក្តីសុខមួយយ៉ាង ដូចទេវតាទាំងឡាយ នៅក្នុងឋានឈ្មោះសុភកិណ្ហៈ ម្នាលបុណ្ណៈ កំណើតនៃសត្វរមែងកើតអំពីភូតកម្មដូច្នេះឯង បុគ្គលធ្វើកម្មណា តែងទៅកើតដោយអំណាចកម្មនោះ ផស្សៈទាំងឡាយ តែងពាល់ត្រូវបុគ្គលដែលកើតឡើងហើយនោះ ម្នាលបុណ្ណៈ យ៉ាងនេះឯង បានជាតថាគតពោលថា សត្វទាំងឡាយមានកម្មជាមត៌ក ម្នាលបុណ្ណៈ នេះហៅថាកម្មស មានវិបាកស ។ ម្នាលបុណ្ណៈ កម្មខ្មៅនិងកម្មស មានវិបាកខ្មៅនិងស តើដូចម្តេច ម្នាលបុណ្ណៈ បុគ្គលពួកមួយក្នុងលោកនេះ តាក់តែងនូវកាយសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ តាក់តែងនូវវចីសង្ខារប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ តាក់តែងនូវមនោសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ បុគ្គលនោះ លុះបានតាក់តែងនូវកាយសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ បានតាក់តែងនូវវចីសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ បានតាក់តែងនូវមនោសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះហើយ តែងទៅកើតក្នុងលោក ដែលប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ

តមេនំ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ លោកំ ឧបបន្នំ សមានំ សព្យាបជ្ឈាបិ អព្យាបជ្ឈាបិ ផស្សា ផុសន្តិ សោ សព្យាបជ្ឈេហិបិ អព្យាបជ្ឈេហិបិ ផស្សេហិ ផុដ្ឋោ សមានោ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ វេទនំ វេទេតិ វោកិណ្ណំ សុខទុក្ខំ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា ឥតិ ខោ បុណ្ណ ភូតា ភូតស្ស ឧបបត្តិ ហោតិ យំ ករោតិ តេន ឧបបជ្ជតិ ឧបបន្នមេតំ ផស្សា ផុសន្តិ ឯវម្បាហំ បុណ្ណ កម្មទាយាទា សត្តាតិ វទាមិ ឥទំ វុច្ចតិ បុណ្ណ កម្មំ កណ្ហសុក្កំ កណ្ហសុក្កវិបាកំ ។ កតមញ្ច បុណ្ណ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ តត្រ បុណ្ណ យមិទំ កម្មំ កណ្ហំ កណ្ហវិបាកំ តស្ស បហានាយ យា ចេតនា យមិទំ កម្មំ សុក្កំ សុក្កវិបាកំ តស្ស បហានាយ យា ចេតនា យមិទំ កម្មំ កណ្ហសុក្កំ កណ្ហសុក្កវិបាកំ តស្ស បហានាយ យា ចេតនា ឥទំ វុច្ចតិ បុណ្ណ កម្មំ

ផស្សៈទាំងឡាយប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ តែង ពាល់ត្រូវបុគ្គល ដែលទៅកើតក្នុងលោក ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះនោះឯង បុគ្គលនោះកាលដែលផស្សៈទាំងឡាយ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះពាល់ត្រូវហើយ រមែង ទទួលនូវវេទនា ដែលប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទ ខ្លះ មានសុខនិងទុក្ខច្រឡូកច្រឡំគ្នា ដូចជាមនុស្សទាំងឡាយខ្លះ ទេវតា ទាំងឡាយពួកខ្លះ វិនិបាតិកៈទាំងឡាយពួកខ្លះ ម្នាលបុណ្ណៈ កំណើត នៃសត្វ រមែងកើតអំពីភូតកម្មដូច្នេះឯង បុគ្គលធ្វើកម្មណា តែងទៅកើត ដោយអំណាចកម្មនោះ ផស្សៈទាំងឡាយ តែងពាល់ត្រូវបុគ្គល ដែលកើត ឡើងហើយនោះឯង ម្នាលបុណ្ណៈ យ៉ាងនេះឯង បានជាតថាគតពោលថា សត្វទាំងឡាយមានកម្មជាមត៌ក ម្នាលបុណ្ណៈ នេះឯងហៅថាកម្មខ្មៅនិងកម្មស មានវិបាកខ្មៅនិងស ។ ម្នាលបុណ្ណៈ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស រមែងប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ម្នាលបុណ្ណៈ មគ្គចេតនាដែល សម្រាប់លះបង់កម្មខ្មៅមានផលខ្មៅ មគ្គចេតនា ដែលសម្រាប់លះបង់ កម្មសមានផលស មគ្គចេតនា ដែលសម្រាប់លះបង់កម្មខ្មៅនិងសមាន វិបាកខ្មៅនិងស ម្នាលបុណ្ណៈ បណ្តាកម្មទាំង ៣ យ៉ាងនោះ កម្មនេះហៅថា

អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ ឥមានិ ខោ បុណ្ណ ចត្តារិ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានីតិ ។

[៨៩] ឯវំ វុត្តេ បុណ្ណោ កោលិយបុត្តោ គោវត្តិកោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្ប-ជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកា-សិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ អចេលោ បន[១] សេនិ-យោ កុក្កុរវត្តិកោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ

១ បនសទ្ទោ កត្ថចិ ន ទិស្សតិ ។

កម្មមិនខ្មៅ មិនស មានវិបាកមិនខ្មៅ មិនស ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃកម្ម ។ ម្នាលបុណ្ណៈ កម្មទាំងឡាយ ៤ នេះឯង ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងដោយបញ្ញាខ្លួនឯង ។

[៨៩] កាលដែលព្រះមានព្រះភាគ ទ្រង់មានព្រះវាចាយ៉ាងនេះហើយ ទើបបុណ្ណកោលិយបុត្រ ជាអ្នកសមាទាននូវគោវត្ត ក៏ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ប្រកាសហើយ ដោយអនេកបរិយាយនេះឯង (ភ្លឺច្បាស់ណាស់) ដូចជាបុគ្គលផ្ងាររបស់ដែលផ្កាប់ ឬក៏ដូចជាបុគ្គលបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចគេទ្រោលប្រទីបក្នុងទីងងឹត ឲ្យមនុស្សដែលមានភ្នែកភ្លឺមើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់ នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវសរណគមន៍ ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះទៅ ។ ឯសេនិយអចេល អ្នកសមាទានកុក្កុរវត្ត ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រ

អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ យោ ខោ សេនិយ អញ្ញតិត្ថិយបុព្វោ ឥមស្មឹ ធម្មវិនយេ អាកង្ខតិ បព្វជ្ជំ អាកង្ខតិ ឧបសម្បទំ សោ ចត្តារោ មាសេ បរិវសតិ ចតុន្នំ មាសានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តិ ឧបសម្បាទេន្តិ ភិក្ខុភាវាយ អបិច មេត្ថ បុគ្គលវេមត្តតា វិទិតាតិ ។

[៩០] សចេ ខោ ភន្តេ[១] អញ្ញតិត្ថិយបុព្វា ឥមស្មឹ ធម្មវិនយេ អាកង្ខន្តា បព្វជ្ជំ អាកង្ខន្តា ឧបសម្បទំ

១ ឱ. ម. សចេ ភន្តេ ។

ព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើនទ្រង់ប្រកាស ដោយអនេកបរិយាយនេះឯង (ភ្លឺច្បាស់ណាស់) ដូចជាបុគ្គលផ្ងាររបស់ដែលផ្កាប់ ឬដូចជាបុគ្គលបើកបង្ហាញរបស់ដែលកំបាំង ពុះនោះដូចជាគេប្រាប់ផ្លូវ ដល់អ្នកវង្វេងទិស ពុំនោះសោតដូចគេទ្រោលប្រទីបក្នុងទីងងឹត ឲ្យមនុស្សមានភ្នែកភ្លឺ មើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាទីពឹងទីរលឹក ខ្ញុំព្រះអង្គគប្បីបាននូវបព្វជ្ជានិងឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ម្នាលសេនិយៈ បុគ្គលណាមួយធ្លាប់ជាអន្យតិរ្ថិយ ហើយប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម្មវិន័យនេះ បុគ្គលនោះលុះតែនៅបរិវាសអស់ ៤ ខែ លុះកាលកន្លងទៅអស់ ៤ ខែហើយ ទើបភិក្ខុទាំងឡាយ ដែលមានចិត្តខ្នះខ្នែង ក៏ឲ្យបព្វជ្ជានិងឧបសម្បទាជាភិក្ខុភាវៈបាន មួយវិញទៀត ការផ្សេងនៃបុគ្គលក្នុងទីនេះ[១] តថាគតបានដឹងច្បាស់ហើយ ។

[៩០] បពិត្រព្រះអង្គដ៏ចម្រើន បើបុគ្គលទាំងឡាយ ធ្លាប់ជាអន្យតិរ្ថិយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទា ក្នុងធម្មវិន័យនេះ ហើយ

---

១ បុគ្គលផ្សេងនោះ គឺផ្សេងថា បុគ្គលនេះគួរនៅបរិវាស បុគ្គលនេះមិនគួរនៅបរិវាស ។ អដ្ឋកថា ។

ចត្តារោ មាសេ បរិវសន្តិ ចតុន្នំ មាសានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តិ ឧបសម្បាទេន្តិ ភិក្ខុភា-វាយ អហំ ចត្តារិ វស្សានិ បរិវសិស្សាមិ ចតុន្នំ វស្សានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តុ ឧបសម្បាទេន្តុ ភិក្ខុភាវាយាតិ ។ អលត្ថ ខោ អចេលោ សេនិយោ កុក្កុរវត្តិកោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧប-សម្បទំ ។ អចិរូបសម្បន្នោ ខោ បនាយស្មា សេនិយោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយ-បរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ចេ[១] ខោ បនាយស្មា សេនិយោ អរហតំ អហោសីតិ ។

កុក្កុរោវាទសុត្តំ សត្តមំ[២] និដ្ឋិតំ ។

១ ឱ. ចសទ្ទោ នត្ថិ ។ ២ ម. វ ។

*នៅបរិវាសអស់ ៤ ខែ លុះកាលកន្លងទៅអស់ ៤ ខែហើយ ភិក្ខុទាំងឡាយ ដែលមានចិត្តខ្ជះខ្ជែង ក៏ឲ្យបព្វជ្ជា ឲ្យឧបសម្បទាជាភិក្ខុភាវៈ ខ្ញុំព្រះអង្គ នឹងនៅបរិវាស អស់ ៤ វស្សាក៏បាន លុះកាលកន្លងទៅអស់ ៤ វស្សា ហើយ ភិក្ខុទាំងឡាយដែលមានចិត្តខ្ជះខ្ជែង ក៏ឲ្យបព្វជ្ជានិងឧបសម្បទាជា ភិក្ខុភាវៈ ។ ឯសេនិយអចេល អ្នកសមាទាននូវកុក្កុរវត្ត ក៏បាននូវបព្វជ្ជា និងឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគ ។ លុះសេនិយភិក្ខុមាន អាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង ជា បុគ្គលមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូន ទៅកាន់ព្រះនិព្វាន កុលបុត្រទាំងឡាយ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដោយត្រឹមត្រូវ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន ក៏បានត្រាស់ដឹងធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះដែលមានព្រហ្មចរិយៈ ជាទីបំផុតដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តដោយឥរិយាបថ ទាំង ៤ ដឹងច្បាស់ថា ជាតិរបស់អញអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញ បានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ កិច្ច ដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះ មិនមានឡើយ ។ បណ្តាពួក ព្រះអរហន្ត សេនិយភិក្ខុមានអាយុ បានជាព្រះអរហន្តមួយអង្គដែរ ។*

ចប់ កុក្កុរវាទសូត្រ ទី ៧ ។

# អដ្ឋមំ អភយរាជកុមារសុត្តំ

[៩១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កឡន្ទកនិវាបេ ។ អថខោ អភយោ រាជកុមារោ យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា និគណ្ឋំ នាដបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[៩២] ឯកមន្តំ និសិន្នំ ខោ អភយំ ខោ រាជកុមារំ និគណ្ឋោ នាដបុត្តោ ឯតទវោច ឯហិ ត្វំ រាជកុមារ សមណស្ស គោតមស្ស វាទំ អារោបេហិ ឯវំ តេ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆិស្សតិ[១] អភយេន រាជកុមារេន សមណស្ស គោតមស្ស ឯវំមហិទ្ធិកស្ស ឯវំមហានុភាវស្ស វាទោ អារោបិតោតិ ។ យថាកថំ បនាហំ ភន្តេ សមណស្ស គោតមស្ស ឯវំមហិទ្ធិកស្ស ឯវំមហានុភាវស្ស វាទំ អារោបេស្សាមីតិ ។ ឯហិ ត្វំ រាជកុមារ យេន សមណោ គោតមោ តេនុបសង្កម ឧបសង្កមិត្វា សមណំ គោតមំ ឯវំ វទេហិ

១ ឱ. អព្ភុគញ្ជីតិ ។ ម. អព្ភុគច្ឆតិ ។

# អភយរាជកុមារសូត្រ ទី ៨

[៩១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្នុងក្រុងរាជគ្រឹះ ។ គ្រានោះ អភយរាជកុមារ[១] ចូលទៅរកនិគន្ថនាដបុត្រ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំនិគន្ថនាដបុត្រ រួចអង្គុយនៅក្នុងទីសមគួរ ។

[៩២] និគន្ថនាដបុត្រ បាននិយាយនឹងអភយរាជកុមារ ដែលអង្គុយនៅ ក្នុងទីសមគួរយ៉ាងនេះថា ម្នាលរាជកុមារ ទ្រង់ចូរមក ចូរទ្រង់លើកឡើងនូវវាទៈ គឺលើកវាទៈ ចំពោះព្រះសមណគោតម ទ្រង់នឹងមានកិត្តិសព្ទដ៏ពីរោះល្បីខ្ចរខ្ចាយទៅយ៉ាងនេះថា អភយរាជកុមារហ៊ានលើកវាទៈព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ។ អភយរាជកុមារសួរថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងលើកទោសព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយប្រការដូចម្តេច ។ និគន្ថនាដបុត្រឆ្លើយថា ម្នាលរាជកុមារ ទ្រង់ចូរមក ចូរទ្រង់ទៅរកព្រះសមណគោតមថា លុះចូលទៅដល់ហើយ ចូរពោលយ៉ាងនេះ នឹងព្រះសមណគោតមថា បពិត្រ

---

១ ជាព្រះរាជឱរស របស់ព្រះបាទពិម្ពិសារ ។ អដ្ឋកថា ។

ភាសេយ្យ នុ ខោ ភន្តេ តថាគតោ តំ វាចំ យា សា វាចា បរេសំ អប្បិយា អមនាបាតិ សចេ បន តេ[១] សមណោ គោតមោ ឯវំ បុដ្ឋោ ឯវំ ព្យាករោតិ ភាសេយ្យ រាជកុមារ តថាគតោ តំ វាចំ សា វាចា បរេសំ អប្បិយា អមនាបាតិ តមេនំ ត្វំ ឯវំ វទេយ្យាសិ អថ កិញ្ចរហិ តេ ភន្តេ បុថុជ្ជនេន នានាករណំ បុថុជ្ជនោបិ ហិ តំ វាចំ ភាសេយ្យ យា សា វាចា បរេសំ អប្បិយា អមនាបាតិ សចេ បន តេ សមណោ គោតមោ ឯវំ បុដ្ឋោ ឯវំ ព្យាករោតិ ន រាជកុមារ តថាគតោ តំ វាចំ ភាសេយ្យ យា សា វាចា បរេសំ អប្បិយា អមនាបាតិ តមេនំ ត្វំ ឯវំ វទេយ្យាសិ អថ កិញ្ចរហិ តេ ភន្តេ ទេវទត្តោ ព្យាកតោ អាបាយិកោ ទេវទត្តោ នេរយិកោ ទេវទត្តោ កប្បដ្ឋោ ទេវទត្តោ អតេកិច្ឆោ

១ ឱ. សចេ តេ ។

ព្រះអង្គដ៏ចម្រើន វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ ព្រះតថាគតគប្បីពោលវាចានោះដែរឬទេ ប្រសិនបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតម នឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគត គប្បីពោលវាចានោះដែរ ទ្រង់គប្បីពោលនឹងព្រះសមណគោតម យ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ អំពើរបស់ព្រះអង្គ ផ្សេងអ្វីអំពីបុថុជ្ជន ព្រោះថា វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ បុថុជ្ជនក៏ពោលនូវវាចានេះដែរ ប្រសិនបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតម គង់នឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណាមិនជាទីស្រឡាញ់ មិនជាគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតមិនពោលនូវវាចានោះទេ ទ្រង់គប្បីពោលនឹងសមណគោតមនោះ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះហេតុអ្វី បានជាព្រះអង្គទ្រង់ព្យាករទេវទត្តថា ទេវទត្តកើតក្នុងអបាយ ទេវទត្តកើតក្នុងនរក ទេវទត្តឋិតនៅអស់ ១ កប្ប ទេវទត្ត (បើទុកជាពាន់នៃព្រះពុទ្ធ) ក៏មិនអាចជួយកែបាន

ទេវទត្តោតិ តាយ ច បន តេ វាចាយ ទេវទត្តោ កុបិតោ អហោសិ អនត្តមនោតិ ។ ឥមំ ខោ តេ រាជកុមារ សមណោ គោតមោ ឧភតោកោដិកំ បញ្ហំ បុដ្ឋោ សមានោ នេវ សក្ខិតិ ឧគ្គិលិតុំ នេវ សក្ខិតិ ឱគ្គិលិតុំ សេយ្យថាបិ នាម បុរិសស្ស អយសិង្ឃាដកំ[១] កណ្ឋេ វិលគ្គំ សោ នេវ សក្កុណេយ្យ ឧគ្គិលិតុំ នេវ សក្កុណេយ្យ ឱគ្គិលិតុំ ឯវមេវ ខោ តេ រាជកុមារ សមណោ គោតមោ ឥមំ ឧភតោកោដិកំ បញ្ហំ បុដ្ឋោ សមានោ នេវ សក្ខិតិ ឧគ្គិលិតុំ នេវ សក្ខិតិ ឱគ្គិលិតុន្តិ ។ ឯវំ ភន្តេតិ ខោ អភយោ រាជកុមារោ និគណ្ឋស្ស នាដបុត្តស្ស បដិស្សុត្វា ឧដ្ឋាយាសនា និគណ្ឋំ នាដបុត្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នស្ស ខោ អភយស្ស រាជកុមារស្ស សុរិយំ ឱលោកេត្វា ឯតទហោសិ អកាលោ ខោ អជ្ជ ភគវតោ វាទំ អារោបេតុំ ស្វេទានាហំ សកេ និវេសនេ ភគវតោ វាទំ អារោបេស្សាមីតិ ។

---

១ ឱ. អយោសិង្ឃាដកំ ។

ហើយទេវទត្តក៏ខឹងអាក់អន់ចិត្ត ដោយវាចារបស់ព្រះអង្គនោះ ។ ម្នាលរាជកុមារ កាលបើទ្រង់សួរបញ្ហា ប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតម ក៏មិនអាចនឹងលេបចូល មិនអាចខ្ជាក់ចេញបានឡើយ ដូចក្រចាប់ដែកស្ទាក់នៅក្នុងបំពង់កនៃបុរស បុរសនោះមិនអាចលេបចូល មិនអាចខ្ជាក់ចេញបាន យ៉ាងណា ម្នាលរាជកុមារ កាលបើទ្រង់សួរបញ្ហា ប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតម ក៏មិនអាចលេបចូល មិនអាចខ្ជាក់ចេញបានយ៉ាងនោះឯង ។ អភយរាជកុមារ ទទួលស្តាប់ពាក្យនិគន្ថនាដបុត្ត ដោយពាក្យថា ករុណាលោកម្ចាស់ ហើយក្រោកចាកទីអង្គុយ ក្រាបថ្វាយបង្គំនិគន្ថនាដបុត្ត ធ្វើប្រទក្សិណហើយ ចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះអភយរាជកុមារ អង្គុយក្នុងទីសមគួរហើយ ក៏ក្រឡេកមើលព្រះអាទិត្យ មានសេចក្តីត្រិះរិះ យ៉ាងនេះថា ថ្ងៃនេះជាកាលមិនសមគួរ ដើម្បីលើកវាទៈ ចំពោះព្រះមានព្រះភាគឡើយ អាត្មាអញនឹងលើកវាទៈចំពោះព្រះមានព្រះភាគ ក្នុងលំនៅរបស់ខ្លួន ក្នុងថ្ងៃស្អែកវិញ ។

ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ អត្តចតុត្ថោ ភត្តន្តិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ អភយោ រាជកុមារោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន អភយស្ស រាជកុមារស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ អភយោ រាជកុមារោ ភគវន្តំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ អភយោ រាជកុមារោ ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។

ឯអភយរាជកុមារ ក៏ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មានភិក្ខុជាគម្រប់ ៤ នឹងព្រះអង្គទៅទទួលភត្តរបស់ខ្ញុំក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ អភយរាជកុមារ ដឹងច្បាស់នូវការទទួលនិមន្តន៍ របស់ព្រះមានព្រះភាគហើយ ក្រោកចាកទីអង្គុយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ គ្រាកាលរាត្រីកន្លងទៅហើយ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ទ្រង់យាងសំដៅទៅកាន់លំនៅ នៃអភយរាជកុមារ លុះទ្រង់ពុទ្ធដំណើរទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ អភយរាជកុមារ បានអង្គាសខាទនីយភោជនីយាហារដ៏ថ្លៃថ្លាញ់ពិសាដោយដៃខ្លួនឯង ថ្វាយព្រះមានព្រះភាគសោយ ឲ្យឆ្អែតស្កប់ស្កល់ ។ គ្រានោះ អភយរាជកុមារ ដឹងថាព្រះមានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យកនូវអាសនៈទាបមួយ អង្គុយក្នុងទីសមគួរ ។

គហបតិវគ្គស្ស អភយរាជកុមារសុត្តេ អមនាបវាចាបញ្ហា

[៩៣] ឯកមន្តំ និសិន្នោ ខោ អភយោ រាជកុមារោ ភគវន្តំ ឯតទវោច ភាសេយ្យ នុ ខោ ភន្តេ តថាគតោ តំ វាចំ យា សា វាចា បរេសំ អប្បិយា អមនាបាតិ ។ ន ខ្វេត្ថ[១] រាជកុមារ ឯកំសេនាតិ ។ ឯត្ថ ភន្តេ អនស្សុំ និគណ្ឋាតិ ។ កឹ បន ត្វំ រាជកុមារ ឯវំ វទេសីតិ[២] ។ ឯត្ថ ភន្តេ អនស្សុំ និគណ្ឋាតិ ឥធាហំ ភន្តេ យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា និគណ្ឋំ នាដបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទឹ ឯកមន្តំ និសិន្នំ ខោ មំ ភន្តេ និគណ្ឋោ នាដបុត្តោ ឯតទវោច ឯហិ ត្វំ រាជកុមារ សមណស្ស គោតមស្ស វាទំ អារោបេហិ ឯវំ តេ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆិស្សតិ អភយេន រាជកុមារេន សមណស្ស គោតមស្ស ឯវំមហិទ្ធិកស្ស ឯវំមហានុភាវស្ស វាទោ អារោបិតោតិ ឯវំ វុត្តេ

---

១ ឱ. ន ខោត្ថ ។ ២ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។

[៩៣] លុះអភយរាជកុមារ អង្គុយក្នុងទីសមគួរហើយ បាន ក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វាចាណា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ ព្រះតថា-គត គប្បីពោលវាចានោះដែរឬទេ ។ ព្រះអង្គត្រាស់ថា ម្នាលរាជ-កុមារ ការដោះស្រាយក្នុងបញ្ហានេះ មិនតែមួយចំណែកទេ ។ បពិត្រ ព្រះអង្គដ៏ចម្រើន បើការដោះស្រាយក្នុងបញ្ហានេះ មិនតែមួយចំណែក នោះហើយ និគ្រន្ថទាំងឡាយ មុខជាវិនាសមិនខាន ។ ម្នាលរាជកុមារ ហេតុដូចម្តេចបានជាអ្នកពោលយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើ ការដោះស្រាយក្នុងបញ្ហានេះ មិនតែមួយចំណែកនោះហើយ ពួកនិគ្រន្ថ មុខជានឹងវិនាសពុំខាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមកក្នុងទីនេះ ព្រោះខ្ញុំព្រះអង្គ បានចូលទៅរកនិគន្ថនាដបុត្ត លុះចូលទៅដល់ហើយ ថ្វាយបង្គំនិគន្ថនាដបុត្ត ហើយអង្គុយក្នុងទីសមគួរ បពិត្រព្រះអង្គដ៏ចម្រើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីសមគួរហើយ និគន្ថនាដបុត្ត ក៏បាននិយាយថា ម្នាលរាជកុមារ សូមទ្រង់មក សូមទ្រង់លើកវាទៈ ចំពោះព្រះសមណគោតម ទ្រង់នឹងមានកិត្តិសព្ទ ល្បីខ្ចរខ្ចាយទៅយ៉ាងនេះថា អភយរាជកុមារ ហ៊ាន លើកវាទៈ ចំពោះព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មាន អានុភាពច្រើនយ៉ាងនេះបាន កាលនិគន្ថនាដបុត្ត ពោលយ៉ាងនេះហើយ

អហំ ភន្តេ និគណ្ឋំ នាដបុត្តំ ឯតទវោចំ យថាកថំ បនាហំ ភន្តេ សមណស្ស គោតមស្ស ឯវំមហិទ្ធិកស្ស ឯវំមហានុភាវស្ស វាទំ អារោបេស្សាមីតិ ឯហិ ត្វំ រាជកុមារ យេន សមណោ គោតមោ តេនុបសង្កម ឧបសង្កមិត្វា សមណំ គោតមំ ឯវំ វទេហិ ភាសេយ្យ នុ ខោ ភន្តេ តថាគតោ តំ វាចំ យា សា វាចា បរេសំ អប្បិយា អមនាបាតិ សចេ តេ សមណោ គោតមោ ឯវំ បុដ្ឋោ សមានោ[១] ឯវំ ព្យាករោតិ ភាសេយ្យ រាជកុមារ តថាគតោ តំ វាចំ យា សា វាចា បរេសំ អប្បិយា អមនាបាតិ តមេនំ ត្វំ ឯវំ វទេយ្យាសិ អថ កិញ្ចរហិ តេ ភន្តេ បុថុជ្ជនេន នានាករណំ បុថុជ្ជនោបិ ហិ តំ វាចំ ភាសេយ្យ យា សា វាចា បរេសំ អប្បិយា អមនាបាតិ សចេ បន តេ សមណោ គោតមោ ឯវំ បុដ្ឋោ ឯវំ ព្យាករោតិ

១ ឱ. ម. សមានោតិ ន ទិស្សតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានពោលពាក្យនេះ នឹងនិគន្ថនាដបុត្តថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងលើកវាទៈ ចំពោះព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយប្រការដូចម្ដេចទៅ និគន្ថនាដបុត្តក៏ពោលថា ម្នាលរាជកុមារ សូមទ្រង់មក សូមទ្រង់ចូលទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ សូមទ្រង់ពោលយ៉ាងនេះនឹងព្រះសមណគោតមថា បពិត្រព្រះអង្គដ៏ចម្រើន វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ ព្រះតថាគតគប្បីពោលវាចានោះដែរឬទេ កាលបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណ-គោតម នឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគតគប្បីពោលវាចានោះដែរ ទ្រង់គប្បីពោលនឹងព្រះសមណគោតម យ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ អំពើរបស់ព្រះអង្គ ផ្សេងអ្វីអំពីបុថុជ្ជនបាន ព្រោះថាវាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ បុថុជ្ជនក៏ពោលវាចានោះដែរ ប្រសិនបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតម មុខជានឹងដោះស្រាយយ៉ាងនេះថា

ន រាជកុមារ តថាគតោ តំ វាចំ ភាសេយ្យ យា សា វាចា បរេសំ អប្បិយា អមនាបាតិ តមេនំ ត្វំ ឯវំ វទេយ្យាសិ អថ កិញ្ចរហិ តេ ភន្តេ ទេវទត្តោ ព្យាកតោ អាបាយិកោ ទេវទត្តោ នេរយិកោ ទេវទត្តោ កប្បដ្ឋោ ទេវទត្តោ អតេកិច្ឆោ ទេវទត្តោតិ តាយ ច បន តេ វាចាយ ទេវទត្តោ កុបិតោ អហោសិ អនត្តមនោតិ ឥមំ ខោ តេ រាជកុមារ សមណោ គោតមោ ឧភតោកោដិកំ បញ្ហំ បុដ្ឋោ សមានោ នេវ សក្ខិតិ ឧគ្គិលិតុំ នេវ សក្ខិតិ ឱគ្គិលិតុំ សេយ្យថាបិ នាម បុរិសស្ស អយសិង្ឃាដកំ កណ្ឋេ វិលគ្គំ សោ នេវ សក្កុណេយ្យ ឧគ្គិលិតុំ នេវ សក្កុណេយ្យ ឱគ្គិលិតុំ ឯវមេវ ខោ តេ រាជកុមារ សមណោ គោតមោ ឥមំ ឧភតោកោដិកំ បញ្ហំ បុដ្ឋោ សមានោ នេវ ឧគ្គិលិតុំ នេវ សក្ខិតិ ឱគ្គិលិតុន្តិ ។

ម្នាលរាជកុមារ វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតមិនពោលវាចានោះឡើយ ទ្រង់គប្បីពោលនឹងព្រះសមណគោតម យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ ហេតុអ្វីបានជាព្រះអង្គទ្រង់ព្យាករទេវទត្តថា ទេវទត្តកើតក្នុងអបាយ ទេវទត្តកើតក្នុងនរក ទេវទត្តឋិតនៅអស់ ១ កប្ប ទេវទត្តទុកជាពាន់នៃព្រះពុទ្ធទាំងឡាយ ក៏ជួយកែមិនបាន ដូច្នេះ ទេវទត្តខឹងអាក់អន់ចិត្ត ចំពោះព្រះអង្គដោយវាចានោះឯង ម្នាលរាជកុមារ កាលបើអ្នកសួរបញ្ហាប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតម ក៏មិនអាចលេបចូល មិនអាចខ្ជាក់ចេញបានឡើយ ដូចក្រចាប់ដែកដែលស្ទាក់នៅក្នុងបំពង់កនៃបុរស បុរសនោះមិនអាចលេបចូល មិនអាចខ្ជាក់ចេញបាន យ៉ាងណា ម្នាលរាជកុមារ កាលបើទ្រង់សួរបញ្ហា ប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតម មិនអាចលេបចូល មិនអាចខ្ជាក់ចេញបាន យ៉ាងនោះឯង ។

[៩៤] តេន ខោ បន សមយេន ទហរោ[១] មន្ទោ ឧត្តានសេយ្យកោ អភយស្ស រាជកុមារស្ស អង្កេ និសិន្នោ ហោតិ ។ អថខោ ភគវា អភយំ រាជកុមារំ ឯតទវោច តំ កិំ មញ្ញសិ រាជកុមារ សចាយំ កុមារោ តុយ្ហំ វា បមាទមន្វាយ ធាតិយា វា បមាទមន្វាយ កដ្ឋំ វា កឋលំ វា មុខេ អាហរេយ្យ កិន្តិ តំ[២] ករេយ្យាសីតិ ។ អាហរេយ្យស្សាហំ ភន្តេ សចាហំ ភន្តេ ន សក្កុណេយ្យំ អាទិកេនេវ អាហរិតុំ[៣] វាមេន ហត្ថេន សីសំ បរិគ្គហេត្វា ទក្ខិណេន ហត្ថេន វង្កង្គុលឹ កត្វា សលោហិតម្បិ អាហរេយ្យំ តំ កិស្ស ហេតុ អត្ថិ ហិ មេ[៤] ភន្តេ កុមារេ អនុកម្បាតិ ។ ឯវមេវ ខោ រាជកុមារ យំ តថាគតោ វាចំ ជានាតិ អភូតំ អតច្ឆំ អនត្ថសញ្ហិតំ សា ច បរេសំ អប្បិយា អមនាបា ន តំ តថាគតោ វាចំ ភាសតិ យម្បិ តថាគតោ វាចំ ជានាតិ ភូតំ តច្ឆំ អនត្ថសញ្ហិតំ សា ច បរេសំ អប្បិយា អមនាបា

---

១ ឱ. ម. ទហរោ កុមារោ ។ ២ ឱ. ម. នំ ។ ៣ ឱ. អាហត្តុំ ។ ម. អាហន្តុំ ។ ៤ ឱ. ម. អត្ថិ មេ ។

[៩៤] សម័យនោះឯង មានកូនខ្ចីមិនទាន់ចេះក្រឡាប់ អង្គុយលើភ្លៅអភយរាជកុមារ ។ លំដាប់នោះ ព្រះមានព្រះភាគ មានព្រះតម្រាស់នឹងអភយរាជកុមារថា ម្នាលរាជកុមារ ទ្រង់សំគាល់កូនខ្ចីនោះដូចម្តេច បើកូនខ្ចីនេះ បៀមកំណាត់ឈើក្តី អំបែងក្តី លេបចូលទៅក្នុងមាត់ ព្រោះសេចក្តីធ្វេសប្រហែស របស់ទ្រង់ ឬព្រោះសេចក្តីធ្វេសប្រហែស របស់មេនំ តើទ្រង់ត្រូវធ្វើក្មេងនោះដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រូវតែលូកទាញចេញ បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គ មិនអាចលូកទាញចេញ ដោយប្រយោគជាដំបូងបានទេ ខ្ញុំព្រះអង្គនឹងចាប់សង្កត់ក្បាលដោយដៃខាងឆ្វេង ខ្វេរម្រាមដៃស្តាំលូកខ្វេះទាញវត្ថុនោះចេញមកដោយទាំងឈាមផង ការខ្វេះទាញចេញវត្ថុនោះ ព្រោះហេតុដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាខ្ញុំព្រះអង្គមានសេចក្តីអាណិតកុមារ ។ ម្នាលរាជកុមារ យ៉ាងហ្នឹងឯង តថាគត ដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃផង តថាគតក៏មិនពោលវាចានោះ តថាគតដឹងនូវវាចាណា ពិត ទៀង តែមិនប្រកបដោយប្រយោជន៍ វាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជន

តម្បិ តថាគតោ វាចំ ន ភាសតិ យញ្ច ខោ តថាគតោ វាចំ ជានាតិ ភូតំ តច្ឆំ អត្ថសញ្ហិតំ សា ច បរេសំ អប្បិយា អមនាបា តត្រ កាលញ្ញូ តថាគតោ ហោតិ តស្សា វាចាយ វេយ្យាករណាយ យំ តថាគតោ វាចំ ជានាតិ អភូតំ អតច្ឆំ អនត្ថសញ្ហិតំ សា ច បរេសំ បិយា មនាបា តំ តថាគតោ វាចំ ន ភាសតិ យម្បិ តថាគតោ វាចំ ជានាតិ ភូតំ តច្ឆំ អនត្ថសញ្ហិតំ សា ច បរេសំ បិយា មនាបា តម្បិ តថាគតោ វាចំ ន ភាសតិ យញ្ច ខោ តថាគតោ វាចំ ជានាតិ ភូតំ តច្ឆំ អត្ថសញ្ហិតំ សា ច បរេសំ បិយា មនាបា តត្រ កាលញ្ញូ តថាគតោ ហោតិ តស្សា វាចាយ ព្យាករណាយ[១] តំ កិស្ស ហេតុ អត្ថិ ហិ[២] រាជកុមារ តថាគតស្ស សត្តេសុ[៣] អនុកម្បាតិ ។

[៩៤] យេ មេ ភន្តេ ខត្តិយបណ្ឌិតាបិ ព្រាហ្មណ-បណ្ឌិតាបិ គហបតិបណ្ឌិតាបិ សមណបណ្ឌិតាបិ បញ្ហំ អភិសង្ខរិត្វា តថាគតំ ឧបសង្កមិត្វា បុច្ឆន្តិ

១ ឱ. ម. វេយ្យាករណាយ ។ ២ ឱ. ម. ហិសទ្ទោ នត្ថិ ។ ៣ ម. សត្តេ ។

ទាំងឡាយដទៃផង តថាគត ក៏មិនពោលនូវវាចានោះ មួយវិញទៀត តថាគតដឹងនូវវាចាណា ដែលពិត ទៀង ប្រកបដោយប្រយោជន៍ តែថា វាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគត ស្គាល់កាលគួរ នឹងពោលវាចានោះ ក្នុងព្យាករណ៍នោះដែរ តថាគតដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំង-ឡាយដទៃ តថាគត ក៏មិនពោលវាចានោះឡើយ តថាគតដឹងនូវវាចាណា ដែលពិត ទៀង តែមិនប្រកបដោយប្រយោជន៍ វាចានោះទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគត ក៏មិនពោលវាចានោះដែរ មួយវិញទៀត តថាគតដឹងនូវវាចាណា ដែលពិត ទៀង ប្រកបដោយប្រយោជន៍ វាចានោះ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃផង តថាគតស្គាល់កាលគួរ នឹងពោលនូវវាចានោះ ក្នុងព្យាករណ៍នោះ ម្នាលរាជកុមារ ព្រោះហេតុអ្វី ព្រោះថា តថាគត មានសេចក្តីអនុគ្រោះ ចំពោះសត្វទាំងឡាយ ។

[៩៥] អភយរាជកុមារ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយជាខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី បានតាក់តែងបញ្ហាដល់ខ្ញុំ ហើយចូលមកសួរព្រះ

បុព្វេ វ នុ ខោ ឯតំ ភន្តេ ភគវតោ ចេតសោ បរិវិតក្កិតំ ហោតិ យេ មំ ឧបសង្កមិត្វា ឯវំ បុច្ឆិស្សន្តិ តេសាហំ ឯវំ បុដ្ឋោ ឯវំ ព្យាករិស្សាមីតិ ឧទាហុ ឋានសោវេតំ តថាគតំ បដិភាតីតិ ។ តេនហិ រាជកុមារ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ តំ កឹ មញ្ញសិ រាជកុមារ កុសលោ ត្វំ រថស្ស អង្គប្បច្ចង្គានន្តិ ។ ឯវំ ភន្តេ កុសលោ អហំ រថស្ស អង្គប្បច្ចង្គានន្តិ ។ តំ កឹ មញ្ញសិ រាជកុមារ យេ តំ ឧបសង្កមិត្វា ឯវំ បុច្ឆេយ្យុំ កិន្នាមិទំ រថស្ស អង្គប្បច្ចង្គន្តិ បុព្វេ វ នុ ខោ តេ ឯតំ ចេតសោ បរិវិតក្កិតំ អស្ស យេ មំ ឧបសង្កមិត្វា ឯវំ បុច្ឆិស្សន្តិ តេសាហំ ឯវំ បុដ្ឋោ ឯវំ ព្យាករិស្សាមីតិ ឧទាហុ ឋានសោវេតំ តំ បដិភាសេយ្យាតិ ។ អហំ ហិ ភន្តេ

តថាគត បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ បានត្រិះរិះបញ្ហានុ៎ះ ទុកក្នុងព្រះហឫទ័យ ស្រេចតាំងពីកាលមុនថា ជនទាំងឡាយណា ចូលមករកតថាគត ហើយសួរយ៉ាងនេះ លុះជនទាំងឡាយនោះ សួរតថាគតយ៉ាងនេះហើយ តថាគតនឹងដោះស្រាយយ៉ាងនេះដែរឬ ឬថាបញ្ហាកម្មនុ៎ះស្រាប់តែប្រាកដឡើង ដល់ព្រះតថាគត ដោយញាណជាទីកើតឡើងនៃហេតុ ។ ព្រះអង្គត្រាស់ថា ម្នាលរាជកុមារ បើដូច្នោះ តថាគតនឹងត្រឡប់សួរទ្រង់ក្នុងដំណើរនុ៎ះវិញ ទ្រង់គាប់ចិត្តយ៉ាងណា គប្បីដោះស្រាយដំណើរនោះយ៉ាងនោះចុះ ម្នាលរាជកុមារ ទ្រង់សំគាល់ហេតុនោះដូចម្តេច ទ្រង់ជាបុគ្គលឈ្លាស ក្នុងអវយវៈតូចធំទាំងឡាយនៃរថដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកឈ្លាស ក្នុងអវយវៈតូចធំនៃរថដែរ ។ ម្នាលរាជកុមារ ទ្រង់សំគាល់ដំណើរនោះដូចម្តេច ជនទាំង-ឡាយណា ចូលទៅរកទ្រង់ហើយសួរយ៉ាងនេះថា អវយវៈតូចធំនៃរថនេះឈ្មោះអ្វី ទ្រង់បានត្រិះរិះហេតុនេះទុកក្នុងចិត្ត ស្រាប់តាំងពីកាលមុនថា ជនទាំងឡាយណា នឹងចូលមករកអាត្មាអញហើយសួរយ៉ាងនេះ ជនទាំង-ឡាយនោះ លុះសួរអាត្មាអញយ៉ាងនេះហើយ អាត្មាអញនឹងដោះស្រាយយ៉ាងនេះឬ ឬថាដំណើរនុ៎ះ ក៏ស្រាប់តែប្រាកដដល់ទ្រង់ ដោយញាណជាទីកើតឡើងនៃហេតុតែម្តង ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គ

វេទិកោ សញ្ញាតោ កុសលោ រថស្ស អង្គប្បច្ចង្គានំ សព្វានិ មេ រថស្ស អង្គប្បច្ចង្គានិ សុវិទិតានិ ឋានសោវេតំ មំ បដិភាសេយ្យាតិ ។ ឯវមេវ ខោ រាជកុមារ យេ តេ ខត្តិយបណ្ឌិតាបិ ព្រាហ្មណបណ្ឌិ-តាបិ គហបតិបណ្ឌិតាបិ សមណបណ្ឌិតាបិ បញ្ហំ អភិសង្ខរិត្វា តថាគតំ ឧបសង្កមិត្វា បុច្ឆិស្សន្តិ[១] ឋានសោវេតំ តថាគតំ បដិភាតិ តំ កិស្ស ហេតុ សា ហិ រាជកុមារ តថាគតស្ស ធម្មធាតុ សុប្បដិវិទ្ធា យស្សា ធម្មធាតុយា សុប្បដិវិទ្ធត្តា ឋានសោវេតំ តថាគតំ បដិភាតីតិ ។

[៩៦] ឯវំ វុត្តេ អភយោ រាជកុមារោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ

១ ឱ. ម. បុច្ឆន្តិ ។

ជាអ្នកចាំបាននូវរថ ជាអ្នកឈ្លាសក្នុងអវយវៈតូចធំនៃរថ អវយវៈតូចធំទាំងអស់របស់រថ ខ្ញុំព្រះអង្គស្គាល់ហើយ បានជាដំណើរនុ៎ះប្រាកដដល់ខ្ញុំព្រះអង្គ ដោយញាណជាទីកើតឡើងនៃហេតុតែម្តង ។ ម្នាលរាជកុមារ ជនទាំងឡាយ ជាខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិ-បណ្ឌិតក្តី សមណបណ្ឌិតក្តី បានតាក់តែងបញ្ហាដល់អ្នក ហើយចូលមកសួរតថាគតថា ដំណើរនុ៎ះប្រាកដ ដល់ព្រះតថាគត ដោយញាណជាទីកើតឡើងនៃហេតុបាន ក៏យ៉ាងនោះដែរ ដំណើរនោះ ព្រោះហេតុដូចម្តេច ម្នាលរាជកុមារ ព្រោះថាធម្មធាតុ (សព្វញ្ញុតញ្ញាណ) ដែលតថាគតចាក់ធ្លុះហើយ បានជាដំណើរនុ៎ះប្រាកដដល់តថាគត ដោយញាណជាទីកើតឡើងនៃហេតុតែម្តង ។

[៩៦] កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ យ៉ាងនេះហើយ អភយរាជកុមារ ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រ

១៦០



សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

អភយរាជកុមារសុត្តំ អដ្ឋមំ និដ្ឋិតំ ។

ព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងបំភ្លឺហើយ ដោយអនេកបរិយាយ យ៉ាងនេះ ដូចគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវ ដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ឲ្យមនុស្សមានភ្នែកភ្លឺមើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ភិក្ខុសង្ឃផង ជាទីពឹង ទីរលឹក សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

ចប់ អភយរាជកុមារសូត្រ ទី ៨ ។

# នវមំ ពហុវេទនីយសុត្តំ

[៩៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ បញ្ចកង្គោ ថបតិ យេនាយស្មា ឧទាយី តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឹ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[៩៨] ឯកមន្តំ និសិន្នោ ខោ សោ[១] បញ្ចកង្គោ ថបតិ អាយស្មន្តំ ឧទាយឹ ឯតទវោច កតិ នុ ខោ ភន្តេ ឧទាយិ វេទនា វុត្តា ភគវតាតិ ។ តិស្សោ ខោ គហបតិ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ឥមា ខោ គហបតិ តិស្សោ វេទនា វុត្តា ភគវតាតិ ។ ន ខោ ភន្តេ ឧទាយិ តិស្សោ វេទនា វុត្តា ភគវតា ទ្វេ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា យាយំ ភន្តេ

១ ឱ. សោតិ ន ទិស្សតិ ។

# ពហុវេទនីយសូត្រទី ៩

[៩៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ លំដាប់នោះ មានជាងឈើម្នាក់ឈ្មោះបញ្ចកង្គៈ[១] ចូលទៅរកព្រះថេរៈឈ្មោះឧទាយិមានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះឧទាយិមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។

[៩៨] លុះជាងឈើឈ្មោះបញ្ចកង្គៈនោះ អង្គុយក្នុងទីសមគួរហើយ បាននិយាយ នឹងព្រះឧទាយិមានអាយុយ៉ាងនេះថា បពិត្រព្រះឧទាយិដ៏ចម្រើន វេទនាដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ មានប៉ុន្មានយ៉ាង ។ ព្រះឧទាយី តបថា ម្នាលគហបតី វេទនាដែលព្រះមានព្រះភាគ ទ្រង់សំដែង មាន ៣ យ៉ាងគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ម្នាលគហបតី វេទនាទាំង ៣ នេះឯង ព្រះមានព្រះភាគ ទ្រង់សំដែងហើយ ។ បពិត្រព្រះឧទាយីដ៏ចម្រើន វេទនាទាំង ៣ ព្រះមានព្រះភាគ មិនទ្រង់សំដែងទេ ព្រះមានព្រះភាគ ទ្រង់សំដែងតែវេទនាពីរគឺ សុខវេទនា ១ ទុក្ខវេទនា ១ បពិត្រលោកដ៏ចម្រើន

---

១ អដ្ឋកថា ថាប្រកបដោយអង្គ ៥ គឺ កាំបិត១ ពូថៅ១ ពន្លាក១ អន្លូង១ ស្នូកបន្ទាត់១ ។

១៦២



អទុក្ខមសុខា វេទនា សន្តស្មឹ ឯសា បណីតេ សុខេ វុត្តា ភគវតាតិ ។ ទុតិយម្បិ ខោ អាយស្មា ឧទាយិ បញ្ចកង្គំ ថបតឹ ឯតទវោច ន ខោ គហបតិ ទ្វេ វេទនា វុត្តា ភគវតា តិស្សោ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ឥមា ខោ គហបតិ តិស្សោ វេទនា វុត្តា ភគវតាតិ ។ ទុតិយម្បិ ខោ បញ្ចកង្គោ ថបតិ អាយស្មន្តំ ឧទាយឹ ឯតទវោច ន ខោ ភន្តេ ឧទាយិ តិស្សោ វេទនា វុត្តា ភគវតា ទ្វេ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា យាយំ ភន្តេ អទុក្ខមសុខា វេទនា សន្តស្មឹ ឯសា បណីតេ សុខេ វុត្តា ភគវតាតិ ។ តតិយម្បិ ខោ អាយស្មា ឧទាយី បញ្ចកង្គំ ថបតឹ ឯតទវោច ន ខោ គហបតិ ទ្វេ វេទនា វុត្តា ភគវតា តិស្សោ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ឥមា ខោ គហបតិ តិស្សោ វេទនា វុត្តា ភគវតាតិ ។ តតិយម្បិ ខោ បញ្ចកង្គោ ថបតិ អាយស្មន្តំ ឧទាយឹ ឯតទវោច

ឯអទុក្ខមសុខវេទនានោះ ព្រះមានព្រះភាគ ទ្រង់សំដែងចំពោះសេចក្តីសុខដ៏ល្អិតឧត្តម ។ ព្រះឧទាយីមានអាយុ បាននិយាយនឹងជាងឈើឈ្មោះបញ្ចកង្គៈជាគម្រប់ពីរដងថា ម្នាលគហបតី ព្រះមានព្រះភាគ មិនទ្រង់សំដែងតែត្រឹមវេទនាពីរទេ វេទនាទាំងបីគឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ក៏ព្រះមានព្រះភាគ ទ្រង់សំដែងដែរ ម្នាលគហបតី វេទនាទាំង ៣ នេះឯង ព្រះមានព្រះភាគ ទ្រង់សំដែងហើយ ។ ជាងឈើឈ្មោះបញ្ចកង្គៈ បាននិយាយនឹងព្រះឧទាយីមានអាយុជាគម្រប់ពីរដងថា បពិត្រព្រះឧទាយីដ៏ចម្រើន វេទនាទាំង ៣ ព្រះមានព្រះភាគ មិនទ្រង់សំដែងទេ ព្រះមានព្រះភាគ ទ្រង់សំដែងតែវេទនាពីរ គឺ សុខ-វេទនា ១ ទុក្ខវេទនា ១ បពិត្រលោកដ៏ចម្រើន ឯអទុក្ខមសុខវេទនានោះ ព្រះមានព្រះភាគ ទ្រង់សំដែងចំពោះតែសេចក្តីសុខដ៏ល្អិតឧត្តម ។ ព្រះឧទាយីមានអាយុ បាននិយាយនឹងជាងឈើឈ្មោះបញ្ចកង្គៈ ជាគម្រប់ ៣ ដងទៀតថា ម្នាលគហបតី ព្រះមានព្រះភាគ មិនទ្រង់សំដែងតែត្រឹមវេទនាពីរទេ វេទនា ៣ គឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ក៏ព្រះមានព្រះភាគ ទ្រង់សំដែងដែរ ម្នាលគហបតី វេទនា ៣ នេះឯង ព្រះមានព្រះភាគ ទ្រង់សំដែងហើយ ។ ជាងឈើឈ្មោះបញ្ចកង្គៈ បាននិយាយនឹងព្រះឧទាយីមានអាយុ ជាគម្រប់ ៣ ដងទៀតថា បពិត្រ

ន ខោ ភន្តេ ឧទាយិ តិស្សោ វេទនា វុត្តា ភគវតា ទ្វេ វេទនា វុត្តា ភគវតា សុខា វេទនា ទុក្ខា វេទនា យាយំ ភន្តេ អទុក្ខមសុខា វេទនា សន្តស្មឹ ឯសា បណីតេ សុខេ វុត្តា ភគវតាតិ ។ នេវ ខោ អសក្ខិ អាយស្មា ឧទាយី បញ្ចកង្គំ ថបតឹ សញ្ញាបេតុំ ន បនាសក្ខិ បញ្ចកង្គោ ថបតិ អាយស្មន្តំ ឧទាយឹ សញ្ញាបេតុំ ។

[៩៩] អស្សោសិ ខោ អាយស្មា អានន្ទោ អាយស្មតោ ឧទាយិស្ស បញ្ចកង្គេន ថបតិនា សទ្ធឹ ឥមំ កថាសល្លាបំ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ យាវតកោ អ-ហោសិ អាយស្មតោ ឧទាយិស្ស បញ្ចកង្គេន ថបតិនា សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ ឯវំ វុត្តេ ភគវា អាយស្មន្តំ អានន្ទំ ឯតទវោច

ព្រះឧទាយីដ៏ចម្រើន វេទនា ៣ ព្រះមានព្រះភាគ មិនបានសំដែងទេ ព្រះមានព្រះភាគ ទ្រង់សំដែងតែវេទនាពីរគឺសុខវេទនា ១ ទុក្ខវេទនា ១ បពិត្រលោកដ៏ចម្រើន ឯអទុក្ខមសុខវេទនានោះ ព្រះមានព្រះភាគ ទ្រង់សំដែងចំពោះតែសេចក្តីសុខដ៏ល្អិតឧត្តម ។ ព្រះឧទាយីមានអាយុមិនអាចធ្វើជាងឈើឈ្មោះបញ្ចកង្គៈ ឲ្យយល់បានឡើយ ចំណែកខាងជាងឈើឈ្មោះបញ្ចកង្គៈសោត ក៏មិនអាចធ្វើព្រះឧទាយីមានអាយុឲ្យយល់បាន ។

[៩៩] ព្រះអានន្ទមានអាយុ បានឮពាក្យចរចានេះ របស់ព្រះឧទាយីមានអាយុ ជាមួយនឹងជាងឈើឈ្មោះបញ្ចកង្គៈ ។ លំដាប់នោះ ព្រះអានន្ទ មានអាយុ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលនូវពាក្យចរចា របស់ព្រះឧទាយីមានអាយុទាំងប៉ុន្មាន ដែលបានចរចា ជាមួយនឹងជាងឈើឈ្មោះបញ្ចកង្គៈទាំងអស់នោះ ចំពោះព្រះមានព្រះភាគ ។ កាលព្រះអានន្ទ ពោលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់មានព្រះតម្រាស់នឹងព្រះអានន្ទមានអាយុដូច្នេះថា ម្នាល

សន្តញ្ញេវ[១] ខោ អានន្ទ បរិយាយំ បញ្ចកង្គោ ថបតិ ឧបាយិស្ស ជាត្តិនុមោទិ[២] សន្តញ្ញេវ ច បន បរិយាយំ ឧទាយី បញ្ចកង្គស្ស ថបតិស្ស ជាត្តិនុមោទិ ទ្វេបានន្ទ វេទនា វុត្តា មយា បរិយាយេន តិស្សោបិ វេទនា វុត្តា មយា បរិយាយេន ចតស្សោបិ វេទនា វុត្តា មយា បរិយាយេន បញ្ចបិ វេទនា វុត្តា មយា បរិយាយេន ឆបិ វេទនា វុត្តា មយា បរិយាយេន អដ្ឋារសបិ វេទនា វុត្តា មយា បរិយាយេន ឆត្តឹសាបិ វេទនា

១ ឱ. សន្តំយេវ ។ ២ ឱ. ម. នាត្តនុមោទិ ។

*អានន្ទ ជាងឈើឈ្មោះបញ្ចកង្គៈ មិនអនុមោទនាចំពោះបរិយាយដ៏ល្អិតម៉ត់ចត់ របស់ឧទាយីភិក្ខុ ចំណែកខាងឧទាយីភិក្ខុសោត ក៏មិនបានអនុមោទនា ចំពោះបរិយាយដ៏ល្អិតម៉ត់ចត់ របស់ជាងឈើឈ្មោះបញ្ចកង្គៈដែរ ម្នាលអានន្ទ វេទនាពីរក៏តថាគត បានសំដែងដោយបរិយាយ វេទនា ៣ ក៏តថាគត បានសំដែងដោយបរិយាយ វេទនា ៤[១] ក៏តថាគត បានសំដែងដោយបរិយាយ វេទនា ៥[២] ក៏តថាគត បានសំដែងដោយបរិយាយ វេទនា ៦[៣] ក៏តថាគត បានសំដែងដោយបរិយាយ វេទនា ១៨[៤] ក៏តថាគត បានសំដែងដោយបរិយាយ វេទនា ៣៦[៥]*

---

១ វេទនា ៤ នោះ មិនឃើញមានពន្យល់ក្នុងអដ្ឋកថាសោះ ។ ២ វេទនា ៥ នោះ គឺ សុខវេទនា ១ ទុក្ខវេទនា ១ ឧបេក្ខាវេទនា ១ សោមនស្សវេទនា ១ ទោមនស្សវេទនា ១ ។ ៣ វេទនា ៦ នោះគឺ ចក្ខុសម្ផស្សជា វេទនា ១ សោតសម្ផស្សជា វេទនា ១ ឃានសម្ផស្សជា វេទនា ១ ជិវ្ហាសម្ផស្សជា វេទនា ១ កាយសម្ផស្សជា វេទនា ១ មនោសម្ផស្សជា វេទនា ១ ។ ៤ វេទនា ១៨ នោះ លោកចែកតាមអារម្មណ៍ទាំង ៦ មានរូបារម្មណ៍ជាដើម ហើយយកអារម្មណ៍ទាំងនោះមកចែកជាវេទនាបី ៗ គឺជា សោមនស្សវេទនា ១ ទោមនស្សវេទនា ១ ឧបេក្ខាវេទនា ១ ដរាបទាល់តែគ្រប់អារម្មណ៍ទាំង ៦ រួមបី ៗ ៦ ដង ជា ១៨ ។ ៥ វេទនា ៣៦ នោះ លោកចាត់តាមបញ្ចកាមគុណ និងការចេញចាកកាម ៦ ៗ ដូច្នេះ គឺគេហសិតសោមនស្ស ៦ នេក្ខម្មសិតសោមនស្ស ៦ គេហសិតទោមនស្ស ៦ នេក្ខម្មសិតទោមនស្ស ៦ គេហសិតឧបេក្ខា ៦ នេក្ខម្មសិតឧបេក្ខា ៦ រួមផងគ្នាត្រូវជា ៣៦ ។

វុត្តា មយា បរិយាយេន អដ្ឋសតម្បិ[១] វេទនា វុត្តា មយា បរិយាយេន ឯវំ បរិយាយទេសិតោ ខោ អានន្ទ មយា ធម្មោ ឯវំ បរិយាយទេសិតេ ខោ អានន្ទ មយា ធម្មេ យេ អញ្ញមញ្ញស្ស សុភាសិតំ សុលបិតំ ន សមនុជានិស្សន្តិ ន សមនុមញ្ញិស្សន្តិ ន សមនុមោទិស្សន្តិ តេសមេតំ បាដិកង្ខំ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរិស្សន្តីតិ[២] ឯវំ បរិយាយទេសិតេ ខោ អានន្ទ មយា ធម្មេ យេ អញ្ញមញ្ញស្ស សុភាសិតំ សុលបិតំ សមនុជានិស្សន្តិ សមនុមញ្ញិស្សន្តិ សមនុមោទិស្សន្តិ តេសមេតំ បាដិកង្ខំ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរិស្សន្តិ ។

---

១ ឱ. អដ្ឋសតំ ។ ២ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។

គហបតិវគ្គ ពហុវេទនីយសូត្រ ពោលអំពីវេទនា

*ក៏តថាគត បានសំដែងដោយបរិយាយ វេទនា ១០៨[១] ក៏តថាគត បានសំដែងដោយបរិយាយ ម្នាលអានន្ទ ធម៌ក៏តថាគត បានសំដែងដោយបរិយាយយ៉ាងនេះឯង ម្នាលអានន្ទ កាលបើធម៌ដែលតថាគត សំដែងហើយដោយបរិយាយយ៉ាងនេះ ជនទាំងឡាយណាមិនដឹងតាម មិនយល់ព្រម មិនរីករាយ ចំពោះភាសិតនិងពាក្យចរចាដ៏ពីរោះ ដល់គ្នានឹងគ្នាហើយ ការបង្កហេតុ ការឈ្លោះ ការទាស់ទែង និងការពោលចាក់ដោតគ្នានឹងគ្នាដោយលំពែង គឺមាត់ ក៏ប្រាកដដល់ជនទាំងនោះដូច្នេះ ម្នាលអានន្ទ ធម៌តថាគត បានសំដែងហើយដោយបរិយាយយ៉ាងនេះឯង ម្នាលអានន្ទ កាលបើធម៌ តថាគត សំដែងដោយបរិយាយយ៉ាងនេះហើយ ជនទាំងឡាយណានឹងដឹងតាម យល់ព្រមតាម រីករាយតាមសុភាសិតនិងពាក្យចរចាដ៏ពីរោះ ដល់គ្នានឹងគ្នាហើយ ការព្រមព្រៀងគ្នា រីករាយរាក់ទាក់រកគ្នា មិនទាស់ទែងគ្នា ដូចទឹកលាយដោយទឹកដោះស្រស់ មើលគ្នានឹងគ្នាដោយភ្នែកជាទីស្រឡាញ់ ក៏នឹងប្រាកដដល់ជនទាំងឡាយនោះ ។*

---

១ ឯវេទនា ១០៨ នោះគឺយកវេទនាទាំង ៣៦ នោះមកចែក ជាអតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ រួមជា ១០៨ ។ អដ្ឋកថា ។

[១០០] បញ្ច ខោ ឥមេ អានន្ទ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោត-វិញ្ញេយ្យា សទ្ទា... ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហា-វិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ឥមេ ខោ អានន្ទ បញ្ច កាមគុណា ។ យំ ខោ អានន្ទ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ កាមសុខំ ។

[១០១] យោ ខោ អានន្ទ ឯវំ វទេយ្យ ឯតបរមំ សត្តា សុខំ សោមនស្សំ បដិសំវេទេន្តីតិ ឥទមស្ស នានុជានាមិ តំ កិស្ស ហេតុ អត្ថានន្ទ

[១០០] ម្នាលអានន្ទ កាមគុណទាំងឡាយនេះ មាន ៥ យ៉ាង កាមគុណទាំងឡាយ ៥ តើដូចម្តេច គឺរូបទាំងឡាយដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម ជាទីរីករាយ សំឡេងទាំងឡាយដែលគប្បីដឹងដោយត្រចៀក... ក្លិនទាំងឡាយដែលគប្បីដឹងដោយច្រមុះ... រសទាំង-ឡាយដែលគប្បីដឹងដោយអណ្តាត... ផោដ្ឋព្វៈទាំងឡាយដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមជាទីរីករាយ ម្នាលអានន្ទ កាមគុណមាន ៥ យ៉ាងនេះឯង ។ ម្នាលអានន្ទ សេចក្តីសុខ សោមនស្សណាមួយកើតឡើង ព្រោះអាស្រ័យកាមគុណទាំងឡាយ ៥ នេះ សេចក្តីសុខ សោមនស្សនេះ ហៅថា កាមសុខ ។

[១០១] ម្នាលអានន្ទ បុគ្គលណាមួយ គប្បីពោលយ៉ាងនេះថា សត្វទាំងឡាយ តែងទទួលសេចក្តីសុខនិងសោមនស្ស មានកំណត់អស់ត្រឹមប៉ុណ្ណេះ ពាក្យនេះរបស់បុគ្គលនោះ តថាគតមិនបានយល់តាមទេ ការដែលមិនយល់តាមនោះ ព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះថា

១៦៧

គហបតិវគ្គស្ស ពហុវេទនីយសុត្តេ រូបារូបជ្ឈានសុខំ

ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ឥធានន្ទ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ យោ ខោ អានន្ទ ឯវំ វទេយ្យ ឯតបរមំ សត្តា សុខំ សោមនស្សំ បដិសំវេទេន្តីតិ ឥទមស្ស នានុជានាមិ តំ កិស្ស ហេតុ អត្ថានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ឥធានន្ទ ភិក្ខុ វិតក្កវិចារានំ វូបសមា

សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ នៅមានទៀត ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនេះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ គឺនីវរណៈ ៥ ក៏បានដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈកើតអំពីសេចក្តីស្ងាត់ ចាកនីវរណធម៌ ទើបសម្រេចសម្រាន្តនៅដោយស្រួល ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ បុគ្គលណាមួយគប្បីពោលយ៉ាងនេះថា សត្វទាំងឡាយ តែងទទួលសេចក្តីសុខនិងសោមនស្សអស់ត្រឹមប៉ុណ្ណោះ ពាក្យនេះរបស់បុគ្គលនោះ តថាគត មិនយល់តាមទេ ការមិនយល់តាមនោះ ព្រោះហេតុដូចម្តេច ម្នាលអានន្ទ ព្រោះថាសេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ នៅមានទៀត ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ក៏ដល់

អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីត-តរញ្ច ឥធានន្ទ ភិក្ខុ សព្វសោ រូបសញ្ញានំ សម-តិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចា-យតនំ ឧបសម្បជ្ជ វិហរតិ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្ត-តរញ្ច បណីតតរញ្ច ឥធានន្ទ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ឥទំ ខោ អានន្ទ

នូវទុតិយជ្ឈាន ជាធម្មជាតមានប្រាកដក្នុងខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា ជាសភាពនៃចិត្តដ៏ខ្ពស់ឯក ឥតមានវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខៈកើតអំពីសមាធិ ។ បេ ។ ដល់នូវតតិយជ្ឈាន... ដល់នូវចតុត្ថជ្ឈាន ក៏សម្រេចសម្រាន្តនៅដោយស្រួល ម្នាលអានន្ទ នេះឯង ជាសេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវរូបសញ្ញា ព្រោះកម្ចាត់បង់នូវបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញាដោយប្រការទាំងពួង ក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយកិរិយាធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ដូច្នេះ ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ ម្នាលអានន្ទ នេះឯង ជាសេចក្តី

ឯតម្ហា សុខា ។ បេ ។ កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ឥធានន្ទ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ឥទំ ខោ អានន្ទ ឯតម្ហា សុខា ។ បេ ។ កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ឥធានន្ទ ភិក្ខុ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញា-នាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។

[១០២] យោ ខោ អានន្ទ ឯវំ វទេយ្យ ឯត-បរមំ សត្តា សុខំ សោមនស្សំ បដិសំវេទេន្តីតិ ឥទមស្ស នានុជានាមិ តំ កិស្ស ហេតុ អត្ថានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីត-តរញ្ច ។ កតមញ្ចានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ឥធានន្ទ ភិក្ខុ

សុខជាងសេចក្តីសុខនុ៎ះ ។ បេ ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វត្ថុបន្តិចបន្តួចមិនមានដូច្នេះ ម្នាលអានន្ទ នេះឯង ជាសេចក្តីសុខជាងសេចក្តីសុខនុ៎ះ ។ បេ ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសា-សនានេះ ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ ។

[១០២] ម្នាលអានន្ទ បុគ្គលណា គប្បីពោល យ៉ាងនេះថា សត្វទាំងឡាយ តែងទទួលនូវសេចក្តីសុខ និងសោមនស្ស អស់កំណត់ត្រឹមតែប៉ុណ្ណេះ ពាក្យនេះ របស់បុគ្គលនោះ តថាគត មិនយល់តាមទេ ការមិនយល់តាមនោះ ព្រោះហេតុដូចម្តេច ម្នាលអានន្ទ ព្រោះថា សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ នៅមានទៀត ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ

១៧០

សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ឥទំ ខោ អានន្ទ ឯតម្ហា សុខា អញ្ញំ សុខំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឋានំ ខោ បនេតំ អានន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ សញ្ញា-វេទយិតនិរោធំ សមណោ គោតមោ អាហ តញ្ច សុខស្មឹ បញ្ញបេតិ តយិទំ កឹសុ តយិទំ កថំសូតិ ឯវំវាទិនោ អានន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា ន ខោ អាវុសោ ភគវា សុខំយេវ វេទនំ សន្ធាយ សុខស្មឹ បញ្ញបេតិ អបិចាវុសោ យត្ថ យត្ថ សុខំ ឧបលព្ភតិ យហឹ យហឹ តំ តំ តថាគតោ សុខស្មឹ បញ្ញបេតីតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ពហុវេទនីយសុត្តំ នវមំ និដ្ឋិតំ ។

ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ទើបបានដល់នូវសញ្ញាវេទយិតនិរោធ ម្នាលអានន្ទ នេះឯង ជាសេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ ហេតុនេះ តែងមានប្រាកដ ត្រង់ពាក្យដែលពួកបរិព្វាជក ជាអន្យតិរ្ថិយនិយាយយ៉ាងនេះថា ព្រះសមណគោតម ពោលអាងសញ្ញាវេទយិត-និរោធ បញ្ញត្តនូវសញ្ញាវេទយិតនិរោធនោះ ថាជាសេចក្តីសុខ អ្វីជាសញ្ញាវេទយិតនិរោធនោះ សញ្ញាវេទយិតនិរោធនោះ តើដូចម្តេច ម្នាលអានន្ទ (បើ) ពួកបរិព្វាជក ជាអន្យតិរ្ថិយនិយាយយ៉ាងនេះ អ្នកគប្បីពោលតបយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគ មិនបានបញ្ញត្ត (នូវសញ្ញាវេទយិតនិរោធ) ថាជាសេចក្តីសុខ ព្រោះសំដៅយកសុខវេទនា (នោះ) ទេ ម្នាលអាវុសោ មួយទៀត បុគ្គលតែងបានសេចក្តីសុខក្នុងទីណា ៗ ព្រះតថាគត ក៏បញ្ញត្តនូវសញ្ញាវេទយិតនិរោធ ថាជាសេចក្តីសុខត្រង់ទីនោះ ៗ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសុភាសិតនោះចប់ហើយ ព្រះអានន្ទមានអាយុ ក៏ពេញចិត្ត ត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ពហុវេទនីយសូត្រទី ៩ ។

# ទសមំ អបណ្ណកសុត្តំ

[១០៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន សាលា នាម កោសលានំ ព្រាហ្មណ-គ្គាមោ តទវសរិ ។ អស្សោសុំ ខោ សាលេយ្យកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ សាលំ អនុប្បត្តោ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា

# អបណ្ណកសូត្រទី ១០

[១០៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងដែនកោសល មួយអន្លើដោយភិក្ខុសង្ឃច្រើន ក៏បានដល់ព្រាហ្មណគ្រាមឈ្មោះសាលា របស់ពួកអ្នកកោសល ។ ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកសាលា ក៏និយាយគ្នាថា ម្នាលគ្នាយើង ឮថា ព្រះសមណគោតម ជាសក្យបុត្រ ចេញចាកសក្យត្រកូលទ្រង់ព្រះផ្នួស ឥឡូវទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងដែនកោសល មួយអន្លើដោយភិក្ខុសង្ឃដ៏ច្រើន បានមកដល់សាលគ្រាមហើយ ។ កិត្តិសព្ទដ៏ល្អ នៃព្រះគោតមដ៏ចម្រើននោះ ឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ទ្រង់ជាគ្រូ

ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ សាលេយ្យកា ព្រាហ្មណគហបតិកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតោ សន្តិកេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។

នៃទេវតានិងមនុស្សទាំងឡាយ ទ្រង់បានត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ទ្រង់បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាចំពោះព្រះអង្គ នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ហើយប្រកាស ទ្រង់សំដែងធម៌មានលំអបទដើម បទកណ្ដាល និងបទចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធ ទាំងអស់ ក៏ការដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពដូច្នោះ ជាការប្រពៃណាស់ ។ លំដាប់នោះ ពួកព្រាហ្មណ៍ និងគហបតីអ្នកស្រុកសាលា ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ អ្នកខ្លះ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ អ្នកខ្លះ ក៏ពោលពាក្យសំណេះសំណាលរាក់ទាក់ ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យជាទីរីករាយ និងពាក្យជាទីរលឹក ហើយអង្គុយក្នុងទីសមគួរ អ្នកខ្លះ ក៏អង្គុយក្នុងទីសមគួរ ប្រណម្យអញ្ជលីឆ្ពោះទៅព្រះមានព្រះភាគ អ្នកខ្លះ ក៏អង្គុយក្នុងទីសមគួរ ប្រកាសនាមនិងគោត្រឲ្យឮ ក្នុងសំណាក់ព្រះមានព្រះភាគ អ្នកខ្លះ ក៏អង្គុយនៅស្ងៀមក្នុងទីសមគួរ ។

[១០៤] ឯកមន្តំ និសិន្នេ ខោ សាលេយ្យកេ ព្រាហ្មណគហបតិកេ ភគវា ឯតទវោច អត្ថិ បន វោ គហបតយោ កោចិ មនាបោ សត្ថា យស្មឹ វោ អាការវតី សទ្ធា បដិលទ្ធាតិ ។ នត្ថិ ខោ នោ ភន្តេ កោចិ មនាបោ សត្ថា យស្មឹ នោ អាការវតី សទ្ធា បដិលទ្ធាតិ ។ មនាបំ វោ គហបតយោ សត្ថារំ អល-ភន្តេហិ អយំ អបណ្ណកោ ធម្មោ សមាទាយ វត្តិតព្វោ អបណ្ណកោ ហិ គហបតយោ ធម្មោ សមត្តោ សមា-ទិន្នោ សោ វោ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយ ។ កតមោ ច គហបតយោ អបណ្ណកោ ធម្មោ ។

[១០៥] សន្តិ គហបតយោ ឯកេ សមណព្រាហ្ម-ណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ

[១០៤] លុះសាលេយ្យកព្រាហ្មណគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតីទាំងឡាយ ចុះអ្នកទាំងឡាយ មានគ្រូណាមួយជាទីគាប់ចិត្ត ល្មមឲ្យអ្នកទាំងឡាយ មានសទ្ធាប្រកបដោយហេតុដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយ មិនមានគ្រូណាមួយជាទីគាប់ចិត្ត ល្មមឲ្យយើងខ្ញុំទាំងឡាយមានសទ្ធាប្រកបដោយហេតុទេ ។ ម្នាលគហបតីទាំងឡាយ កាលបើអ្នកទាំងឡាយ មិនបានគ្រូជាទីគាប់ចិត្តហើយ ត្រូវប្រព្រឹត្តសមាទាននូវអបណ្ណកធម៌នេះវិញ ម្នាលគហបតីទាំងឡាយ ព្រោះថាអបណ្ណកធម៌ ដែលអ្នកទាំងឡាយ បានធ្វើឲ្យបរិបូណ៌ បានសមាទានហើយ ជាធម៌ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយ អស់កាលជាយូរអង្វែង ។ ម្នាលគហបតីទាំងឡាយ អបណ្ណកធម៌ តើដូចម្តេច ។

[១០៥] ម្នាលគហបតីទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អនិងធ្វើអាក្រក់ មិនមាន

នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ តេសញ្ញេវ[១] ខោ គហបតយោ សមណព្រាហ្មណានំ ឯកេ សមណព្រាហ្មណា ឧជុវិបច្ចនីកវាទា តេ ឯវមាហំសុ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ តំ កឹ មញ្ញថ គហបតយោ ននុមេ សមណព្រាហ្មណា អញ្ញមញ្ញំ ឧជុវិបច្ចនីកវាទាតិ ។ ឯវំ ភន្តេ ។

១ ឱ. តេសំយេវ ។

លោកនេះមិនមាន បរលោកមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ សត្វទាំងឡាយ ជាឧបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ជាអ្នកព្រមព្រៀងប្រតិបត្តិត្រឹមត្រូវ បានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញារបស់ខ្លួន នូវលោកនេះនិងបរលោកហើយប្រកាសបាន ក្នុងលោកនេះមិនមាន ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ មានសមណ-ព្រាហ្មណ៍ពួកមួយ មានវាទៈជាសឹកសត្រូវដោយត្រង់ (ខុសទីទៃពីគ្នា) ពោលទៅរកសមណព្រាហ្មណ៍ទាំងនោះវិញថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាករបស់កម្ម ដែលសត្វធ្វើល្អនិងធ្វើអាក្រក់មាន លោកនេះមាន បរលោកមាន មាតាមានគុណ បិតាមានគុណ សត្វទាំងឡាយជាឧបបាតិកៈមាន ពួកសមណព្រាហ្មណ៍ជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិត្រឹមត្រូវបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញារបស់ខ្លួន នូវលោកនេះនិងបរលោកហើយប្រកាសបាន ក្នុងលោកនេះមាន ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្តេច ក្រែងសមណព្រាហ្មណ៍ទាំងឡាយនេះ ពោលពាក្យជាសឹកសត្រូវដោយត្រង់ទៅរកគ្នានិងគ្នាមែនឬ ។ ព្រះករុណាព្រះអង្គ ។

[១០៦] តត្រ គហបតយោ យេ តេ សមណ-
ព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ ទិន្នំ នត្ថិ
យិដ្ឋំ នត្ថិ ហុតំ ។ បេ ។ យេ ឥមញ្ច លោកំ
បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ
តេសមេតំ បាដិកង្ខំ យមិទំ កាយសុចរិតំ វចីសុចរិតំ
មនោសុចរិតំ ឥមេ តយោ កុសលេ ធម្មេ អភិ-
និព្វជ្ជេត្វា យមិទំ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ
ឥមេ តយោ អកុសលេ ធម្មេ សមាទាយ វត្តិស្សន្តិ
តំ កិស្ស ហេតុ ន ហិ តេ ភោន្តោ សមណព្រាហ្ម-
ណា បស្សន្តិ អកុសលានំ ធម្មានំ អាទីនវំ ឱការំ
សង្កិលេសំ កុសលានំ ធម្មានំ នេក្ខម្មេ អានិសំសំ
វោទានបក្ខំ ។ សន្តំយេវ ខោ[១] បន បរំ លោកំ
នត្ថិ បរោ លោកោតិស្ស ទិដ្ឋិ ហោតិ សាស្ស
ហោតិ មិច្ឆាទិដ្ឋិ ។ សន្តំយេវ ខោ បន បរំ លោកំ
នត្ថិ បរោ លោកោតិ សង្កប្បេតិ ស្វាស្ស ហោតិ

១ ម. ខោសន្តោ នត្ថិ ។

គហបតិវគ្គ អបណ្ណកសូត្រ ពោលអំពីវាទៈដែលជាសឹកសត្រូវ

[១០៦] ម្នាលគហបតីទាំងឡាយ បណ្ដាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ។ បេ ។ បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញារបស់ខ្លួនឯង នូវលោកនេះនិងបរលោក ហើយប្រកាសបានក៏មិនមាន ហេតុនោះ ក៏ប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ (សមណ-ព្រាហ្មណ៍ទាំងនោះ) ក៏លះបង់នូវកុសលធម៌ទាំង ៣ នេះគឺ កាយសុចរិត វចីសុចរិត មនោសុចរិត ហើយសមាទានប្រព្រឹត្តអកុសលធម៌ទាំង ៣ នេះគឺ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតវិញ ការប្រព្រឹត្តនោះ ព្រោះហេតុដូចម្ដេច ព្រោះថា ពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនឃើញទោសនៃអកុសលធម៌ទាំងឡាយដ៏លាមក ដ៏សៅហ្មងព្រមទាំងមិនឃើញអានិសង្ស នៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្ដីផូរផង់ ក្នុងកិរិយាចេញចាកកាម ។ បុគ្គលមានសេចក្ដីយល់ឃើញបរលោកដែលមានប្រាកដមែនថា បរលោកមិនមានវិញ សេចក្ដីយល់ឃើញរបស់អ្នកនោះ ឈ្មោះថាមិច្ឆាទិដ្ឋិ ។ បុគ្គលត្រិះរិះនូវបរលោកដែលមានប្រាកដមែនថា បរលោកមិនមានទៅវិញ សេចក្ដីត្រិះរិះរបស់

មិច្ឆាសង្កប្បោ ។ សន្តំយេវ ខោ បន បរំ លោកំ នត្ថិ បរោ លោកោតិ វាចំ ភាសតិ សាស្ស ហោតិ មិច្ឆាវាចា ។ សន្តំយេវ ខោ បន បរំ លោកំ នត្ថិ បរោ លោកោតិ អាហ យេ តេ អរហន្តោ បរលោកវិទុនោ តេសមយំ បច្ចនីកំ ករោតិ ។ សន្តំយេវ ខោ បន បរំ លោកំ នត្ថិ បរោ លោកោតិ បរំ សញ្ញាបេតិ សាស្ស ហោតិ អសទ្ធម្មសញ្ញត្តិ[១] តាយ ច បន អសទ្ធម្មសញ្ញត្តិយា អត្តានុក្កំសេតិ បរំ វម្ភេតិ ។ ឥតិ បុព្វេវ ខោ បនស្ស សុសីល្យំ បហីនំ ហោតិ ទុស្សីល្យំ បច្ចុបដ្ឋិតំ អយញ្ច មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា អរិយានំ បច្ចនីកតា អសទ្ធម្មសញ្ញត្តិ អត្តុក្កំសនា បរវម្ភនា ។ ឯវំសិមេ អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ មិច្ឆាទិដ្ឋិប្បច្ចយា ។

---

១ អដ្ឋកថាយម្បន អសទ្ធម្មប្បញ្ញត្តីតិ ទិស្សតិ ។

បុគ្គលនោះ ឈ្មោះថាមិច្ឆាសង្កប្បៈ ។ បុគ្គលពោលវាចាចំពោះបរលោក ដែលមានពិតប្រាកដមែនថា បរលោកមិនមានទៅវិញ វាចារបស់បុគ្គលនោះ ឈ្មោះថាមិច្ឆាវាចា ។ បុគ្គលពោលបរលោក ដែលមានពិតមែនថា បរលោក មិនមានវិញ បុគ្គលនេះ ឈ្មោះថាធ្វើសឹកសត្រូវចំពោះព្រះអរហន្តទាំងឡាយ ជាអ្នកជ្រាបច្បាស់នូវបរលោក ។ បុគ្គលណាពន្យល់អ្នកដទៃ ឲ្យយល់បរលោកដែលមានពិតមែនថា បរលោកមិនមានវិញ ការពន្យល់នោះរបស់បុគ្គលនោះ ឈ្មោះថាអសទ្ធម្មសញ្ញត្តិ គឺពន្យល់ខុសចាកព្រះសទ្ធម្ម ហើយលើកតម្កើងខ្លួនឯង បង្អាប់បុគ្គលដទៃ ដោយអសទ្ធម្មសញ្ញត្តិនោះ ។ មួយវិញទៀត បុគ្គលលះបង់នូវភាវៈជាអ្នកមានសីលល្អក្នុងកាលមុន ហើយតាំងទុកនូវភាវៈជាអ្នកទ្រុស្តសីលវិញ នេះឈ្មោះថា មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា ជាសឹកសត្រូវនឹងព្រះអរិយៈទាំងឡាយ ជាសទ្ធម្មសញ្ញត្តិ ហៅថា លើកតម្កើងខ្លួនឯង បង្អាប់បុគ្គលដទៃ ។ ធម៌ជាអកុសលដ៏លាមកមានច្រើនទាំងអម្បាលនេះ កើតឡើងព្រម ព្រោះមានមិច្ឆាទិដ្ឋិជាបច្ច័យយ៉ាងនេះ ។

១៧៧

គហបតិវគ្គស្ស អបណ្ណកសុត្តេ ទុស្សមត្ថាបណ្ណកោ

[១០៧] តត្រ គហបតយោ វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ សចេ ខោ នត្ថិ បរោ លោកោ ឯវមយំ ភវំ បុរិសបុគ្គលោ កាយស្ស ភេទា បរម្ម-រណា[១] សោត្ថិមត្តានំ ករិស្សតិ សចេ ខោ អត្ថិ បរោ លោកោ ឯវមយំ ភវំ បុរិសបុគ្គលោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតិ ។ កាមំ ខោ បន មាហុ បរោ លោកោ ហោតុ នេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ វចនំ អថ ច បនាយំ ភវំ បុរិសបុគ្គលោ ទិដ្ឋេវ ធម្មេ វិញ្ញូនំ គារយ្ហោ ទុស្សីលោ បុរិសបុគ្គ-លោ មិច្ឆាទិដ្ឋី នត្ថិកវាទោតិ ។ សចេ ខោ អត្ថេវ បរោ លោកោ ឯវំ ឥមស្ស ភោតោ បុរិសបុគ្គលស្ស ឧភយត្ថ កលិគ្គាហោ យញ្ច ទិដ្ឋេវ ធម្មេ វិញ្ញូនំ គារយ្ហោ យញ្ច កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតិ ។ ឯវមស្សាយំ អបណ្ណកោ ធម្មោ ទុស្សមត្តោ ទុស្សមាទិន្នោ ឯកំសំ ផរិត្វា តិដ្ឋតិ រិញ្ចតិ កុសលដ្ឋានំ[២] ។

១ បរម្មរណាតិ ន ទិស្សតិ ។ ២ ឱ. ម. កុសលំ ឋានន្តិ ទិស្សតិ ។

[១០៧] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរស តែងពិចារណាឃើញក្នុងលទ្ធិ របស់ពួកសមណព្រាហ្មណ៍នោះដូច្នេះថា បើបរលោកមិនមានទេ បុរសបុគ្គលដ៏ចម្រើននេះ បែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅនឹងធ្វើខ្លួនឲ្យសួស្តីបានយ៉ាងនេះ បើបរលោកមានមែន បុរសបុគ្គលដ៏ចម្រើននេះ បែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ មុខជានឹងទៅកើតក្នុងកំណើត តិរច្ឆាន ប្រេត អសុរកាយ នរក យ៉ាងនេះមិនខាន ។ បើបរលោក មិនមានដោយពិត ពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឈ្មោះថាជាពាក្យពិត តែថាបុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំង-ឡាយ លោកតិះដៀលក្នុងបច្ចុប្បន្ននេះថា បុរសបុគ្គលដ៏ចម្រើននេះ ជាអ្នកទ្រុស្តសីល ជាមិច្ឆាទិដ្ឋិ ជានត្ថិកវាទ ។ បើបរលោកមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ ទទួលចាញ់ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយតិះដៀលក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅនឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ។ អបណ្ណក-ធម៌ ដែលបុគ្គលធ្វើមិនពេញលេញ សមាទានមិនល្អហើយ រមែងផ្សាយទៅតាមវាទៈ របស់ខ្លួនដោយចំណែកមួយ ហើយវៀរបង់នូវហេតុជាទីតាំងនៃកុសលយ៉ាងនេះ ។

[១០៨] តត្រ គហបតយោ យេ តេ សមណ-ព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អត្ថិ ទិន្នំ ។ បេ ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ តេសមេតំ បាដិកង្ខំ យមិទំ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ឥមេ តយោ អកុសលេ ធម្មេ អភិនិវជ្ជេត្វា យមិទំ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ ឥមេ តយោ កុសលេ ធម្មេ សមាទាយ វត្តិស្សន្តិ តំ កិស្ស ហេតុ បស្សន្តិ ហិ តេ ភោន្តោ សមណព្រាហ្មណា អកុសលានំ ធម្មានំ អាទីនវំ ឱការំ សង្កិលេសំ កុសលានំ ធម្មានំ នេក្ខម្មេ អានិសំសំ វោទានបក្ខំ ។ សន្តំយេវ ខោ បន បរំ លោកំ អត្ថិ បរោ លោកោតិស្ស ទិដ្ឋិ ហោតិ សាស្ស ហោតិ សម្មាទិដ្ឋិ ។ សន្តំយេវ ខោ បន បរំ លោកំ អត្ថិ បរោ លោកោតិ សង្កប្បេតិ ស្វាស្ស ហោតិ សម្មាសង្កប្បោ ។ សន្តំយេវ ខោ បន បរំ លោកំ អត្ថិ បរោ លោកោតិ វាចំ ភាសតិ

[១០៨] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមានផល ។ បេ ។ សមណព្រាហ្មណ៍ទាំងឡាយណា បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញារបស់ខ្លួន នូវលោកនេះនិងបរលោក ហើយប្រកាសបានក៏មាន ហេតុនោះ ក៏ប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ (សមណព្រាហ្មណ៍ទាំងនោះ) បានលះបង់អកុសលធម៌ទាំង ៣ នេះគឺ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ហើយនឹងសមាទានប្រព្រឹត្តនូវកុសលធម៌ទាំងឡាយ ៣ គឺ កាយសុចរិត វចីសុចរិត មនោសុចរិតវិញ ដំណើរនោះ ព្រោះហេតុដូចម្តេច ព្រោះថា សមណព្រាហ្មណ៍ទាំងឡាយ ដ៏ចម្រើននោះ បានឃើញទោសនៃអកុសលធម៌ទាំងឡាយដ៏ថោកទាប សៅហ្មង ឃើញនូវអានិសង្សនៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្តីផូរផង់ ក្នុងកិរិយាចេញចាកកាម ។ បរលោកមានពិតមែន បុគ្គលនោះមានសេចក្តីយល់ឃើញថា បរលោកមានមែន សេចក្តីយល់ច្បាស់របស់បុគ្គលនោះ ឈ្មោះថា សម្មាទិដ្ឋិ ។ បុគ្គលត្រិះរិះនូវបរលោកដែលមានពិតមែនថា បរលោកមានមែន សេចក្តីត្រិះរិះរបស់បុគ្គលនោះ ឈ្មោះថា សម្មាសង្កប្បៈ ។ បុគ្គលពោលវាចា ចំពោះបរលោកដែលមានពិតមែនថា បរលោកមានមែន

សាស្ស ហោតិ សម្មាវាចា ។ សន្តំយេវ ខោ បន បរំ លោកំ អត្ថិ បរោ លោកោតិ អាហ យេ តេ អរហន្តោ បរលោកវិទុនោ តេសមយំ ន បច្ចនីកំ ករោតិ ។ សន្តំយេវ ខោ បន បរំ លោកំ អត្ថិ បរោ លោកោតិ បរំ សញ្ញាបេតិ សាស្ស ហោតិ សទ្ធម្មសញ្ញត្តិ តាយ ច បន សទ្ធម្មសញ្ញត្តិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ ឥតិ បុព្វេវ ខោ បនស្ស ទុស្សីល្យំ បហីនំ ហោតិ សុសីល្យំ បច្ចុបដ្ឋិតំ អយញ្ច សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា អរិយានំ អប្បច្ចនីកតា សទ្ធម្មសញ្ញត្តិ អនត្តុក្កំសនា អបរវម្ភនា ។ ឯវំសិមេ អនេកេ កុសលា ធម្មា សម្ភវន្តិ សម្មាទិដ្ឋិប្បច្ចយា ។

[១០៩] តត្រ គហបតយោ វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ សចេ ខោ អត្ថិ បរោ លោកោ ឯវមយំ ភវំ បុរិសបុគ្គលោ កាយស្ស ភេទា បរម្មរណា

វាចារបស់បុគ្គលនោះឈ្មោះថា សម្មាវាចា ។ បុគ្គលពោលនូវបរលោក ដែលមានពិតមែនថា បរលោកមានមែន បុគ្គលនេះឈ្មោះថា មិនធ្វើនូវសឹកសត្រូវដល់ព្រះអរហន្ត ដែលជ្រាបច្បាស់ នូវបរលោកទាំងនោះឡើយ ។ បុគ្គលពន្យល់អ្នកដទៃឲ្យយល់នូវបរលោក ដែលមានពិតមែនថា បរលោកមានមែន សេចក្តីពន្យល់របស់បុគ្គលនោះឈ្មោះថា ជាសទ្ធម្មសញ្ញត្តិ គឺពន្យល់តាមព្រះសទ្ធម្ម ហើយក៏មិនលើកតម្កើងខ្លួនឯង មិនបង្អាប់បុគ្គលដទៃ ដោយសទ្ធម្មសញ្ញត្តិនោះឡើយ ។ មួយវិញទៀត បុគ្គលលះបង់នូវភាវៈជាអ្នកទ្រុស្តសីល អំពីកាលមុនពិត ហើយតាំងទុកនូវភាវៈជាអ្នកមានសីលល្អ នេះឈ្មោះថា សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មា-វាចា មិនជាសឹកសត្រូវនឹងព្រះអរិយៈទាំងឡាយ ជាអ្នកពន្យល់តាមព្រះសទ្ធម្ម ហៅថា មិនលើកតម្កើងខ្លួនឯង មិនបង្អាប់បុគ្គលដទៃ ។ កុសល-ធម៌មានច្រើនទាំងអម្បាលនេះ តែងកើតឡើងព្រម ព្រោះមានសម្មាទិដ្ឋិជាបច្ច័យយ៉ាងនេះ ។

[១០៩] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរស តែងពិចារណាឃើញក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍ទាំងនោះដូច្នេះថា បើបរលោកមានមែន បុរសបុគ្គលដ៏ចម្រើននេះ បែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ

សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតិ ។ កាមំ ខោ បន មាហុ បរោ លោកោ ហោតុ នេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ វចនំ អថ ច បនាយំ ភវំ បុរិសបុគ្គលោ ទិដ្ឋេវ ធម្មេ វិញ្ញូនំ បាសំសោ សីលវា បុរិសបុគ្គលោ សម្មាទិដ្ឋិ អត្ថិកវាទោតិ ។ សចេ ខោ អត្ថេវ បរោ លោកោ ឯវំ ឥមស្ស ភោតោ បុរិសបុគ្គលស្ស ឧភយត្ថ កដគ្គាហោ យញ្ច ទិដ្ឋេវ ធម្មេ វិញ្ញូនំ បាសំសោ យញ្ច កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតិ ។ ឯវមស្សាយំ អបណ្ណកោ ធម្មោ សុសមត្តោ សមាទិន្នោ ឧភយំសំ ផរិត្វា តិដ្ឋតិ រិញ្ចតិ អកុសលដ្ឋានំ[១] ។

[១១០] សន្តិ គហបតយោ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ករតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បចាបយតោ[២] សោចតោ

១ ឱ. ម. អកុសលំ ឋានន្តិ ទិស្សតិ ។ ២ ឱ. ម. បាចយតោ ។

មុខជានឹងទៅកាន់សុគតិសួគ៌ទេវលោកយ៉ាងនេះ ។ បើបរលោកមិនមាន ដោយពិតទេ ពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឈ្មោះថាជាពាក្យពិត តែថា បុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយសរសើរក្នុងបច្ចុប្បន្ននេះថា បុរសបុគ្គលដ៏ចម្រើននេះជាអ្នកមានសីល ជាសម្មាទិដ្ឋិ ជាអត្ថិកវាទ ។ បើបរលោកមានមែន បុរសបុគ្គលដ៏ចម្រើននេះទទួលយកជ័យជម្នះ ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយសរសើរក្នុងបច្ចុប្បន្ននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ នឹងទៅកាន់សុគតិសួគ៌ទេវលោក ។ អបណ្ណកធម៌នេះ ដែលបុគ្គលធ្វើឲ្យពេញលេញសមាទានល្អហើយ ក៏ផ្សាយទៅតាមវាទៈរបស់ខ្លួន ដោយចំណែកទាំងពីរ ហើយវៀរបង់ នូវហេតុជាទីតាំងនៃអកុសលបាន ។

[១១០] ម្នាលគហបតីទាំងឡាយ សមណព្រាហ្មណ៍ ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ កាត់ (អវយវៈគេ) ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃ ឲ្យបៀតបៀន ធ្វើគេឲ្យសោកសៅ

សោចាបយតោ ភិលមតោ ភិលមាបយតោ[១] ផន្ទតោ ផន្ទាបយតោ ចាណាមតិចាតាបយតោ[២] អជិន្នំ អាជិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា ភណាតោ ករោតោ[៣] ន ករីយតិ ចាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បឋវិយា ចាណេ ឯកមំសខលំ ឯកមំសបុញ្ជំ ករេយ្យ នត្ថិ តតោនិទានំ ចាបំ នត្ថិ ចាបស្ស អាគមោ ទក្ខិណំ ចេបិ[៤] គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ ចាចេន្តោ នត្ថិ តតោនិទានំ ចាបំ នត្ថិ ចាបស្ស អាគមោ

---

១ ឱ. សោចយតោ កិលមយតោតិ ទិស្សតិ ។ ២ ឱ. បាណមតិមាបយតោ ។ ៣ ឱ. ករតោ ។ ៤ ឱ. ទក្ខិណញ្ចេបិ ។

ឬប្រើអ្នកដទៃឲ្យធ្វើគេ ឲ្យសោកសៅ ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យលំបាក ធ្វើគេឲ្យញាប់ញ័រ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យញាប់ញ័រ សម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាន់យកទ្រព្យ ដែលគេមិនបានឲ្យ ឬប្រើអ្នកដទៃឲ្យកាន់យក កាត់ទី-តផ្ទះ ឬប្រើអ្នកដទៃឲ្យកាត់ ប្លន់ពួកអ្នកស្រុក ឬប្រើអ្នកដទៃឲ្យប្លន់ ប្លន់យកទ្រព្យផ្ទះមួយ ឬប្រើអ្នកដទៃឲ្យប្លន់ ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ ឬប្រើអ្នកដទៃឲ្យឈរចាំដណ្តើម លួចភរិយាបុគ្គលដទៃ ឬប្រើអ្នកដទៃឲ្យលួច ពោលពាក្យកុហក ឬប្រើអ្នកដទៃ[១] ឲ្យកុហក (បុគ្គលនោះ) ឈ្មោះថា មិនធ្វើបាបទេ ទុកជាបុគ្គលណា ធ្វើសត្វទាំងឡាយ លើផែនដីនេះ ដោយគ្រឿងចក្រមានខ្នងកង់ដ៏មុត ដូចជាកាំបិតកោរ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ បាបមានអំពើនោះជាហេតុ នៃបុគ្គល (នោះ) មិនមានទេ អំពើបាប ក៏មិនមកឲ្យផល ដល់បុគ្គលនោះទេ ទុកជាបុគ្គលច្ងងទៅ កាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់អវយវៈគេ ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន បាបមានអំពើនោះជាហេតុនៃបុគ្គលនោះមិនមាន (ឡើយ) អំពើបាប ក៏មិនមកឲ្យផល ដល់បុគ្គលនោះទេ

---

១ ពីត្រឹមពាក្យថា កាន់យកទ្រព្យដែលគេមិនបានឲ្យ រៀងមកដល់ពាក្យនេះ ប្រែសេចក្តីបន្ថែមសេចក្តីខ្លះតាមអដ្ឋកថា ។

ឧត្តរំ ចេបិ[១] គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទាបេន្តោ យជន្តោ យជាបេន្តោ[២] នត្ថិ តតោនិទានំ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោ ទានេន ទមេន សញ្ញមេន សច្ចវជ្ជេន នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។ តេសំយេវ ខោ គហបតយោ សមណព្រាហ្មណានំ ឯកេ សមណព្រាហ្មណា ឧជុវិបច្ចនីកវាទា តេ ឯវមាហំសុ ករតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បចាបយតោ សោចតោ សោចាបយតោ កិលមតោ កិលមាបយតោ ផន្ទតោ ផន្ទាបយតោ បាណមតិបាតាបយតោ អទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា

---

១ ឱ. ឧត្តរញ្ចេបិ ។ ២ ឱ. យាជេន្តោ ។

ទុកជាបុគ្គលធ្ងន់ទៅ កាន់ត្រើយទន្លេគង្គាខាងជើង ហើយឲ្យទានឬប្រើអ្នកដទៃឲ្យឲ្យ បូជា ឬប្រើអ្នកដទៃឲ្យបូជា បុណ្យមានអំពើនោះជាហេតុ នៃបុគ្គលនោះមិនមានទេ អំពើបុណ្យ មិនមកឲ្យផលដល់បុគ្គលនោះឡើយ បុណ្យមិនមានដោយការឲ្យទាន ដោយការទូន្មាននូវឥន្ទ្រិយ ដោយការសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈទេ បុណ្យមិនមានមកដល់បុគ្គលនោះទេ ។ ម្នាលគហបតីទាំងឡាយ មានសមណ-ព្រាហ្មណ៍ពួកមួយ មានវាទៈជាសឹកសត្រូវដោយត្រង់ ទៅរកសមណ-ព្រាហ្មណ៍ទាំងនោះហើយ ពោលយ៉ាងនេះថា បុគ្គលធ្វើបាប ឬប្រើអ្នកដទៃឲ្យធ្វើ កាត់អវយវៈគេ ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន ធ្វើគេឲ្យសោកសៅ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យសោកសៅ ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យលំបាក ធ្វើគេឲ្យញាប់ញ័រ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យញាប់ញ័រ សម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាន់យកទ្រព្យ ដែលគេមិនបានឲ្យ ឬប្រើអ្នកដទៃឲ្យកាន់យក កាត់ទី-តផ្ទះ ឬប្រើអ្នកដទៃឲ្យកាត់ ប្លន់ពួកអ្នកស្រុក ឬប្រើអ្នកដទៃឲ្យប្លន់ ប្លន់យកទ្រព្យតែផ្ទះមួយ ឬប្រើអ្នកដទៃឲ្យប្លន់ ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ ឬប្រើអ្នកដទៃឲ្យឈរចាំដណ្តើម លួចភរិយាបុគ្គលដទៃ ឬប្រើអ្នកដទៃឲ្យលួច ពោលពាក្យកុហក ឬប្រើ

១៨៣

គហបតិវគ្គស្ស អបណ្ណកសុត្តេ វិបច្ចនីកវាទោ

ភណតោ ករោតោ[១] ករីយតិ បាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បថវិយា បាណេ ឯកមំសខលំ ឯកមំសបុញ្ជំ ករេយ្យ អត្ថិ តតោ-និទានំ បាបំ អត្ថិ បាបស្ស អាគមោ ទក្ខិណំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ បាចេន្តោ អត្ថិ តតោនិទានំ បាបំ អត្ថិ បាបស្ស អាគមោ ឧត្តរំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទាបេន្តោ យជន្តោ យជាបេន្តោ អត្ថិ តតោនិទានំ បុញ្ញំ អត្ថិ បុញ្ញស្ស អាគមោ ទានេន ទមេន សញ្ញមេន សច្ចវជ្ជេន អត្ថិ បុញ្ញំ អត្ថិ បុញ្ញស្ស អាគមោតិ ។ តំ កឹ មញ្ញថ គហបតយោ ននុមេ សមណព្រាហ្មណា អញ្ញមញ្ញស្ស ឧជុវិបច្ចនីកវាទាតិ ។ ឯវំ ភន្តេ ។

១ ឱ. ករតោ ។

អ្នកដទៃឲ្យកុហក (បុគ្គលនោះ) ឈ្មោះថាធ្វើបាប ទុកជាបុគ្គលណា ធ្វើសត្វទាំងឡាយ លើផែនដីនេះ ដោយគ្រឿងចក្រមានខ្នងកង់ដ៏មុត ដូចជាកាំបិតកោរ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ បាបដែលមានអំពើនោះជាហេតុ តែងមាន បាបនៃបុគ្គល (នោះ) មាន ទុកជាបុគ្គលច្ឆងទៅ កាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់អវយវៈគេ ឬប្រើគេឲ្យកាត់ បៀតបៀន គេ ឬប្រើអ្នកដទៃឲ្យបៀតបៀន បាបមានអំពើនោះជាហេតុ តែងមាន បាបនៃបុគ្គលនោះមាន ចំណែកបុគ្គលច្ឆងទៅ កាន់ត្រើយទន្លេគង្គាខាងជើង ហើយឲ្យទាន ឬប្រើអ្នកដទៃឲ្យឲ្យ បូជា ឬប្រើអ្នកដទៃឲ្យបូជា បុណ្យមានអំពើនោះជាហេតុ តែងមាន បុណ្យនៃបុគ្គលនោះមាន បុណ្យមាន ដោយការឲ្យទាន ដោយការទូន្មានទូវឥន្ទ្រិយ ដោយការសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈ បុណ្យនៃបុគ្គល (នោះ) តែងមាន ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះ ដូចម្តេច សមណព្រាហ្មណ៍ទាំងនេះ មានវាទៈជាសឹកសត្រូវ ដោយត្រង់ទៅរកគ្នានឹងគ្នា មិនមែនឬ ។ ព្រះករុណា ព្រះអង្គ ។

[១១១] តត្រ គហបតយោ យេ តេ សមណព្រាហ្ម-ណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ករោតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បាចាបយតោ សោចតោ សោ-ចាបយតោ កិលមតោ កិលមាបយតោ ផន្ទតោ ផន្ទាបយតោ បាណមតិបាតាបយតោ អទិន្នំ អាទិ-យតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា ភណតោ ករោតោ ន ករីយតិ បាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បឋវិយា បាណេ ឯកមំសខលំ ឯកមំសបុញ្ជំ ករេយ្យ នត្ថិ តតោនិ-ទានំ បាបំ នត្ថិ បាបស្ស អាគមោ ទក្ខិណំ ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ

[១១១] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះ ថា បុគ្គលធ្វើបាប ឬប្រើអ្នកដទៃឲ្យធ្វើ កាត់អវយវៈគេ ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន ធ្វើគេឲ្យសោកសៅ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យសោកសៅ ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យលំបាក ធ្វើគេឲ្យញាប់ញ័រ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យញាប់ញ័រ សម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាន់យកទ្រព្យដែលគេមិនបានឲ្យ ឬប្រើគេឲ្យកាន់យក កាត់ទី-តផ្ទះ ឬប្រើគេឲ្យកាត់ ប្លន់ពួកអ្នកស្រុក ឬប្រើអ្នកដទៃឲ្យប្លន់ ប្លន់យកទ្រព្យតែផ្ទះមួយ ឬប្រើអ្នកដទៃឲ្យប្លន់ ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ ឬប្រើអ្នកដទៃឲ្យឈរចាំដណ្តើម លួចភរិយាបុគ្គលដទៃ ឬប្រើអ្នកដទៃឲ្យលួច ពោលពាក្យកុហក ឬប្រើអ្នកដទៃឲ្យពោលពាក្យកុហក បុគ្គលអ្នកធ្វើនោះឈ្មោះថាមិនធ្វើបាប ទុកជាបុគ្គលណា ធ្វើសត្វទាំងឡាយលើផែនដីនេះ ដោយគ្រឿងចក្រមានខ្នងកង់ដ៏មុតដូចជាកាំបិតកោរ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ បាបមានអំពើនោះជាហេតុ តែងមិនមាន បាបមិនមកឲ្យផលឡើយ ទុកជាបុគ្គលធ្វើទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វ ឬប្រើគេឲ្យសម្លាប់

។ បេ ។ ទានេន ទមេន សញ្ញមេន សច្ចវជ្ជេន នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។ តេសមេតំ បាដិកង្ខំ យមិទំ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ ឥមេ តយោ កុសលេ ធម្មេ អភិនិព្វជ្ជេត្វា យមិទំ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ឥមេ តយោ អកុសលេ ធម្មេ សមាទាយ វត្តិស្សន្តិ តំ កិស្ស ហេតុ ន ហិ តេ ភោន្តោ សមណព្រាហ្មណា បស្សន្តិ អកុសលានំ ធម្មានំ អាទីនវំ ឱការំ សង្កិលេសំ កុសលានំ ធម្មានំ នេក្ខម្មេ អានិសំសំ វោទានបក្ខំ ។ សន្តំយេវ ខោ បន កិរិយំ នត្ថិ កិរិយាតិស្ស ទិដ្ឋិ ហោតិ សាស្ស ហោតិ មិច្ឆាទិដ្ឋិ ។ សន្តំយេវ ខោ បន កិរិយំ នត្ថិ កិរិយាតិ សង្កប្បេតិ ស្វាស្ស ហោតិ មិច្ឆាសង្កប្បោ ។ សន្តំយេវ ខោ បន កិរិយំ នត្ថិ កិរិយាតិ វាចំ ភាសតិ សាស្ស ហោតិ មិច្ឆាវាចា ។

។ បេ ។ បុណ្យមិនមានដោយការឲ្យទាន ដោយការទូន្មានឥន្ទ្រិយ ដោយការសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈទេ បុណ្យមិនមកឲ្យផលឡើយ ។ ហេតុនេះមានប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ គឺ (សមណព្រាហ្មណ៍ទាំងនោះ) លះបង់នូវកុសលធម៌ ៣ នេះ គឺ កាយសុចរិត វចីសុចរិត មនោសុចរិត ហើយសមាទានប្រព្រឹត្តនូវអកុសលធម៌ ៣ នេះ គឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតវិញ ដំណើរនោះព្រោះហេតុដូចម្តេច ព្រោះថាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើននោះ មិនឃើញនូវទោសរបស់អកុសលធម៌ទាំងឡាយ ដ៏លាមក សៅហ្មង មិនឃើញអានិសង្សនៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្តីផូរផង់ ក្នុងកិរិយាចេញចាកកាម ។ សេចក្តីយល់ឃើញអំពើ ដែលមានពិតមែនរបស់បុគ្គលនោះថា អំពើមិនមានដូច្នេះ សេចក្តីយល់ឃើញរបស់បុគ្គលនោះ ឈ្មោះថាមិច្ឆាទិដ្ឋិ ។ មួយទៀត បុគ្គលត្រិះរិះនូវអំពើ ដែលមានពិតមែនថា អំពើមិនមានដូច្នេះ សេចក្តីត្រិះរិះរបស់បុគ្គលនោះឈ្មោះថាមិច្ឆាសង្កប្បៈ ។ មួយទៀត បុគ្គលណាពោលវាចាចំពោះអំពើ ដែលមានមែនពិតថា អំពើមិនមានវិញ វាចារបស់បុគ្គលនោះ ឈ្មោះថាមិច្ឆាវាចា ។

សន្តំយេវ ខោ បន កិរិយំ នត្ថិ កិរិយាតិ អាហ យេ តេ អរហន្តោ កិរិយវាទា តេសមយំ បច្ចនីកំ ករោតិ ។ សន្តំយេវ ខោ បន កិរិយំ នត្ថិ កិរិយាតិ បរំ សញ្ញាបេតិ សាស្ស ហោតិ អសទ្ធម្មសញ្ញត្តិ តាយ ច បន អសទ្ធម្មសញ្ញត្តិយា អត្តានុក្កំសេតិ បរំ វម្ភេតិ ។ ឥតិ បុព្វេវ ខោ បនស្ស សុសីល្យំ បហីនំ ហោតិ ទុស្សីល្យំ បច្ចុបដ្ឋិតំ អយញ្ច មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា អរិយានំ បច្ចនីកតា អសទ្ធម្មសញ្ញត្តិ អត្តុក្កំសនា បរវម្ភនា ។ ឯវំសិមេ អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ មិច្ឆាទិដ្ឋិប្បច្ចយា ។

[១១២] តត្រ គហបតយោ វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ សចេ ខោ នត្ថិ កិរិយា ឯវមយំ ភវំ បុរិសបុគ្គលោ កាយស្ស ភេទា បរម្មរណា[១] សោត្ថិមត្តានំ ករិស្សតិ ។ សចេ ខោ អត្ថិ កិរិយា ឯវមយំ ភវំ បុរិសបុគ្គលោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតិ ។

---

១ ឱ. ម. បរម្មរណាតិ ន ទិស្សតិ ។

មួយទៀតបុគ្គលណាពោលនូវអំពើ ដែលមានមែនពិតថា អំពើមិនមានវិញ បុគ្គលនេះឈ្មោះថាធ្វើសឹកសត្រូវ ចំពោះព្រះអរហន្ត ដែលជាកិរិយវាទ ។ មួយវិញទៀត បុគ្គលពន្យល់អ្នកដទៃឲ្យយល់ នូវអំពើដែលមានពិតថា អំពើមិនមានវិញ សេចក្ដីពន្យល់របស់បុគ្គលនោះឈ្មោះថាអសទ្ធម្មសញ្ញត្តិ ឯបុគ្គលនោះ ឈ្មោះថាលើកតម្កើងខ្លួនឯង បង្អាប់បុគ្គលដទៃដោយសារអសទ្ធម្មសញ្ញត្តិនោះ ។ ព្រោះហេតុនោះ បុគ្គលនោះលះបង់នូវភាវៈនៃសីលល្អក្នុងកាលមុនចោល ហើយតាំងទុកនូវភាវៈជាអ្នកទ្រុស្តសីលវិញ នេះឈ្មោះថាមិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា ជាសឹកសត្រូវនឹងព្រះអរិយៈទាំងឡាយ ជាអសទ្ធម្មសញ្ញត្តិ ឈ្មោះថាលើកតម្កើងខ្លួនឯងបន្តុះបង្អាប់បុគ្គលដទៃ ។ អកុសលធម៌ទាំងឡាយ ដ៏លាមក ច្រើនប្រការទាំងនេះ តែងកើតឡើងព្រមព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ យ៉ាងនេះឯង ។

[១១២] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរសតែងពិចារណាឃើញក្នុងលទ្ធិ របស់ពួកសមណព្រាហ្មណ៍ទាំងនោះដូច្នេះថា បើអំពើមិនមានទេ កាលបើយ៉ាងនេះ បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅនឹងធ្វើខ្លួនឲ្យសួស្តីបាន ។ តែបើអំពើមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅហើយ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក មិនលែងឡើយ ។

កាមំ ខោ បន មាហុ កិរិយា ហោតុ នេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ វចនំ អថ ច បនាយំ ភវំ បុរិសបុគ្គលោ ទិដ្ឋេវ ធម្មេ វិញ្ញូនំ គារយ្ហោ ទុស្សីលោ បុរិសបុគ្គលោ មិច្ឆាទិដ្ឋី អកិរិយវាទោតិ ។ សចេ ខោ អត្ថិ កិរិយា ឯវំ ឥមស្ស ភោតោ បុរិសបុគ្គលស្ស ឧភយត្ថ កលិគ្គាហោ យញ្ច ទិដ្ឋេវ ធម្មេ វិញ្ញូនំ គារយ្ហោ យញ្ច កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតីតិ[១] ។ ឯវមស្សាយំ អបណ្ណកោ ធម្មោ ទុស្សមត្តោ ទុស្សមាទិន្នោ ឯកំសំ ផរិត្វា តិដ្ឋតិ រិញ្ចតិ កុសលដ្ឋានំ ។

[១១៣] តត្រ គហបតយោ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ករោតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បចាបយតោ សោចតោ សោចាបយតោ កិលមតោ កិលមាបយតោ ផន្ទតោ ផន្ទាបយតោ បាណមតិបាតាបយតោ អទិន្នំ

១ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។

បើអំពើមិនមានដោយពិត ពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឈ្មោះថាជាពាក្យពិត តែថា បុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយគប្បីតិះដៀលក្នុងបច្ចុប្បន្ននេះថា បុរសបុគ្គលនេះ ជាអ្នកទ្រុស្តសីល ជាមិច្ឆាទិដ្ឋិ ជាអកិរិយវាទ ។ ប្រសិនណាបើអំពើមានមែនពិត បុរសបុគ្គលដ៏ចម្រើននេះ ទទួលចាញ់ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយតិះដៀលក្នុងបច្ចុប្បន្ននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ នឹងទៅកើតក្នុងកំណើត តិរច្ឆាន ប្រេត អសុរកាយ នរក មិនខាន ។ អបណ្ណកធម៌នេះ ដែលបុគ្គលនោះ ធ្វើមិនពេញលេញ សមាទានមិនល្អហើយ រមែងផ្សាយទៅតាមវាទៈ របស់ខ្លួនដោយចំណែកមួយ វៀរបង់នូវហេតុជាទីតាំងនៃកុសល យ៉ាងនេះឯង ។

[១១៣] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលធ្វើបាប ឬប្រើគេឲ្យធ្វើ កាត់អវយវៈគេ ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន ធ្វើគេឲ្យសោកសៅ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យសោកសៅ ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យលំបាក ធ្វើគេឲ្យញាប់ញ័រ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យញាប់ញ័រ សម្លាប់សត្វខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្លាប់ កាន់យកទ្រព្យ

អាទិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ ឯកា-
គារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ
មុសា ភណតោ ករោតោ ករីយតិ បាបំ ខុរបរិយន្តេន
ចេបិ ចក្កេន យោ ឥមិស្សា បឋវិយា បាណេ ឯកមំ-
សខលំ ឯកមំសបុញ្ជំ ករេយ្យ នត្ថិ តតោនិទានំ
បាបំ នត្ថិ បាបស្ស អាគមោ ទក្ខិណញ្ចេបិ គង្គាយ
តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ
បចន្តោ បាចេន្តោ នត្ថិ តតោនិទានំ បាបំ នត្ថិ
បាបស្ស អាគមោ ឧត្តរញ្ចេបិ គង្គាយ តីរំ
គច្ឆេយ្យ ទទន្តោ ទាបេន្តោ យជន្តោ យជាបេន្តោ
នត្ថិ តតោនិទានំ បុញ្ញំ នត្ថិ បុញ្ញស្ស
អាគមោ ទានេន ទមេន សញ្ញមេន សច្ចវជ្ជេន
នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។

ដែលគេមិនបានឲ្យ ឬប្រើគេឲ្យកាន់យក កាត់ទី-តផ្ទះ ឬប្រើអ្នកដទៃឲ្យកាត់ ប្លន់ពួកអ្នកស្រុក ឬប្រើអ្នកដទៃឲ្យប្លន់ ប្លន់យកទ្រព្យតែផ្ទះ ១ ឬប្រើគេឲ្យប្លន់ ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ ឬប្រើអ្នកដទៃឲ្យឈរចាំដណ្តើម លួចភរិយាបុគ្គលដទៃ ឬប្រើអ្នកដទៃឲ្យលួច ពោលពាក្យកុហក ឬប្រើអ្នកដទៃឲ្យកុហក បុគ្គលអ្នកធ្វើនោះឈ្មោះថាធ្វើបាប ទោះបីបុគ្គលណាធ្វើសត្វលើផែនដីនេះ ដោយគ្រឿងចក្រ មានខ្នងកង់ដ៏មុតដូចជាកាំបិតកោរ ឲ្យមានគំនរសាច់តែ ១ ឲ្យមានពំនូកសាច់តែ ១ បាបមានអំពើនោះជាហេតុ តែងមាន បាបនឹងមកឲ្យផល ទុកជាបុគ្គលនោះចូលទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់អវយវៈគេ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន បាបមានអំពើនោះជាហេតុ តែងមាន បាបនឹងមកឲ្យផល ចំណែកបុគ្គលចូលទៅ កាន់ត្រើយទន្លេគង្គាខាងជើងហើយឲ្យទាន ឬប្រើគេឲ្យឲ្យ បូជា ឬប្រើអ្នកដទៃឲ្យបូជា បុណ្យមានអំពើនោះជាហេតុ តែងមាន បុណ្យនឹងមកឲ្យផល បុណ្យមានដោយការឲ្យទាន ដោយការទូន្មានឥន្ទ្រិយ ដោយការសង្រួមកាយវាចា ដោយការពោលពាក្យសច្ចៈ បុណ្យនឹងមកឲ្យផល ។

តេសមេតំ ចាដិកង្ខំ យមិទំ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ឥមេ តយោ អកុសលេ ធម្មេ អភិនិព្វជ្ជេត្វា យមិទំ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ ឥមេ តយោ កុសលេ ធម្មេ សមាទាយ វត្តិស្សន្តីតិ[១] តំ កិស្ស ហេតុ បស្សន្តិ ហិ តេ ភោន្តោ សមណព្រាហ្មណា អកុសលានំ ធម្មានំ អាទីនវំ ឱការំ សង្កិលេសំ កុសលានំ ធម្មានំ នេក្ខម្មេ អានិសំសំ វោទានបក្ខំ ។ សន្តំយេវ ខោ បន កិរិយំ អត្ថិ កិរិយាតិស្ស ទិដ្ឋិ ហោតិ សាស្ស ហោតិ សម្មាទិដ្ឋិ ។ សន្តំយេវ ខោ បន កិរិយំ អត្ថិ កិរិយាតិ សង្កប្បេតិ ស្វាស្ស ហោតិ សម្មាសង្កប្បោ ។ សន្តំយេវ ខោ បន កិរិយំ អត្ថិ កិរិយាតិ វាចំ ភាសតិ សាស្ស ហោតិ សម្មាវាចា ។

---

១ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។

ហេតុនោះមានប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ គឺ (សមណព្រាហ្មណ៍ទាំងនោះ) លះបង់នូវអកុសលធម៌ទាំង ៣ នេះគឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ហើយសមាទានប្រព្រឹត្តនូវកុសលធម៌ទាំង ៣ នេះគឺ កាយសុចរិត វចីសុចរិត មនោសុចរិតវិញ ដំណើរនោះ ព្រោះហេតុដូចម្ដេច ព្រោះថា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឃើញទោសរបស់អកុសលធម៌ទាំងឡាយ ដ៏លាមក សៅហ្មង ឃើញអានិសង្សនៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្ដីផូរផង់ ក្នុងកិរិយាចេញចាកកាម ។ មួយទៀត បុគ្គលមានសេចក្ដីយល់ឃើញ នូវអំពើដែលមានពិតមែន ថា អំពើមានពិតមែន សេចក្ដីយល់ឃើញរបស់បុគ្គលនោះ ឈ្មោះថា សម្មាទិដ្ឋិ ។ មួយទៀត បុគ្គលណាត្រិះរិះ នូវអំពើដែលមានពិតមែន ថា អំពើមានពិតមែន សេចក្ដីត្រិះរិះរបស់បុគ្គលនោះ ឈ្មោះថាសម្មាសង្កប្បៈ ។ មួយទៀត បុគ្គលណាពោលវាចា ចំពោះអំពើដែលមានពិតមែនថា អំពើមានពិតមែន វាចារបស់បុគ្គលនោះ ឈ្មោះថាសម្មាវាចា ។

សន្តំយេវ ខោ បន កិរិយំ អត្ថិ កិរិយាតិ អាហ យេ តេ អរហន្តោ កិរិយវាទា តេសមយំ ន បច្ចនីកំ ករោតិ ។ សន្តំយេវ ខោ បន កិរិយំ អត្ថិ កិរិយាតិ បរំ សញ្ញាបេតិ សាស្ស ហោតិ សទ្ធម្មសញ្ញត្តិ តាយ ច បន សទ្ធម្មសញ្ញត្តិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ ឥតិ បុព្វេវ ខោ បនស្ស ទុស្សីល្យំ បហីនំ ហោតិ សុសីល្យំ បច្ចុបដ្ឋិតំ អយញ្ច សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា អរិយានំ អបច្ចនីកតា សទ្ធម្មសញ្ញត្តិ អនត្តុក្កំសនា អបរវម្ភនា ។ ឯវំសិមេ អនេកេ កុសលា ធម្មា សម្ភវន្តិ សម្មាទិដ្ឋិប្បច្ចយា ។

[១១៤] តត្រ គហបតយោ វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ សចេ ខោ អត្ថិ កិរិយា ឯវមយំ ភវំ បុរិសបុគ្គលោ កាយស្ស ភេទា បរម្មរណា

មួយវិញទៀត បុគ្គលណាពោល នូវអំពើដែលមានពិតមែនថា អំពើមានពិតមែន បុគ្គលនេះឈ្មោះថាមិនធ្វើសឹកសត្រូវ ចំពោះព្រះអរហន្តដែលជាកិរិយវាទឡើយ ។ មួយវិញទៀត បុគ្គលពន្យល់អ្នកដទៃឲ្យយល់ នូវអំពើដែលមានពិតមែនថា អំពើមានពិតមែន សេចក្តីពន្យល់របស់បុគ្គលនោះ ឈ្មោះថាសទ្ធម្មសញ្ញត្តិ ឯបុគ្គលនោះឈ្មោះថាមិនលើកតម្កើងខ្លួនឯង មិនបង្អាប់បុគ្គលដទៃ ដោយសារសទ្ធម្មសញ្ញត្តិនោះ ។ ព្រោះហេតុនោះ បុគ្គលនោះលះបង់ នូវភាវៈទ្រុស្តសីលក្នុងកាលមុនចោល ហើយតាំងទុកនូវភាវៈជាអ្នកមានសីលល្អ នេះឈ្មោះថាសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា មិនជាសឹកសត្រូវនឹងព្រះអរិយៈទាំងឡាយ ជាសទ្ធម្មសញ្ញត្តិ ឈ្មោះថាមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់បុគ្គលដទៃ ។ កុសលធម៌ទាំងឡាយ មានច្រើនប្រការទាំងនេះ តែងកើតឡើងព្រម ព្រោះសម្មាទិដ្ឋិជាបច្ច័យ យ៉ាងនេះ ។

[១១៤] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរសតែងពិចារណាឃើញក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ដូច្នេះថា បើអំពើមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ

សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតិ ។ កាមំ ខោ បន មាហុ កិរិយា ហោតុ តេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ វចនំ អថ ច បនាយំ ភវំ បុរិសបុគ្គលោ ទិដ្ឋេវ ធម្មេ វិញ្ញូនំ បាសំសោ សីលវា បុរិសបុគ្គលោ សម្មាទិដ្ឋី កិរិយវាទោតិ ។ សចេ ខោ អត្ថេវ កិរិយា ឯវំ ឥមស្ស ភោតោ បុរិសបុគ្គលស្ស ឧភយត្ថ កដគ្គាហោ យញ្ច ទិដ្ឋេវ ធម្មេ វិញ្ញូនំ បាសំសោ យញ្ច កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតិ ។ ឯវមស្សាយំ អបណ្ណកោ ធម្មោ សុសមត្តោ សមាទិន្នោ ឧភយំសំ ផរិត្វា តិដ្ឋតិ វិញ្ចតិ អកុសលដ្ឋានំ ។

[១១៨] សន្តិ គហបតយោ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ អហេតូ អប្បច្ចយា សត្តា សង្កិលិស្សន្តិ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ វិសុទ្ធិយា អហេតូ អប្បច្ចយា សត្តា វិសុជ្ឈន្តិ នត្ថិ ពលំ នត្ថិ វីរិយំ នត្ថិ បុរិសត្ថាមោ

នឹងទៅកាន់សុគតិសួគ៌ទេវលោកយ៉ាងនេះ ។ បើអំពើមិនមានដោយពិតទេ ពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឈ្មោះថាជាពាក្យពិត តែថាបុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយសរសើរក្នុងបច្ចុប្បន្ននេះថា បុរសបុគ្គលនេះជាអ្នកមានសីល ជាសម្មាទិដ្ឋិ ជាកិរិយវាទ ។ បើអំពើមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ ទទួលយកជ័យជំនះ ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយសរសើរក្នុងបច្ចុប្បន្ននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ នឹងបានទៅកាន់សុគតិសួគ៌ទេវលោក ។ អបណ្ណកធម៌ ដែលបុគ្គលធ្វើឲ្យពេញលេញ សមាទានល្អហើយ ក៏ផ្សាយទៅតាមវាទៈ របស់ខ្លួនដោយចំណែកទាំងពីរ វៀរបង់នូវហេតុជាទីតាំងនៃអកុសល យ៉ាងនេះ ។

[១១៥] ម្នាលគហបតីទាំងឡាយ មានសមណព្រាហ្មណ៍ ទាំង-ឡាយពួក ១ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយសៅហ្មងមិនមានឡើយ សត្វទាំងឡាយរមែងសៅហ្មងដោយឥតហេតុ ឥតបច្ច័យ ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយបរិសុទ្ធមិនមានឡើយ សត្វទាំងឡាយ តែងបរិសុទ្ធដោយឥតហេតុ ឥតបច្ច័យ កម្លាំងមិនមាន សេចក្តីព្យាយាមមិនមាន កម្លាំងរបស់បុរសក៏មិនមាន

នត្ថិ បុរិសបរក្កមោ សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា សព្វេ ជីវា អវសា អពលា អវីរិយា និយតិសង្គតិភាវបរិណតា[១] ឆស្វេវាភិជាតីសុ[២] សុខទុក្ខំ បដិសំវេទេន្តីតិ តេសំយេវ ខោ គហបតយោ សមណព្រាហ្មណានំ ឯកេ សមណព្រាហ្មណា ឧជុវិបច្ចនីកវាទា តេ ឯវមាហំសុ អត្ថិ ហេតុ អត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ សហេតូ សប្បច្ចយា

---

១ ម. និយតិសង្គតិសភាវបរិណតា ។ ២ ឱ. ឆស្សេវាភិជាតីសុ ។

សេចក្តីសង្វាតរបស់បុរសក៏មិនមាន ពួកសត្វទាំងអស់ (មានសត្វឱដ្ឋ គោជាដើម) បាណៈ[១] ទាំងអស់ ភូតទាំងអស់ (មានសត្វកើតក្នុងស្រោមស៊ុតជាដើម) ជីវៈគឺពញ្ញជាតិជាដើមទាំងអស់ ឥតមានអំណាច ឥតមានកម្លាំង ឥតមានព្យាយាម មានតែសេចក្តីប្រែប្រួល ដោយនិយតិ[២] សង្គតិ[៣] និងភាវៈ[៤] តាំងនៅក្នុងអភិជាតិទាំង ៦ ទទួលសុខនិងទុក្ខ ម្នាលគហបតីទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ មានវាទៈជាសឹកសត្រូវ ដោយត្រង់ទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយពោលពាក្យយ៉ាងនេះថា ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយសៅហ្មងមានមែន សត្វទាំងឡាយ តែងសៅហ្មងដោយមានហេតុ មានបច្ច័យ

---

១ សត្វដែលមានឥន្ទ្រិយ ១ គឺ រូបជីវិតិន្ទ្រិយ បានដល់អសញ្ញីសត្វ មានឥន្ទ្រិយ ២ គឺ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ បានដល់រូបព្រហ្ម ១៤ ជាន់ វៀរលែងតែអសញ្ញីព្រហ្មចេញ ។ ២ សេចក្តីជិតស្និទ្ធមិនបែកធ្លាយ ដូចដុំកែវមណីដែលមិនប្រេះឆា ឈ្មោះថា និយតិ ។ ៣ ការត្រាច់រង្គាត់ទៅក្នុងអភិជាតិទាំង ៦ ឈ្មោះថា សង្គតិ ។ ៤ ធម្មតាដែលកើតឡើងដោយទំនងត្រូវ ៗ គ្នាឈ្មោះថា ភាវៈ ដូចបន្លាដែលស្រួចឯង ដូចផ្លែខ្វិតដែលមានសណ្ឋានមូលដោយខ្លួនឯង សត្វម្រឹគបក្សីទាំងពួងមានរូបរាងវិចិត្រផ្សេង ៗ ដោយធម្មតាឯង យ៉ាងណាមិញ លោកទាំងអស់មានសេចក្តីប្រែប្រួលទៅដូច្នោះ ៗ មិនត្រូវអាស្រ័យហេតុបច្ច័យឡើយ ដូចបន្លាជាដើមក៏យ៉ាងនោះឯង ឈ្មោះថា ភាវៈ ។ អដ្ឋកថា ។

សត្តា សង្កិលិស្សន្តិ អត្ថិ ហេតុ អត្ថិ បច្ចយោ សត្តានំ វិសុទ្ធិយា សហេតូ សប្បច្ចយា សត្តា វិសុជ្ឈន្តិ អត្ថិ ពលំ អត្ថិ វីរិយំ អត្ថិ បុរិសថាមោ អត្ថិ បុរិសបរក្កមោ[១] សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា សព្វេ ជីវា សវសា សពលា សវីរិ-យា[២] និយតិសង្គតិភាវបរិណតា ឆស្វេវាភិជាតីសុ សុខទុក្ខំ បដិសំវេទេន្តីតិ ។ តំ កឹ មញ្ញថ គហប-តយោ ននុមេ សមណព្រាហ្មណា អញ្ញមញ្ញំ ឧជុ-វិបច្ចនីកវាទាតិ ។ ឯវំ ភន្តេ ។

[១១៦] តត្រ គហបតយោ យេ តេ សមណ-ព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ អហេតូ អប្បច្ចយា សត្តា សង្កិលិស្សន្តិ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ វិសុទ្ធិយា អហេតូ អប្បច្ចយា សត្តា វិសុជ្ឈន្តិ នត្ថិ ពលំ នត្ថិ វីរិយំ នត្ថិ បុរិសថាមោ នត្ថិ បុរិសបរក្ក-មោ សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា

---

១ ឱ. ឥធ នាតិ ទិស្សតិ ។ ២ ឱ. អវសា អពលា អវីរិយា ។

ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយបរិសុទ្ធមានមែន សត្វទាំងឡាយតែងបរិសុទ្ធដោយមានហេតុ មានបច្ច័យ កម្លាំងក៏មាន ព្យាយាមក៏មាន កម្លាំងរបស់បុរសក៏មាន សេចក្តីសង្វាតរបស់បុរសក៏មាន ពួកសត្វទាំងអស់ បាណៈទាំងអស់ ភូតទាំងអស់ ជីវៈទាំងអស់ មានអំណាច មានកម្លាំង មានព្យាយាម មានសេចក្តីប្រែប្រួលដោយនិយតិ សង្គតិនិងភាវៈ តាំងនៅក្នុងអភិជាតិទាំង ៦ ទើបទទួលសុខនិងទុក្ខបាន ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយសំគាល់ហេតុនោះ ដូចម្តេច ក្រែងសមណព្រាហ្មណ៍ទាំងនេះ មានវាទៈជាសឹកសត្រូវ ដោយត្រង់ដល់គ្នានឹងគ្នាមិនមែនឬ ។ ព្រះករុណាព្រះអង្គ ។

[១១៦] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយសៅហ្មងមិនមានឡើយ សត្វទាំង-ឡាយនឹងសៅហ្មងដោយឥតហេតុឥតបច្ច័យ ហេតុបច្ច័យនាំឲ្យសត្វទាំង-ឡាយបរិសុទ្ធមិនមាន សត្វទាំងឡាយ បរិសុទ្ធដោយឥតហេតុ ឥតបច្ច័យ កម្លាំងមិនមាន សេចក្តីព្យាយាមមិនមាន កម្លាំងនៃបុរសមិនមាន សេចក្តីសង្វាតនៃបុរសមិនមាន សត្វទាំងអស់ បាណៈទាំងអស់ ភូតទាំងអស់

សព្វេ ជីវា អវសា អពលា អវីរិយា និយតិសង្គតិភាវ-បរិណតា ឆស្វេវាភិជាតីសុ សុខទុក្ខំ បដិសំវេទេន្តីតិ តេសមេតំ បាដិកង្ខំ យមិទំ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ ឥមេ តយោ កុសលេ ធម្មេ អភិនិវជ្ជេត្វា យមិទំ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ឥមេ តយោ អកុសលេ ធម្មេ សមាទាយ វត្តិស្សន្តិ តំ កិស្ស ហេតុ ន ហិ តេ ភោន្តោ សមណព្រាហ្មណា បស្សន្តិ អកុសលានំ ធម្មានំ អាទីនវំ ឱការំ សង្កិ-លេសំ កុសលានំ ធម្មានំ នេក្ខម្មេ អានិសំសំ វោទានបក្ខំ ។ សន្តំយេវ ខោ បន ហេតុំ នត្ថិ ហេតូតិស្ស ទិដ្ឋិ ហោតិ សាស្ស ហោតិ មិច្ឆាទិដ្ឋិ ។ សន្តំយេវ ខោ បន ហេតុំ នត្ថិ ហេតូតិ សង្កប្បេតិ ស្វាស្ស ហោតិ មិច្ឆាសង្កប្បោ ។ សន្តំយេវ ខោ បន ហេតុំ នត្ថិ ហេតូតិ វាចំ ភាសតិ សាស្ស ហោតិ

ជីវៈទាំងអស់ ឥតមានអំណាច ឥតមានកម្លាំង ឥតមានព្យាយាម មានតែសេចក្ដីប្រែប្រួល ដោយនិយតិ សង្គតិ និងភាវៈ តាំងនៅក្នុងអភិជាតិទាំង ៦ ទើបទទួលសុខនិងទុក្ខបាន ហេតុនេះ ក៏ប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ (សមណព្រាហ្មណ៍ទាំងនោះ) លះបង់កុសលធម៌ ៣ នេះគឺ កាយសុចរិត វចីសុចរិត មនោសុចរិត ហើយសមាទានប្រព្រឹត្តអកុសលធម៌ ៣ នេះគឺ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតវិញដំណើរនោះ ព្រោះហេតុដូចម្ដេច ព្រោះថាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនបានឃើញទោស នៃអកុសលធម៌ទាំងឡាយ ដ៏លាមកសៅហ្មង ទាំងមិនឃើញអានិសង្ស នៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្ដីផូរផង់ ក្នុងការចេញចាកកាម ។ មួយទៀត បុគ្គលណាមានសេចក្ដីយល់ឃើញហេតុ ដែលមានមែនពិតថា ហេតុមិនមាន សេចក្ដីយល់របស់បុគ្គលនោះ ឈ្មោះថា មិច្ឆាទិដ្ឋិ ។ មួយទៀត បុគ្គលត្រិះរិះនូវហេតុដែលមានមែនពិតថា ហេតុមិនមាន សេចក្ដីត្រិះរិះរបស់បុគ្គលនោះ ឈ្មោះថា មិច្ឆាសង្កប្បៈ ។ មួយទៀត បុគ្គលពោលវាចា ចំពោះហេតុដែលមានមែនពិតថា ហេតុមិនមាន វាចារបស់បុគ្គលនោះ ឈ្មោះថា

មិច្ឆាវាចា ។ សន្តំយេវ ខោ បន ហេតុំ នត្ថិ ហេតូតិ អាហ យេ តេ អរហន្តោ ហេតុវាទា តេសមយំ បច្ចនីកំ ករោតិ ។ សន្តំយេវ ខោ បន ហេតុំ នត្ថិ ហេតូតិ បរំ សញ្ញាបេតិ សាស្ស ហោតិ អសទ្ធម្មសញ្ញត្តិ តាយ ច បន អសទ្ធម្មសញ្ញត្តិយា អត្តានុក្កំសេតិ បរំ វម្ភេតិ ។ ឥតិ បុព្វេវ ខោ បនស្ស សុសីល្យំ បហីនំ ហោតិ ទុស្សីល្យំ បច្ចុបដ្ឋិតំ អយញ្ច មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បោ មិច្ឆាវាចា អរិយានំ បច្ចនីកតា អសទ្ធម្មសញ្ញត្តិ អត្តានុក្កំសនា បរវម្ភនា ។ ឯវំសិមេ អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ មិច្ឆាទិដ្ឋិប្បច្ចយា ។

[១១៧] តត្រ គហបតយោ វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ សចេ ខោ នត្ថិ ហេតុ ឯវមយំ ភវំ បុរិសបុគ្គលោ កាយស្ស ភេទា បរម្មរណា សោត្ថិមត្តានំ ករិស្សតិ ។ សចេ ខោ អត្ថិ ហេតុ ឯវមយំ ភវំ បុរិសបុគ្គលោ កាយស្ស ភេទា

មិច្ឆាវាចា ។ មួយទៀត បុគ្គលណាពោលនូវហេតុ ដែលមានមែនពិត ថា ហេតុមិនមាន បុគ្គលនេះឈ្មោះថាធ្វើសឹកសត្រូវ ចំពោះព្រះអរហន្ត ដែលជាហេតុវាទ ។ មួយទៀត បុគ្គលណាពន្យល់អ្នកដទៃឲ្យយល់នូវ ហេតុ ដែលមានពិតថា ហេតុមិនមាន សេចក្តីពន្យល់របស់បុគ្គលនោះ ឈ្មោះថា អសទ្ធម្មសញ្ញត្តិ ឯបុគ្គលនោះឈ្មោះថាលើកតម្កើងខ្លួនឯង តិះ ដៀលបុគ្គលដទៃ ដោយសារអសទ្ធម្មសញ្ញត្តិនោះ ។ ព្រោះហេតុនោះ បុគ្គលនោះលះបង់ នូវភាវៈជាអ្នកមានសីលល្អក្នុងកាលមុន ហើយតាំង ទុកនូវភាវៈជាអ្នកទ្រុស្តសីលវិញ នេះឈ្មោះថា មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាចា ជាសឹកសត្រូវនឹងព្រះអរិយៈទាំងឡាយ ជាអសទ្ធម្មសញ្ញត្តិ ឈ្មោះថាលើកតម្កើងខ្លួនឯង បង្អាប់បុគ្គលដទៃ ។ អកុសលធម៌ដ៏លាមក ច្រើនប្រការទាំងនេះ តែងកើតព្រមព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ យ៉ាងនេះ ។

[១១៧] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរសតែងពិចារណាឃើញក្នុង លទ្ធិរបស់សមណព្រាហ្មណ៍ទាំងនោះថា បើហេតុមិនមានទេ បុរស បុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ នឹងធ្វើខ្លួន ឲ្យមានសួស្តី ។ បើហេតុមានមែន បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយ

បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតិ ។ យាមំ ខោ បន មាហុ ហោតុ ហោតុ នេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ វចនំ អថ ច បនាយំ ភវំ បុរិសបុគ្គលោ និជ្ជេវ ជម្មេ វិញ្ញូនំ គារយ្ហោ ទុស្សីលោ បុរិសបុគ្គលោ មិច្ឆាទិដ្ឋិ អហេតុកវាទោតិ ។ សចេ ខោ អត្ថេវ ហោតុ ឯវំ ឥមស្ស ភោតោ បុរិសបុគ្គលស្ស ឧភយត្ថ កលិគ្គាហោ យញ្ច និជ្ជេវ ជម្មេ វិញ្ញូនំ គារយ្ហោ យញ្ច កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតិ ។ ឯវមស្សាយំ អបណ្ណកោ ធម្មោ ទុស្សមត្តោ សមាទិន្នោ ឯកំសំ ផរិត្វា តិដ្ឋតិ រិញ្ចតិ កុសលដ្ឋានំ ។

[១១៨] តត្រ គហបតយោ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អត្ថិ ហេតុ អត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ សហេតូ សប្បច្ចយា សត្តា សង្កិលិស្សន្តិ អត្ថិ ហេតុ អត្ថិ បច្ចយោ

រាងកាយបន្ទាប់អំពីមរណៈទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក មិនខាន ។ មួយទៀត បើហេតុមិនមានដោយពិត ពាក្យរបស់សមណព្រាហ្មណ៍ ដ៏ចម្រើនទាំងនោះ ក៏នៅជាពាក្យពិត តែថាបុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយ តិះដៀលក្នុងបច្ចុប្បន្ននេះថា បុរសបុគ្គលនេះ ជាអ្នកទ្រុស្តសីល ជាមិច្ឆាទិដ្ឋិ ជាអហេតុកវាទ ។ បើហេតុមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ ទទួលចាញ់ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយ គប្បីតិះដៀលក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក មិនខាន ។ អបណ្ណកធម៌ ដែលបុគ្គលធ្វើមិនពេញលេញ សមាទានមិនល្អហើយ ក៏ផ្សាយទៅតាមវាទៈរបស់ខ្លួនដោយចំណែកមួយ វៀរបង់នូវហេតុជាទីតាំងនៃកុសល យ៉ាងនេះ ។

[១១៨] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ហេតុបច្ច័យនាំឲ្យសត្វសៅហ្មង មានពិតមែន សត្វទាំងឡាយ តែងសៅហ្មងដោយមានហេតុមានបច្ច័យ ហេតុបច្ច័យនាំឲ្យសត្វ

សត្តានំ វិសុទ្ធិយា សហេតូ សប្បច្ចយា សត្តា វិសុជ្ឈន្តិ អត្ថិ ពលំ អត្ថិ វីរិយំ អត្ថិ បុរិសថាមោ អត្ថិ បុរិសបរក្កមោ សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា សព្វេ ជីវា សវសា សពលា សវី-រិយា និយតិសង្គតិភាវបរិណតា ឆស្វេវាភិជាតីសុ សុខទុក្ខំ បដិសំវេទេន្តីតិ តេសមេតំ បាដិកង្ខំ យមិទំ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ឥមេ តយោ អកុសលេ ធម្មេ អភិនិព្វជ្ជេត្វា យមិទំ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ ឥមេ តយោ កុសលេ ធម្មេ សមាទាយ វត្តិស្សន្តិ តំ កិស្ស ហេតុ បស្សន្តិ ហិ តេ ភោន្តោ សមណព្រាហ្មណា អកុសលានំ ធម្មានំ អាទីនវំ ឱការំ សង្កិលេសំ កុសលានំ ធម្មានំ នេក្ខម្មេ អានិសំសំ វោទាន-បក្ខំ ។ សន្តំយេវ ខោ បន ហេតុំ អត្ថិ ហេតូតិស្ស ទិដ្ឋិ ហោតិ សាស្ស ហោតិ សម្មាទិដ្ឋិ ។ សន្តំយេវ ខោ បន ហេតុំ អត្ថិ ហេតូតិ សង្កប្បេតិ ស្វាស្ស ហោតិ សម្មាសង្កប្បោ ។

បរិសុទ្ធមានពិតមែន សត្វទាំងឡាយតែងបរិសុទ្ធដោយមានហេតុ មានបច្ច័យ កម្លាំងមាន សេចក្តីព្យាយាមមាន កម្លាំងរបស់បុរសមាន សេចក្តីសង្វាតនៃបុរសមាន ពួកសត្វទាំងអស់ បាណៈទាំងអស់ ភូតទាំងអស់ ជីវៈទាំងអស់ មានអំណាច មានកម្លាំង មានព្យាយាម មានសេចក្តីប្រែប្រួលដោយនិយតិ សង្គតិ និងភាវៈ ឋិតនៅក្នុងអភិជាតិទាំង ៦ ទើបទទួលសុខនិងទុក្ខបាន ហេតុនោះ ក៏ប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ (សមណព្រាហ្មណ៍ទាំងនោះ) លះបង់អកុសល ៣ នេះគឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ហើយសមាទានប្រព្រឹត្តកុសលធម៌ ៣ នេះគឺ កាយសុចរិត វចីសុចរិត មនោសុចរិតវិញ ដំណើរនោះព្រោះហេតុដូចម្តេច ព្រោះថា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឃើញទោសនៃអកុសលធម៌ទាំងឡាយ ដ៏លាមក សៅហ្មង ឃើញអានិសង្សនៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្តីផូរផង់ ក្នុងកិរិយាចេញចាកកាម ។ មួយទៀត បុគ្គលមានសេចក្តីយល់ឃើញ នូវហេតុដែលមានពិតមែនថាហេតុមានពិតមែន សេចក្តីយល់ឃើញរបស់បុគ្គលនោះ ឈ្មោះថា សម្មាទិដ្ឋិ ។ មួយទៀត បុគ្គលណាត្រិះរិះហេតុ ដែលមានពិតមែនថា ហេតុមានពិតមែន សេចក្តីត្រិះរិះរបស់បុគ្គលនោះ ឈ្មោះថា សម្មាសង្កប្បៈ ។

សន្តំយេវ ខោ បន ហេតុំ អត្ថិ ហេតូតិ វាចំ ភាសតិ សាស្ស ហោតិ សម្មាវាចា ។ សន្តំយេវ ខោ បន ហេតុំ អត្ថិ ហេតូតិ អាហ យេ តេ អរហន្តោ ហេតុវាទា តេសមយំ ន បច្ចនីកំ ករោតិ ។ សន្តំយេវ ខោ បន ហេតុំ អត្ថិ ហេតូតិ បរំ សញ្ញាបេតិ សាស្ស ហោតិ សទ្ធម្មសញ្ញត្តិ តាយ ច បន សទ្ធម្មសញ្ញត្តិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ ឥតិ បុព្វេវ ខោ បនស្ស ទុស្សីល្យំ បហីនំ ហោតិ សុសីល្យំ បច្ចុបដ្ឋិតំ អយញ្ច សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា អរិយានំ អបច្ចនីកតា សទ្ធម្មសញ្ញត្តិ អនត្តុក្កំសនា អបរវម្ភនា ។ ឯវំសិមេ អនេកេ កុសលា ធម្មា សម្ភវន្តិ សម្មាទិដ្ឋិប្បច្ចយា ។

[១១៩] តត្រ គហបតយោ វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ សចេ ខោ អត្ថិ ហេតុ ឯវមយំ ភវំ បុរិសបុគ្គលោ កាយស្ស ភេទា បរម្មរណា

មួយទៀត បុគ្គលណា ពោលវាចាចំពោះហេតុ ដែលមានពិតមែនថា ហេតុមានពិតមែន វាចារបស់បុគ្គលនោះ ឈ្មោះថា សម្មាវាចា ។ មួយទៀត បុគ្គលណា ពោលនូវហេតុ ដែលមានពិតមែនថា ហេតុមានពិតមែន បុគ្គលនេះ ឈ្មោះថាមិនធ្វើសឹកសត្រូវ ចំពោះព្រះអរហន្តជាហេតុវាទទាំងនោះ ។ មួយទៀត បុគ្គលណាពន្យល់អ្នកដទៃឲ្យយល់នូវហេតុដែលមានពិតមែនថា ហេតុមានពិតមែន សេចក្តីពន្យល់របស់បុគ្គលនោះ ឈ្មោះថា សទ្ធម្មសញ្ញត្តិ មិនលើកតម្កើងខ្លួនឯង ឯបុគ្គលនោះឈ្មោះថាមិនបង្អាប់បុគ្គលដទៃ ដោយសារសទ្ធម្មសញ្ញត្តិនោះទេ ។ ព្រោះហេតុនោះ បុគ្គលនោះបានលះបង់នូវភាវៈជាអ្នកទ្រុស្តសីលក្នុងកាលមុន ហើយតាំងទុកនូវភាវៈជាអ្នកមានសីលល្អវិញ នេះឈ្មោះថាសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា មិនជាសឹកសត្រូវចំពោះព្រះអរិយៈទាំងឡាយ ជាសទ្ធម្មសញ្ញត្តិ ឈ្មោះថាមិនលើកតម្កើងខ្លួនឯង មិនបង្អាប់បុគ្គលដទៃ ។ កុសលធម៌ទាំងឡាយនេះច្រើនប្រការ កើតឡើងព្រម ព្រោះសម្មាទិដ្ឋិជាបច្ច័យ យ៉ាងនេះ ។

[១១៩] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរស តែងពិចារណាឃើញក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ដូច្នេះថា បើហេតុមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ

សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតិ ។ កាមំ ខោ បន មាហុ ហោតុ ហោតុ នេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ វចនំ អថ ច បនាយំ ភវំ បុរិសបុគ្គលោ ទិដ្ឋេវ ធម្មេ វិញ្ញូនំ ចាសំសោ សីលវា បុរិសបុគ្គលោ សម្មាទិដ្ឋី ហោតុវាទោតិ ។ សចេ ខោ អត្ថេវ ហោតុ ឯវំ ឥមស្ស ភោតោ បុរិសបុគ្គលស្ស ឧភយត្ថ កដគ្គាហោ យញ្ច ទិដ្ឋេវ ធម្មេ វិញ្ញូនំ ចាសំសោ យញ្ច កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតិ ។ ឯវមស្សាយំ អបណ្ណកោ ធម្មោ សុសមត្តោ សមា-ទិន្នោ ឧភយំសំ ផរិត្វា តិដ្ឋតិ រិញ្ចតិ អកុសលដ្ឋានំ ។

[១២០] សន្តិ គហបតយោ ឯកេ សមណព្រាហ្ម-ណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ សព្វសោ អា-រុប្បាតិ តេសំយេវ ខោ គហបតយោ សមណព្រាហ្ម-ណានំ ឯកេ សមណព្រាហ្មណា ឧជុវិបច្ចនីក-វាទា តេ ឯវមាហំសុ អត្ថិ សព្វសោ អារុប្បាតិ ។

នឹងចូលទៅកាន់សុគតិសួគ៌ទេវលោក ។ មួយទៀត បើហេតុមិនមាន ដោយពិត ពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ទុកជាពាក្យពិត តែថាបុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយសរសើរក្នុងបច្ចុប្បន្នថា បុរសបុគ្គលនេះ ជាអ្នកមានសីល ជាសម្មាទិដ្ឋិ ជាហេតុវាទ ។ បើហេតុ មានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ ទទួលជ័យជំនះ ក្នុងចំណែកទាំង ពីរ គឺអ្នកប្រាជ្ញទាំងឡាយសរសើរ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ នឹងចូលទៅកាន់សុគតិសួគ៌ទេវលោក ។ អបណ្ណក-ធម៌នេះ ដែលបុគ្គលធ្វើឲ្យពេញលេញ សមាទានល្អហើយ ក៏ផ្សាយ ទៅតាមវាទៈរបស់ខ្លួន ដោយចំណែកទាំងពីរ វៀរបង់នូវហេតុជាទី តាំងនៃអកុសល យ៉ាងនេះ ។

[១២០] ម្នាលគហបតីទាំងឡាយ មានសមណព្រាហ្មណ៍ពួក មួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា អរូបព្រហ្ម មិនមាន ដោយប្រការទាំងពួង ម្នាលគហបតីទាំងឡាយ សមណព្រាហ្មណ៍ពួក មួយ មានវាទៈជាសឹកសត្រូវដោយត្រង់ ទៅរកសមណព្រាហ្មណ៍ទាំង នោះ ហើយពោលយ៉ាងនេះថា អរូបព្រហ្មមានដោយប្រការទាំងពួង ។

តំ កឹ មញ្ញថ គហបតយោ ននុមេ សមណព្រាហ្មណា អញ្ញមញ្ញស្ស ឧជុវិបច្ចនីកវាទាតិ ។ ឯវំ ភន្តេ ។ តត្រ គហបតយោ វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ យេ ខោ[១] តេ ភោន្តោ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ សព្វសោ អារុប្បាតិ ឥទំ មេ អទិដ្ឋំ យេបិ តេ ភោន្តោ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អត្ថិ សព្វសោ អារុប្បាតិ ឥទំ មេ អវិទិតំ អហញ្ចេវ ខោ បន អជានន្តោ អបស្សន្តោ ឯកំសេន អាទាយ វោហរេយ្យំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ន មេតំ អស្ស បដិរូបំ យេ ខោ តេ ភោន្តោ សមណព្រាហ្មណា ឯវំ-វាទិនោ ឯវំទិដ្ឋិនោ នត្ថិ សព្វសោ អារុប្បាតិ សចេ ខោ តេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ វចនំ ឋានមេតំ វិជ្ជតិ យេ តេ ទេវា រូបិនោ មនោមយា អបណ្ណកំ មេ តត្រូបបត្តិ ភវិស្សតិ យេ បន តេ ភោន្តោ សមណព្រាហ្មណា ឯវំវាទិនោ

១ ម. យេ ច ខោ ។

ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយសំគាល់ហេតុនោះដូចម្តេច ក្រែង សមណព្រាហ្មណ៍ទាំងនេះ មានវាទៈជាសឹកសត្រូវដោយត្រង់ ទៅរកគ្នានឹងគ្នាមិនមែនឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតីទាំងឡាយ វិញ្ញូបុរស តែងពិចារណាឃើញ ក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍ទាំងនោះដូច្នេះថា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា អរូបព្រហ្មមិនមានដោយប្រការទាំងពួង ពាក្យនេះយើងក៏មិនដែលឃើញ សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា អរូបព្រហ្មមានដោយប្រការទាំងពួង ពាក្យនេះយើងក៏មិនដែលដឹង ឯយើងកាលបើមិនដឹងមិនឃើញ គប្បីកាន់យកដោយចំណែកមួយ ហើយនិយាយថា ពាក្យនេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនេះ មិនសមគួរទេ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា អរូបព្រហ្ម មិនមាន ដោយប្រការទាំងពួង បើពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះជាពាក្យពិត ពាក្យនុ៎ះយកជាទីតាំងបានប្រាកដ ទេវតាទាំងឡាយណា មានរូប កើតដោយឈានចិត្ត ពាក្យនេះ (មិនខុស) ការទៅកើតក្នុងរូបព្រហ្មនោះ នឹងមានដល់យើងមួយទៀត សមណព្រាហ្មណ៍ដ៏ចម្រើនទាំងឡាយណា មានវាទៈយ៉ាងនេះ

ឯវំទិដ្ឋិនោ អត្ថិ សព្វសោ អារុប្បាតិ សចេ តេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ វចនំ ឋានមេតំ វិជ្ជតិ យេ តេ ទេវា អរូបិនោ សញ្ញាមយា អបណ្ណកំ មេ តត្រូបបត្តិ ភវិស្សតិ ទិស្សន្តេ ខោ បន រូបាធិករណំ ទណ្ឌាទានសត្ថាទានកលហវិគ្គហវិវាទតុវំតុវបេសុញ្ញមុសាវាទា នត្ថិ ខោ បនេតំ សព្វសោ អារុប្បេតិ ។ សោ ឥតិ បដិសង្ខាយ រូបានំយេវ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។

[១២១] សន្តិ គហបតយោ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ សព្វសោ ភវនិរោធោតិ ។ តេសំយេវ ខោ គហបតយោ សមណព្រាហ្មណានំ ឯកេ សមណព្រាហ្មណា ឧជុវិបច្ចនីកវាទា តេ ឯវមាហំសុ អត្ថិ សព្វសោ ភវនិរោធោតិ ។ តំ កឹ មញ្ញថ គហបតយោ ននុមេ សមណព្រាហ្មណា

មានទិដ្ឋិយ៉ាងនេះថា អរូបព្រហ្មមានដោយប្រការទាំងពួង បើពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ជាពាក្យពិត ពាក្យនុ៎ះយកជាទីតាំងបានប្រាកដ ទេវតាទាំងឡាយណាដែលឥតរូប កើតដោយសញ្ញា ពាក្យនោះ (មិនខុស) ការទៅកើតក្នុងអរូបព្រហ្មនោះ នឹងមានដល់យើង ការកាន់យកដំបង ការកាន់យកគ្រឿងសស្ត្រា ការឈ្លោះទាស់ទែងគ្នា ការពោលជជែកគ្នា ការប្រកាន់ថាឯងអញ ការពោលញុះញង់ ការពោលពាក្យកុហកដែលប្រាកដឡើង ព្រោះមានរូបជាអធិករណ៍ ក៏ឯអធិករណ៍នុ៎ះ មិនមាន ក្នុងរូបព្រហ្ម ដោយប្រការទាំងពួង ។ វិញ្ញុបុរសនោះ លុះពិចារណាឃើញដូច្នេះហើយ ក៏ប្រតិបត្តិ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់នូវរូបនោះ ។

[១២១] ម្នាលគហបតីទាំងឡាយ មានសមណព្រាហ្មណ៍ទាំងឡាយពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់នៃភពដោយប្រការទាំងពួង មិនមានឡើយ ។ ម្នាលគហបតីទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ មានវាទៈជាសឹកសត្រូវដោយត្រង់ទៅរកសមណព្រាហ្មណ៍ទាំងនោះហើយពោលថា ការរលត់នៃភពដោយប្រការទាំងពួងមាន ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយសំគាល់ហេតុនោះដូចម្តេច ក្រែងសមណព្រាហ្មណ៍ទាំងឡាយនេះ មានវាទៈ

អញ្ញមញ្ញស្ស ឧជុវិបច្ចនីកវាទាតិ ។ ឯវំ ភន្តេ ។ តត្រ គហបតយោ វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ យេ ខោ តេ ភោន្តោ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ សព្វសោ ភវនិរោធោតិ ឥទំ មេ អទិដ្ឋំ យេបិ តេ ភោន្តោ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អត្ថិ សព្វសោ ភវនិរោធោតិ ឥទំ មេ អវិទិតំ អហាញ្ចេវ ខោ បន អជានន្តោ អបស្សន្តោ ឯកំសេន អាទាយ វោហរេយ្យំ ឥទមេវ សច្ចំ មោ-ឃមញ្ញន្តិ ន មេតំ អស្ស បដិរូបំ យេ ខោ តេ ភោន្តោ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ សព្វសោ ភវនិរោធោតិ សចេ តេសំ ភវតំ សម-ណព្រាហ្មណានំ សច្ចំ វចនំ ឋានមេតំ វិជ្ជតិ យេ តេ ទេវា អរូបិនោ សញ្ញាមយា អបណ្ណកំ មេ តត្រូបបត្តិ ភវិស្សតិ យេ បន តេ ភោន្តោ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អត្ថិ សព្វសោ ភវនិរោធោតិ សចេ តេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ វចនំ

ជាសឹកសត្រូវដោយត្រង់ទៅរកគ្នានិងគ្នាមិនមែនឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតីទាំងឡាយ វិញ្ញូបុរស តែងពិចារណាឃើញ ក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ដូច្នេះថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់ទៅនៃភពដោយប្រការទាំងពួងមិនមានឡើយ ហេតុនេះ យើងមិនដែលឃើញទេ សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់នៃភពដោយប្រការទាំងពួងមាន ហេតុនេះយើងមិនដឹង កាលបើយើងមិនដឹង មិនឃើញ គប្បីកាន់យកដោយចំណែកមួយ ហើយនិយាយថា ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះ ពាក្យនេះមិនសមគួរទេ សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់នៃភពដោយប្រការទាំងពួងមិនមាន បើពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ជាពាក្យពិត ហេតុនេះ យកជាទីតាំងបានប្រាកដ ទេវតាទាំងឡាយណាដែលឥតរូបកើតដោយអរូបជ្ឈានសញ្ញា ពាក្យនោះមិនខុស ការកើតក្នុងអរូបព្រហ្មនោះនឹងមានដល់យើង មួយទៀត សមណព្រាហ្មណ៍ដ៏ចម្រើនទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់នៃភព ដោយប្រការទាំងពួងមាន បើពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះជា

ឋានមេតំ វិជ្ជតិ យំ ទិដ្ឋេវ ធម្មេ បរិនិព្វាយិស្សាមិ ។ យេ ខោ តេ ភោន្តោ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ សព្វសោ ភវនិរោធោតិ តេសមយំ ទិដ្ឋិ សារាគាយ សន្តិកេ សំយោគាយ សន្តិកេ អភិនន្ទនាយ សន្តិកេ អជ្ឈោសានាយ សន្តិកេ ឧបាទានាយ សន្តិកេ យេ បន តេ ភោន្តោ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អត្ថិ សព្វសោ ភវនិរោធោតិ តេសមយំ ទិដ្ឋិ អសារាគាយ សន្តិកេ អសំយោគាយ សន្តិកេ អនភិនន្ទនាយ សន្តិកេ អនជ្ឈោសានាយ សន្តិកេ អនុបាទានាយ សន្តិកេតិ ។ សោ ឥតិ បដិសង្ខាយ ភវានំយេវ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។

[១២២] ចត្តារោមេ គហបតយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ កតមេ ចត្តារោ ឥធ គហប-

ពាក្យពិត ហេតុនេះ ទើបយកជាទីតាំងបានប្រាកដ យើងនឹងបរិនិព្វាន ក្នុងបច្ចុប្បន្ននេះ ។ សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈ យ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់នៃភព ដោយប្រការទាំងពួង មិនមាន សេចក្ដីយល់នេះ របស់សមណព្រាហ្មណ៍ទាំងនោះ ក៏ប្រព្រឹត្ត ទៅក្នុងទីជិតនៃសេចក្ដីត្រេកត្រអាល ក្នុងទីជិតនៃសំយោគធម៌ ក្នុងទីជិត នៃសេចក្ដីរីករាយ ក្នុងទីជិតនៃសេចក្ដីចូលចិត្តស៊ប់ ក្នុងទីជិតនៃឧបាទាន មួយទៀត សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា កិរិយារលត់ទៅនៃភព មានដោយប្រការទាំងពួង សេចក្ដីយល់នេះ របស់សមណព្រាហ្មណ៍ទាំងនោះ ប្រព្រឹត្តទៅក្នុងទីជិត នៃសេចក្ដីមិនត្រេកត្រអាល ក្នុងទីជិតនៃសំយោគធម៌ ក្នុងទីជិតនៃសេចក្ដី មិនរីករាយ ក្នុងទីជិតនៃសេចក្ដីមិនចូលចិត្តស៊ប់ ក្នុងទីជិតនៃសេចក្ដីមិន មានឧបាទាន ។ វិញ្ញូបុរសនោះពិចារណាឃើញដូច្នេះហើយ ក៏ប្រតិបត្តិ ដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ភពទាំងឡាយ ។

[១២២] ម្នាលគហបតីទាំងឡាយ បុគ្គលទាំងឡាយ ក្នុងលោក មាន ៤ ពួកនេះ បុគ្គលទាំង ៤ ពួកតើដូចម្ដេចខ្លះ ម្នាលគហបតីទាំងឡាយ

តយោ ឯកច្ចោ បុគ្គលោ អត្តន្តបោ ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ ឥធ គហបតយោ ឯកច្ចោ បុគ្គលោ បរន្តបោ ហោតិ បរបរិតាបនានុយោគមនុយុត្តោ ឥធ គហបតយោ ឯកច្ចោ បុគ្គលោ អត្តន្តបោ ច ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ ឥធ គហបតយោ ឯកច្ចោ បុគ្គលោ នេវត្តន្តបោ ច ហោតិ នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ។

[១២៣] កតមោ ច គហបតយោ បុគ្គលោ អត្តន្តបោ អត្តបរិតាបនានុយោគមនុយុត្តោ ។ ឥធ គហបតយោ ឯកច្ចោ បុគ្គលោ អចេលកោ ហោតិ

បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកប្រកបព្យាយាមរឿយ ៗ ដុតកម្តៅខ្លួនឯង ឈ្មោះអត្តន្តបៈ ១ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកប្រកបព្យាយាមរឿយ ៗ ដុតកម្តៅបុគ្គលដទៃ ឈ្មោះបរន្តបៈ ១ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកប្រកបព្យាយាមរឿយ ៗ ដុតកម្តៅខ្លួនឯង ឈ្មោះអត្តន្តបៈផង ជាអ្នកប្រកបព្យាយាមរឿយ ៗ ដុតកម្តៅបុគ្គលដទៃ ឈ្មោះបរន្តបៈផង ១ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកប្រកបព្យាយាមរឿយ ៗ មិនដុតកម្តៅខ្លួនឯង ឈ្មោះនេវត្តន្តបៈផង ជាអ្នកប្រកបព្យាយាមរឿយ ៗ មិនដុតកម្តៅបុគ្គលដទៃ ឈ្មោះនបរន្តបៈផង ១ អនត្តន្តបបុគ្គលនិងអបរន្តបបុគ្គលនោះ ជាអ្នកលែងមានសេចក្តីស្រេកឃ្លាន មានទុក្ខរំលត់ មានត្រជាក់កើតហើយ មានប្រក្រតីទទួលសុខ មានខ្លួនដូចជាព្រហ្ម នៅក្នុងបច្ចុប្បន្ននេះ ។

[១២៣] ម្នាលគហបតីទាំងឡាយ បុគ្គលប្រកបព្យាយាមរឿយ ៗ ដុតកម្តៅខ្លួនឯង ឈ្មោះអត្តន្តបៈ តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកប្រព្រឹត្តអាក្រាត

មុត្តាចារោ ហត្ថាវលេខនោ[១] ។ យថា កន្ទរក-សុត្តំ[២] តថា វិត្ថារោ ។ ឥតិ ឯវរូបំ អនេកវិហិតំ កាយស្ស អាតាបនបរិតាបនានុយោគមនុយុត្តោ វិហ-រតិ អយំ វុច្ចតិ គហបតយោ បុគ្គលោ អត្តន្តបោ អត្តបរិតាបនានុយោគមនុយុត្តោ ។ កតមោ ច គហ-បតយោ បុគ្គលោ បរន្តបោ បរបរិតាបនានុយោគមនុ-យុត្តោ ។ ឥធ គហបតយោ បុគ្គលោ ឱរព្ភិកោ ហោតិ សូករិកោ ហោតិ ។ បេ ។ យេ វា បនញ្ញេបិ កេចិ កុរូរកម្មន្តា អយំ វុច្ចតិ គហបតយោ បុគ្គលោ បរន្តបោ បរបរិតាបនានុយោគមនុយុត្តោ ។ កតមោ ច គហបតយោ បុគ្គលោ អត្តន្តបោ ច អត្តបរិតាបនា-នុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគ-មនុយុត្តោ ។ ឥធ គហបតយោ ឯកច្ចោ បុគ្គលោ រាជា វា ហោតិ ខត្តិយោ មុទ្ធាវសិត្តោ ។ បេ ។ តេបិ ទណ្ឌតជ្ជិតា ភយតជ្ជិតា អស្សុមុខា រោទមានា បរិកម្មានិ ករោន្តិ អយំ វុច្ចតិ គហបតយោ បុគ្គលោ

---

១ ឱ. ម. ហត្ថាបលេខនោ ។ ២ ឱ. កន្ទរកសុត្តន្តំ ។ ម. កន្ទរកសុត្តន្តេ ។

លះមារយាទល្អចេញ ប្រព្រឹត្តស៊ីលិទ្ធដៃ ។ សេចក្ដីពិស្ដារដូចគ្នានឹងកន្ទរកសូត្រ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រកបព្យាយាមរឿយ ៗ ញ៉ាំងកាយ ឲ្យក្ដៅក្រហល់ក្រហាយ មានប្រការផ្សេង ៗ ជាអ្នកប្រកបព្យាយាមរឿយ ៗ ដុតកម្ដៅខ្លួនឯងមានសភាពយ៉ាងនេះ បុគ្គលនេះហៅថា អត្តន្តបៈ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រកបព្យាយាមរឿយ ៗ ដុតកម្ដៅបុគ្គលដទៃ ឈ្មោះថា បរន្តបៈ តើដូចម្ដេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលក្នុងលោកនេះ ជាអ្នកសម្លាប់ចៀមចិញ្ចឹមជីវិត សម្លាប់ជ្រូកចិញ្ចឹមជីវិត ។ បេ ។ ឬក៏បុគ្គលណាមួយមានការងាររឹករេ ជាអ្នកប្រកបព្យាយាមរឿយ ៗ ដុតកម្ដៅបុគ្គលដទៃ ម្នាលគហបតីទាំងឡាយ បុគ្គលនេះហៅថា បរន្តបៈ ។ ម្នាលគហបតីទាំងឡាយ ចុះបុគ្គលប្រកបព្យាយាមរឿយ ៗ ដុតកម្ដៅខ្លួនឯង ឈ្មោះអត្តន្តបៈផង ជាអ្នកប្រកបព្យាយាមរឿយ ៗ ដុតកម្ដៅនូវបុគ្គលដទៃ ឈ្មោះបរន្តបៈផង តើដូចម្ដេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ គឺស្ដេចជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ។ បេ ។ ក៏បុគ្គលទាំងនោះ តែងមានសេចក្ដីតក់ស្លុតដោយអាជ្ញា តក់ស្លុតដោយភ័យ មានមុខទទឹកដោយទឹកភ្នែក ទួញយំ ធ្វើការងារទាំងឡាយ ជាអ្នកប្រកបព្យាយាមរឿយ ៗ ដុតកម្ដៅខ្លួនឯង ម្នាលគហបតីទាំងឡាយ បុគ្គលនេះហៅថា

អត្តន្តបោ ច អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ ។ កតមោ ច គហបតយោ បុគ្គលោ នេវត្តន្តបោ ច នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ច ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ។ ឥធ គហបតយោ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ។ បេ ។

អត្តន្តបៈផង ជាអ្នកប្រកបព្យាយាមរឿយ ៗ ដុតកម្ដៅបុគ្គលដទៃ ហៅថា បរន្តបៈផង ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រកបព្យាយាមរឿយ ៗ មិនដុតកម្ដៅខ្លួនឯង ហៅថា នេវត្តន្តបៈផង ជាអ្នកប្រកបព្យាយាមរឿយ ៗ មិនដុតកម្ដៅបុគ្គលដទៃ ហៅថា នបរន្តបៈផង តើដូចម្ដេច អនត្តន្តបៈនិងអបរន្តបបុគ្គលនោះ លែងមានសេចក្ដីស្រេកឃ្លាន មានទុក្ខរំលត់ហើយ មានត្រជាក់កើតហើយ មានប្រក្រតីទទួលសេចក្ដីសុខ មានខ្លួនដូចជាព្រហ្មនៅក្នុងបច្ចុប្បន្ននេះ ។ ម្នាលគហបតីទាំងឡាយ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោកនេះ ។ បេ ។ ព្រះតថាគតនោះលះបង់នីវរណធម៌ទាំង ៥ នេះ ដែលជាឧបក្កិលេសក្នុងហឫទ័យ ជាធម៌ធ្វើបញ្ញាឲ្យថយកម្លាំង មានហឫទ័យស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈវិចារៈ មានតែបីតិនិងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ជាអារម្មណ៍ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈហើយ ក៏បានដល់ទុតិយជ្ឈាន ដែលមានក្នុងខ្លួនជាទីជ្រះថ្លា មានភាវៈជាចិត្តខ្ពស់ឯក មិនមានវិតក្កៈនិងវិចារៈទេ មានតែបីតិនិងសុខ ដែលកើតអំពីសមាធិប៉ុណ្ណោះ ព្រោះប្រាសចាកបីតិ ។ បេ ។ បានដល់តតិយជ្ឈាន ព្រោះលះបង់សេចក្ដីសុខផង ។ បេ ។

ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គ-ណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ

ក៏បានដល់ចតុត្ថជ្ឈាន ។ ព្រះតថាគតនោះ កាលបើចិត្តខ្ជាប់ខ្ជួនបរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះ ហើយក៏បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ ព្រះតថាគតនោះ រលឹកជាតិ ដែលបានអាស្រ័យនៅមកពីមុនជាអនេកជាតិ រលឹកជាតិបានដូចម្តេច គឺរលឹកបាន ១ ជាតិ ២ ជាតិ ។ បេ ។ រលឹកតាមជាតិ ដែលអាស្រ័យនៅមកពីមុនបានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ព្រះតថាគតនោះ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ នៃសត្វទាំងឡាយ ។ ព្រះតថាគតនោះ មានចក្ខុដូចជាទិព្វ បរិសុទ្ធជាងចក្ខុរបស់មនុស្សសាម័ញ្ញ បានឃើញសត្វទាំងឡាយ ដែលចុតិនិងបដិសន្ធិ ទាបថោក និងឧត្តម មានសណ្ឋានល្អ

ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ អាស-វនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ អយំ វុច្ចតិ គហបតយោ បុគ្គលោ នេវត្តន្តបោ នាត្តបរិតាបនានុយោគមនុយុត្តោ

និងអាក្រក់ ទៅកាន់សុគតិនិងទុគ្គតិ ។ បេ ។ ក៏ដឹងច្បាស់នូវសត្វទាំង-ឡាយ ដែលអន្ទោលទៅតាមកម្ម ។ ព្រះតថាគតនោះ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកសេចក្ដីសៅហ្មង មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ព្រះតថាគតនោះ ដឹងប្រាកដតាមពិតថា នេះជាទុក្ខ ។ បេ ។ ដឹងប្រាកដតាមពិតថា នេះជាបដិបទា ដំណើរទៅដើម្បីរលត់អាសវៈ ។ កាលដែលព្រះតថាគតនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតចាកកាមាសវៈផង ចិត្តក៏ផុតចាកភវាសវៈផង ចិត្តក៏ផុតចាកអវិជ្ជាសវៈផង ញាណ ក៏កើតឡើងប្រាកដថា ចិត្តផុតស្រឡះហើយ ព្រះតថាគតក៏ដឹងដូច្នេះថា ជាតិអស់ហើយ មគ្គព្រហ្មចរិយធម៌ បាននៅរួចហើយ កិច្ចដែលគួរធ្វើក៏បានធ្វើរួចហើយ កិច្ចដទៃក្រៅពីនេះ មិនមានឡើយ ម្នាលគហបតីទាំងឡាយ បុគ្គលនេះ ហៅថាជាអ្នកប្រកបរឿយ ៗ នូវព្យាយាម មិនដុតកម្ដៅខ្លួនឯង ហៅថានៅវត្តន្តបៈផង ជាអ្នកប្រកបរឿយ ៗ

ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ ។

[១២៤] ឯវំ វុត្តេ សាលេយ្យកា ព្រាហ្មណគហបតិកា ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ[១] ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯតេ មយំ

---

១ ឱ. ឯវមេវំ ។ ម. ឯវមេវ ខោ ។

នូវព្យាយាម មិនដុតកម្ដៅបុគ្គលដទៃ ហៅថា នបរន្តប:ផង អនត្តន្តប-បុគ្គលនិងអបរន្តបបុគ្គលនោះ លែងមានសេចក្ដីស្រេកឃ្លាន មានទុក្ខរលត់ហើយ មានត្រជាក់កើតហើយ មានប្រក្រតីទទួលនូវសុខ មានខ្លួនដូចជាព្រហ្មក្នុងបច្ចុប្បន្ន ។

[១២៤] កាលដែលព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ពួកព្រាហ្មណគហបតី អ្នកស្រុកសាលា បានក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើនប្រកាសហើយ ដោយអនេកបរិយាយនេះឯង (ភ្លឺច្បាស់ណាស់) ដូចបុគ្គលផ្ងាររបស់ដែលគេផ្កាប់ ឬ ដូចបុគ្គលបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវ ដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ឲ្យមនុស្សដែលមានភ្នែកភ្លឺមើលឃើញរូបទាំងឡាយបាន យើងខ្ញុំទាំងឡាយនេះ

ភវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណង្គតេតិ ។

អបណ្ណកសុត្តំ ទសមំ និដ្ឋិតំ ។

គហបតិវគ្គោ បឋមោ ។

## តស្ស វគ្គស្ស ឧទ្ទានំ

កន្ទរនាគរសេខវរោ បោតលិយោ បុន ជីវកភច្ចោ
ឧបាលិទមោ តថា កុក្កុរោ អភយោ
ពហុវេទនិយោបិ ច អបណ្ណកតាទសមោ
បឋមោ បវរោ វគ្គោ ច ។

*សូមដល់ព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹកស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ សូមព្រះគោតមដ៏ចម្រើនជ្រាប នូវយើងខ្ញុំទាំងឡាយ ថាជាឧបាសក ដល់នូវសរណគមន៍ ស្មើដោយជីវិត ។*

ចប់ អបណ្ណកសូត្រ ទី ១០ ។

ចប់ គហបតិវគ្គ ទី ១ ។

## បញ្ជីរឿងនៃវគ្គនោះ ដូច្នេះ

*កន្ទរកសូត្រ ១ អដ្ឋកនាគរសូត្រ ១ សំវរៈ គឺសេក្ខបដិបទាសូត្រ ១ បោតលិយសូត្រ ១ ជីវកកច្ចសូត្រ ១ ឧបាលិទមសូត្រគឺឧបាលិវាទសូត្រ ១ កុក្កុរោវាទសូត្រ ១ អភយសូត្រ ១ ពហុវេទនីយសូត្រ ១ ជា ១០ នឹងអបណ្ណកសូត្រ (នេះគឺ) វគ្គដ៏ប្រសើរ ជាបឋម ។*

# ភិក្ខុវគ្គោ

## បឋមំ ចូឡរាហុលោវាទសុត្តំ

[១២៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា រាហុលោ អម្ពលដ្ឋិកាយំ វិហរតិ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន អម្ពលដ្ឋិកា យេនាយស្មា រាហុលោ តេនុបសង្កមិ ។ អទ្ទសា ខោ អាយស្មា រាហុលោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន អាសនំ បញ្ញាបេសិ ឧទកញ្ច បាទានំ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ និសជ្ជ បាទេ បក្ខាលេសិ ។ អាយស្មាបិ ខោ រាហុលោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[១២៦] អថខោ ភគវា បរិត្តំ ឧទកាវសេសំ ឧទកាធានេ ឋបេត្វា អាយស្មន្តំ រាហុលំ អាមន្តេសិ

# ភិក្ខុវគ្គ

## ចូឡរាហុលោវាទសូត្រ ទី ១

[១២៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង ព្រះរាហុលមានអាយុ គង់នៅក្នុងអម្ពលដ្ឋិកាវ័ន ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចេញចាកផលសមាបត្តិ ក្នុងវេលាសាយណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរចូលទៅ ឯអម្ពលដ្ឋិកាវ័ន សំដៅទៅត្រង់កន្លែង ដែលព្រះរាហុលមានអាយុនៅ ។ ព្រះរាហុលមានអាយុ ក៏បានឃើញព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរមកអំពីចម្ងាយ លុះឃើញហើយ ក៏រៀបចំអាសនៈនិងទឹកសម្រាប់លាងព្រះបាទ ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈ ដែលព្រះរាហុលក្រាលបម្រុងទុក លុះគង់ហើយទើបលាងព្រះបាទា ។ ចំណែកខាងព្រះរាហុលមានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយដាក់អង្គគង់ក្នុងទីសមគួរ ។

[១២៦] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ទុកទឹកឲ្យសល់បន្តិច ក្នុងផ្តិលទឹក ហើយទ្រង់ត្រាស់សួរព្រះរាហុលមានអាយុថា

បស្សសិ នោ ត្វំ រាហុល ឥមំ បរិត្តំ ឧទកាវសេសំ ឧទកាធានេ ឋបិតន្តិ ។ ឯវំ ភន្តេ ។ ឯវំ បរិត្តំ ខោ រាហុល តេសំ សាមញ្ញំ យេសំ នត្ថិ សម្បជានមុសាវាទេ លជ្ជាតិ ។ អថខោ ភគវា តំ បរិត្តំ ឧទកាវសេសំ ឆឌ្ឌេត្វា អាយស្មន្តំ រាហុលំ អាមន្តេសិ បស្សសិ នោ ត្វំ រាហុល ឥមំ បរិត្តំ ឧទកាវសេសំ ឆឌ្ឌិតន្តិ ។ ឯវំ ភន្តេ ។ ឯវំ ឆឌ្ឌិតំ ខោ រាហុល តេសំ សាមញ្ញំ យេសំ នត្ថិ សម្បជានមុសាវាទេ លជ្ជាតិ ។ អថខោ ភគវា តំ ឧទកាធានំ និក្កុជ្ជិត្វា អាយស្មន្តំ រាហុលំ អាមន្តេសិ បស្សសិ នោ ត្វំ រាហុល ឥមំ ឧទកាធានំ និក្កុជ្ជិតន្តិ ។ ឯវំ ភន្តេ ។ ឯវំ និក្កុជ្ជិតំ ខោ រាហុល តេសំ សាមញ្ញំ យេសំ នត្ថិ សម្បជានមុសាវាទេ លជ្ជាតិ ។ អថខោ ភគវា តំ ឧទកាធានំ ឧក្កុជ្ជិត្វា

ម្នាលរាហុល អ្នកបានឃើញទឹកសល់បន្តិច ដែលតថាគត ដាក់ក្នុងផ្តិលទឹកនេះឬទេ ។ ព្រះរាហុលក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ (ឃើញ) ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចជាទឹកដែលមានប្រមាណតិចយ៉ាងនេះឯង ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគទ្រង់ចាក់ទឹកដែលសល់បន្តិចនោះចោល ហើយសួរបញ្ជាក់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញទឹកសល់បន្តិច ដែលតថាគត ចាក់ចោលហើយនេះឬទេ ។ ព្រះករុណាព្រះអង្គ (ឃើញ) ។ ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុ ដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចទឹកដែលតថាគត ចាក់ចោលហើយយ៉ាងនេះឯង ។ ទើបព្រះមានព្រះភាគ ទ្រង់ផ្កាប់ផ្តិលទឹកនោះ ហើយត្រាស់សួរបញ្ជាក់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញផ្តិលទឹកដែលតថាគតផ្កាប់ហើយនេះឬទេ ។ ព្រះករុណាព្រះអង្គ (ឃើញ) ។ ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុ ដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចផ្តិលទឹកដែលតថាគត ផ្កាប់យ៉ាងនេះឯង ។ តអំពីនោះមកទៀត ព្រះមានព្រះភាគ ទ្រង់ផ្ងារផ្តិលទឹកនោះហើយ

អាយស្មន្តំ រាហុលំ អាមន្តេសិ បស្សសិ នោ ត្វំ រាហុល ឥមំ ឧទកាធានំ រិត្តំយេវ[១] តុច្ឆន្តិ ។ ឯវំ ភន្តេ ។ ឯវំ រិត្តំ តុច្ឆំ ខោ រាហុល តេសំ សាមញ្ញំ យេសំ នត្ថិ សម្បជានមុសាវាទេ លជ្ជាតិ[២] ។

[១២៧] សេយ្យថាបិ រាហុល រញ្ញោ នាគោ ឦសាទន្តោ ឧរុឡ្ហវាភិជាតោ[៣] សង្គាមាវចរោ សោ[៤] សង្គាមគតោ បុរិមេហិបិ បាទេហិ កម្មំ ករោតិ បច្ឆិមេហិបិ បាទេហិ កម្មំ ករោតិ បុរិមេនបិ កាយេន កម្មំ ករោតិ បច្ឆិមេនបិ កាយេន កម្មំ ករោតិ សីសេនបិ កម្មំ ករោតិ កណ្ណេហិបិ កម្មំ ករោតិ ទន្តេហិបិ កម្មំ ករោតិ នង្គុដ្ឋេនបិ កម្មំ ករោតិ រក្ខតេវ សោណ្ឌំ ។ តត្ថ ហត្ថារោហស្ស ឯវំ ហោតិ អយំ ខោ រញ្ញោ នាគោ ឦសាទន្តោ ឧរុឡ្ហវាភិជាតោ សង្គាមាវចរោ សង្គាមគតោ

១ ឱ. ម. រិត្តំ ។ ២ ឱ. ឥតិសទ្ទោ ន ទិស្សតិ ។ ៣ ឱ. ឧព្ពូឡ្ហវាភិជាតោ ។ ៤ ម. សោតិ នត្ថិ ។

ត្រាស់សួរបញ្ជាក់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញផ្តិលទឹក ដែលទទេរលីងធេងនេះឬទេ ។ ព្រះករុណាព្រះអង្គ (ឃើញ) ។ ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុ ដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចជាផ្តិលទឹកដែលទទេរលីងធេង យ៉ាងនេះឯង ។

[១២៧] ម្នាលរាហុល ដូចជាដំរីរបស់ស្តេចដែលមានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ដំរីនោះកាលបើចូលកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ធ្វើការដោយជើងក្រោយខ្លះ ធ្វើការដោយកាយខាងមុខខ្លះ ធ្វើការដោយកាយខាងក្រោយខ្លះ ធ្វើការដោយក្បាលខ្លះ ធ្វើការដោយត្រចៀកខ្លះ ធ្វើការដោយភ្លុកខ្លះ ធ្វើការដោយកន្ទុយខ្លះ រក្សាទុកតែប្រមោយប៉ុណ្ណោះ ។ ឯហ្មដំរី មានសេចក្តីត្រិះរិះក្នុងដំណើរ ដែលដំរីរក្សាប្រមោយទុកនោះយ៉ាងនេះថា ដំរីរបស់ស្តេចនេះឯង មានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ទោះបីចូលទៅកាន់សង្គ្រាម

បុរិមេហិបិ ចាទេហិ កម្មំ ករោតិ បច្ឆិមេហិបិ ចាទេហិ កម្មំ ករោតិ បុរិមេនបិ កាយេន កម្មំ ករោតិ បច្ឆិមេនបិ កាយេន កម្មំ ករោតិ សីសេនបិ កម្មំ ករោតិ កណ្ណេហិបិ កម្មំ ករោតិ ទន្តេហិបិ កម្មំ ករោតិ នង្គុដ្ឋេនបិ កម្មំ ករោតិ រក្ខតេវ សោណ្ឌំ អបរិច្ចត្តំ ខោ រញ្ញោ នាគស្ស ជីវិតន្តិ ។ យតោ ខោ រាហុល រញ្ញោ នាគោ ឦសាទន្តោ ឧរុឡ្ហវាភិជាតោ សង្គាមាវចរោ សង្គាមគតោ បុរិមេហិបិ ចាទេហិ កម្មំ ករោតិ បច្ឆិមេហិបិ ចាទេហិ កម្មំ ករោតិ ។ បេ ។ នង្គុដ្ឋេនបិ កម្មំ ករោតិ សោណ្ឌាយបិ កម្មំ ករោតិ ។ តត្ថ ហត្ថារោហស្ស ឯវំ ហោតិ អយញ្ច ខោ រញ្ញោ នាគោ ឦសាទន្តោ ឧរុឡ្ហវាភិជាតោ សង្គាមាវចរោ សង្គាមគតោ បុរិមេហិបិ ចាទេហិ កម្មំ ករោតិ បច្ឆិមេហិបិ ចាទេហិ កម្មំ ករោតិ បុរិមេនបិ កាយេន កម្មំ ករោតិ បច្ឆិមេនបិ កាយេន កម្មំ ករោតិ សីសេនបិ កម្មំ ករោតិ កណ្ណេហិបិ កម្មំ ករោតិ

តែងធ្វើការដោយជើងមុខខ្លះ ធ្វើការដោយជើងក្រោយខ្លះ ធ្វើការដោយកាយខាងមុខខ្លះ ធ្វើការដោយកាយខាងក្រោយខ្លះ ធ្វើការដោយក្បាលខ្លះ ធ្វើការដោយស្លឹកត្រចៀកខ្លះ ធ្វើការដោយភ្លុកខ្លះ ធ្វើការដោយកន្ទុយខ្លះ រក្សាទុកតែប្រមោយប៉ុណ្ណោះ ដំរីរបស់ស្តេច (នេះ) ឈ្មោះថាមិនទាន់ប្រថុយជីវិតនៅឡើយ ។ ម្នាលរាហុល កាលដែលដំរីរបស់ស្តេចមានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ទោះបីចូលទៅកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ធ្វើការដោយជើងក្រោយខ្លះ ។ បេ ។ ធ្វើការដោយកន្ទុយខ្លះ ធ្វើការដោយប្រមោយខ្លះ ។ ហ្មដំរី មានសេចក្តីត្រិះរិះក្នុងដំណើរនោះយ៉ាងនេះថា ដំរីរបស់ស្តេចនេះឯង មានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ទោះបីចូលកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ធ្វើការដោយជើងក្រោយខ្លះ ធ្វើការដោយកាយខាងមុខខ្លះ ធ្វើការដោយកាយខាងក្រោយខ្លះ ធ្វើការដោយក្បាលខ្លះ ធ្វើការដោយស្លឹកត្រចៀកខ្លះ

ឧន្តេហិបិ កម្មំ ករោតិ ឧក្កុជ្ជេឧបិ កម្មំ ករោតិ សោណ្ឌាយបិ កម្មំ ករោតិ បរិច្ចត្តំ ខោ រញ្ញោ នាគស្ស ជីវិតំ នត្ថិទានិ កិញ្ចិ រញ្ញោ នាគស្ស អករណីយន្តិ ។ ឯវមេវ ខោ រាហុល យស្ស កស្សចិ សម្បជានមុសាវាទេ នត្ថិ លជ្ជា នាហំ តស្ស កិញ្ចិ បាបំ កម្មំ អករណីយន្តិ វទាមិ ។ តស្មាតិហ តេ រាហុល ហស្សាបិ ន មុសា ភណិស្សាមីតិ ឯវញ្ហិ តេ រាហុល សិក្ខិតព្វំ ។

[១២៨] តំ កឹ មញ្ញសិ រាហុល កិមត្ថិយោ អាទាសោតិ ។ បច្ចវេក្ខណត្ថោ ភន្តេតិ ។ ឯវមេវ ខោ រាហុល បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា កាយេន កម្មំ កាតព្វំ[១] បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា វាចាយ កម្មំ កាតព្វំ[២] បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា មនសា កម្មំ កាតព្វំ[៣] ។

---

១-២-៣ ឱ. ម. កត្តព្វំ ។

ធ្វើការដោយក្តុកខ្វះ ធ្វើការដោយកន្ទុយខ្វះ ធ្វើការដោយប្រមោយខ្វះ ដំរីរបស់ស្តេចនេះ ទើបឈ្មោះថា ប្រថុយលះបង់ជីវិតហើយ ឥឡូវនេះ អំពើណាមួយ ដែលដំរីរបស់ស្តេច ឈ្មោះថាមិនទាន់ធ្វើ មិនមានឡើយ សេចក្តីនេះមានឧបមាយ៉ាងណា ។ ម្នាលរាហុល មានឧបមេយ្យដូចភិក្ខុណាមួយ ដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ តថាគត មិនពោលថា ភិក្ខុនោះមិនធ្វើបាបកម្មតិចតួច ដូច្នេះទេ ។ ម្នាលរាហុល ព្រោះហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគួរសិក្សាថា អាត្មាអញនឹងមិនពោលពាក្យកុហក សូម្បីដើម្បីសើចលេង ម្នាលរាហុល អ្នកត្រូវសិក្សា យ៉ាងនេះចុះ ។

[១២៨] ម្នាលរាហុល អ្នកសំគាល់សេចក្តីនោះថាដូចម្តេច កញ្ចក់មានប្រយោជន៍ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន កញ្ចក់មានប្រយោជន៍ខាងការឆ្លុះមើលមុខ ។ ម្នាលរាហុល យ៉ាងនោះមែនហើយ អ្នកគប្បីពិចារណាត្រិះរិះមើលរួចហើយ សឹមធ្វើកម្មដោយកាយ ពិចារណាត្រិះរិះមើលរួចហើយ សឹមធ្វើកម្មដោយវាចា ពិចារណាត្រិះរិះមើលរួចហើយ សឹមធ្វើកម្មដោយចិត្ត ។

[១២៩] យទេវ ត្វំ រាហុល កាយេន កម្មំ កត្តុកាមោ អហោសិ តទេវ តេ កាយកម្មំ បច្ចវេក្ខិតព្វំ យន្នុ ខោ អហំ ឥទំ កាយេន កម្មំ កត្តុកាមោ ឥទំ មេ កាយកម្មំ អត្តព្យាពាធាយបិ សំវត្តេយ្យ បរព្យាពាធាយបិ សំវត្តេយ្យ ឧភយព្យាពាធាយបិ សំវត្តេយ្យ អកុសលំ ឥទំ កាយកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ សចេ ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ កាយេន កម្មំ កត្តុកាមោ ឥទំ មេ កាយកម្មំ អត្តព្យាពាធាយបិ សំវត្តេយ្យ បរព្យាពាធាយបិ សំវត្តេយ្យ ឧភយព្យាពាធាយបិ សំវត្តេយ្យ អកុសលំ ឥទំ កាយកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ឯវរូបំ តេ រាហុល កាយេន កម្មំ សសក្កំ[១] ន ករណីយំ ។ សចេ បន ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ កាយេន កម្មំ កត្តុកាមោ ឥទំ មេ កាយកម្មំ នេវត្តព្យាពាធាយបិ សំវត្តេយ្យ ន បរព្យាពាធាយបិ សំវត្តេយ្យ

១ ម. សំសក្កំ ។

[១២៩] ម្នាលរាហុល បើអ្នកចង់ធ្វើអំពើណាមួយ ដោយកាយ អ្នកត្រូវពិចារណាមើល នូវកាយកម្មនោះសិនថា អាត្មាអញ ចង់ធ្វើអំពើណាដោយកាយ តើកាយកម្មរបស់អាត្មាអញនេះឯង ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែក គឺខ្លួនឯងនិងអ្នកដទៃផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ឬហ្ន៎ ។ ម្នាលរាហុល បើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ ចង់ធ្វើអំពើណាដោយកាយ កាយកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកមិនត្រូវធ្វើអំពើដោយកាយ ដែលមានទំនង់យ៉ាងនេះ ដោយដាច់ខាត ។ ម្នាលរាហុល ប្រសិនបើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញ ចង់ធ្វើអំពើណាដោយកាយ កាយកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គល

ន ឧភយព្យាពាធាយបិ សំវត្តេយ្យ កុសលំ ឥទំ កាយកម្មំ សុខុទ្រយំ សុខវិបាកន្តិ ឯវរូបំ តេ រាហុល កាយេន កម្មំ ករណីយំ ។ ករោន្តេនបិ តេ រាហុល កាយេន កម្មំ តទេវ តេ កាយកម្មំ បច្ចវេក្ខិតព្វំ យន្នុ ខោ អហំ ឥទំ កាយេន កម្មំ ករោមិ ឥទំ មេ កាយកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ កាយកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ សចេ[១] ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ កាយេន កម្មំ ករោមិ ឥទំ មេ កាយកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ កាយកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ បដិសំហរេយ្យាសិ ត្វំ រាហុល ឯវរូបំ កាយកម្មំ ។ សចេ បន ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ កាយេន កម្មំ ករោមិ ឥទំ មេ កាយកម្មំ

---

១ ម. សចេ បន ។

ដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយ-កម្មនេះជាកុសល ចម្រើនតែខាងសេចក្ដីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើអំពើដោយកាយយ៉ាងនេះចុះ ។ ម្នាលរាហុល បើទុកជាអ្នកកំពុងធ្វើអំពើដោយកាយ អ្នកត្រូវតែពិចារណាមើល នូវកាយកម្មនោះឯងថា អាត្មាអញ កំពុងធ្វើអំពើណាដោយកាយ តើកាយកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខ ឬហ្ន៎ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ កំពុងធ្វើអំពើណាដោយកាយ កាយកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវលះបង់កាយកម្ម ដែលមានទំនងយ៉ាងនេះចេញ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញកំពុងធ្វើអំពើណា ដោយកាយ កាយកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្ត

នេវត្តព្យាពាធាយបិ សំវត្តតិ ន បរព្យាពាធាយបិ សំវត្តតិ ន ឧភយព្យាពាធាយបិ សំវត្តតិ កុសលំ ឥទំ កាយកម្មំ សុខុទ្រយំ សុខវិបាកន្តិ អនុប-ធជ្ជេយ្យាសិ[១] ត្វំ រាហុល ឯវរូបំ កាយកម្មំ ។ កត្វាបិ តេ រាហុល កាយេន កម្មំ តទេវ តេ កាយកម្មំ បច្ចវេក្ខិតព្វំ យន្នុ ខោ អហំ ឥទំ កាយេន កម្មំ អកាសឹ ឥទំ មេ កាយកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ កា-យេន កម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ សចេ[២] ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ កាយកម្មំ អកាសឹ ឥទំ មេ កាយកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ

១ ម. អនុបរជ្ជេយ្យាសិ ។ ២ ម. សចេ ខោ ។

ទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើឲ្យរឿយ ៗ នូវកាយកម្ម ដែលមានទំនងយ៉ាងនេះចុះ ។ ម្នាលរាហុល បើអ្នកបានធ្វើអំពើដោយកាយរួចហើយ អ្នកត្រូវពិចារណាមើលកាយកម្មនោះថា អាត្មាអញបានធ្វើអំពើណាដោយកាយ តើកាយកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល ប្រសិនបើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ បានធ្វើកាយកម្មណា កាយកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង

ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ កាយកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ឯវរូបំ តេ រាហុល កាយកម្មំ សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ ទេសេតព្វំ វិវរិតព្វំ ឧត្តានីកាតព្វំ ទេសេត្វា វិវរិត្វា ឧត្តានីកត្វា អាយតឹ សំវរំ អាបជ្ជិតព្វំ ។ សចេ បន ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខ្វាហំ ឥទំ កាយេន កម្មំ អកាសឹ ឥទំ មេ កាយកម្មំ នេវត្តព្យាពាធាយបិ សំវត្តតិ ន បរព្យាពាធាយបិ សំវត្តតិ ន ឧភយព្យាពាធាយបិ សំវត្តតិ កុសលំ ឥទំ កាយកម្មំ សុខុទ្រយំ សុខវិបាកន្តិ តេនេវ ត្វំ រាហុល បីតិប្បាមុជ្ជេន វិហរេយ្យាសិ អហោរត្តានុសិក្ខី កុសលេសុ ធម្មេសុ ។

ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវសំដែងបើកបង្ហើបប្រាប់នូវកាយកម្ម ដែលមានទំនងយ៉ាងនេះ ចំពោះគ្រូ ឬចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ជាអ្នកប្រាជ្ញ លុះអ្នកសំដែងបើកបង្ហើប ប្រាប់រួចហើយ អ្នកគប្បីដល់នូវការសង្រួមតទៅ ។ ម្នាលរាហុល ប្រសិនបើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញ បានធ្វើអំពើណាដោយកាយ កាយកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវខំសិក្សាទាំងយប់ទាំងថ្ងៃ ក្នុងធម៌ទាំងឡាយជាកុសល ហើយនៅដោយបីតិនិងបាមុជ្ជៈនោះឯង ។

[១៣០] យទេវ ត្វំ រាហុល វាចាយ កម្មំ កត្តុកាមោ អហោសិ តទេវ តេ វចីកម្មំ បច្ច-វេក្ខិតព្វំ យន្នុ ខោ អហំ ឥទំ វាចាយ កម្មំ កត្តុកាមោ ឥទំ មេ វចីកម្មំ អត្តព្យាពាធាយបិ សំវត្តេយ្យ បរព្យាពាធាយបិ សំវត្តេយ្យ ឧភយព្យា-ពាធាយបិ សំវត្តេយ្យ អកុសលំ ឥទំ វចីកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ សចេ ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ វាចាយ កម្មំ កត្តុកាមោ ឥទំ មេ វចីកម្មំ អត្តព្យាពាធាយបិ សំវត្តេយ្យ បរព្យាពាធាយបិ សំ-វត្តេយ្យ ឧភយព្យាពាធាយបិ សំវត្តេយ្យ អកុសលំ ឥទំ វចីកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ឯវរូបំ តេ រាហុល វាចាយ កម្មំ សសក្កំ ន ករណីយំ ។ សចេ បន ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ វាចាយ កម្មំ កត្តុកាមោ ឥទំ មេ វចីកម្មំ នេវត្តព្យាពាធាយបិ សំវត្តេយ្យ

[១៣០] ម្នាលរាហុល បើអ្នកចង់ធ្វើអំពើណាមួយ ដោយវាចា អ្នកត្រូវពិចារណា នូវវចីកម្មនោះសិនថា អាត្មាអញ ចង់ធ្វើអំពើណា ដោយវាចា តើវចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែក គឺខ្លួននិងបុគ្គលដទៃផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញចង់ធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកមិនត្រូវធ្វើអំពើដោយវាចា ដែលមានទំនង់យ៉ាងនេះដោយដាច់ខាត ។ ម្នាលរាហុល បើប្រសិនជាអ្នកពិ-ចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញចង់ធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង

ន បរព្យាពាធាយបិ សំវត្តេយ្យ ន ឧភយព្យាពាធា-យបិ សំវត្តេយ្យ កុសលំ ឥទំ វចីកម្មំ សុខុទ្រយំ សុខវិបាកន្តិ ឯវរូបំ តេ រាហុល វាចាយ កម្មំ ករណីយំ ។ ករោន្តេនបិ តេ រាហុល វាចាយ កម្មំ តទេវ តេ វចីកម្មំ បច្ចវេក្ខិតព្វំ យន្នុ ខោ អហំ ឥទំ វាចាយ កម្មំ ករោមិ ឥទំ មេ វចីកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ វចី-កម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ សចេ ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ វាចាយ កម្មំ ករោមិ ឥទំ មេ វចីកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ វចីកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ បដិសំហរេយ្យាសិ ត្វំ រាហុល ឯវរូបំ វចីកម្មំ ។ សចេ បន ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ វាចាយ កម្មំ ករោមិ ឥទំ មេ វចីកម្មំ

មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើអំពើដោយវាចា ដែលមានទំនងយ៉ាងនេះចុះ ។ ម្នាលរាហុល បើអ្នកកំពុងធ្វើអំពើដោយវាចា អ្នកត្រូវពិចារណាមើលវចីកម្មនោះថា អាត្មាអញ កំពុងធ្វើអំពើណាដោយវាចា តើវចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ឬហ្ន៎ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ កំពុងធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវលះបង់វចីកម្ម មានទំនងយ៉ាងនេះចេញ ដោយដាច់ខាត ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញ កំពុងធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ

នេវត្តព្យាពាធាយបិ សំវត្តតិ ន បរព្យាពាធាយបិ សំវត្តតិ ន ឧភយព្យាពាធាយបិ សំវត្តតិ កុសលំ ឥទំ វចីកម្មំ សុខុទ្រយំ សុខវិបាកន្តិ អនុបទជ្ជេយ្យាសិ ត្វំ រាហុល ឯវរូបំ វចីកម្មំ ។ កត្វាបិ តេ រាហុល វាចាយ កម្មំ តទេវ តេ វចីកម្មំ បច្ចវេក្ខិតព្វំ យន្នុ ខោ អហំ ឥទំ វាចាយ កម្មំ អកាសឹ ឥទំ មេ វចីកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ វចីកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ សចេ ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ វាចាយ កម្មំ អកាសឹ ឥទំ មេ វចីកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ វចីកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ឯវរូបំ តេ រាហុល វចីកម្មំ សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ ទេសេតព្វំ វិវរិតព្វំ ឧត្តានីកាតព្វំ ទេសេត្វា វិវរិត្វា ឧត្តានីកត្វា អាយតឹ សំវរំ អាបជ្ជិតព្វំ ។

មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើវចីកម្មដែលមានទំនងយ៉ាងនេះឲ្យរឿយ ៗ ទៅចុះ ។ ម្នាលរាហុល បើអ្នកបានធ្វើអំពើដោយវាចារួចហើយ អ្នកត្រូវពិចារ-ណាមើលវចីកម្មនោះថា អាត្មាអញ បានធ្វើអំពើណា ដោយវាចាហើយ តើវចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ឬហ្ន៎ ។ ម្នាលរាហុល បើអ្នកបានពិចារណាមើលទៅដឹងយ៉ាងនេះថា អាត្មាអញ បានធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកគប្បីសំដែងបើកបង្ហើប ប្រាប់នូវវចីកម្មដែលមានទំនងយ៉ាងនេះចំពោះគ្រូ ឬចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ដែលមានប្រាជ្ញា លុះអ្នកសំដែងបើកបង្ហើបប្រាប់រួចហើយ គប្បីដល់នូវការសង្រួមតទៅ ។

សចេ បន ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ វាចាយ កម្មំ អកាសឹ ឥទំ មេ វចីកម្មំ នេវត្តព្យាពាធាយបិ សំវត្តតិ ន បរព្យាពាធាយបិ សំវត្តតិ ន ឧភយព្យាពាធាយបិ សំវត្តតិ កុសលំ ឥទំ វចីកម្មំ សុខុទ្រយំ សុខវិបាកន្តិ តេនេវ ត្វំ រាហុល បីតិបាមុជ្ជេន វិហរេយ្យាសិ អហោរត្តានុសិក្ខី កុសលេសុ ធម្មេសុ ។

[១៣១] យនេវ ត្វំ រាហុល មនសា កម្មំ កត្តុកាមោ អហោសិ តទេវ តេ មនោកម្មំ បច្ចវេក្ខិតព្វំ យន្នុ ខោ អហំ ឥទំ មនសា កម្មំ កត្តុកាមោ ឥទំ មេ មនោកម្មំ អត្តព្យាពាធាយបិ សំវត្តេយ្យ បរព្យាពាធាយបិ សំវត្តេយ្យ ឧភយព្យាពាធាយបិ សំវត្តេយ្យ អកុសលំ ឥទំ មនោកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ សចេ ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ មនសា កម្មំ កត្តុកាមោ ឥទំ មេ មនោកម្មំ អត្តព្យា-

ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ ធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះ ជាកុសល ចម្រើនតែខាងសេចក្ដីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវខំសិក្សាទាំងយប់ទាំងថ្ងៃ ក្នុងធម៌ជាកុសលទាំងឡាយ ហើយនៅដោយបីតីនិងបាមោជ្ជៈនោះចុះ ។

[១៣១] ម្នាលរាហុល បើអ្នកចង់ធ្វើអំពើណាដោយចិត្ត អ្នកត្រូវពិចារណាមើល នូវមនោកម្មនោះសិនថា អាត្មាអញ ចង់ធ្វើអំពើណាដោយចិត្ត តើមនោកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែក គឺខ្លួននិងអ្នកដទៃផង មនោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខ ឬហ្ន៎ ។ ម្នាលរាហុល បើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញចង់ធ្វើអំពើណាដោយចិត្ត មនោកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀន

ពាធាយបិ សំវត្តេយ្យ បរព្យាពាធាយបិ សំវត្តេយ្យ ឧភ-យព្យាពាធាយបិ សំវត្តេយ្យ អកុសលំ ឥទំ មនោកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ឯវរូបំ តេ រាហុល មនសា កម្មំ សសក្កំ ន ករណីយំ ។ សចេ បន ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ មនសា កម្មំ កត្តុកាមោ ឥទំ មេ មនោកម្មំ នេវត្តព្យាពាធាយបិ សំវត្តេយ្យ ន បរ-ព្យាពាធាយបិ សំវត្តេយ្យ ន ឧភយព្យាពាធាយបិ សំវត្តេយ្យ កុសលំ ឥទំ មនោកម្មំ សុខុទ្រយំ សុខវិបាកន្តិ ឯវរូបំ តេ រាហុល មនសា កម្មំ ករណីយំ ។ ករោន្តេនបិ តេ រាហុល មនសា កម្មំ តទេវ តេ មនោកម្មំ បច្ចវេក្ខិតព្វំ យន្នុ ខោ អហំ ឥទំ មនសា កម្មំ ករោមិ ឥទំ មេ មនោកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធា-យបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុ-សលំ ឥទំ មនោកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។

ខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកមិនត្រូវធ្វើអំពើដោយចិត្ត ដែលមានទំនងយ៉ាងនេះ ដោយដាច់ខាត ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញចង់ធ្វើអំពើណាដោយចិត្ត មនោកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះ ជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើអំពើ ដែលមានទំនងយ៉ាងនេះចុះ ។ ម្នាលរាហុល បើអ្នកកំពុងធ្វើអំពើណាដោយចិត្ត អ្នកត្រូវពិចារណាមើល នូវមនោកម្មនោះថា អាត្មាអញកំពុងធ្វើអំពើណាដោយចិត្ត តើមនោកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ឬហ្ន៎ ។

២២៤



សចេ ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ មនសា កម្មំ ករោមិ ឥទំ មេ មនោកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ មនោកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ បដិសំហរេយ្យាសិ ត្វំ រាហុល ឯវរូបំ មនោកម្មំ ។ សចេ បន ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ មនសា កម្មំ ករោមិ ឥទំ មេ មនោកម្មំ នេវត្តព្យាពាធាយបិ សំវត្តតិ ន បរព្យាពាធាយបិ សំវត្តតិ ន ឧភយព្យាពាធាយបិ សំវត្តតិ កុសលំ ឥទំ មនោកម្មំ សុខុទ្រយំ សុខវិបាកន្តិ អនុបទជ្ជេយ្យាសិ ត្វំ រាហុល ឯវរូបំ មនោកម្មំ ។ កត្វាបិ តេ រាហុល មនសា កម្មំ តទេវ តេ មនោកម្មំ បច្ចវេក្ខិតព្វំ យន្នុ ខោ អយំ ឥទំ មនសា កម្មំ អកាសឹ ឥទំ មេ មនោកម្មំ អត្តព្យាពាធាយបិ សំវត្តតិ

ម្នាលរាហុល បើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ កំពុងធ្វើអំពើណា ដោយចិត្ត មនោកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនោះ ជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវ លះបង់មនោកម្ម ដែលមានទំនងយ៉ាងនេះចេញ ។ ម្នាលរាហុល ប្រសិន បើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញកំពុងធ្វើអំពើ ណាដោយចិត្ត មនោកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀត បៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនអ្នកដទៃផង មិនប្រព្រឹត្ត ទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះ ជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើ នូវមនោកម្ម ដែលមានទំនងយ៉ាងនេះឲ្យរឿយ ៗ ទៅចុះ ។ ម្នាលរាហុល បើអ្នកបានធ្វើអំពើ ដោយចិត្តរួចហើយ អ្នកត្រូវពិចារណានូវមនោកម្ម នោះឯងថា អាត្មាអញ បានធ្វើនូវអំពើណាដោយចិត្តហើយ តើមនោកម្ម របស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្ត

បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ មនោកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ សចេ ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ មនសា កម្មំ អកាសឹ ឥទំ មេ មនោកម្មំ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ អកុសលំ ឥទំ មនោកម្មំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ឯវរូបេ[១] បន តេ រាហុល មនោកម្មេ[២] អដ្ដិយិតព្វំ ហរាយិតព្វំ ជិគុច្ឆិតព្វំ អដ្ដិយិត្វា ហរាយិត្វា ជិគុច្ឆិត្វា អាយតឹ សំវរំ អាបជ្ជិតព្វំ ។ សចេ បន ត្វំ រាហុល បច្ចវេក្ខមានោ ឯវំ ជានេយ្យាសិ យំ ខោ អហំ ឥទំ មនសា កម្មំ អកាសឹ ឥទំ មេ មនោកម្មំ នេវត្តព្យាពាធាយបិ សំវត្តតិ ន បរព្យាពាធាយបិ សំវត្តតិ ន ឧភយព្យាពាធាយបិ សំវត្តតិ កុសលំ ឥទំ មនោកម្មំ សុខុទ្រយំ សុខវិបាកន្តិ តេនេវ ត្វំ រាហុល បីតិប្បាមុជ្ជេន វិហរេយ្យាសិ អហោរត្តានុសិក្ខី កុសលេសុ ធម្មេសុ ។

១ ម. ឯវរូបំ ។ ២ ម. មនោកម្មំ ។

ទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ឬហ្ន៎ ។ ម្នាលរាហុល បើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញបានធ្វើអំពើណា ដោយចិត្តហើយ មនោកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះ ជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវធុញទ្រាន់ នឿយណាយ ខ្ពើមរអើមចំពោះមនោកម្ម ដែលមានទំនងយ៉ាងនេះ លុះអ្នកធុញទ្រាន់នឿយណាយខ្ពើមរអើមហើយ ត្រូវដល់នូវការសង្រួមតទៅ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញ បានធ្វើនូវអំពើណាដោយចិត្តហើយ មនោកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះ ជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវខំសិក្សាទាំងយប់ទាំងថ្ងៃ ក្នុងធម៌ជាកុសលទាំងឡាយ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះចុះ ។

[១៣២] យេ ហិ កេចិ រាហុល អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា កាយកម្មំ បរិសោធេសុំ វចីកម្មំ បរិសោធេសុំ មនោកម្មំ បរិសោធេសុំ សព្វេ តេ ឯវមេវ(១) បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា កាយកម្មំ បរិសោធេសុំ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា វចីកម្មំ បរិសោធេសុំ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា មនោកម្មំ បរិសោធេសុំ ។ យេបិ ហិ(២) កេចិ រាហុល អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា កាយកម្មំ បរិសោធេស្សន្តិ វចីកម្មំ បរិសោធេស្សន្តិ មនោកម្មំ បរិសោធេស្សន្តិ សព្វេ តេ ឯវមេវ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា កាយកម្មំ បរិសោធេស្សន្តិ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា វចីកម្មំ បរិសោធេស្សន្តិ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា មនោកម្មំ បរិសោធេស្សន្តិ ។ យេបិ ហិ កេចិ រាហុល ឯតរហិ សមណា វា ព្រាហ្មណា វា កាយកម្មំ បរិសោធេន្តិ វចីកម្មំ បរិសោធេន្តិ មនោកម្មំ បរិសោធេន្តិ សព្វេ តេ

១ ឱ. ម. ឯវមេវំ ។ ២ ឱ. ម. យេហិបិ ។

[១៣២] ម្នាលរាហុល ព្រោះថាសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលដែលកន្លងទៅហើយ បានជម្រះកាយកម្ម ជម្រះវចីកម្ម ជម្រះមនោកម្ម ពួកសមណព្រាហ្មណ៍ទាំងអស់នោះ សុទ្ធតែបានពិចារណាត្រិះរិះមើលសព្វ យ៉ាងនេះហើយ ទើបជម្រះកាយកម្ម ពិចារណាត្រិះរិះមើលសព្វ យ៉ាងនេះហើយ ទើបជម្រះវចីកម្ម ពិចារណាត្រិះរិះមើលសព្វយ៉ាងនេះហើយ ទើបជម្រះមនោកម្មដែរ ។ ម្នាលរាហុល សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលដ៏មិនទាន់មានមក នឹងជម្រះកាយកម្ម នឹងជម្រះវចីកម្ម នឹងជម្រះមនោកម្ម ក៏ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ នឹងពិចារណាត្រិះរិះមើលសព្វយ៉ាងនេះហើយ ទើបជម្រះកាយកម្ម ពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះវចីកម្ម ពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះមនោកម្មដែរ ។ ម្នាលរាហុល សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលឥឡូវនេះ ជម្រះកាយកម្ម ជម្រះវចីកម្ម ជម្រះមនោកម្ម ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ

ឯវមេវ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា កាយកម្មំ បរិសោធេន្តិ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា វចីកម្មំ បរិសោធេន្តិ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា មនោកម្មំ បរិសោធេន្តិ ។ តស្មាតិហ តេ រាហុល បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា កាយកម្មំ បរិសោធេស្សាមិ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា វចីកម្មំ បរិសោធេស្សាមិ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា មនោកម្មំ បរិសោធេស្សាមីតិ ឯវញ្ហិ តេ(២) រាហុល សិក្ខិតព្វន្តិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា រាហុលោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ចូឡរាហុលោវាទសុត្តំ បឋមំ និដ្ឋិតំ ។

---

១ ឱ. ម. តេតិ ន បញ្ញាយតិ ។ ២ ឱ. ឯវំ ហិ វោ ។ ម. ឯវំ ហិ តេ ។

តែងពិចារណាត្រិះរិះមើលសព្វគ្រប់ យ៉ាងនេះហើយ ទើបជម្រះកាយ-កម្ម ពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះវចីកម្ម ពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះមនោកម្មដែរ ។ ម្នាលរាហុល ព្រោះហេតុដូច្នោះក្នុងសាសនានេះ អ្នកត្រូវសិក្សាថា អាត្មាអញ នឹងពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះកាយកម្ម អាត្មាអញនឹងពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះវចីកម្ម អាត្មាអញនឹងពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះមនោកម្ម ដូច្នេះ ម្នាលរាហុល អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះរាហុលមានអាយុ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ចូឡរាហុលោវាទសូត្រ ទី ១ ។

# ទុតិយំ មហារាហុលោវាទសុត្តំ

[១៣៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ អាយស្មាបិ ខោ រាហុលោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ អថខោ ភគវា អបលោកេត្វា អាយស្មន្តំ រាហុលំ អាមន្តេសិ យំ កិញ្ចិ រាហុល រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វន្តិ ។ រូបមេវ នុ ខោ ភគវា រូបមេវ នុ ខោ សុគតាតិ ។

# មហារាហុលោវាទសូត្រ ទី ២

[១៣៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរចូលទៅ កាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ ចំណែកខាងព្រះរាហុលមានអាយុ ក៏ស្លៀកស្បង់ប្រដាប់បាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយដើរតាមក្រោយ ៗ ព្រះមានព្រះភាគ ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ឆ្មៀងព្រះកត្រ្គ ត្រាស់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល រូបណាមួយជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឬរូបណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដែលជាអតីត អនាគត ជាបច្ចុប្បន្ន រូបទាំងអស់នោះក៏គ្រាន់តែជារូប (ប៉ុណ្ណោះឯង) អ្នកគួរយល់ឃើញនូវរូបនុ៎ះ ដោយប្រាជ្ញាដ៏ល្អតាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ ព្រះរាហុលក្រាបបង្គំសួរថា បពិត្រព្រះមានព្រះភាគ (សេចក្តីនេះ) មានតែរូបម្យ៉ាងទេឬ បពិត្រព្រះសុគត (សេចក្តីនេះ) មានតែរូបម្យ៉ាងទេឬ ។

រូបម្បិ រាហុល វេទនាបិ រាហុល សញ្ញាបិ រាហុល សង្ខារាបិ រាហុល វិញ្ញាណម្បិ រាហុលាតិ ។

[១៣៤] អថខោ អាយស្មា រាហុលោ កោ ជ្ជ[១] ភគវតា សម្មុខា ឱវាទេន ឱវទិតោ គាមំ បិណ្ឌាយ បវិសិស្សតីតិ តតោ បដិនិវត្តិត្វា អញ្ញតរស្មឹ រុក្ខមូលេ និសីទិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ អទ្ទសា ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ រាហុលំ អញ្ញតរស្មឹ រុក្ខមូលេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ទិស្វាន អាយស្មន្តំ រាហុលំ អាមន្តេសិ អានាបានស្សតឹ រាហុល ភាវនំ ភាវេហិ អានាបានស្សតិ រាហុល ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសាតិ ។ អថខោ អាយស្មា រាហុលោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

១ ឱ. ម. នជ្ជ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលរាហុល រូបក៏មាន ម្នាលរាហុល វេទនាក៏មាន ម្នាលរាហុល សញ្ញាក៏មាន ម្នាលរាហុល សង្ខារទាំងឡាយក៏មាន ម្នាលរាហុល វិញ្ញាណក៏មាន ។

[១៣៤] គ្រានោះឯង ព្រះរាហុលមានអាយុគិតថា បាននរណាហ្ន៎ (ជាវិញ្ញូបណ្ឌិត) ដែលព្រះមានព្រះភាគ ទូន្មានហើយដោយដំបូន្មានផ្ទាល់ព្រះឱស្ឋ នឹងចូលមកកាន់ស្រុក ដើម្បីបិណ្ឌបាត ក្នុងថ្ងៃនេះទៅអេះ ដូច្នេះហើយលោកក៏ត្រឡប់ថយចេញ អំពីសំណាក់ព្រះមានព្រះភាគនោះ ហើយទៅអង្គុយផ្គត់ភ្នែនតម្រង់កាយឲ្យត្រង់ តាំងស្មារតីឲ្យមានមុខឆ្ពោះទៅរកព្រះកម្មដ្ឋាន ទៀបគល់ឈើ ១ ដើម ។ គាប់ចួនជាព្រះសារីបុត្តមានអាយុ បានឃើញព្រះរាហុលមានអាយុ កំពុងអង្គុយផ្គត់ភ្នែនតម្រង់កាយឲ្យត្រង់ តាំងស្មារតីឲ្យមានមុខឆ្ពោះទៅរកព្រះកម្មដ្ឋានទៀបគល់ឈើ ១ ដើម លុះឃើញហើយ ក៏ប្រាប់ព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកចូរចម្រើនអានាបានស្សតិភាវនាចុះ ម្នាលរាហុល (ដ្បិត) អានាបានស្សតិភាវនា ដែលគេបានអប់រំបន្ទុំធ្វើឲ្យរឿយ ៗ ហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ លុះដល់ពេលថ្ងៃរសៀល ព្រះរាហុលមានអាយុ ក្រោកអំពីសំណឹង ហើយចូលសំដៅទៅត្រង់ទី ដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ

ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាហុលោ ភគវន្តំ ឯតទវោច កថំ ភាវិតា នុ ខោ ភន្តេ អានាបានស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសាតិ ។

[១៣៨] យំ កិញ្ចិ រាហុល រូបំ[១] អជ្ឈត្តំ បច្ចត្តំ កក្ខលំ ខរិគតំ ឧបាទិន្នំ សេយ្យថីទំ កេសា លោមា នខា ទន្តា តចោ មំសំ ន្ហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ កក្ខលំ ខរគតំ ឧបាទិន្នំ អយំ វុច្ចតិ រាហុល អជ្ឈត្តិកា បឋវីធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា បឋវីធាតុ យា ច ពាហិរា បឋវីធាតុ បឋវីធាតុរេវេសា ។

១ ឱ. ម. រូបន្តិ ន បញ្ញាយតិ ។

ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចហើយដាក់អង្គគង់ ក្នុងទីសមគួរ ។ លុះព្រះរាហុលមានអាយុ គង់ក្នុងទីសមគួរហើយ ក៏បានទូលស្នើសេចក្តីនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ចុះអានាបានស្សតិត្រូវចម្រើនដោយប្រការដូចម្តេច ត្រូវបន្ទុំ ធ្វើឲ្យរឿយ ៗ ដោយប្រការដូចម្តេច ទើបជាគុណជាតិមានផលច្រើន មានអានិសង្សច្រើនបាន ។

[១៣៥] ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលរាហុល រូបណាមួយ ដែលជារូបខាងក្នុង អាស្រ័យនូវខ្លួន ជារូបគ្រោតគ្រាត ជារូបរឹង ជារូបដែលវិញ្ញាណកាន់កាប់ គឺសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ពុំនោះសោតរូបណាមួយ ក្រៅអំពីនេះ ដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជារូបគ្រោតគ្រាត ជារូបរឹង ជារូបដែលវិញ្ញាណកាន់កាប់ ម្នាលរាហុលនេះហៅថា បឋវីធាតុខាងក្នុង ។ មួយទៀត បឋវីធាតុណាខាងក្នុងក្តី បឋវីធាតុណាខាងក្រៅក្តី ធាតុទាំងនុ៎ះ ឈ្មោះថា បឋវីធាតុដូចគ្នា ។

តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា បឋវីធាតុយា និព្វិន្ទតិ បឋវីធាតុយា ចិត្តំ វិរាជេតិ ។

[១៣៦] កតមា ច រាហុល អាបោធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ច រាហុល អជ្ឈត្តិកា អាបោធាតុ យំ អជ្ឈត្តំ បច្ចត្តំ អាបោ អាបោគតំ ឧបាទិន្នំ សេយ្យថីទំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តំ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ អាបោ អាបោគតំ ឧបាទិន្នំ អយំ វុច្ចតិ រាហុល អជ្ឈត្តិកា អាបោធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា អាបោធាតុ

បុគ្គលគួរឃើញបឋវីធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិតយ៉ាង នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ លុះបុគ្គលឃើញបឋវីធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិត យ៉ាងនេះហើយ រមែងនឿយណាយ ចាកបឋវីធាតុ ធ្វើចិត្តឲ្យប្រាសចេញចាកបឋវីធាតុ ។

[១៣៦] ម្នាលរាហុល ចុះអាបោធាតុ តើដូចម្តេចខ្លះ អាបោ-ធាតុ (នោះ) ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល ចុះអាបោធាតុខាងក្នុងដូចម្តេច រូបណា ដែលជាខាងក្នុង អាស្រ័យនូវខ្លួន មានសភាពជាទឹក ដល់នូវភាពជាទឹក ដែលវិញ្ញាណចូលទៅកាន់យក គឺប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ពុំនោះសោត រូបណា-មួយក្រៅអំពីនេះ ដែលជាខាងក្នុង អាស្រ័យនូវខ្លួន មានសភាពជាទឹក ដល់នូវភាពជាទឹក ដែលវិញ្ញាណចូលទៅកាន់យក ម្នាលរាហុល នេះហៅថា អាបោធាតុខាងក្នុង ។ មួយវិញទៀត អាបោធាតុណា ជា

យា ច ពាហិរា អាបោធាតុ អាបោធាតុរេវេសា ។ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អាបោធាតុយា និព្វិន្ទតិ អាបោធាតុយា ចិត្តំ វិរាជេតិ ។

[១៣៧] កតមា ច រាហុល តេជោធាតុ តេជោធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ច រាហុល អជ្ឈត្តិកា តេជោធាតុ យំ អជ្ឈត្តំ បច្ចត្តំ តេជោ តេជោគតំ ឧបាទិន្នំ សេយ្យថីទំ យេន ច សន្តបតិ យេន ច ជីរតិ(១) យេន ច បរិឌយ្ហតិ(២) យេន ច អសិតំ បីតំ ខាយិតំ សាយិតំ(៣) សម្មា បរិណាមំ គច្ឆតិ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ តេជោ តេជោគតំ ឧបាទិន្នំ អយំ វុច្ចតិ រាហុល អជ្ឈត្តិកា តេជោធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា តេជោធាតុ យា ច ពាហិរា តេជោធាតុ តេជោធាតុរេវេសា ។

---

១ ឱ. ម. ជីរិយតិ ។ ២ ម. បរិទយ្ហតិ ។ ៣ ឱ. អសិតបីតខាយិតសាយតំ ។

ខាងក្នុងក្តី អាបោធាតុណាជាខាងក្រៅក្តី ធាតុទាំងនុ៎ះហៅថា អាបោ-ធាតុដូចគ្នា ។ បុគ្គលគួរឃើញអាបោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួន របស់អញឡើយ ។ លុះបុគ្គលឃើញអាបោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះហើយ រមែងនឿយណាយ ចាកអាបោធាតុ ធ្វើចិត្តឲ្យប្រាសចេញចាកអាបោធាតុ ។

[១៣៧] ម្នាលរាហុល ចុះតេជោធាតុតើដូចម្តេចខ្លះ តេជោធាតុ (នោះ) ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល ចុះតេជោធាតុ ខាងក្នុងដូចម្តេច រូបណាដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជារបស់ក្តៅ ដល់នូវភាពជារបស់ក្តៅ ដែលវិញ្ញាណចូលទៅកាន់យក គឺភ្លើងដែលធ្វើ កាយឲ្យផ្សព្វផ្សាយ ១ ភ្លើងដែលធ្វើកាយឲ្យទ្រុឌទ្រោម ១ ភ្លើងដែលធ្វើ កាយឲ្យក្តៅពេលរាល ១ ភ្លើងធ្វើអាហារដែលស៊ី ផឹក ទំពា លិទ្ធភ្លក្ស ហើយឲ្យទ្រុឌទ្រោមរលួយទៅដោយស្រួល ១ ពុំនោះសោត រូបណា-មួយក្រៅអំពីនេះ ដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជារបស់ក្តៅ ដល់នូវ ភាពជារបស់ក្តៅ ដែលវិញ្ញាណចូលទៅកាន់យក ម្នាលរាហុល នេះហៅ ថា តេជោធាតុខាងក្នុង ។ មួយវិញទៀត តេជោធាតុណាខាងក្នុងក្តី តេជោធាតុណាខាងក្រៅក្តី ធាតុទាំងនុ៎ះ ហៅថា តេជោធាតុដូចគ្នា ។

តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា តេជោធាតុយា និព្វិន្ទតិ តេជោធាតុយា ចិត្តំ វិរាជេតិ ។

[១៣៨] កតមា ច រាហុល វាយោធាតុ វា-យោធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ច រាហុល អជ្ឈត្តិកា វាយោធាតុ យំ អជ្ឈត្តំ បច្ចត្តំ វាយោ វាយោគតំ ឧបាទិន្នំ សេយ្យថីទំ ឧទ្ធង្គមា វាតា អធោគមា វាតា កុច្ឆិសយា វាតា កោដ្ឋសយា វាតា អង្គមង្គានុសារិនោ វាតា អស្សា-សោ បស្សាសោ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ វាយោ វាយោគតំ ឧបាទិន្នំ អយំ វុច្ចតិ រាហុល អជ្ឈត្តិកា វាយោធាតុ ។ យា ចេវ ខោ បន

បុគ្គលគួរឃើញ នូវតេជោធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ លុះបុគ្គលឃើញតេជោធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិត យ៉ាងនេះហើយ រមែងនឿយណាយចាកតេជោធាតុ ធ្វើចិត្តឲ្យប្រាសចេញចាកតេជោធាតុ ។

[១៣៨] ម្នាលរាហុល ចុះវាយោធាតុតើដូចម្តេចខ្លះ វាយោធាតុ (នោះ) ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល រូបណាដែលជាខាងក្នុង អាស្រ័យនូវខ្លួន មានសភាពជាខ្យល់ ដល់នូវភាពជាខ្យល់ ដែលវិញ្ញាណចូលទៅកាន់យក គឺខ្យល់បក់ឡើងទៅខាងលើ ១ ខ្យល់បក់ចុះមកខាងក្រោម ១ ខ្យល់បក់ក្នុងពោះក្រៅពោះវៀន ១ ខ្យល់បក់ក្នុងពោះវៀន ១ ខ្យល់បក់សព្វអវយវៈតូចធំ ១ ខ្យល់ដង្ហើមចេញចូល ១ ពុំនោះសោត រូបណាមួយក្រៅអំពីនេះ ដែលជាខាងក្នុង អាស្រ័យនូវខ្លួន មានសភាពជាខ្យល់ ដល់នូវភាពជាខ្យល់ ដែលវិញ្ញាណចូលទៅកាន់យក ម្នាលរាហុល នេះហៅថា វាយោធាតុខាងក្នុង ។ មួយទៀត វាយោ-

អជ្ឈត្តិកា វាយោធាតុ យា ច ពាហិរា វាយោធាតុ វាយោធាតុរេវេសា ។ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា វាយោធាតុយា និព្វិន្ទតិ វាយោធាតុយា ចិត្តំ វិរាជេតិ ។

[១៣៩] កតមា ច រាហុល អាកាសធាតុ អាកាសធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ច រាហុល អជ្ឈត្តិកា អាកាសធាតុ យំ អជ្ឈត្តំ បច្ចត្តំ អាកាសំ អាកាសគតំ ឧបាទិន្នំ សេយ្យថីទំ កណ្ណច្ឆិទ្ទំ នាសច្ឆិទ្ទំ មុខទ្វារំ យេន ច អសិតំ បីតំ ខាយិតំ សាយិតំ អជ្ឈោហរតិ យត្ថ ច អសិតំ បីតំ ខាយិតំ សាយិតំ សំតិដ្ឋតិ យេន ច អសិតំ បីតំ ខាយិតំ សាយិតំ អធោភាគា និក្ខមតិ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ អាកាសំ អាកាសគតំ អឃំ អឃគតំ

ធាតុណាជាខាងក្នុងក្តី វាយោធាតុណា ជាខាងក្រៅក្តី ធាតុទាំងនុ៎ះ ហៅថា វាយោធាតុដូចគ្នា ។ បុគ្គលគួរឃើញវាយោធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ លុះបុគ្គលឃើញវាយោធាតុនុ៎ះដោយប្រាជ្ញាល្អ តាមសេចក្តីពិតយ៉ាងនេះហើយ រមែងនឿយណាយចាកវាយោធាតុ ធ្វើចិត្តឲ្យប្រាសចេញចាកវាយោធាតុ ។

[១៣៩] ម្នាលរាហុល អាកាសធាតុ តើដូចម្តេចខ្លះ អាកាស-ធាតុ (នោះ) ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល អាកាសធាតុខាងក្នុង តើដូចម្តេច រូបណាជាខាងក្នុង អាស្រ័យនូវខ្លួន មានភាពជាទីវាល ដល់នូវភាពជាទីទំនេរ ដែលវិញ្ញាណចូលទៅកាន់យក គឺរន្ធត្រចៀក រន្ធច្រមុះ ទ្វារមាត់ដែលសម្រាប់លេបចូលនូវអាហារដែលស៊ី ផឹក ទំពា លិទ្ធភ្លក្សហើយដោយទ្វារណាក្តី ភោជនដែលស៊ី ផឹក ទំពា លិទ្ធភ្លក្សហើយ ឋិតនៅក្នុងទ្វារណាក្តី ភោជនដែលស៊ី ផឹក ទំពា លិទ្ធភ្លក្សហើយ តែងចេញមកតាមចំណែកខាងក្រោម ដោយទ្វារណាក្តី ពុំនោះសោត រូបណាមួយក្រៅអំពីនេះ ដែលជាខាងក្នុង អាស្រ័យនូវខ្លួន មានភាពជាទីវាល ដល់នូវភាពជាទីទំនេរ ជាទីទទេ ដល់នូវភាពទទេ

វិវរំ វិវរគតំ អសម្ផុដ្ឋំ មំសលោហិតេហិ[១] ឧបាទិន្នំ អយំ វុច្ចតិ រាហុល អជ្ឈត្តិកា អាកាសធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា អាកាសធាតុ យា ច ពាហិរា អាកាសធាតុ អាកាសធាតុរេវេសា ។ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អាកាសធាតុយា និព្វិន្ទតិ អាកាសធាតុយា ចិត្តំ វិរាជេតិ ។

[១៤០] បឋវីសមំ រាហុល ភាវនំ ភាវេហិ បឋវីសមញ្ហិ[២] តេ រាហុល ភាវនំ ភាវយតោ ឧប្បន្នា មនាបាមនាបា ផស្សា ចិត្តំ ន បរិយាទាយ ឋស្សន្តិ ។ សេយ្យថាបិ រាហុល បឋវិយា សុចិម្បិ និក្ខិបន្តិ អសុចិម្បិ និក្ខិបន្តិ គូថគតម្បិ និក្ខិបន្តិ មុត្តគតម្បិ និក្ខិបន្តិ ខេឡគតម្បិ និក្ខិបន្តិ បុព្វគតម្បិ និក្ខិបន្តិ លោហិតគតម្បិ និក្ខិបន្តិ

១ ឱ. អយំ អយគតំ វិវរំ វិវរគតំ អសម្ផុដ្ឋំ មំសលោហិតេហីតិ ន ទិស្សតិ ។ ២ ឱ. ម. បឋវីសមំ ហិ ។

ជាចន្លោះ ដល់នូវទីជាចន្លោះ ដែលសាច់និងឈាម មិនប៉ះពាល់គ្នា ដែលវិញ្ញាណចូលទៅកាន់យក ម្នាលរាហុល នេះហៅថា អាកាសធាតុខាងក្នុង ។ មួយទៀត អាកាសធាតុណាជាខាងក្នុងក្តី អាកាសធាតុណាជាខាងក្រៅក្តី ធាតុទាំងនុ៎ះ ហៅថា អាកាសធាតុដូចគ្នា ។ បុគ្គលគួរឃើញអាកាសធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ លុះបុគ្គលឃើញអាកាសធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិតយ៉ាងនេះហើយ រមែងនឿយណាយចាកអាកាសធាតុ ធ្វើចិត្តឲ្យប្រាសចេញចាកអាកាសធាតុ ។

[១៤០] ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាផែនដី ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនា ឲ្យដូចជាផែនដីហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់នូវចិត្តអ្នក ។ ម្នាលរាហុល ជនទាំងឡាយដាក់វត្ថុស្អាតក្តី ដាក់វត្ថុមិនស្អាតក្តី ដាក់ចុះនូវគូថក្តី ដាក់ចុះនូវទឹកមូត្រក្តី ដាក់ចុះនូវទឹកមាត់ក្តី ដាក់ចុះនូវខ្ទុះក្តី សម្រក់ឈាមដាក់ក្តី លើផែនដី ផែន

ន ច តេន បឋវី អដ្ដីយតិ វា ហរាយតិ វា ជិគុច្ឆតិ វា ឯវមេវ ខោ ត្វំ រាហុល បឋវីសមំ ភាវនំ ភាវេហិ បឋវីសមញ្ហិ តេ រាហុល ភាវនំ ភាវយតោ ឧប្បន្នា មនាបាមនាបា ផស្សា ចិត្តំ ន បរិយាទាយ ឋស្សន្តិ ។

[១៤១] អាបោសមំ រាហុល ភាវនំ ភាវេហិ អាបោសមញ្ហិ តេ រាហុល ភាវនំ ភាវយតោ ឧប្បន្នា មនាបាមនាបា ផស្សា ចិត្តំ ន បរិយាទាយ ឋស្សន្តិ ។ សេយ្យថាបិ រាហុល អាបស្មឹ សុចិម្បិ ធោវន្តិ អសុចិម្បិ ធោវន្តិ គូថគតម្បិ ធោវន្តិ មុត្តគតម្បិ ធោវន្តិ ខេឡគតម្បិ ធោវន្តិ បុព្វគតម្បិ ធោវន្តិ លោហិតគតម្បិ ធោវន្តិ ន ច តេន អាបោ អដ្ដីយតិ វា ហរាយតិ ជិគុច្ឆតិ វា ឯវមេវ ខោ ត្វំ រាហុល អាបោសមំ ភាវនំ ភាវេហិ អាបោសមញ្ហិ តេ រាហុល ភាវនំ ភាវយតោ ឧប្បន្នា មនាបាមនាបា ផស្សា ចិត្តំ ន បរិយាទាយ ឋស្សន្តិ ។

ដីក៏មិនធ្មើយណាយ ឬធុញទ្រាន់ ឬខ្ពើមរអើមដោយវត្ថុទាំងនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាផែនដី យ៉ាងនោះឯង ព្រោះថា កាលបើអ្នកចម្រើនភាវនា ឲ្យដូចជាផែនដីហើយ ផស្សជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្តដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

[១៤១] ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាទឹក ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនា ឲ្យដូចជាទឹកហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្តដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។ ម្នាលរាហុល ជនទាំងឡាយ លាងវត្ថុស្អាតក្តី លាងវត្ថុមិនស្អាតក្តី លាងគូថក្តី លាងទឹកមូត្រក្តី លាងទឹកមាត់ក្តី លាងខ្ទុះក្តី លាងឈាមក្តី ក្នុងទឹក ទឹកក៏មិនបានធ្មើយណាយ ឬធុញទ្រាន់ឬខ្ពើមរអើមដោយវត្ថុទាំងនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាទឹក យ៉ាងនោះឯង ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាទឹកហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្តដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

[១៤២] តេជោសមំ រាហុល ភាវនំ ភាវេហិ តេជោសមញ្ហិ តេ រាហុល ភាវនំ ភាវយតោ ឧប្បន្នា មនាបាមនាបា ផស្សា ចិត្តំ ន បរិយាទាយ ឋស្សន្តិ ។ សេយ្យថាបិ រាហុល តេជោ សុចិម្បិ ឌហតិ អសុចិម្បិ ឌហតិ គូថគតម្បិ ឌហតិ មុត្តគតម្បិ ឌហតិ ខេឡ-គតម្បិ ឌហតិ បុព្វគតម្បិ ឌហតិ លោហិតគតម្បិ ឌហតិ ន ច តេន តេជោ អដ្ដិយតិ វា ហរាយតិ វា ជិគុច្ឆតិ វា ឯវមេវ ខោ ត្វំ រាហុល តេជោសមំ ភាវនំ ភាវេហិ តេជោសមញ្ហិ តេ រាហុល ភាវនំ ភាវយតោ ឧប្បន្នា មនាបាមនាបា ផស្សា ចិត្តំ ន បរិយាទាយ ឋស្សន្តិ ។

[១៤៣] វាយោសមំ រាហុល ភាវនំ ភាវេហិ វាយោសមញ្ហិ តេ រាហុល ភាវនំ ភាវយតោ ឧប្បន្នា មនាបាមនាបា ផស្សា ចិត្តំ ន បរិយាទាយ ឋស្សន្តិ ។

[១៤២] ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាភ្លើង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាភ្លើងហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្តដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។ ម្នាលរាហុល ភ្លើងឆេះវត្ថុស្អាតក្តី ឆេះវត្ថុមិនស្អាតក្តី ឆេះគូថក្តី ឆេះទឹកមូត្រក្តី ឆេះទឹកមាត់ក្តី ឆេះខ្ទុះក្តី ឆេះឈាមក្តី ភ្លើងក៏មិនធឿយណាយ ឬធុញទ្រាន់ ឬខ្ពើមរអើមដោយវត្ថុទាំងនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាភ្លើង យ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាភ្លើងហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្តដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

[១៤៣] ម្នាលរាហុល អ្នកចូរចម្រើនភាវនា ឲ្យដូចជាខ្យល់ ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាខ្យល់ហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។

សេយ្យថាបិ រាហុល វាយោ សុចិម្បិ ឧបវាយតិ អសុចិម្បិ ឧបវាយតិ គូថគតម្បិ ឧបវាយតិ មុត្តគតម្បិ ឧបវាយតិ ខេឡគតម្បិ ឧបវាយតិ បុព្វគតម្បិ ឧបវាយតិ លោហិតគតម្បិ ឧបវាយតិ ន ច តេន វាយោ អដ្ដីយតិ វា ហរាយតិ វា ជិគុច្ឆតិ វា ឯវមេវ ខោ ត្វំ រាហុល វាយោសមំ ភាវនំ ភាវេហិ វាយោសមញ្ហិ តេ រាហុល ភាវនំ ភាវយតោ ឧប្បន្នា មនាបាមនាបា ផស្សា ចិត្តំ ន បរិយាទាយ ឋស្សន្តិ ។

[១៤៤] អាកាសសមំ រាហុល ភាវនំ ភាវេហិ អាកាសសមញ្ហិ តេ រាហុល ភាវនំ ភាវយតោ ឧប្បន្នា មនាបាមនាបា ផស្សា ចិត្តំ ន បរិយាទាយ ឋស្សន្តិ ។ សេយ្យថាបិ រាហុល អាកាសោ ន កត្ថចិ បតិដ្ឋិតោ ឯវមេវ ខោ ត្វំ រាហុល អាកាសសមំ ភាវនំ ភាវេហិ អាកាសសមញ្ហិ តេ រាហុល ភាវនំ ភាវយតោ ឧប្បន្នា មនាបាមនាបា ផស្សា ចិត្តំ ន បរិយាទាយ ឋស្សន្តិ ។

ម្នាលរាហុល ខ្យល់បក់វត្ថុស្អាតក្តី បក់វត្ថុមិនស្អាតក្តី បក់គូថក្តី បក់ទឹកមូត្រក្តី បក់ទឹកមាត់ក្តី បក់ខ្ទុះក្តី បក់ឈាមក្តី ខ្យល់ក៏មិននឿយណាយ ឬធុញទ្រាន់ ឬខ្ពើមរអើម ដោយវត្ថុនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាខ្យល់ យ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាខ្យល់ហើយ ផស្សៈជាទីគាប់ចិត្តឬមិនជាទីគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

[១៤៤] ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាអាកាស ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាអាកាសហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។ ម្នាលរាហុល អាកាសដែលមិនប្រតិស្ឋាននៅក្នុងទីណាមួយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាអាកាសយ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាអាកាសហើយ ផស្សៈជាទីគាប់ចិត្តឬមិនជាទីគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

[១៤៨] មេត្តំ រាហុល ភាវនំ ភាវេហិ មេត្តញ្ហិ[១] តេ រាហុល ភាវនំ ភាវយតោ យោ ព្យាបាទោ សោ បហិយិស្សតិ ។ ករុណំ រាហុល ភាវនំ ភាវេហិ ករុណាញ្ហិ តេ រាហុល ភាវនំ ភាវយតោ យា វិហេសា សា បហិយិស្សតិ ។ មុទិតំ រាហុល ភាវនំ ភាវេហិ មុទិតញ្ហិ តេ រាហុល ភាវនំ ភាវយតោ យា អរតិ សា បហិយិស្សតិ ។ ឧបេក្ខំ រាហុល ភាវនំ ភាវេហិ ឧបេក្ខញ្ហិ តេ រាហុល ភាវនំ ភាវយតោ យោ បដិឃោ សោ បហិយិស្សតិ ។ អសុភំ រាហុល ភាវនំ ភាវេហិ អសុភញ្ហិ តេ រាហុល ភាវនំ ភាវយតោ យោ រាគោ សោ បហិយិស្សតិ ។ អនិច្ចសញ្ញំ រាហុល ភាវនំ ភាវេហិ អនិច្ចសញ្ញញ្ហិ តេ រាហុល ភាវនំ ភាវយតោ យោ អស្មិមានោ សោ បហិយិស្សតិ ។

១ ឱ. ម. មេត្តំ ហិ ។

[១៤៥] ម្នាលរាហុល អ្នកចូរចម្រើនមេត្តាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនមេត្តាភាវនាហើយ ព្យាបាទនឹងវិនាសសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនករុណាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនករុណាភាវនាហើយ វិហេសាគឺសេចក្តីបៀតបៀន នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនមុទិតាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនមុទិតាភាវនាហើយ អរតិ គឺសេចក្តីមិនត្រេកអរ នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនឧបេក្ខាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនឧបេក្ខាភាវនាហើយ បដិឃៈគឺសេចក្តីថ្នាំងថ្នាក់ចិត្ត នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនអសុភភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនអសុភភាវនាហើយ រាគៈគឺតម្រេកក្នុងកាមគុណ នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនអនិច្ចសញ្ញាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនអនិច្ចសញ្ញាភាវនាហើយ អស្មិមានះគឺសេចក្តីប្រកាន់ខ្លួន នឹងសាបសូន្យទៅ ។

[១៤៦] អានាបានស្សតឹ រាហុល ភាវនំ ភាវេហិ អានាបានស្សតិ រាហុល ភាវិតា ពហុលីកតា មហប្ផ-លា ហោតិ មហានិសំសា ។ កថំ ភាវិតា ច រាហុល អានាបានស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ ឥធ រាហុល ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋ-បេត្វា សោ សតោវ អស្សសតិ សតោ បស្សសតិ ។ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ ។ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ ។ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។

[១៤៦] ម្នាលរាហុល អ្នកចូរចម្រើនអានាបានស្សតិភាវនា ម្នាលរាហុល អានាបានស្សតិភាវនា ដែលអ្នកបានចម្រើនហើយ បានធ្វើឲ្យរឿយ ៗ ហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលរាហុល ចុះអានាបានស្សតិភាវនា ដែលចម្រើនហើយ តើដូចម្តេច ដែលធ្វើឲ្យរឿយ ៗ ហើយ តើដូចម្តេច ទើបជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលរាហុល ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយផ្គត់ភ្នែនតាំងកាយឲ្យត្រង់ តម្កល់ស្មារតីឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ភិក្ខុនោះ មានស្មារតីចាំជាក់ដកដង្ហើមចេញ មានស្មារតីចាំជាក់ដកដង្ហើមចូល ។ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ឬកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី ។ ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយគឺដកដង្ហើមទាំងពួង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយ គឺដកដង្ហើមទាំងពួង ហើយដកដង្ហើមចូល

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។ សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ

សិក្សាថា អាត្មាអញ នឹងរម្ងាប់កាយសង្ខារ គឺដង្ហើមចេញ និងដង្ហើមចូល ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងរម្ងាប់នូវកាយសង្ខារ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវសេចក្តីសុខ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវសេចក្តីសុខ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្តសង្ខារ គឺវេទនាខន្ធនិងសញ្ញាខន្ធ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្តសង្ខារ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងរម្ងាប់នូវចិត្តសង្ខារ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងរម្ងាប់នូវចិត្តសង្ខារ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្ត ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្ត ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងធ្វើចិត្តឲ្យរីករាយ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងធ្វើចិត្តឲ្យរីករាយ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងតម្កល់ចិត្តឲ្យស្មើ ហើយដកដង្ហើមចេញ

វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។ អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ ឯវំ ភាវិតា ខោ រាហុល អានាបានស្សតិ ឯវំ ពហុលីកតា

សិក្សាថា អាត្មាអញ នឹងតម្កល់ចិត្តឲ្យស្មើ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងដោះចិត្តឲ្យផុតស្រឡះ (ចាកនីវរណៈជាដើម) ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងដោះចិត្តឲ្យផុតស្រឡះ (ចាកនីវរណធម៌ជាដើម) ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណា (នូវបញ្ចក្ខន្ធថា) មិនទៀង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងពិចារណា (នូវបញ្ចក្ខន្ធថា) មិនទៀង ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណាធម៌ជាគ្រឿងធ្វើចិត្ត ឲ្យប្រាសចាកតម្រេក គឺវិបស្សនានិងមគ្គ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងពិចារណាធម៌ជាគ្រឿងធ្វើចិត្ត ឲ្យប្រាសចាកតម្រេកហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណានូវសេចក្តីរលត់ (នៃកងទុក្ខ) ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងពិចារ-ណានូវសេចក្តីរលត់ (នៃកងទុក្ខ) ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណាធម៌ជាគ្រឿងធ្វើចិត្ត ឲ្យលះបោល (នូវកិលេសព្រមទាំងខន្ធនិងអភិសង្ខារ) ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងពិចារណាធម៌ជាគ្រឿងធ្វើចិត្ត ឲ្យលះបោល (នូវកិលេសព្រមទាំងខន្ធនិងអភិសង្ខារ) ហើយដកដង្ហើមចូល ។ ម្នាលរាហុល អានាបានស្សតិដែលបុគ្គលបានចម្រើនហើយយ៉ាងនេះ ធ្វើឲ្យរឿយ ៗ ហើយយ៉ាងនេះឯង

មហប្ផលា ហោតិ មហានិសំសា ។ ឯវំ ភាវិតាយ ខោ រាហុល អានាបានស្សតិយា ឯវំ ពហុលីកតាយ យេបិ តេ ចរិមកា អស្សាសប្បស្សាសា តេបិ វិទិតាវ និរុជ្ឈន្តិ នោ អវិទិតាតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា រាហុលោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

មហារាហុលោវាទសុត្តំ ទុតិយំ និដ្ឋិតំ ។

ទើបជាគុណជាតិ មានផលច្រើន មានអានិសង្សច្រើន ម្នាលរាហុល កាលបើអានាបានស្សតិ ដែលបុគ្គលចម្រើនហើយយ៉ាងនេះ ធ្វើឲ្យរឿយ ៗ ហើយយ៉ាងនេះ ដង្ហើមចេញនិងដង្ហើមចូលទាំងឡាយណា ដែលមាន ក្នុងកាលជាខាងក្រោយ ដង្ហើមចេញនិងដង្ហើមចូលទាំងនោះ នឹងរលត់ទៅវិញជាប្រាកដ មិនមែនមិនរលត់ទៅវិញទេ ។ លុះព្រះមានព្រះភាគ សំដែងព្រះសូត្រនេះចប់ហើយ ព្រះរាហុលមានអាយុ ក៏មានចិត្តរីករាយ ត្រេកអរ ចំពោះភាសិត នៃព្រះមានព្រះភាគ ។

ចប់ មហារាហុលោវាទសូត្រ ទី ២ ។

# តតិយំ ចូឡមាលុង្ក្យោវាទសុត្តំ

[១៤៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មតោ មាលុង្ក្យបុត្តស្ស[១] រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យានិមានិ ទិដ្ឋិគតានិ ភគវតា អព្យាកតានិ ឋបិតានិ បដិក្ខិត្តានិ សស្សតោ លោកោតិបិ[២] អសស្សតោ លោកោតិបិ[៣] អន្តវា លោកោតិបិ[៤] អនន្តវា លោកោតិបិ[៥] តំ ជីវំ តំ សរីរន្តិបិ[៦] អញ្ញំ ជីវំ អញ្ញំ សរីរន្តិបិ[៧] ហោតិ តថាគតោ បរម្មរណាតិបិ ន ហោតិ តថាគតោ បរម្មរណាតិបិ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិបិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិបិ តានិ មេ ភគវា ន ព្យាករោតិ យានិ មេ ភគវា ន ព្យាករោតិ តម្មេ ន រុច្ចតិ

---

១ ឱ. មាលុង្ក្យាបុត្តស្ស ។ ម. មាលុក្យបុត្តស្ស ។ ២-៣-៤-៥ ឱ. លោកោ ឥតិបិ ។ ៦-៧ ឱ. សរីរំ ឥតិបិ ។

# ចូឡមាលុង្ក្យោវាទសូត្រ ទី ៣

[១៤៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមាលុង្ក្យបុត្រមានអាយុ ចូលទៅសម្ងំនៅក្នុងទីរហោស្ថាន ក៏មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ទិដ្ឋិទាំង-ឡាយណាថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែនមិនកើតទៀតក៏មិនមែនដូច្នេះក្តី ព្រះមានព្រះភាគ មិនបានសំដែង គ្រាន់តែតម្កល់ទុកតែទ្រង់ហាមឃាត់ ព្រះមានព្រះភាគ មិនបានសំដែងទិដ្ឋិទាំងនោះដល់អញទេ ព្រះមានព្រះភាគ មិនបានសំដែងទិដ្ឋិទាំងឡាយណាដល់អញ ដំណើរដែលមិនបានសំដែងទិដ្ឋិនោះ មិនគាប់ចិត្តអញទេ

តម្ហេ ឯកច្ចមតិ សោហំ ភគវន្តំ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆិស្សាមិ សចេ មេ ភគវា ព្យាករិស្សតិ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា ឯវាហំ ភគវតិ ព្រហ្មចរិយំ ចរិស្សាមិ នោ ចេ[១] ភគវា ព្យាករិស្សតិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា ឯវាហំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ ។

[១៤៨] អថខោ អាយស្មា មាលុង្ក្យបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

១ ឱ. ម. ចេ មេ ។

ដំណើរដែលមិនបានសំដែងទិដ្ឋិនោះ មិនបានពេញចិត្តអញឡើយ អញឯងនឹងចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរដំណើរនុ៎ះ ប្រសិនបើព្រះមានព្រះភាគ នឹងសំដែងប្រាប់អញថា លោកទៀងដូច្នេះក្តី ។ បេ ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី កាលបើយ៉ាងនេះ អាត្មាអញ នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ តែប្រសិនបើព្រះមានព្រះភាគ មិនបានសំដែងថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃ សរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី កាលបើយ៉ាងនេះ អាត្មាអញ នឹងលះបង់សិក្ខាហើយត្រឡប់មកកាន់ហីនភេទវិញ ។

[១៤៨] គ្រានោះឯង ព្រះមាលុង្ក្យបុត្រមានអាយុ ក្រោកចេញអំពីសំណឹង ក្នុងវេលាសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មាលុង្ក្យបុត្តោ ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យានិមានិ ទិដ្ឋិគតានិ ភគវតា អព្យាកតានិ ឋបិតានិ បដិក្ខិត្តានិ សស្សតោ លោកោតិបិ អសស្សតោ លោកោតិបិ អន្តវា លោកោតិបិ អនន្តវា លោកោតិបិ តំ ជីវំ តំ សរីរន្តិបិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិបិ ហោតិ តថាគតោ បរម្មរណាតិបិ ន ហោតិ តថាគតោ បរម្មរណាតិបិ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិបិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិបិ តានិ មេ ភគវា ន ព្យាករោតិ យានិ មេ ភគវា ន ព្យាករោតិ តម្មេ ន រុច្ចតិ តម្មេ នក្ខមតិ សោហំ ភគវន្តំ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆិស្សាមិ សចេ[១] ភគវា

១ ឱ. ម. សចេ មេ ។

ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះមាលុង្ក្យបុត្រមានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូល នូវដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ ខ្ញុំព្រះអង្គចូលទៅសម្ងំនៅក្នុងទីរហោស្ថាន ក៏មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ទិដ្ឋិទាំងឡាយណាថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះ ក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយ មិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយ កើតទៀតក៏មានមិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ព្រះមានព្រះភាគ មិនបានសំដែង គ្រាន់តែតម្កល់ទុក តែទ្រង់ឃាត់ហាម ព្រះមានព្រះភាគ មិនទាន់សំដែងទិដ្ឋិទាំងនោះ ប្រាប់អាត្មាអញនៅឡើយ ព្រះមានព្រះភាគ មិនបានសំដែងនូវទិដ្ឋិទាំងឡាយណា ដល់អាត្មាអញ ដំណើរដែលមិនបានសំដែងទិដ្ឋិនោះ មិនគាប់ចិត្តដល់អាត្មាអញទេ ដំណើរដែលមិនបានសំដែងទិដ្ឋិនោះ មិនពេញចិត្តដល់អាត្មាអញឡើយ អាត្មាអញ នឹងចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលសួរ នូវដំណើរនុ៎ះ បើព្រះមានព្រះភាគ

ព្យាករិស្សតិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា ឯវាហំ ភគវតិ ព្រហ្មចរិយំ ចរិស្សាមិ នោ ចេ មេ ភគវា ព្យាករិស្សតិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា ឯវាហំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ ។ សចេ ភគវា ជានាតិ សស្សតោ លោកោតិ សស្សតោ លោកោតិ មេ ភគវា ព្យាករោតុ សចេ ភគវា ជានាតិ អសស្សតោ លោកោតិ អសស្សតោ លោកោតិ មេ ភគវា ព្យាករោតុ នោ ចេ ភគវា ជានាតិ

សំដែងប្រាប់អាត្មាអញថា លោកទៀងក្តី ថា លោកមិនទៀងក្តី ថា លោកមានទីបំផុតក្តី ថា លោកមិនមានទីបំផុតក្តី ថា ជីវិតនោះក៏គឺសរីរៈនោះក្តី ថាជីវិតដទៃសរីរៈក៏ដទៃក្តី ថា សត្វស្លាប់ហើយកើតទៀតក្តី ថា សត្វស្លាប់ហើយមិនកើតទៀតក្តី ថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានក្តី ថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី កាលបើយ៉ាងនេះ ទើបអាត្មាអញ នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំ-ណាក់នៃព្រះមានព្រះភាគ បើព្រះមានព្រះភាគ មិនសំដែងថា លោកទៀងក្តី ថា លោកមិនទៀងក្តី ។ បេ ។ ថាសត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី កាលបើយ៉ាងនេះ អាត្មាអញនឹងលាសិក្ខាហើយត្រឡប់មកកាន់ហីនភេទវិញ ។ បើព្រះមានព្រះភាគទ្រង់ជ្រាបថា លោកទៀងដូច្នេះហើយ សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀងដូច្នេះ ឲ្យទាន បើព្រះមានព្រះភាគ ទ្រង់ជ្រាបថា លោកមិនទៀង សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកមិនទៀងដូច្នេះ ឲ្យទាន បើព្រះមានព្រះភាគ មិនជ្រាបថា

សស្សតោ លោកោតិ វា អស្សស្សតោ លោកោតិ វា អជានតោ ខោ បន អបស្សតោ ឯតទេវ ឧជុកំ ហោតិ យទិទំ ន ជានាមិ ន បស្សាមីតិ ។ សចេ ភគវា ជានាតិ អន្តវា លោកោតិ អន្តវា លោកោតិ មេ ភគវា ព្យាករោតុ សចេ ភគវា ជានាតិ អនន្តវា លោកោតិ អនន្តវា លោកោតិ មេ ភគវា ព្យាករោតុ នោ ចេ ភគវា ជានាតិ អន្តវា លោកោតិ វា អនន្តវា លោកោតិ វា អជានតោ ខោ បន អបស្សតោ ឯតទេវ ឧជុកំ ហោតិ យទិទំ ន ជានាមិ ន បស្សាមីតិ ។ សចេ ភគវា ជានាតិ តំ ជីវំ តំ សរីរន្តិ តំ ជីវំ តំ សរីរន្តិ មេ ភគវា ព្យាករោតុ សចេ ភគវា ជានាតិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ មេ ភគវា ព្យាករោតុ នោ ច ភគវា ជានាតិ តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា អជានតោ ខោ បន អបស្សតោ ឯតទេវ ឧជុកំ ហោតិ យទិទំ ន ជានាមិ

លោកទៀងក្តី ថា លោកមិនទៀងក្តី កាលបើព្រះមានព្រះភាគ មិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្មានឹងខ្ញុំព្រះអង្គដែលមិនដឹងមិនឃើញដែរ ។ បើព្រះមានព្រះភាគ ជ្រាបថា លោកមានទីបំផុត សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកមានទីបំផុតដូច្នេះ ឲ្យទាន បើព្រះមានព្រះភាគ ជ្រាបថា លោកមិនមានទីបំផុត សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកមិនមានទីបំផុតដូច្នេះ ឲ្យទាន បើព្រះមានព្រះភាគ មិនជ្រាបថា លោកមានទីបំផុតក្តី ថា លោកមិនមានទីបំផុតក្តី កាលបើព្រះមានព្រះភាគ មិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្មានឹងខ្ញុំព្រះអង្គដែលមិនដឹង មិនឃើញដែរ ។ បើព្រះមានព្រះភាគ ជ្រាបថា ជីវិតនោះក៏គឺសរីរៈនោះ សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា ជីវិតនោះក៏គឺសរីរៈនោះដូច្នេះ ឲ្យទាន បើព្រះមានព្រះភាគ ជ្រាបថា ជីវិតដទៃសរីរៈក៏ដទៃ សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា ជីវិតដទៃសរីរៈក៏ដទៃដូច្នេះ ឲ្យទាន បើព្រះមានព្រះភាគ មិនជ្រាបថា ជីវិតនោះក៏គឺសរីរៈនោះក្តី ថា ជីវិតដទៃសរីរៈក៏ដទៃក្តី កាលបើព្រះមានព្រះភាគ មិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្មានឹងខ្ញុំព្រះអង្គដែលមិនដឹង

ន បស្សាមីតិ ។ សចេ ភគវា ជានាតិ ហោតិ តថាគតោ បរម្មរណាតិ ហោតិ តថាគតោ បរម្មរណាតិ មេ ភគវា ព្យាករោតុ សចេ ភគវា ជានាតិ ន ហោតិ តថាគតោ បរម្មរណាតិ ន ហោតិ តថាគតោ បរម្មរណាតិ មេ ភគវា ព្យាករោតុ នោ ចេ ភគវា ជានាតិ ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា អជានតោ ខោ បន អបស្សតោ ឯតទេវ ឧជុកំ ហោតិ យទិទំ ន ជានាមិ ន បស្សាមីតិ ។ សចេ ភគវា ជានាតិ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ មេ ភគវា ព្យាករោតុ សចេ ភគវា ជានាតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ មេ ភគវា ព្យាករោតុ នោ ចេ ភគវា ជានាតិ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា

មិនឃើញដែរ ។ បើព្រះមានព្រះភាគ ជ្រាបថា សត្វស្លាប់ហើយកើតទៀត សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយកើតទៀតដូច្នេះ ឲ្យទាន បើព្រះមានព្រះភាគ ជ្រាបថា សត្វស្លាប់ហើយមិនកើតទៀត សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយ មិនកើតទៀតដូច្នេះ ឲ្យទាន បើព្រះមានព្រះភាគមិនជ្រាបថា សត្វស្លាប់ហើយកើតទៀតក្តី ថា សត្វស្លាប់ហើយមិនកើតទៀតក្តី កាលបើព្រះមានព្រះភាគ មិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្មានទីផងខ្ញុំព្រះអង្គ ដែលមិនដឹង មិនឃើញដែរ ។ បើព្រះមានព្រះភាគ ជ្រាបថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះ ឲ្យទាន បើព្រះមានព្រះភាគ ជ្រាបថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន សូមព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះ ឲ្យទាន បើព្រះមានព្រះភាគ មិនជ្រាបថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានក្តី ថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី

អញាតោ ខោ បន អបស្សតោ ឯតទេវ ឧជុកំ ហោតិ យទិទំ ន ជានាមិ ន បស្សាមីតិ ។

[១៤៩] កិន្នុ ខោ តាហំ[១] មាលុង្ក្យបុត្ត ឯវំ អវចំ ឯហិ ត្វំ មាលុង្ក្យបុត្ត មយិ ព្រហ្មចរិយំ ចរ អហន្តេ ព្យាករិស្សាមិ សស្សតោ លោកោតិ វា អស្សស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ ។ នោ ហេតំ ភន្តេ ។ ត្វំ វា បន មំ ឯវំ អវច អហំ ភន្តេ ភគវតិ ព្រហ្មចរិយំ ចរិស្សាមិ ភគវា មេ ព្យាករិស្សតិ សស្សតោ លោកោតិ វា អស្សស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា

១ ឱ. កិន្នុ តាហំ ។ ម. កឹ នុ ខោ សាហំ ។

កាលបើព្រះមានព្រះភាគ មិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្នានឹងខ្ញុំព្រះអង្គដែលមិនដឹង មិនឃើញដែរ ។

[១៤៩] ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលមាលុង្ក្យបុត្រ ចុះតថាគត បាននិយាយនឹងអ្នកយ៉ាងនេះថា ម្នាលមាលុង្ក្យបុត្រ អ្នកចូរមកអាយ អ្នកចូរប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគតចុះ តថាគតនឹងសំដែងប្រាប់អ្នកថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ឬអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ចុះអ្នកបាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគ ឲ្យតែព្រះមានព្រះភាគ នឹងសំដែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី

អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ ។ នោ ហេតំ ភន្តេ ។ ឥតិ កិរ មាលុង្ក្យបុត្ត នេវាហាន្តំ វទាមិ ឯហិ ត្វំ មាលុង្ក្យបុត្ត មយិ ព្រហ្មចរិយំ ចរ អហាន្តេ ព្យាករិស្សាមិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ នបិ កិរ ត្វំ វទេសិ អហំ ភន្តេ ភគវតិ ព្រហ្មចរិយំ ចរិស្សាមិ ភគវា មេ ព្យាករិស្សតិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ ឯវំ សន្តេ មោឃបុរិស កោ សន្តោ កំ បច្ចាចិក្ខសិ ។

ជីវិតដទៃសរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ឬអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលមាលុង្ក្យបុត្រ បានឮថា តថាគត មិនបាននិយាយនឹងអ្នកថា ម្នាលមាលុង្ក្យបុត្រ អ្នកចូរមកអាយ ចូរអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគតចុះ តថាគត នឹងសំដែងប្រាប់អ្នកថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី ។ បេ ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ទាំងបានឮថា អ្នកក៏មិនបាននិយាយថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគ ឲ្យតែព្រះមានព្រះភាគ សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី ។ បេ ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ម្នាលមោឃបុរស កាលបើហេតុយ៉ាងនេះទេ ចុះអ្នកជាអ្នក ជាទុក្ខ ប្រាប់អ្នកណា ។

[១៩០] យោ ខោ មាលុង្ក្យបុត្ត ឯវំ វទេយ្យ ន តាវាហំ ភគវតិ ព្រហ្មចរិយំ ចរិស្សាមិ យាវ មេ ភគវា ន ព្យាករិស្សតិ សស្សតោ លោកោតិ វា អស្សស្សតោ លោកោតិ វា ។ បេ ។ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ អព្យាកតមេវ តំ មាលុង្ក្យបុត្ត តថាគតេន អស្ស អថខោ[១] សោ បុគ្គលោ កាលំ ករេយ្យ ។ សេយ្យថាបិ មាលុង្ក្យបុត្ត បុរិសោ សល្លេន វិទ្ធោ អស្ស សវិសេន គាឡ្ហូបលេ-បនេន តស្ស មិត្តាមច្ចា ញាតិសាលោហិតា ភិសក្កំ សល្លកត្តំ ឧបដ្ឋបេយ្យុំ ។ សោ ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ បុរិសំ ជានាមិ យេនម្ហិ វិទ្ធោ ខត្តិយោ វា ព្រាហ្មណោ វា វេស្សោ វា សុទ្ទោ វាតិ ។ សោ ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ បុរិសំ ជានាមិ យេនម្ហិ វិទ្ធោ ឯវំនាមោ ឯវំគោត្តោ ឥតិ វាតិ ។ សោ

១ ឱ. ម. សោសទ្ធោ នត្ថិ ។

[១៥០] ម្នាលមាលុង្ក្យបុត្រ បុគ្គលណា និយាយ យ៉ាងនេះថា ខ្ញុំមិនទាន់ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគទេ ព្រោះព្រះមានព្រះភាគ មិនទាន់សំដែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី ។ បេ ។ សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ម្នាលមាលុង្ក្យបុត្រ តថាគតនឹងសំដែងនូវដំណើរនោះឲ្យស្តាប់មិនទាន់ទេ បុគ្គលនោះមុខជានឹងធ្វើមរណៈកាលទៅ (មុនសំដែង) ដោយពិត ។ ម្នាលមាលុង្ក្យបុត្រ ដូចជាបុរសមុតព្រួញ (របស់សេនានៃស្តេចដទៃ) ដែលលាបប្រឡាក់ដោយថ្នាំពិសដ៏ក្រាស់ មិត្តអាមាត្យញាតិនិងសាលោហិតរបស់បុរសនោះ ក៏ចូលទៅរកពេទ្យជាអ្នកវះ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ជាក្សត្រ ឬព្រាហ្មណ៍ ឬវេស្សៈ ឬសុទ្ទៈ នៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះថាមាននាមយ៉ាងនេះ ឬមានគោត្រយ៉ាងនេះ នៅឡើយ ។ បុរសនោះ

ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ បុរិសំ ជានាមិ យេនម្ហិ វិទ្ធោ ទីឃោ វា រស្សោ វា មជ្ឈិមោ វាតិ ។ សោ ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ បុរិសំ ជានាមិ យេនម្ហិ វិទ្ធោ កាឡោ វា សាមោ វា មង្គុរច្ឆវី វាតិ ។ សោ ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ បុរិសំ ជានាមិ យេនម្ហិ វិទ្ធោ អមុកស្មឹ គាមេ វា និគមេ វា នគរេ វាតិ ។ សោ ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ ធនុំ ជានាមិ យេនម្ហិ វិទ្ធោ យទិ វា ចាបោ យទិ វា កោទណ្ឌោតិ ។ សោ ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ ជិយំ ជានាមិ យាយម្ហិ វិទ្ធោ យទិ វា អក្កស្ស យទិ វា សណ្ហស្ស យទិ វា ន្ហារុស្ស យទិ វា មរុវាយ យទិ វា ខីរបណ្ណិនោតិ ។ សោ ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ កណ្ឌំ ជានាមិ យេនម្ហិ វិទ្ធោ យទិ

និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ជាមនុស្សខ្ពស់ឬទាប ឬកណ្តាលនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ជាមនុស្សសម្បុរខ្មៅ ឬសណ្តែកបាយ ឬប្រផេះនៅឡើយ ។ បុរសនោះ និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរស ដែលបាញ់ខ្ញុំនោះនៅក្នុងស្រុកឬនិគម ឬនគរឯណោះ ៗ នៅឡើយ ។ បុរសនោះ និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ធ្នូដែលមុតខ្ញុំនោះ ជាកាំភ្លើងឬស្នានៅឡើយ ។ បុរសនោះ និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ខ្សែបន្ទោះដែលបាញ់ខ្ញុំនោះ ជាសម្បកវាក់ ឬពន្ទុងឫស្សី ជាសរសៃសត្វឬសម្បកខ្សែងព័រ ឬវល្លិទឹកដោះនៅឡើយ ។ បុរសនោះ និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ព្រួញដែលមុតខ្ញុំ ជា

វា គច្ឆំ[១] យទិ វា ពោបិមត្តិ ។ សោ ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ កណ្ឌំ ជានាមិ យេនម្ហិ វិទ្ធោ យស្ស បត្តេហិ វា ជិតំ[២] យទិ វា គិជ្ឈស្ស យទិ វា កង្កស្ស យទិ វា កុលលស្ស យទិ វា មោរស្ស យទិ វា សិថិលហនុនោតិ ។ សោ ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ កណ្ឌំ ជានាមិ យេនម្ហិ វិទ្ធោ យស្ស ន្ហារុនា បរិក្ខិត្តំ យទិ វា គវស្ស យទិ វា មហិសស្ស យទិ វា ភេរុវស្ស[៣] យទិ វា សេម្ហារស្សាតិ ។ សោ ឯវំ វទេយ្យ ន តាវាហំ ឥមំ សល្លំ អាហរិស្សាមិ យាវ ន តំ កណ្ឌំ ជានាមិ យេនម្ហិ វិទ្ធោ យទិ វា សល្លំ យទិ វា ខុរប្បំ យទិ វា វេកណ្ឌំ[៤] យទិ វា នារាចំ យទិ វា វច្ឆទន្តំ យទិ វា ករវីរបត្តន្តិ អញ្ញាតមេវ តំ មាលុង្ក្យបុត្ត តេន បុរិសេន អស្ស អថខោ[៥] សោ បុរិសោ កាលំ ករេយ្យ ។

១ ម. ឯវំ ។ ឱ. កច្ឆំ ។ ២ ម. វា ខិត្តំ ។ ៣ ម. ភេរវស្ស ។ ៤ ឱ. ម. វេកណ្ណំ ។ ៥ ឱ. ម. ខោសទ្ធោ នត្ថិ ។

ព្រួញឈើព្រៃ ឬព្រួញឈើដែលគេដាំ នៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ព្រួញដែលមុតខ្ញុំនោះ ជាព្រួញដែលគេសៀតដោយស្លាបសត្វណា សត្វនោះជាត្មាត ឬប្រមង់ ខ្លែង ឬក្ងោក ឬទុង នៅឡើយ ។ បុរសនោះ និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ព្រួញដែលមុតខ្ញុំនោះ ជាព្រួញដែលគេរុំដោយសរសៃគោ ឬក្របីសរសៃសីហៈខ្មៅឬស្វា នៅឡើយ ។ បុរសនោះ និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ព្រួញដែលមុតខ្ញុំនោះ ជាព្រួញមានមុខមូល ឬមានមុខសំប៉ែតដូចមុខកាំបិត ព្រួញមានធ្មេញ ឬមានមុខស្រោបដែក ព្រួញមានមុខដូចពន្លាក ឬព្រួញធ្វើអំពីទ្រនុងធាងទ្រាំង នៅឡើយ ម្នាលមាលុង្ក្យបុត្រ បុរសនោះ ចាំដឹងដំណើរនោះមិនទាន់ទេ មុខជាបុរសនោះ នឹងធ្វើមរណកាលទៅពុំខាន ។

ឯវមេវ ខោ មាលុង្ក្យបុត្ត យោ ឯវំ វទេយ្យ ន តាវាហំ ភគវតិ ព្រហ្មចរិយំ ចរិស្សាមិ យាវ តំ[១] មេ ភគវា ន ព្យាករិស្សតិ សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោ-តិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វាតិ អព្យាកតមេវ តំ មាលុង្ក្យបុត្ត តថាគតេន អស្ស អថខោ សោ បុគ្គលោ កាលំ ករេយ្យ ។

[១៤១] សស្សតោ លោកោតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ អភវិស្សាតិ ឯវំ នោ អសស្សតោ លោកោតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ

១ ឱ. ម. តន្តិ នត្ថិ ។

ម្នាលមាលុង្ក្យបុត្រ បុគ្គលណានិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ប្រព្រឹត្ត ព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគទេ ព្រោះព្រះមានព្រះភាគ មិនទាន់សំដែងប្រាប់ខ្ញុំថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺ សរីរៈនោះដូច្នេះក្តី ជីវិតដទៃ សរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី ម្នាលមាលុង្ក្យបុត្រ តថាគត នឹងសំដែងដំណើរនោះឲ្យស្តាប់មិនទាន់ទេ បុគ្គលនោះ មុខជានឹងធ្វើ មរណកាលទៅ (មុនសំដែង) ពុំខាន មានឧបមេយ្យដូចជាបុរស ដែល ត្រូវព្រួញមុតនោះឯង ។

[១៥១] ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកទៀងដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកមិនទៀងដូច្នេះហើយ សេចក្តីយល់ឃើញថា

២៤៧

ព្រហ្មចរិយវាសោ អភវិស្សាតិ ឯវម្បិ នោ សស្សតោ លោកោតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ អសស្សតោ លោកោតិ វា ទិដ្ឋិយា សតិ អត្ថេវ ជាតិ អត្ថិ ជរា អត្ថិ មរណំ សន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា យេសាហំ ទិដ្ឋេវ ធម្មេ និឃាតំ បញ្ញបេមិ ។ អន្តវា លោកោតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ អភវិស្សាតិ ឯវំ នោ អនន្តវា លោកោតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ អភវិស្សាតិ ឯវម្បិ នោ អន្តវា លោកោតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ អនន្តវា លោកោតិ វា ទិដ្ឋិយា សតិ អត្ថេវ ជាតិ អត្ថិ ជរា អត្ថិ មរណំ សន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា យេសាហំ ទិដ្ឋេវ ធម្មេ និឃាតំ បញ្ញបេមិ ។ តំ ជីវំ តំ សរីរន្តិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ អភវិស្សាតិ

ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកទៀង ឬថាលោកមិនទៀងដូច្នេះហើយ ជាតិក៏មាន ជរាក៏មាន មរណៈក៏មាន សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំចិត្តក៏មាន ជាធម៌ដែលតថាគតបញ្ញត្តថាមានសេចក្តីវិនាសក្នុងបច្ចុប្បន្ន ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកមានទីបំផុតដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកមិនមានទីបំផុតដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកមានទីបំផុត ឬថាលោកមិនមានទីបំផុតដូច្នេះហើយ ជាតិក៏មាន ជរាក៏មាន សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំចិត្តក៏មាន ជាធម៌ដែលតថាគតបញ្ញត្តថាមានសេចក្តីវិនាស ក្នុងបច្ចុប្បន្ន ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា ជីវិតនោះក៏គឺសរីរៈនោះ ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌នឹងមាន ដូច្នេះ មិនមានទេ

ឯវំ ខោ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ អភវិស្សាតិ ឯវម្បិ ខោ តំ ជីវំ តំ សរីរន្តិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ទិដ្ឋិយា សតិ អត្ថេវ ជាតិ ។ បេ ។ និឃាតំ បញ្ញាបេមិ ។ ហោតិ តថាគតោ បរម្មរណាតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ អភវិស្សាតិ ឯវំ ខោ ន ហោតិ តថាគតោ បរម្មរណាតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ អភវិស្សាតិ ឯវម្បិ ខោ ហោតិ តថាគតោ បរម្មរណាតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ ន ហោតិ តថាគតោ បរម្មរណាតិ វា ទិដ្ឋិយា សតិ អត្ថេវ ជាតិ ។ បេ ។ យេសាហំ ទិដ្ឋេវ ធម្មេ និឃាតំ បញ្ញាបេមិ ។ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ ព្រហ្មចរិយវាសោ អភវិស្សាតិ

ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា ជីវិតដទៃ សរីរៈក៏ដទៃដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា ជីវិតនោះក៏គឺសរីរៈនោះ ឬថា ជីវិតដទៃ សរីរៈក៏ដទៃដូច្នេះហើយ ជាតិក៏មាន ។ បេ ។ បញ្ញត្តថាមានសេចក្តីវិនាស ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយកើតទៀតដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយមិនកើតទៀតដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយកើតទៀត ឬថា សត្វស្លាប់ហើយមិនកើតទៀតដូច្នេះហើយ ជាតិក៏មាន ។ បេ ។ ជាធម៌ដែលតថាគតបញ្ញត្តថា មានសេចក្តីវិនាសក្នុងបច្ចុប្បន្ន ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមាន ដូច្នេះ

ឯវំ នោ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ ព្រហ្មចរិយ-វាសោ អភវិស្សាតិ ឯវម្បិ នោ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ មាលុង្ក្យបុត្ត ទិដ្ឋិយា សតិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា ទិដ្ឋិយា សតិ អត្ថេវ ជាតិ អត្ថិ ជរា អត្ថិ មរណំ សន្តិ សោកបរិទេវទុក្ខទោ-មនស្សុបាយាសា យេសាហំ ទិដ្ឋេវ ធម្មេ និឃាតំ បញ្ញបេមិ ។

[១៤២] តស្មាតិហ មាលុង្ក្យបុត្ត អព្យាកតញ្ច មេ អព្យាកតតោ ធារេថ ព្យាកតញ្ច មេ ព្យាកតតោ ធារេថ ។ កិញ្ច មាលុង្ក្យបុត្ត មយា អព្យាកតំ សស្សតោ លោកោតិ មាលុង្ក្យបុត្ត មយា អព្យាកតំ អសស្សតោ លោកោតិ មាលុង្ក្យបុត្ត[១] មយា

១ ឱ. មាលុង្ក្យបុត្ត ឥតិ ន ទិស្សតិ ។

មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្ដីយល់ឃើញថា សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះហើយ សេចក្ដីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌នឹងមាន ដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្ដីយល់ឃើញថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន ឬថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះហើយ ជាតិក៏មាន ជរាក៏មាន មរណៈក៏មាន សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ សេចក្ដីតូចចិត្ត សេចក្ដីក្រៀមក្រំចិត្តក៏មាន ជាធម៌ដែលតថាគតបញ្ញត្តថា មានសេចក្ដីវិនាសក្នុងបច្ចុប្បន្ន ។

[១៥២] ម្នាលមាលុង្ក្យបុត្រ ព្រោះហេតុនោះ អ្នកទាំងឡាយចូរចាំទុកនូវសេចក្ដី ដែលតថាគតមិនបានសំដែងហើយ តាមសេចក្ដីដែលតថាគតមិនបានសំដែង ទាំងចូរចាំទុកនូវសេចក្ដី ដែលតថាគតបានសំដែងហើយ តាមសេចក្ដីដែលតថាគតបានសំដែងចុះ ។ ម្នាលមាលុង្ក្យ-បុត្រ ចុះតថាគតមិនបានសំដែងសេចក្ដីដូចម្ដេចខ្លះ ម្នាលមាលុង្ក្យបុត្រ តថា-គត មិនបានសំដែងថា លោកទៀង ម្នាលមាលុង្ក្យបុត្រ តថាគតមិនបាន

អព្យាកតំ អន្តវា លោកោតិ មាលុង្ក្យបុត្ត[១] មយា អព្យាកតំ អនន្តវា លោកោតិ មាលុង្ក្យបុត្ត[២] មយា អព្យាកតំ តំ ជីវំ តំ សរីរន្តិ មយា អព្យាកតំ អញ្ញំ ជីវំ អញ្ញំ សរីរន្តិ មយា អព្យាកតំ ហោតិ តថាគតោ បរម្មរណាតិ មយា អព្យាកតំ ន ហោតិ តថាគតោ បរម្មរណាតិ មយា អព្យាកតំ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ មយា អព្យាកតំ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ មយា អព្យាកតំ ។ កស្មា ចេតំ មាលុង្ក្យបុត្ត មយា អព្យាកតំ ន ហេតំ មាលុង្ក្យបុត្ត អត្ថសញ្ហិតំ នាទិព្រហ្មចរិយកំ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ តស្មា តំ មយា អព្យាកតំ ។ កិញ្ច មាលុង្ក្យបុត្ត មយា ព្យាកតំ

១-២ ឱ. មាលុង្ក្យបុត្ត ឥតិ ន ទិស្សតិ ។

សំដែងថា លោកមិនទៀង ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា លោកមានទីបំផុត ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា លោកមិនមានទីបំផុត ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា ជីវិតនោះក៏គឺសរីរៈនោះ តថាគតមិនបានសំដែងថា ជីវិតដទៃ សរីរៈក៏ដទៃ តថាគតមិនបានសំដែងថា សត្វស្លាប់ហើយកើតទៀត តថាគតមិនបានសំដែងថា សត្វស្លាប់ហើយមិនកើតទៀត តថាគតមិនបានសំដែងថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន តថាគតមិនបានសំដែងថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ ម្នាលមាលុង្ក្យបុត្រ ព្រោះហេតុអ្វី បានជាតថាគតមិនសំដែងទិដ្ឋិនុ៎ះ ម្នាលមាលុង្ក្យបុត្រ ព្រោះទិដ្ឋិនោះមិនប្រកបដោយប្រយោជន៍ មិនមែនជាខាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ មិនប្រព្រឹត្តទៅដើម្បីសេចក្តីរំលត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតមិនសំដែងទិដ្ឋិនោះ ។ ម្នាលមាលុង្ក្យបុត្រ ចុះសេចក្តីដូចម្តេចដែលតថាគតតែងសំដែង

ឥទំ ទុក្ខន្តិ មាលុង្ក្យបុត្ត មយា ព្យាកតំ អយំ ទុក្ខសមុទយោតិ មយា ព្យាកតំ អយំ ទុក្ខនិរោធោតិ មយា ព្យាកតំ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ មយា ព្យាកតំ ។ កស្មា ចេតំ មាលុង្ក្យបុត្ត មយា ព្យាកតំ ឯតញ្ហិ មាលុង្ក្យបុត្ត អត្ថសញ្ហិតំ ឯតំ អាទិព្រហ្មចរិយកំ ឯតំ[១] និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ តស្មា តំ មយា ព្យាកតំ ។ តស្មាតិហ មាលុង្ក្យបុត្ត អព្យាកតញ្ច មេ អព្យាកតតោ ធារេថ ព្យាកតញ្ច មេ ព្យាកតតោ ធារេថាតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា មាលុង្ក្យបុត្តោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ចូឡមាលុង្ក្យោវាទសុត្តំ   តតិយំ   និដ្ឋិតំ ។

---

១ ម. ឯតន្តិ ន ទិស្សតិ ។

ម្នាលមាលុង្ក្យបុត្រ តថាគតតែងសំដែងថា នេះជាទុក្ខ ម្នាលមាលុង្ក្យបុត្រ តថាគតតែងសំដែងថា នេះជាហេតុប្រជុំកើតឡើងនៃទុក្ខ តថាគតតែងសំដែងថា នេះជាគ្រឿងរលត់ទុក្ខ តថាគតតែងសំដែងថា នេះសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ ម្នាលមាលុង្ក្យបុត្រ ហេតុដូចម្តេចបានជាតថាគតសំដែងពាក្យនុ៎ះ ម្នាលមាលុង្ក្យបុត្រ ព្រោះថាពាក្យនុ៎ះប្រកបដោយប្រយោជន៍ ពាក្យនុ៎ះជាខាងដើមនៃព្រហ្មចរិយធម៌ ពាក្យនុ៎ះប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ ប្រព្រឹត្តទៅដើម្បីសេចក្តីរំលត់ទុក្ខ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីសេចក្តីដឹងច្បាស់ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតសំដែងពាក្យនោះ ។ ម្នាលមាលុង្ក្យបុត្រ ព្រោះហេតុនោះ អ្នកទាំងឡាយចូរចាំទុកនូវសេចក្តីដែលតថាគតមិនបានសំដែងហើយ តាមសេចក្តីដែលតថា-គតមិនបានសំដែងហើយផង ចូរចាំទុកនូវសេចក្តីដែលតថាគតបានសំដែងហើយ តាមសេចក្តីដែលតថាគតបានសំដែងហើយផង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងព្រះសូត្រនេះចប់ហើយ ព្រះមាលុង្ក្យបុត្រមានអាយុក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ចូឡមាលុង្ក្យោវាទសូត្រ ទី ៣ ។

# ចតុត្ថំ មហាមាលុង្ក្យោវាទសុត្តំ

[១៨៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ធារេថ នោ តុម្ហេ ភិក្ខវេ មយា ទេសិតានិ បញ្ចោរម្ភាគិយានិ សញ្ញោជនានីតិ ។ ឯវំ វុត្តេ អាយស្មា មាលុង្ក្យបុត្តោ[១] ភគវន្តំ ឯតទវោច អហំ ខោ ភន្តេ ធារេមិ ភគវតា ទេសិតានិ បញ្ចោរម្ភាគិយានិ សញ្ញោជនានីតិ[២] ។ យថាកថំ បន ត្វំ មាលុង្ក្យបុត្ត ធារេសិ មយា ទេសិតានិ បញ្ចោរម្ភាគិយានិ សញ្ញោជនានីតិ ។ សក្កាយទិដ្ឋឹ ខោ អហំ ភន្តេ ភគវតា ឱរម្ភាគិយំ សញ្ញោជនំ ទេសិតំ ធារេមិ

---

១ មាលុង្ក្យាបុត្តោតិបិ មាលុក្យបុត្តោតិបិ បាឋោ ទិស្សតិ ។ ២ ឱ. ម. សំយោជនានីតិ ។

# មហាមាលុង្ក្យោវាទសូត្រ ទី ៤

[១៨៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយបានចាំឱរម្ភាគិយសំយោជនៈ[១] ៥ ដែលតថាគតបានសំដែងហើយដែរឬ ។ កាលដែលព្រះមានព្រះភាគ ត្រាស់សួរយ៉ាងនេះហើយ ព្រះមាលុង្ក្យបុត្រមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំឱរម្ភាគិយសំយោជនៈ ៥ ដែលព្រះមានព្រះភាគ សំដែងហើយ ។ ព្រះអង្គត្រាស់សួរថា ម្នាលមាលុង្ក្យបុត្រ ចុះអ្នកចាំឱរម្ភាគិយសំយោជនៈ ៥ ដែលតថាគតសំដែងហើយដូចម្តេចខ្លះ ។ មាលុង្ក្យបុត្រក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំថា សក្កាយទិដ្ឋិ ជាឱរម្ភាគិយសំយោជនៈ ដែលព្រះមានព្រះភាគ សំដែងហើយ

---

១ សំយោជនៈ ជាចំណែកខាងជាន់ទាប មានអំណាចចងរឹតសត្វភ្ជាប់ក្នុងភពជាន់ទាប គឺកាមភព ។ អដ្ឋកថា ។

វិចិកិច្ឆំ ខោ អហំ ភន្តេ ភគវតា ឱរម្ភាគិយំ សញ្ញោជនំ ទេសិតំ ធារេមិ សីលព្វតបរាមាសំ ខោ អហំ ភន្តេ ភគវតា ឱរម្ភាគិយំ សញ្ញោជនំ ទេសិតំ ធារេមិ កាមច្ឆន្ទំ ខោ អហំ ភន្តេ ភគវតា ឱរម្ភាគិយំ សញ្ញោជនំ ទេសិតំ ធារេមិ ព្យាបាទំ ខោ អហំ ភគវតា ឱរម្ភាគិយំ សញ្ញោជនំ ទេសិតំ ធារេមិ ឯវំ ខោ អហំ ភន្តេ ធារេមិ ភគវតា ទេសិតានិ បញ្ចោរម្ភាគិយានិ សញ្ញោជនានីតិ ។

[១៨៤] កស្ស ខោ នាម ត្វំ មាលុង្ក្យបុត្ត មយា ឥមានិ(១) ឯវំ បញ្ចោរម្ភាគិយានិ សញ្ញោជនានិ ទេសិតានិ ធារេសិ ននុ មាលុង្ក្យបុត្ត អញ្ញតិត្ថិយា បរិព្វាជកា ឥមិនា តរុណូបមេន ឧបារម្ភេន ឧបារម្ភិស្សន្តិ ទហរស្ស ហិ មាលុង្ក្យបុត្ត កុមារស្ស មន្ទស្ស ឧត្តានសេយ្យកស្ស សក្កាយោតិបិ ន ហោតិ កុតោ បនស្ស ឧប្បជ្ជិស្សតិ សក្កាយទិដ្ឋិ អនុសេតិ ត្វេវស្ស សក្កាយទិដ្ឋានុសយោ ទហរស្ស ហិ មាលុង្ក្យបុត្ត កុមារស្ស មន្ទស្ស

១ ឱ. ឥមានីតិ ន ទិស្សតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំថា វិចិកិច្ឆា ជាឱរម្ភាគិយសំយោជនៈ ដែលព្រះមានព្រះភាគសំដែងហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំថា សីលព្វតបរាមាសៈ ជាឱរម្ភាគិយសំយោជនៈ ដែលព្រះមានព្រះភាគសំដែងហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំថា កាមច្ឆន្ទៈ ជាឱរម្ភាគិយសំយោជនៈ ដែលព្រះមានព្រះភាគសំដែងហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំថា ព្យាបាទៈ ជាឱរម្ភាគិយសំយោជនៈ ដែលព្រះមានព្រះភាគសំដែងហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំបាននូវឱរម្ភាគិយសំយោជនៈ ៥ ដែលព្រះមានព្រះភាគសំដែងហើយយ៉ាងនេះឯង ។

[១៥៤] ព្រះអង្គត្រាស់ថា ម្នាលមាលុង្ក្យបុត្រ អ្នកចាំបាននូវឱរម្ភាគិយសំយោជនៈ ៥ យ៉ាងនេះ ដែលតថាគតបានសំដែងហើយ ថាជាសំយោជនៈរបស់អ្នកណា ម្នាលមាលុង្ក្យបុត្រ ក្រែងពួកបរិព្វាជកជាអន្យតិរ្ថិយ នឹងពោលប្រកួតប្រកាន់ ដោយសេចក្តីប្រកួតប្រកាន់ ដែលប្រៀបដោយកូនក្មេងតូចទេដឹង ម្នាលមាលុង្ក្យបុត្រ ដ្បិតកូនក្មេងតូចកំពុងដេកផ្ងារនៅឡើយ នឹងថាមានសក្កាយមិនទាន់បានទេ តើសក្កាយទិដ្ឋិនឹងកើតឡើងដល់កូនក្មេងនោះដូចម្តេចបាន តែត្រង់សក្កាយទិដ្ឋានុស័យរបស់កូនក្មេងនោះ គង់ដេកនៅខាងក្នុង ម្នាលមាលុង្ក្យបុត្រ កូនក្មេងតូចខ្ចី

ឧត្តានសេយ្យកស្ស ធម្មាតិបិ ន ហោតិ កុតោ បនស្ស ឧប្បជ្ជិស្សតិ ធម្មេសុ វិចិកិច្ឆា អនុសេតិ ត្វេវស្ស វិចិកិច្ឆានុសយោ ទហរស្ស ហិ មាលុង្ក្យបុត្ត កុមារស្ស មន្ទស្ស ឧត្តានសេយ្យកស្ស សីលាតិបិ ន ហោតិ កុតោ បនស្ស ឧប្បជ្ជិស្សតិ សីលេសុ សីលព្វតបរាមាសោ អនុសេតិ ត្វេវស្ស សីលព្វតបរាមាសានុសយោ ទហរស្ស ហិ មាលុង្ក្យបុត្ត កុមារស្ស មន្ទស្ស ឧត្តានសេយ្យកស្ស កាមាតិបិ ន ហោតិ កុតោ បនស្ស ឧប្បជ្ជិស្សតិ កាមេសុ កាមច្ឆន្ទោ អនុសេតិ ត្វេវស្ស កាមរាគានុសយោ ទហរស្ស ហិ មាលុង្ក្យបុត្ត កុមារស្ស មន្ទស្ស ឧត្តានសេយ្យកស្ស សត្តាតិបិ ន ហោតិ កុតោ បនស្ស ឧប្បជ្ជិស្សតិ សត្តេសុ ព្យាបាទោ អនុសេតិ ត្វេវស្ស ព្យាបាទានុសយោ ននុ មាលុង្ក្យបុត្ត អញ្ញតិត្ថិយា បរិព្វាជកា ឥមិនា តរុណូបមេន ឧបារម្ភេន ឧបារម្ភិស្សន្តីតិ ។ ឯវំ វុត្តេ

កំពុងដេកផ្ងារនៅឡើយ នឹងថាមានធម៌មិនទាន់បានទេ តើសេចក្ដីសង្ស័យក្នុងធម៌ទាំងឡាយ នឹងកើតឡើងដល់កូនក្មេងនោះ ដូចម្ដេចបាន តែត្រង់វិចិកិច្ឆានុស័យ របស់កូនក្មេងនោះ គង់ដេកនៅខាងក្នុង ម្នាលមាលុង្ក្យបុត្រ តាមសេចក្ដីពិត កូនក្មេងតូចខ្ចី កំពុងដេកផ្ងារនៅឡើយ នឹងថាមានសីលមិនទាន់បានទេ តើសីលព្វតបរាមាសៈ ក្នុងសីលទាំងឡាយ នឹងកើតឡើងដល់កូនក្មេងនោះ ដូចម្ដេចបាន តែត្រង់សីលព្វតបរាមាសានុស័យ របស់កូនក្មេងនោះ គង់ដេកនៅខាងក្នុង ម្នាលមាលុង្ក្យបុត្រ កូនក្មេងតូចខ្ចីកំពុងដេកផ្ងារនៅឡើយ នឹងថាមានកាមមិនទាន់បានទេ តើកាមច្ឆន្ទៈក្នុងកាមទាំងឡាយ នឹងកើតឡើងដល់កូនក្មេងនោះ ដូចម្ដេចបាន តែត្រង់កាមរាគានុស័យ របស់កូនក្មេងនោះ គង់ដេកនៅខាងក្នុង ម្នាលមាលុង្ក្យបុត្រ កូនក្មេងតូចខ្ចី កំពុងដេកផ្ងារនៅឡើយ នឹងថាមានសត្វមិនទាន់បានទេ តើព្យាបាទទៅរកសត្វទាំងឡាយ នឹងកើតឡើងដល់កូនក្មេងនោះដូចម្ដេចបាន តែត្រង់ព្យាបាទានុស័យ របស់កូនក្មេងនោះ គង់ដេកនៅខាងក្នុង ម្នាលមាលុង្ក្យបុត្រ ក្រែងពួកបរិព្វាជកជាអន្យតិរ្ថិយ នឹងពោលប្រកួតប្រកាន់ ដោយសេចក្ដីប្រកួតប្រកាន់ ដែលប្រៀបដោយកូនក្មេងនេះឯង ទេដឹង ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់

អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា បញ្ចោរម្ភាគិយានិ សញ្ញោជនានិ ទេសេយ្យ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហានន្ទ សុណាហិ[១] សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។

[១៥៥] ភគវា ឯតទវោច ឥធានន្ទ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិស-ធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ សក្កា-យទិដ្ឋិបរិយុដ្ឋិតេន ចេតសា វិហរតិ សក្កាយទិដ្ឋិប-រេតេន ឧប្បន្នាយ ច សក្កាយទិដ្ឋិយា និស្សរណំ យថាភូតំ នប្បជានាតិ តស្ស សា សក្កាយទិដ្ឋិ

១ ឱ. ម. សុណោហិ ។

យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះ ព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ កាលនេះជាកាលគួរ ហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរ ដែលព្រះមានព្រះភាគ នឹងសំដែងនូវឱរម្ភាគិយសំយោជនៈ ៥ ហើយ ពួកភិក្ខុបើបានស្តាប់ភាសិត របស់ព្រះមានព្រះភាគហើយ នឹងចងចាំទុកបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកប្រុងស្តាប់ ចូរយកចិត្តទុកដាក់ ដោយ ប្រពៃចុះ តថាគតនឹងសំដែង ។ ព្រះអានន្ទមានអាយុ ក៏ទទួលព្រះ ពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១៥៥] ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាល អានន្ទ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់មិនបានឃើញព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនបានសិក្សាក្នុងធម៌របស់ព្រះអរិយៈ ទាំងមិនបានជួបប្រទះពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនបានសិក្សាក្នុងធម៌របស់សប្បុរស ជាអ្នកមានសក្កាយទិដ្ឋិគ្របសង្កត់ចិត្ត មានសក្កាយទិដ្ឋិរួបរឹតចិត្ត ទាំងមិនដឹងច្បាស់នូវព្រះនិព្វានជាគ្រឿងរលាស់ ចេញនូវសក្កាយទិដ្ឋិដែលកើតឡើង តាមសេចក្តីពិតបានឡើយ សក្កាយ-

ថាមគតា អប្បដិវិនីតា ឱរម្ភាគិយសញ្ញោជនំ ។ វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នប្បជានាតិ តស្ស សា វិចិកិច្ឆា ថាមគតា[១] អប្បដិវិនីតា ឱរម្ភាគិយសញ្ញោជនំ[២] ។ សីលព្វតបរាមាសបរិយុដ្ឋិតេន ចេតសា វិហរតិ សីលព្វតបរាមាសបរេតេន ឧប្បន្នស្ស ច សីលព្វតបរាមាសស្ស និស្សរណំ យថាភូតំ នប្បជានាតិ តស្ស សោ សីលព្វតបរាមាសោ ថាមគតោ អប្បដិវិនីតោ ឱរម្ភាគិយសញ្ញោជនំ[៣] ។ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាតិ តស្ស សោ កាមរាគោ ថាមគតោ អប្បដិវិនីតោ ឱរម្ភាគិយសញ្ញោជនំ[៤] ។ ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ព្យាបាទបរេតេន

---

១-២-៣-៤ ឱ. ម. ឱរម្ភាគិយំ សំយោជនំ ។

ទិដ្ឋិនោះរបស់បុគ្គលនោះ មានកម្លាំង បុគ្គលនោះក៏មិនអាចនឹងលះបង់ចោលបាន (នេះ) ជាឱរម្ភាគិយសំយោជនៈ ១ ។ ជាអ្នកមានវិចិកិច្ឆាគ្របសង្កត់ចិត្ត មានវិចិកិច្ឆារួបរឹតចិត្ត ទាំងមិនបានដឹងច្បាស់ នូវព្រះនិព្វាន ជាគ្រឿងរលាស់ចេញនូវវិចិកិច្ឆាដែលកើតឡើង តាមសេចក្តីពិតបានឡើយ វិចិកិច្ឆានោះ របស់បុគ្គលនោះ មានកម្លាំង បុគ្គលនោះក៏មិនអាចនឹងរលាស់ចេញបាន (នេះ) ជាឱរម្ភាគិយសំយោជនៈ ១ ។ ជាអ្នកមានសីលព្វតបរាមាសៈគ្របសង្កត់ចិត្ត មានសីលព្វតបរាមាសៈរួបរឹតចិត្ត ទាំងមិនដឹងច្បាស់នូវព្រះនិព្វាន ជាគ្រឿងរលាស់ចេញនូវសីលព្វត្តបរាមាសៈ ដែលកើតឡើង តាមសេចក្តីពិតបានឡើយ សីលព្វត្តបរាមាសៈនោះ របស់បុគ្គលនោះមានកម្លាំង បុគ្គលនោះមិនអាចនឹងរលាស់ចោលបាន (នេះ) ជាឱរម្ភាគិយសំយោជនៈ ១ ។ ជាអ្នកមានកាមរាគគ្របសង្កត់ចិត្ត មានកាមរាគរួបរឹតចិត្ត ទាំងមិនដឹងច្បាស់នូវព្រះនិព្វាន ជាគ្រឿងរលាស់ចេញ នូវកាមរាគដែលកើតឡើង តាមសេចក្តីពិតបានឡើយ កាមរាគនោះរបស់បុគ្គលនោះ មានកម្លាំង បុគ្គលនោះមិនអាចនឹងរលាស់ចេញបាន (នេះ) ជាឱរម្ភាគិយសំយោជនៈ ១ ។ ជាអ្នកមានព្យាបាទគ្របសង្កត់ចិត្ត មានព្យាបាទរួបរឹតចិត្ត ទាំងមិន

ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ នប្បជានាតិ តស្ស សោ ព្យាបាទោ ថាមគតោ អប្បដិវិនីតោ ឱរម្ភាគិយសញ្ញោជនំ ។ សុតវា ច ខោ អានន្ទ អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន សក្កាយទិដ្ឋិបរិយុដ្ឋិតេន ចេតសា វិហរតិ ន សក្កាយទិដ្ឋិបរេតេន ឧប្បន្នាយ ច សក្កាយទិដ្ឋិយា និស្សរណំ យថាភូតំ បជានាតិ តស្ស សា សក្កាយទិដ្ឋិ សានុសយា បហីយតិ ។ ន វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ ន វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ បជានាតិ តស្ស សា វិចិកិច្ឆា សានុសយា បហីយតិ ។ ន សីលព្វតបរាមាសបរិយុដ្ឋិតេន ចេតសា វិហរតិ ន សីលព្វតបរាមាសបរេតេន

ដឹងច្បាស់នូវព្រះនិព្វាន ជាគ្រឿងរលាស់ចេញនូវព្យាបាទដែលកើតឡើង តាមពិតបានឡើយ ព្យាបាទនោះរបស់បុគ្គលនោះ មានកម្លាំង បុគ្គលនោះមិនអាចនឹងរលាស់ចេញបាន (នេះ) ជាឱរម្ភាគិយសំយោជនៈ ១ ។ ម្នាលអានន្ទ ចំណែកខាងអរិយសាវ័ក ជាអ្នកបានស្តាប់បានឃើញពួកព្រះអរិយៈ ជាអ្នកឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ បានសិក្សាក្នុងធម៌របស់ព្រះអរិយៈ ទាំងបានឃើញពួកសប្បុរស ជាអ្នកឈ្លាសវៃក្នុងធម៌របស់សប្បុរស បានសិក្សាក្នុងធម៌របស់សប្បុរស ជាអ្នកមិនមានសក្កាយ-ទិដ្ឋិគ្របសង្កត់ចិត្ត មិនមានសក្កាយទិដ្ឋិរួបរឹតចិត្ត ទាំងដឹងច្បាស់នូវព្រះនិព្វាន ជាគ្រឿងរលាស់ចេញនូវសក្កាយទិដ្ឋិ ដែលកើតឡើង តាមសេចក្តីពិតបាន អរិយសាវ័កនោះ តែងលះបង់នូវសក្កាយទិដ្ឋិ ដែលប្រកបដោយអនុស័យ[១] នោះ ។ ជាអ្នកមិនមានវិចិកិច្ឆាគ្របសង្កត់ចិត្ត មិនមានវិចិកិច្ឆារួបរឹតចិត្ត ទាំងដឹងច្បាស់នូវព្រះនិព្វាន ជាគ្រឿងរលាស់ចេញ នូវវិចិកិច្ឆា ដែលកើតឡើងតាមសេចក្តីពិតបាន អរិយសាវ័កនោះ តែងលះបង់នូវវិចិកិច្ឆា ដែលប្រកបដោយអនុស័យនោះ ។ ជាអ្នកមិនមានសីលព្វតបរាមាសៈគ្របសង្កត់ចិត្ត មិនមានសីលព្វតបរាមាសៈរួបរឹតចិត្ត

---

១ អដ្ឋកថា ថា កេចិអាចារ្យយល់ថា លះសក្កាយទិដ្ឋិព្រមទាំងអនុស័យ ។

ឧប្បន្នស្ស ច សីលព្វតបរាមាសស្ស និស្សរណំ យថាភូតំ បជានាតិ តស្ស សោ សីលព្វតបរាមាសោ សានុសយោ បហីយតិ ។ ន កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ ន កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ បជានាតិ តស្ស សោ កាមរាគោ សានុសយោ បហីយតិ ។ ន ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ន ព្យាបាទបរេតេន ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ បជានាតិ តស្ស សោ ព្យាបាទោ សានុសយោ បហីយតិ ។

[១៥៦] យោ អានន្ទ មគ្គោ យា បដិបទា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បហានាយ តំ មគ្គំ តំ បដិបទំ អនាគម្ម បញ្ចោរម្ភាគិយានិ សញ្ញោជនានិ ញស្សតិ វា ទក្ខតិ វា បជហិស្សតិ វាតិ នេតំ ឋានំ វិជ្ជតិ ។ សេយ្យថាបិ អានន្ទ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ តចំ អច្ឆេត្វា ផេគ្គុំ អច្ឆេត្វា សារច្ឆេទោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ ឯវមេវ ខោ អានន្ទ

ទាំងដឹងច្បាស់នូវព្រះនិព្វានជាគ្រឿងរលាស់ចេញ នូវសីលព្វត្តបរាមាសៈ ដែលកើតឡើងតាមសេចក្តីពិតបាន អរិយសាវ័កនោះតែងលះបង់នូវសីលព្វត្តបរាមាសៈ ដែលប្រកបដោយអនុស័យនោះ ។ ជាអ្នកមិនមានកាមរាគគ្របសង្កត់ចិត្ត មិនមានកាមរាគរួបរឹតចិត្ត ទាំងដឹងច្បាស់នូវព្រះនិព្វានជាគ្រឿងរលាស់ចេញនូវកាមរាគ ដែលកើតឡើងតាមសេចក្តីពិតបាន អរិយសាវ័កនោះ តែងលះបង់នូវកាមរាគ ដែលប្រកបដោយអនុស័យនោះ ។ ជាអ្នកមិនមានព្យាបាទគ្របសង្កត់ចិត្ត មិនមានព្យាបាទរួបរឹតចិត្ត ទាំងបានដឹងច្បាស់នូវព្រះនិព្វានជាគ្រឿងរលាស់ចេញ នូវព្យាបាទដែលកើតឡើង តាមសេចក្តីពិតបាន អរិយសាវ័កនោះ តែងលះបង់នូវព្យាបាទដែលប្រកបដោយអនុស័យនោះ ។

[១៥៦] ម្នាលអានន្ទ មគ្គណា បដិបទាណា ប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈ ៥ បុគ្គលមិនបាច់អាស្រ័យនូវមគ្គនោះ នូវបដិបទានោះទេ ក៏គង់ដឹង ឬគង់ឃើញ គង់លះបង់នូវឱរម្ភាគិយសំយោជនៈ ៥ បាន ពាក្យដូច្នេះមិនសមហេតុទេ ។ ម្នាលអានន្ទ ដូចដើមឈើធំដែលមានខ្លឹម កំពុងឋិតនៅ បុគ្គលមិនបានប្រាសយកសម្បកចេញ មិនបានចាំងយកស្រាយចេញ ក៏គង់តែកាប់យកខ្លឹមបាន ពាក្យដូច្នេះនេះមិនសមហេតុឡើយ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ

យោ មគ្គោ យា បដិបទា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បហានាយ តំ មគ្គំ តំ បដិបទំ អនាគម្ម បញ្ចោរម្ភាគិយានិ សញ្ញោជនានិ ញស្សតិ វា ទក្ខតិ វា បជហិស្សតិ វាតិ នេតំ ឋានំ វិជ្ជតិ ។ យោ ច ខោ អានន្ទ មគ្គោ យា បដិបទា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បហានាយ តំ មគ្គំ តំ បដិបទំ អាគម្ម បញ្ចោរម្ភាគិយានិ សញ្ញោជនានិ ញស្សតិ វា ទក្ខតិ វា បជហិស្សតិ វាតិ ឋានមេតំ វិជ្ជតិ ។ សេយ្យថាបិ អានន្ទ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ តចំ ឆេត្វា ផេគ្គុំ ឆេត្វា សារច្ឆេទោ ភវិស្សតីតិ ឋានមេតំ វិជ្ជតិ ឯវមេវ ខោ អានន្ទ យោ មគ្គោ យា បដិបទា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បហានាយ តំ មគ្គំ តំ បដិបទំ អាគម្ម បញ្ចោរម្ភាគិយានិ សញ្ញោ-ជនានិ ញស្សតិ វា ទក្ខតិ វា បជហិស្សតិ វាតិ ឋានមេតំ វិជ្ជតិ ។ សេយ្យថាបិ អានន្ទ គង្គា នទី បូរា ឧទកស្ស សមតិត្តិកា កាកបេយ្យា អថ ទុព្ពលកោ បុរិសោ អាគច្ឆេយ្យ អហំ

មគ្គណា បដិបទាណា ដែលប្រព្រឹត្តទៅដើម្បីលះបង់ នូវឱរម្ភាគិយ-សំយោជនៈ ៥ បុគ្គលមិនបាច់អាស្រ័យមគ្គនោះ បដិបទានោះទេ ក៏គង់ដឹង ឬគង់ឃើញ គង់លះបង់នូវឱរម្ភាគិយសំយោជនៈ ៥ បាន ពាក្យដូច្នេះនេះមិនសមហេតុឡើយ មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលអានន្ទ លុះតែមគ្គណា បដិបទាណា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈ ៥ បុគ្គលក៏បានអាស្រ័យ នូវមគ្គនោះ នូវបដិបទានោះ នឹងដឹង ឬនឹងឃើញ នឹងលះបង់ នូវឱរម្ភាគិយសំ-យោជនៈ ៥ បាន ពាក្យដូច្នេះនេះទើបសមហេតុមែន ។ ម្នាលអានន្ទ ដូចដើមឈើដែលមានខ្លឹម កំពុងឋិតនៅ ហើយគេបានប្រាសសំបកចេញ ចាំងស្រាយចេញ ទើបគេកាប់យកខ្លឹមបាន ពាក្យដូច្នេះនេះទើបសមហេតុ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ មគ្គណា បដិបទាណា ដែលប្រព្រឹត្តទៅដើម្បីលះបង់ នូវឱរម្ភាគិយសំយោជនៈ ៥ បុគ្គលក៏បានអាស្រ័យនូវមគ្គនោះ នូវបដិបទានោះ នឹងដឹង ឬនឹងឃើញ នឹងលះបង់នូវឱរម្ភាគិយសំយោជនៈ ៥ បាន ពាក្យដូច្នេះនេះទើបសមហេតុក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលអានន្ទ មួយទៀត ដូចទន្លេគង្គាមានទឹកពេញប្រៀបស្មើនឹងច្រាំង ល្មមក្អែកទំលើមាត់ច្រាំងឱនផឹកបាន កាលនោះ មានបុរសមានកម្លាំងខ្សោយដើរមកដោយគិតថា អាត្មាអញ

ឥមិស្សា គង្គាយ នទិយា តិរិយំ ពាហាយ សោតំ ឆេត្វា សោត្ថិនា បារំ គច្ឆិស្សាមីតិ[១] សោ ន សក្កុណេយ្យ គង្គាយ នទិយា តិរិយំ ពាហាយ សោតំ ឆេត្វា សោត្ថិនា បារំ គន្តុំ ឯវមេវ ខោ អានន្ទ យស្ស កស្សចិ សក្កាយនិរោធាយ ធម្មេ ទេសិយមានេ ចិត្តំ ន បក្ខន្ទតិ នប្បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ។ សេយ្យថាបិ សោ ទុព្វលកោ បុរិសោ ឯវមេវ តេ[២] ទដ្ឋព្វា ។ សេយ្យថាបិ អានន្ទ គង្គា នទី បូរា ឧទកស្ស សមតិត្តិកា កាកបេយ្យា អថ ពលវា បុរិសោ អាគច្ឆេយ្យ អហំ ឥមិស្សា គង្គាយ នទិយា តិរិយំ ពាហាយ សោតំ ឆេត្វា សោត្ថិនា បារំ គមិស្សាមីតិ សោ សក្កុណេយ្យ គង្គាយ នទិយា តិរិយំ ពាហាយ សោតំ ឆេត្វា សោត្ថិនា បារំ គន្តុំ ឯវមេវ ខោ អានន្ទ យស្ស កស្សចិ សក្កាយនិរោធាយ ធម្មេ ទេសិយមានេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ។ សេយ្យថាបិ សោ ពលវា បុរិសោ ឯវមេវ តេ[៣] ទដ្ឋព្វា ។

---

១ ឱ. គច្ឆាមីតិ ។ ២-៣ ឱ. ម. ឯវមេតេ ។

នឹងឆ្វេងកាត់ខ្សែទឹក ត្រង់ទទឹងទន្លេគង្គានេះដោយដៃ ហើយនឹងបានដល់ទៅត្រើយនាយដោយសួស្តីដូច្នេះ បុរសនោះមិនអាចនឹងឆ្វេងកាត់ខ្សែទឹក ត្រង់ទទឹងទន្លេគង្គាដោយដៃ ទៅដល់ត្រើយខាងនាយ ដោយសួស្តីបានឡើយ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ កាលតថាគតសំដែងធម៌ដើម្បីរំលត់នូវសក្កាយៈដល់បុគ្គលណាមួយ ចិត្តរបស់បុគ្គលនោះមិនស្ទុះទៅ មិនជ្រះថ្លា មិនឋិតនៅស៊ប់ មិនជឿជាក់ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បណ្ឌិតត្រូវឃើញពួកជនទាំងនោះ ដូចជាបុរសដែលមានកម្លាំងខ្សោយនោះឯង ។ ម្នាលអានន្ទ ទន្លេគង្គាមានទឹកពេញប្រៀបស្មើមាត់ច្រាំង ល្មមក្អែកទំលើមាត់ច្រាំងឱនផឹកទឹកបាន កាលនោះ បុរសមានកម្លាំងដើរមកដោយគិតថា អាត្មាអញនឹងឆ្វេងកាត់ខ្សែទឹក ត្រង់ទទឹងទន្លេគង្គានេះដោយដៃហើយ នឹងបានដល់ត្រើយខាងនាយដោយសួស្តីដូច្នេះ បុរសនោះអាចនឹងឆ្វេងកាត់ខ្សែទឹក ត្រង់ទទឹងទន្លេគង្គាដោយដៃ ក៏ដល់ទៅត្រើយខាងនាយដោយសួស្តីបាន មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ កាលតថាគតសំដែងធម៌ដើម្បីរំលត់ នូវសក្កាយៈដល់បុគ្គលណាមួយ ចិត្ត (របស់បុគ្គលនោះ) ក៏ស្ទុះទៅ ជ្រះថ្លា ឋិតនៅស៊ប់ ជឿជាក់ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បណ្ឌិតត្រូវឃើញពួកជនទាំងនោះ ដូចបុរសដែលមានកម្លាំងនោះឯង ។

[១៨៧] កតមោ ច អានន្ទ មគ្គោ កតមា ច បដិបទា[១] បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បហានាយ ។ ឥធានន្ទ ភិក្ខុ ឧបធិវិវេកា អកុសលានំ ធម្មានំ បហានា សព្វសោ កាយទុដ្ឋុល្លានំ បដិប្បស្សទ្ធិយា វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ តេហិ ធម្មេហិ ចិត្តំ បដិចាបេតិ[២] សោ តេហិ ធម្មេហិ ចិត្តំ បដិចាបេត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។

---

១ ឱ. កតមោ ចានន្ទ មគ្គោ កតមា បដិបទាតិ ទិស្សន្តិ ។ ២ ឱ. បដិវាបេតិ ។ ម. បតិដ្ឋាបេតិ បដិបាទេតីតិ អដ្ឋកថាយំ ទិស្សតិ ។

[១៩៧] ម្នាលអានន្ទ ចុះមគ្គដូចម្តេច បដិបទាដូចម្តេច ដែលប្រព្រឹត្តទៅដើម្បីលះបង់ នូវឱរម្ភាគិយសំយោជនៈ ៥ បាន ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានឧបធិវិវេក ព្រោះលះបង់នូវពួកអកុសលធម៌ ព្រោះរម្ងាប់នូវការប្រព្រឹត្តអាក្រក់ដោយកាយ ដោយសព្វអន្ទើហើយស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំង-ឡាយ បានចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិនិងសុខ ដែលកើតអំពីវិវេក ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះរមែងពិចារណាឃើញច្បាស់នូវពួកធម៌ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងខណៈដែលចូលសមាបត្តិនោះ ថាជារបស់មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាព្រួញ ជាសេចក្តីមិនសប្បាយ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សាបសូន្យ ជារបស់មិនស្តាប់បង្គាប់ចិត្ត ។ ភិក្ខុនោះ រមែងដោះចិត្តចាកធម៌ទាំងនោះ លុះភិក្ខុនោះបានដោះចិត្តចាកធម៌ទាំងនោះហើយ ក៏បង្អោនចិត្តទៅក្នុងអមតធាតុថា ការរម្ងាប់នូវសង្ខារទាំងពួង ការលះបង់នូវឧបក្កិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននោះជាសេចក្តីល្អិត ព្រះនិព្វាននុ៎ះជារបស់ប្រសើរ ។

សោ តត្ថដ្ឋិតោ អាសវានំ ខយំ បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ អយម្បិ ខោ អានន្ទ មគ្គោ អយំ បដិបទា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោ-ជនានំ បហានាយ ។ បុន ចបរំ អានន្ទ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ តតិយំ ឈានំ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ ។ បេ ។ សញ្ញោជនានំ បហានាយ ។

ភិក្ខុនោះបានឋិតនៅក្នុងវិបស្សនា ដែលមានព្រះត្រៃលក្ខណ៍ជាអារម្មណ៍នោះហើយ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្តីត្រេកអរចំពោះសមថធម៌និងវិបស្សនាធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌ទីនោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលអានន្ទ មគ្គនេះឯង បដិបទានេះឯង ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈ ៥ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ បេ ។ ចូលកាន់តតិយជ្ឈាន ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថ ទាំង ៤ ។ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់ នូវពួកធម៌ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងខណៈដែលចូលសមាបត្តិ ។ បេ ។ ដើម្បីលះបង់នូវសំយោជនៈទាំងឡាយ ។

[១៤៨] បុន ចបរំ អានន្ទ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ តេហិ ធម្មេហិ ចិត្តំ បដិវាបេតិ សោ តេហិ ធម្មេហិ ចិត្តំ បដិវាបេត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ សោ តត្ថដ្ឋិតោ អាសវានំ ខយំ បាបុណាតិ នោ ចេ

[១៥៨] ម្នាលអានន្ទ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរំលត់នូវបដិឃសញ្ញា ព្រោះមិនយកចិត្តទុកដាក់ នូវនានត្តសញ្ញា ដោយប្រការទាំងពួង ចូលកាន់អាកាសានញ្ចាយតនៈ ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ ។ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់ នូវពួកធម៌ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងខណៈដែលចូលកាន់សមាបត្តិនោះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាព្រួញ ជាសេចក្តីមិនសប្បាយ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សាបសូន្យ ជារបស់មិនស្តាប់បង្គាប់ចិត្ត ។ ភិក្ខុនោះរមែងដោះចិត្តចាកធម៌ទាំងនោះបាន លុះភិក្ខុនោះបានដោះចិត្តចាកធម៌ទាំងនោះហើយ ក៏បង្អោនចិត្តទៅក្នុងអមតធាតុថា ការរម្ងាប់បង់នូវសង្ខារទាំងពួង ការលះបង់នូវឧបក្កិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់នៃតណ្ហាគឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះជារបស់ល្អិត ព្រះនិព្វាននុ៎ះជារបស់ប្រសើរល្អ ។ ភិក្ខុនោះបានឋិតនៅហើយ ក្នុងវិបស្សនា ដែលមានព្រះត្រៃលក្ខណ៍ជាអារម្មណ៍នោះហើយ រមែងដល់នូវការអស់ទៅ នៃអាសវៈទាំងឡាយ បើបែរជា

អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ អយម្បិ ខោ អានន្ទ មគ្គោ អយំ បដិបទា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បហានាយ ។ បុន ចបរំ អានន្ទ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ វេទនាគតំ ។ បេ ។ សញ្ញោជនានំ បហានាយ ។ បុន ចបរំ អានន្ទ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ

មិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្តីត្រេកអរចំពោះធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលអានន្ទ មគ្គនេះឯង បដិបទានេះឯង ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈ ៥ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុកន្លងបង់នូវអាកាសានញ្ចាយតនៈ ដោយសព្វអន្លើហើយ ចូលកាន់វិញ្ញាណញ្ចាយតនៈ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ។ ភិក្ខុនោះពិចារណានូវពួកធម៌ គឺ វេទនា ។ បេ ។ ដើម្បីលះបង់នូវសំយោជនៈទាំងឡាយ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុកន្លងបង់នូវវិញ្ញាណញ្ចាយតនៈ ដោយសព្វអន្លើហើយ ទើបចូលកាន់អាកិញ្ចញ្ញាយតនៈ ដោយបរិកម្មថា អ្វីបន្តិចបន្តួច មិនមាន ។ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់នូវពួកធម៌ គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងខណៈដែលចូលសមាបត្តិនោះ ថាជារបស់មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាព្រួញ

២៧៤



អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ ។ សោ តេហិ ធម្មេហិ ចិត្តំ បដិបាបេតិ សោ តេហិ ធម្មេហិ ចិត្តំ បដិបាបេត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ សោ តត្ថដ្ឋិតោ អាសវា ខយំ បាបុណាតិ នោ ចេ អាសវានំ ខយំ បាបុណាតិ តេនេវ ធម្មរាគេន តាយ ធម្មនន្ទិយា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ អយំ ខោ អានន្ទ មគ្គោ អយំ បដិបទា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បហានាយាតិ ។

ជាសេចក្ដីមិនសប្បាយ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សាបសូន្យ ជារបស់មិនស្ដាប់បង្គាប់ចិត្ត ។ ភិក្ខុនោះរមែងដោះចិត្តចាកធម៌ទាំងនោះបាន លុះភិក្ខុនោះបានដោះចិត្តចាកធម៌ទាំងនោះហើយ រមែងបង្អោនចិត្តទៅក្នុងអមតធាតុថា ការរម្ងាប់បង់នូវសង្ខារទាំងពួង ការលះបង់នូវឧបធិក្កិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្ដីនឿយណាយ សេចក្ដីរលត់តណ្ហាគឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជារបស់ល្អិត ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរល្អ ។ ភិក្ខុនោះបានឋិតនៅក្នុងវិបស្សនា ដែលមានព្រះត្រៃលក្ខណ៍ជាអារម្មណ៍ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើបែរជាមិនបានដល់នូវការអស់ទៅនៃអាសវៈទាំងនោះទេ ក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្ដីត្រេកអរក្នុងធម៌នោះ ព្រោះសេចក្ដីរីករាយក្នុងធម៌នោះ ព្រោះការអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលអានន្ទ មគ្គនេះឯង បដិបទានេះឯងហើយ ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈ ៥ ។

[១៩៩] ឯសោ ចេ ភន្តេ មគ្គោ ឯសា បដិបទា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បហានាយ អថ កិញ្ចរហិ ឯកេកច្ចេ ភិក្ខូ ចេតោវិមុត្តិនោ ឯកច្ចេ ភិក្ខូ[១] បញ្ញាវិមុត្តិនោតិ ។ ឯត្ថ ខោ តេសាហំ អានន្ទ ឥន្ទ្រិយវេមត្តតំ វទាមីតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

មហាមាលុង្ក្យោវាទសុត្តំ ចតុត្ថំ និដ្ឋិតំ ។

---

១ ឱ. ភិក្ខូតិ ន ទិស្សតិ ។

[១៥៩] ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើមគ្គនុ៎ះ បដិបទានុ៎ះ ប្រព្រឹត្តទៅដើម្បីលះបង់ នូវឱរម្ភាគិយសំយោជនៈ ៥ បាន កាលបើដូច្នេះ ចុះហេតុដូចម្តេច បានជាក្នុងសាសនានេះ មានពួកភិក្ខុខ្លះ ជាចេតោវិមុត្តិ ពួកភិក្ខុខ្លះ ជាបញ្ញាវិមុត្តិ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ក្នុងសាសនានេះឯង តថាគតពោលថា ពួកភិក្ខុទាំងនោះ មានឥន្ទ្រិយផ្សេង ៗ គ្នា ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុក៏រីករាយ ត្រេកអរនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ មហាមាលុង្ក្យោវាទសូត្រ ជាគម្រប់ ៤ ។

# បញ្ចមំ ភទ្ទាលិសុត្តំ

[១៦០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អហំ ខោ ភិក្ខវេ ឯកាសនភោជនំ ភុញ្ជាមិ ឯកាសនភោជនំ ខោ អហំ ភិក្ខវេ ភុញ្ជមានោ អប្បាពាធតញ្ច សញ្ជានាមិ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ច អថ តុម្ហេបិ ភិក្ខវេ ឯកាសនភោជនំ ភុញ្ជថ ឯកាសនភោជនំ ខោ ភិក្ខវេ តុម្ហេបិ ភុញ្ជមានា អប្បាពាធតញ្ច សញ្ជានិស្សថ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ចាតិ ។

# ភទ្ទាលិសូត្រ ទី ៥

[១៦០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតតែងឆាន់ភោជន ដែលគួរបរិ-ភោគតែមួយពេល ម្នាលភិក្ខុទាំងឡាយ កាលតថាគតឆាន់ភោជន ដែលគួរបរិភោគតែមួយពេល ក៏បានដឹងច្បាស់នូវភាពមិនមានអាពាធ មិនមានទុក្ខ ការងើបក្រោកដោយរហ័ស កម្លាំងកាយ និងការនៅសប្បាយដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកមកណោះ ចូរបរិភោគភោជន ដែលគួរបរិភោគតែមួយពេលចុះ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយបរិភោគភោជន ដែលគួរបរិភោគតែមួយពេលហើយ មុខជានឹងបានដឹងច្បាស់ នូវភាពមិនមានអាពាធ មិនមានទុក្ខ ការងើបក្រោកដោយរហ័ស កម្លាំងកាយ និងការនៅសប្បាយដោយឥរិយាបថទាំង ៤ ។

[១៦១] ឯវំ វុត្តេ អាយស្មា ភទ្ទាលិ ភគវន្តំ ឯតទវោច អហំ ខោ ភន្តេ ន ឧស្សហាមិ ឯកាសនភោជនំ ភុញ្ជិតុំ ឯកាសនភោជនញ្ហិ មេ ភន្តេ ភុញ្ជតោ សិយា កុក្កុច្ចំ សិយា វិប្បដិសារោតិ ។ តេនហិ ត្វំ ភទ្ទាលិ យត្ថ និមន្តិតោ អស្សសិ តត្ថ ឯកទេសំ ភុញ្ជិត្វា ឯកទេសំ នីហរិត្វាបិ បរិភុញ្ជេយ្យាសិ ឯវម្បិ ខោ ត្វំ ភទ្ទាលិ ភុញ្ជមានោ បេស្សសីតិ ។ ឯវម្បិ ខោ អហំ ភន្តេ ន ឧស្សហាមិ ភុញ្ជិតុំ ឯវម្បិ ហិ មេ ភន្តេ ភុញ្ជតោ សិយា កុក្កុច្ចំ សិយា វិប្បដិសារោតិ ។ អថខោ អាយស្មា ភទ្ទាលិ ភគវតា សិក្ខាបទេ បញ្ញាបិយមានេ ភិក្ខុសង្ឃេ សិក្ខំ សមាទិយមានេ អនុស្សាហំ បវេទេសិ ។ អថខោ អាយស្មា ភទ្ទាលិ សព្វន្តំ តេមាសំ ន ភគវតោ សម្មុខីភាវំ ភទ្ទាលិ យថាតំ សត្ថុ សាសនេ សិក្ខាយ អបរិបូរការី[១] ។

១ អបរិបូរិការីបីតិ បាហោ ។

[១៦១] កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះភទ្ទាលិមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចនឹងបរិភោគភោជន ដែលគួរបរិភោគតែមួយពេលបានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាកាលបើខ្ញុំព្រះអង្គបរិភោគភោជន ដែលគួរបរិភោគតែមួយពេលហើយ សេចក្តីរសាប់រសល់ក៏មាន សេចក្តីក្តៅក្រហាយក៏មាន ។ ព្រះអង្គត្រាស់ថា ម្នាលភទ្ទាលិ បើដូច្នោះ គេនិមន្តអ្នកឆាន់ក្នុងទីណា អ្នកគប្បីបរិភោគតែបន្តិចបន្តួច ឬរំលែកយកមកបរិភោគតែបន្តិចបន្តួចក្នុងទីនោះ ម្នាលភទ្ទាលិ កាលបើអ្នកបរិភោគយ៉ាងនេះហើយ ក៏គង់ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។ ភទ្ទាលិក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាចនឹងបរិភោគយ៉ាងនេះបានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាកាលបើខ្ញុំព្រះអង្គបរិភោគយ៉ាងនេះហើយ សេចក្តីរសាប់រសល់ក៏មាន សេចក្តីក្តៅក្រហាយក៏មាន ។ គ្រាកាលដែលព្រះមានព្រះភាគ កំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទាននូវសិក្ខា ព្រះភទ្ទាលិមានអាយុក៏ក្រាបទូលនូវសេចក្តីមិនអាចធ្វើតាមបាន ។ លំដាប់នោះឯង ព្រះភទ្ទាលិមានអាយុ លែងឲ្យជួបព្រះភក្ត្រព្រះមានព្រះភាគ ពេញ ៣ ខែគត់ លែងបំពេញសិក្ខាក្នុងសាសនា របស់ព្រះសាស្តាដោយដាច់ស្រឡះ ។

ភិក្ខុវគ្គស្ស ភទ្ទាលិសុត្តេ ចីវរកម្មករណំ

[១៦២] តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ភគវតោ ចីវរកម្មំ ករោន្តិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ អថខោ អាយស្មា ភទ្ទាលិ យេ តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេហិ ភិក្ខូហិ សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ភទ្ទាលឹ តេ ភិក្ខូ ឯតទវោចុំ ឥទំ ខោ អាវុសោ ភទ្ទាលិ ភគវតោ ចីវរកម្មំ ករីយតិ និដ្ឋិតចីវរោ ភគវា តេមាសច្ចយេន ចារិកំ បក្កមិស្សតីតិ ។ ឥង្ឃាវុសោ ភទ្ទាលិ ឯតំ ទេសំ សាធុកំ មនសិករោហិ មា តេ បច្ឆា ទុក្ករតរំ អហោសីតិ ។ ឯវមាវុសោតិ ខោ អាយស្មា ភទ្ទាលិ តេសំ ភិក្ខូនំ បដិស្សុត្វា

ភិក្ខុវគ្គ ភទ្ទាលិសូត្រ ការធ្វើចីវរកម្ម

[១៦២] សម័យនោះឯង ភិក្ខុទាំងឡាយមានប្រមាណច្រើនរូប នាំគ្នាធ្វើចីវរកម្ម ថ្វាយព្រះមានព្រះភាគ ដោយព្រះមានព្រះភាគ មានចីវរសម្រេចហើយ កន្លង ៣ ខែទៅ ព្រះអង្គបម្រុងនឹងស្ដេចចេញទៅកាន់ចារិក ។ គ្រានោះឯង ព្រះភទ្ទាលិមានអាយុ បានចូលទៅរកពួកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល មួយអន្លើដោយពួកភិក្ខុទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ទើបអង្គុយក្នុងទីសមគួរ ។ លុះព្រះភទ្ទាលិមានអាយុ អង្គុយក្នុងទីសមគួរហើយ ភិក្ខុទាំងឡាយនោះក៏នាំគ្នានិយាយយ៉ាងនេះថា ម្នាលអាវុសោភទ្ទាលិ ចីវរកម្មនេះឯងដែលយើងទាំងឡាយធ្វើថ្វាយព្រះមានព្រះភាគ លុះព្រះមានព្រះភាគ មានចីវរកម្មសម្រេចហើយ កន្លង ៣ ខែទៅ ទ្រង់នឹងស្ដេចចេញទៅកាន់ចារិក ។ ម្នាលភទ្ទាលិមានអាយុ យើងសូមដាស់តឿន ចូរលោកយកចិត្តទុកដាក់នឹងកំហុស (ចំពោះសិក្ខាបទដែលព្រះសាស្ដាទ្រង់បញ្ញត្ត) នុ៎ះ ឲ្យប្រពៃចុះ អ្នកកុំធ្វើឲ្យលំបាក ក្នុងកាលជាខាងក្រោយឡើយ ។ ព្រះភទ្ទាលិមានអាយុ ក៏ទទួលពាក្យពួកភិក្ខុទាំងនោះថា ករុណាអាវុសោ ដូច្នេះហើយ

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ភទ្ទាលិ ភគវន្តំ ឯតទវោច អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោហំ ភគវតា សិក្ខាបទេ បញ្ញាបិយមានេ ភិក្ខុសង្ឃេ សិក្ខំ សមាទិយមានេ អនុស្សាហំ បវេទេសឹ[១] តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។

[១៦៣] តគ្ឃ ត្វំ ភទ្ទាលិ អច្ចយោ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យំ ត្វំ មយា សិក្ខាបទេ បញ្ញាបិយមានេ ភិក្ខុសង្ឃេ សិក្ខំ សមាទិយមានេ អនុស្សាហំ បវេទេសិ ។ សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ ភគវា ខោ សាវត្ថិយំ វិហរតិ ភគវាបិ មំ ជានិស្សតិ ភទ្ទាលិ នាម ភិក្ខុ សត្ថុ សាសនេ សិក្ខាយ អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ

១ ម. បវេទេមិ ។

ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចទើបអង្គុយក្នុងទីសមគួរ ។ លុះព្រះភទ្ទាលិមានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទោសគ្របសង្កត់ខ្ញុំព្រះអង្គ ដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាស ព្រោះកាលព្រះមានព្រះភាគកំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា ខ្ញុំព្រះអង្គក៏បានក្រាបទូល នូវសេចក្តីមិនអាចធ្វើតាមបាន បពិត្រព្រះអង្គដ៏ចម្រើនសូមព្រះមានព្រះភាគ អត់ទោសចំពោះកំហុស តាមទោសរបស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅទៀត ។

[១៦៣] ព្រះអង្គទ្រង់ត្រាស់ថា អើភទ្ទាលិ ទោសគ្របសង្កត់អ្នកដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាសពិតមែនហើយ ព្រោះកាលដែលតថាគតកំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា អ្នកបានប្រាប់នូវសេចក្តីមិនអាចធ្វើតាមបាន ។ ម្នាលភទ្ទាលិអ្នកមិនបានដឹងហេតុថា ព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី តែព្រះមានព្រះភាគ គង់ដឹងអាត្មាអញថា ភិក្ខុឈ្មោះភទ្ទាលិ មិនបានបំពេញសិក្ខាក្នុងសាសនា របស់ព្រះសាស្តាដូច្នេះឡើយ ម្នាលភទ្ទាលិ នេះឯង

២៨១



សមយោ អប្បដិវិទ្ធោ អហោសិ ។ សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ សម្ពហុលា ខោ ភិក្ខូ សាវត្ថិយំ វស្សំ ឧបគតា តេបិ មំ ជានិស្សន្តិ ភទ្ទាលិ នាម ភិក្ខុ សត្ថុ សាសនេ សិក្ខាយ អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសិ ។ សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ សម្ពហុលា ខោ ភិក្ខុនិយោ សាវត្ថិយំ វស្សំ ឧបគតា តាបិ មំ ជានិស្សន្តិ ភទ្ទាលិ នាម ភិក្ខុ សត្ថុ សាសនេ សិក្ខាយ អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសិ ។ សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ សម្ពហុលា ខោ ឧបាសកា សាវត្ថិយំ បដិវសន្តិ តេបិ មំ ជានិស្សន្តិ ភទ្ទាលិ នាម ភិក្ខុ សត្ថុ សាសនេ សិក្ខាយ អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសិ ។ សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ សម្ពហុលា ខោ ឧបាសិកា សាវត្ថិយំ បដិវសន្តិ តាបិ មំ ជានិស្សន្តិ ភទ្ទាលិ នាម ភិក្ខុ

ជាហេតុដែលអ្នកមិនបានដឹង ។ ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ពួកភិក្ខុច្រើនរូប នៅចាំវស្សាក្នុងក្រុងសាវត្ថី សូម្បីភិក្ខុទាំងនោះ គង់ដឹង អាត្មាអញថា ភទ្ទាលិភិក្ខុ មិនបានបំពេញសិក្ខាក្នុងសាសនា របស់ព្រះសាស្តាដូច្នេះឡើយ ម្នាលភទ្ទាលិ នេះឯងជាហេតុដែលអ្នកមិនបានដឹង ។ ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ពួកភិក្ខុនីមានប្រមាណច្រើនរូប នៅចាំវស្សាក្នុងក្រុងសាវត្ថី សូម្បីភិក្ខុនីទាំងនោះ គង់ដឹងអាត្មាអញថា ភទ្ទាលិភិក្ខុ មិនបានបំពេញសិក្ខាក្នុងសាសនា របស់ព្រះសាស្តាដូច្នេះឡើយ ម្នាលភទ្ទាលិ នេះឯងជាហេតុដែលអ្នកមិនបានដឹង ។ ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ពួកឧបាសកមានប្រមាណច្រើននាក់ ដែលនៅអាស្រ័យក្នុងក្រុងសាវត្ថី សូម្បីពួកឧបាសកទាំងនោះ ក៏គង់ដឹង អាត្មាអញថា ភទ្ទាលិភិក្ខុ មិនបានបំពេញសិក្ខាក្នុងសាសនា របស់ព្រះសាស្តាដូច្នេះឡើយ នេះឯងជាហេតុដែលអ្នកមិនបានដឹង ។ ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ពួកឧបាសិកាច្រើនគ្នាដែលអាស្រ័យនៅក្នុងក្រុងសាវត្ថី សូម្បីពួកឧបាសិកាទាំងនោះ ក៏គង់ដឹងអាត្មាអញថា ភទ្ទាលិភិក្ខុ

សត្ថុ សាសនេ សិក្ខាយ អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសិ ។ សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ សម្ពហុលា ខោ នានាតិត្ថិយា សមណព្រាហ្មណា សាវត្ថិយំ វស្សំ ឧបគតា តេបិ មំ ជានិស្សន្តិ ភទ្ទាលិ នាម ភិក្ខុ សមណស្ស គោតមស្ស សាវកោ ថេរញ្ញតរោ សត្ថុ សាសនេ សិក្ខាយ អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសីតិ ។ អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោហំ ភគវតា សិក្ខាបទេ បញ្ញាបិយមានេ ភិក្ខុសង្ឃេ សិក្ខំ សមាទិយមានេ អនុស្សាហំ បវេទេសឹ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។

មិនបានបំពេញសិក្ខាក្នុងសាសនា របស់ព្រះសាស្តាដូច្នេះឡើយ នេះឯង ជាហេតុដែលអ្នកមិនបានដឹង ។ ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ពួកសមណៈឬព្រាហ្មណ៍ជាតិរិយផ្សេង ៗ មានប្រមាណច្រើនរូប ដែលនៅចាំវស្សាក្នុងក្រុងសាវត្ថី សូម្បីពួកអ្នកទាំងនោះ ក៏គង់ដឹងអាត្មាអញថា ភទ្ទាលិភិក្ខុជាសាវ័ករបស់ព្រះសមណគោតម ជាព្រះថេរៈមួយអង្គមិនបាន បំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តាដូច្នេះឡើយ នេះឯងជាហេតុ ដែលអ្នកមិនបានដឹង ។ ព្រះភទ្ទាលិក្រាបបង្គំទូលថា បពិត្រព្រះអង្គ ដ៏ចម្រើន ទោសគ្របសង្កត់នូវខ្ញុំព្រះអង្គ ដែលជាមនុស្សពាល ជាមនុស្ស ល្ងង់ ជាមនុស្សមិនឈ្លាស ព្រោះកាលដែលព្រះមានព្រះភាគ កំពុង បញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា ខ្ញុំព្រះអង្គបានក្រាប ទូលនូវសេចក្តីមិនអាចធ្វើតាមបាន ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះ មានព្រះភាគ អត់ទោសចំពោះកំហុសតាមទោស របស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅ ។

[១៦៤] តស្ស តំ ភទ្ទាលិ អច្ចយោ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យំ ត្វំ មយា សិក្ខាបទេ បញ្ញាបិយមានេ ភិក្ខុសង្ឃេ សិក្ខំ សមាទិយមានេ អនុស្សាហំ បវេទេសិ ។ តំ កិំ មញ្ញសិ ភទ្ទាលិ ឥធស្ស ភិក្ខុ ឧភតោភាគវិមុត្តោ តមហំ ឯវំ វទេយ្យំ ឯហិ មេ ត្វំ ភិក្ខុ បង្កេ សង្កមោ ហោតីតិ អបិ នុ ខោ[១] សោ សង្កមេយ្យ វា អញ្ញេន វា កាយំ សន្នាមេយ្យ នោតិ វា វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិំ មញ្ញសិ ភទ្ទាលិ ឥធស្ស ភិក្ខុ បញ្ញាវិមុត្តោ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ធម្មានុសារី សទ្ធានុសារី តមហំ ឯវំ វទេយ្យំ ឯហិ មេ ត្វំ ខោ[២] សោ សង្កមេយ្យ វា អញ្ញេន វា កាយំ សន្នាមេយ្យ នោតិ វា វទេយ្យាតិ ។

---

១-២ ឱ. ខោសទ្ទោ នត្ថិ ។

[១៦៤] ព្រះអង្គទ្រង់ត្រាស់ថា អើភទ្ទាលិ ទោសគ្របសង្កត់អ្នកដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាស ពិតមែនហើយ ព្រោះកាលដែលតថាគត កំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា អ្នកក៏បានប្រាប់ នូវសេចក្តីមិនអាចនឹងធ្វើតាមបាន ។ ម្នាលភទ្ទាលិ អ្នកសំគាល់ហេតុនោះថាដូចម្តេច ភិក្ខុក្នុងសាសនានេះ ជាឧភតោភាគវិមុត្ត តថាគតនិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលភិក្ខុ អ្នកចូរមកចុះ ស្ពានរបស់តថាគតមានក្នុងភក់ដូច្នេះ តើភិក្ខុនោះគប្បីទៅខ្លួនឯង ឬប្រើអ្នកដទៃឲ្យប្រានកាយរបស់ខ្លួន ឬគប្បីពោលប្រកែកថាទេ ។ ព្រះភទ្ទាលិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនគួរទេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភទ្ទាលិ អ្នកសំគាល់ហេតុនោះថាដូចម្តេច ភិក្ខុក្នុងសាសនានេះ ជាបញ្ញាវិមុត្តបុគ្គល ជាកាយសក្ខីបុគ្គល ជាទិដ្ឋិប្បត្តបុគ្គល ជាសទ្ធាវិមុត្តបុគ្គល ជាធម្មានុសារីបុគ្គល ជាសទ្ធានុសារីបុគ្គល[១] តថាគតនិយាយនឹងបុគ្គលនោះយ៉ាងនេះថា ម្នាលភិក្ខុ អ្នកចូរមកចុះ ស្ពានរបស់តថាគតមានក្នុងភក់ដូច្នេះ តើភិក្ខុនោះគប្បីដើរទៅខ្លួនឯង ឬប្រើអ្នកដទៃឲ្យប្រានកាយរបស់ខ្លួន ឬគប្បីពោលប្រកែកថាទេ ។

---

១ សេចក្តីអធិប្បាយអំពីបុគ្គលទាំងនេះ ចូរមើលនយលក្ខណៈក្នុងសម្បសាទនីយសូត្រ ទីឃនិកាយ បាដិកវគ្គ ផងចុះ ។

នោ ហេតំ ភន្តេ ។ តំ កឹ មញ្ញសិ ភទ្ទាលិ អបិ នុ ត្វំ ភទ្ទាលិ[១] តស្មឹ សមយេ ឧភតោភាគវិមុត្តោ វា ហោសិ បញ្ញាវិមុត្តោ វា កាយសក្ខី វា ទិដ្ឋិប្បត្តោ វា សទ្ធាវិមុត្តោ វា ធម្មានុសារី វា សទ្ធានុសារី វាតិ ។ នោ ហេតំ ភន្តេ ។ ននុ ត្វំ ភទ្ទាលិ តស្មឹ សមយេ រិត្តោ តុច្ឆោ អបរទ្ធោតិ ។ ឯវំ ភន្តេ អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោហំ ភគវតា សិក្ខាបទេ បញ្ញាបិយមានេ ភិក្ខុសង្ឃេ សិក្ខំ សមាទិយមានេ អនុស្សាហំ បវេទេសឹ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។

១ ម. ភទ្ទាលីតិ ន ទិស្សតិ ។

ព្រះភទ្ទាលិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនគួរទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភទ្ទាលិ អ្នកសំគាល់ហេតុនោះដូចម្តេច ម្នាលភទ្ទាលិ ក្នុងសម័យនោះ អ្នកបានជាឧភតោភាគវិមុត្តបុគ្គល ឬបានជាបញ្ញាវិមុត្តបុគ្គល ជាកាយសក្ខីបុគ្គល ជាទិដ្ឋិប្បត្តបុគ្គល ជាសទ្ធាវិមុត្តបុគ្គល ជាធម្មានុសារីបុគ្គល ជាសទ្ធានុសារីបុគ្គលដែរឬ ។ ព្រះភទ្ទាលិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនុ៎ះមិនមានទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភទ្ទាលិ ចុះមានតែក្នុងសម័យនោះ អ្នកជាបុគ្គលសោះសូន្យ ជាមនុស្សទទេ មានកំហុសទេឬ ។ ព្រះភទ្ទាលិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែនហើយ បពិត្រព្រះអង្គដ៏ចម្រើន ទោសគ្របសង្កត់នូវខ្ញុំព្រះអង្គ ដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាស ព្រោះកាលដែលព្រះមានព្រះភាគកំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា ខ្ញុំព្រះអង្គក៏ក្រាបទូលនូវសេចក្តីមិនអាចនឹងធ្វើតាមបាន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់អត់ទោសចំពោះកំហុស តាមកំហុសរបស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅទៀត ។

[១៦៥] តគ្ឃ ត្វំ ភទ្ទាលិ អច្ចយោ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យំ ត្វំ មយា សិក្ខាបទេ បញ្ញាបិយមានេ ភិក្ខុសង្ឃេ សិក្ខំ សមាទិយមានេ អនុស្សាហំ បវេទេសិ យតោ ច ខោ ត្វំ ភទ្ទាលិ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តន្តេ មយំ បដិគ្គណ្ហាម វុឌ្ឍិ ហេសា ភទ្ទាលិ អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតិ ។

[១៦៦] ឥធ ភទ្ទាលិ ឯកច្ចោ ភិក្ខុ សត្ថុ សាសនេ សិក្ខាយ[១] អបរិបូរការី ហោតិ តស្ស ឯវំ ហោតិ យន្នូនាហំ វិវិត្តំ សេនាសនំ ភជេយ្យំ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ អប្បេវនាមាហំ ឧត្តរឹ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសំ សច្ឆិករេយ្យន្តិ ។ សោ វិវិត្តំ សេនាសនំ ភជតិ

១ ឱ. សិក្ខាយាតិ ន ទិស្សតិ ។

ភិក្ខុវគ្គ ភទ្ទាលិសូត្រ ការមិនបានបំពេញសិក្ខា

[១៦៥] ព្រះអង្គទ្រង់ត្រាស់ថា អើភទ្ទាលិ ទោសគ្របសង្កត់នូវអ្នកដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាសពិតមែនហើយ ព្រោះកាលដែលតថាគតកំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា អ្នកបានប្រាប់ នូវសេចក្តីមិនអាចនឹងធ្វើតាមបាន ម្នាលភទ្ទាលិ កាលណាអ្នកបានឃើញទោសតាមទោសហើយ ត្រឡប់មកធ្វើតាមធម៌គឺសូមខមាទោស តថាគតនឹងអត់ទោសចំពោះកំហុសនោះដល់អ្នក ម្នាលភទ្ទាលិ ព្រោះថា បុគ្គលដែលបានឃើញទោសតាមទោសហើយត្រឡប់មកធ្វើតាមធម៌គឺសូមខមាទោសវិញ ទើបដល់នូវការសង្រួមតទៅ នេះឯងជាសេចក្តីចម្រើន ក្នុងវិន័យរបស់ព្រះអរិយៈ ។

[១៦៦] ម្នាលភទ្ទាលិ ភិក្ខុពួកខ្លះក្នុងសាសនានេះ មិនបានបំពេញសិក្ខាក្នុងសាសនា របស់ព្រះសាស្តាទេ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ គប់រកសេនាសនៈស្ងាត់គឺព្រៃម្ញប់ឈើ ភ្នំ ជ្រោះភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង (កាលបើនៅក្នុងទីដូច្នេះ) មុខជាអាត្មាអញនឹងធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរ អាចកម្ចាត់បង់នូវកិលេសដ៏ក្រៃលែងជាងមនុស្សធម៌ ។ ភិក្ខុនោះក៏គប់រកសេនាសនៈស្ងាត់ គឺ

អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ តស្ស តថា វូបកដ្ឋស្ស វិហរតោ សត្ថាបិ ឧបវទតិ អនុវិច្ច វិញ្ញូ សព្រហ្មចារី ឧបវទន្តិ ទេវតាបិ ឧបវទន្តិ អត្តាបិ[១] អត្តានំ ឧបវទតិ សោ សត្ថារាបិ ឧបវទិតោ អនុវិច្ច វិញ្ញូហិ សព្រហ្មចារីហិ ឧបវទិតោ ទេវតាហិបិ ឧបវទិតោ អត្តនាបិ អត្តា[២] ឧបវទិតោ ន ឧត្តរឹ មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សច្ឆិ-ករោតិ តំ កិស្ស ហេតុ ឯវញ្ហេតំ[៣] ភទ្ទាលិ ហោតិ យថាតំ សត្ថុ សាសនេ សិក្ខាយ អបរិបូរការិស្ស ។

[១៦៧] ឥធ បន ភទ្ទាលិ ឯកច្ចោ ភិក្ខុ សត្ថុ សាសនេ សិក្ខាយ បរិបូរការី ហោតិ តស្ស ឯវំ ហោតិ យន្នូនាហំ វិវិត្តំ សេនាសនំ ភជេយ្យំ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ

---

១ ម. អត្តនាបិ ។ ២ ឱ. អត្តានំ ។ ៣ ម. ឯវញ្ហិទំ ។

ព្រៃ ម្ចប់ឈើ ភ្នំ ជ្រោះភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង កាលបើភិក្ខុនោះចេញទៅនៅដូច្នោះហើយ ព្រះសាស្តាក៏តិះដៀល ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹង បានគយគន់ហើយក៏តិះដៀល ទេវតាទាំងឡាយក៏តិះដៀល ទាំងខ្លួនឯងក៏តិះដៀលខ្លួនឯង បុគ្គលនោះកាលបើព្រះសាស្តាតិះដៀល ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹង បានគយគន់ហើយក៏តិះដៀល ពួកទេវតាក៏តិះដៀលហើយ ទាំងខ្លួនឯងក៏តិះដៀលខ្លួនឯងហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរ អាចកម្ចាត់បង់នូវកិលេសក៏ក្រៃលែងជាងមនុស្សធម៌ មិនបានឡើយ ដំណើរនុ៎ះតើព្រោះហេតុអ្វី ម្នាលភទ្ទាលិ ព្រោះហេតុតែភិក្ខុនោះមិនបានបំពេញសិក្ខាក្នុងសាសនា របស់ព្រះសាស្តានុ៎ះឯងដោយពិត ។

[១៦៧] ម្នាលភទ្ទាលិ មួយទៀត ភិក្ខុពួកខ្លះក្នុងសាសនានេះ បានបំពេញសិក្ខាក្នុងសាសនា របស់ព្រះសាស្តា ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរអាត្មាអញ គប់រកនូវសេនាសនៈស្ងាត់ គឺព្រៃ ម្ចប់ឈើ ភ្នំ ជ្រោះភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ

២៨៧



អព្ភោកាសំ បលាលបុញ្ជំ អប្បេវនាមាហំ ឧត្តរឹ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសំ សច្ឆិករេយ្យន្តិ ។ សោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ តស្ស តថា វូបកដ្ឋស្ស វិហរតោ សត្ថាបិ ន ឧបវទតិ អនុវិច្ច វិញ្ញូ សព្រហ្មចារី ន ឧបវទន្តិ ទេវតាបិ ន ឧបវទន្តិ អត្តាបិ អត្តានំ ន ឧបវទតិ សោ សត្ថាភបិ អនុបវទិតោ អនុវិច្ច វិញ្ញូហិ សព្រហ្មចារីហិ អនុបវទិតោ ទេវតាហិបិ អនុបវទិតោ អត្តនាបិ អត្តា អនុបវទិតោ ឧត្តរឹ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសំ សច្ឆិករោតិ ។ សោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ តំ កិស្ស ហេតុ ឯវញ្ហេតំ ភទ្ទាលិ ហោតិ យថាតំ សត្ថុ សាសនេ សិក្ខាយ បរិបូរការិស្ស ។ បុន ចបរំ ភទ្ទាលិ ភិក្ខុ

ទីវាល គំនរចំបើង គួរតែអាត្មាអញ ធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរ អាចកម្ចាត់បង់នូវកិលេស ដ៏ក្រៃលែងជាង មនុស្សធម៌ ។ ភិក្ខុនោះ ក៏គប់រកសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរ ចំបើង កាលបើភិក្ខុនោះ ចេញទៅនៅដូច្នេះហើយ ព្រះសាស្តាក៏មិន តិះដៀល ពួកសព្រហ្មចារីបុគ្គល ជាអ្នកចេះដឹង បានគយគន់ហើយ ក៏មិនតិះដៀល ពួកទេវតាក៏មិនតិះដៀល ទាំងខ្លួនឯងក៏មិនតិះដៀលខ្លួន ឯង បុគ្គលនោះកាលបើព្រះសាស្តាមិនតិះដៀល ពួកសព្រហ្មចារីបុគ្គល ជាអ្នកចេះដឹង បានគយគន់ហើយ ក៏មិនតិះដៀល ពួកទេវតាក៏មិនតិះ ដៀល ទាំងខ្លួនឯងក៏មិនតិះដៀលខ្លួនឯងហើយ រមែងធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរ អាចកម្ចាត់បង់នូវកិលេស ដ៏ក្រៃលែងជាងមនុស្សធម៌បាន ។ ភិក្ខុនោះ រមែងស្ងប់ស្ងាត់ចាកកាម ស្ងប់ស្ងាត់ចាកអកុសលធម៌ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈនិង វិចារៈ មានតែបីតិនិងសុខដែលកើតអំពីវិវេក ដំណើរនុ៎ះតើព្រោះហេតុ អ្វី ម្នាលភទ្ទាលិ ព្រោះហេតុតែភិក្ខុនោះ បានបំពេញសិក្ខាក្នុងសាសនា របស់ព្រះសាស្តា យ៉ាងនោះឯង ។ ម្នាលភទ្ទាលិ មួយទៀត ភិក្ខុ

វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ តំ កិស្ស ហេតុ ឯវញ្ហេតំ ភទ្ទាលិ ហោតិ យថាតំ សត្ថុ សាសនេ សិក្ខាយ បរិបូរការិស្ស ។ បុន ចបរំ ភទ្ទាលិ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ តំ កិស្ស ហេតុ ឯវញ្ហេតំ ភទ្ទាលិ ហោតិ យថាតំ សត្ថុ សាសនេ សិក្ខាយ បរិបូរការិស្ស ។ បុន ចបរំ ភទ្ទាលិ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តំ កិស្ស ហេតុ ឯវញ្ហេតំ ភទ្ទាលិ ហោតិ យថាតំ សត្ថុ សាសនេ សិក្ខាយ បរិបូរការិស្ស ។

[១៦៨] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ

ព្រោះបានរម្ងាប់នូវវិតក្កៈនិងវិចារៈ ក៏ចូលកាន់ទុតិយជ្ឈាន ជាទីផូរផង់ក្នុងសន្ដាន មានភាពនៃចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខ ដែលកើតអំពីសមាធិប៉ុណ្ណោះ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភទ្ទាលិ ព្រោះហេតុតែភិក្ខុនោះ ជាអ្នកបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្ដា យ៉ាងនោះឯង ។ ម្នាលភទ្ទាលិ មួយទៀត ភិក្ខុព្រោះប្រាសចាកបីតិ ។ បេ ។ ចូលកាន់តតិយជ្ឈាន ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះហេតុតែភិក្ខុនោះ ជាអ្នកបំពេញនូវសិក្ខា ក្នុងសាសនារបស់ព្រះសាស្ដា យ៉ាងនោះឯង ។ ម្នាលភទ្ទាលិ មួយទៀត ភិក្ខុព្រោះលះបង់សេចក្ដីសុខ ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភទ្ទាលិ ព្រោះហេតុតែភិក្ខុនោះ ជាអ្នកបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្ដា យ៉ាងនោះឯង ។

[១៦៨] កាលបើចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ ឥតមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់

កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្ស-តិញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ តំ កិស្ស ហេតុ ឯវញ្ហេតំ ភទ្ទាលិ ហោតិ យថាតំ សត្ថុ សាសនេ សិក្ខាយ បរិបូរការិស្ស ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ

ភាវនាកម្ម ជាចិត្តនឹងធឹង មិនបានញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ភិក្ខុនោះរមែងបង្អោនចិត្តទៅរកបុព្វេនិវាសានុស្សតិញ្ញាណ ។ ភិក្ខុនោះរមែងរលឹកឃើញនូវជាតិ ដែលធ្លាប់អាស្រ័យក្នុងភពមុនជាច្រើនជាតិ គឺរលឹកឃើញមួយជាតិ ។ បេ ។ រលឹកឃើញនូវជាតិ ដែលធ្លាប់អាស្រ័យនៅ ក្នុងភពមុនបានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភទ្ទាលិ ព្រោះហេតុតែភិក្ខុនោះជាអ្នកបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា យ៉ាងនោះឯង ។ កាលបើចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ ឥតមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនបានញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះរមែងបង្អោនចិត្តទៅរកចុតូបបាតញ្ញាណ របស់សត្វទាំង-ឡាយ ។ ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា បានឃើញសត្វទាំងឡាយ ដែលច្យុត ដែលកើត ថោកទាបឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួនថា ឱហ្ន៎

សត្តា កាយទុច្ចរិតេន សមន្នាគតោ ។ បេ ។ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា ។ បេ ។ សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ តំ កិស្ស ហេតុ ឯវញ្ហេតំ ភទ្ទាលិ ហោតិ យថាតំ សត្ថុ សាសនេ សិក្ខាយ បរិបូរការិស្ស ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិ-និន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថា-ភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាស-វនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។

សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ។ បេ ។ ហើយកើតក្នុងកំណើតអសុរកាយ នរក ។ បេ ។ ចំណែកខាងសត្វទាំងឡាយនេះ ប្រកបដោយកាយសុចរិត ។ បេ ។ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ភិក្ខុដែលមានចក្ខុ ដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា ។ បេ ។ រមែងដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួនដូច្នេះឯង ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភទ្ទាលិ ព្រោះហេតុតែភិក្ខុនោះ ជាអ្នកបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តាយ៉ាងនោះឯង ។ កាលបើចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ ឥតមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនបានញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ភិក្ខុនោះរមែងបង្អោនចិត្តទៅរកអាសវក្ខយញ្ញាណ ។ ភិក្ខុនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាអាសវៈ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាសេចក្តីរលត់នៃអាសវៈ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទា ជាដំណើរដើម្បីរលត់នៃអាសវៈ ។

តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ទិដ្ឋាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ តំ កិស្ស ហេតុ ឯវញ្ហេតំ ភទ្ទាលិ ហោតិ យថាតំ សត្ថុ សាសនេ សិក្ខាយ បរិបូរការិស្សាតិ ។ ឯវំ វុត្តេ អាយស្មា ភទ្ទាលិ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនមិធេកច្ចំ ភិក្ខុំ បសយ្ហ បសយ្ហ ការណំ ករោន្តិ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេនមិធេកច្ចំ ភិក្ខុំ នោ តថា បសយ្ហ បសយ្ហ ការណំ ករោន្តីតិ ។

កាលភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏រួចស្រឡះចាកកាមាសវៈផង ចិត្តក៏រួចចាកទិដ្ឋាសវៈផង ចិត្តក៏រួចចាកភវាសវៈផង ចិត្តក៏រួចស្រឡះចាកអវិជ្ជាសវៈផង កាលបើចិត្តរួចស្រឡះ ប្រាជ្ញាក៏កើតមានឡើងថា (ចិត្តរបស់អាត្មាអញ) រួចស្រឡះហើយ ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើហើយ មគ្គភាវនាកិច្ចដទៃដើម្បីសោឡសកិច្ចនេះមិនមានឡើយ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភទ្ទាលិ ព្រោះហេតុតែភិក្ខុនោះជាអ្នកបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា យ៉ាងនោះឯង ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះភទ្ទាលិមានអាយុ ក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកភិក្ខុធ្វើការសង្កត់សង្កិននូវភិក្ខុពួកខ្លះ ក្នុងសាសនានេះ បពិត្រព្រះអង្គដ៏ចម្រើនមួយទៀត អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកភិក្ខុមិនធ្វើការសង្កត់សង្កិននូវភិក្ខុពួកខ្លះ ក្នុងសាសនានេះ ។

[១៦៩] ឥធ ភន្តេ ឯកច្ចោ ភិក្ខុ អភិណ្ហាបត្តិកោ ហោតិ អាបត្តិពហុលោ សោ ភិក្ខូហិ វុច្ចមានោ អញ្ញេនញ្ញំ[១] បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ន សម្មា វត្តតិ ន លោមំ បាតេតិ ន នេត្ថារំ វត្តតិ យេន សង្ឃោ អត្តមនោ ហោតិ តំ ករោមីតិ នាហ ។ តត្រ ភន្តេ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ អភិណ្ហាបត្តិកោ អាបត្តិពហុលោ សោ ភិក្ខូហិ វុច្ចមានោ អញ្ញេនញ្ញំ បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ន សម្មា វត្តតិ ន លោមំ បាតេតិ ន នេត្ថារំ វត្តតិ យេន សង្ឃោ អត្តមនោ ហោតិ តំ ករោមីតិ នាហ

១ ម. អញ្ញេនាញ្ញំ ។

[១៦៩] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភទ្ទាលិ ភិក្ខុពួកខ្លះក្នុងសាសនានេះ ជាអ្នកត្រូវអាបត្តិរឿយ ៗ ជាអ្នកច្រើនដោយអាបត្តិ កាលពួកភិក្ខុស្តីប្រដៅ ភិក្ខុនោះក៏ពោលបន្ទែបន្ទប់ពាក្យដទៃ ដោយពាក្យដទៃ តែងបោះពាក្យទៅខាងក្រៅ ធ្វើនូវសេចក្តីក្រោធ សេចក្តីប្រទូស្ត សេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើង មិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្ងបរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកអាបត្តិ សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា មិនបានប្រាប់ហេតុនោះថា ខ្ញុំធ្វើដូច្នេះឡើយ ។ ម្នាលភទ្ទាលិ ពួកភិក្ខុមានសេចក្តីត្រិះរិះក្នុងហេតុដែលប្រដៅក្រនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះត្រូវអាបត្តិរឿយ ៗ ច្រើនដោយអាបត្តិ ភិក្ខុនោះកាលពួកភិក្ខុផងគ្នាស្តីប្រដៅ ភិក្ខុនោះក៏ពោលបន្ទែបន្ទប់ពាក្យដទៃដោយពាក្យដទៃ តែងបោះពាក្យទៅខាងក្រៅ ធ្វើនូវសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្ត មិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្ងបរោម មិនប្រ-ព្រឹត្តវត្តគួរដល់កិរិយារើខ្លួនចេញចាកអាបត្តិ សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា មិនប្រាប់ហេតុនោះថា ខ្ញុំធ្វើដូច្នេះឡើយ បពិត្រ

២៩៣



សាធុ វតាយស្មន្តោ ឥមស្ស ភិក្ខុនោ តថា តថា ឧបបរិក្ខថ យថយិទំ[១] អធិករណំ ន ខិប្បមេវ វូបសម្មេយ្យាតិ ។ តស្ស ខោ ឯវំ ភទ្ទាលិ ភិក្ខុនោ ភិក្ខូ តថា តថា ឧបបរិក្ខន្តិ យថយិទំ អធិករណំ ន ខិប្បមេវ វូបសម្មតិ ។ ឥធ បន ភទ្ទាលិ ឯកច្ចោ ភិក្ខុ អភិណ្ហាបត្តិកោ ហោតិ[២] អាបត្តិពហុលោ សោ ភិក្ខូហិ វុច្ចមានោ នាញ្ញេនញ្ញំ បដិចរតិ ពហិទ្ធា កថំ ន អបនាមេតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច ចាតុករោតិ សម្មា វត្តតិ លោមំ ចាតេតិ នេត្ថារំ វត្តតិ យេន សង្ឃោ អត្តមនោ ហោតិ តំ ករោមីតិ អាហ ។ តត្រ ភទ្ទាលិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ អភិណ្ហា-បត្តិកោ អាបត្តិពហុលោ សោ ភិក្ខូហិ វុច្ចមានោ នាញ្ញេនញ្ញំ បដិចរតិ ពហិទ្ធា កថំ ន អបនាមេតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច ចាតុករោតិ សម្មា វត្តតិ លោមំ ចាតេតិ នេត្ថារំ វត្តតិ

---

១ ឱ. យថាស្សិទំ ។ ២ ឱ. ហោតីតិ ន ទិស្សតិ ។

លោកមានអាយុទាំងឡាយ សូមលោកទាំងឡាយ ពិចារណាមើលអធិករណ៍ របស់ភិក្ខុនេះដោយឆាប់រហ័ស តាមទំនងដែលមិនបានរម្ងាប់ដោយឆាប់រហ័សនេះចុះ ។ ម្នាលភទ្ទាលិ ពួកភិក្ខុក៏ពិចារណានូវអធិករណ៍របស់ភិក្ខុនោះតាមទំនង ដែលមិនរម្ងាប់ដោយឆាប់រហ័សយ៉ាងនេះឯង ។ ម្នាលភទ្ទាលិ ចំណែកភិក្ខុពួកខ្លះក្នុងសាសនានេះ ជាអ្នកត្រូវអាបត្តិរឿយ ៗ ជាអ្នកច្រើនដោយអាបត្តិ កាលភិក្ខុទាំងឡាយស្តីប្រដៅ ភិក្ខុនោះក៏មិនពោលបន្ទែបន្ទប់ពាក្យដទៃដោយពាក្យដទៃ មិនបោះពាក្យទៅខាងក្រៅ មិនបានធ្វើនូវសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើយ រមែងប្រព្រឹត្តវត្តដោយប្រពៃ សម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយាវើខ្លួនចេញចាកអាបត្តិ សង្ឃគាប់ចិត្តដោយហេតុណា ក៏ប្រាប់ហេតុនោះថា ខ្ញុំធ្វើ ។ ម្នាលភទ្ទាលិ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះក្នុងហេតុដែលប្រដៅងាយនោះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះជាអ្នកត្រូវអាបត្តិរឿយ ៗ ជាអ្នកច្រើនទៅដោយអាបត្តិ កាលភិក្ខុទាំង-ឡាយស្តីប្រដៅ ភិក្ខុនោះក៏មិនបានពោលបន្ទែបន្ទប់ពាក្យដទៃ ដោយពាក្យដទៃ មិនបានបោះពាក្យទៅខាងក្រៅ ទាំងមិនធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើយ តែងប្រព្រឹត្តវត្ត ដោយប្រពៃ សម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយាវើខ្លួនចេញចាកអាបត្តិ

យេន សង្ឃោ អត្តមនោ ហោតិ តំ ករោមីតិ អាហ សាធុ វតាយស្មន្តោ ឥមស្ស ភិក្ខុនោ តថា តថា ឧបបរិក្ខថ យថយិទំ អធិករណំ ខិប្បមេវ វូបសម្មេយ្យាតិ ។ តស្ស ខោ ឯវំ ភទ្ទាលិ ភិក្ខុនោ ភិក្ខូ តថា តថា ឧបបរិក្ខន្តិ យថយិទំ អធិករណំ ខិប្បមេវ វូបសម្មតិ ។

[១៧០] ឥធ ភទ្ទាលិ ឯកច្ចោ ភិក្ខុ អធិច្ចាបត្តិកោ ហោតិ អនាបត្តិពហុលោ សោ ភិក្ខូហិ វុច្ចមានោ អញ្ញេនញ្ញំ[១] បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ន សម្មា វត្តតិ ន លោមំ បាតេតិ ន នេត្ថារំ វត្តតិ យេន សង្ឃោ អត្តមនោ ហោតិ តំ ករោមីតិ នាហ ។ តត្រ ភទ្ទាលិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ អធិច្ចាបត្តិកោ អនាបត្តិពហុលោ សោ ភិក្ខូហិ វុច្ចមានោ អញ្ញេនញ្ញំ បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ

១ ម. អញ្ញេនាញ្ញំ ។

សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា ក៏ប្រាប់ហេតុនោះថា ខ្ញុំធ្វើ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមលោកទាំងឡាយ ពិចារណាមើលអធិករណ៍របស់ភិក្ខុនេះ តាមទំនងដែលបានរម្ងាប់ដោយឆាប់រហ័សយ៉ាងនេះចុះ ។ ម្នាលភទ្ទាលិ ពួកភិក្ខុក៏ពិចារណានូវអធិករណ៍របស់ភិក្ខុនោះ តាមទំនងដែលបានរម្ងាប់ដោយឆាប់រហ័សយ៉ាងនេះឯង ។

[១៧០] ម្នាលភទ្ទាលិ ភិក្ខុពួកខ្លះក្នុងសាសនានេះ ជាអ្នកត្រូវអាបត្តិក្នុងកាលម្តង ៗ ជាអ្នកមិនច្រើនដោយអាបត្តិ កាលភិក្ខុទាំងឡាយស្តីប្រដៅ ភិក្ខុនោះ រមែងពោលបន្ទែបន្ទប់ពាក្យដទៃដោយពាក្យដទៃ បោះពាក្យទៅខាងក្រៅ ធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើង មិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្ងបរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារើខ្លួនចេញចាកអាបត្តិ សង្ឃមានសេចក្តីពេញចិត្តដោយហេតុណា មិនបានប្រាប់ហេតុនោះថា ខ្ញុំធ្វើដូច្នេះឡើយ ។ ម្នាលភទ្ទាលិ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះ ក្នុងហេតុដែលប្រដៅក្រនោះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះជាអ្នកត្រូវអាបត្តិក្នុងកាលម្តង ៗ ជាអ្នកមិនច្រើនដោយអាបត្តិ កាលភិក្ខុទាំងឡាយស្តីប្រដៅ ភិក្ខុនោះរមែងពោលបន្ទែបន្ទប់ពាក្យដទៃដោយពាក្យដទៃ បោះពាក្យទៅខាងក្រៅធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើង

ន សម្មា វត្តតិ ន លោមំ បាតេតិ ន នេត្ថារំ វត្តតិ យេន សង្ឃោ អត្តមនោ ហោតិ តំ ករោមីតិ នាហ សាធុ វតាយស្មន្តោ ឥមស្ស ភិក្ខុនោ តថា តថា ឧបបរិក្ខថ យថយិទំ អធិករណំ ន ខិប្បមេវ វូបសម្មេយ្យាតិ ។ តស្ស ខោ ឯវំ(១) ភទ្ទាលិ ភិក្ខុនោ ភិក្ខូ តថា តថា ឧបបរិក្ខន្តិ យថយិទំ អធិករណំ ន ខិប្បមេវ វូបសម្មតិ ។ ឥធ បន ភទ្ទាលិ ឯកច្ចោ ភិក្ខុ អភិណ្ហាបត្តិកោ ហោតិ អនាបត្តិពហុលោ សោ ភិក្ខូហិ វុច្ចមានោ នាញ្ញេ-នញ្ញំ បដិចរតិ ន ពហិទ្ធា កថំ អបនាមេតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ សម្មា វត្តតិ លោមំ បាតេតិ នេត្ថារំ វត្តតិ យេន សង្ឃោ អត្តមនោ ហោតិ តំ ករោមីតិ អាហ ។ តត្រ ភទ្ទាលិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ អភិណ្ហាបត្តិកោ អនាបត្តិពហុលោ សោ ភិក្ខូហិ វុច្ចមានោ នាញ្ញេនញ្ញំ បដិចរតិ

១ ឱ. ឯតំ ។

មិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្ងបរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយាវេីខ្លួនចេញចាកអាបត្តិ សង្ឃមានសេចក្ដីពេញចិត្ត ដោយហេតុណា មិនបានប្រាប់ហេតុនោះថា ខ្ញុំធ្វើដូច្នេះឡើយ បពិត្រលោកទាំងឡាយមានអាយុ សូមលោកទាំងឡាយ ពិចារណាមើលអធិករណ៍របស់ភិក្ខុនេះ តាមទំនងដែលមិនរម្ងាប់ ដោយឆាប់រហ័សនេះចុះ ។ ម្នាលភទ្ទាលិ ពួកភិក្ខុពិចារណាអធិករណ៍របស់ភិក្ខុនោះ តាមទំនងដែលមិនរម្ងាប់ដោយឆាប់រហ័សយ៉ាងនេះឯង ។ ម្នាលភទ្ទាលិ ចំណែកខាងភិក្ខុពួកមួយក្នុងសាសនានេះ ជាអ្នកត្រូវអាបត្តិក្នុងកាលម្ដង ៗ មិនច្រើនដោយអាបត្តិ កាលភិក្ខុទាំងឡាយស្ដីប្រដៅ ភិក្ខុនោះមិនបានពោលបន្ទែបន្ទប់ពាក្យដទៃដោយពាក្យដទៃ មិនបោះពាក្យទៅខាងក្រៅ មិនបានធ្វើសេចក្ដីក្រោធ សេចក្ដីប្រទូស្ត និងសេចក្ដីអាក់អន់ចិត្តឲ្យប្រាកដឡើយ ប្រព្រឹត្តវត្តដោយប្រពៃ សម្ងបរោម ប្រព្រឹត្តវត្តគួរដល់កិរិយាវេីខ្លួនចេញចាកអាបត្តិ សង្ឃមានសេចក្ដីពេញចិត្ត ដោយហេតុណា បានប្រាប់ហេតុនោះថា ខ្ញុំធ្វើ ។ ម្នាលភទ្ទាលិ ភិក្ខុទាំងឡាយ មានសេចក្ដីត្រិះរិះ ក្នុងហេតុដែលប្រដៅផងាយនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះជាអ្នកត្រូវអាបត្តិក្នុងកាលម្ដង ៗ មិនច្រើនដោយអាបត្តិ កាលភិក្ខុទាំងឡាយស្ដីប្រដៅ ភិក្ខុនោះមិនបានពោលបន្ទែបន្ទប់ពាក្យដទៃ ដោយពាក្យដទៃ

ន ពហិទ្ធា កាចំ អបដាមេតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច ចាតុករោតិ សម្មា វត្តតិ លោមំ ចាតេតិ នេត្ថារំ វត្តតិ យេន សង្ឃោ អត្តមនោ ហោតិ តំ ករោមីតិ អាហ សាធុ វតាយស្មន្តោ ឥមស្ស ភិក្ខុនោ តថា តថា ឧបបរិក្ខថ យថយិទំ អធិករណំ វិប្បមេវ វូប-សម្មេយ្យាតិ ។ តស្ស ខោ ឯវំ ភទ្ទាលិ ភិក្ខុនោ ភិក្ខូ តថា តថា ឧបបរិក្ខន្តិ យថយិទំ អធិករណំ វិប្បមេវ វូបសម្មតិ ។

[១៧១] ឥធ ភទ្ទាលិ ឯកច្ចោ ភិក្ខុ សទ្ធាមត្តកេន វហតិ បេមមត្តកេន ។ តត្រ ភទ្ទាលិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សទ្ធាមត្តកេន វហតិ បេមមត្តកេន សចេ មយំ ឥមំ ភិក្ខុំ បវយ្ហ បវយ្ហ(១) ការណំ ការេស្សាម មា យម្បិស្ស តំ សទ្ធាមត្តកំ បេមមត្តកំ តម្ហាបិ បរិហា-យីតិ ។ សេយ្យថាបិ ភទ្ទាលិ បុរិសស្ស ឯកំ ចក្ខុំ

១ ម. បសយ្ហ បសយ្ហ ។

មិនបោះពាក្យទៅខាងក្រៅ មិនបានធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើយ ប្រព្រឹត្តវត្តដោយប្រពៃ សម្រួបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារើខ្លួនចេញចាកអាបត្តិបាន សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា ក៏ប្រាប់ហេតុនោះថា ខ្ញុំធ្វើ បពិត្រលោកមានអាយុទាំងឡាយ សូមលោកពិចារណាអធិករណ៍ របស់ភិក្ខុនេះ តាមទំនងដែលគប្បីរម្ងាប់ដោយឆាប់រហ័សនេះចុះ ។ ម្នាលភទ្ទាលិ ពួកភិក្ខុពិចារណាអធិករណ៍ របស់ភិក្ខុនោះតាមទំនងដែលបានរម្ងាប់ដោយឆាប់រហ័ស យ៉ាងនេះឯង ។

[១៧០] ម្នាលភទ្ទាលិ ភិក្ខុពួកមួយ ក្នុងសាសនានេះ ប្រព្រឹត្តដោយសទ្ធាស្តួចស្តើង ដោយសេចក្តីស្រឡាញ់ស្តួចស្តើង (ចំពោះអាចារ្យនិងឧបជ្ឈាយ៍) ។ ម្នាលភទ្ទាលិ ភិក្ខុទាំងឡាយ តែងមានសេចក្តីត្រិះរិះចំពោះហេតុនោះ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះប្រព្រឹត្ត ដោយសទ្ធាស្តួចស្តើង ដោយសេចក្តីស្រឡាញ់ស្តួចស្តើង (ចំពោះអាចារ្យនិងឧបជ្ឈាយ៍) ប្រសិនបើយើងទាំងឡាយ ធ្វើនូវការសង្កត់សង្កិនភិក្ខុនេះ សទ្ធាស្តួចស្តើង និងសេចក្តីស្រឡាញ់ស្តួចស្តើងណាដែលមាននៅ ភិក្ខុនេះនឹងមិនសាបសូន្យចាកសទ្ធានិងសេចក្តីស្រឡាញ់ស្តួចស្តើងនោះឡើយ ។ ម្នាលភទ្ទាលិ បុរសមានចក្ខុតែមួយ ពួក

២៩៧



តស្ស មិត្តាមច្ចា ញាតិសាលោហិតា តំ ឯកំ ចក្ខុំ រក្ខេយ្យុំ មា យម្បិស្ស តំ ឯកំ ចក្ខុំ តម្បិ បរិហាយីតិ ឯវមេវ ខោ ភទ្ទាលិ[១] ឥធេកច្ចោ ភិក្ខុ សទ្ធាមត្តកេន វហតិ បេមមត្តកេន ។ តត្រ ភទ្ទាលិ ភិក្ខូនំ ឯវំ ហោតិ អយំ ខោ អាវុសោ ភិក្ខុ សទ្ធាមត្តកេន វហតិ បេមមត្តកេន សចេ មយំ ឥមំ ភិក្ខុំ បវយ្ហ បវយ្ហ ការណំ ការេស្សាម មា យម្បិស្ស តំ សទ្ធាមត្តកំ បេមមត្តកំ តម្បិ បរិហាយីតិ ។ អយំ ខោ[២] ភទ្ទាលិ ហេតុ អយំ បច្ចយោ យេនមិធេកច្ចំ ភិក្ខុំ[៣] បវយ្ហ បវយ្ហ កា-រណំ ការេន្តិ[៤] អយំ បន ភទ្ទាលិ ហេតុ អយំ បច្ចយោ យេនមិធេកច្ចំ ភិក្ខុំ ន តថា បវយ្ហ បវយ្ហ ការណំ ការេន្តីតិ[៥] ។ កោ នុ ខោ ភន្តេ ហេតុ

---

១ ម. ឯវមេវំ ភទ្ទាលិ ។ ២ ម. ខោសទ្ទោ នត្ថិ ។ ៣ ម. យេនមិធេកច្ចេ ភិក្ខូ តថា តថា ។ ឱ. ករោន្តិ ។ ៤ ម. ករោន្តីតិ ។ ៥ ម. អយំ បន ភទ្ទាលិ ហេតុ អយំ បច្ចយោ យេនមិធេកច្ចំ ភិក្ខុំ ន តថា បវយ្ហ បវយ្ហ ការណំ ការេន្តីតិ ន ទិស្សន្តិ ។

មិត្តអាមាត្យញាតិសាលោហិត គប្បីជួយថែរក្សាចក្ខុម្ខាងរបស់បុរសនោះ ដោយគិតថា ចក្ខុណាដែលមាននៅ សូមកុំឲ្យបុរសនោះសាបសូន្យចាកចក្ខុម្ខាងនោះឡើយ យ៉ាងណាមិញ ម្នាលភទ្ទាលិ ភិក្ខុពួកមួយក្នុងសាសនានេះ ប្រព្រឹត្ត ដោយសទ្ធាស្តួចស្តើង ដោយសេចក្តីស្រឡាញ់ស្តួចស្តើង (ចំពោះអាចារ្យនិងឧបជ្ឈាយ៍) យ៉ាងនោះឯង ។ ម្នាលភទ្ទាលិ ភិក្ខុទាំងឡាយ តែងមានសេចក្តីត្រិះរិះ ចំពោះហេតុយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះ ប្រព្រឹត្ត ដោយសទ្ធាស្តួចស្តើង ដោយសេចក្តីស្រឡាញ់ស្តួចស្តើង (ចំពោះអាចារ្យនិងឧបជ្ឈាយ៍) ប្រសិនបើយើងទាំងឡាយនាំគ្នាធ្វើការសង្កត់សង្កិនភិក្ខុនេះ សទ្ធាស្តួចស្តើងនិងសេចក្តីស្រឡាញ់ស្តួចស្តើងណាដែលមាននៅ ភិក្ខុនេះនឹងមិនសាបសូន្យចាកសទ្ធានិងសេចក្តីស្រឡាញ់ស្តួចស្តើង (ចំពោះអាចារ្យនិងឧបជ្ឈាយ៍) នោះឡើយ យ៉ាងនោះឯង ។ ម្នាលភទ្ទាលិ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យភិក្ខុទាំងឡាយ ធ្វើការសង្កត់សង្កិនភិក្ខុពួកមួយក្នុងសាសនានេះ ម្នាលភទ្ទាលិ មួយទៀត នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យពួកភិក្ខុ មិនធ្វើការសង្កត់សង្កិនភិក្ខុពួកមួយក្នុងសាសនានេះ ។ ព្រះភទ្ទាលិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាហេតុ

កោ បច្ចយោ យេន បុព្វេ អប្បតរានិ ចេវ សិក្ខាបទានិ អហេសុំ ពហុតរា ច ភិក្ខូ អញ្ញាយ សណ្ឋហឹសុ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេនេតរហិ ពហុតរានិ ចេវ សិក្ខាបទានិ ហោន្តិ អប្បតរា ច ភិក្ខូ អញ្ញាយ សណ្ឋហន្តីតិ ។

[១៧២] ឯវញ្ចេតំ(១) ភទ្ទាលិ ហោតិ សត្តេសុ ហាយមានេសុ សទ្ធម្មេ អន្តរធាយមានេ ពហុតរានិ ចេវ សិក្ខាបទានិ ហោន្តិ អប្បតរា ច ភិក្ខូ អញ្ញាយ សណ្ឋហន្តិ(២) ។ ន តាវ ភទ្ទាលិ សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ យាវ ន ឥធេកច្ចេ អាសវដ្ឋានីយា ធម្មា សង្ឃេ បាតុភវន្តិ ។ យតោ ច ខោ ភទ្ទាលិ ឥធេកច្ចេ អាសវដ្ឋានីយា ធម្មា សង្ឃេ បាតុភវន្តិ អថ សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ តេសំយេវ អាសវដ្ឋានីយានំ ធម្មានំ បដិឃាតាយ ។

---

១ ឱ. ឯវំហេតំ ។ ម. ឯវមេតំ ។ ២ ម. សណ្ឋហន្តីតិ ។

អ្វីហ្ន៎ជាបច្ច័យ បានជាក្នុងកាលពីដើមមានសិក្ខាបទតិចល្មម តែពួកភិក្ខុច្រើនរូបបានតាំងនៅក្នុងព្រះអរហត្ត បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត អ្វីជាហេតុ អ្វីជាបច្ច័យ បានជាក្នុងកាលឥឡូវនេះ មានសិក្ខាបទច្រើនណាស់ តែពួកភិក្ខុតិចពេក ដែលបានតាំងនៅក្នុងព្រះអរហត្ត ។

[១៧២] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភទ្ទាលិ ដំណើរនោះយ៉ាងនេះឯង គឺកាលបើសត្វទាំងឡាយសាបសូន្យ កាលបើព្រះសទ្ធម្មអន្តរធាន សិក្ខាបទទាំងឡាយ រមែងមានច្រើន ឯពួកភិក្ខុដែលបានឋិតនៅក្នុងព្រះអរហត្តមានតិច ។ ម្នាលភទ្ទាលិ ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ មិនទាន់កើតប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្តាក៏មិនទាន់បញ្ញត្តសិក្ខាបទ ដល់សាវ័កទាំងឡាយត្រឹមណោះ ។ ម្នាលភទ្ទាលិ លុះតែធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ កើតប្រាកដចំពោះសង្ឃ ក្នុងសាសនានេះ ក្នុងកាលណាទើបព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័កក្នុងកាលនោះ ដើម្បីនឹងការពារនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈនោះប៉ុណ្ណោះ ។

ន តាវ ភទ្ទាលិ ឥធេកច្ចេ អាសវដ្ឋានីយា ធម្មា សង្ឃេ បាតុភវន្តិ យាវ ន សង្ឃោ មហត្តំ បត្តោ ហោតិ ។ យតោ ច ខោ ភទ្ទាលិ សង្ឃោ មហត្តំ បត្តោ ហោតិ អថ[១] ឥធេកច្ចេ អាសវដ្ឋានីយា ធម្មា សង្ឃេ បាតុភវន្តិ អថ សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ តេសំយេវ អាសវដ្ឋានីយានំ ធម្មានំ បដិឃាតាយ ។ ន តាវ ភទ្ទាលិ ឥធេកច្ចេ អាសវដ្ឋានីយា ធម្មា សង្ឃេ បាតុភវន្តិ យាវ ន សង្ឃោ លាភគ្គំ បត្តោ ហោ-តិ... យសគ្គំ បត្តោ ហោតិ... ពាហុសច្ចំ បត្តោ ហោតិ... រត្តញ្ញុតំ[២] បត្តោ ហោតិ ។ យតោ ច ខោ ភទ្ទាលិ សង្ឃោ រត្តញ្ញុតំ បត្តោ ហោតិ អថ ឥធេកច្ចេ អាសវដ្ឋានីយា ធម្មា សង្ឃេ បាតុភវន្តិ អថ សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ តេសំយេវ អាសវដ្ឋានីយានំ ធម្មានំ បដិឃាតាយ ។

---

១ ម. បត្តោតិ អថ ។ ២ ឱ. រត្តញ្ញុត្តំ ។

ម្នាលភទ្ទាលិ សង្ឃមិនទាន់មានច្រើនត្រឹមណា ធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃត្រឹមណោះដែរ ។ ម្នាលភទ្ទាលិ លុះតែសង្ឃមានច្រើន ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងឡើងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះ ព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ដើម្បីការពារនូវធម៌ទាំងឡាយ ដែលជាទីតាំងឡើងនៃអាសវៈនោះឯង ។ ម្នាលភទ្ទាលិ សង្ឃមិនទាន់ដល់នូវលាភដ៏ប្រសើរ... មិនទាន់ដល់នូវយសដ៏ប្រសើរ... មិនទាន់ដល់នូវភាពជាពហុស្សូត... មិនទាន់ដល់នូវភាពជាអ្នកស្គាល់នូវរាត្រី (ច្រើន) ត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងឡើងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃ ក្នុងសាសនានេះត្រឹមណោះដែរ ។ ម្នាលភទ្ទាលិ លុះតែសង្ឃដល់នូវភាពជាអ្នកស្គាល់រាត្រី (ច្រើន) ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងឡើងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃ ក្នុងសាសនានេះ ក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ដើម្បីនឹងការពារនូវធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈនោះឯង ។

[១៧៣] អប្បកា ខោ តុម្ហេ ភទ្ទាលិ តេន សមយេន អហុវត្ថ យទា វោ អហំ អាជានីយសុសូបមំ ធម្មបរិយាយំ ទេសេសឹ[១] តំ សរសិ ត្វំ[២] ភទ្ទាលីតិ ។ នោ ហេតំ ភន្តេ ។ តត្រ ភទ្ទាលិ កឹ[៣] ហេតុំ បច្ចេសីតិ ។ សោ ហិ នូនាហំ ភន្តេ ទីឃរត្តំ សត្ថុ សាសនេ សិក្ខាយ អបរិបូរការី អហោសិន្តិ ។ ន ខោ ភទ្ទាលិ ឯសេវ ហេតុ ឯស បច្ចយោ អបិច មេ ត្វំ ភទ្ទាលិ ទីឃរត្តំ ចេតសា ចេតោ បរិច្ច វិទិតោ ឯវាយំ[៤] មោឃបុរិសោ មយា ធម្មេ ទេសិយមានេ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតោ ធម្មំ សុណាតីតិ អបិច តេ អហំ ភទ្ទាលិ អាជានីយសុសូបមំ ធម្មបរិយាយំ ទេសិស្សាមិ តំ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា ភទ្ទាលិ ភគវតោ បច្ចស្សោសិ ។

១ ឱ. តន្តិ ន ទិស្សតិ ។ ២ ម. ត្វន្តិ នត្ថិ ។ ៣ ឱ. ម. កំ ។ ៤ ម. នបាយំ ។

[១៧៣] ព្រះអង្គត្រាស់ថា ម្នាលភទ្ទាលិ តថាគតបានសំដែងធម្មបរិយាយ ប្រៀបដោយសំទុះនៃសេះអាជានេយ្យស្មាវ ដល់អ្នកក្នុងកាលណា អ្នកទាំងឡាយមានប្រមាណតិច បាននាំគ្នាពោលក្នុងសម័យនោះ ម្នាលភទ្ទាលិ អ្នករលឹកឃើញហេតុនោះដែរឬ ។ ព្រះភទ្ទាលិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនឃើញទេ ។ ម្នាលភទ្ទាលិ អ្នកជឿនូវហេតុក្នុងការរលឹកមិនឃើញដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះជាអ្នកមិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្ដាអស់កាលយូរពិតមែន ។ ម្នាលភទ្ទាលិ នុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ម្នាលភទ្ទាលិ ចំណែកខាងអ្នក តថាគតបានកំណត់ដឹងចិត្តដោយចិត្ត (របស់តថាគត) អស់កាលយូរមកហើយថា មោឃបុរសនេះ កាលដែលតថាគតសំដែងធម៌ ក៏មិនធ្វើឲ្យជាប្រយោជន៍ យកចិត្តទុកដាក់ពិចារណាដោយចិត្តសព្វគ្រប់ ផ្ទៀងត្រចៀកស្ដាប់ធម៌ឡើយ ម្នាលភទ្ទាលិ ចំណែកខាងតថាគតនឹងសំដែងនូវធម្មបរិយាយ ដែលប្រៀបដោយសំទុះនៃសេះអាជានេយ្យស្មាវដល់អ្នក ចូរអ្នកយកចិត្តទុកដាក់ស្ដាប់ធម្មបរិយាយនោះដោយគោរពចុះ តថាគតនឹងសំដែង ។ ភទ្ទាលិមានអាយុ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

ភិក្ខុវគ្គស្ស ភទ្ទាលិសុត្តេ អស្សទមកោបមា

[១៧៤] ភគវា ឯតទវោច សេយ្យថាបិ ភទ្ទាលិ ទក្ខោ អស្សទមកោ ភទ្រំ អស្សាជានីយំ លភិត្វា បឋមេនេវ មុខាធានេ ការណំ ការេតិ ។ តស្ស មុខាធានេ ការណំ ការិយមានស្ស ហោន្តិយេវ វិសូកាយិតានិ វិសេវិតានិ វិប្ផន្ទិតានិ កានិចិ កានិចិ យថាតំ អការិតបុព្វំ ការណំ ការិយមានស្ស ។ សោ អភិណ្ហការណា អនុបុព្វការណា តស្មឹ ឋានេ បរិនិព្វាយតិ ។ យតោ ខោ ភទ្ទាលិ ភទ្រោ អស្សាជា-នីយោ អភិណ្ហការណា អនុបុព្វការណា តស្មឹ ឋានេ បរិនិព្វុតោ ហោតិ តមេនំ អស្សទមកោ ឧត្តរឹ ការណំ ការិយមានស្ស ហោន្តិយេវ វិសូកាយិតានិ វិសេវិតានិ វិប្ផន្ទិតានិ កានិចិ កានិចិ យថាតំ អការិតបុព្វំ ការណំ ការិយមានស្ស ។ សោ អភិណ្ហការណា

ភិក្ខុវគ្គ ភទ្ទាលិសូត្រ ឧបមាដូចបុរសអ្នកបង្ហាត់សេះ

[១៧៤] ព្រះមានព្រះភាគ បានត្រាស់សេចក្ដីនុ៎ះថា ម្នាលភទ្ទាលិ បុរសអ្នកបង្ហាត់សេះ ដែលឈ្លាសវៃ បានសេះអាជានេយ្យល្អមកហើយ រមែងធ្វើនូវការបង្ហាត់ ដោយបង្ហៀរជាដំបូង ។ សេះនោះ កាលបើសារថីធ្វើនូវការបង្ហាត់ ចំពោះបង្ហៀរហើយ ពុតត្បុតកិកកុក កៀចបន្តិចបន្តួចគង់មាននៅមិនខាន ដូចជាសេះដែលគេមិនបានធ្វើនូវការបង្ហាត់ ។ សេះនោះ លុះគេបានបង្ហាត់រឿយ ៗ បានបង្ហាត់ដោយលំដាប់ ក៏បានរាបទាបក្នុងទីនោះ ។ ម្នាលភទ្ទាលិ កាលណាសេះអាជានេយ្យល្អ ដែលគេបានបង្ហាត់រឿយ ៗ បានបង្ហាត់ដោយលំដាប់ ក៏បានរាបទាបក្នុងទីនោះ អ្នកបង្ហាត់សេះ រមែងធ្វើនូវការបង្ហាត់សេះនោះតទៅទៀត ដោយការដាក់នឹម ។ សេះនោះ កាលដែលសារថី ធ្វើនូវការបង្ហាត់ដាក់នឹមហើយ ពុតត្បុត កិកកុក កៀចបន្តិចបន្តួចគង់នៅមានមិនខាន ដូចជាសេះដែលគេមិនបានធ្វើនូវការបង្ហាត់ ។ សេះនោះ លុះគេបានបង្ហាត់រឿយ ៗ

អនុបុព្វការណា តស្មឹ តស្មឹ ឋានេ បរិនិព្វាយតិ ។ យតោ ខោ ភទ្ទាលិ ភទ្រោ អស្សាជានីយោ អភិណ្ហការណា អនុបុព្វការណា តស្មឹ ឋានេ បរិនិព្វុតោ ហោតិ តមេនំ អស្សទមកោ ឧត្តរឹ ការណំ ការេតិ អនុក្កមេ មណ្ឌលេ ខុរកាសេ[១] ធាវេ ទវត្តេ[២] រាជគុណេ រាជវំសេ ឧត្តមេ ជវេ ឧត្តមេ ហយេ ឧត្តមេ សាខល្យេ ។ តស្ស ឧត្តមេ ជវេ ឧត្តមេ ហយេ ឧត្តមេ សាខល្យេ ការណំ ការិយមានស្ស ហោន្តិយេវ វិសូកាយិតានិ វិសេវិតានិ វិប្ផន្ទិតានិ កានិចិ កានិចិ យថាតំ អការិតបុព្វំ ការណំ ការិយមានស្ស ។ សោ អភិណ្ហការណា អនុបុព្វការណា តស្មឹ ឋានេ បរិនិព្វាយតិ ។ យតោ ខោ ភទ្ទាលិ ភទ្រោ អស្សាជានីយោ អភិណ្ហការណា

១ ឱ. ខុរកាយេ ។ ២ ម. ទវត្តេ ។

បានបង្ហាត់ដោយលំដាប់ ក៏រាបទាបក្នុងទីនោះ ។ ម្នាលកទ្ទាលិ កាលណាសេះអាជានេយ្យល្អ គេបានបង្ហាត់រឿយ ៗ បានបង្ហាត់ដោយលំដាប់ រមែងបានរាបទាបក្នុងទីនោះ ទើបអ្នកបង្ហាត់សេះ ធ្វើនូវការបង្ហាត់សេះនោះតទៅទៀត ក្នុងទីដែលលើកឬដាក់ (នូវជើង) ក្នុងមណ្ឌល ក្នុងទីដែលកកាយផែនដីដោយចុងក្រចក ក្នុងសំទុះដ៏រហ័ស ក្នុងកាលដែលត្រូវការកញ្ឆៀវ ក្នុងព្រះរាជគុណ[១] ក្នុងព្រះរាជវង្ស ក្នុងសំទុះដ៏ប្រសើរ ក្នុងភាវៈនៃសេះដ៏ប្រសើរ ក្នុងកាលដែលមានវាចាដ៏ពីរោះ ។ សេះនោះកាលបើសារថីធ្វើនូវការបង្ហាត់ ក្នុងសំទុះដ៏ប្រសើរ ក្នុងភាវៈនៃសេះដ៏ប្រសើរ ក្នុងកាលដែលមានវាចាពីរោះហើយ ពុតត្បុតកិកកុក កៀចបន្តិចបន្តួចគង់នៅមានមិនខាន ដូចសេះដែលគេមិនបានធ្វើនូវការបង្ហាត់ដែរ ។ សេះនោះលុះតែគេបានបង្ហាត់រឿយ ៗ បង្ហាត់ដោយលំដាប់ ក៏រាបទាបក្នុងទីនោះ ។ ម្នាលកទ្ទាលិ កាលណាសេះអាជានេយ្យដ៏ល្អ ដែលសារថីបង្ហាត់រឿយ ៗ

---

១ គុណដែលព្រះរាជាគួរជ្រាប ។ អដ្ឋកថា ។

អនុបុព្វការណា តស្មឹ ឋានេ បរិនិព្វុតោ ហោតិ តមេនំ អស្សទមកោ ឧត្តរឹ វណ្ណិយំ ច ពលិយំ ច[១] អនុប្បវេច្ឆតិ ។ ឥមេហិ ខោ ភទ្ទាលិ ទសហង្គេហិ សមន្នាគតោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេ្វវ សង្ខ្យំ[២] គច្ឆតិ ឯវមេវ ខោ ភទ្ទាលិ ទសហិ ធម្មេហិ សមន្នា-គតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ[៣] កតមេហិ ទសហិ ឥធ ភទ្ទាលិ ភិក្ខុ អសេក្ខាយ សម្មាទិដ្ឋិយា សមន្នាគតោ ហោតិ

---

១ ឱ. ឧត្តរី វណ្ណិយញ្ច វលិយញ្ច ។ ម. ឧត្តរិវណ្ណិយញ្ច វាណិយញ្ច ។ ២ ឱ. សង្ខំ ។

៣ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។

បង្ហាត់ដោយលំដាប់ ក៏រាបទាបក្នុងទីនោះហើយ ទើបសារថីជាអ្នកបង្ហាត់សេះ បំប៉នសេះនោះឲ្យមានសម្បុរល្អ និងកម្លាំងច្រើនតទៅទៀត ។ ម្នាលភទ្ទាលិ សេះអាជានេយ្យល្អ ប្រកបដោយអង្គ ១០[១] នេះឯង ជាសេះគួរសមដល់ស្តេច ជាសេះគួរស្តេចប្រើប្រាស់ ដល់នូវការរាប់ថាជាអង្គរបស់ស្តេចបាន សេចក្តីទាំងនេះ មានឧបមាយ៉ាងណា ម្នាលភទ្ទាលិ មានឧបមេយ្យដូចភិក្ខុ ដែលប្រកបដោយធម៌ ១០ ប្រការ ឈ្មោះថាជាអ្នកគួរទទួលចតុប្បច្ច័យ ដែលគេនាំមកបូជា ជាអ្នកគួរទទួលអាគន្តុកទាន ជាអ្នកគួរទទួលទក្ខិណាទាន ជាអ្នកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក អង្គ ១០ ប្រការនោះ តើអ្វីខ្លះ ម្នាលភទ្ទាលិ ភិក្ខុក្នុងសាសនានេះ ប្រកបដោយអសេក្ខសម្មាទិដ្ឋិ ១

---

១ សេះអាជានេយ្យប្រកបដោយអង្គ ១០ នោះគឺ អនុក្កមេ ក្នុងកាលលើកដាក់នូវជើងព្រមគ្នាល្អ ១ មណ្ឌលេ ក្នុងកាលដែលម្ចាស់ជិះវិលវង់បត់ចុះបត់ឡើងបាន ១ ខុរកាសេ ក្នុងកាលជាទីកកាយផែនដីដាក់គេដោយចុងក្រចក ១ ធាវេ ក្នុងកាលដែលត្រូវលុនឬផាយលឿនឆាប់ទាន់ចិត្ត ១ រវត្ថេ ក្នុងកាលដែលត្រូវការកញ្ច្រៀវ ១ រាជគុណេ ក្នុងកាលដែលស្តេចគួរដឹងគុណបំណាច់ ១ រាជវំសេ ក្នុងវង្សនៃសេះជាស្តេច ១ ឧត្តមេ ជវេ ក្នុងកាលដែលបោលមានសំទុះដ៏ល្អ ១ ឧត្តមេ ហយេ ក្នុងភាពនៃសេះដ៏ល្អ ១ ឧត្តមេ សាខល្យេ ក្នុងកាលដែលម្ចាស់ប្រើដោយពាក្យសំដីដ៏ល្អ ក៏ស្តាប់ពាក្យម្ចាស់បាន ១ ។

អសេខេន សម្មាសង្កប្បេន សមន្នាគតោ ហោតិ អសេ-ខាយ សម្មាវាចាយ សមន្នាគតោ ហោតិ អសេខេន សម្មាកម្មន្តេន សមន្នាគតោ ហោតិ អសេខេន សម្មា-អាជីវេន សមន្នាគតោ ហោតិ អសេខេន សម្មាវាយា-មេន សមន្នាគតោ ហោតិ អសេខាយ សម្មាសតិយា សមន្នាគតោ ហោតិ អសេខេន សម្មាសមាធិនា សមន្នាគតោ ហោតិ អសេខេន សម្មាញាណេន សមន្នាគតោ ហោតិ អសេខាយ សម្មាវិមុត្តិយា សមន្នាគតោ ហោតិ ឥមេហិ ខោ ភទ្ទាលិ ទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា ភទ្ទាលិ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ភទ្ទាលិសុត្តំ បញ្ចមំ និដ្ឋិតំ ។

ប្រកបដោយអសេខសម្មាសង្កប្បៈ ១ ប្រកបដោយអសេខសម្មាវាចា ១ ប្រកបដោយអសេខសម្មាកម្មន្តៈ ១ ប្រកបដោយអសេខសម្មាអាជីវៈ ១ ប្រកបដោយអសេខសម្មាវាយាមៈ ១ ប្រកបដោយអសេខសម្មាសតិ ១ ប្រកបដោយអសេខសម្មាសមាធិ ១ ប្រកបដោយអសេខសម្មាញាណៈ ១ ប្រកបដោយអសេខសម្មាវិមុត្តិ ១ ម្នាលភទ្ទាលិ ភិក្ខុដែលប្រកបដោយធម៌ ១០ ប្រការនេះឯង ឈ្មោះថាជាអ្នកគួរទទួលចតុប្បច្ច័យ ដែលគេនាំមកបូជា ជាអ្នកគួរទទួលអាគន្តុកទាន ជាអ្នកគួរទទួលទក្ខិណាទាន ជាអ្នកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ ព្រះភទ្ទាលិមានអាយុ ក៏មានចិត្តរីករាយ ត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ភទ្ទាលិសូត្រ ទី ៥ ។

# ឆដ្ឋំ លដុកិកោបមសុត្តំ

[១៧៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អង្គុត្តរាបេសុ វិហរតិ អាបណំ នាម អង្គុត្តរាបានំ និគមោ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ អាបណំ បិណ្ឌាយ បាវិសិ ។ អាបណេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្ប-ដិក្កន្តោ យេនញ្ញតរោ វនសណ្ឌោ តេនុបសង្កមិ ឧបសង្កមិត្វា ទិវាវិហារាយ តំ វនសណ្ឌំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។ អាយស្មាបិ ខោ ឧទាយី បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ អាបណំ បិណ្ឌាយ បាវិសិ ។ អាបណេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្ប-ដិក្កន្តោ យេន សោ វនសណ្ឌោ តេនុបសង្កមិ ឧបសង្កមិត្វា ទិវាវិហារាយ តំ វនសណ្ឌំ អជ្ឈោគា-ហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។

# លដុកិកោបមសូត្រ ទី ៦

[១៧៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអាបណនិគម របស់ពួកជនអង្គុត្តរាបៈ ក្នុងដែនឈ្មោះអង្គុត្តរាបៈ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់អាបណនិគម ដើម្បីបិណ្ឌបាត ។ លុះព្រះអង្គស្តេចទៅបិណ្ឌបាត ក្នុងអាបណនិគមហើយ ត្រឡប់មកពីបិណ្ឌបាត ក្នុងវេលាក្រោយកត្ត ក៏ស្តេចចូលទៅត្រង់ដងព្រៃមួយ លុះចូលសំដៅទៅរកដងព្រៃនោះហើយ ទើបគង់សម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយដើម ។ ចំណែកខាងព្រះឧទាយីមានអាយុ ក៏ស្លៀកស្បង់ប្រដាប់បាត្រចីវរ ចូលទៅកាន់អាបណនិគម ដើម្បីបិណ្ឌបាត ក្នុងវេលាព្រឹកព្រហាមដែរ ។ លុះលោកទៅបិណ្ឌបាត ក្នុងអាបណនិគមហើយ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយកត្ត ក៏ចូលទៅរកដងព្រៃមួយ លុះចូលទៅសំដៅទៅកាន់ដងព្រៃនោះហើយ ទើបអង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយដើម ។

អថខោ អាយស្មតោ ឧទាយិស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ពហុន្នំ វត នោ ភគវា ទុក្ខធម្មានំ អបហត្តា ពហុន្នំ វត នោ ភគវា សុខធម្មានំ ឧបហត្តា ពហុន្នំ វត នោ ភគវា អកុសលានំ ធម្មានំ អបហត្តា ពហុន្នំ វត នោ ភគវា កុសលានំ ធម្មានំ ឧបហត្តាតិ ។ អថខោ អាយស្មា ឧទាយី សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[១៧៦] ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧទាយី ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ពហុន្នំ វត នោ ភគវា ទុក្ខធម្មានំ អបហត្តា ពហុន្នំ វត នោ ភគវា សុខធម្មានំ ឧបហត្តា ពហុន្នំ វត នោ ភគវា អកុសលានំ ធម្មានំ អបហត្តា

កាលដែលព្រះឧទាយី មានអាយុ នៅក្នុងទីស្ងាត់ កំពុងតែសម្ងំក្នុងផលសមាបត្តិ ក៏មានសេចក្តីត្រិះរិះ ក្នុងចិត្តកើតឡើងយ៉ាងនេះថា ឱហ្ន៎ ព្រះមានព្រះភាគនៃយើង ទ្រង់កម្ចាត់បង់នូវធម៌ជាទុក្ខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគនៃយើង ទ្រង់ប្រកបនូវធម៌ជាសុខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគនៃយើង ទ្រង់កម្ចាត់បង់នូវធម៌ជាអកុសលច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគនៃយើង ទ្រង់ប្រកបនូវធម៌ជាកុសលច្រើនយ៉ាង ។ គ្រានោះឯង ព្រះឧទាយីមានអាយុ ចេញអំពីផលសមាបត្តិ ក្នុងវេលាថ្ងៃរសៀលហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។

[១៧៦] លុះព្រះឧទាយីមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសេចក្តីនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅក្នុងទីស្ងាត់ កំពុងតែសម្ងំ ក្នុងផលសមាបត្តិក្នុងទីឯណោះ ក៏មានសេចកក្តីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ឱហ្ន៎ ព្រះមានព្រះភាគនៃយើង ទ្រង់កម្ចាត់បង់នូវធម៌ជាទុក្ខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគនៃយើង ទ្រង់ប្រកបនូវធម៌ជាសុខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគនៃយើង ទ្រង់កម្ចាត់បង់នូវធម៌ជាអកុសលច្រើនយ៉ាង

ភិក្ខុវគ្គស្ស លដុកិកោបមសុត្តេ បរិវិតក្កាវោចនំ

ពហុន្នំ វត នោ ភគវា កុសលានំ ធម្មានំ ឧបហត្តាតិ ។ មយញ្ហិ ភន្តេ បុព្វេ សាយញ្ចេវ ភុញ្ជាម បាតោ ច ទិវា ច វិកាលេ ។ អហុ ខោ សោ ភន្តេ សមយោ យំ ភគវា ភិក្ខូ អាមន្តេសិ ឥង្ឃ តុម្ហេ ភិក្ខវេ ឯតំ ទិវា វិកាលភោជនំ បជហថាតិ ។ តស្ស មយ្ហំ ភន្តេ អហុទេវ អញ្ញថត្តំ អហុទេវ[១] ទោមនស្សំ យម្បិ នោ សទ្ធា គហបតិកា ទិវា វិកាលេ បណីតំ ខាទនីយំ ភោជនីយំ ទេន្តិ តស្សបិ នោ ភគវា បហានមាហ តស្សបិ នោ សុគតោ បដិនិស្សគ្គមាហាតិ តេ មយំ ភន្តេ ភគវតិ បេមញ្ច គារវញ្ច ហិរិញ្ច ឱត្តប្បញ្ច សម្បស្សមានា ឯវន្តំ ទិវា វិកាលភោជនំ បជហិម្ហា តេ មយំ ភន្តេ

១ ឱ. អហុ ។

ឱហ្ន៎ ព្រះមានព្រះភាគនៃយើង ទ្រង់ប្រកបនូវធម៌ជាកុសលច្រើនយ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា កាលពីដើម ពួកយើងខ្ញុំព្រះអង្គបរិភោគក្នុងវេលាល្ងាចផង ក្នុងវេលាព្រឹកផង ក្នុងវេលាថ្ងៃ ជាវេលាវិកាលផង ។ បពិត្រព្រះអង្គដ៏ចម្រើន មានសម័យមួយ ដែលព្រះមានព្រះភាគបានទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយលះបង់ នូវការបរិភោគ ក្នុងវេលាថ្ងៃ ដែលជាវេលាវិកាលនុ៎ះចេញ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្ដីពាយមាយចិត្ត និងទោមនស្ស ដោយគិតថា ពួកគហបតីដែលមានសទ្ធា រមែងឲ្យនូវខាទនីយភោជនីយាហារ ដ៏ឧត្តមណា ដល់យើងទាំងឡាយ ក្នុងវេលាថ្ងៃដែលជាវេលាវិកាល ព្រះមានព្រះភាគ បានត្រាស់ឲ្យយើងលះបង់ នូវខាទនីយភោជនីយាហារដ៏ឧត្តមនោះផង ព្រះសុគតបានត្រាស់ឲ្យយើងលះចោល នូវខាទនីយភោជនីយាហារដ៏ឧត្តមនោះផង បពិត្រព្រះអង្គដ៏ចម្រើន តែឥឡូវនេះពួកយើងខ្ញុំព្រះអង្គទាំងនោះ បែរជាបាននូវសេចក្ដីស្រឡាញ់ សេចក្ដីគោរព សេចក្ដីខ្មាសបាប និងសេចក្ដីខ្លាចបាប ចំពោះព្រះមានព្រះភាគវិញ កាលបើយ៉ាងនេះ ទើបយើងខ្ញុំព្រះអង្គលះបង់នូវការបរិភោគ ក្នុងវេលាថ្ងៃដែលជាវេលាវិកាលចេញ បពិត្រព្រះអង្គដ៏ចម្រើន តែពួកយើងខ្ញុំ

សាយញ្ចេវ ភុញ្ជាម បាតោ ច អហុ ខោ សោ ភន្តេ សមយោ យំ ភគវា ភិក្ខូ អាមន្តេសិ ឥង្ឃ តុម្ហេ ភិក្ខវេ ឯតំ រត្តឹ វិកាលភោជនំ បជហថាតិ តស្ស មយ្ហំ ភន្តេ អហុទេវ អញ្ញថត្តំ អហុទេវ[1] ទោមនស្សំ យម្បិ នោ ឥមេសំ ទ្វិន្នំ ភត្តានំ បណីតសង្ខាតតរំ តស្សបិ នោ ភគវា បហានមាហ តស្សបិ នោ សុគតោ បដិនិស្សគ្គមាហាតិ ។ ភូតបុព្វំ ភន្តេ អញ្ញតរោ បុរិសោ ទិវា សូបេយ្យំ លភិត្វា បជាបតឹ[2] ឯវមាហ ភុញ្ជិស្សាមាតិ យាកាចិ ភន្តេ សង្ខតិយោ សព្វា តា រត្តឹ អប្បា ទិវា តេ មយំ ភន្តេ

១ ឱ. អហុ ។ ២ ឱ. ម. បជាបតិន្តិ ន ទិស្សតិ ។ ៣ ឱ. ម. ហន្ទ ច ។

ព្រះអង្គនោះ នៅបរិភោគក្នុងវេលាល្ងាចផង ក្នុងវេលាព្រឹកផង បពិត្រព្រះអង្គដ៏ចម្រើន មានសម័យមួយ ដែលព្រះមានព្រះភាគ បានត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយលះបង់នូវការបរិភោគ ក្នុងវេលាយប់ ដែលជាវេលាវិកាលទ៊ុះចេញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្ដីពាយមាយចិត្ត និងសេចក្ដីទោមនស្ស ដោយគិតថា បណ្ដាភត្តទាំងពីរនេះ ភត្តណាឧត្តមវិសេស ដែលគេបានចាត់ចែង បម្រុងយើងទាំងឡាយ ព្រះមានព្រះភាគ បានត្រាស់នូវការលះបង់នូវភត្តនោះ ដល់យើងទាំងឡាយផង ព្រះសុគតបានត្រាស់ឲ្យយើងលះបោល នូវភត្តនោះ ផង ។ បពិត្រព្រះអង្គដ៏ចម្រើន រឿងធ្លាប់មានមកហើយ មានបុរសម្នាក់បាននូវគ្រឿងសម្ល ក្នុងវេលាថ្ងៃ ហើយនិយាយនឹងប្រពន្ធ យ៉ាងនេះថា ហ៏ នាងចូរទុកនូវគ្រឿងសម្លនេះសិនចុះ ចាំដល់វេលាល្ងាច យើងនឹងបរិភោគទាំងអស់គ្នាជាមួយគ្នាតែម្ដង បពិត្រព្រះអង្គដ៏ចម្រើន ខាទនីយភោជនីយាហារណាមួយ ដែលគួរចាត់ចែងទុក ខាទនីយភោជនីយាហារ ដែលគួរចាត់ចែងនោះ មានពោរពាស តែក្នុងវេលាយប់ដល់វេលាថ្ងៃមានតិច បពិត្រព្រះអង្គដ៏ចម្រើន តែខ្ញុំព្រះអង្គទាំងឡាយនោះ

ភគវតិ បេមញ្ច គារវញ្ច ហិរិញ្ច ឱត្តប្បញ្ច សម្បស្សមានា ឯវន្តំ រត្តឹ វិកាលភោជនំ បជហិម្ហា ។ ភូតបុព្វំ ភន្តេ ភិក្ខូ រត្តន្ធការតិមិសាយំ បិណ្ឌាយ ចរន្តា ចន្ទនិកម្បិ បវិសន្តិ ឱឡិគល្លេបិ បបតន្តិ កណ្ដកាវាដម្បិ[១] អារោហន្តិ សុត្តម្បិ គាវឹ អារោហន្តិ មាណវេហិបិ សមាគច្ឆន្តិ កតកម្មេហិបិ អកត-កម្មេហិបិ មាតុគ្គាមោបិ តេ អសទ្ធម្មេន និមន្តេតិ ។ ភូតបុព្វាហំ ភន្តេ រត្តន្ធការតិមិសាយំ បិណ្ឌាយ ចរាមិ អទ្ទសា ខោ មំ ភន្តេ អញ្ញតរា ឥត្ថី វិជ្ជន្តរិកាយ ភាជនំ ធោវន្តី ទិស្វា មំ ភីតា វិស្សរមកាសិ អព្ភុម្មេ[២] បិសាចោ វត មន្តិ ។ ឯវំ វុត្តេ អហំ ភន្តេ តំ ឥត្ថឹ ឯតទវោចំ ន ភគិនិ បិសាចោ ភិក្ខុ បិណ្ឌាយ ឋិតោតិ ។ ភិក្ខុស្ស បិតុ មារិ ភិក្ខុស្ស មាតុ មារិ

១ ឱ. កណ្ដកវដ្ដម្បិ ។ ២ ឱ. អព្ភុំ មេ ។

បែរជាបាននូវសេចក្តីស្រឡាញ់ សេចក្តីគោរព សេចក្តីខ្មាសបាប និង សេចក្តីខ្លាចបាប ចំពោះព្រះមានព្រះភាគវិញ កាលបើយ៉ាងនេះ ទើប យើងខ្ញុំព្រះអង្គលះបង់នូវការបរិភោគនូវភោជន ក្នុងវេលាយប់ ដែលជា វេលាវិកាលនុ៎ះចេញ ។ បពិត្រព្រះអង្គដ៏ចម្រើន រឿងធ្លាប់មានមកហើយ ពួកភិក្ខុត្រាច់ទៅបិណ្ឌបាត ក្នុងវេលារាត្រី ងងឹតសូន្យសុង ក៏ចូល ទៅប្រទះនឹងអណ្តូងជ្រាំខ្លះ ធ្លាក់ទៅក្នុងទីទំនាបទឹកជ្រាំខ្លះ ឡើងទៅ ប្រទះគំនរបន្លាខ្លះ ដើរពានទៅលើមេគោកំពុងដេកលក់ខ្លះ ជួបប្រទះ នឹងពួកមាណពគឺចោរ ដែលកំពុងធ្វើចោរកម្មខ្លះ មិនទាន់បានធ្វើចោរ-កម្មខ្លះ មាតុគ្រាមនិមន្តពួកភិក្ខុនោះដោយអសទ្ធម្មខ្លះ ។ បពិត្រព្រះអង្គ ដ៏ចម្រើន រឿងធ្លាប់មានមកហើយ ខ្ញុំព្រះអង្គត្រាច់ទៅបិណ្ឌបាត ក្នុងវេលា រាត្រីងងឹតសូន្យសុង បពិត្រព្រះអង្គដ៏ចម្រើន ស្រីម្នាក់កំពុងលាងភាជនៈ បានឃើញខ្ញុំព្រះអង្គក្នុងពេលមានផ្លេកបន្ទោរ លុះឃើញខ្ញុំព្រះអង្គហើយ ក៏ភិតភ័យស្រែកយ៉ាងខ្លាំងថា អញវិនាសហើយ យីអើអ្នកនេះជាបិសាច (មកប្រុងស៊ី) អញទេដឹង ។ បពិត្រព្រះអង្គដ៏ចម្រើន កាលស្រីនោះស្រែក យ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយពាក្យនេះនឹងស្រីនោះថា ម្នាល ប្អូនស្រី មិនមែនបិសាចទេ ភិក្ខុឈរបិណ្ឌបាតទេតើ ។ ស្រីនោះ ឆ្លើយតបថា ឪពុករបស់ភិក្ខុស្លាប់ហើយ ម្តាយរបស់ភិក្ខុស្លាប់ហើយ

វទន្តេ ភិក្ខុ តិណ្ហេន គោវិកន្តនេន(១) កុច្ឆិ បរិកន្តោ(២) ន ត្វេវ(៣) យំ(៤) រត្តន្ធការតិមិសាយំ កុច្ឆិហេតុ បិណ្ឌាយ ចរសីតិ ។ តស្ស មយ្ហំ ភន្តេ តទនុស្ស-រតោ ឯវំ ហោតិ ពហុន្នំ វត នោ ភគវា ទុក្ខធម្មានំ អបហត្តា ពហុន្នំ វត នោ ភគវា សុខធម្មានំ ឧបហត្តា ពហុន្នំ វត នោ ភគវា អកុសលានំ ធម្មានំ អបហត្តា ពហុន្នំ វត នោ ភគវា កុសលានំ ធម្មានំ ឧបហត្តាតិ ។

[១៧៧] ឯវមេវ បនុទាយិ ឥធេកច្ចេ មោឃបុរិសា ឥទំ បជហាថាតិ មយា វុច្ចមានា តេ ឯវមាហំសុ កឹ បនិមស្ស អប្បមត្តកស្ស ឱរមត្តកស្ស អធិសល្លិខតេវាយំ សមណោតិ តេ តញ្ចេវ នប្បជហន្តិ មយិ ច អប្បច្ចយំ ឧបដ្ឋបេន្តិ(៥) យេ ច ភិក្ខូ សិក្ខាកាមា តេសន្តំ ឧទាយិ ហោតិ

១ ឱ. គោវិកត្តនេន ។ ២ ឱ. បរិកត្តោ ។ ៣ ម. ន ត្វេវ វរំ ។ ៤ ឱ. យា ។ ៥ ឱ. ម. ឧបដ្ឋាបេន្តិ ។

ម្នាលភិក្ខុ លោកវះផ្ទៃរបស់លោកដោយកាំបិតដ៏មុតសម្រាប់វះគោ ប្រសើរជាង លោកត្រាច់ទៅក្នុងវេលារាត្រីងងឹតសូន្យសុង ព្រោះហេតុតែផ្ទៃមិនប្រសើរទេ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គនោះ រលឹកឃើញដំណើរនោះ ក៏មានសេចក្តីត្រិះរិះ យ៉ាងនេះថា ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់កម្ចាត់បង់នូវធម៌ជាទុក្ខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់ប្រកបនូវធម៌ ជាសុខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់កម្ចាត់បង់នូវធម៌ ជាអកុសលច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់ប្រកបនូវពួកធម៌ ជាកុសលច្រើនយ៉ាង ។

[១៧៧] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧទាយី ដូចយ៉ាងមោឃបុរសពួកខ្លះក្នុងលោកនេះ កាលតថាគតពោលថា អ្នកទាំងឡាយចូរលះបង់នូវអំពើនេះចេញ ពួកមោឃបុរសទាំងនោះ ក៏និយាយយ៉ាងនេះថា ចុះសមណៈនេះ សព្វបើហេតុរប៉ិចរប៉ុ បន្តិចបន្តួច ក៏ប្រិតអ្វីដល់ម្ល៉េះ ពួកមោឃបុរសទាំងនោះ ក៏មិនលះបង់អំពើនោះចេញទេ ថែមទាំងធ្វើសេចក្តីអាក់អន់ឲ្យកើតឡើងចំពោះតថាគត ម្នាលឧទាយី ចំណែកពួកភិក្ខុដែលជាសិក្ខាកាម (តែងធ្វើសេចក្តីអាក់អន់នឹងពួកមោឃបុរសនោះ) កិច្ចដែលត្រូវលះបង់បន្តិចបន្តួច របស់ពួកមោឃបុរសនោះ ទុកដូច

ពលវំ ពន្ធនំ ទឡ្ហំ ពន្ធនំ ថិរំ ពន្ធនំ អបូតិកំ ពន្ធនំ ថូលោ កលិង្គរោ ។ សេយ្យថាបិ ឧទាយិ លដុកិកា[១] សកុណិកា បូតិលតាយ ពន្ធនេន ពទ្ធា[២] តត្ថេវ វធំ វា ពន្ធំ វា មរណំ វា អាគមេតិ យោ នុ ខោ ឧទាយិ ឯវំ វទេយ្យ យេន សា លដុកិកា សកុណិកា បូតិលតាយ ពន្ធនេន ពទ្ធា តត្ថេវ វធំ វា ពន្ធំ វា មរណំ វា អាគមេតិ តញ្ហិ តស្សា អពលំ ពន្ធនំ ទុព្វលំ ពន្ធនំ បូតិកំ ពន្ធនំ អសារកំ ពន្ធនន្តិ សម្មា នុ ខោ សោ ឧទាយិ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ យេន សា ភន្តេ លដុកិកា សកុណិកា បូតិលតាយ ពន្ធនេន ពទ្ធា តត្ថេវ វធំ វា ពន្ធំ វា មរណំ វា អាគមេតិ តញ្ហិ តស្សា ពលវំ ពន្ធនំ ទឡ្ហំ ពន្ធនំ ថិរំ ពន្ធនំ អបូតិកំ ពន្ធនំ ថូលោ កលិង្គរោតិ ឯវមេវ ខោ ឧទាយិ ឥធេកច្ចេ មោឃបុរិសា ឥទំ បជហថាតិ មយា វុច្ចមានា តេ

---

១ លឌុកិកាតិប្បត្តិ ។ ២ ឱ. ពទ្ធា ។

ជាចំណងមានកម្លាំង ចំណងមាំ ចំណងជាប់ ចំណងមិនពុកផុយ ឬដូច កំណាត់ឈើធំ ។ ម្នាលឧទាយី សត្វប្រចៀចដែលជាប់ដោយចំណង វល្លិផោម ដែលត្រូវគេសម្លាប់ ឬជាប់ចំណង ឬដល់នូវសេចក្តីស្លាប់ក្នុងទី នោះទៀត ម្នាលឧទាយី បើបុគ្គលណានិយាយយ៉ាងនេះថា សត្វប្រចៀច នោះ ជាប់ដោយចំណងវល្លិផោមណា តែងត្រូវគេសម្លាប់ ឬជាប់ចំណង ឬដល់នូវសេចក្តីស្លាប់ក្នុងទីនោះ ដោយចំណងណា ចំណងនោះរបស់សត្វ នោះ ជាចំណងឥតកម្លាំង ចំណងមិនមាំ ចំណងពុកផុយ ចំណងមិន មានខ្លឹម ម្នាលឧទាយី បុគ្គលដែលនិយាយនោះ ឈ្មោះថានិយាយត្រូវ ឬដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន មិនត្រូវទេ បពិត្រព្រះអង្គដ៏ចម្រើន សត្វប្រចៀចនោះ ជាប់ដោយចំណងវល្លិផោមណា តែងត្រូវគេសម្លាប់ ឬជាប់ចំណង ឬដល់នូវសេចក្តីស្លាប់ក្នុងទីនោះ ដោយចំណងណា ឯចំ-ណងនោះ របស់សត្វនោះ ជាចំណងមានកម្លាំង ចំណងមាំ ចំណងជាប់ ចំណងមិនពុកផុយ ជាកំណាត់ឈើធំ ។ ម្នាលឧទាយី យ៉ាងនេះឯង ហើយ រឿងនេះដូចមោឃបុរសពួកខ្លះ ក្នុងលោកនេះកាលតថាគតប្រាប់ ថា ចូរអ្នកទាំងឡាយលះបង់ នូវអំពើនេះចេញ ពួកមោឃបុរសទាំងនោះ

ឯវមាហំសុ កឹ បនិមស្ស អប្បមត្តកស្ស ឱរមត្តកស្ស អធិសល្លិខតេវាយំ សមណោតិ តេ តញ្ច នប្បជ-ហន្តិ មយិ ច អប្បច្ចយំ ឧបដ្ឋបេន្តិ យេ ច ភិក្ខូ សិក្ខាកាមា តេសន្តំ ឧទាយិ ហោតិ ពលវំ ពន្ធនំ ទឡ្ហំ ពន្ធនំ ថិរំ ពន្ធនំ អបូតិកំ ពន្ធនំ ថូលោ កឡិង្គរោ ។

[១៧៨] ឥធ បនុទាយិ ឯកច្ចេ កុលបុត្តា ឥទំ បជហាថាតិ មយា វុច្ចមានា តេ ឯវមាហំសុ កឹ បនិមស្ស អប្បមត្តកស្ស ឱរមត្តកស្ស បហាតព្វស្ស យស្ស នោ ភគវា បហានមាហ យស្ស នោ សុគតោ បដិនិស្សគ្គមាហាតិ តេ តញ្ចេវ បជហន្តិ មយិ ច ន អប្បច្ចយំ ឧបដ្ឋបេន្តិ យេ ច ភិក្ខូ សិក្ខាកាមា តេ តំ បហាយ

ក៏ត្រឡប់និយាយយ៉ាងនេះថា ចុះសមណៈនេះ សព្វបើហេតុរបុិចរបុិបន្តិចបន្តួច ក៏ប្រិតអ្វីដល់ម៉្លេះ ពួកមោឃបុរសនោះ ក៏មិនលះបង់នូវអំពើនោះចោលឡើយ ថែមទាំងធ្វើសេចក្តីអាក់អន់ ឲ្យកើតឡើងដល់តថាគត ម្នាលឧទាយិ ចំណែកពួកភិក្ខុដែលជាសិក្ខាកាម (ក៏ធ្វើសេចក្តីអាក់អន់ចិត្ត ចំពោះមោឃបុរសទាំងនោះ) កិច្ចដែលត្រូវលះបង់បន្តិចបន្តួចរបស់ពួកមោឃបុរសទាំងនោះ ទុកដូចជាចំណងមានកម្លាំង ចំណងមាំចំណងជាប់ ចំណងមិនពុកផុយ ឬទុកដូចជាកំណាត់ឈើធំ ។

[១៧៨] ម្នាលឧទាយី មួយទៀត ពួកកុលបុត្រ ក្នុងសាសនានេះ កាលតថាគតប្រាប់ថា អ្នកទាំងឡាយចូរលះបង់អំពើនេះចេញ ពួកកុលបុត្រនោះ បាននិយាយយ៉ាងនេះថា ព្រះមានព្រះភាគ ត្រាស់ឲ្យយើងទាំងឡាយ លះបង់អំពើណា ព្រះសុគតត្រាស់ឲ្យយើងលះបង់ចោលអំពើណា ថ្វីបើអំពើនេះជាហេតុរបុិចរបុិបន្តិចបន្តួច យើងទាំងឡាយត្រូវតែលះបង់ចោលចេញ ពួកកុលបុត្រទាំងនោះ ក៏លះបង់នូវអំពើនោះចេញ ទាំងមិនធ្វើឲ្យទាស់អធ្យាស្រ័យតថាគតឡើយ មួយវិញទៀតភិក្ខុណាជាសិក្ខាកាម ពួកភិក្ខុនោះក៏បានលះបង់ នូវអំពើនោះចេញ

៣១៣



អប្បោស្សុក្កា បន្នលោមា បរទវុត្តា(១) មិគភូតេន ចេតសា វិហរន្តិ តេសន្តំ ឧទាយិ ហោតិ អពលំ ពន្ធនំ ទុព្វលំ ពន្ធនំ បូតិកំ ពន្ធនំ អសារកំ ពន្ធនំ ។ សេយ្យថាបិ ឧទាយិ រញ្ញោ នាគោ ឦសាទន្តោ ឧរុឡ្ហវាភិជាតោ(២) សង្គាមាវចរោ ទឡ្ហេហិ វរត្តេហិ ពន្ធនេហិ ពទ្ធោ ឦសកំយេវ កាយំ សន្នាមេត្វា តានិ ពន្ធនានិ សញ្ឆិន្ទិត្វា សម្បទាលេត្វា យេនកាមំ បក្កមតិ យោ នុ ខោ ឧទាយិ ឯវំ វទេយ្យ យេហិ សោ រញ្ញោ នាគោ ឦសាទន្តោ ឧរុឡ្ហវាភិជាតោ សង្គាមាវចរោ ទឡ្ហេហិ វរត្តេហិ ពន្ធនេហិ ពទ្ធោ ឦសកំយេវ កាយំ សន្នាមេត្វា តានិ ពន្ធនានិ សញ្ឆិន្ទិត្វា សម្បទាលេត្វា យេនកាមំ បក្កមតិ តញ្ហិ តស្ស ពលវំ ពន្ធនំ ទឡ្ហំ ពន្ធនំ ថិរំ ពន្ធនំ អបូតិកំ ពន្ធនំ ថូលោ កឡិង្គរោតិ សម្មា នុ ខោ សោ ឧទាយិ វទមានោ វទេយ្យាតិ ។

១ ម. បរទត្តវុត្តា ។ ២ ឱ. អព្វុឡ្ហវាភិជាតោ ។

ជាអ្នកមានសេចក្តីខ្វល់ខ្វាយ ជាអ្នកសម្ងបរោម ចិញ្ចឹមជីវិតដោយចតុប្បច្ច័យ ដែលអ្នកដទៃឲ្យ មានចិត្តប្រព្រឹត្តដូចជាសត្វម្រឹគ[១] ម្នាលឧទាយី ភិក្ខុនោះឈ្មោះថា មានចំណងមិនមានកម្លាំង មានចំណងខ្សោយ មានចំណងផុយ មានចំណងឥតខ្លឹម ។ ម្នាលឧទាយី ដូចដំរីរបស់ព្រះរាជាដែលមានភ្លុកងទន្នាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម គេចងដោយចំណងយ៉ាងមាំ ក៏ទម្រោមកាយបន្តិចហើយកាត់ទម្លាយនូវចំណងទាំងនោះ រួចចៀសចេញទៅតាមប្រាថ្នា ម្នាលឧទាយី បុគ្គលណាពោលយ៉ាងនេះថា ដំរីរបស់ព្រះរាជានោះ ជាដំរីមានភ្លុកងទន្នាំ មានរូបសមរម្យ គួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះកាន់សង្គ្រាម គេចងដោយចំណងព្រ័ត្រដ៏មាំណា ក៏ទម្រោមកាយបន្តិចហើយកាត់ទម្លាយនូវចំណងទាំងនោះ រួចចៀសចេញទៅតាមប្រាថ្នា ដំរីនោះឈ្មោះថា មានចំណងមានកម្លាំង មានចំណងមាំ មានចំណងខ្ជាប់ខ្ជួន មានចំណងមិនផុយ ឬទុកដូចជាកំណាត់ឈើធំ ម្នាលឧទាយី បុគ្គលដែលនិយាយនោះ ឈ្មោះថានិយាយត្រូវ ឬដូចម្តេច ។

---

១ ម្រឹគដែលត្រូវគេពាធាហើយ មិនមានបំណងនឹងមកឲ្យគេព្យាបាលវិញ តែងចូលទៅរកព្រៃរក្សារបួសដោយខ្លួនឯង ។ អដ្ឋកថា ។

នោ ហេតំ ភន្តេ យេហិ ភន្តេ សោ[១] រញ្ញោ នាគោ ឦសាទន្តោ ឧរូឡ្ហវាភិជាតោ សង្គាមាវចរោ ទឡ្ហេហិ វរត្តេហិ ពន្ធនេហិ ពន្ធោ ឦសកំយេវ កាយំ សន្នាមេត្វា តានិ ពន្ធនានិ សញ្ឆិន្ទិត្វា សម្បទាលេត្វា យេនកាមំ បក្កមតិ តញ្ហិ តស្ស អពលំ ពន្ធនំ ។ បេ ។ អសារកំ ពន្ធនន្តិ ។ ឯវមេវ ខោ ឧទាយិ ឥធេកច្ចេ កុលបុត្តា ឥទំ បជហថាតិ មយា វុច្ចមានា តេ ឯវមាហំសុ កិំ បនិមស្ស អប្បមត្តកស្ស ឱរមត្តកស្ស បហាតព្វស្ស យស្ស នោ ភគវា បហានមាហ យស្ស នោ សុគតោ បដិនិស្សគ្គមាហាតិ តេ តញ្ចេវ បជហន្តិ មយិ ច ន អប្បច្ចយំ ឧបដ្ឋបេន្តិ យេ ច ភិក្ខូ សិក្ខាកាមា តេ តំ បហាយ អប្បោស្សុក្កា បន្នលោមា បរទវុត្តា មិគភូតេន ចេតសា វិហរន្តិ តេសន្តំ ឧទាយិ ហោតិ អពលំ ពន្ធនំ បូតិកំ ពន្ធនំ អសារកំ ពន្ធនំ ។

១ ឱ. យេហិ សោ ភន្តេ ។ ម. យេហិ ភន្តេ ។

សូមទ្រង់ព្រះមេត្តាប្រោស និយាយនោះមិនត្រូវទេ បពិត្រព្រះអង្គដ៏ចម្រើន ដំរីរបស់ព្រះរាជានោះ មានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ដែលគេចងដោយចំណងព្រ័ត្រដ៏មាំណា ក៏ទម្រោមកាយបន្តិច ហើយកាត់ទម្លាយនូវចំណងទាំងនោះ រួចចៀសចេញទៅតាមប្រាថ្នា ព្រោះថាដំរីនោះ មានចំណងមិនមានកម្លាំង ។ បេ ។ មានចំណងឥតខ្លឹម ។ ម្នាលឧទាយី យ៉ាងនោះឯងហើយ រឿងនេះ ដូចពួកកុលបុត្រខ្លះ ក្នុងសាសនានេះ កាលតថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់អំពើនេះចេញដូច្នេះ ពួកកុលបុត្រនោះពោលយ៉ាងនេះថា ព្រះមានព្រះភាគ ត្រាស់ឲ្យយើងទាំងឡាយលះបង់អំពើណា ព្រះសុគតត្រាស់ឲ្យយើងទាំងឡាយលះបង់ចោលអំពើណា ថ្វីបើអំពើនេះជាហេតុរបុិចរបុីបន្តិចបន្តួច យើងទាំងឡាយត្រូវតែលះបង់ចោលចេញ ពួកកុលបុត្រនោះ ក៏លះបង់នូវអំពើនោះចេញបាន ទាំងមិនធ្វើឲ្យទាស់អធ្យាស្រ័យតថាគត មួយទៀត ពួកភិក្ខុណាដែលជាសិក្ខាកាម ពួកភិក្ខុនោះ បានលះបង់នូវអំពើនោះ ជាអ្នកខ្វល់ខ្វាយតិច សម្ងបរោម ប្រព្រឹត្តចិញ្ចឹមជីវិតដោយបច្ច័យ ដែលបុគ្គលដទៃឲ្យ មានចិត្តប្រព្រឹត្តដូចជាសត្វម្រឹគ ម្នាលឧទាយី អំពើរបស់កុលបុត្រនោះ ទុកដូចជាចំណងឥតកម្លាំង ចំណងផុយ ចំណងឥតខ្លឹម ។

[១៧៩] សេយ្យថាបិ ឧទាយិ បុរិសោ ទលិទ្ទោ អស្សកោ អនាឡ្ហិយោ[១] តស្សស្ស ឯកំ អគារកំ ឱលុគ្គវិលុគ្គំ កាកាតិទាយឹ[២] ន បរមរូបំ ឯកា ខឡោបិកា[៣] ឱលុគ្គវិលុគ្គា ន បរមរូបា ឯកិស្សា កុម្ភិយា ធញ្ញសមវាបកំ ន បរមរូបំ ឯកា ជាយិកា ន បរមរូបា សោ អារាមគតំ ភិក្ខុំ បស្សេយ្យ សុធោតហត្ថបាទំ មនុញ្ញំ ភោជនំ ភុត្តាវឹ សីតាយ ឆាយាយ និសិន្នំ អធិចិត្តេ យុត្តំ ។ តស្ស ឯវមស្ស សុខំ វត ភោ សាមញ្ញំ អារោគ្យំ វត ភោ សាមញ្ញំ សោ វតស្សំ យោហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជ្ជេយ្យន្តិ ។ សោ ន សក្កុណេយ្យ ឯកំ អគារកំ ឱលុគ្គវិលុគ្គំ កាកាតិទាយឹ ន បរមរូបំ បហាយ ឯកំ ខឡោបិកំ ឱលុគ្គវិលុគ្គំ ន បរមរូបំ បហាយ ឯកិស្សា កុម្ភិយា ធញ្ញសមវាបកំ ន បរមរូបំ បហាយ ឯកំ ជាយិកំ ន បរមរូបំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា

១ អនាឡ្ហិយោតិ អដ្ឋកថា ។ ២ កាកបាយិន្តិ តត្ថេវ ទិស្សតិ ។ ៣ ឱ. ខដោបិកា ។

ភិក្ខុវគ្គ លដុកិកោបមសូត្រ ឧបមាដូចបុរសកម្សត់

[១៧៩] ម្នាលឧទាយី ដូចបុរសកម្សត់ឥតយស មិនមានសម្បត្តិស្តុកស្តម្ភ បុរសនោះមានខ្ទមតូច ១ រខេករខាកក្អែកហើរកាត់ចុះឡើងបាន មានរាងរៅមិនល្អ មានគ្រែ ១ ដែលវែងដោយបន្ទោះឫស្សី ទ្រេតទ្រោត មានរាងមិនចំណាប់ មានស្រូវនិងពូជសម្រាប់សាបព្រោះរាល់ឆ្នាំ ១ ក្អម ជាពូជមិនល្អ មានស្រីម្នាក់ជាប្រពន្ធមានរូបមិនល្អ បុរសនោះឃើញភិក្ខុ ១ រូបនៅក្នុងអារាមលាងដៃជើងស្អាតល្អ បរិភោគភោជនជាទីពេញចិត្ត អង្គុយតែក្នុងម្លប់ត្រជាក់ប្រកបក្នុងអធិចិត្ត ។ បុរសនោះក៏គិតយ៉ាងនេះថា អើភាពជាសមណៈសុខណាស់ហ្ន៎ ភាពជាសមណៈឥតមានរោគអ្វីសោះ គួរតែអាត្មាអញកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ តែបុរសនោះមិនអាចនឹងលះបង់ផ្ទះតូចដែលរខេករខាកក្អែកហើរកាត់ចុះឡើងបាន ដែលមានរាងរៅមិនល្អ មិនអាចនឹងលះបង់គ្រែ ១ ដែលវែងដោយបន្ទោះឫស្សី ទ្រេតទ្រោត រាងរៅមិនចំណាប់ មិនអាចនឹងលះបង់ស្រូវនិងពូជសម្រាប់ព្រោះរាល់ឆ្នាំ ១ ក្អមដែលជាពូជមិនល្អ មិនអាចនឹងលះបង់ស្រីម្នាក់ជាប្រពន្ធ ដែលមានរូបមិនល្អ ហើយកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ

អគារស្មា អនគារិយំ បព្វជិតុំ ។ យោ នុ ខោ ឧទាយិ ឯវំ វទេយ្យ យេហិ សោ បុរិសោ ពន្ធនេហិ ពទ្ធោ ន សក្កោតិ ឯកំ អគារកំ ឱលុគ្គវិលុគ្គំ កាកាតិទាយឹ ន បរមរូបំ បហាយ ឯកំ កឡោ-បិកំ ឱលុគ្គវិលុគ្គំ ន បរមរូបំ បហាយ ឯកិស្សា កុម្ភិយា ធញ្ញសមវាបកំ ន បរមរូបំ បហាយ ឯកំ ជាយិកំ ន បរមរូបំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតុំ តញ្ហិ តស្ស អពលំ ពន្ធនំ ទុព្វលំ ពន្ធនំ បូតិកំ ពន្ធនំ អាសារកំ ពន្ធនន្តិ សម្មា នុ ខោ សោ ឧទាយិ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ យេហិ ភន្តេ សោ បុរិសោ ពន្ធនេហិ ពទ្ធោ ន សក្កោតិ ឯកំ អគារកំ ឱលុគ្គវិលុគ្គំ កាកាតិទាយឹ ន បរមរូបំ បហាយ ឯកំ កឡោបិកំ ឱលុគ្គវិលុគ្គំ ន បរមរូបំ បហាយ ឯកិស្សា កុម្ភិយា ធញ្ញសមវាបកំ ន បរមរូបំ បហាយ ឯកំ ជាយិកំ ន បរមរូបំ បហាយ

ចេញចាកផ្ទះចូលទៅកាន់ផ្នួសបានឡើយ ។ ម្នាលឧទាយី បុគ្គលណា និយាយយ៉ាងនេះថា បុរសនោះជាប់ដោយចំណងណា ទើបមិនអាចនឹងលះបង់ផ្ទះតូច ដែលរខេករខាកក្អែកហើរកាត់ចុះកាត់ឡើងបាន មានរាងពៅមិនល្អ មិនអាចនឹងលះបង់នូវគ្រែ ១ ដែលវែងដោយបន្ទោះឫស្សី ទ្រេតទ្រោត រាងពៅមិនចំណាប់ មិនអាចនឹងលះបង់ស្រូវនិងពូជសម្រាប់សាបព្រោះរាល់ឆ្នាំ ១ ក្អម ដែលជាពូជមិនល្អ មិនអាចនឹងលះបង់ស្រីម្នាក់ជាប្រពន្ធដែលមានរូបមិនល្អ ហើយកោរសក់និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សំពត់កាសាយ: ចេញចាកផ្ទះចូលទៅកាន់ផ្នួសបានឡើយ ព្រោះចំណងរបស់បុរសនោះជាចំណងធូរ ចំណងខ្សោយ ចំណងផុយ ចំណងឥតខ្លឹមទេ ម្នាលឧទាយី បុគ្គលដែលនិយាយនោះ ឈ្មោះថានិយាយត្រូវឬដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន និយាយនេះមិនត្រូវទេ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះជាប់ដោយចំណងណា ហើយមិនអាចនឹងលះបង់ផ្ទះតូចមួយដែលរខេករខាកក្អែកហើរកាត់ចុះកាត់ឡើងបាន មានរាងពៅមិនល្អ មិនអាចនឹងលះបង់គ្រែ ១ ដែលវែងដោយបន្ទោះឫស្សី ទ្រេតទ្រោត មានរាងពៅមិនចំណាប់ មិនអាចនឹងលះបង់ស្រូវនិងពូជ សម្រាប់សាបព្រោះរាល់ឆ្នាំ ១ ក្អម ដែលជាពូជមិនល្អ មិនអាចនឹងលះបង់ស្រីម្នាក់ជាប្រពន្ធដែល

កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆា-
ទេត្វា អគារស្មា អនគារិយំ បព្វជិតុំ តញ្ហិ តស្ស
ពលវំ ពន្ធនំ ទឡ្ហំ ពន្ធនំ ថិរំ ពន្ធនំ អបូតិកំ
ពន្ធនំ ថូលោ កឡិង្គរោតិ ។ ឯវមេវ ខោ
ឧទាយិ ឥធេកច្ចេ មោឃបុរិសា ឥទំ បជហថាតិ
មយា វុច្ចមានា តេ ឯវមាហំសុ កិំ បនិមស្ស
អប្បមត្តកស្ស ឱរមត្តកស្ស អធិសល្លិខតេវាយំ
សមណោតិ តេ តញ្ចេវ នប្បជហន្តិ មយិ ច អប្បច្ចយំ
ឧបដ្ឋបេន្តិ យេ ច ភិក្ខូ សិក្ខាកាមា តេសន្តំ
ឧទាយិ ហោតិ ពលវំ ពន្ធនំ ទឡ្ហំ ពន្ធនំ ថិរំ
ពន្ធនំ អបូតិកំ ពន្ធនំ ថូលោ កឡិង្គរោតិ ។

[១៨០] សេយ្យថាបិ ឧទាយិ គហបតិ វា គហបតិ-
បុត្តោ វា អឌ្ឍោ មហទ្ធនោ មហាភោគោ នេកានំ និក្ខ-
គណានំ ចយោ នេកានំ ធញ្ញគណានំ ចយោ នេ-
កានំ ខេត្តគណានំ ចយោ នេកានំ វត្ថុគណានំ ចយោ

មានរូបមិនល្អ ហើយកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ រួចចេញចាកផ្ទះ ចូលទៅកាន់ផ្នួសបានឡើយ ព្រោះថាចំណង របស់បុរសនោះជាចំណងតឹង ចំណងមាំ ចំណងខ្ជាប់ខ្ជួន ចំណងមិនផុយ ឬទុកដូចជាកំណាត់ឈើធំ ។ ម្នាលឧទាយី យ៉ាងនោះឯង ហើយ រឿងនេះដូចមោឃបុរសពួកខ្លះ ក្នុងលោកនេះ កាលតថាគតប្រាប់ថា អ្នកទាំងឡាយចូរលះបង់អំពើនេះចេញ ពួកមោឃបុរសទាំងនោះនិយាយយ៉ាងនេះថា ចុះសមណៈនេះសព្វបើហេតុរបុិចរបុិបន្តិចបន្តួចក៏ប្រិតអ្វីដល់ម្ល៉េះ ហើយពួកមោឃបុរសទាំងនោះ ក៏មិនលះបង់នូវអំពើនោះចោល ថែមទាំងធ្វើឲ្យទាស់អធ្យាស្រ័យតថាគតទៀត ចំណែកពួកភិក្ខុដែលជាសិក្ខាកាម (តែងធ្វើសេចក្ដីអាក់អន់ចិត្ត ចំពោះមោឃបុរសទាំងនោះ) ម្នាលឧទាយី កិច្ចដែលត្រូវលះបង់បន្តិចបន្តួច របស់មោឃ-បុរសទាំងនោះ ទុកជាចំណងតឹង ចំណងមាំ ចំណងខ្ជាប់ខ្ជួន មិនមែនជាចំណងពុកផុយ ឬទុកដូចកំណាត់ឈើធំ ។

[១៨០] ម្នាលឧទាយី ដូចគហបតីក្ដី គហបតិបុត្រក្ដី ជាអ្នកស្ដុកស្ដម្ភ មានទ្រព្យសម្បត្តិច្រើន មានគ្រឿងប្រើប្រាស់ច្រើន ជាអ្នកសន្សំនូវគំនរមាសឆ្លោរទុកច្រើន ជាអ្នកសន្សំ នូវគំនរស្រូវទុកច្រើន ជាអ្នកសន្សំនូវចំនួនស្រែទុកច្រើន ជាអ្នកសន្សំនូវចំនួនចម្ការទុកច្រើន ជា

នេកានំ ភរិយគណានំ[១] ចយោ នេកានំ ទាស-គណានំ ចយោ នេកានំ ទាសីគណានំ ចយោ សោ អារាមគតំ ភិក្ខុំ បស្សេយ្យ សុជោតហត្ថចាជំ មនុញ្ញំ ភោជនំ កុត្វាវី សីតាយ ឆាយាយ និសិន្នំ អនិចិត្តេ យុត្តំ ។ តស្ស ឯវមស្ស សុខំ វត ភោ សាមញ្ញំ អារោគ្យំ វត ភោ សាមញ្ញំ សោ វតស្សំ យោហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជ្ជេយ្យន្តិ ។ សោ សក្កុណេយ្យ នេកានិ និក្ខគណានិ បហាយ នេកានិ ជញ្ញគណានិ បហាយ នេកានិ ខេត្តគណានិ បហាយ នេកានិ វត្ថុគណានិ បហាយ នេកានិ ភរិយគណានិ បហាយ នេកានិ ទាសគណានិ បហាយ នេកានិ ទាសីគណានិ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតុំ ។ យោ នុ ខោ ឧទាយិ ឯវំ វទេយ្យ យេហិ សោ គហបតិ វា គហបតិបុត្តោ វា

---

១ ឱ. ភរិយាគណានន្តិប្បត្តិ ។

អ្នកសន្សំពួកភរិយាទុកច្រើន ជាអ្នកសន្សំពួកខ្ញុំប្រុសទុកច្រើន ជាអ្នកសន្សំពួកខ្ញុំស្រីទុកច្រើន គហបតីនោះ ឃើញភិក្ខុក្នុងអារាម មានដៃជើងលាងស្អាតល្អ ឆាន់ភោជនជាទីគាប់ចិត្ត អង្គុយក្នុងម្លប់ត្រជាក់ប្រកបក្នុងអធិចិត្ត ។ គហបតីឬគហបតិបុត្រនោះ ក៏គិតថា អើភាពជាសមណៈនេះ សុខណាស់ហ្ន៎ ភាពជាសមណៈ ឥតមានរោគសោះ គួរតែអាត្មាអញកោរសក់ និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ ជននោះ ក៏អាចលះបង់នូវគំនរមាសប្រាក់ច្រើន លះបង់គំនរស្រូវច្រើន លះបង់ចំនួនស្រែច្រើន លះបង់ចំនួនចម្ការច្រើន លះបង់ពួកភរិយាច្រើន លះបង់ពួកខ្ញុំប្រុសច្រើន លះបង់ពួកខ្ញុំស្រីច្រើនបាន ហើយកោរសក់និងពុកមាត់ពុកចង្ការួចស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ ម្នាលឧទាយី បុគ្គលណានិយាយយ៉ាងនេះថា គហបតីក្តី គហបតិបុត្រក្តី

ភិក្ខុវគ្គស្ស លដុកិកោបមសុត្តេ គហបតិគហបតិបុត្តូបមា

ពន្ធនេហិ ពទ្ធោ សក្កោតិ នេកានិ និក្ខគណានិ បហាយ នេកានិ ធញ្ញគណានិ បហាយ នេកានិ ខេត្តគណានិ បហាយ នេកានិ វត្ថុគណានិ បហាយ នេកានិ ភរិយគណានិ បហាយ នេកានិ ទាសគណានិ បហាយ នេកានិ ទាសីគណានិ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតុំ តញ្ហិ តស្ស ពលវំ ពន្ធនំ ទឡ្ហំ ពន្ធនំ ថិរំ ពន្ធនំ អបូតិកំ ពន្ធនំ ថូលោ កឡិង្គរោតិ សម្មា នុ ខោ សោ ឧទាយិ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ យេហិ ភន្តេ សោ គហបតិ វា គហបតិបុត្តោ វា ពន្ធនេហិ ពទ្ធោ សក្កោតិ នេកានិ និក្ខគណានិ បហាយ នេកានិ ធញ្ញគណានិ បហាយ នេកានិ ខេត្តគណានិ បហាយ នេកានិ វត្ថុគណានិ បហាយ នេកានិ ភរិយគណានិ បហាយ នេកានិ ទាសគណានិ បហាយ នេកានិ ទាសីគណានិ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា

ជាប់ដោយចំណងណា ហើយអាចលះបង់គំនរមាសត្ថោរជាច្រើន លះបង់គំនរស្រូវជាច្រើន លះបង់ចំនួនស្រែជាច្រើន លះបង់ចំនួនចម្ការជាច្រើន លះបង់ពួកភរិយាជាច្រើន លះបង់ពួកខ្ញុំប្រុសជាច្រើន លះបង់ពួកខ្ញុំស្រីជាច្រើន ហើយកោរសក់កោរពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួសបាន ព្រោះចំណងនោះ របស់ជននោះជាចំណងតឹង ជាចំណងមាំ ចំណងខ្ជាប់ខ្ជួន មិនមែនជាចំណងផុយ ទុកដូចកំណាត់ឈើធំ ដូច្នេះ ឬដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន និយាយយ៉ាងនេះមិនត្រូវទេ បពិត្រព្រះអង្គដ៏ចម្រើន គហបតីក្តី គហបតិបុត្រក្តី ទោះជាប់ដោយចំណងណា ហើយអាចលះបង់គំនរមាសត្ថោរច្រើនបាន លះបង់គំនរស្រូវច្រើនបាន លះបង់ចំនួនស្រែច្រើនបាន លះបង់ចំនួនចម្ការច្រើនបាន លះបង់ពួកភរិយាច្រើនបាន លះបង់ពួកខ្ញុំប្រុសច្រើនបាន លះបង់ពួកខ្ញុំស្រីជាច្រើន ហើយកោរសក់កោរពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់

អគារស្មា អនគារិយំ បព្វជិតុំ តញ្ហិ តស្ស អពលំ ពន្ធនំ ទុព្វលំ ពន្ធនំ បូតិកំ ពន្ធនំ អសារកំ ពន្ធនន្តិ ។ ឯវមេវ ខោ ឧទាយិ ឥធេកច្ចេ កុលបុត្តា ឥទំ បជហថាតិ មយា វុច្ចមានា តេ ឯវមាហំសុ កឹ បនិមស្ស អប្បមត្តកស្ស ឱរមត្តកស្ស បហាតព្វស្ស យស្ស នោ ភគវា បហានមាហ យស្ស នោ សុគតោ បដិនិស្សគ្គមាហាតិ តេ តញ្ចេវ បជហន្តិ មយិ ច ន អប្បច្ចយំ ឧបដ្ឋបេន្តិ យេ ច ភិក្ខូ សិក្ខាកាមា តេ តំ បហាយ អប្បោស្សុក្កា បន្នលោមា បរទវុត្តា មិគភូតេន ចេតសា វិហរន្តិ តេសន្តំ ឧទាយិ ហោតិ អពលំ ពន្ធនំ ទុព្វលំ ពន្ធនំ បូតិកំ ពន្ធនំ អាសារកំ ពន្ធនំ ។

កាសាយ: ចេញចាកផ្ទះចូលទៅកាន់ផ្នួសបាន ព្រោះថា ចំណងនោះ របស់ជននោះ មិនមែនជាចំណងតឹង ជាចំណងខ្សោយ ជាចំណងផុយ ជាចំណងឥតខ្លឹម ។ ម្នាលឧទាយី យ៉ាងនោះឯងហើយ រឿងនេះដូច ពួកកុលបុត្រខ្លះ ក្នុងសាសនានេះ កាលតថាគតប្រាប់ថា អ្នកទាំង-ឡាយ ចូរលះបង់នូវអំពើនេះចេញ ពួកកុលបុត្រនោះ ក៏ពោលយ៉ាងនេះថា ព្រះមានព្រះភាគ ត្រាស់ឲ្យយើងទាំងឡាយលះបង់អំពើណា ព្រះសុគត ត្រាស់ឲ្យយើងលះបង់អំពើណា ថ្វីបើអំពើនោះ ជាអំពើរបិចរបិបន្តិចបន្តួច យើងត្រូវលះបង់ចោលចេញ ហើយពួកកុលបុត្រនោះ ក៏បានលះបង់នូវ អំពើនោះចេញ ទាំងមិនធ្វើឲ្យទាស់អធ្យាស្រ័យតថាគតឡើយ មួយ វិញទៀត ពួកភិក្ខុណាជាសិក្ខាកាម ភិក្ខុទាំងនោះ លះបង់នូវអំពើនោះ ហើយជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច សម្បរោម ប្រព្រឹត្តចិញ្ចឹមជីវិត ដោយបច្ច័យដែលអ្នកដទៃឲ្យ មានចិត្តប្រព្រឹត្តដូចជាសត្វម្រឹគ ម្នាល ឧទាយី អំពើរបស់ភិក្ខុនោះ ទុកដូចជាចំណងធួរ ចំណងទុព្វលភាព ចំណងផុយ ចំណងឥតខ្លឹម ។

[១៨១] ចត្តារោមេ ឧទាយិ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ កតមេ ចត្តារោ ឥធុទាយិ ឯកច្ចោ បុគ្គលោ ឧបធិប្បហានាយ បដិបន្នោ ហោតិ ឧបធិប្បដិនិស្សគ្គាយ តមេនំ ឧបធិប្បហានាយ បដិបន្នំ ឧបធិប្បដិនិស្សគ្គាយ ឧបធិប្បដិសំយុត្តា សរសង្កប្បា សមុទាចរន្តិ សោ តេ អធិវាសេតិ នប្បជហតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវង្គមេតិ ឥមំ ខោ អហំ ឧទាយិ បុគ្គលំ សំយុត្តោតិ វទាមិ នោ វិសំយុត្តោ តំ កិស្ស ហេតុ ឥន្ទ្រិយវេមត្តតា ហិ មេ ឧទាយិ ឥមស្មឹ បុគ្គលេ វិទិតា ។ ឥធ បនុទាយិ ឯកច្ចោ បុគ្គលោ ឧបធិប្បហានាយ បដិបន្នោ ហោតិ ឧបធិប្បដិនិស្សគ្គាយ តមេនំ ឧបធិប្បហានាយ បដិបន្នំ ឧបធិប្បដិនិស្សគ្គាយ ឧបធិប្បដិសំយុត្តា សរសង្កប្បា សមុទាចរន្តិ សោ តេ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ

[១៨១] ម្នាលឧទាយី បុគ្គលទាំងឡាយ ៤ ពួកនេះ តែងមានប្រាកដក្នុងលោក បុគ្គល ៤ ពួក តើដូចម្ដេចខ្លះ ម្នាលឧទាយី បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកប្រតិបត្តិដើម្បីលះបង់ឧបធិ[១] ដើម្បីលាស់ចោលនូវឧបធិ សេចក្ដីរលឹកឃើញនិងការត្រិះរិះ ដែលប្រកបដោយឧបធិ តែងគ្របសង្កត់បុគ្គលនោះ ដែលប្រតិបត្តិ ដើម្បីលះបង់ឧបធិ ដើម្បីលាស់ចោលនូវឧបធិ បុគ្គលនោះ ក៏ស៊ូអត់ទ្រាំ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យមានកំណើតទៀត នូវឧបធិទាំងនោះឡើយ ម្នាលឧទាយី តថាគតហៅបុគ្គលនេះឯងថា ជាអ្នកប្រកបដោយកិលេស មិនហៅថា ជាអ្នកប្រាសចាកកិលេសទេ ដំណើរនោះព្រោះហេតុអ្វី ម្នាលឧទាយី ព្រោះតថាគត ដឹងច្បាស់ថា ឥន្ទ្រិយផ្សេង ៗ (មាន) ក្នុងបុគ្គលនេះ ។ ម្នាលឧទាយី បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកប្រតិបត្តិដើម្បីលះបង់ឧបធិ ដើម្បីលាស់ចោលនូវឧបធិ សេចក្ដីរលឹកឃើញនិងការត្រិះរិះ ដែលប្រកបដោយឧបធិ តែងគ្របសង្កត់នូវបុគ្គលនោះ ដែលប្រតិបត្តិដើម្បីលះបង់ឧបធិ ដើម្បីលាស់ចោលនូវឧបធិ បុគ្គលនោះ មិនអត់ទ្រាំ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស

---

១ ឧបធិសព្ទ ប្រែថា សភាវៈដែលតម្កល់ទុកនូវកងទុក្ខ គឺជាឫសគល់នៃកងទុក្ខ បានដល់ឧបធិ ៤ យ៉ាង គឺ ខន្ធូបធិ ១ កិលេសូបធិ ១ អភិសង្ខារូបធិ ១ កាមគុណូបធិ ១ ។ អដ្ឋកថា ។

អនភាវង្គមេតិ ឥមម្បិ ខោ អហំ ឧទាយិ បុគ្គលំ សំយុត្តោតិ វទាមិ នោ វិសំយុត្តោ តំ កិស្ស ហេតុ ឥន្ទ្រិយវេមត្តតា ហិ មេ ឧទាយិ ឥមស្មឹ បុគ្គលេ វិទិតា ។ ឥធ បនុទាយិ ឯកច្ចោ បុគ្គលោ ឧបធិប្បហានាយ បដិបន្នោ ហោតិ ឧបធិប្បដិនិស្សគ្គាយ តមេនំ ឧបធិប្បហានាយ បដិបន្នំ ឧបធិប្បដិនិស្សគ្គាយ កទាចិ ករហចិ សតិសម្មោសា ឧបធិប្បដិសំយុត្តា សរសង្កប្បា សមុទាចរន្តិ ទន្ធោ ឧទាយិ សតុប្បាទោ អថខោ នំ ខិប្បមេវ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភា-វង្គមេតិ ។ សេយ្យថាបិ ឧទាយិ បុរិសោ ទិវសសន្តត្តេ អយោកដាហេ ទ្វេ វា តីណិ វា ឧទកផុសិតានិ និបាតេយ្យ ទន្ធោ ឧទាយិ ឧទកផុសិតានំ និបាតោ អថខោ នំ ខិប្បមេវ បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ឯវមេវ ខោ ឧទាយិ ឥធេកច្ចោ បុគ្គលោ ឧបធិប្ប-ហានាយ បដិបន្នោ ហោតិ ឧបធិប្បដិនិស្សគ្គាយ

ធ្វើមិនឲ្យកើតទៀតនូវឧបធិទាំងនោះ ម្នាលឧទាយី តថាគតហៅបុគ្គលនេះឯងថា ជាអ្នកប្រកបដោយកិលេស មិនហៅថា ជាអ្នកប្រាសចាកកិលេសទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះតថាគត ដឹងច្បាស់ថា ឥន្ទ្រិយផ្សេង ៗ (មាន) ក្នុងបុគ្គលនោះ ។ ម្នាលឧទាយី បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកប្រតិបត្តិ ដើម្បីលះបង់ឧបធិ ដើម្បីលាស់ចោលនូវឧបធិ ការរលឹកឃើញ និងសេចក្តីត្រិះរិះ ដែលប្រកបដោយឧបធិ តែងគ្របសង្កត់បុគ្គលនោះ ដែលប្រតិបត្តិ ដើម្បីលះបង់ ដើម្បីលាស់ចោលនូវឧបធិ ព្រោះការភ្លេចស្មារតីក្នុងកាលម្តង ៗ ម្នាលឧទាយី ការកើតឡើងនៃសតិជារបស់យឺតយូរ តែបុគ្គលនោះលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតទៀតនូវឧបធិនោះ ដោយឆាប់រហ័ស ។ ម្នាលឧទាយី បុរសចាក់តំណក់ទឹកពីរបីតំណក់ ទៅក្នុងខ្ទះដែក ដែលគេដុតអស់មួយថ្ងៃ ម្នាលឧទាយី ការស្រក់ចុះនៃតំណក់នោះរមែងយឺតយូរ តែតំណក់ទឹកនោះ ក៏ដល់នូវការរីងស្ងួតអស់ទៅដោយឆាប់រហ័ស សេចក្តីនេះ មានឧបមាយ៉ាងណា ម្នាលឧទាយី មានឧបមេយ្យដូចបុគ្គលពួកមួយក្នុងលោកនេះ ប្រតិបត្តិ ដើម្បីលះបង់ឧបធិ ដើម្បីលាស់ចោលនូវ

៣២៣



តមេនំ ឧបធិប្បហានាយ បដិបន្នំ ឧបធិប្បដិនិស្សគ្គាយ កទាចិ ករហចិ សតិសម្មោសា ឧបធិប្បដិសំយុត្តា សរសង្កប្បា សមុទាចរន្តិ ទន្ធោ ឧទាយិ សតុប្បាទោ អថខោ នំ ខិប្បមេវ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ឥមម្បិ ខោ អហំ ឧទាយិ បុគ្គលំ សំយុត្តោតិ វទាមិ នោ វិសំយុត្តោ តំ កិស្ស ហេតុ ឥន្ទ្រិយវេមត្តតា ហិ មេ ឧទាយិ ឥមស្មឹ បុគ្គលេ វិទិតា ។ ឥធ បនុទាយិ ឯកច្ចោ បុគ្គលោ ឧបធិ ទុក្ខស្ស មូលន្តិ ឥតិ វិទិត្វា និរុបធី ហោតិ ឧបធិសង្ខយេ វិមុត្តោ ឥមំ ខោ អហំ ឧទាយិ បុគ្គលំ វិសំយុត្តោតិ វទាមិ នោ សំយុត្តោ តំ កិស្ស ហេតុ ឥន្ទ្រិយវេមត្តតា ហិ មេ ឧទាយិ ឥមស្មឹ បុគ្គលេ វិទិតា ។ ឥមេ ខោ ឧទាយិ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ [១] ។

---

១ ឱ. ម. ឥមេ ខោ ឧទាយិ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ន ទិស្សន្តិ ។

ឧបធិ ការរលឹកឃើញនិងសេចក្ដីត្រិះរិះ ដែលប្រកបដោយឧបធិ រមែង គ្របសង្កត់បុគ្គលនោះ ដែលប្រតិបត្តិដើម្បីលះបង់ឧបធិ ដើម្បីរលាស់ចោលនូវឧបធិ ព្រោះភ្លេចស្មារតីក្នុងកាលម្ដង ៗ ម្នាលឧទាយី ការកើតឡើងនៃស្មារតីយឺតយូរ តែបុគ្គលនោះលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានកំណើតទៀតនូវឧបធិនោះ ដោយឆាប់រហ័ស ម្នាលឧទាយី តថាគតហៅបុគ្គលនេះឯងថា ជាអ្នកប្រកបដោយកិលេស មិនហៅថា ជាអ្នកប្រាសចាកកិលេសទេ ដំណើរនោះព្រោះហេតុអ្វី ម្នាលឧទាយី ព្រោះតថាគតដឹងច្បាស់ថា ឥន្ទ្រិយផ្សេង ៗ គ្នា (មាន) ក្នុងបុគ្គលនេះ ។ ម្នាលឧទាយី បុគ្គលពួកមួយក្នុងលោកនេះដឹងច្បាស់ថា ឧបធិគឺបញ្ចក្ខន្ធ ជាឫសគល់នៃសេចក្ដីទុក្ខ តែជាអ្នកឥតមានឧបក្កិលេស មានចិត្តជឿស៊ប់នូវព្រះនិព្វានជាគ្រឿងអស់ទៅនៃឧបធិក្កិលេស ម្នាលឧទាយី តថាគតហៅបុគ្គលនេះឯងថា ជាអ្នកប្រាសចាកឧបធិក្កិលេស មិនហៅថាប្រកបដោយឧបធិក្កិលេសឡើយ ដំណើរនោះព្រោះហេតុអ្វី ម្នាលឧទាយី ព្រោះតថាគតដឹងច្បាស់ថា ឥន្ទ្រិយដែលផ្សេង ៗ គ្នា (មាន) ក្នុងបុគ្គលនេះ ។ ម្នាលឧទាយី បុគ្គលទាំងឡាយ ៤ ពួកនេះឯងដែលមានប្រាកដក្នុងលោក ។

[១៨២] បញ្ច ខោ ឥមេ ឧទាយិ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា... ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហាវិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ ឥមេ ខោ ឧទាយិ បញ្ច កាមគុណា ។ យំ ខោ ឧទាយិ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ កាមសុខំ មិឡ្ហសុខំ បុថុជ្ជនសុខំ អនរិយសុខំ ន អាសេវិតព្វំ ន ភាវេតព្វំ ន ពហុលីកាតព្វំ ភាយិតព្វំ ឯតស្ស សុខស្សាតិ វទាមិ ។

[១៨៣] ឥធុទាយិ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ។ បេ ។

[១៨២] ម្នាលឧទាយី កាមគុណនេះមាន ៥ ប្រការ កាមគុណ ៥ ប្រការតើអ្វីខ្លះ គឺរូបទាំងឡាយ ដែលបុគ្គលគប្បីដឹងបាន ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួររីករាយ ១ សំឡេងទាំងឡាយ ដែលបុគ្គលគប្បីដឹងបានដោយត្រចៀក... ១ ក្លិនទាំងឡាយ ដែលបុគ្គលគប្បីដឹងបានដោយច្រមុះ... ១ រសទាំងឡាយ ដែលបុគ្គលគប្បីដឹងបានដោយអណ្តាត... ១ ផោដ្ឋព្វៈទាំងឡាយ ដែលបុគ្គលគប្បីដឹងបានដោយកាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ១ ។ ម្នាលឧទាយី នេះឯងហៅថា កាមគុណ ៥ ប្រការ ។ ម្នាលឧទាយី សុខនិងសោមនស្សណា កើតឡើងព្រោះអាស្រ័យកាមគុណទាំង ៥ ប្រការនេះ សេចក្តីសុខនិងសោមនស្សនេះ តថាគតហៅថា ជាសុខក្នុងកាម ជាសុខមិនស្អាត ជាសុខរបស់បុថុជ្ជន មិនមែនជាសុខរបស់ព្រះអរិយៈ ដែលគេមិនគួរធ្វើឲ្យថ្នឹក មិនគួរចម្រើន មិនគួរធ្វើឲ្យរឿយ ៗ ឡើយ តថាគតពោលថា គួរខ្លាចសេចក្តីសុខនេះ ។

[១៨៣] ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ភិក្ខុព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ព្រោះប្រាសចាកបីតិ ។ បេ ។

តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥទំ វុច្ចតិ នេក្ខម្មសុខំ វិវេកសុខំ(១) ឧបសមសុខំ សម្ពោធិសុខំ អាសេវិតព្វំ ភាវេតព្វំ ពហុលីកាតព្វំ ន ភាយិតព្វំ ឯតស្ស សុខស្សាតិ វទាមិ ។

[១៨៤] ឥធុទាយិ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អហំ ឧទាយិ ឥញ្ជិតស្មឹ វទាមិ កិញ្ច តត្ថ ឥញ្ជិតស្មឹ យទេវ តត្ថ វិតក្កវិចារា អនិរុទ្ធា ហោន្តិ ឥទំ តត្ថ ឥញ្ជិតស្មឹ ។ ឥធុទាយិ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទម្បិ ខោ អហំ ឧទាយិ ឥញ្ជិតស្មឹ វទាមិ កិញ្ច តត្ថ ឥញ្ជិតស្មឹ យទេវ តត្ថ បីតិសុខំ អនិរុទ្ធំ ហោតិ ឥទំ តត្ថ ឥញ្ជិ-តស្មឹ ។ ឥធុទាយិ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។

១ ឱ. ម. បវិវេកសុខំ ។

ចូលកាន់តតិយជ្ឈាន ព្រោះលះបង់សេចក្ដីសុខ ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន នេះទើបតថាគតហៅថា សុខផុតចាកកាម សុខស្ងប់ស្ងាត់ សុខស្ងប់រម្ងាប់ សុខប្រព្រឹត្តទៅដើម្បីសេចក្ដីត្រាស់ដឹង ដែលបុគ្គលគួរធ្វើឲ្យច្រើន គួរចម្រើន គួរធ្វើឲ្យរឿយ ៗ តថាគតហៅថា បុគ្គលមិនគួរខ្លាចសេចក្ដីសុខនេះឡើយ ។

[១៨២] ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ។ ម្នាលឧទាយី តថាគតពោលថា បឋមជ្ឈាននោះឯង ជាធម្មជាតញាប់ញ័រនៅឡើយ អ្វីដែលញាប់ញ័រ ក្នុងបឋមជ្ឈាននោះ វិតក្កៈនិងវិចារៈណា ក្នុងបឋមជ្ឈាននោះដែលមិនទាន់រំលត់នៅឡើយ នេះឯងជាធម្មជាតញាប់ញ័រ ក្នុងបឋមជ្ឈាននោះ ។ ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ។ ម្នាលឧទាយី តថាគតពោលថា ទុតិយជ្ឈាននេះឯង ជាធម្មជាតញាប់ញ័រនៅឡើយ ចុះអ្វីដែលញាប់ញ័រ ក្នុងទុតិយជ្ឈាននោះ បីតិនិងសុខណា ក្នុងទុតិយជ្ឈាននោះ ដែលមិនទាន់រំលត់នៅឡើយ នេះឯងជាធម្មជាតញាប់ញ័រ ក្នុងទុតិយជ្ឈាននោះ ។ ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះប្រាសចាកបីតិ ។ បេ ។

តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទម្បិ ខោ អយំ ឧទាយិ ឥញ្ជិតស្មឹ វទាមិ កិញ្ច តត្ថ ឥញ្ជិតស្មឹ យទេវ តត្ថ ឧបេក្ខាសុខំ អនិរុទ្ធំ ហោតិ ឥទំ តត្ថ ឥញ្ជិតស្មឹ ។ ឥធុទាយិ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អហំ ឧទាយិ អនេញ្ជិតស្មឹ វទាមិ ។

[១៨៥] ឥធុទាយិ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ អហំ ឧទាយិ អនលន្តិ វទាមិ បជហថាតិ វទាមិ សមតិក្កមថាតិ វទាមិ ។ កោ ច តស្ស សមតិក្កមោ ឥធុទាយិ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ តស្ស សមតិក្កមោ ។ ឥទម្បិ ខោ អហំ ឧទាយិ អនលន្តិ វទាមិ បជហថាតិ វទាមិ សមតិក្កមថាតិ វទាមិ ។ កោ ច តស្ស សមតិក្កមោ

ចូលកាន់តតិយជ្ឈាន ។ ម្នាលឧទាយី តថាគតពោលថា តតិយជ្ឈាន នេះឯង ជាធម្មជាតញាប់ញ័រនៅឡើយ ចុះអ្វីដែលញាប់ញ័រ ក្នុងតតិយជ្ឈាននោះ ឧបេក្ខានិងសុខណា ក្នុងតតិយជ្ឈាននោះ ដែលមិនទាន់រំលត់នៅឡើយ នេះឯង ជាធម្មជាតញាប់ញ័រ ក្នុងតតិយជ្ឈាននោះ ។ ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខ ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលឧទាយី តថាគតពោលថា ចតុត្ថជ្ឈាននេះឯង ជាធម្មជាតឥតមានញាប់ញ័រឡើយ ។

[១៨៥] ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ។ ម្នាលឧទាយី តថាគតពោលនូវបឋមជ្ឈាននេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយ ចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងចេញនូវបឋមជ្ឈាននោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈទាំងឡាយ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន នេះហៅថាការកន្លងនូវបឋមជ្ឈាននោះ ។ ម្នាលឧទាយី តថាគតពោលនូវទុតិយជ្ឈាននេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយ ចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងទុតិយជ្ឈាននោះ តើដូចម្តេច

ឥធុទាយិ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ តស្ស សមតិក្កមោ ។ ឥទម្បិ ខោ អហំ ឧទាយិ អនលន្តិ វទាមិ បជហថាតិ វទាមិ សមតិក្កមថាតិ វទាមិ ។ កោ ច តស្ស សមតិក្កមោ ឥធុទាយិ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ តស្ស សមតិក្កមោ ។ ឥទម្បិ ខោ អហំ ឧទាយិ អនលន្តិ វទាមិ បជហថាតិ វទាមិ សមតិក្កមថាតិ វទាមិ ។ កោ ច តស្ស សមតិក្កមោ ឥធុទាយិ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ តស្ស សមតិក្កមោ ។ ឥទម្បិ ខោ អហំ ឧទាយិ អនលន្តិ វទាមិ បជហថាតិ វទាមិ សមតិក្កមថាតិ វទាមិ ។ កោ ច តស្ស សមតិក្កមោ ឥធុទាយិ

ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះប្រាសចាកបីតិ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន នេះហៅថាការកន្លងនូវទុតិយជ្ឈាន ។ ម្នាលឧទាយី តថាគតពោលនូវតតិយជ្ឈាននេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវតតិយជ្ឈាននោះ តើដូចម្តេច ម្នាលឧទាយី តថាគតពោល នូវចតុត្ថជ្ឈាននេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវចតុត្ថជ្ឈាននោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់នូវបដិឃសញ្ញា ព្រោះមិនមានមនសិការៈចំពោះនានត្តសញ្ញា ដោយប្រការទាំងពួង ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុត នេះហៅថាការកន្លងនូវចតុត្ថជ្ឈាននោះ ។ ម្នាលឧទាយី តថាគតពោលនូវអាកាសានញ្ចាយតនជ្ឈាននេះឯងថា មិនទាន់ល្មម តថាគតពោលថា អ្នកទាំងឡាយចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវអាកាសានញ្ចាយតនជ្ឈាននោះ តើដូចម្តេច ម្នាលឧទាយី

ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ តស្ស សមតិក្កមោ ។ ឥធម្បិ ខោ អហំ ឧបាយំ អនលន្តិ វទាមិ បជហាថាតិ វទាមិ សមតិក្កមថាតិ វទាមិ ។ កោ ច តស្ស សមតិក្កមោ ឥធុទាយិ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ តស្ស សមតិក្កមោ ។ ឥធម្បិ ខោ អហំ ឧបាយំ អនលន្តិ វទាមិ បជហាថាតិ វទាមិ សមតិក្កមថាតិ វទាមិ ។ កោ ច តស្ស សមតិក្កមោ ឥធុទាយិ ភិក្ខុ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ តស្ស សមតិក្កមោ ។

ភិក្ខុក្នុងសាសនានេះ កន្លងនូវអាកាសានញ្ចាយតនៈ ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនៈ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះហៅថាការកន្លងនូវអាកាសានញ្ចាយតនៈនោះ ។ ម្នាលឧទាយី តថាគតពោលនូវវិញ្ញាណញ្ចាយតនៈនេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវវិញ្ញាណញ្ចាយតនៈនោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ កន្លងនូវវិញ្ញាណញ្ចាយតនៈដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនៈ ដោយបរិកម្មថា អ្វីតិចតួចមិនមានដូច្នេះ នេះហៅថាការកន្លងនូវវិញ្ញាណញ្ចាយតនៈនោះ ។ ម្នាលឧទាយី តថាគតពោលនូវអាកិញ្ចញ្ញាយតនៈនេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវអាកិញ្ចញ្ញាយតនៈនោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ កន្លងនូវអាកិញ្ចញ្ញាយតនៈដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះហៅថាការកន្លងនូវអាកិញ្ចញ្ញាយតនៈនោះ ។

ឥទម្បិ ខោ អហំ ឧទាយិ អនលន្តិ វទាមិ បជហថាតិ វទាមិ សមតិក្កមថាតិ វទាមិ ។ កោ ច តស្ស សមតិក្កមោ ឥធុទាយិ សព្វសោ នេវសញ្ញា-នាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ អយំ តស្ស សមតិក្កមោ ។ ឥតិ ខោ អហំ ឧទាយិ នេវសញ្ញានាសញ្ញាយតនស្សបិ បហានំ វទាមិ ។ បស្សសិ នោ ត្វំ ឧទាយិ តំ សញ្ញោជនំ អណុំ វា ថូលំ វា យស្សាហំ នោ បហានំ វទាមីតិ ។ នោ ហេតំ ភន្តេ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា ឧទាយី ភគវតោ ភាសិតំ អភិនន្ទីតិ ។

លដុកិកោបមសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

ម្នាលឧទាយី តថាគតពោលនូវនេវសញ្ញានាសញ្ញាយតនៈនេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវនេវសញ្ញានា-សញ្ញាយតនៈនោះ តើដូចម្ដេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ កន្លងនូវនេវសញ្ញានាសញ្ញាយតនៈ ដោយប្រការទាំងពួង ហើយចូលកាន់សញ្ញាវេទយិតនិរោធ (រលត់សញ្ញាព្រមទាំងវេទនា) នេះហៅថាការកន្លងនូវនេវសញ្ញានាសញ្ញាយតនៈនោះ ។ ម្នាលឧទាយី តថាគតពោលនូវការលះបង់នេវសញ្ញានាសញ្ញាយតនៈដូច្នេះឯង ។ ម្នាលឧទាយី តថាគតពោល នូវការលះបង់សំយោជនៈណា អ្នកឃើញសំយោជនៈទាំងតូចទាំងធំនោះឬទេ ។ ឧទាយីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើនមិនឃើញទេ ។ លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះឧទាយីមានអាយុ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ លដុកិកោបមសូត្រ ជាគម្រប់ ៦ ។

# សត្តមំ ចាតុមសុត្តំ

[១៨៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ចាតុមាយំ វិហរតិ អាមលកីវនេ ។ តេន ខោ បន សមយេន សារីបុត្តមោគ្គល្លានប្បមុខានិ បញ្ចមត្តានិ ភិក្ខុសតានិ ចាតុមំ អនុប្បត្តានិ ហោន្តិ ភគវន្តំ ទស្សនាយ ។ តេ ច អាគន្តុកា ភិក្ខូ នេវាសិកេហិ ភិក្ខូហិ សទ្ធឹ បដិសម្មោទមានា សេនាសនានិ បញ្ញាបយមានា បត្តចីវរានិ បដិសាមយមានា ឧច្ចាសទ្ទា មហាសទ្ទា អហេសុំ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ កេ បនេតេ អានន្ទ ឧច្ចាសទ្ទា មហាសទ្ទា កេវដ្ដា មញ្ញេ មច្ឆំ វិលោបេន្តីតិ ។ ឯតានិ ភន្តេ សារីបុត្តមោគ្គល្លានប្បមុខានិ បញ្ចមត្តានិ ភិក្ខុសតានិ ចាតុមំ អនុប្បត្តានិ ភគវន្តំ ទស្សនាយ តេ អាគន្តុកា ភិក្ខូ នេវាសិកេហិ ភិក្ខូហិ សទ្ធឹ បដិសម្មោទមានា អាសនានិ[១] បញ្ញាបយមានា បត្តចីវរានិ បដិសាមយមានា

១ ឱ. ម. សេនាសនានិ ។

# ចាតុមសូត្រ ទី ៧

[១៨៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអាមលកីវ័ន (ព្រៃកន្ទួតព្រៃ) ក្នុងស្រុកចាតុមា ។ ក៏សម័យនោះ ពួកភិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្តនិងព្រះមោគ្គល្លានជាប្រធាន និមន្តទៅដល់ស្រុកចាតុមា ដើម្បីគាល់ព្រះមានព្រះភាគ ។ ក៏ឯពួកភិក្ខុអាគន្តុកៈអម្បាលនោះ ក៏និយាយរាក់ទាក់មួយអន្លើដោយពួកនេវាសិកភិក្ខុ ប្រើគ្នានិងគ្នាឲ្យក្រាលសេនាសនៈ ឲ្យរៀបចំទុកដាក់បាត្រចីវរ មានសំឡេងគឹកកងសំឡេងអ៊ូអា ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកសួរថា ម្នាលអានន្ទ ចុះសំឡេងគឹកកងអ៊ូអាទាំងនុ៎ះតើជាសំឡេងអ្វី ហាក់ដូចជាពួកព្រានសំណាញ់ដណ្តើមចាប់ត្រី ដូច្នោះ ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្តនិងព្រះមោគ្គល្លានជាប្រធាននុ៎ះ មកដល់ស្រុកចាតុមា ដើម្បីគាល់ព្រះមានព្រះភាគ ពួកអាគន្តុកភិក្ខុអម្បាលនោះ ក៏និយាយរាក់ទាក់មួយអន្លើ ដោយពួកនេវាសិកភិក្ខុ ប្រើគ្នានិងគ្នាឲ្យក្រាលអាសនៈ ឲ្យរៀបចំទុកដាក់បាត្រនិង

៣៣១



ឧច្ចាសទ្ទា មហាសទ្ទាតិ ។ តេនាហានន្ទ មម វចនេន ភិក្ខូ[1] អាមន្តេហិ សត្ថា អាយស្មន្តេ[2] អាមន្តេសីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច សត្ថា អាយស្មន្តេ[3] អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ ភគវា ឯតទវោច កិន្នុ តុម្ហេ ភិក្ខវេ ឧច្ចាសទ្ទា មហាសទ្ទា កេវដ្ដា មញ្ញេ មច្ឆំ វិលោបេន្តីតិ ។ ឥមានិ ភន្តេ សារីបុត្តមោគ្គល្លានប្បមុខានិ បញ្ចមត្តានិ ភិក្ខុសតានិ ចាតុមំ អនុប្បត្តានិ ភគវន្តំ ទស្សនាយ តេមេ អាគន្តុកា ភិក្ខូ នេវាសិកេហិ ភិក្ខូហិ សទ្ធឹ បដិសម្មោទមានា សេនាសនានិ បញ្ញាបយមានា បត្តចីវរានិ បដិសាមយមានា ឧច្ចាសទ្ទា

---

១ ឱ. ម. តេ ភិក្ខូ ។ ២-៣ ឱ. សត្ថាយស្មន្តេ ។

ចីវរ ទើបមានសំឡេងគឹកកងអ៊ូអាដូច្នេះ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរហៅភិក្ខុទាំងឡាយមក តាមពាក្យរបស់តថាគតថា ព្រះសាស្ដា ទ្រង់ត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ព្រះអានន្ទមានអាយុ ទទួលស្ដាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅរកពួកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ បាននិយាយនឹងភិក្ខុទាំងនោះយ៉ាងនេះថា ព្រះសាស្ដា ទ្រង់ត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលស្ដាប់ពាក្យព្រះអានន្ទមានអាយុថា ករុណាលោកមានអាយុ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុទាំង-ឡាយ ដូចម្ដេចបានជាអ្នកទាំងឡាយ មានសំឡេងគឹកកងអ៊ូអា បីដូចជាពួកព្រានសំណាញ់ ដណ្ដើមចាប់ត្រីដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្តនិងព្រះមោគ្គល្លានជាប្រធាននេះ មកដល់ស្រុកចាតុមា ដើម្បីនឹងគាល់ព្រះមានព្រះភាគ អាគន្តុកភិក្ខុអម្បាលនោះ ក៏និយាយរាក់ទាក់ជាមួយពួកនេវាសិកភិក្ខុ ប្រើគ្នានិងគ្នាឲ្យក្រាលសេនាសនៈ ឲ្យរៀបចំទុកដាក់បាត្រចីវរ ទើបមានសំឡេងគឹក

មហាសង្ឃាតិ ។ គច្ឆថ ភិក្ខវេ បណាមេមិ វោ ន វោ មម សន្តិកេ វត្ថព្វន្តិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ បក្កមឹសុ ។

[១៨៧] តេន ខោ បន សមយេន ចាតុមេយ្យកា សក្យា សន្ធាគារេ សន្និបតិតា ហោន្តិ កេនចិទេវ ករណីយេន ។ អទ្ទសំសុ[១] ខោ ចាតុមេយ្យកា សក្យា តេ ភិក្ខូ ទូរតោវ អាគច្ឆន្តេ ទិស្វាន យេន តេ ភិក្ខូ តេនុបសង្កមឹសុ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោចុំ ហន្ទ កហំ បន តុម្ហេ អាយស្មន្តោ គច្ឆថាតិ ។ ភគវតា ខោ អាវុសោ ភិក្ខុសង្ឃោ បណាមិតោតិ ។ តេនហាយស្មន្តោ មុហុត្តំ និសីទថ អប្បេវនាម មយំ សក្កុណេយ្យាម ភគវន្តំ បសាទេតុន្តិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ ចាតុមេយ្យកានំ សក្យានំ បច្ចស្សោសុំ ។ អថខោ

១ ឱ. អទ្ទសាសុំ ។

កង់អ៊ូអាដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទៅទៅ តថាគត បណ្តេញអ្នកទាំងឡាយ អ្នកទាំងឡាយមិនគួរនៅ ក្នុងសំណាក់តថាគត ទេ ។ ភិក្ខុអម្បាលនោះ ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគ ថា ព្រះករុណាព្រះអង្គ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះ មានព្រះភាគ ធ្វើប្រទក្សិណហើយរៀបចំទុកដាក់សេនាសនៈ ហើយ កាន់យកបាត្រនិងចីវរចៀសចេញទៅ ។

[១៨៧] ក៏សម័យនោះ សក្យៈទាំងឡាយ អ្នកស្រុកចាតុមាប្រជុំ គ្នាក្នុងរោងភាក់អាស្រ័យដោយកិច្ច ដែលគួរធ្វើណាមួយ ។ លុះសក្យៈ ទាំងឡាយអ្នកស្រុកចាតុមា បានឃើញភិក្ខុទាំងឡាយនោះ កំពុងដើរមក ពីចម្ងាយ លុះឃើញច្បាស់ហើយ បានចូលទៅរកភិក្ខុទាំងអម្បាលនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងភិក្ខុទាំងអម្បាលនោះ ថា បពិត្រលោកមានអាយុទាំងឡាយ លោកទាំងឡាយនិមន្តទៅណា ។ ម្នាលអាវុសោ ព្រះមានព្រះភាគ បានបណ្តេញភិក្ខុសង្ឃទៅហើយ ។ បពិត្រលោកមានអាយុទាំងឡាយ បើដូច្នោះ សូមលោកទាំងឡាយ និមន្តគង់មួយរំពេចសិន ក្រែងជួនជាយើងទាំងឡាយ សម្រួលព្រះទ័យ ព្រះមានព្រះភាគបាន ។ ភិក្ខុទាំងនោះ ទទួលស្តាប់សក្យៈទាំងឡាយ អ្នកស្រុកចាតុមាថា ថ្វាយព្រះពរ សក្យៈមានអាយុ ។ លំដាប់នោះ

៣៣៣

### ភិក្ខុវគ្គស្ស ចាតុមសុត្តេ សក្យានំ ភគវន្តូបសង្កមនំ

ចាតុមេយ្យកា សក្យា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ ចាតុមេយ្យកា សក្យា ភគវន្តំ ឯតទវោចុំ អភិនន្ទតុ ភន្តេ ភគវា ភិក្ខុសង្ឃំ អភិវទតុ ភន្តេ ភគវា ភិក្ខុសង្ឃំ សេយ្យថាបិ ភន្តេ ភគវតា បុព្វេ ភិក្ខុសង្ឃោ អនុគ្គហិតោ ឯវមេវ ភគវា ឯតរហិ អនុគ្គណ្ហាតុ ភិក្ខុសង្ឃំ សន្តេត្ថ ភន្តេ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ ភគវន្តំ ទស្សនាយ អលភន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ សេយ្យថាបិ ភន្តេ ពីជានំ តរុណានំ ឧទកំ អលភន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ ឯវមេវ[១] ភន្តេ សន្តេត្ថ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ

១ ឱ. ម. ឯវមេវ ខោ ។

សក្យៈទាំងឡាយអ្នកស្រុកចាតុមា បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសក្យៈទាំងឡាយអ្នកស្រុកចាតុមា គង់ក្នុងទីសមគួរហើយ បានក្រាបទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគត្រេកអរ (នឹងការចូលមកវិញនៃភិក្ខុសង្ឃ) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុសង្ឃ (ថាចូរមកវិញ) ចុះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃដែលព្រះមានព្រះភាគ ធ្លាប់ទ្រង់អនុគ្រោះហើយក្នុងកាលមុន ដោយប្រការយ៉ាងណា ឥឡូវនេះសូមព្រះមានព្រះភាគ ទ្រង់អនុគ្រោះភិក្ខុសង្ឃយ៉ាងនោះទៀត បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃដែលមានក្នុងទីនេះជាភិក្ខុថ្មី បួសហើយមិនយូរប៉ុន្មាន ទើបតែនឹងមកកាន់ធម្មវិន័យនេះ កាលភិក្ខុទាំងឡាយនោះ មិនបានជួបនឹងព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តីរាយមាយនិងសេចក្តីប្រែប្រួលពុំខាន បពិត្រព្រះអង្គដ៏ចម្រើន ដូចជាពូជទាំងឡាយដ៏ខ្ចី កាលមិនមានទឹកហើយ នឹងស្វិតស្រពោន ឬប្រែប្រួលយ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលមានក្នុងទីនេះ ជាភិក្ខុថ្មីបួសហើយមិនយូរប៉ុន្មាន ទើបតែនឹងមកកាន់ធម្មវិន័យនេះ កាលភិក្ខុទាំងនោះ

ភគវន្តំ ឧស្សជាយ អលភន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ សេយ្យថាបិ ភន្តេ វច្ឆស្ស តរុណស្ស មាតរំ អបស្សន្តស្ស សិយា អញ្ញថត្តំ សិយា វិបរិណាមោ ឯវមេវ ខោ ភន្តេ សន្តេត្ថ ភិក្ខូ នវា អចិរប្បព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ ភគវន្តំ អបស្សន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ អភិនន្ទតុ ភន្តេ ភគវា ភិក្ខុសង្ឃំ អភិវទតុ ភន្តេ ភគវា ភិក្ខុសង្ឃំ សេយ្យថាបិ ភន្តេ ភគវតា បុព្វេ ភិក្ខុសង្ឃោ អនុគ្គហិតោ ឯវមេវ ភគវា ឯតរហិ អនុគ្គណ្ហាតុ ភិក្ខុសង្ឃន្តិ ។

[១៨៨] អថខោ ព្រហ្មា សហម្បតិ ភគវតោ ចេតសា ចេតោ បរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ ភគវតោ បុរតោ បាតុរហោសិ ។ អថខោ

មិនបានជួបព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តីពាយមាយ និង សេចក្តីប្រែប្រួល ពុំខាន យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ដូច កូនគោតូច កាលមិនឃើញមេហើយ មុខជានឹងស្គាំងស្គម ឬប្រែប្រួល យ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលមានក្នុងទីនេះ ជាភិក្ខុថ្មី បួសហើយមិនយូរប៉ុន្មាន ទើបតែនឹងមកកាន់ធម្មវិន័យនេះ កាលភិក្ខុទាំង-ឡាយនោះ មិនបានជួបនឹងព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តី ពាយមាយ និងសេចក្តីប្រែប្រួលពុំខាន យ៉ាងនោះឯង បពិត្រព្រះអង្គ ដ៏ចម្រើន សូមព្រះមានព្រះភាគ ត្រេកអរ (នឹងការចូលមកវិញនៃភិក្ខុសង្ឃ) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុសង្ឃ (ថា ចូរមកវិញ) ចុះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃដែលព្រះមានព្រះភាគ ធ្លាប់អនុគ្រោះហើយក្នុងកាលមុន ដោយប្រការ យ៉ាងណា ឥឡូវនេះ សូមព្រះមានព្រះភាគ ទ្រង់អនុគ្រោះភិក្ខុសង្ឃ យ៉ាងនោះទៀត ។

[១៨៨] គ្រានោះ សហម្បតិព្រហ្ម បានជ្រាបសេចក្តីបរិវិតក្កៈ ក្នុងព្រះហឫទ័យនៃព្រះមានព្រះភាគ ដោយចិត្ត (របស់ខ្លួន) ហើយ ក៏ស្រាប់តែបាត់ អំពីព្រហ្មលោកមួយរំពេច ហើយមកប្រាកដនៅទី ចំពោះព្រះភក្ត្រព្រះមានព្រះភាគ ហាក់ដូចបុរស មានកម្លាំង លាដៃ ដែលខ្លួនបត់ចូល ឬបត់ដៃដែលខ្លួនលាចេញ ។ លំដាប់នោះ

ព្រហ្មា សហម្បតិ ឯកំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច អភិនន្ទតុ ភន្តេ ភគវា ភិក្ខុសង្ឃំ អភិវទតុ ភន្តេ ភគវា ភិក្ខុសង្ឃំ សេយ្យថាបិ ភន្តេ ភគវតា បុព្វេ ភិក្ខុសង្ឃោ អនុគ្គហិតោ ឯវមេវ ភគវា ឯតរហិ អនុគ្គណ្ហាតុ ភិក្ខុសង្ឃំ សន្តេត្ថ ភន្តេ ភិក្ខូ នវា អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ ភគវន្តំ ទស្សនាយ អលភន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ សេយ្យថាបិ ភន្តេ ពីជានំ តរុណានំ ឧទកំ អលភន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ ឯវមេវ ភន្តេ[១]

---

១ ឱ. ម. ឯវមេវ ខោ ។

សហម្បតិព្រហ្ម ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីទៅរកព្រះមានព្រះភាគ ក្រាបទូលសេចក្តីនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគត្រេកអរ (នឹងការចូលមកនៃភិក្ខុសង្ឃ) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុសង្ឃ (ថាចូរមកចុះ) បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃដែលព្រះមានព្រះភាគ ធ្លាប់អនុគ្រោះហើយ ក្នុងកាលមុន ដោយប្រការយ៉ាងណាឥឡូវនេះ សូមព្រះមានព្រះភាគ អនុគ្រោះភិក្ខុសង្ឃដោយប្រការយ៉ាងនោះទៀត បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុដែលមានក្នុងទីនេះ ជាភិក្ខុថ្មីបួសហើយមិនយូរប៉ុន្មាន ទើបតែមកកាន់ធម្មវិន័យនេះ កាលបើភិក្ខុទាំងនោះ មិនបានជួបនឹងព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តីភាយ-មាយ និងសេចក្តីប្រែប្រួលជាពុំខាន បពិត្រព្រះអង្គដ៏ចម្រើន ដូចពូជទាំងឡាយដ៏ខ្ចី កាលមិនបានទឹកហើយ នឹងមានការស្វិតស្រពោន ឬនឹងមានដំណើរប្រែប្រួលពុំខាន យ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន

សន្តេត្ថ ភិក្ខូ ឥធ អចិរប្បព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ ភគវន្តំ ទស្សនាយ អលភន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ សេយ្យថាបិ ភន្តេ វច្ឆស្ស តរុណស្ស មាតរំ អបស្សន្តស្ស សិយា អញ្ញថត្តំ សិយា វិបរិណាមោ ឯវមេវ ខោ ភន្តេ សន្តេត្ថ ភិក្ខូ ឥធ អចិរប្បព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេសំ ភគវន្តំ អបស្សន្តានំ សិយា អញ្ញថត្តំ សិយា វិបរិណាមោ អភិនន្ទតុ ភន្តេ ភគវា ភិក្ខុសង្ឃំ អភិវទតុ ភន្តេ ភគវា ភិក្ខុសង្ឃំ សេយ្យថាបិ ភន្តេ ភគវតា បុព្វេ ភិក្ខុសង្ឃោ អនុគ្គហិតោ ឯវមេវ ភគវា ឯតរហិ អនុគ្គណ្ហាតុ ភិក្ខុសង្ឃន្តិ ។ អសក្ខឹសុ ខោ ចាតុមេយ្យកា ច សក្យា ព្រហ្មា ច សហម្បតិ ភគវន្តំ បសាទេតុំ ពីជូបមេន ច តរុណូបមេន ចាតិ[១] ។

---

១ ឱ. ម. ច ។

ពួកភិក្ខុដែលមានក្នុងទីនេះ ជាភិក្ខុថ្មីបួសហើយមិនយូរប៉ុន្មាន ទើបតែមកកាន់ធម្មវិន័យនេះ កាលភិក្ខុទាំងនោះ មិនបានជួបនឹងព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តីពាយមាយ និងសេចក្តីប្រែប្រួល ពុំខានយ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ដូចកូនគោតូច កាលមិនឃើញមេហើយ នឹងមានការស្គាំងស្គម ឬប្រែប្រួលពុំខាន យ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុដែលមានក្នុងទីនេះ ជាភិក្ខុថ្មី បួសហើយមិនយូរប៉ុន្មាន ទើបតែមកកាន់ធម្មវិន័យនេះ កាលបើភិក្ខុទាំងនោះ មិនបានជួបនឹងព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តីពាយមាយ និងសេចក្តីប្រែប្រួលពុំខាន យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគត្រេកអរ (នឹងការចូលមកនៃភិក្ខុសង្ឃ) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុសង្ឃ (ថាចូរមកចុះ) បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃដែលព្រះមានព្រះភាគ ធ្លាប់អនុគ្រោះហើយ ក្នុងកាលមុន ដោយប្រការយ៉ាងណា ឥឡូវនេះសូមព្រះមានព្រះភាគ ទ្រង់អនុគ្រោះភិក្ខុសង្ឃដោយប្រការយ៉ាងនោះទៀត ។ សក្យៈទាំងឡាយអ្នកស្រុកចាតុមានិងសហម្បតិព្រហ្ម អាចធ្វើព្រះមានព្រះភាគឲ្យត្រេកអរបាន ដោយពាក្យប្រៀបធៀបនឹងពូជផង ដោយពាក្យប្រៀបធៀបនឹងកូនគោតូចផង ។

៣៣៧

ភិក្ខុវគ្គស្ស ចាតុមសុត្តេ ភិក្ខូនំ ភគវន្តូបសង្កមនំ

[១៨៩] អថខោ អាយស្មា មហាមោគ្គល្លានោ ភិក្ខូ អាមន្តេសិ ឧដ្ឋេថាវុសោ(១) គណ្ហថ បត្តចីវរំ បសាទិតោ ភគវា ចាតុមេយ្យកេហិ ច សក្យេហិ ព្រហ្មុនា ច សហម្បតិនា ពីជូបមេន ច តរុណូបមេន ចាតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាមោគ្គល្លានស្ស បដិស្សុត្វា ឧដ្ឋាយាសនា បត្តចី-វរមាទាយ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សារីបុត្តំ ភគវា ឯតទវោច កិន្តិ តេ សារីបុត្ត អហោសិ មយា ភិក្ខុសង្ឃេ បណាមិតេតិ(២) ។ ឯវំ ខោ មេ ភន្តេ អហោសិ ភគ-វតា ភិក្ខុសង្ឃេ បណាមិតេ អប្បោស្សុក្កោ ទានិ ភគវា ទិដ្ឋធម្មសុខវិហារំ អនុយុត្តោ វិហរិស្សតិ មយម្បិ ទានិ

---

១ ម. អយមេវ បាឋោ ។ ឱ. ឧដ្ឋហថាវុសោ ។ ២ ម. ភិក្ខុសង្ឃោ បណាមិតោតិ ។

[១៨៩] លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ បានប្រាប់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ អ្នកទាំងឡាយចូរក្រោកកាន់បាត្រនិងចីវរឡើង ដ្បិតសក្យៈទាំងឡាយអ្នកស្រុកចាតុមា និងសហម្បតិព្រហ្ម បានសម្រួលព្រះទ័យព្រះមានព្រះភាគ ដោយពាក្យប្រៀបធៀបនឹងពូជផង ដោយពាក្យប្រៀបធៀបនឹងកូនគោតូចផង ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះមោគ្គល្លានមានអាយុថា ករុណាលោកមានអាយុ ហើយក៏ក្រោកចាកអាសនៈ កាន់យកបាត្រចីវរហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ កាលដែលព្រះសារីបុត្តមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលសារីបុត្ត កាលបើភិក្ខុសង្ឃ ដែលតថាគតបណ្តេញហើយ តើអ្នកមានគំនិតដូចម្តេច ។ ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃដែលព្រះមានព្រះភាគ ទ្រង់បណ្តេញហើយ ខ្ញុំព្រះអង្គមានគំនិតយ៉ាងនេះថា សូមព្រះមានព្រះភាគ មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបរឿយ ៗ នូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ក្នុងកាលឥឡូវនេះចុះ សូម្បីខ្ញុំព្រះអង្គ

អប្បោស្សុក្កា ទិដ្ឋធម្មសុខវិហារមនុយុត្តា វិហរិស្សាមាតិ ។ អាគមេហិ ត្វំ សារីបុត្ត អាគមេហិ ត្វំ សារីបុត្ត[១] ន ខោ តេ សារីបុត្ត បុនបិ ឯវរូបំ ចិត្តំ ឧប្បាទេតព្វន្តិ ។ អថខោ ភគវា អាយស្មន្តំ មហាមោគ្គល្លានំ អាមន្តេសិ កិន្តិ តេ មោគ្គល្លាន អហោសិ មយា ភិក្ខុសង្ឃេ បណាមិតេតិ ។ ឯវំ ខោ មេ ភន្តេ អហោសិ ភគវតា ភិក្ខុសង្ឃេ បណាមិតេ អប្បោស្សុក្កោទានិ ភគវា ទិដ្ឋធម្មសុខវិហារំ អនុយុត្តោ វិហរិស្សតិ អហញ្ចទានិ អាយស្មា ច សារីបុត្តោ ភិក្ខុសង្ឃំ បរិហរិស្សាមាតិ ។ សាធុ សាធុ មោគ្គល្លាន អហំ វា ហិ មោគ្គល្លាន ភិក្ខុសង្ឃំ បរិហរេយ្យំ សារីបុត្តមោគ្គល្លានា វាតិ ។

[១៩០] អថខោ ភគវា ភិក្ខូ អាមន្តេសិ ចត្តារិមានិ ភិក្ខវេ ភយានិ ឧទកោរោហន្តេ បាដិកង្ខិតព្វានិ កតមានិ ចត្តារិ ឩម្មិភយំ កុម្ភីលភយំ

---

១ ម. ឥតោ បរំ ទិដ្ឋធម្មសុខវិហារន្តិ បាឋោ ទិស្សតិ ។

ទាំងឡាយ ក៏មានសេចក្តីខ្វល់ខ្វាយតិច ប្រកបរឿយ ៗ នូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ក្នុងកាលឥឡូវនេះដែរ ។ ម្នាលសារីបុត្ត អ្នកចូរឈប់សិនចុះ ម្នាលសារីបុត្ត អ្នកចូរឈប់សិនចុះ ម្នាលសារីបុត្ត គំនិតរបស់អ្នកមានសភាពយ៉ាងនេះ មិនគួរឲ្យកើតឡើងទៀតទេ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរព្រះមហាមោគ្គល្លានមានអាយុថា ម្នាលមោគ្គល្លាន កាលបើភិក្ខុសង្ឃដែលតថាគតបណ្តេញចេញហើយ តើអ្នកមានគំនិតដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃដែលព្រះមានព្រះភាគ ទ្រង់បណ្តេញចេញហើយ ខ្ញុំព្រះអង្គមានគំនិតយ៉ាងនេះថា សូមព្រះមានព្រះភាគ មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបរឿយ ៗ នូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ក្នុងកាលឥឡូវនេះចុះ ឯខ្ញុំព្រះអង្គនិងព្រះសារីបុត្តមានអាយុ នឹងគ្រប់គ្រងភិក្ខុសង្ឃជំនួសព្រះអង្គ ។ ម្នាលមោគ្គល្លាន ប្រពៃហើយ ម្នាលមោគ្គល្លាន ដ្បិតថា តថាគតក្តី សារីបុត្តក្តី មោគ្គល្លានក្តី គួរគ្រប់គ្រងភិក្ខុសង្ឃមែនហើយ ។

[១៩០] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយនេះ មាន ៤ យ៉ាង តែងមានចំពោះបុគ្គលអ្នកចុះទឹក ភ័យ ៤ យ៉ាងនោះ ដូចម្តេចខ្លះ ភ័យ ៤ យ៉ាងគឺ ភ័យកើតពីរលក ១ ភ័យកើតពីក្រពើ ១ ភ័យកើតពី

អាវដ្ដភយំ សុសុកាភយំ ឥមានិ ខោ ភិក្ខវេ ចត្តារិ ភយានិ ឧទកោរោហន្តេ បាដិកង្ខិតព្វានិ ឯវមេវ ខោ ភិក្ខវេ ចត្តារិមានិ ភយានិ ឥធេកច្ចេ បុគ្គលេ ឥមស្មឹ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិតេ បាដិកង្ខិតព្វានិ កតមានិ ចត្តារិ ឧម្មិភយំ កុម្ភីលភយំ អាវដ្ដភយំ សុសុកាភយំ ។

[១៩១] កតមញ្ច ភិក្ខវេ ឧម្មិភយំ ឥធ ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខ-បរេតោ អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ តមេនំ តថា បព្វជិតំ សមានំ សព្រហ្មចារី ឱវទន្តិ អនុសាសន្តិ ឯវន្តេ អភិក្កមិតព្វំ ឯវន្តេ បដិក្កមិតព្វំ ឯវន្តេ អាលោ-កិតព្វំ ឯវន្តេ វិលោកិតព្វំ ឯវន្តេ សម្មិញ្ជិតព្វំ

អន្ទង់ទឹក ១ ភ័យកើតពីត្រីសាហាវ ១ ម្នាលភិក្ខុទាំងឡាយ ភ័យទាំង ៤ នេះឯង តែងមានចំពោះបុគ្គលអ្នកចុះទឹក ម្នាលភិក្ខុទាំងឡាយ ភ័យ ៤ យ៉ាង តែងមានចំពោះបុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលចេញចាកផ្ទះហើយ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យនេះដែរ ភ័យ ៤ យ៉ាងនោះតើដូចម្តេចខ្លះ គឺ ភ័យកើតពីរលក ១ ភ័យកើតពីក្រពើ ១ ភ័យកើតពីអន្ទង់ទឹក ១ ភ័យកើតពីត្រីសាហាវ ១ ។

[១៩១] ម្នាលភិក្ខុទាំងឡាយ ភ័យកើតអំពីរលក តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ កុលបុត្តពួកខ្លះ ក្នុងធម្មវិន័យនេះ ចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ និងសេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងឧបាយាសៈ គឺសេចក្តីខ្ញាលផ្សាចិត្តគ្របសង្កត់ ឈ្មោះថាមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតហើយ ឱធ្វើម្តេចហ្ន៎ ការធ្វើនូវទីបំផុតទុក្ខទាំងអស់នេះ នឹងច្បាស់ប្រាកដបាន ។ កាលពួកកុលបុត្រនោះបួសហើយ សព្រហ្មចារីបុគ្គលទាំងឡាយ តែងទូន្មានប្រៀនប្រដៅយ៉ាងនេះថា អ្នកគប្បីឈានទៅខាងមុខយ៉ាងនេះ អ្នកគប្បីឈានថយក្រោយយ៉ាងនេះ អ្នកគប្បីក្រឡេកមើលទៅខាងមុខយ៉ាងនេះ អ្នកគប្បីងាកឆ្វេងងាកស្តាំយ៉ាងនេះ អ្នកគប្បីអង្គុញ

ឯវន្តេ បសារិតព្វំ ឯវន្តេ សង្ឃាដិបត្តចីវរំ ធារេតព្វន្តិ ។ តស្ស ឯវំ ហោតិ មយំ បុព្វេ អគារិយភូតា សមានា អញ្ញេ ឱវទាមបិ អនុសាសាមបិ ឥមេ បនម្ហាកំ បុត្តមត្តា មញ្ញេ នត្តមត្តា មញ្ញេ អម្ហេ ឱវទិតព្វំ អនុសាសិតព្វំ មញ្ញន្តីតិ ។ សោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ អយំ វុច្ចតិ ភិក្ខវេ ឩម្មិភយស្ស ភីតោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោ ។ ឩម្មិភយន្តិ ខោ ភិក្ខវេ កោធុបាយាសស្សេតំ អធិវចនំ ។

[១៩២] កតមញ្ច ភិក្ខវេ កុម្ភីលភយំ ឥធ ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខ-បរេតោ អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ តមេនំ តថា បព្វជិតំ សមានំ សព្រហ្មចារី ឱវទន្តិ អនុសា-សន្តិ ឥទំ តេ ខាទិតព្វំ ឥទំ តេ ន ខាទិតព្វំ

យ៉ាងនេះ អ្នកគប្បីសណ្ដូកយ៉ាងនេះ អ្នកគប្បីទ្រទ្រង់សំពត់សង្ឃាដី បាត្រចីវរយ៉ាងនេះ ។ កុលបុត្តនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលពីមុន យើងនៅជាគ្រហស្ថ តែងទូន្មានប្រៀនប្រដៅជនទាំងឡាយដទៃ ឯសព្រហ្មចារីបុគ្គលទាំងឡាយនេះ ប្រហែលនឹងកូនចៅរបស់យើងស្មានថា យើងជាបុគ្គលគួរទូន្មានប្រៀនប្រដៅបាន ។ កុលបុត្តនោះក៏លាសិក្ខាវិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តនេះ តថាគតពោលថា មានភ័យអំពីរលក បានដាពោល លាសិក្ខាវិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីរលក នុ៎ះជាឈ្មោះនៃសេចក្ដីក្រោធនិងឧបាយាសៈ ។

[១៩២] ម្នាលភិក្ខុទាំងឡាយ ភ័យកើតអំពីក្រពើ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ កុលបុត្តពួកមួយ ក្នុងធម្មវិន័យនេះ ចេញចាកផ្ទះហើយចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈនិងសេចក្ដីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្ដីខ្វាចផ្សាចិត្ត គ្របសង្កត់ ឈ្មោះថាមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតហើយ ឱធ្វើម្ដេចហ្ន៎ ការធ្វើនូវទីបំផុតទុក្ខទាំងអស់នេះ នឹងច្បាស់ប្រាកដបាន ។ កាលដែលកុលបុត្តនោះបួសហើយ សព្រហ្មចារីបុគ្គលទាំងឡាយ តែងទូន្មានប្រៀនប្រដៅយ៉ាងនេះថា របស់នេះអ្នកគួរទំពា របស់នេះអ្នកមិនគួរ

ឥធំ តេ កុញ្ជិតព្វំ ឥធំ តេ ន កុញ្ជិតព្វំ ឥធំ តេ សាយិតព្វំ ឥធំ តេ ន សាយិតព្វំ ឥធំ តេ ចាតព្វំ ឥធំ តេ ន ចាតព្វំ កប្បិយំ តេ ខាទិតព្វំ អកប្បិយំ តេ ន ខាទិតព្វំ កប្បិយំ តេ កុញ្ជិតព្វំ អកប្បិយំ តេ ន កុញ្ជិតព្វំ កប្បិយំ តេ សាយិតព្វំ អកប្បិយំ តេ ន សាយិតព្វំ កប្បិយំ តេ ចាតព្វំ អកប្បិយំ តេ ន ចាតព្វំ កាលេ តេ ខាទិតព្វំ វិកាលេ តេ ន ខាទិតព្វំ កាលេ តេ កុញ្ជិតព្វំ វិកាលេ តេ ន កុញ្ជិតព្វំ កាលេ តេ សាយិតព្វំ វិកាលេ តេ ន សាយិតព្វំ កាលេ តេ ចាតព្វំ វិកាលេ តេ ន ចាតព្វន្តិ ។ តស្ស ឯវំ ហោតិ មយំ ខោ បុព្វេ អគារិយភូតា សមានា យំ ឥច្ឆាម តំ ខាទាម យំ ន ឥច្ឆាម ន តំ ខាទាម យំ ឥច្ឆាម តំ កុញ្ជាម យំ ន ឥច្ឆាម ន តំ កុញ្ជាម យំ ឥច្ឆាម តំ សាយាម យំ ន ឥច្ឆាម ន តំ សាយាម យំ ឥច្ឆាម តំ បិវាម[១] យំ ន ឥច្ឆាម

១ ឱ. បិបាម ។

ទំពា របស់នេះអ្នកគួរឆាន់ របស់នេះអ្នកមិនគួរឆាន់ របស់នេះអ្នកគួរជញ្ជក់ជញ្ជាប របស់នេះអ្នកមិនគួរជញ្ជក់ជញ្ជាប របស់នេះអ្នកគួរក្រេបផឹក របស់នេះអ្នកមិនគួរក្រេបផឹក (របស់នេះ) ជាកប្បិយវត្ថុ អ្នកគួរទំពា ជាអកប្បិយវត្ថុ អ្នកមិនគួរទំពា ជាកប្បិយវត្ថុអ្នកគួរឆាន់ ជាអកប្បិយវត្ថុ អ្នកមិនគួរឆាន់ ជាកប្បិយវត្ថុ អ្នកគួរជញ្ជក់ជញ្ជាប ជាអកប្បិយវត្ថុ អ្នកមិនគួរជញ្ជក់ជញ្ជាប ជាកប្បិយវត្ថុ អ្នកគួរក្រេបផឹក ជាអកប្បិយវត្ថុ អ្នកមិនគួរក្រេបផឹក របស់នេះគួរទំពាក្នុងកាល (គឺតាំងពីព្រឹកដល់ថ្ងៃត្រង់) របស់នេះអ្នកមិនគួរទំពាក្នុងវិកាល (គឺតាំងពីថ្ងៃជ្រេទៅ) របស់នេះអ្នកគួរឆាន់ក្នុងកាល របស់នេះអ្នកមិនគួរឆាន់ក្នុងវិកាល របស់នេះអ្នកគួរជញ្ជក់ជញ្ជាបក្នុងកាល របស់នេះអ្នកមិនគួរជញ្ជក់ជញ្ជាបក្នុងវិកាល របស់នេះអ្នកគួរក្រេបផឹកក្នុងកាល របស់នេះអ្នកមិនគួរក្រេបផឹកក្នុងវិកាល ។ កុលបុត្តនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុន យើងនៅជាគ្រហស្ថ យើងចង់របស់ណា ក៏ទំពារបស់នោះបាន យើងមិនចង់របស់ណាក៏មិនទំពារបស់នោះ យើងចង់របស់ណា ក៏បរិភោគរបស់នោះបាន យើងមិនចង់របស់ណា ក៏មិនបរិភោគរបស់នោះ យើងចង់របស់ណាក៏ជញ្ជក់ជញ្ជាបរបស់នោះ យើងមិនចង់របស់ណាក៏មិនជញ្ជក់ជញ្ជាបរបស់នោះ យើងចង់របស់ណា ក៏ក្រេបផឹករបស់នោះ យើងមិនចង់របស់ណា

ច តំ បិវាម កប្បិយម្បិ ខាទាម អកប្បិយម្បិ ខាទាម កប្បិយម្បិ ភុញ្ជាម អកប្បិយម្បិ ភុញ្ជាម កប្បិយម្បិ សាយាម អកប្បិយម្បិ សាយាម កប្បិយម្បិ បិវាម អកប្បិយម្បិ បិវាម កាលេបិ ខាទាម វិកាលេបិ ខាទាម កាលេបិ ភុញ្ជាម វិកាលេបិ ភុញ្ជាម កាលេបិ សាយាម វិកាលេបិ សាយាម កាលេបិ បិវាម វិកាលេបិ បិវាម យម្បិ នោ សទ្ធា គហបតិកា ទិវា វិកាលេ បណីតំ ខាទនីយំ ភោជនីយំ ទេន្តិ តត្ថបិ មេ មុខាវរណំ មញ្ញេ ករោន្តីតិ ។ សោ សិក្ខំ បច្ចក្ខាយ ហីនាយា-វត្តតិ ។ អយំ វុច្ចតិ ភិក្ខវេ កុម្ភីលភយស្ស ភីតោ

ក៏មិនក្រេបផឹករបស់នោះ យើងទំពានូវរបស់ដែលគួរក៏បាន យើងទំពានូវរបស់ដែលមិនគួរក៏បាន យើងបរិភោគនូវរបស់ដែលគួរក៏បាន យើងបរិភោគនូវរបស់ដែលមិនគួរក៏បាន យើងជញ្ជក់ជញ្ជាប នូវរបស់ដែលគួរក៏បាន យើងជញ្ជក់ជញ្ជាបនូវរបស់ដែលមិនគួរក៏បាន យើងក្រេបផឹកនូវរបស់ដែលគួរក៏បាន យើងក្រេបផឹកនូវរបស់ ដែលមិនគួរក៏បាន យើងទំពានូវរបស់ក្នុងកាលក៏បាន យើងទំពានូវរបស់ ក្នុងវិកាលក៏បាន យើងបរិភោគនូវរបស់ក្នុងកាលក៏បាន យើងបរិភោគនូវរបស់ ក្នុងវិកាលក៏បាន យើងជញ្ជក់ជញ្ជាបនូវរបស់ក្នុងកាលក៏បាន យើងជញ្ជក់ជញ្ជាបរបស់ក្នុងវិកាលក៏បាន យើងក្រេបផឹករបស់ក្នុងកាលក៏បាន យើងក្រេបផឹករបស់ក្នុងវិកាលក៏បាន មួយវិញទៀត គហបតីទាំងឡាយមានសទ្ធា តែងឲ្យរបស់ដែលគួរឆាន់ គួរបរិភោគដ៏ប្រណីតណា ដល់យើងទាំងឡាយ ក្នុងវេលាព្រឹក (ឬ) ក្នុងវេលាថ្ងៃរសៀល លោកអម្បាលនេះ ហាក់ដូចជាធ្វើកិរិយាហាមឃាត់មាត់យើង ក្នុងរបស់ទាំងនោះ ។ កុលបុត្តនោះក៏ពោលលាសិក្ខាវិលត្រឡប់ ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រនេះតថាគតពោលថា មានភ័យអំពីក្រពើ បាន

សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោ ។ កុម្ភីលភយន្តិ ខោ ភិក្ខវេ ឱទរិកត្តស្សេតំ អធិវចនំ ។

[១៩៣] កាតមញ្ច ភិក្ខវេ អាវដ្ដភយំ ឥធ ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរ-ណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បវិសតិ អរក្ខិតេនេវ កាយេន អរក្ខិតាយ វាចាយ អនុបដ្ឋិតាយ សតិយា អសំវុតេហិ ឥន្ទ្រិយេហិ ។ សោ តត្ថ បស្សតិ គហបតឹ វា គហបតិបុត្តំ វា បញ្ចហិ កាមគុណេហិ សមប្បិតំ សមង្គីភូតំ បរិចារិយមានំ ។ តស្ស

ជាពោលលាសិក្ខាវិលត្រឡប់ ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីក្រពើ នុ៎ះជាឈ្មោះរបស់បុគ្គល ដែលឃើញតែត្រង់ការបំពេញផ្ទៃប៉ុណ្ណោះ ។

[១៩៣] ម្នាលភិក្ខុទាំងឡាយ ភ័យកើតអំពីអន្លង់ទឹក តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ កុលបុត្តពួកមួយ ក្នុងធម្មវិន័យនេះ ចេញចាកផ្ទះចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ និងសេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីខ្វោចផ្សាចិត្ត គ្របសង្កត់ ឈ្មោះថាមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតហើយ ឱធ្វើម្តេចហ្ន៎ ការធ្វើនូវទីបំផុតទុក្ខទាំងអស់នេះ នឹងប្រាកដបាន ។ កាលដែលកុលបុត្តនោះ បួសយ៉ាងនេះហើយ ក្នុងវេលាព្រឹកព្រហាមក៏ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ចូលទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត តែមិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានតម្កល់ស្មារតីឲ្យខ្ជាប់ខ្ជួន ទាំងមិនបានសង្រួមឥន្ទ្រិយទាំងឡាយឡើយ ។ កុលបុត្តនោះ ឃើញគហបតីក្តី គហបតិបុត្តក្តី ក្នុងស្រុកនោះ ឬនិគមនោះដែលកំពុងតែឆ្អែតស្កប់ស្កល់មូលមិត្តផ្តេកផ្តិត ដោយកាមគុណទាំង ៥ ។ កុលបុត្តនោះ

ឯវំ ហោតិ មយំ[១] បុព្វេ អគារិយភូតា សមានា បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គីភូតា បរិចារិម្ហា សំវិជ្ជន្តេ[២] ខោ កុលេ ភោគា សក្កា ភោគេ ច ភុញ្ជិតុំ បុញ្ញានិ ច កាតុន្តិ ។ សោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ អយំ វុច្ចតិ ភិក្ខវេ អាវដ្ដភយស្ស ភីតោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោ ។ អាវដ្ដភយន្តិ ខោ ភិក្ខវេ បញ្ចន្នេតំ កាមគុណានំ[៣] អធិវចនំ ។

[១៩៤] កតមញ្ច ភិក្ខវេ សុសុកាភយំ ឥធ ភិក្ខវេ ឯកច្ចោ កុលបុត្តោ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឱតិណ្ណោម្ហិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ

១ ឱ. ម. មយំ ខោ ។ ២ ម. សំវិជ្ជន្តិ ។ ៣ បញ្ចន្នំ កាមគុណានមេតំ ។

ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ពីមុនយើងនៅជាគ្រហស្ថតែងឆ្អែតស្កប់ស្កល់មូលមិត្រផ្តេកផ្តិត ដោយកាមគុណ ៥ ទាំងភោគសម្បត្តិក្នុងត្រកូលរបស់យើងក៏មានព្រម យើងអាចនឹងបរិភោគភោគសម្បត្តិ នឹងធ្វើបុណ្យទាំងឡាយបានដែរ ។ កុលបុត្តនោះ ក៏ពោលលាសិក្ខាវិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តនេះ តថាគតពោលថា មានភ័យអំពីអន្ទង់ទឹក បានជាពោលលាសិក្ខាវិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យកើតអំពីអន្ទង់ទឹក នុ៎ះជាឈ្មោះនៃកាមគុណទាំង ៥ ។

[១៩៤] ម្នាលភិក្ខុទាំងឡាយ ភ័យកើតអំពីត្រីសាហាវ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ កុលបុត្តពួកមួយ ក្នុងធម្មវិន័យនេះ ចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ និងសេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីខ្ចោចផ្សាចិត្ត គ្របសង្កត់ ឈ្មោះថាមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹត

អប្បេវនាម ឥមស្ស កោវលស្ស ទុក្ខក្ខន្ធស្ស អន្ត-
កិរិយា បញ្ញាយេថាតិ ។ សោ ឯវំ បព្វជិតោ សមានោ
បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ
វា និគមំ វា បិណ្ឌាយ បវិសតិ អរក្ខិតេនេវ កាយេន
អរក្ខិតាយ វាចាយ អនុបដ្ឋិតាយ សតិយា អសំវុ-
តេហិ ឥន្ទ្រិយេហិ ។ សោ តត្ថ បស្សតិ មាតុគ្គាមំ
ទុន្និវត្ថំ វា ទុប្បារុតំ វា តស្ស មាតុគ្គាមំ ទិស្វា
ទុន្និវត្ថំ វា ទុប្បារុតំ វា រាគោ ចិត្តំ អនុទ្ធំសេតិ ។ សោ
រាគានុទ្ធំសេន ចិត្តេន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។
អយំ វុច្ចតិ ភិក្ខវេ សុសុកាភយស្ស ភីតោ សិក្ខំ
បច្ចក្ខាយ ហីនាយាវត្តោ ។ សុសុកាភយន្តិ ខោ
ភិក្ខវេ មាតុគ្គាមស្សេតំ អធិវចនំ ។ ឥមានិ ខោ ភិក្ខវេ

ហើយ ឱ្យធ្វើម្ដេចហ្ន៎ ការធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ នឹងប្រាកដបាន ។ កាលដែលកុលបុត្តនោះ បួសយ៉ាងនេះហើយ ក្នុងវេលាព្រឹកព្រហាមក៏ស្លៀកស្បង់ប្រដាប់បាត្រចីវរ ចូលទៅកាន់ស្រុកឬនិគមដើម្បីបិណ្ឌបាត តែមិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានតម្កល់ស្មារតីឲ្យខ្ជាប់ខ្ជួន ទាំងមិនបានសង្រួមឥន្ទ្រិយទាំងឡាយ ។ កុលបុត្តនោះ បានឃើញមាតុគ្រាមក្នុងស្រុកឬនិគមនោះ ដែលមានសំពត់ស្លៀកមិនស្រួល មានសំពត់ដណ្ដប់មិនស្រួល សេចក្ដីតម្រេកក៏ញុំាងចិត្តរបស់កុលបុត្តនោះឲ្យស្វិតស្រពោន ព្រោះឃើញនូវមាតុគ្រាម ដែលមានសំពត់ស្លៀកមិនស្រួល ឬមានសំពត់ដណ្ដប់មិនស្រួល ។ កុលបុត្តនោះក៏ពោលលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ព្រោះចិត្តដែលស្វិតស្រពោនដោយរាគៈ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តនេះ តថាគតពោលថា មានភ័យអំពីត្រីសាហារ បានជាពោលលាសិក្ខាវិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យកើតអំពីត្រីសាហារ នុ៎ះជាឈ្មោះនៃមាតុគ្រាម ។ ម្នាលភិក្ខុទាំងឡាយ

ចត្តារិ ភយានិ ឥធេកច្ចោ បុគ្គលេ ឥមស្មឹ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិតេ ចាជិកង្ខិតព្វានីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ចាតុមសុត្តំ សត្តមំ និដ្ឋិតំ ។

ភ័យទាំង ៤ នេះឯង ដែលកើតមានចំពោះបុគ្គលពួកមួយ ក្នុងសាសនានេះ ជាបព្វជិតដែលចេញចាកផ្ទះ ចូលកាន់ផ្នួសក្នុងធម្មវិន័យនេះ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះចប់ហើយ ភិក្ខុទាំងអម្បាលនោះ ក៏មានសេចក្ដីពេញចិត្តត្រេកអរ ចំពោះភាសិត របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ ចាតុមសូត្រ ទី ៧ ។

# អដ្ឋមំ នឡកបានសុត្តំ

[១៩៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ វិហរតិ នឡកបានេ បលាសវនេ ។ តេន ខោ បន សមយេន សម្ពហុលា អភិញ្ញាតា អភិញ្ញាតា កុលបុត្តា ភគវន្តំ ឧទ្ទិស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតា ហោន្តិ អាយស្មា ច អនុរុទ្ធោ អាយស្មា ច ភទ្ទិយោ(១) អាយស្មា ច កិម្ពិលោ(២) អាយស្មា ច ភគុ អាយស្មា ច កោណ្ឌញ្ញោ អាយស្មា ច រេវតោ អាយស្មា ច អានន្ទោ អញ្ញេ ច អភិញ្ញាតា អភិញ្ញាតា កុលបុត្តា ។ តេន ខោ បន សមយេន ភគវា ភិក្ខុសង្ឃបរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ ។ អថខោ ភគវា កុលបុត្តេ(៤) អារព្ភ ភិក្ខូ អាមន្តេសិ យេ តេ ភិក្ខវេ កុលបុត្តា មមំ ឧទ្ទិស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតា កច្ចិ តេ ភិក្ខវេ អភិរតា ព្រហ្មចរិយេតិ ។

---

១ ម. ឯវំ ។ ឱ. នន្ទិយោ ។ ២ កិមិលោតិប្បត្តិ ។ ៣ ម. ឯវំ ។ ឱ. កុណ្ឌធានោ ។ ៤ ឱ. ម. តេ កុលបុត្តេ ។

# នឡកបានសូត្រ ទី ៨

[១៩៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃចារ ទៀបស្រុកនឡកបានៈ[១] ក្នុងដែនកោសល ។ ក៏សម័យនោះ កុលបុត្តទាំងឡាយច្រើនរូប ជាអ្នកមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ចេញចាកផ្ទះចូលមកកាន់ផ្នួស ដោយសទ្ធាឧទ្ទិសព្រះមានព្រះភាគ គឺព្រះអនុរុទ្ធមានអាយុ ១ ព្រះភទ្ទិយៈមានអាយុ ១ ព្រះកិម្ពិលៈមានអាយុ ១ ព្រះភគ្គុមានអាយុ ១ ព្រះកោណ្ឌញ្ញៈមានអាយុ ១ ព្រះរេវតៈមានអាយុ ១ ព្រះអានន្ទមានអាយុ ១ និងកុលបុត្តទាំងឡាយ ដែលមានកេរ្តិ៍ឈ្មោះប្រាកដជាងគេដទៃទៀត ។ ក៏សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃជាបរិវារ ទ្រង់គង់ក្នុងទីវាល ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ប្រារព្ធនូវកុលបុត្តទាំងឡាយ ហើយត្រាស់ហៅពួកភិក្ខុមកសួរថា ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងឡាយណា ចេញចាកផ្ទះចូលមកកាន់ផ្នួសហើយ ដោយសទ្ធាឧទ្ទិសតថាគត ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងនោះ ត្រេកអរហើយ ក្នុងព្រហ្មចរិយៈ ខ្លះដែរឬទេ ។

---

១ ប្រទេសដែលស្តេចពានរ ព្រមដោយបរិវារក្រេបផឹកទឹកដោយដើមបបុស មកអំពីព្រេងនាយ ។ អដ្ឋកថា ។

តេ ភិក្ខូ តុណ្ហី[១] អហេសុំ ។ ទុតិយម្បិ ខោ ភគវា តេ កុលបុត្តេ អាវុត្ត ភិក្ខូ អាមន្តេសិ យេ តេ ភិក្ខវេ កុលបុត្តា មមំ ឧទ្ទិស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតា កច្ចិ តេ ភិក្ខវេ ភិក្ខូ អភិរតា ព្រហ្មចរិយេតិ ។ ទុតិយម្បិ ខោ តេ ភិក្ខូ តុណ្ហី អហេសុំ ។ តតិយម្បិ ខោ ភគវា តេ កុលបុត្តេ អាវុត្ត ភិក្ខូ អាមន្តេសិ យេ តេ ភិក្ខវេ កុលបុត្តា មមំ ឧទ្ទិស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតា កច្ចិ តេ ភិក្ខវេ ភិក្ខូ អភិរតា ព្រហ្មចរិយេតិ ។ តតិយម្បិ ខោ តេ ភិក្ខូ តុណ្ហី អហេសុំ ។

[១៩៦] អថខោ ភគវតោ ឯតទហោសិ យន្នូនាហំ តេវ កុលបុត្តេ បុច្ឆេយ្យន្តិ ។ អថខោ ភគវា

១ ឯវំ វុត្តេ តេ ភិក្ខូ តុណ្ហី អហេសុន្តិ កត្ថចិ បោត្ថកេសុ ទិស្សន្តិ ។

ភិក្ខុទាំងឡាយនោះក៏នៅស្ងៀម ។ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធកុលបុត្តទាំងនោះ ទើបត្រាស់សួរពួកភិក្ខុអស់វារៈពីរដងថា ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងឡាយណា ចេញចាកផ្ទះចូលមកកាន់ផ្នួសហើយ ដោយសទ្ធាឧទ្ទិសតថាគត ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអម្បាលនោះ ត្រេកអរហើយក្នុងព្រហ្មចរិយៈ ខ្លះដែរឬទេ ។ ភិក្ខុអម្បាលនោះ ក៏នៅស្ងៀមអស់វារៈពីរដងទៀត ។ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធកុលបុត្តទាំងនោះ ទើបត្រាស់សួរពួកភិក្ខុអស់វារៈបីដងថា ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងឡាយណា ចេញចាកផ្ទះចូលមកកាន់ផ្នួសហើយ ដោយសទ្ធាឧទ្ទិសតថាគត ម្នាលភិក្ខុទាំងឡាយ ភិក្ខុអម្បាលនោះត្រេកអរហើយ ក្នុងព្រហ្មចរិយៈ ខ្លះដែរឬទេ ។ ភិក្ខុអម្បាលនោះ ក៏ស្ងៀមអស់វារៈបីដងទៀត ។

[១៩៦] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា បើដូច្នោះគួរតែតថាគត សួរកុលបុត្តអម្បាលនោះឯង ។ គ្រានោះ ព្រះមាន

៣៤៩

ភិក្ខុវគ្គស្ស នឡកបានសុត្តេ ព្រហ្មចរិយាភិរមកថា

អាយស្មន្តំ អនុរុទ្ធំ អាមន្តេសិ កច្ចិ តុម្ហេ អនុរុទ្ធា អភិរតា ព្រហ្មចរិយេតិ ។ តគ្ឃ មយំ ភន្តេ អភិរតា ព្រហ្មចរិយេតិ ។ សាធុ សាធុ អនុរុទ្ធា ឯតំ ខោ អនុរុទ្ធា តុម្ហាកំ បដិរូបំ កុលបុត្តានំ សទ្ធា អគារស្មា អនគារិយំ បព្វជិតានំ យំ តុម្ហេ អភិរមេយ្យាថ ព្រហ្មចរិយេ យេន តុម្ហេ អនុរុទ្ធា ភទ្រេន យោព្វនេន សមន្នាគតា បឋមេន វយសា សុសុកាឡកេសា កាមេ បរិភុញ្ជេយ្យាថ តេន តុម្ហេ អនុរុទ្ធា ភទ្រេន យោព្វនេន សមន្នាគតា បឋមេន វយសា សុសុកាឡកេសា អគារស្មា អនគារិយំ បព្វជិតា តេ ខោ បន តុម្ហេ អនុរុទ្ធា នេវ រាជាភិនីតា អគារស្មា អនគារិយំ បព្វជិតា ន ចោរាភិនីតា អគារស្មា អនគារិយំ បព្វជិតា ន ឥណដ្ដា អគារស្មា អនគារិយំ បព្វជិតា ន ភយដ្ដា អគារស្មា អនគារិយំ បព្វជិតា ន អាជីវិកាបកតា[១] អគារស្មា អនគារិយំ បព្វជិតា

១ ម. នាជីវិកាបកតា ។

ព្រះភាគ ទ្រង់ត្រាស់សួរព្រះអនុរុទ្ធមានអាយុថា ម្នាលពួកអនុរុទ្ធ អ្នកទាំងឡាយត្រេកអរហើយ ក្នុងព្រហ្មចរិយៈ ខ្លះដែរឬទេ ។ ឱព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គត្រេកអរ ក្នុងព្រហ្មចរិយៈ ។ ម្នាលពួកអនុរុទ្ធ ប្រពៃហើយ ប្រពៃហើយ ម្នាលពួកអនុរុទ្ធ អ្នកទាំងឡាយត្រេកអរហើយ ក្នុងព្រហ្មចរិយៈ ដោយហេតុណា ហេតុនុ៎ះឯងសមគួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្តចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធាហើយ ម្នាលពួកអនុរុទ្ធ ព្រោះថាអ្នកទាំងឡាយប្រកបដោយវ័យជាដំបូង ជាកំឡោះដ៏ចម្រើន មានសក់ខ្មៅស្រិល គួរនឹងបរិភោគកាមទាំងឡាយ ព្រោះហេតុណា ម្នាលពួកអនុរុទ្ធ ព្រោះហេតុនោះ អ្នកទាំងឡាយកំពុងប្រកបដោយវ័យជាដំបូង ជាកំឡោះដ៏ចម្រើន មានសក់ខ្មៅស្រិល ក៏ធៀតចេញចាកផ្ទះ ចូលមកកាន់ផ្នួសបាន ម្នាលពួកអនុរុទ្ធ មួយវិញទៀត អ្នកទាំងឡាយនោះ មិនមែនព្រះរាជាគុំគួន ហើយចេញចាកផ្ទះ ចូលមកកាន់ផ្នួសទេ មិនមែនចោរគុំគួន ហើយចេញចាកផ្ទះចូលមកកាន់ផ្នួសទេ មិនមែនចំពាក់បំណុលគេ ហើយចេញចាកផ្ទះ ចូលមកកាន់ផ្នួសទេ មិនមែនមានរឿងក្តី ហើយភ័យចេញចាកផ្ទះចូលមកកាន់ផ្នួសទេ មិនវិបត្តិដោយចិញ្ចឹមជីវិត ហើយចេញចាកផ្ទះ ចូលមកកាន់ផ្នួសទេ

អបិច ខោម្ហិ ឱតិណ្ណោ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ននុ តុម្ហេ អនុរុទ្ធា ឯវំ សទ្ធា អគារស្មា អនគារិយំ បព្វជិតាតិ ។ ឯវំ ភន្តេ ។ ឯវំ បព្វជិតេន ច បន អនុរុទ្ធា កុលបុត្តេន កិមស្ស ករណីយំ ។ វិវេកំ អនុរុទ្ធា កាមេហិ វិវេកំ អកុសលេហិ ធម្មេហិ បីតិសុខំ នាធិគច្ឆតិ អញ្ញំ វា តតោ សន្តតរំ ។ តស្ស អភិជ្ឈាបិ ចិត្តំ បរិយាទាយ តិដ្ឋតិ ព្យាបាទោបិ ចិត្តំ បរិយាទាយ តិដ្ឋតិ ថីនមិទ្ធម្បិ ចិត្តំ បរិយាទាយ តិដ្ឋតិ វិចិកិច្ឆាបិ ចិត្តំ បរិយាទាយ តិដ្ឋតិ ឧទ្ធច្ចកុក្កុច្ចម្បិ ចិត្តំ បរិយាទាយ តិដ្ឋតិ អរតិបិ ចិត្តំ បរិយាទាយ តិដ្ឋតិ តន្ទីបិ ចិត្តំ បរិយាទាយ តិដ្ឋតិ វិវេកំ អនុរុទ្ធា កាមេហិ វិវេកំ

គឺពិតជា (អ្នកទាំងឡាយ គិតឃើញថា) ឱហ្ន៎ អាត្មាអញជាអ្នកត្រូវជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ និងឧបាយាសៈគ្របសង្កត់ ឈ្មោះថាអ្នកមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតហើយ ឱធ្វើម្តេចហ្ន៎ ការធ្វើនូវទីបំផុតកងទុក្ខទាំងអស់នេះ នឹងប្រាកដបាន ម្នាលពួកអនុរុទ្ធ ក្រែងអ្នកទាំងឡាយមានសទ្ធាយ៉ាងនេះ ហើយចេញចាកផ្ទះចូលមកកាន់ផ្នួស ឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលពួកអនុរុទ្ធ ចុះកុលបុត្តដែលបួសយ៉ាងនេះហើយ ត្រូវធ្វើកិច្ចអ្វីខ្លះ ។ ម្នាលពួកអនុរុទ្ធ (ប្រសិនបើ) បុគ្គលស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ តែនៅមិនទាន់បានដល់បីតិនិងសុខ ឬមិនទាន់បានដល់សេចក្តីសុខដទៃដែលស្ងាត់លើសជាងបីតិនិងសុខនោះទេ ។ អភិជ្ឈាក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ព្យាបាទក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ថីនមិទ្ធៈក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន វិចិកិច្ឆាក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ឧទ្ធច្ចកុក្កុច្ចៈក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន អរតិក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន សេចក្តីខ្ជិលច្រអូសក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ម្នាលពួកអនុរុទ្ធ (ព្រោះថា) បុគ្គលនោះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់

អកុសលេហិ ធម្មេហិ បីតិសុខំ នាធិគច្ឆតិ អញ្ញំ វា តតោ សន្តតរំ ។ វិវេកំ អនុរុទ្ធា កាមេហិ វិវេកំ អកុសលេហិ ធម្មេហិ បីតិសុខំ អធិគច្ឆតិ អញ្ញំ វា[(១)] តតោ សន្តតរំ ។ តស្ស អភិជ្ឈាបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ ព្យាបាទោបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ ថីនមិទ្ធម្បិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ ឧទ្ធច្ចកុក្កុច្ចម្បិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ វិចិកិច្ឆាបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ អរតិបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ តន្ទីបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ វិវេកំ អនុរុទ្ធា កាមេហិ វិវេកំ អកុសលេហិ ធម្មេហិ បីតិសុខំ អធិគច្ឆតិ អញ្ញំ វា តតោ សន្តតរំ ។

---

១ ឱ. អញ្ញញ្ច ។ ម. អញ្ញំ ច ។

ចាកអកុសលធម៌ទាំងឡាយ តែនៅមិនទាន់បានបីតិនិងសុខ ឬមិនទាន់បានសេចក្តីសុខដទៃ ដែលស្ងាត់លើសជាងបីតិនិងសុខនោះ ។ ម្នាលពួកអនុរុទ្ធ (បើ) បុគ្គលស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់បីតិនិងសុខ ឬបានដល់សេចក្តីសុខដទៃ ដែលស្ងាត់លើសជាងបីតិនិងសុខនោះហើយ ។ អភិជ្ឈាក្តី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ព្យាបាទក្តី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ថីនមិទ្ធៈក្តី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ឧទ្ធច្ចកុក្កុច្ចៈក្តី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន វិចិកិច្ឆាក្តី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន អរតិក្តី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន សេចក្តីខ្ជិលច្រអូសក្តី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ម្នាលពួកអនុរុទ្ធ (ព្រោះថា) បុគ្គលនោះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលទាំងឡាយ ហើយបានដល់នូវបីតិនិងសុខ ឬបានដល់នូវសេចក្តីសុខដទៃ ដែលស្ងាត់ជាងបីតិនិងសុខនោះ ។

[១៩៧] កិន្តិ វោ[១] អនុរុទ្ធា មយិ ហោតិ យេ អាសវា សង្កិលេសិកា ចោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណិយា អប្បហីនា តេ តថាគតស្ស តស្មា តថាគតោ សង្ខាយេកំ បដិសេវតិ សង្ខាយេកំ អធិវាសេតិ សង្ខាយេកំ បរិវជ្ជេតិ សង្ខាយេកំ វិនោទេតីតិ ។ ន ខោ នោ ភន្តេ ភគវតិ ឯវំ ហោតិ យេ អាសវា សង្កិលេសិកា ចោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណិយា អប្បហីនា តេ តថាគតស្ស តស្មា តថាគតោ សង្ខាយេកំ បដិសេវតិ សង្ខាយេកំ អធិវាសេតិ សង្ខាយេកំ បរិវជ្ជេតិ សង្ខាយេកំ វិនោទេតីតិ ឯវំ ខោ នោ ភន្តេ ភគវតិ ហោតិ យេ អាសវា សង្កិលេសិកា ចោនោព្ភវិកា

១ ម. តេ ។

[១៩៧] ម្នាលពួកអនុរុទ្ធ អ្នកទាំងឡាយមានសេចក្តីត្រិះរិះ ក្នុងតថាគត ថា អាសវៈទាំងឡាយណា នាំមកនូវសេចក្តីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាក ជាទុក្ខតទៅ ជាទីតាំងនៃជាតិ ជរា និងមរណៈ អាសវៈអម្បាលនោះ ព្រះតថាគតពុំទាន់បានលះបង់ទេ ហេតុដូច្នោះបានជាព្រះតថាគតដឹងហើយទើបសេពរបស់ខ្លះ (ដែលគួរសេព) ដឹងហើយទើបអត់សង្កត់របស់ខ្លះ (ដែលគួរអត់សង្កត់) ដឹងហើយទើបវៀររបស់ខ្លះ (ដែលគួរវៀរ) ដឹងហើយទើបបន្ទោបង់របស់ខ្លះ (ដែលគួរបន្ទោបង់) ដូច្នេះឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ នឹងបានត្រិះរិះ ចំពោះព្រះមានព្រះភាគ យ៉ាងនេះថា អាសវៈទាំងឡាយណា នាំមកនូវសេចក្តីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខតទៅ ជាទីតាំងនៃជាតិជរាមរណៈ អាសវៈអម្បាលនោះ ព្រះតថាគតមិនទាន់បានលះបង់ទេ ហេតុដូច្នោះបានជាព្រះតថាគត ទ្រង់ជ្រាបហើយទើបសេពរបស់ខ្លះ ទ្រង់ជ្រាបហើយ ទើបអត់សង្កត់របស់ខ្លះ ទ្រង់ជ្រាបហើយ ទើបវៀររបស់ខ្លះ ទ្រង់ជ្រាបហើយ ទើបបន្ទោបង់របស់ខ្លះ ដូច្នេះក៏ទេ បពិត្រព្រះអង្គដ៏ចម្រើន តែពួកខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ ចំពោះព្រះមានព្រះភាគយ៉ាងនេះថា អាសវៈទាំងឡាយណា នាំមកនូវសេចក្តីសៅហ្មង នាំមកនូវភពថ្មី

សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណិយា បហីនា តេ តថាគតស្ស តស្មា តថាគតោ សង្ខាយេកំ បដិសេវតិ សង្ខាយេកំ អធិវាសេតិ សង្ខាយេកំ បរិវជ្ជេតិ សង្ខាយេកំ វិនោទេតីតិ ។ សាធុ សាធុ អនុរុទ្ធា តថាគតស្ស អនុរុទ្ធា យេ អាសវា សង្កិលេសិកា ពោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណិយា បហីនា តេ[១] ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា[២] អាយតឹ អនុប្បាទធម្មា សេយ្យថាបិ អនុរុទ្ធា តាលោ មត្ថកច្ឆិន្នោ អភព្វោ បុន វិរូឡ្ហិយា ឯវមេវ ខោ អនុរុទ្ធា តថាគតស្ស យេ អាសវា សង្កិលេសិកា ពោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណិយា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា

---

១ ឱ. តេតិ ន ទិស្សតិ ។ ២ ម. អយមេវ បាឋោ ។ ឱ. អនភាវគតោ ។

ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខតទៅ ជាទីតាំងនៃជាតិ ជរា មរណៈ អាសវៈអម្បាលនោះ ព្រះតថាគតទ្រង់លះបង់បានហើយ ហេតុដូច្នោះបានជាព្រះតថាគត ទ្រង់ជ្រាបហើយ ទើបសេពរបស់ខ្លះ ទ្រង់ជ្រាបហើយទើបអត់សង្កត់របស់ខ្លះ ទ្រង់ជ្រាបហើយ ទើបវៀររបស់ខ្លះ ទ្រង់ជ្រាបហើយ ទើបបន្ទោបង់របស់ខ្លះ ដូច្នេះឯង ។ ម្នាលពួកអនុរុទ្ធ ប្រពៃហើយប្រពៃហើយ ម្នាលពួកអនុរុទ្ធ អាសវៈទាំងឡាយណា ដែលនាំមកនូវសេចក្តីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខតទៅ ជាទីតាំងនៃជាតិ ជរា មរណៈ អាសវៈអម្បាលនោះ តថាគតបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចជាដើមត្នោតដែលគេក្របែលគាស់រំលើងឲ្យលែងដុះតទៅទៀត ជាធម៌លែងមានបែបភាពតទៅទៀត ជាធម៌មិនមានកំណើតទៅខាងមុខទៀត ម្នាលពួកអនុរុទ្ធ ដូចជាដើមត្នោតកំបុតក មិនគួរដុះឡើងវិញបាន យ៉ាងណា ម្នាលពួកអនុរុទ្ធ អាសវៈទាំងឡាយណា ដែលនាំមកនូវសេចក្តីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខតទៅ ជាទីតាំងនៃជាតិ ជរា មរណៈ (អាសវៈទាំងនោះ) តថាគតលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង

អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា តថាគតោ សង្ខាយេកំ បដិសេវតិ សង្ខាយេកំ អធិវាសេតិ សង្ខាយេកំ បរិវជ្ជេតិ សង្ខាយេកំ វិនោទេតីតិ[១] ។

[១៩៨] តំ កឹ មញ្ញសិ អនុរុទ្ធា កំ អត្ថវសំ សម្បស្សមានោ តថាគតោ សាវកេ អព្ភតីតេ កាលកតេ[២] ឧបបត្តីសុ ព្យាករោតិ អសុ អមុត្រ ឧប្បន្នោ[៣] អសុ អមុត្រ ឧប្បន្នោតិ ។ ភគវំ-មូលកា[៤] នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំប-ដិសរណា សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ ន ខោ អនុរុទ្ធា តថាគតោ

---

១ ឱ. វិនោទេតិ ។ ២ ម. កាលំ កតេ ។ ៣ ឱ. ឧបបន្នោ ។ ម. ភគវំមូលិកា ។

ដូចជាដើមត្នោត ដែលគេក្របែលគាស់រំលើង ឲ្យលែងដុះតទៅទៀត ជាធម៌លែងមានបែបភាពតទៅទៀតហើយ ជាធម៌មិនមានកំណើតតទៅខាងមុខទៀតទេ យ៉ាងនោះឯង ព្រោះហេតុនោះ បានជាតថាគតដឹងហើយទើបសេពរបស់ខ្លះ ដឹងហើយទើបអត់សង្កត់របស់ខ្លះ ដឹងហើយទើបវៀររបស់ខ្លះ ដឹងហើយទើបបន្ទោបង់របស់ខ្លះ ។

[១៩៨] ម្នាលពួកអនុរុទ្ធ អ្នកសំគាល់សេចក្តីនោះដូចម្តេច ព្រះតថាគតឃើញប្រយោជន៍ដូចម្តេច បានជាព្យាករក្នុងកំណើតរបស់ពួកសាវ័កដែលធ្វើមរណកាលកន្លងទៅហើយថា សាវ័កឯណោះ កើតក្នុងទីឯណោះ សាវ័កឯណោះ កើតក្នុងទីឯណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ របស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះមានព្រះភាគជាមូល មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹងអាស្រ័យ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគមេត្តាប្រោសបំភ្លឺសេចក្តីនៃភាសិតនុ៎ះ ភិក្ខុទាំងឡាយបានស្តាប់ភាសិតរបស់ព្រះអង្គហើយ នឹងចងចាំទុកបាន ។ ម្នាលពួកអនុរុទ្ធ តថាគត

ជនកុហនត្ថំ ន ជនលបនត្ថំ ន លាភសក្ការសិលោ-កានិសំសត្ថំ ន ឥតិ មំ ជនោ ជានាតូតិ សាវកេ អព្ភតីតេ កាលកតេ ឧបបត្តីសុ ព្យាករោតិ អសុ អមុត្រ ឧប្បន្នោ អសុ អមុត្រ ឧប្បន្នោតិ ។ សន្តិ ច ខោ អនុរុទ្ធា កុលបុត្តា សទ្ធា ឧឡារវេទា ឧឡារប្បាមុជ្ជា តេ តំ សុត្វា តទត្ថាយ ចិត្តំ ឧបសំហរន្តិ តេសំ តំ អនុរុទ្ធា ហោតិ ទីឃរត្តំ ហិតាយ សុខាយ ។

[១៩៩] ឥធានុរុទ្ធា ភិក្ខុ សុណាតិ ឥត្ថន្នាមោ ភិក្ខុ កាលកតោ សោ ភគវតា ព្យាកតោ អញ្ញាយ សណ្ឋាហីតិ សោ ខោ បនស្ស អាយស្មា សាមំ ទិដ្ឋោ វា ហោតិ អនុស្សវសុតោ វា ឯវំសីលោ សោ អាយស្មា អហោសិ ឥតិបិ ឯវំធម្មោ សោ អាយស្មា អហោសិ ឥតិបិ ឯវំបញ្ញោ សោ អាយស្មា អហោសិ ឥតិបិ ឯវំវិហារី សោ អាយស្មា អហោសិ ឥតិបិ

ព្យាករក្នុងកំណើតរបស់ពួកសាវ័ក ដែលធ្វើមរណកាលកន្លងទៅហើយ ថា សាវ័កឯណោះ កើតក្នុងទីឯណោះ សាវ័កឯណោះ កើតក្នុងទីឯណោះ ដើម្បីឲ្យជនស្ញប់ស្ញែងក៏ទេ ដើម្បីប្រលោមជនក៏ទេ ដើម្បីអានិសង្ស គឺលាភសក្ការៈនិងសេចក្តីសរសើរក៏ទេ (ឬ) គិតថា ឲ្យគេស្គាល់តថាគត ក៏ទេ ។ ម្នាលពួកអនុរុទ្ធ កុលបុត្តទាំងឡាយមានសទ្ធា មានសេចក្តីត្រេកអរខ្លាំង មានបាមោជ្ជៈក្លៀវក្លា លុះកុលបុត្តអម្បាលនោះ បាន ស្តាប់ព្យាករណ៍នោះហើយ តែងបង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ម្នាលពួកអនុរុទ្ធ ការព្យាករនោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និង សេចក្តីសុខ ដល់បុគ្គលទាំងឡាយនោះ អស់កាលជាយូរអង្វែង ។

[១៩៩] ម្នាលពួកអនុរុទ្ធ ភិក្ខុក្នុងធម្មវិន័យនេះ រមែងឮថា ភិក្ខុឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនោះព្រះមានព្រះភាគ ទ្រង់ព្យាករថា បានឋិតនៅក្នុងអរហត្តផលដូច្នេះ ភិក្ខុនោះយល់ ឃើញលោកមានអាយុនោះដោយខ្លួនឯង ឬបានឮត ៗ មកថា លោក មានអាយុនោះ មានសីលយ៉ាងនេះដូច្នេះខ្លះ លោកមានអាយុនោះ មានធម៌យ៉ាងនេះដូច្នេះខ្លះ លោកមានអាយុនោះ មានបញ្ញាយ៉ាង នេះដូច្នេះខ្លះ លោកមានអាយុនោះ មានវិហារធម៌យ៉ាងនេះដូច្នេះខ្លះ

ឯវំវិមុត្តោ សោ អាយស្មា អហោសិ ឥតិបីតិ ។ សោ តស្ស សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តោ តទត្ថាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អានន្ទ ភិក្ខុនោ ផាសុវិហារោ ហោតិ ។ ឥធានន្ទ ភិក្ខុ សុណាតិ ឥត្ថន្នាមោ ភិក្ខុ កាលកតោ សោ ភគវតា ព្យាកតោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកាតិ សោ ខោ បនស្ស អាយស្មា សាមំ ទិដ្ឋោ វា ហោតិ អនុស្សវស្សុតោ វា ឯវំសីលោ សោ អាយស្មា អហោសិ ឥតិបិ ឯវំធម្មោ ។ បេ ។ ឯវំបញ្ញោ... ឯវំវិហារី... ឯវំវិមុត្តោ សោ អាយស្មា អហោសិ ឥតិបីតិ ។ សោ តស្ស សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តោ តទត្ថាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អានន្ទ ភិក្ខុនោ ផាសុវិហារោ ហោតិ ។ ឥធានន្ទ ភិក្ខុ

លោកមានអាយុនោះ មានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ភិក្ខុនោះរលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់លោកនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯងឈ្មោះថា ផាសុវិហារធម៌របស់ភិក្ខុ ។ ម្នាលពួកអនុរុទ្ធ ភិក្ខុក្នុងធម្មវិន័យនេះ រមែងឮថា ភិក្ខុឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនោះព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាឱបបាតិកៈកំណើត (កើតក្នុងសុទ្ធាវាស) បរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈទាំងឡាយ ៥ ដូច្នេះ ភិក្ខុនោះយល់ឃើញលោកមានអាយុនោះដោយខ្លួនឯង ឬបានឮត ៗ មកថា លោកមានអាយុនោះ មានសីលយ៉ាងនេះដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។ បេ ។ មានបញ្ញាយ៉ាងនេះ... មានវិហារធម៌យ៉ាងនេះ... លោកមានអាយុនោះ មានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ភិក្ខុនោះរលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់លោកនោះហើយក៏បង្អោនចិត្តទៅដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯងឈ្មោះថាផាសុវិហារធម៌របស់ភិក្ខុ ។ ម្នាលពួកអនុរុទ្ធ ភិក្ខុក្នុងធម្មវិន័យនេះ

៣៨៧

ភិក្ខុវគ្គស្ស នឡកបានសុត្តេ ភិក្ខុផាសុវិហារោ

សុណាតិ ឥត្ថន្នាមោ ភិក្ខុ កាលកតោ សោ ភគវតា ព្យាកតោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សតីតិ សោ ខោ បនស្ស អាយស្មា សាមំ ទិដ្ឋោ វា ហោតិ អនុស្ស-វសុតោ វា ឯវំសីលោ សោ អាយស្មា អហោសិ ឥតិបិ ឯវំធម្មោ ។ បេ ។ ឯវំបញ្ញោ... ឯវំវិហារី... ឯវំវិមុត្តោ សោ អាយស្មា អហោសិ ឥតិបីតិ ។ សោ តស្ស សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តោ តថត្តាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អនុរុទ្ធា ភិក្ខុនោ ផាសុវិហារោ ហោតិ ឥធានុរុទ្ធា ភិក្ខុ សុណាតិ ឥត្ថន្នាមោ ភិក្ខុ កាលកតោ សោ ភគវតា ព្យាកតោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ អវិនិចាតធម្មោ និយតោ សម្ពោធិបរាយនោតិ សោ ខោ បនស្ស អាយស្មា សាមំ ទិដ្ឋោ វា ហោតិ អនុស្សវសុតោ វា ឯវំសីលោ សោ អាយស្មា អហោសិ

រមែងឮថា ភិក្ខុឈ្មោះនេះមានមរណកាលធ្វើហើយ ភិក្ខុនោះព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតទុក្ខបាន ព្រោះអស់ទៅនៃសំយោជនៈទាំង ៣ មានរាគៈ ទោសៈ មោហៈ ស្រាលស្តើងដូច្នេះ ភិក្ខុនោះយល់ឃើញលោកមានអាយុនោះដោយខ្លួនឯង ឬបានឮត ៗ មកថា លោកមានអាយុនោះ មានសីលយ៉ាងនេះដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។ បេ ។ មានបញ្ញាយ៉ាងនេះ... មានវិហារធម៌យ៉ាងនេះ... លោកមានអាយុនោះមានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ភិក្ខុនោះរលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់លោកនោះហើយ ក៏បង្អោនចិត្តទៅដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថាផាសុវិហារ-ធម៌របស់ភិក្ខុ ។ ម្នាលពួកអនុរុទ្ធ ភិក្ខុក្នុងធម្មវិន័យនេះរមែងឮថា ភិក្ខុឈ្មោះនេះមានមរណកាលធ្វើហើយ ភិក្ខុនោះព្រះមានព្រះភាគ ទ្រង់ព្យា-ករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំ-យោជនៈទាំង ៣ ដូច្នេះ ភិក្ខុនោះយល់ឃើញលោកមានអាយុនោះដោយខ្លួនឯង ឬបានឮត ៗ មកថា លោកមានអាយុនោះ មានសីលយ៉ាងនេះ

ឥតិបិ ឯវំធម្មោ ។ បេ ។ ឯវំបញ្ញោ... ឯវំវិហារី... ឯវំវិមុត្តោ សោ អាយស្មា អហោសិ ឥតិបីតិ ។ សោ តស្ស សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តោ តទត្ថាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អនុរុទ្ធា ភិក្ខុនោ ផាសុវិហារោ ហោតិ ។

[២០០] ឥធានុរុទ្ធា ភិក្ខុនី សុណាតិ ឥត្ថន្នាមា ភិក្ខុនី កាលកតា សា ភគវតា ព្យាកតា អញ្ញាយ សណ្ឋាហីតិ សា ខោ បនស្សា ភគិនី សាមំ ទិដ្ឋា វា ហោតិ អនុស្សវសុតា វា ឯវំសីលា សា ភគិនី អហោសិ ឥតិបិ ឯវំធម្មា សា ភគិនី អហោសិ ឥតិបិ ឯវំបញ្ញា សា ភគិនី អហោសិ ឥតិបិ ឯវំវិហារិនី សា ភគិនី អហោសិ ឥតិបិ ឯវំវិមុត្តា សា ភគិនី អហោ-សិ ឥតិបីតិ ។ សា តស្សា សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តី តទត្ថាយ ចិត្តំ ឧបសំហ-រតិ ។ ឯវម្បិ ខោ អនុរុទ្ធា ភិក្ខុនិយា ផាសុវិហារោ ហោតិ ។ ឥធានុរុទ្ធា ភិក្ខុនី សុណាតិ ឥត្ថន្នា-មា ភិក្ខុនី កាលកតា សា ភគវតា ព្យាកតា

ដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។ បេ ។ មានបញ្ញាយ៉ាងនេះ... មានវិហារធម៌យ៉ាងនេះ... លោកមានអាយុនោះ មានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ភិក្ខុនោះរលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់លោកនោះហើយ ក៏បង្អោនចិត្តទៅដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថាផាសុវិហារធម៌ របស់ភិក្ខុ ។

[២០០] ម្នាលពួកអនុរុទ្ធ ភិក្ខុនីក្នុងធម្មវិន័យនេះ រមែងឮថា ភិក្ខុនីឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនីនោះព្រះមានព្រះភាគទ្រង់ព្យាករថា បានឋិតនៅក្នុងអរហត្តផលដូច្នេះ ភិក្ខុនីនោះយល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮត ៗ មកថា នាងនោះមានសីលយ៉ាងនេះដូច្នេះខ្លះ នាងនោះមានធម៌យ៉ាងនេះដូច្នេះខ្លះ នាងនោះមានបញ្ញាយ៉ាងនេះដូច្នេះខ្លះ នាងនោះមានវិហារធម៌យ៉ាងនេះដូច្នេះខ្លះ នាងនោះមានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ភិក្ខុនីនោះរលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់ភិក្ខុនីនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ភិក្ខុនី ។ ម្នាលពួកអនុរុទ្ធ ភិក្ខុនីក្នុងធម្មវិន័យនេះ រមែងឮថា ភិក្ខុនីឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនីនោះព្រះមានព្រះភាគ ទ្រង់ព្យាករថា

បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនី អនាវត្តិធម្មា តស្មា លោកាតិ សា ខោ បនស្ស ភគិនី សាមំ ទិដ្ឋា វា ហោតិ អនុស្សវសុតា វា ឯវំសីលា សា ភគិនី អហោសិ ឥតិបិ ឯវំធម្មា សា ភគិនី អហោសិ ឥតិបិ ឯវំបញ្ញា សា ភគិនី អហោសិ ឥតិបិ ឯវំវិហារិនី សា ភគិនី អហោសិ ឥតិបិ ឯវំវិមុត្តា សា ភគិនី អហោសិ ឥតិបីតិ ។ សា តស្សា សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តោ តទត្ថាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អានន្ទ ភិក្ខុនិយា ផាសុវិហារោ ហោតិ ។ ឥធានន្ទ ភិក្ខុ សុណាតិ ឥត្ថន្នាមា ភិក្ខុនី កាលកតា សា ភគវតា ព្យាកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនី សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សតីតិ សា ខោ បនស្ស ភគិនី សាមំ ទិដ្ឋា វា ហោតិ អនុស្សវសុតា វា ឯវំសីលា សា ភគិនី អហោសិ ឥតិបិ ឯវំធម្មា ។ បេ ។ ឯវំបញ្ញា... ឯវំវិហារិនី... ឯវំវិមុត្តា សា ភគិនី អហោសិ

មានសភាពជាឱបបាតិកៈកំណើត បរិនិព្វានក្នុងលោកនោះ មានសភាព មិនត្រឡប់ ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយ-សំយោជនៈទាំង ៥ ដូច្នេះ ភិក្ខុនីនោះយល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮត ៗ មកថា នាងនោះមានសីលយ៉ាងនេះដូច្នេះខ្លះ នាងនោះមាន ធម៌យ៉ាងនេះដូច្នេះខ្លះ នាងនោះមានបញ្ញាយ៉ាងនេះដូច្នេះខ្លះ នាងនោះ មានវិហារធម៌យ៉ាងនេះដូច្នេះខ្លះ នាងនោះមានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ភិក្ខុនីនោះ រលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់ ភិក្ខុនីនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ភិក្ខុនី ។ ម្នាលពួកអនុរុទ្ធ ភិក្ខុនីក្នុងធម្មវិន័យនេះ រមែងឮថា ភិក្ខុនីឈ្មោះនេះ មានមរណកាល ធ្វើហើយ ភិក្ខុនីនោះព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាសកទាគាមិនី-បុគ្គល មកកាន់លោកនេះតែម្តងទៀតហើយធ្វើនូវទីបំផុតទុក្ខ ព្រោះអស់ ទៅនៃសំយោជនៈទាំង ៣ មានរាគៈ ទោសៈ មោហៈ ស្រាលស្តើងដូច្នេះ ភិក្ខុនីនោះ បានយល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮត ៗ មកថា នាងនោះមានសីលយ៉ាងនេះដូច្នេះខ្លះ មានធម៌យ៉ាងនេះខ្លះ ។ បេ ។ មាន បញ្ញាយ៉ាងនេះ... មានវិហារធម៌យ៉ាងនេះ... នាងនោះមានវិមុត្តិយ៉ាងនេះ

ឥតិបីតិ ។ សា តស្ស សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តី តទត្ថាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អនុរុទ្ធា ភិក្ខុនិយា ផាសុវិហារោ ហោតិ ។ ឥធានុរុទ្ធា ភិក្ខុនី សុណាតិ ឥត្ថន្នាមា ភិក្ខុនី កាលកតា សា ភគវតា ព្យាកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ សា ខោ បនស្សា ភគិនី សាមំ ទិដ្ឋា វា ហោតិ អនុស្សវសុតា វា ឯវំសីលា សា ភគិនី អហោសិ ឥតិបិ ឯវំធម្មា ។ បេ ។ ឯវំបញ្ញា... ឯវំវិហារិនី... ឯវំវិមុត្តា សា ភគិនី អហោសិ ឥតិបីតិ ។ សា តស្សា សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តី តទត្ថាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អនុរុទ្ធា ភិក្ខុនិយា ផាសុវិហារោ ហោតិ ។

ដូច្នេះខ្លះ ។ ភិក្ខុនីនោះ រលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និង បញ្ញារបស់ភិក្ខុនីនោះ ក៏បង្អោនចិត្តទៅដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ភិក្ខុនី ។ ម្នាលពួកអនុរុទ្ធ ភិក្ខុនីក្នុងធម្មវិន័យនេះ រមែងឮថា ភិក្ខុនីឈ្មោះនេះមានមរណកាលធ្វើ ហើយ ភិក្ខុនីនោះព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រ-ព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ដូច្នេះ ភិក្ខុនីនោះ បានយល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮត ៗ មកថា នាងនោះ មានសីលយ៉ាងនេះដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។ បេ ។ មានបញ្ញាយ៉ាង នេះ... មានវិហារធម៌យ៉ាងនេះ... នាងនោះមានវិមុត្តិយ៉ាងនេះដូច្នេះ ខ្លះ ។ ភិក្ខុនីនោះ រលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់ភិក្ខុនីនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួក អនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ភិក្ខុនី ។

ភិក្ខុវគ្គស្ស នឡកបានសុត្តេ ឧបាសកផាសុវិហារោ

[២០១] ឥធានុរុទ្ធា ឧបាសកោ សុណាតិ ឥត្ថន្នាមោ ឧបាសកោ កាលកតោ សោ ភគវតា ព្យាកតោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកាតិ សោ ខោ បនស្ស អាយស្មា សាមំ ទិដ្ឋោ វា ហោតិ អនុស្សវស្សុតោ វា ឯវំសីលោ សោ អាយស្មា អហោសិ ឥតិបិ ឯវំធម្មោ សោ អាយស្មា អហោសិ ឥតិបិ ឯវំបញ្ញោ សោ អាយស្មា អហោសិ ឥតិបិ ឯវំវិហារី សោ អាយស្មា អហោសិ ឥតិបិ ឯវំវិមុត្តោ សោ អាយស្មា អហោ-សិ ឥតិបីតិ ។ សោ តស្ស សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តោ តទត្ថាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អនុរុទ្ធា ឧបាសកស្ស ផាសុវិហារោ ហោតិ ។ ឥធានុរុទ្ធា ឧបាសកោ សុណាតិ ឥត្ថន្នាមោ ឧបាសកោ កាលកតោ សោ

[២០១] ម្នាលពួកអនុរុទ្ធ ឧបាសក ក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសកឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសកនោះព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាឱបបាតិកៈកំណើត បរិនិព្វានក្នុងលោកនោះ មានសភាពមិនត្រឡប់ ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ដូច្នេះ ឧបាសកនោះបានយល់ឃើញអ្នកមានអាយុនោះដោយខ្លួនឯង ឬបានឮត ៗ មកថា អ្នកមានអាយុនោះមានសីលយ៉ាងនេះដូច្នេះខ្លះ អ្នកមានអាយុនោះ មានធម៌យ៉ាងនេះដូច្នេះខ្លះ អ្នកមានអាយុនោះ មានបញ្ញាយ៉ាងនេះដូច្នេះខ្លះ អ្នកមានអាយុនោះមានវិហារធម៌យ៉ាងនេះដូច្នេះខ្លះ អ្នកមានអាយុនោះ មានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ឧបាសកនោះ រលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់ឧបាសកនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ឧបាសក ។ ម្នាលពួកអនុរុទ្ធ ឧបាសក ក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសកឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសកនោះ

ភគវតា ព្យាកតោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សតីតិ សោ ខោ បនស្ស អាយស្មា សាមំ ទិដ្ឋោ វា ហោតិ អនុស្សវសុតោ វា ឯវំសីលោ សោ អាយស្មា អហោសិ ឥតិបិ ឯវំធម្មោ ។ បេ ។ ឯវំបញ្ញោ... ឯវំវិហារី... ឯវំវិមុត្តោ សោ អាយស្មា អហោសិ ឥតិបីតិ ។ សោ តស្ស សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តោ តទត្ថាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អនុរុទ្ធា ឧបាសកស្ស ផាសុវិហារោ ហោតិ ។ ឥធានុរុទ្ធា ឧបាសកោ សុណាតិ ឥត្ថន្នាមោ ឧបាសកោ កាលកតោ សោ ភគវតា ព្យាកតោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ សោ ខោ បនស្ស អាយស្មា សាមំ ទិដ្ឋោ វា ហោតិ អនុស្សវសុតោ វា ឯវំសីលោ សោ អាយស្មា អហោសិ ឥតិបិ ឯវំធម្មោ ។ បេ ។

ព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ៣ មានរាគៈ ទោសៈ មោហៈ ស្រាលស្តើងដូច្នេះ ឧបាសកនោះ បានយល់ឃើញអ្នកមានអាយុនោះដោយខ្លួនឯង ឬបានឮត ៗ មកថា អ្នកមានអាយុនោះ មានសីលយ៉ាងនេះដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។ បេ ។ មានបញ្ញាយ៉ាងនេះ.... មានវិហារធម៌យ៉ាងនេះ... អ្នកមានអាយុនោះ មានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ឧបាសកនោះ រលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់ឧបាសកនោះហើយក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ឧបាសក ។ ម្នាលពួកអនុរុទ្ធ ឧបាសកក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសកឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសកនោះ ព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិ ជាទីប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ដូច្នេះ ឧបាសកនោះ បានយល់ឃើញអ្នកមានអាយុនោះដោយខ្លួនឯង ឬបានឮត ៗ មកថា អ្នកមានអាយុនោះ មានសីលយ៉ាងនេះដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។ បេ ។

ឯវំបញ្ញោ... ឯវំវិហារី... ឯវំវិមុត្តោ សោ អាយស្មា អហោសិ ឥតិបីតិ ។ សោ តស្ស សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តោ តជត្តាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អនុរុទ្ធា ឧចាសកស្ស ផាសុវិហារោ ហោតិ ។

[២០២] ឥធានុរុទ្ធា ឧចាសិកា សុណាតិ ឥត្ថន្នាមា ឧចាសិកា កាលកតា សា ភគវតា ព្យាកតា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបចាតិកា តត្ថ បរិនិព្វាយិនី អនាវត្តិធម្មា តស្មា លោកាតិ សា ខោ បនស្សា ភគិនី សាមំ ទិដ្ឋា វា ហោតិ អនុស្សវសុតា វា ឯវំសីលា សា ភគិនី អហោសិ ឥតិបិ ឯវំធម្មា ។ បេ ។ ឯវំបញ្ញា... ឯវំវិ-ហារិនី... ឯវំវិមុត្តា សា ភគិនី អហោសិ ឥតិបីតិ ។ សា តស្សា សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តី សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តី តជត្តាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អនុរុទ្ធា ឧចាសិកាយ ផាសុវិហារោ ហោតិ ។

មានបញ្ញាយ៉ាងនេះ... មានវិហារធម៌យ៉ាងនេះ... អ្នកមានអាយុនោះ មានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ឧបាសកនោះ រលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់ឧបាសកនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌ របស់ឧបាសក ។

[២០២] ម្នាលពួកអនុរុទ្ធ ឧបាសិកាក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសិកាឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសិកានោះព្រះមានព្រះភាគ ទ្រង់ព្យាករថា មានសភាពជាឱបបាតិកៈកំណើត បរិនិព្វានក្នុងលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ដូច្នេះ ឧបាសិកានោះបានយល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮត ៗ មកថា នាងនោះមានសីលយ៉ាងនេះ ដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។ បេ ។ មានបញ្ញាយ៉ាងនេះ មានវិហារធម៌យ៉ាងនេះ... នាងនោះមានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ឧបាសិកានោះ រលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់ឧបាសិកានោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌ របស់ឧបាសិកា ។

ឥធានុរុទ្ធា ឧបាសិកា សុណាតិ ឥត្ថន្នាមា ឧបា-
សិកា កាលកតា សា ភគវតា ព្យាកតា តិណ្ណំ
សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា
សកទាគាមិនី សកិទេវ ឥមំ លោកំ អាគន្ត្វា
ទុក្ខស្សន្តំ ករិស្សតីតិ សា ខោ បនស្សា ភគិនី
សាមំ ទិដ្ឋា វា ហោតិ អនុស្សវសុតា វា ឯវំសីលា សា
ភគិនី អហោសិ ឥតិបិ ឯវំធម្មា ។ បេ ។ ឯវំបញ្ញា...
ឯវំវិហារិនី... ឯវំវិមុត្តា សា ភគិនី អហោសិ
ឥតិបីតិ ។ សា តស្សា សទ្ធញ្ច សីលញ្ច សុតញ្ច
ចាគញ្ច បញ្ញញ្ច អនុស្សរន្តី តទត្ថាយ ចិត្តំ
ឧបសំហរតិ ។ ឯវម្បិ ខោ អនុរុទ្ធា ឧបាសិកាយ
ផាសុវិហារោ ហោតិ ។ ឥធានុរុទ្ធា ឧបាសិកា
សុណាតិ ឥត្ថន្នាមា ឧបាសិកា កាលកតា សា
ភគវតា ព្យាកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា
សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ

ម្នាលពួកអនុរុទ្ធ ឧបាសិកា ក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសិកាឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសិកានោះ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិនីបុគ្គល នឹងមកកាន់លោកនេះម្តងទៀតហើយធ្វើនូវទីបំផុតទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ៣ មានរាគៈ ទោសៈ មោហៈ ស្រាលស្តើងដូច្នេះ ឧបាសិកានោះយល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮត ៗ មកថា នាងនោះឯងមានសីលយ៉ាងនេះដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។ បេ ។ មានបញ្ញាយ៉ាងនេះ... មានវិហារធម៌យ៉ាងនេះ.... នាងនោះមានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ឧបាសិកានោះរលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់ឧបាសិកានោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលអនុរុទ្ធ យ៉ាងនេះឯងឈ្មោះថា ផាសុវិហារធម៌ របស់ឧបាសិកា ។ ម្នាលអនុរុទ្ធ ឧបាសិកាក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសិកាឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសិកានោះព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាសោ-តាបន្នបុគ្គល មានភាពមិនធ្លាក់ចុះ ក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ដូច្នេះ

សា ខោ បនស្សា ភគិនី សាមំ ទិដ្ឋា វា ហោតិ អនុស្សវសុតា វា ឯវំសីលា សា ភគិនី អហោសិ ឥតិបិ ឯវំធម្មា សា ភគិនី អហោសិ ឥតិបិ ឯវំវិហារិនី សា ភគិនី អហោសិ ឥតិបិ ឯវំវិមុត្តា សា ភគិនី អហោសិ ឥតិបីតិ ។ សា តស្សា សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរន្តី តទត្ថាយ ចិត្តំ ឧបសំហរតិ ។ ឯវម្បិ ខោ អនុរុទ្ធា ឧចាសិកាយ ផាសុវិហារោ ហោតិ ។ ឥតិ ខោ អនុរុទ្ធា តថាគតោ ន ជនកុហនត្ថំ ន ជនលបនត្ថំ ន លាភសក្ការសិ-លោកានិសំសត្ថំ ន ឥតិ មំ ជនោ ជានាតូតិ សាវកេ អព្ភតីតេ កាលកតេ ឧបបត្តីសុ ព្យាករោតិ អសុ អមុត្រ ឧប្បន្នោ អសុ អមុត្រ ឧប្បន្នោតិ ។ សន្តិ ខោ[១] អនុរុទ្ធា កុលបុត្តា សទ្ធា ឱឡារវេទា

១ ឱ. ម. សន្តិ ច ខោ ។

ឧបាសិកានោះ យល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮត ៗ មកថា នាងនោះ មានសីលយ៉ាងនេះដូច្នេះខ្លះ នាងនោះមានធម៌យ៉ាងនេះដូច្នេះខ្លះ នាងនោះ មានវិហារធម៌យ៉ាងនេះដូច្នេះខ្លះ នាងនោះមានវិមុត្តិយ៉ាងនេះដូច្នេះខ្លះ ។ ឧបាសិកានោះ រលឹកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់ឧបាសិកានោះហើយក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថាផាសុវិហារធម៌ របស់ឧបាសិកា ។ ម្នាលពួកអនុរុទ្ធ ហេតុដូច្នោះបានជាតថាគត ព្យាករក្នុងកំណើតរបស់ពួកសាវ័ក ដែលធ្វើមរណកាលកន្លងទៅហើយថា សាវ័កឯណោះ កើតក្នុងទីឯណោះ សាវ័កឯណោះ កើតក្នុងទីឯណោះ ដើម្បីនឹងឲ្យជនស្ញប់ស្ញែងក៏ទេ ដើម្បីនឹងប្រលោមជនក៏ទេ ដើម្បីអានិសង្សគឺលាភសក្ការៈនិងសេចក្តីសរសើរក៏ទេ (ឬ) គិតថា ឲ្យគេស្គាល់តថាគតក៏ទេដែរ ។ ម្នាលពួកអនុរុទ្ធ កុលបុត្តទាំងឡាយអ្នកមានសទ្ធា មានសេចក្តីត្រេកអរខ្លាំង

ឱឡារប្បាមុជ្ជា តេ តំ សុត្វា តទត្ថាយ ចិត្តំ ឧបសំហរន្តិ តេសន្តំ អនុរុទ្ធា ហោតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អនុរុទ្ធោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

នឡកបានសុត្តំ អដ្ឋមំ និដ្ឋិតំ ។

មានបាមោជ្ជៈក្បៀវក្លា កុលបុត្តអម្បាលនោះ លុះបានស្តាប់នូវព្យាករណ៍នោះហើយ តែងបង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ម្នាលពួកអនុរុទ្ធ ការព្យាករនោះ (តែងប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍និងសេចក្តីសុខ ដល់កុលបុត្តទាំងឡាយនោះ អស់កាលជាយូរអង្វែង ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះចប់ហើយ ព្រះអនុរុទ្ធមានអាយុ ក៏មានសេចក្តីពេញចិត្តត្រេកអរ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ នឡកបានសូត្រ ទី ៨ ។

# នវមំ គោលិស្សានិសុត្តំ

[២០៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន គោលិស្សានិ នាម[១] ភិក្ខុ អារញ្ញកោ បទរសមាចារោ សង្ឃមជ្ឈេ ឱសដោ ហោតិ កេនចិទេវ ករណីយេន ។

[២០៤] តត្រ ខោ អាយស្មា សារីបុត្តោ គោលិស្សានឹ នាម ភិក្ខុំ អារព្ភ ភិក្ខូ អាមន្តេសិ អារញ្ញកេនាវុសោ ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន សព្រហ្មចារីសុ សគារវេន ភវិតព្វំ សប្បតិស្សេន ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ សង្ឃគតោ សង្ឃេ វិហរន្តោ សព្រហ្មចារីសុ អគារវោ ហោតិ អប្បតិស្សោ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរិវិហារេន យោ អយមាយស្មា សព្រហ្មចារីសុ អគារវោ ហោតិ[២] អប្បតិស្សោតិ

---

១ ម. គោលិយានិ នាម ។ ឱ. គុលិស្សានិ នាម ។ ២ ឱ. ហោតីតិ ន ទិស្សតិ ។

# គោលិស្សានិសូត្រ ទី ៩

[២០៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង មានភិក្ខុមួយរូបឈ្មោះគោលិស្សានិ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកមានមារយាទមិនរៀបរយ អង្គុយក្នុងកណ្តាលជំនុំសង្ឃ ដោយកិច្ចណាមួយ ។

[២០៤] លំដាប់នោះ ព្រះសារីបុត្តមានអាយុ ប្រារព្ធនូវគោលិស្សានិភិក្ខុ ហើយទើបពោលនឹងភិក្ខុទាំងឡាយថា ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុដែលសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរតែប្រកបដោយសេចក្តីគោរពកោតក្រែង ចំពោះពួកសព្រហ្មចារីទាំងឡាយ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ ជាអ្នកមិនគោរព មិនកោតក្រែង ចំពោះពួកសព្រហ្មចារីហើយ ពួកជននឹងពោលតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វីលោកមានអាយុនេះ សមាទានអារញ្ញិកធុតង្គនៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ចំពោះសព្រហ្មចារីទាំងឡាយ

តស្ស[១] ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន សព្រហ្មចារីសុ សគារវេន ភវិតព្វំ សប្បតិស្សេន ។

[២០៤] អារញ្ញកេនាវុសោ ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន អាសនកុសលេន ភវិតព្វំ ឥតិ ថេរេ ច ភិក្ខូ នានុបខជ្ជ និសីទិស្សាមិ នវេ ច ភិក្ខូ ន អាសនេន បដិពាហិស្សាមីតិ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ សង្ឃគតោ សង្ឃេ វិហរន្តោ ន អាសនកុសលោ ហោតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរិវិហារេន យោ អយមាយស្មា[២] អភិសមាចារិកម្បិ ធម្មំ ន ជានាតីតិ តស្ស ភវន្តិ វត្តារោ

១ ឥតិស្សាតិ បាឋេន ភវិតព្វំ ។ ២ ឥតោ បរំ អាសនកុសលោ ន ហោតីតិ មរម្មបោត្ថកេ ទិស្សតិ ។

លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរតែប្រកបដោយសេចក្តីគោរព កោតក្រែង ចំពោះសព្រហ្មចារីទាំងឡាយ ។

[២០៥] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរជាអ្នកឈ្លាសក្នុងការអង្គុយថា អាត្មាអញ នឹងមិនអង្គុយជ្រៀតបៀត ភិក្ខុទាំងឡាយជាថេរៈផង មិនហាមឃាត់ភិក្ខុថ្មីទាំងឡាយដោយអាសនៈផង ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃមិនឈ្លាសក្នុងការអង្គុយហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វីលោកមានអាយុនេះ សមាទានអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង ព្រោះលោកមានអាយុនេះ មិនដឹងច្បាប់អភិសមាចារិកវត្តសោះ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង

តស្មា អារញ្ញកេន ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន អាសនកុសលេន ភវិតព្វំ[១] ។

[២០៦] អារញ្ញកេនាវុសោ ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន នាតិកាលេន គាមោ បវិសិតព្វោ ន ទិវា បដិក្កមិតព្វំ សចេ អាវុសោ អារញ្ញកោ ភិក្ខុ សង្ឃគតោ សង្ឃេ វិហរន្តោ អតិកាលេន គាមំ បវិសតិ ទិវា បដិក្កមតីតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរីវិហារេន យោ អយមាយស្មា អតិកាលេន គាមំ បវិសតិ ទិវា បដិក្កមតីតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន នាតិកាលេន គាមោ បវិសិតព្វោ ន ទិវា បដិក្កមិតព្វំ ។

---

១ ម. ឥតោ បរំ អភិសមាចារិកោបិ ធម្មោ ជានិតព្វោ សចេ អាវុសោ អារញ្ញកោ ភិក្ខុ.. ន អភិសមាចារិកម្បិ ធម្មំ ន ជានាតិ តស្ស ភវន្តិ វត្តារោ កិម្បិនិមស្សាយស្មតោ... ន ជានាតីតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា អភិសមាចារោ ធម្មោ ជានិតព្វោ ទិស្សន្តិ ។

ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរតែឈ្លាសក្នុងការអង្គុយ ។

[២០៦] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ មិនគួរចូលទៅ កាន់ស្រុកឲ្យហួសវេលា មិនគួរត្រឡប់មកឲ្យទាល់ថ្ងៃ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ នឹងចូលទៅកាន់ស្រុកឲ្យហួសវេលា ត្រឡប់មកទាល់ថ្ងៃហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វីលោកមានអាយុនេះ សមាទានអារញ្ញិក-ធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង ព្រោះលោកមានអាយុនេះ ចូលទៅកាន់ស្រុក ឲ្យហួសវេលា ត្រឡប់មកវិញទាល់ថ្ងៃ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមា-ទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ មិនគួរចូលទៅកាន់ស្រុកឲ្យហួសវេលា មិនគួរត្រឡប់មកឲ្យទាល់ថ្ងៃឡើយ ។

[២០៧] អារញ្ញកេនាវុសោ ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន ន បុរេភត្តំ បច្ឆាភត្តំ កុលេសុ ចារិត្តំ អាបជ្ជិតព្វំ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ សង្ឃគតោ សង្ឃេ វិហរន្តោ បុរេភត្តំ បច្ឆា-ភត្តំ កុលេសុ ចារិត្តំ អាបជ្ជតិ តស្ស ភវន្តិ វត្តារោ អយន្នូនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរីវិហារេន វិហរតោ វិកាលេ ចរិយា ពហុលីកតា តមេនំ សង្ឃគតម្បិ សមុទាចរតីតិ តស្ស[១] ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន ន បុរេភត្តំ បច្ឆាភត្តំ កុលេសុ ចារិត្តំ អាបជ្ជិតព្វំ ។

---

១ ឱ. សមុទាចរតីតិស្ស ។

[២០៧] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ មិនគួរដល់នូវការត្រាច់ទៅ ក្នុងត្រកូលទាំងឡាយ ក្នុងវេលាមុនភត្តនិងក្រោយភត្តឡើយ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ ដល់នូវការត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងវេលាមុនភត្តនិងក្រោយភត្តហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង ទាំងការត្រាច់ទៅក្នុងវេលាវិកាល ភិក្ខុនោះក៏បានធ្វើរឿយ ៗ នាំឲ្យសង្ឃលំបាកហៅរកភិក្ខុនោះមកកាន់ជំនុំសង្ឃ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃហើយ មិនគួរដល់នូវការត្រាច់ទៅ ក្នុងត្រកូលទាំង-ឡាយ ក្នុងវេលាមុនភត្តនិងក្រោយភត្តឡើយ ។

[២០៨] អារញ្ញកេនាវុសោ ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន អនុទ្ធតេន ភវិតព្វំ អចបលេន ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ សង្ឃគតោ សង្ឃេ វិហរន្តោ ឧទ្ធតោ ហោតិ ចបលោ តស្ស ភវន្តិ វត្តារោ ឥទន្នូនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរីវិហារេន វិហរតោ ឧទ្ធច្ចំ ចាបល្យំ ពហុលីកតំ តមេនំ សង្ឃគតម្បិ សមុទាចរតីតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន អនុទ្ធតេន ភវិតព្វំ អចបលេន ។

[២០៩] អារញ្ញកេនាវុសោ ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន អមុខរេន ភវិតព្វំ អវិកិណ្ណវាចេន ។

ភិក្ខុវគ្គ គោលិស្សានិសូត្រ អារញ្ញកវគ្គ ទី ៥

[២០៨] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ មិនគួរមានចិត្តរាយមាយឃ្លេងឃ្លោងឡើយ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ មានចិត្តរាយមាយឃ្លេងឃ្លោងហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯងមែន តែមានចិត្តរាយមាយឃ្លេងឃ្លោងធ្វើឲ្យរឿយ ៗ នាំឲ្យសង្ឃលំបាកហៅរកមកកាន់ជំនុំសង្ឃ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងទីប្រជុំសង្ឃ មិនគួរជាអ្នកមានចិត្តរាយមាយឃ្លេងឃ្លោងឡើយ ។

[២០៩] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ កុំជាអ្នកមានមាត់រឹង កុំជាអ្នកមានវាចាឡេះឡោះឡើយ ។

សចេ អាវុសោ អារញ្ញកោ ភិក្ខុ សង្ឃគតោ សង្ឃេ វិហរន្តោ មុខរោ ហោតិ វិកិណ្ណវាចោ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរិវិហារេន យោ អយមាយស្មា មុខរោ វិកិណ្ណវាចោតិ តស្ស[១] ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន អមុខរេន ភវិតព្វំ អវិកិណ្ណវាចេន ។

[២១០] អារញ្ញកេនាវុសោ ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន សុវចេន ភវិតព្វំ កល្យាណមិត្តេន ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ សង្ឃគតោ សង្ឃេ វិហរន្តោ ទុព្វចោ ហោតិ បាបមិត្តោ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរិវិហារេន យោ អយមាយស្មា ទុព្វចោ

១ ឱ. វិកិណ្ណវាចោតិស្ស ។

ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ ជាអ្នកមានមាត់រឹងពោលវាចាឡេះឡោះហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វីលោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកមានមាត់រឹងពោលវាចាឡេះឡោះ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃហើយ កុំជាអ្នកមានមាត់រឹង កុំជាអ្នកមានវាចាឡេះឡោះឡើយ ។

[២១០] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរជាអ្នកប្រដៅងាយ មានមនុស្សល្អជាមិត្រ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ ជាអ្នកប្រដៅក្រ មានមនុស្សអាក្រក់ជាមិត្រហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វីលោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកប្រដៅក្រ

ចាបមិត្តោតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា សង្ឃគតេន សង្ឃេ វិហរន្តេន សុវចេន ភវិតព្វំ កល្យាណមិត្តេន ។

[២១១] អារញ្ញកេនាវុសោ ភិក្ខុនា ឥន្ទ្រិយេសុ គុត្តទ្វារេន ភវិតព្វំ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ន(១) ហោតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរិវិហារេន យោ អយមាយស្មា ឥន្ទ្រិយេសុ គុត្តទ្វារោ ន(២) ហោតីតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា ឥន្ទ្រិយេសុ គុត្តទ្វារេន ភវិតព្វំ ។

---

១-២ ឱ. ម. អគុត្តទ្វារោ ។

មានមនុស្សអាក្រក់ជាមិត្រ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរជាអ្នកប្រដៅងាយ មានមនុស្សល្អជាមិត្រ ។

[២១១] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាន នូវអារញ្ញិកធុតង្គ ជាអ្នកមិនមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វីលោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកមានទ្វារមិនបានគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ។

[២១២] អារញ្ញកេនាវុសោ ភិក្ខុនា ភោជនេ មត្តញ្ញុនា ភវិតព្វំ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ ភោជនេ អមត្តញ្ញូ ហោតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរិវិហារេន យោ អយមាយស្មា ភោជនេ អមត្តញ្ញូ ហោតីតិ តស្ស[១] ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា ភោជនេ មត្តញ្ញុនា ភវិតព្វំ ។

[២១៣] អារញ្ញកេនាវុសោ ភិក្ខុនា ជាគរិយំ អនុយុត្តេន ភវិតព្វំ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ ជាគរិយំ អននុយុត្តោ ហោតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯ-កស្សារញ្ញេ សេរិវិហារេន យោ អយមាយស្មា

១ ឱ. អមត្តញ្ញូតិស្ស ។ ម. អមត្តញ្ញូតិ តស្ស ។

[២១២] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកដឹងប្រមាណក្នុងភោជន ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកមិនដឹងប្រមាណ ក្នុងភោជនហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកមិនដឹងប្រមាណក្នុងភោជន លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកដឹងប្រមាណក្នុងភោជន ។

[២១៣] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកប្រកបរឿយ ៗ នូវការភ្ញាក់រលឹក ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ មិនប្រកបរឿយ ៗ នូវការភ្ញាក់រលឹកហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង ព្រោះលោកមានអាយុនេះ

ជាតរិយំ អននុយុត្តោ ហោតីតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា ជាតរិយំ អនុយុត្តេន ភវិតព្វំ ។

[២១៤] អារញ្ញកេនាវុសោ ភិក្ខុនា អារទ្ធវីរិយេន ភវិតព្វំ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ កុសីតោ ហោតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរីវិហារេន យោ អយមាយស្មា កុសីតោ ហោតីតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា អារទ្ធវីរិយេន ភវិតព្វំ ។

[២១៥] អារញ្ញកេនាវុសោ ភិក្ខុនា ឧបដ្ឋិតស្សតិនា ភវិតព្វំ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ មុដ្ឋស្សតិ ហោតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរីវិហារេន យោ

ជាអ្នកមិនប្រកបរឿយ ៗ នូវការភ្ញាក់រលឹក លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកប្រកបរឿយ ៗ នូវការភ្ញាក់រលឹក ។

[២១៤] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកប្រារព្ធព្យាយាម ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកខ្ជិលច្រអូសហើយ នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះជាអ្នកខ្ជិលច្រអូស លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកប្រារព្ធព្យាយាម ។

[២១៥] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកតាំងស្មារតីឲ្យមាំ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកភ្លេចស្មារតីហើយ នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង

អយមាយស្មា មុដ្ឋស្សតីតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា ឧបដ្ឋិតស្សតិនា ភវិតព្វំ ។

[២១៦] អារញ្ញកេនាវុសោ ភិក្ខុនា សមាហិតេន ភវិតព្វំ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ អសមាហិតោ ហោតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរីវិហារេន យោ អយមាយស្មា អសមាហិតោតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា សមាហិតេន ភវិតព្វំ ។

[២១៧] អារញ្ញកេនាវុសោ ភិក្ខុនា បញ្ញវតា ភវិតព្វំ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ ទុប្បញ្ញោ ហោតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ

ព្រោះលោកមានអាយុនេះជាអ្នកភ្លេចស្មារតី លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកតាំងស្មារតីឲ្យមាំ ។

[២១៦] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានចិត្តខ្ជាប់ខ្ជួន ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកមានចិត្តមិនខ្ជាប់ខ្ជួនហើយ នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកមានចិត្តមិនខ្ជាប់ខ្ជួន លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានចិត្តខ្ជាប់ខ្ជួន ។

[២១៧] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានប្រាជ្ញា ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកគ្មានប្រាជ្ញាហើយ នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ

អារញ្ញកស្ស ឯកស្សារញ្ញេ សេរីវិហារេន យោ អយមាយស្មា ឧប្បញ្ញោតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា បញ្ញវតា ភវិតព្វំ ។

[២១៨] អារញ្ញកេនាវុសោ ភិក្ខុនា អភិធម្មេ អភិវិនយេ យោគោ ករណីយោ ។ សន្តាវុសោ អារញ្ញកំ ភិក្ខុំ អភិធម្មេ អភិវិនយេ បញ្ហំ បុច្ឆិ-តារោ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ អភិធម្មេ អភិវិនយេ បញ្ហំ បុដ្ឋោ ន សម្បាយតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរីវិហារេន យោ អយមាយស្មា អភិធម្មេ អភិវិនយេ បញ្ហំ បុដ្ឋោ ន សម្បាយតីតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា អភិធម្មេ អភិវិនយេ យោគោ ករណីយោ ។

ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកគ្មានប្រាជ្ញា លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានប្រាជ្ញា ។

[២១៨] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីធ្វើសេចក្តីព្យាយាម ក្នុងអភិធម្មនិងអភិវិន័យ ។ ម្នាលលោកមានអាយុទាំងឡាយ ពួកជនអ្នកសួរប្រស្នា ក្នុងអភិធម្មនិងអភិវិន័យ ចំពោះភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គង់មាន ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ត្រូវគេសួរប្រស្នា ក្នុងអភិធម្មនិងអភិវិន័យ ហើយឆ្លើយមិនរួច នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ តាមអំពើចិត្តខ្លួននៅក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះ ត្រូវគេសួរប្រស្នា ក្នុងអភិធម្មនិងអភិវិន័យហើយឆ្លើយមិនរួច លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីជាអ្នកធ្វើសេចក្តីព្យាយាមក្នុងអភិធម្មនិងអភិវិន័យ ។

[២១៩] អារញ្ញកេនាវុសោ ភិក្ខុនា យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តត្ថ យោគោ ករណីយោ ។ សន្តាវុសោ អារញ្ញកំ ភិក្ខុំ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តត្ថ[១] បុច្ឆិតារោ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តត្ថ បញ្ហំ បុដ្ឋោ ន សម្បាយតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរីវិហារេន យោ អយមាយស្មា យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តត្ថ បញ្ហំ បុដ្ឋោ ន សម្បាយតីតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តត្ថ យោគោ ករណីយោ ។

---

១ ឱ. ម. តត្ថ បញ្ហំ ។

[២១៩] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីធ្វើសេចក្តីព្យាយាមក្នុងវិមោក្ខ ជាអារុប្បៈដែលហួសរូបសមាបត្តិទៅ[១] ។ ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុជាអ្នកសមាទាននូវអារញ្ញិកធុតង្គ តែងមានគេសួរប្រស្នា ក្នុងវិមោក្ខជាអារុប្បៈដែលហួសរូបសមាបត្តិទៅ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ មានគេសួរប្រស្នាក្នុងវិមោក្ខជាអារុប្បៈដែលហួសរូបសមាបត្តិទៅ ហើយឆ្លើយមិនរួច នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង ព្រោះលោកមានអាយុនេះ មានគេសួរប្រស្នាក្នុងវិមោក្ខជាអារុប្បៈ ដែលហួសរូបសមាបត្តិទៅ ហើយឆ្លើយមិនរួច លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីធ្វើសេចក្តីព្យាយាមក្នុងវិមោក្ខជាអារុប្បៈ ដែលហួសរូបសមាបត្តិទៅ ។

---

១ សំដៅយករូបារូបសមាបត្តិទាំង ៨ ។ អដ្ឋកថា ។

[២២០] អារញ្ញកេនាវុសោ ភិក្ខុនា ឧត្តរិមនុស្ស-ធម្មេ យោគោ ករណីយោ ។ សន្តាវុសោ អារញ្ញកំ ភិក្ខុំ ឧត្តរិមនុស្សធម្មេ បញ្ហំ បុច្ឆិតារោ ។ សចេ អាវុសោ អារញ្ញកោ ភិក្ខុ ឧត្តរិមនុស្សធម្មេ បញ្ហំ បុដ្ឋោ ន សម្បាយតិ តស្ស ភវន្តិ វត្តារោ កិម្បនិមស្សាយស្មតោ អារញ្ញកស្ស ឯកស្សារញ្ញេ សេរីវិហារេន យោ អយមាយស្មា យស្សត្ថាយ[១] បព្វជិតោ តមត្ថំ ន ជានាតីតិ តស្ស ភវន្តិ វត្តារោ តស្មា អារញ្ញកេន ភិក្ខុនា ឧត្តរិមនុស្សធម្មេ យោគោ ករណីយោតិ ។

---

១ ឱ. យស្សបត្ថាយ ។

ភិក្ខុវគ្គ គោលិស្សានិសូត្រ អារញ្ញកវគ្គ ទី ១៧

[២២០] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីជាអ្នកធ្វើសេចក្តីព្យាយាម ក្នុងឧត្តរិមនុស្សធម៌ ។ ម្នាលលោកមានអាយុទាំងឡាយ ពួកជនអ្នកសួរប្រស្នា ក្នុងឧត្តរិមនុស្សធម៌ ចំពោះភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គគង់មាន ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ត្រូវគេសួរប្រស្នាក្នុងឧត្តរិមនុស្សធម៌ ហើយឆ្លើយមិនរួច នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះ បួសហើយដើម្បីប្រយោជន៍ណា ក៏មិនដឹងប្រយោជន៍នោះ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីជាអ្នកធ្វើសេចក្តីព្យាយាម ក្នុងឧត្តរិមនុស្សធម៌ ។

[២២១] ឯវំ វុត្តេ អាយស្មា មហាមោគ្គល្លានោ អាយស្មន្តំ សារីបុត្តំ ឯតទវោច អារញ្ញកេនេវ ឥធ ខោ អាវុសោ សារីបុត្ត ភិក្ខុនា ឥមេ ធម្មា សមាទាយ វត្តិតព្វា ឧទាហុ គាមន្តវិហារិនាបីតិ ។ អារញ្ញកេនបិ ខោ អាវុសោ មោគ្គល្លាន ភិក្ខុនា ឥមេ ធម្មា សមាទាយ វត្តិតព្វា បគេវ គាមន្តវិហារិនាតិ ។

គោលិស្សានិសុត្តំ នវមំ[១] និដ្ឋិតំ ។

---

១ ឱ. គុលិស្សានិសុត្តន្តំ នវមំ ។ ម. គោលិយានិ សុត្តន្តំ នវមំ ។

[២២១] កាលព្រះសារីបុត្តពោលយ៉ាងនេះហើយ ព្រះមហាមោគ្គ-ល្លានមានអាយុ បានពោលពាក្យនេះ នឹងព្រះសារីបុត្តមានអាយុថា ម្នាលអាវុសោសារីបុត្ត ចុះធម៌ទាំងនេះគួរតែភិក្ខុអ្នកសមាទាននូវអារញ្ញិក-ធុតង្គ ទើបសមាទានប្រព្រឹត្តបានឬ ឬក៏ភិក្ខុដែលនៅក្នុងស្រុកគួរសមា-ទានប្រព្រឹត្តបានដែរ ។ ម្នាលអាវុសោមោគ្គល្លាន ធម៌ទាំងនេះសូម្បីភិក្ខុអ្នកសមាទាន នូវអារញ្ញិកធុតង្គ ក៏គួរតែសមាទានប្រព្រឹត្តទៅហើយ នឹងចាំបាច់ពោលទៅថ្វីដល់ភិក្ខុដែលនៅក្នុងស្រុក ។

ចប់ គោលិស្សានិសូត្រ ទី ៩ ។

# ទសមំ កីដាគិរិសុត្តំ

[២២២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កាសីសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ អហំ ខោ ភិក្ខវេ អញ្ញត្រេវ រត្តិភោជនា[១] ភុញ្ជាមិ អញ្ញត្រ[២] ខោ បនាហំ ភិក្ខវេ រត្តិភោជនា ភុញ្ជមានោ អប្បាពាធតញ្ច សញ្ជានាមិ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ច ឯថ តុម្ហេបិ ភិក្ខវេ អញ្ញត្រេវ រត្តិភោជនា ភុញ្ជថ អញ្ញត្រ ខោ បន ភិក្ខវេ តុម្ហេបិ រត្តិភោជនា ភុញ្ជមានា អប្បាពាធតញ្ច សញ្ជានិស្សថ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ចាតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[២២៣] អថខោ ភគវា កាសីសុ អនុបុព្វេន ចារិកំ ចរមានោ យេន កីដាគិរិ នាម កាសីនំ និគមោ តទវសរិ ។ តត្រ សុទំ ភគវា

---

១ ម. សព្វត្ថ រត្តិភោជនន្តិ ទិស្សតិ ។ ២ ម. អញ្ញត្រេវ ។

# កីដាគិរិសូត្រ ទី ១០

[២២២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចទៅកាន់ចារិកក្នុងកាសីជនបទ មួយអន្លើដោយភិក្ខុសង្ឃច្រើនរូប ។ គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ ម្នាលភិក្ខុទាំងឡាយ កាលតថាគតបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមក ចូរបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ចេញ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ គង់ដឹងច្បាស់ នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយពុំខាន ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[២២៣] គ្រានោះឯង ព្រះមានព្រះភាគ ស្តេចទៅកាន់ចារិកតាមលំដាប់ក្នុងកាសីជនបទ បានស្តេចទៅដល់និគមឈ្មោះកីដាគិរី របស់កាសីជនបទ ។ មានសេចក្តីដំណាលថា ព្រះមានព្រះភាគ ទ្រង់

កីដាគិរិស្មឹ វិហរតិ កាសីនំ និគមេ ។ តេន ខោ បន សមយេន អស្សជិបុនព្វសុកា នាម ភិក្ខូ កីដាគិរិស្មឹ អាវាសិកា ហោន្តិ ។ អថខោ សម្ពហុលា ភិក្ខូ យេន អស្សជិបុនព្វសុកា ភិក្ខូ តេនុបសង្កមឹសុ ឧបសង្កមិត្វា អស្សជិបុនព្វសុកេ ភិក្ខូ ឯតទវោចុំ ភគវា ខោ អាវុសោ អញ្ញត្រេវ រត្តិភោជនា ភុញ្ជតិ ភិក្ខុសង្ឃោ ច អញ្ញត្រ ខោ បនាវុសោ រត្តិភោជនា ភុញ្ជមានា អប្បាពាធតញ្ច សញ្ជានន្តិ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ច ឯថ តុម្ហេបិ អាវុសោ អញ្ញត្រេវ រត្តិភោជនា ភុញ្ជថ អញ្ញត្រ ខោ បនាវុសោ តុម្ហេបិ រត្តិភោជនា ភុញ្ជ-មានា អប្បាពាធតញ្ច សញ្ជានិស្សថ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ចាតិ ។ ឯវំ វុត្តេ អស្សជិបុនព្វសុកា ភិក្ខូ តេ ភិក្ខូ ឯតទវោចុំ មយំ ខោ អាវុសោ សាយញ្ចេវ ភុញ្ជាម បាតោ ច ទិវា ច

គង់នៅក្នុងកីដាគិរីនិគម របស់កាសីជនបទនោះ ។ ជួនសម័យនោះឯង ភិក្ខុឈ្មោះអស្សជិនិងឈ្មោះបុនព្វសុកៈ អ្នកនៅក្នុងកីដាគិរិនិគម ។ គ្រានោះឯង មានភិក្ខុច្រើនរូប ចូលទៅរកអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះ នឹងអស្សជិភិក្ខុនិងបុនព្វ-សុកភិក្ខុថា ម្នាលលោកមានអាយុទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សោយ វៀរចាកការសោយភោជន ក្នុងវេលាយប់ ម្នាលលោកមានអាយុទាំងឡាយ ទាំងភិក្ខុសង្ឃក៏បរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ដែរ កាលពួកភិក្ខុបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ម្នាលលោកមានអាយុទាំងឡាយ លោកទាំងឡាយចូរបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ចុះ ម្នាលលោកមានអាយុទាំងឡាយ កាលបើលោកទាំងឡាយបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ គង់នឹងបានដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយពុំខាន ។ កាលបើភិក្ខុទាំងឡាយពោលយ៉ាងនេះហើយ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ក៏ឆ្លើយតបទៅនឹងភិក្ខុទាំងនោះ យ៉ាងនេះថា ម្នាលលោកមានអាយុទាំង-ឡាយ ពួកយើងតែងបរិភោគ ក្នុងវេលាល្ងាច វេលាព្រឹក និងវេលា

វិកាលេ តេ មយំ សាយញ្ហេវ កុញ្ចមាជា ចាតោ ច ធិវា ច វិកាលេ អប្បាពាជតញ្ច សញ្ជាជាម អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ជាសុវិហារញ្ច តេ មយំ កឹ សន្ធិដ្ឋិកំ ហិត្វា កាលិកំ អនុជាវិស្សាម សាយញ្ហេវ មយំ កុញ្ជិស្សាម ចាតោ ច ធិវា ច វិកាលេតិ ។

[២២៤] យតោ ខោ[១] តេ ភិក្ខូ ជាសក្ខឹសុ អស្សជិបុនព្វសុកេ ភិក្ខូ សញ្ញាបេតុំ អថ តេ ភិក្ខូ[២] យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ មយំ ភន្តេ យេន អស្សជិបុនព្វសុកា ភិក្ខូ តេនុបសង្កមិម្ហា[៣] ឧបសង្កមិត្វា អស្សជិបុនព្វសុកេ ភិក្ខូ ឯតទវោចុម្ហា[៤] ភគវា ខោ អាវុសោ

១ ម. យតោ ច ខោ ។ ២ ឱ. ម. តេ ភិក្ខូតិ ន ទិស្សតិ ។ ៣ ឱ. ម. តេនុបសង្កមិម្ហ ។ ៤ ឱ. ម. ឯតទវោចុម្ហ ។

ថ្ងៃដែលជាវេលាវិកាល ពួកយើងទាំងនោះ កាលបរិភោគ ក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាលហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ពួកយើងទាំងនោះ នឹងលះបង់អានិសង្ស ដែលត្រូវបានក្នុងបច្ចុប្បន្ន ហើយស្ទុះតាមរកអានិសង្ស ក្នុងអនាគតដូចម្តេចកើត ពួកយើងនឹងនៅតែបរិភោគក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃដែលជាវេលាវិកាលដដែល ។

[២២៤] ពួកភិក្ខុទាំងនោះ មិនអាចធ្វើអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុឲ្យយល់បានក្នុងកាលណាហើយ ទើបភិក្ខុទាំងនោះចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយនៅក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកយើងខ្ញុំព្រះអង្គដែលមានក្នុងទីនេះ បានចូលទៅរកអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុថា ម្នាលលោកមានអាយុទាំងឡាយ ព្រះមានព្រះភាគ

អញ្ញត្រេវ រត្តិភោជនា ភុញ្ជតិ ភិក្ខុសង្ឃោ ច អញ្ញត្រ ខោ បនាវុសោ រត្តិភោជនា ភុញ្ជមានា អប្បាពាធតញ្ច សញ្ជានន្តិ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ច ឯថ តុម្ហេបិ អាវុសោ អញ្ញត្រេវ រត្តិភោជនា ភុញ្ជថ អញ្ញត្រ ខោ បនាវុសោ តុម្ហេបិ រត្តិភោជនា ភុញ្ជមានា អប្បាពាធតញ្ច សញ្ជានិស្សថ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ចាតិ ឯវំ វុត្តេ ភន្តេ[1] អស្សជិបុនព្វសុកា ភិក្ខូ អម្ហេ ឯតទវោចុំ មយំ ខោ អាវុសោ សាយញ្ចេវ ភុញ្ជាម បាតោ ច ទិវា ច វិកាលេ តេ មយំ សាយញ្ចេវ ភុញ្ជមានា បាតោ ច ទិវា ច វិកាលេ អប្បាពាធតញ្ច សញ្ជានាម អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ច

---

១ ម. ភន្តេតិ ន ទិស្សតិ ។

ទ្រង់សោយ វៀរចាកការសោយភោជនក្នុងវេលាយប់ ទាំងភិក្ខុសង្ឃ ក៏បរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ដែរ ម្នាលអាវុសោទាំងឡាយ កាលពួកភិក្ខុបរិភោគ វៀរចាកការបរិភោគភោជន ក្នុងវេលាយប់ហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ម្នាលលោកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរមក ចូរបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ចេញ ម្នាលលោកមានអាយុទាំងឡាយ កាលបើលោកទាំង-ឡាយបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ គង់នឹងបានដឹងច្បាស់ នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ បពិត្រព្រះអង្គដ៏ចម្រើន កាលពួកខ្ញុំព្រះអង្គពោលយ៉ាងនេះហើយ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ក៏ឆ្លើយតបមកនឹងពួកខ្ញុំព្រះអង្គ យ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ពួកយើងតែងបរិភោគក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាល ពួកយើងនោះ កាលបរិភោគភោជនក្នុងវេលាល្ងាច វេលាព្រឹកនិងវេលាថ្ងៃដែលជាវេលាវិកាលហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ

តេ មយំ កឹ សន្ទិដ្ឋិកំ ហិត្វា កាលិកំ អនុធាវិស្សាម សាយញ្ចេវ មយំ ភុញ្ជិស្សាម បាតោ ច ទិវា ច វិកាលេតិ យតោ ខោ មយំ ភន្តេ នាសក្ខិម្ហា អស្សជិបុនព្វសុកេ ភិក្ខូ សញ្ញាបេតុំ អថ មយំ ឯតមត្ថំ ភគវតោ អារោចេមាតិ ។ អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន អស្សជិបុនព្វសុកេ ភិក្ខូ អាមន្តេហិ សត្ថាយស្មន្តេ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេន អស្សជិបុនព្វសុកា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា អស្សជិបុនព្វសុកេ ភិក្ខូ ឯតទវោច សត្ថាយស្មន្តេ អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ អស្សជិបុនព្វសុកា ភិក្ខូ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯក-មន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ អស្សជិបុ-នព្វសុកេ ភិក្ខូ ភគវា ឯតទវោច សច្ចំ កិរ ភិក្ខវេ

ពួកយើងទាំងនោះ នឹងលះបង់អានិសង្សដែលត្រូវបានក្នុងបច្ចុប្បន្ន ហើយស្ទុះតាមរកអានិសង្ស ដែលត្រូវបានក្នុងអនាគតទៅវិញដូចម្តេចកើត ពួកយើងនឹងនៅតែបរិភោគក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាលដដែល បពិត្រព្រះអង្គដ៏ចម្រើន កាលណាពួកខ្ញុំព្រះអង្គ មិនអាចធ្វើអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ឲ្យយល់បានហើយ ទើបពួកខ្ញុំព្រះអង្គមកសូមក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ១ រូបមកប្រាប់ថា ម្នាលភិក្ខុ អ្នកចូរមកចូរទៅហៅអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ តាមពាក្យតថាគតថា ព្រះសាស្តាត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ភិក្ខុនោះទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ យ៉ាងនេះថា ព្រះសាស្តាទ្រង់ត្រាស់ហៅលោកមានអាយុទាំងឡាយ ។ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ទទួលពាក្យភិក្ខុនោះថា ករុណាលោកមានអាយុ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បានឮថា

សម្ពហុលា ភិក្ខូ តុម្ហេ ឧបសង្កមិត្វា ឯតទវោចុំ ភគវា ខោ អាវុសោ អញ្ញត្រេវ រត្តិភោជនា ភុញ្ជតិ ភិក្ខុសង្ឃោ ច អញ្ញត្រ ខោ បនាវុសោ រត្តិភោជនា ភុញ្ជមានា អប្បាពាធតញ្ច សញ្ជានន្តិ អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ច ឯថ តុម្ហេបិ អាវុសោ អញ្ញត្រេវ រត្តិភោជនា ភុញ្ជមានា អប្បាពាធតញ្ច សញ្ជានិស្សថ អប្បាតង្ក-តញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ចាតិ ឯវំ វុត្តេ កិរ[១] ភិក្ខវេ តុម្ហេ តេ ភិក្ខូ ឯវំ អវចុត្ថ មយំ ខោ បនាវុសោ សាយញ្ចេវ ភុញ្ជាម បាតោ ច ទិវា ច វិកាលេ តេ មយំ សាយញ្ចេវ ភុញ្ជមានា បាតោ ច ទិវា ច វិកាលេ អប្បាពាធតញ្ច សញ្ជានាម អប្បាតង្កតញ្ច លហុដ្ឋានញ្ច ពលញ្ច ផាសុវិហារញ្ច

---

១ ម. កឹ នុ ។

ពួកភិក្ខុច្រើនរូបចូលទៅរកអ្នកទាំងឡាយ ហើយបាននិយាយថា ម្នាលលោកមានអាយុទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សោយ វៀរចាកការសោយភោជនក្នុងវេលាយប់ ទាំងភិក្ខុសង្ឃក៏បរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ដែរ ម្នាលលោកមានអាយុទាំងឡាយ កាលពួកភិក្ខុបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ ក៏ដឹងច្បាស់ នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ម្នាលលោកមានអាយុទាំងឡាយ លោកទាំងឡាយចូរមក ចូរបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ចេញ ម្នាលលោកមានអាយុទាំងឡាយ កាលបើលោកទាំងឡាយបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ គង់នឹងបានដឹងច្បាស់ នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ម្នាលភិក្ខុទាំងឡាយ បានឮថា កាលដែលពួកភិក្ខុពោលយ៉ាងនេះហើយ អ្នកទាំងឡាយបានឆ្លើយតបទៅនឹងពួកភិក្ខុទាំងនោះ យ៉ាងនេះវិញថា ម្នាលលោកមានអាយុទាំងឡាយ ពួកយើងតែងបរិភោគ ក្នុងវេលាល្ងាចវេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាល យើងទាំងនោះ កាលបរិភោគក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាលហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ

តេ មយំ កឹ សន្ទិដ្ឋិកំ ហិត្វា កាលិកំ អនុធាវិស្សាម សាយញ្ចេវ មយំ ភុញ្ជិស្សាម បាតោ ច ទិវា ច វិកាលេតិ ។ ឯវំ ភន្តេ ។

[២២៩] កិន្នុ មេ តុម្ហេ ភិក្ខវេ ឯវំ ធម្មំ ទេសិតំ អាជានាថ យំ កិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្ស អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ។ នោ ហេតំ ភន្តេ ។ ននុ មេ តុម្ហេ ភិក្ខវេ ឯវំ ធម្មំ ទេសិតំ អាជានាថ ឥធេកច្ចស្ស ឯវរូបំ សុខំ វេទនំ វេទិយតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឥធ បនេកច្ចស្ស ឯវរូបំ សុខំ វេទនំ វេទិយតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឥធេកច្ចស្ស ឯវរូបំ ទុក្ខំ វេទនំ វេទិយតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ

យើងទាំងនោះ នឹងលះបង់អានិសង្ស ដែលត្រូវបានក្នុងបច្ចុប្បន្ន ហើយស្ទុះតាមរកអានិសង្ស ដែលត្រូវបានក្នុងអនាគតទៅវិញដូចម្ដេចកើត ពួកយើងនឹងនៅតែបរិភោគក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាលដដែល យ៉ាងនេះមែនឬ ។ ព្រះករុណាព្រះអង្គ មែន ។

[២២៥] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ធម៌ ដែលតថាគតសំដែងហើយ យ៉ាងនេះថា បុរសបុគ្គលនេះ រមែងទទួលវេទនាណាមួយ ជាសុខឬជាទុក្ខ ឬមិនទុក្ខមិនសុខ អកុសលធម៌ទាំង-ឡាយរបស់គេនោះ រមែងសាបសូន្យទៅ កុសលធម៌ទាំងឡាយរមែងចម្រើនឡើង ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំមិនយល់ទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រៃងយល់ធម៌ ដែលតថាគតសំដែងហើយយ៉ាងនេះថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលសុខវេទនាបែបនេះហើយ អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយសាបសូន្យទៅ មួយទៀត បុរសបុគ្គលពួកមួយក្នុងសាសនានេះ កាលទទួលសុខវេទនាបែបនេះហើយ អកុសលធម៌ទាំង-ឡាយរមែងសាបសូន្យទៅ កុសលធម៌ទាំងឡាយរមែងចម្រើនឡើង បុរសបុគ្គលពួកមួយក្នុងសាសនានេះ កាលទទួលទុក្ខវេទនាបែបនេះ អកុ-សលធម៌ទាំងឡាយតែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាប-

ឥធ បនេកច្ចស្ស ឯវរូបំ ទុក្ខំ វេទនំ វេទិយតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឥធេកច្ចស្ស ឯវរូបំ អទុក្ខមសុខំ វេទនំ វេទិយតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឥធ បនេកច្ចស្ស ឯវរូបំ អទុក្ខមសុខំ វេទនំ វេទិយតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ ឯវំ ភន្តេ ។

[២២៦] សាធុ ភិក្ខវេ មយា ចេតំ ភិក្ខវេ អញ្ញាតំ អភវិស្ស អទិដ្ឋំ អវិទិតំ អសច្ឆិកាតំ អផុសិតំ[១] បញ្ញាយ ឥធេកច្ចស្ស ឯវរូបំ សុខំ វេទនំ វេទិយតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវាហំ អជានន្តោ ឯវរូបំ សុខំ វេទនំ បជហាថាតិ វទេយ្យំ អបិ នុ[២] មេ ឯតំ ភិក្ខវេ ឯវរូបំ អភវិស្សាតិ ។ នោ ហេតំ ភន្តេ ។ យស្មា ច ខោ ឯតំ ភិក្ខវេ មយា ញាតំ

១ ឱ. ម. អផស្សិតំ ។ ២ ម. អបិ នុ ខោ ។

សូន្យទៅ មួយទៀត បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលទុក្ខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចម្រើនឡើង បុរសបុគ្គលពួកមួយក្នុងសាសនានេះ កាលទទួលអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយតែងចម្រើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ មួយវិញទៀត បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចម្រើនឡើង ដែរឬ ។ ព្រះករុណាព្រះអង្គ យើងខ្ញុំយល់ ។

[២២៦] ម្នាលភិក្ខុទាំងឡាយ ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ មួយទៀត ហេតុនុ៎ះ តថាគតមិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កាលតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំងឡាយចូរលះបង់ នូវសុខវេទនាបែបនេះចេញ ម្នាលភិក្ខុទាំងឡាយ ហេតុបែបនុ៎ះដែលមានដល់តថាគតឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនដែលមានទេ ។ ម្នាលភិក្ខុទាំងឡាយ តែហេតុនុ៎ះតថាគតធ្លាប់ដឹង

ទិដ្ឋំ វិទិតំ សច្ឆិកតំ ផុសិតំ បញ្ញាយ ឥធេកច្ចស្ស ឯវរូបំ សុខំ វេទនំ វេទិយតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ តស្មាហំ ឯវរូបំ សុខំ វេទនំ បជហថាតិ វទាមិ ។ មយា ចេតំ ភិក្ខវេ អញ្ញាតំ អភវិស្ស អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ បញ្ញាយ ឥធេកច្ចស្ស ឯវរូបំ សុខំ វេទនំ វេទិយតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវមហំ[១] អជានន្តោ ឯវរូបំ សុខំ វេទនំ ឧបសម្បជ្ជ វិហរថាតិ វទេយ្យំ អបិ នុ មេ ឯតំ ភិក្ខវេ បតិរូបំ អភវិស្សាតិ ។ នោ ហេតំ ភន្តេ ។ យស្មា ច ខោ ឯតំ ភិក្ខវេ មយា ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ ផុសិតំ បញ្ញាយ ឥធេកច្ចស្ស ឯវរូបំ សុខំ វេទនំ វេទិយតោ

---

១ ម. ឯវាហំ ។

ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយតែងចម្រើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា អ្នកទាំងឡាយចូរលះបង់នូវសុខវេទនាបែបនេះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតហេតុនុ៎ះ តថាគតមិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំង-ឡាយតែងចម្រើនឡើង កាលតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថាអ្នកទាំងឡាយចូរសម្រេចនៅ ដោយសុខវេទនាបែបនេះចុះ ម្នាលភិក្ខុទាំង-ឡាយ ហេតុនុ៎ះសមគួរដល់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនសមគួរទេ ។ ម្នាលភិក្ខុទាំងឡាយ តែហេតុនុ៎ះតថាគត ធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយក្នុងសាសនានេះ កាលទទួលនូវសុខវេទនាបែបនេះ

អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ តស្មាហំ ឯវរូបំ សុខំ វេទនំ ឧបសម្បជ្ជ វិហរថាតិ វទាមិ ។

[២២៧] មយា ចេតំ ភិក្ខវេ អញ្ញាតំ អភវិស្ស អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ បញ្ញាយ ឥធេកច្ចស្ស ឯវរូបំ ទុក្ខំ វេទនំ វេទិយតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវាហំ អជានន្តោ ឯវរូបំ ទុក្ខំ វេទនំ បជហថាតិ វទេយ្យំ អបិ នុ មេ ឯតំ ភិក្ខវេ បតិរូបំ អភវិស្សាតិ ។ នោ ហេតំ ភន្តេ ។ យស្មា ច ខោ ឯតំ ភិក្ខវេ មយា ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ ផុសិតំ បញ្ញាយ ឥធេកច្ចស្ស ឯវរូបំ ទុក្ខំ វេទនំ វេទិយតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ តស្មាហំ ឯវរូបំ ទុក្ខំ វេទនំ បជហថាតិ វទាមិ ។ មយា ចេតំ ភិក្ខវេ

អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ព្រោះហេតុណា ព្រោះហើយនោះ ទើបតថាគតពោលថា អ្នកទាំងឡាយចូរសម្រេចនៅ ដោយសុខវេទនាបែបនេះចុះ ។

[២២៧] ម្នាលភិក្ខុទាំងឡាយ មួយទៀតហេតុនុ៎ះ តថាគត មិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលទុក្ខវេទនាបែបនេះ អកុសលធម៌តែងចម្រើនឡើង កុសលធម៌ តែងសាបសូន្យទៅ កាលបើតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំង-ឡាយចូរលះទុក្ខវេទនាបែបនេះចេញ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សមគួរដល់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនសមគួរទេ ។ ម្នាលភិក្ខុទាំងឡាយ តែហេតុនុ៎ះ តថាគត ធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលទុក្ខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ព្រោះហេតុណា ព្រោះហេតុនោះទើបតថាគតពោលថា អ្នកទាំងឡាយចូរលះបង់ទុក្ខ-វេទនាបែបនេះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតហេតុនុ៎ះ តថាគត

ភិក្ខុវគ្គស្ស កីដាគិរិសុត្តេ ទុក្ខវេទនាកថា

អញ្ញាតំ អភវិស្ស អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ បញ្ញាយ ឥដេកច្ចស្ស ឯវរូបំ ទុក្ខំ វេទនំ វេទិយតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវមហំ អជានន្តោ ឯវរូបំ ទុក្ខំ វេទនំ ឧបសម្បជ្ជ វិហរថាតិ វទេយ្យំ អបិ នុ មេ ឯតំ ភិក្ខវេ បដិរូបំ អភវិស្សាតិ ។ នោ ហេតំ ភន្តេ ។ យស្មា ច ខោ ឯតំ ភិក្ខវេ មយា ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ ផុសិតំ បញ្ញាយ ឥដេកច្ចស្ស ឯវរូបំ ទុក្ខំ វេទនំ វេទិយតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ តស្មាហំ ឯវរូបំ ទុក្ខំ វេទនំ ឧបសម្បជ្ជ វិហរថាតិ វទាមិ ។

មិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវទុក្ខវេទនាបែបនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង កាលតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំងឡាយចូរសម្រេចនៅ ដោយទុក្ខវេទនាបែបនេះចុះ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សមគួរដល់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនសមគួរទេ ។ ម្នាលភិក្ខុទាំងឡាយ តែហេតុនុ៎ះ តថាគតធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយក្នុងសាសនានេះ កាលទទួលនូវទុក្ខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ព្រោះហេតុណា ព្រោះហេតុនោះ បានជាតថាគតពោលថា អ្នកទាំងឡាយចូរសម្រេចនៅ ដោយទុក្ខវេទនាបែបនេះចុះ ។

[២២៨] មយា ចេតំ ភិក្ខវេ អញ្ញាតំ អភវិស្ស អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ បញ្ញាយ ឥធេកច្ចស្ស ឯវរូបំ អទុក្ខមសុខំ វេទនំ វេទិយតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវមហំ អជានន្តោ ឯវរូបំ អទុក្ខមសុខំ វេទនំ បជហាថាតិ វទេយ្យំ អបិ នុ មេ ឯតំ ភិក្ខវេ បដិរូបំ អភវិស្សាតិ ។ នោ ហេតំ ភន្តេ ។ យស្មា ច ខោ ឯតំ ភិក្ខវេ មយា ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ ផុសិតំ បញ្ញាយ ឥធេកច្ចស្ស ឯវរូបំ អទុក្ខមសុខំ វេទនំ វេទិយតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ តស្មាហំ ឯវរូបំ អទុក្ខមសុខំ វេទនំ បជហាថាតិ វទាមិ ។ មយា ចេតំ ភិក្ខវេ អញ្ញាតំ អភវិស្ស អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ បញ្ញាយ ឥធេកច្ចស្ស ឯវរូបំ អទុក្ខមសុខំ វេទនំ វេទិយតោ អកុសលា ធម្មា

[២២៨] ម្នាលភិក្ខុទាំងឡាយ មួយទៀត ហេតុនុ៎ះតថាគតមិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កាលតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំងឡាយចូរលះបង់ នូវអទុក្ខមសុខវេទនាបែបនេះចេញ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះសមគួរដល់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនសមគួរទេ ។ ម្នាលភិក្ខុទាំងឡាយ តែហេតុនុ៎ះតថាគត ធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួល នូវអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយតែងចម្រើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យទៅ ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា អ្នកទាំងឡាយចូរលះបង់នូវអទុក្ខមសុខវេទនាបែបនេះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ហេតុនុ៎ះតថាគត មិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌

បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវមហំ អជានន្តោ ឯវរូបំ អទុក្ខមសុខំ វេទនំ ឧបសម្បជ្ជ វិហរេយ្យាតិ វទេយ្យំ អបិ នុ មេ ឯតំ ភិក្ខវេ បដិរូបំ អភវិស្សាតិ ។ នោ ហេតំ ភន្តេ ។ យស្មា ច ខោ ឯតំ ភិក្ខវេ មយា ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ ផុសិតំ បញ្ញាយ ឥធេកច្ចស្ស ឯវរូបំ អទុក្ខមសុខំ វេទនំ វេទិយតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ តស្មាហំ ឯវរូបំ អទុក្ខមសុខំ វេទនំ ឧបសម្បជ្ជ វិហរថាតិ វទាមិ ។

[២២៩] នាហំ ភិក្ខវេ សព្វេសំយេវ ភិក្ខូនំ អប្បមាទេន ករណីយន្តិ វទាមិ ន បនាហំ ភិក្ខវេ សព្វេសំយេវ ភិក្ខូនំ ន អប្បមាទេន ករណីយន្តិ វទាមិ ។ យេ តេ ភិក្ខវេ ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ

ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង កាលតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំងឡាយចូរសម្រេចនៅ ដោយអទុក្ខមសុខវេទនាបែបនេះចុះ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សមគួរដល់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនសមគួរទេ ។ ម្នាលភិក្ខុទាំងឡាយ តែហេតុនុ៎ះតថាគត ធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវអទុក្ខម-សុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា អ្នកទាំងឡាយចូរសម្រេចនៅ ដោយអទុក្ខមសុខវេទនាបែបនេះចុះ ។

[២២៩] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងពោលថា ភិក្ខុទាំងអស់ត្រូវធ្វើកិច្ច ដោយសេចក្តីមិនប្រមាទ ដូច្នេះក៏ទេ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត តថាគតនឹងបានពោលថា ភិក្ខុទាំងអស់មិនត្រូវធ្វើកិច្ចដោយសេចក្តីមិនប្រមាទ ដូច្នេះក៏ទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំង-ឡាយណាជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌នៅរួចហើយ មាន

កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណ-
ភវសញ្ញោជនា សម្មទញ្ញា វិមុត្តា តថារូបានាហំ
ភិក្ខវេ ភិក្ខូនំ ន អប្បមាទេន ករណីយន្តិ វទាមិ តំ
កិស្ស ហេតុ កតន្តេសំ អប្បមាទេន អភព្វា តេ
បមជ្ជិតុំ ។ យេ ច ខោ តេ ភិក្ខវេ ភិក្ខូ សេក្ខា
អប្បត្តមានសា អនុត្តរំ យោគក្ខេមំ បត្ថយមានា
វិហរន្តិ តថារូបានាហំ ភិក្ខវេ ភិក្ខូនំ អប្បមាទេន
ករណីយន្តិ វទាមិ តំ កិស្ស ហេតុ អប្បេវនាម
ឥមេ អាយស្មន្តោ អនុលោមិកានិ សេនា-
សនានិ បដិសេវមានា កល្យាណមិត្តេ ភជមានា
ឥន្ទ្រិយានិ សមន្នានយមានា យស្សត្ថាយ កុលបុត្តា

កិច្ចដែលគួរធ្វើបានធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានសំយោជនៈក្នុងភពអស់រលីងហើយ ជាអ្នកផុតស្រឡះដោយប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ពួកភិក្ខុមានសភាពដូច្នោះ មិនបាច់ធ្វើកិច្ច ដោយសេចក្តីមិនប្រមាទឡើយ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ភិក្ខុទាំងឡាយនោះ បានធ្វើកិច្ចរួចហើយ ដោយសេចក្តីមិនប្រមាទ ពួកភិក្ខុជាអរហន្តខីណាស្រពនោះ មិនគួរប្រមាទទៀតឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណាជាសេក្ខបុគ្គល មិនទាន់បានដល់អរហត្តផល កំពុងប្រាថ្នានូវធម៌ដ៏ប្រសើរជាទីក្សេមចាកយោគៈ ម្នាលភិក្ខុទាំងឡាយ តថា-គតពោលថា ពួកភិក្ខុមានសភាពដូច្នោះ ទើបត្រូវធ្វើកិច្ចដោយសេចក្តីមិនប្រមាទ ដំណើរនោះព្រោះហេតុអ្វី ព្រោះថា ត្រាតែលោកមានអាយុទាំងនេះ សេពសេនាសនៈដ៏សមគួរ សេពគប់នូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ កុលបុត្តទាំងឡាយ ចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់លោកុត្តរធម៌ណា ក៏បាន

សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យុន្តិ ។ ឥមំ ខោ អហំ ភិក្ខវេ ឥមេសំ ភិក្ខូនំ អប្បមាទផលំ សម្បស្សមានោ អប្បមាទេន ករណីយន្តិ វទាមិ ។

[២៣០] សត្តិមេ ភិក្ខវេ បុគ្គលា សន្តោ សំ-វិជ្ជមានា លោកស្មឹ កតមេ សត្ត ឧភតោភាគវិមុត្តោ បញ្ញាវិមុត្តោ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ធម្មានុសារី សទ្ធានុសារី ។

[២៣១] កតមោ ច ភិក្ខវេ បុគ្គលោ ឧភតោភាគវិមុត្តោ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ កាយេន ផុសិត្វា វិហរតិ បញ្ញាយ ចស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ ឧភតោភាគវិមុត្តោ ។ ឥមស្ស ខោ អហំ ភិក្ខវេ

ធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញ នូវផលនៃសេចក្តីមិនប្រមាទនេះឯង របស់ភិក្ខុទាំងឡាយនេះហើយ ទើបពោលថា ពួកភិក្ខុទាំងនោះ ត្រូវតែធ្វើកិច្ចដោយសេចក្តីមិនប្រមាទ ។

[២៣០] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ តែងមានគ្រប់គ្រាន់ក្នុងលោក បុគ្គល ៧ ពួកដូចម្តេចខ្លះ គឺឧភតោភាគវិមុត្តបុគ្គល ១ បញ្ញាវិមុត្តបុគ្គល ១ កាយសក្ខីបុគ្គល ១ ទិដ្ឋិប្បត្តបុគ្គល ១ សទ្ធាវិមុត្តបុគ្គល ១ ធម្មានុសារីបុគ្គល ១ សទ្ធានុសារីបុគ្គល ១ ។

[២៣១] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះឧភតោភាគវិមុត្តៈនោះ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងសាសនានេះ ពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូបដោយកាយផង បានឃើញច្បាស់ (នូវអរិយសច្ចធម៌) ដោយប្រាជ្ញាផង អាសវៈទាំងឡាយរបស់បុគ្គលនោះអស់ទៅផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា ឧភតោភាគវិមុត្តបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគត

ភិក្ខុនោ ន អប្បមាទេន ករណីយន្តិ វទាមិ តំ កិស្ស ហេតុ កតន្តស្ស អប្បមាទេន អភព្វោ សោ បមជ្ជិតុំ ។

[២៣២] កតមោ ច ភិក្ខវេ បុគ្គលោ បញ្ញាវិមុត្តោ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ ន កាយេន ផុសិត្វា វិហរតិ បញ្ញាយ ចស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ បញ្ញាវិមុត្តោ ។ ឥមស្សបិ ខោ អហំ ភិក្ខវេ ភិក្ខុនោ ន អប្បមាទេន[១] ករណីយន្តិ វទាមិ តំ កិស្ស ហេតុ កតន្តស្ស អប្បមាទេន អភព្វោ សោ បមជ្ជិតុំ ។

[២៣៣] កតមោ ច ភិក្ខវេ បុគ្គលោ កាយសក្ខី ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ កាយេន ផុសិត្វា វិហរតិ បញ្ញាយ ចស្ស ទិស្វា ឯកច្ចេ អាសវា

---

១ ម. នាហំ ភិក្ខវេ ភិក្ខុនោ អប្បមាទេន ។

ពោលថា ភិក្ខុនេះឯងមិនបាច់ធ្វើកិច្ច ដោយសេចក្តីមិនប្រមាទឡើយ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ភិក្ខុនោះបានធ្វើកិច្ចនោះរួចហើយ ដោយសេចក្តីមិនប្រមាទ ភិក្ខុនោះមិនគួរប្រមាទទៀតឡើយ ។

[២៣២] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះបញ្ញាវិមុត្តៈនោះ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ មិនបានពាល់ត្រូវ នូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូប ដោយកាយទេ តែបានឃើញច្បាស់ (នូវអរិយសច្ចធម៌) ដោយប្រាជ្ញាផង អាសវៈទាំងឡាយរបស់បុគ្គលនោះក៏អស់ទៅផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា បញ្ញាវិមុត្តបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯងមិនបាច់ធ្វើកិច្ច ដោយសេចក្តីមិនប្រមាទទៀតឡើយ ដំណើរនោះព្រោះហេតុអ្វី ព្រោះថា ភិក្ខុនោះបានធ្វើកិច្ចនោះ ដោយសេចក្តីមិនប្រមាទរួចហើយ ភិក្ខុនោះមិនគួរប្រមាទទៀតទេ ។

[២៣៣] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះកាយសក្ខីនោះតើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ បានពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូបដោយកាយផង បានឃើញច្បាស់ (នូវអរិយសច្ចធម៌) ដោយប្រាជ្ញាផង អាសវៈ

បរិក្ខីណា ហោន្តិ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ កាយសក្ខី ។ ឥមស្ស ខោ អហំ ភិក្ខវេ ភិក្ខុនោ អប្បមាទេន ករណីយន្តិ វទាមិ តំ កិស្ស ហេតុ អប្បេវនាម អយមាយស្មា អនុលោមិកានិ សេនាសនានិ បដិសេវមានោ កល្យាណមិត្តេ ភជមានោ ឥន្ទ្រិយានិ សមន្នានយមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ ឥមំ ខោ អហំ ភិក្ខវេ ឥមស្ស ភិក្ខុនោ អប្បមាទផលំ សម្បស្សមានោ អប្បមាទេន ករណីយន្តិ វទាមិ ។

[២៣៤] កតមោ ច ភិក្ខវេ បុគ្គលោ ទិដ្ឋិប្បត្តោ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ ន[1] កាយេន ផុសិត្វា វិហរតិ បញ្ញាយ ចស្ស ទិស្វា

១ ម. នសទ្ទោ ន ហោតិ ។

ទាំងឡាយពួកខ្លះ របស់បុគ្គលនោះក៏អស់ទៅផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា កាយសក្ខីបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯងទើបត្រូវធ្វើកិច្ច ដោយសេចក្ដីមិនប្រមាទទៀត ដំណើរនោះព្រោះហេតុអ្វី ព្រោះថា ត្រាតែលោកមានអាយុនេះ សេពនូវសេនាសនៈដ៏សមគួរ សេពគប់នូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ កុលបុត្តទាំងឡាយចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់លោកុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ នូវលោកុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញផល នៃសេចក្ដីមិនប្រមាទនេះឯងរបស់ភិក្ខុនេះច្បាស់ហើយ ទើបបានពោលថា ភិក្ខុនោះ ត្រូវតែធ្វើកិច្ចដោយសេចក្ដីមិនប្រមាទទៀត ។

[២៣៤] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះទិដ្ឋិប្បត្តៈ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងសាសនានេះ មិនបានពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូបដោយកាយទេ គ្រាន់តែបានឃើញ (នូវអរិយសច្ចធម៌) ដោយប្រាជ្ញាប៉ុណ្ណោះ

ឯកច្ចេ អាសវា បរិក្ខីណា ហោន្តិ តថាគតប្បវេទិតា ចស្ស ធម្មា បញ្ញាយ វោទិដ្ឋា ហោន្តិ វោចរិតា អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ ទិដ្ឋិប្បត្តោ ។ ឥមស្សាបិ ខោ អហំ ភិក្ខវេ ភិក្ខុនោ អប្បមាទេន ករណីយន្តិ វទាមិ តំ កិស្ស ហេតុ អប្បេវនាម អយមាយស្មា អនុលោ-មិកានិ សេនាសនានិ បដិសេវមានោ កល្យាណមិត្តេ ភជមានោ ឥន្ទ្រិយានិ សមន្នានយមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ ឥមំ ខោ អហំ ភិក្ខវេ ឥមស្ស ភិក្ខុនោ អប្បមាទផលំ សម្បស្សមានោ អប្បមាទេន ករណីយន្តិ វទាមិ ។

[២៣៤] កតមោ ច ភិក្ខវេ បុគ្គលោ សទ្ធាវិមុត្តោ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ ន កាយេន ផុសិត្វា វិហរតិ បញ្ញាយ ចស្ស ទិស្វា

ហើយ អាសវៈទាំងឡាយពួកខ្លះ របស់បុគ្គលនោះក៏អស់ទៅ ទាំងពួកធម៌ ដែលតថាគតសំដែងហើយ ក៏បុគ្គលនោះ បានយល់ច្បាស់ដោយប្រាជ្ញា បានប្រព្រឹត្តត្រឹមត្រូវ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា ទិដ្ឋិប្បត្ត-បុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯងត្រូវតែធ្វើកិច្ចដោយសេចក្ដីមិនប្រមាទទៀត ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ត្រាតែលោកមានអាយុនេះ សេពនូវសេនាសនៈដ៏សមគួរ គប់នូវកល្យាណមិត្ត ទូន្មាននូវឥន្រ្ទិយទាំងឡាយ កុលបុត្តទាំងឡាយចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់លោកុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ នូវលោកុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញនូវផលនៃសេចក្ដីមិនប្រមាទនេះឯង របស់ភិក្ខុនេះច្បាស់ហើយ បានជាពោលថា ភិក្ខុនោះត្រូវតែធ្វើកិច្ច ដោយសេចក្ដីមិនប្រមាទទៀត ។

[២៣៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលឈ្មោះសទ្ធាវិមុត្តៈ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ មិនបានពាល់ត្រូវ នូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូបដោយកាយទេ គ្រាន់តែឃើញ (នូវអរិយសច្ចធម៌) ដោយប្រាជ្ញាប៉ុណ្ណោះ

ឯកច្ចេ អាសវា បរិក្ខីណា ហោន្តិ តថាគតេ ចស្ស សទ្ធា និវិដ្ឋា ហោតិ មូលជាតា បតិដ្ឋិតា អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ សទ្ធាវិមុត្តោ ។ ឥមស្សបិ ខោ អហំ ភិក្ខវេ ភិក្ខុនោ អប្បមាទេន ករណីយន្តិ វទាមិ តំ កិស្ស ហេតុ អប្បេវនាម អយមា- យស្មា អនុលោមិកានិ សេនាសនានិ បដិសេវមានោ កល្យាណមិត្តេ ភជមានោ ឥន្ទ្រិយានិ សមន្នានយមា- នោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ ឥមំ ខោ អហំ ភិក្ខវេ ឥមស្ស ភិក្ខុនោ អប្បមាទផលំ សម្បស្សមានោ អប្បមាទេន ករណីយន្តិ វទាមិ ។

[២៣៦] កតមោ ច ភិក្ខវេ បុគ្គលោ ធម្មានុសារី ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ ន កាយេន ផុសិត្វា វិហរតិ បញ្ញាយ ចស្ស និស្សា

ហើយ អាសវៈទាំងឡាយពួកខ្លះ របស់បុគ្គលនោះក៏អស់ទៅ ទាំងសទ្ធា ក៏បុគ្គលនោះតាំងមាំ មានឫសគល់ប្រតិស្ឋានខ្ជាប់ខ្ជួន ក្នុងព្រះតថាគត ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា សទ្ធាវិមុត្ត ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯងត្រូវតែធ្វើកិច្ច ដោយសេចក្តីមិនប្រមាទទៀត ដំណើរនោះព្រោះហេតុអ្វី ព្រោះថា ត្រាតែលោកមានអាយុនេះ សេព នូវសេនាសនៈដ៏សមគួរ គប់នូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ កុលបុត្តទាំងឡាយ ដែលចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ ដល់លោកុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ នូវលោកុត្តរធម៌នោះដែល ជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយ សម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពិចារណាឃើញនូវផល នៃសេចក្តីមិនប្រមាទនេះឯង របស់ភិក្ខុនេះ ច្បាស់ហើយ បានជាពោលថា ភិក្ខុនោះត្រូវធ្វើកិច្ច ដោយសេចក្តីមិន ប្រមាទទៀត ។

[២៣៦] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះថាធម្មានុសារី តើ ដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ មិនបាន ពាល់ត្រូវ នូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូប ដោយកាយទេ គ្រាន់តែឃើញ (នូវអរិយសច្ចធម៌) ដោយប្រាជ្ញាប៉ុណ្ណោះ

ឯកច្ចេ អាសវា បរិក្ខីណា ហោន្តិ តថាគតប្បវេទិតា ចស្ស ធម្មា បញ្ញាយ មត្តសោ និជ្ឈានំ ខមន្តិ អបិចស្ស ឥមេ ធម្មា ហោន្តិ សេយ្យថីទំ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ ធម្មានុសារី ។ ឥមស្សបិ ខោ អហំ ភិក្ខវេ ភិក្ខុនោ អប្បមាទេន ករណីយន្តិ វទាមិ តំ កិស្ស ហេតុ អប្បេវនាម អយមាយស្មា អនុលោមិកានិ សេនាសនានិ បដិសេវមានោ កល្យាណមិត្តេ ភជមានោ ឥន្ទ្រិយានិ សមន្នានយមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ ឥមំ ខោ អហំ ភិក្ខវេ ឥមស្ស ភិក្ខុនោ អប្បមាទផលំ សម្បស្សមានោ អប្បមាទេន ករណីយន្តិ វទាមិ ។

ហើយ អាសវៈទាំងឡាយពួកខ្លះ នៃបុគ្គលនោះក៏អស់ទៅ ទាំងពួកធម៌ដែលព្រះតថាគតសំដែងហើយ ក៏គួរដល់កិរិយាសំឡឹងមើលដោយប្រាជ្ញារបស់បុគ្គលនោះ ព្រមទាំងបុគ្គលនោះ មានធម៌នេះគឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា ធម្មានុសារី ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯងត្រូវតែធ្វើកិច្ច ដោយសេចក្ដីមិនប្រមាទទៀត ដំណើរនោះព្រោះហេតុអ្វី ព្រោះថា ត្រាតែលោកមានអាយុនេះ សេពនូវសេនាសនៈដ៏សមគួរ គប់នូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ ពួកកុលបុត្តចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់លោកុត្តរ-ធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញផលនៃសេចក្ដីមិនប្រមាទនេះឯង របស់ភិក្ខុនេះ ច្បាស់ហើយ បានជាតថាគតពោលថា ភិក្ខុនោះត្រូវតែធ្វើកិច្ច ដោយសេចក្ដីមិនប្រមាទទៀត ។

[២៣៧] កតមោ ច ភិក្ខវេ បុគ្គលោ សទ្ធានុសារី ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ យេ តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អារុប្បា តេ ន កាយេន ផុសិត្វា វិហរតិ បញ្ញាយ ចស្ស ទិស្វា ឯកច្ចេ អាសវា បរិក្ខីណា ហោន្តិ តថាគតេ ចស្ស សទ្ធាមត្តំ ហោតិ បេមមត្តំ អបិចស្ស ឥមេ ធម្មា ហោន្តិ សេយ្យថីទំ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ សទ្ធានុសារី ។ ឥមស្សបិ ខោ អហំ ភិក្ខវេ ភិក្ខុនោ អប្បមាទេន ករណីយន្តិ វទាមិ តំ កិស្ស ហេតុ អប្បេវនាម អយមាយស្មា អនុលោមិកានិ សេនាសនានិ បដិសេវមានោ កល្យាណមិត្តេ ភជមានោ ឥន្ទ្រិយានិ សមន្នានយមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ

ភិក្ខុវគ្គ កីដាគិរិសូត្រ បុគ្គលទី ៧ ក្នុងពួកបុគ្គលទាំង ៧

[២៣៧] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះថា សទ្ធានុសារី តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ មិនបានពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូបដោយកាយទេ គ្រាន់តែឃើញ (នូវអរិយសច្ចធម៌) ដោយប្រាជ្ញាប៉ុណ្ណោះ ទាំងអាសវៈទាំងឡាយពួកខ្លះ នៃបុគ្គលនោះក៏អស់ទៅ បុគ្គលនោះមានត្រឹមតែសេចក្តីជឿ និងសេចក្តីស្រឡាញ់ ក្នុងព្រះតថាគត ព្រមទាំងមានធម៌ទាំងឡាយនេះ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ហៅថា សទ្ធានុសារី ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនោះឯងត្រូវតែធ្វើកិច្ច ដោយសេចក្តីមិនប្រមាទទៀត ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ត្រាតែលោកមានអាយុនេះ សេពនូវសេនាសនៈដ៏សមគួរ គប់រកនូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ ពួកកុលបុត្តចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់លោកុត្តរធម៌ណា

តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ ឥមំ ខោ អហំ ភិក្ខវេ ឥមស្ស ភិក្ខុនោ អប្បមាទផលំ សម្បស្សមានោ អប្បមាទេន ករណីយន្តិ វទាមិ ។

[២៣៨] នាហំ ភិក្ខវេ អាទិកេនេវ អញ្ញារាធនំ វទាមិ អបិច ភិក្ខវេ អនុបុព្វសិក្ខា អនុបុព្វ-កិរិយា អនុបុព្វប្បដិបទា អញ្ញារាធនា ហោតិ ។ កថញ្ច ភិក្ខវេ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វប្បដិបទា អញ្ញារាធនា ហោតិ ។ ឥធ ភិក្ខវេ សទ្ធាជាតោ ឧបសង្កមតិ ឧបសង្កមន្តោ បយិរុបាសតិ បយិរុបាសន្តោ សោតំ ឱទហតិ ឱហិតសោតោ ធម្មំ សុណាតិ សុត្វា ធម្មំ ធារេតិ

ក៏បានធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌នោះ ដែលជាទីបំផុត នៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញនូវផលនៃសេចក្តីមិនប្រមាទនេះឯង របស់ភិក្ខុនេះច្បាស់ហើយ បានជាពោលថា ភិក្ខុនោះត្រូវតែធ្វើកិច្ច ដោយសេចក្តីមិនប្រមាទទៀត ។

[២៣៨] ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោល នូវសេចក្តីត្រេកអរចំពោះអរហត្តផល ថាជាធម៌ខាងដើមទេ ម្នាលភិក្ខុទាំងឡាយ ព្រោះថា សេចក្តីត្រេកអរចំពោះអរហត្តផល តែងមានការសិក្សាដោយលំដាប់ មានការធ្វើដោយលំដាប់ មានការប្រតិបត្តិដោយលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រេកអរចំពោះអរហត្តផល មានការសិក្សាដោយលំដាប់ មានការធ្វើដោយលំដាប់ មានការប្រតិបត្តិដោយលំដាប់ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងសាសនានេះ មានសទ្ធាទើបចូលទៅរក កាលបើចូលទៅរកហើយ ទើបចូលទៅអង្គុយជិត លុះចូលទៅអង្គុយជិតហើយ ទើបផ្ទៀងនូវសោតបសាទ លុះផ្ទៀងនូវសោតបសាទហើយ ទើបស្តាប់ធម៌ លុះស្តាប់ធម៌ហើយ ទើបចងចាំធម៌ (នោះ)

ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខតោ ធម្មា និជ្ឈានំ ខមន្តិ ធម្មនិជ្ឈានក្ខន្តិយា សតិ ឆន្ទោ ជាយតិ ឆន្ទជាតោ ឧស្សហតិ ឧស្សហិត្វា តុលេតិ តុលយិត្វា បទហតិ បហិតត្តោ សមានោ កាយេន ចេវ បរមំ សច្ចំ សច្ឆិករោតិ បញ្ញាយ ច នំ អតិវិជ្ឈ[១] បស្សតិ ។ សាបិ នាម ភិក្ខវេ សទ្ធា នាហោសិ តម្បិ នាម ភិក្ខវេ ឧបសង្កមនំ នាហោសិ សាបិ នាម ភិក្ខវេ បយិរុបាសនា នាហោសិ តម្បិ នាម ភិក្ខវេ សោតាវធានំ នាហោសិ តម្បិ នាម ភិក្ខវេ ធម្មស្សវនំ នាហោសិ សាបិ នាម ភិក្ខវេ ធម្មធារណា នាហោសិ សាបិ នាម ភិក្ខវេ អត្ថុបបរិក្ខតា[២] នាហោសិ សាបិ នាម ភិក្ខវេ ធម្មនិជ្ឈានក្ខន្តិ នាហោសិ សោបិ នាម ភិក្ខវេ ឆន្ទោ នាហោសិ

---

១ បដិវិជ្ឈាតីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. អត្ថូបបរិក្ខា ។ ម. អត្ថុបបរិក្ខា ។

កាលបើចង់ចាំធម៌ (នោះ) ហើយ ទើបពិចារណារកសេចក្តី លុះពិ-ចារណារកសេចក្តីនៃធម៌នោះហើយ ធម៌ទាំងឡាយ តែងគួរដល់កិរិយាលៃលកមើល កាលបើមានការលៃលកមើលហើយ ឆន្ទៈក៏កើតឡើង បុគ្គលនោះលុះមានឆន្ទៈកើតហើយ ទើបព្យាយាម លុះព្យាយាមហើយ រមែងស្ទង់មើល លុះស្ទង់មើលហើយ រមែងតម្កល់ទុក មានចិត្តបញ្ជូនទៅ (កាន់ព្រះនិព្វាន) ធ្វើឲ្យជាក់ច្បាស់នូវបរមសច្ច ដោយនាម-កាយ ទាំងបានចាក់ធ្លុះឃើញច្បាស់ នូវបរមសច្ចនោះដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ បើសទ្ធានោះ មិនមានហើយ ម្នាលភិក្ខុទាំង-ឡាយ ការចូលទៅរកនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការចូលទៅអង្គុយជិតនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការផ្ទៀងចុះនូវសោត-បសាទនោះក៏មិនមាន ការចង់ចាំធម៌នោះក៏មិនមាន ម្នាលភិក្ខុទាំង-ឡាយ ការពិចារណាសេចក្តីនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការសំឡឹងនូវធម៌នោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ឆន្ទៈនោះក៏មិនមាន

សោបិ នាម ភិក្ខវេ ឧស្សាហោ នាហោសិ សាបិ នាម ភិក្ខវេ តុលនា នាហោសិ តម្បិ នាម ភិក្ខវេ បធានំ នាហោសិ វិប្បដិបន្នាត្ថ ភិក្ខវេ មិច្ឆាបដិបន្នាត្ថ ភិក្ខវេ កីវទូរេវិមេ ភិក្ខវេ មោឃបុរិសា អបក្កន្តា ឥមស្មា ធម្មវិនយា ។

[២៣៩] អត្ថិ ភិក្ខវេ ចតុប្បទំ វេយ្យាករណំ យស្សុទ្ទិដ្ឋស្ស វិញ្ញូ បុរិសោ នចិរស្សេវ បញ្ញាយ អត្ថំ[១] អាជានេយ្យ ឧទ្ទិសិស្សាម[២] វោ[៣] ភិក្ខវេ អាជានិស្សថ មេតន្តិ ។ តេ ច មយំ ភន្តេ កេ ច ធម្មស្ស អញ្ញាតារោតិ ។ យោបិ សោ ភិក្ខវេ សត្ថា អាមិសគរុកោ[៤] អាមិសទាយាទោ អាមិសេហិ សំសដ្ឋោ វិហរតិ តស្សចាយំ ឯវរូបី បណោបណវិយា[៥] ន ឧបេតិ ឯវញ្ច នោ អស្ស អថ នំ ករេយ្យាម ន ច នោ ឯវមស្ស[៦] ន

១ ឱ. ម. បញ្ញាយត្ថំ ។ ២ ឱ. ឧទ្ទិសិស្សាមិ ។ ៣ ម. វោតិ ន ទិស្សតិ ។ ៤ ឱ. ម. អាមិសគរុ ។ ៥ ឱ. បណោបណវិធា ។ ៦ ឱ. ឯវស្ស ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីព្យាយាមនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ សេចក្តីស្ទង់មើលនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ សេចក្តីតម្កល់ទុកនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមុខតែនឹងដល់នូវវិបត្តិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មុខតែនឹងប្រតិបត្តិខុសពុំខាន ម្នាលភិក្ខុទាំងឡាយ មោឃបុរសអម្បាលនេះ នឹងឃ្លាតចាកធម្មវិន័យនេះ ឆ្ងាយអម្បាលម៉ានទៅ ។

[២៣៩] ម្នាលភិក្ខុទាំងឡាយ ការព្យាករនូវសច្ចៈទាំង ៤ ពួកវិញ្ញូបុរសគួរដឹងច្បាស់ នូវសេចក្តីនៃសច្ចៈទាំង ៤ ណា ដែលតថាគតបានសំដែងហើយ មិនយូរប៉ុន្មានឡើយ តថាគតនឹងសំដែងប្រាប់ ដល់អ្នកទាំងឡាយ ៗ នឹងបានដឹងច្បាស់នូវសច្ចៈនុ៎ះ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងឡាយណាខ្លះ ពួកជនទាំងឡាយណាខ្លះ ដែលជាអ្នកគួរដឹងនូវធម៌បាន ។ ម្នាលភិក្ខុទាំងឡាយ សាស្តាណា ជាអ្នកធ្ងន់ដោយអាមិសៈ ជាអ្នកមានអាមិសៈជាមត៌ក ជាអ្នកចំពាក់ដោយអាមិសៈទាំងឡាយហើយ គុណសម្បត្តិមានសភាពយ៉ាងនេះ ឥតមានចម្រើនដល់សាស្តានោះឡើយថា បើហេតុយ៉ាងនេះ មានដល់យើងទាំងឡាយ ក្នុងកាលណាហើយ យើងទាំងឡាយក៏នឹងធ្វើហេតុនោះក្នុងកាលនោះ បើហេតុយ៉ាងនេះ មិនមានដល់យើងទាំងឡាយ យើងទាំងឡាយក៏មិនគប្បី

ណំ ការេយ្យាមាតិ ។ កិម្បន ភិក្ខវេ យំ តថាគតោ សព្វសោ អាមិសេហិ វិសំសដ្ឋោ វិហរតិ សទ្ធស្ស ភិក្ខវេ សាវកស្ស សត្ថុ សាសនេ បរិយោគយ្ហ[1] វត្តតោ អយមនុធម្មោ ហោតិ សត្ថា ភគវា សាវកោ-ហមស្មិ ជានាតិ ភគវា នាហំ ជានាមីតិ ។ សទ្ធស្ស ភិក្ខវេ សាវកស្ស សត្ថុ សាសនេ បរិយោគយ្ហ វត្តតោ រុឡ្ហនីយំ[2] សត្ថុ សាសនំ ហោតិ ឱជវន្តំ ។ សទ្ធស្ស ភិក្ខវេ សាវកស្ស សត្ថុ សាសនេ បរិយោ-គយ្ហ វត្តតោ អយមនុធម្មោ ហោតិ កាមំ តចោ ច នហារុ ច អដ្ឋិ ច អវសិស្សតុ មេ សរីរេ អវ-សុស្សតុ មំសលោហិតំ យន្តំ បុរិសត្ថាមេន បុរិស-វីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបាបុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតីតិ ។ សទ្ធស្ស ភិក្ខវេ សាវកស្ស សត្ថុ សាសនេ បរិយោគយ្ហ វត្តតោ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ

១ ឱ. ម. បរិយោគាយាតិ ទិស្សតិ ។ ២ ឱ. រុម្ហនិយំ ។

ធ្វើនូវហេតុនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនជាប់ចំពាក់ដោយអាមិសៈទាំងឡាយ ដោយប្រការទាំងពួងមែនឬ ម្នាលភិក្ខុទាំង-ឡាយ កាលសាវ័ក ជាអ្នកមានសទ្ធា កាន់តាមហើយប្រព្រឹត្តក្នុងសាស-នានៃព្រះសាស្តា សភាវៈនេះតែងមានថា ព្រះមានព្រះភាគជាសាស្តា អាត្មាអញជាសាវ័ក ព្រះមានព្រះភាគ តែងទ្រង់ជ្រាប (នូវអានិសង្សក្នុងការបរិភោគតែម្តង) អាត្មាអញមិនបានដឹងឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ កាលសាវ័កមានសទ្ធា កាន់តាមហើយប្រព្រឹត្ត ក្នុងសាសនានៃព្រះសាស្តា សាសនារបស់ព្រះសាស្តា នឹងដុះដាល មានឱជៈទៅបាន ។ ម្នាលភិក្ខុទាំងឡាយ កាលសាវ័ក ជាអ្នកមានសទ្ធា កាន់តាមហើយប្រព្រឹត្ត ក្នុងសាសនារបស់ព្រះសាស្តា សភាវៈនេះតែងមានថា សូមឲ្យស្បែក សរសៃ និងឆ្អឹង សល់នៅចុះ ឯសាច់ឈាមក្នុងសរីរៈរបស់អាត្មាអញ ចង់រីងស្ងួត ក៏រីងស្ងួតទៅចុះ កិច្ចណាដែលបុគ្គលត្រូវបានដោយកម្លាំងរបស់បុរស ដោយព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស បើអាត្មាអញមិនទាន់សម្រេចកិច្ចនោះទេ ក៏មិនបន្ធូរបន្ថយព្យាយាមឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលសាវ័កអ្នកមានសទ្ធា កាន់តាមហើយប្រព្រឹត្តក្នុងសាសនា របស់ព្រះសាស្តា បណ្តាផលទាំងពីរ ផលណាមួយ តែងបានសម្រេចក្នុងបច្ចុប្បន្នពុំខាន

អញ្ញា សតិ វា ឧចាជិសេសេ អជាតាមិតាតិ ។ ឥជមវោច ភគវា អត្តមជា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

កីដាគិរិសុត្តំ ទសមំ និដ្ឋិតំ ។

ភិក្ខុវគ្គោ ទុតិយោ និដ្ឋិតោ ។

## តស្ស វគ្គស្ស ឧទ្ទានំ

កុញ្ជរាហុលសស្សតលោកោ
មាលុង្ក្យបុត្តោ ច ភទ្ទាលិជាមោ
ជិជខុទ្ទសហាម្បតិយាចជា
ជាឡ្បកីបជរតិរិជាមោ
អសមោ បរោ ទុតិយោ វរវគ្គោ ។

គឺនឹងបានសម្រេចអរហត្តផល ឬបើនៅមានឧបាទានក្ខន្ធសេសសល់ ក៏គង់បានជាអនាគាមិបុគ្គលពុំខានឡើយ ។ លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរ ចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ កីដាគិរិសូត្រ ទី ១០ ។

ចប់ ភិក្ខុវគ្គ ទី ២ ។

# បញ្ជីរឿងនៃវគ្គនោះគឺ

ចូឡរាហុលោវាទសូត្រ ១ មហារាហុលោវាទសូត្រ ១

ចូឡមាលុង្ក្យោវាទសូត្រ ១ មហាមាលុង្ក្យោវាទសូត្រ ១

ភទ្ទាលិសូត្រ ១ លដុកិកោបមសូត្រ ១ ចាតុមសូត្រ ១

នឡកបានសូត្រ ១ គោលិស្សានិសូត្រ ១ កីដាគិរិសូត្រ ១

(ចប់) វរវគ្គទី ២ ដែលមិនមានវគ្គដទៃស្មើ ។

# សុត្តន្តបិដកេ មជ្ឈិមនិកាយស្ស

# មជ្ឈិមបណ្ណាសកំ

# ចតុត្ថោ ភាគោ

# គហបតិវគ្គោ

## បឋមំ កន្ទរកសុត្តំ


| | | | អង្កេ |
|---|---|---|---|
| គហបតិវគ្គស្ស | កន្ទរកសុត្តេ | សម្មាបដិបាទនំ............................ | ៣ |
| | | ចត្តារោ សតិប្បដ្ឋានា..................... | ៥ |
| | | ចត្តារោ បុគ្គលា............................ | ៧ |
| | | បេស្សហត្ថារោហបុត្តប្បសំសា ....... | ១១ |
| | | បឋមបុគ្គលវិភជនំ........................ | ១៣ |
| | | តតិយបុគ្គលវិភជនំ ..................... | ១៥ |
| | | ចតុត្ថបុគ្គលវិភជនំ ....................... | ១៧ |
| | | សិក្ខាសាជីវសមាបន្នតា................ | ១៩ |
| | | នីវរណបរិសោធនំ ....................... | ២៣ |

# សុត្តន្តបិដក មជ្ឈិមនិកាយ

# មជ្ឈិមបណ្ណាសក

# ចតុត្ថភាគ

# គហបតិវគ្គ

## *កន្ទរកសូត្រ ទី ១*

លេខទំព័រ


| | | | |
|---|---|---|---|
| គហបតិវគ្គ | កន្ទរកសូត្រ | ការទ្រង់ប្រដៅដោយល្អ ........................ | ៣ |
| | | សតិប្បដ្ឋាន ៤ ...................................... | ៥ |
| | | បុគ្គល ៤ ពួក......................................... | ៧ |
| | | ការទ្រង់សរសើរបេស្សហត្ថារោហបុត្រ..... | ១១ |
| | | ការទ្រង់ចែកបុគ្គលទី ១.......................... | ១៣ |
| | | ការទ្រង់ចែកបុគ្គលទី ៣......................... | ១៥ |
| | | ការទ្រង់ចែកបុគ្គលទី ៤ ......................... | ១៧ |
| | | ការដល់ព្រមដោយសិក្ខានិងសាជីវៈ......... | ១៩ |
| | | ការជម្រះឲ្យស្អាតចាកនីវរណធម៌.............. | ២៣ |

# មាតិកាបត្តានិ

អង្កេ

គហបតិវគ្គស្ស កន្ទរកសុត្តេ បុព្វេនិវាសានុស្សតិញ្ញាណំ........... ២៥

ចុតូបបាតញ្ញាណំ......................... ២៧

អាសវក្ខយញ្ញាណំ........................ ២៩

## ទុតិយំ អដ្ឋកនាគរសុត្តំ

គហបតិវគ្គស្ស អដ្ឋកនាគរសុត្តេ ទសមគហបតិវត្ថុ ......................... ៣១

ចតុរូបដ្ឋានំ ................................. ៣៣

អប្បមញ្ញាភាវនា.......................... ៣៥

ចត្វារុប្បដ្ឋានំ............................... ៣៧

អានន្ទស្ស បូជា............................. ៣៩

## តតិយំ សេក្ខប្បដិបទាសុត្តំ

គហបតិវគ្គស្ស សេក្ខប្បដិបទាសុត្តេ ភគវតោ បឋមំ បរិកុញ្ចនំ ............. ៤១

ឆព្វិធោ ធម្មោ............................... ៤៣

ភោជនេ មត្តញ្ញុតា ....................... ៤៥

សត្ត សទ្ធម្មា................................ ៤៧

សេក្ខប្បដិបទា.............................. ៤៩

# សង្ខឹកាចង្អុលប្រាប់មាតិកា

លេខទំព័រ


| | | | |
|---|---|---|---|
| គហបតិវគ្គ | កន្ទរកសូត្រ | បុព្វេនិវាសានុស្សតិញ្ញាណ | ២៥ |
| | | ចុតូបបាតញ្ញាណ | ២៧ |
| | | អាសវក្ខយញ្ញាណ | ២៩ |

## អដ្ឋកនាគរសូត្រ ទី ២

| | | | |
|---|---|---|---|
| គហបតិវគ្គ | អដ្ឋកនាគរសូត្រ | រឿងទសមគហបតី | ៣១ |
| | | រូបជ្ឈាន ៤ | ៣៣ |
| | | អប្បមញ្ញាភាវនា | ៣៥ |
| | | អរូបជ្ឈាន ៤ | ៣៧ |
| | | ការបូជាព្រះអានន្ទ | ៣៩ |

## សេក្ខប្បដិបទាសូត្រ ទី ៣

| | | | |
|---|---|---|---|
| គហបតិវគ្គ | សេក្ខប្បដិបទាសូត្រ | ការទ្រង់ប្រើប្រាស់ជាដំបូងនៃព្រះមានព្រះភាគ | ៤១ |
| | | ធម៌ ៦ យ៉ាង | ៤៣ |
| | | ការស្គាល់ប្រមាណក្នុងភោជន | ៤៥ |
| | | ព្រះសទ្ធម្ម ៧ ប្រការ | ៤៧ |
| | | បដិបទានៃសេក្ខបុគ្គល | ៤៩ |

# មាតិកាបត្តានិ

អង្កេ

គហបតិវគ្គស្ស សេក្ខប្បដិបទាសុត្តេ វិជ្ជាចរណតា................................ ៥៣

អានន្ទប្បសំសា ............................ ៥៥

## ចតុត្ថំ ចោតលិយសុត្តំ

គហបតិវគ្គស្ស ចោតលិយសុត្តេ គហបតិវាទេន សមុទាចរណំ........ ៥៧

បឋមធម្មោ .................................. ៥៩

តតិយធម្មោ ................................. ៦៣

បញ្ចមធម្មោ ................................. ៦៥

ឆដ្ឋធម្មោ..................................... ៦៧

អដ្ឋមធម្មោ.................................... ៦៩

អដ្ឋិកង្កលូបមា ............................. ៧១

មំសបេសូបមា ............................. ៧៣

សុបិនកូបមា ................................ ៧៥

រុក្ខផលូបមា ................................ ៧៧

តេវិជ្ជកថា .................................. ៧៩

អាជានីយនាជានីយតា................. ៨១

# សង្ខឹកចង្កុលប្រាប់មាតិកា

លេខទំព័រ

គហបតិវគ្គ សេក្ខប្បដិបទាសូត្រ ភាពនៃវិជ្ជានិងចរណៈ .................................... ៥៣

ការទ្រង់សរសើរព្រះអានន្ទ ................................ ៥៥

## បោតលិយសូត្រ ទី ៤

គហបតិវគ្គ បោតលិយសូត្រ ការទ្រង់ត្រាស់ហៅដោយពាក្យថាគហបតី ......... ៥៧

ធម៌ទី ១ .......................................................... ៥៩

ធម៌ទី ៣ .......................................................... ៦៣

ធម៌ទី ៥ .......................................................... ៦៥

ធម៌ទី ៦ .......................................................... ៦៧

ធម៌ទី ៨ .......................................................... ៦៩

សេចក្តីឧបមាដោយរាងឆ្អឹង................................ ៧១

សេចក្តីឧបមាដោយដុំសាច់ ............................... ៧៣

សេចក្តីឧបមាដោយការយល់សប្តិ...................... ៧៥

សេចក្តីឧបមាដោយផ្លែឈើ ............................... ៧៧

ភាពនៃត្រៃវិជ្ជា .................................................. ៧៩

ភាពនៃបុរសជាអាជានេយ្យនិងមិនមែនអាជានេយ្យ ៨១

# មាតិកាបត្តានិ

## បញ្ចមំ ជីវកសុត្តំ

អង្កេ

គហបតិវគ្គស្ស ជីវកសុត្តេ មេត្តាភាវនា ........................................ ៨៥
កររុណាទិភាវនា ...................................... ៨៧
បាណារម្ភស្ស បញ្ចដ្ឋានានិ ................... ៨៩
បាណុបេតសរណគតតា ....................... ៩១

## ឆដ្ឋំ ឧបាលិវាទសុត្តំ

គហបតិវគ្គស្ស ឧបាលិវាទសុត្តេ តីណិ ទណ្ឌានិ .................................. ៩៣
តីណិ កម្មានិ ........................................ ៩៥
កថាសល្លាបារោចនំ.............................. ៩៧
វាទារោបនកាមតា ................................. ៩៩
ឧបាលិស្ស ភគវន្តូបសង្កមនំ.................. ១០៣
ទណ្ឌាបញ្ហា ......................................... ១០៥
បដិបុច្ឆិតបញ្ហា.................................... ១០៧
បាណុបេតសរណគតតា ....................... ១១១

# សង្ខេបដង្កូលច្រាប់មាតិកា

## ជីវកសូត្រ ទី ៥

លេខទំព័រ


| | | | |
|---|---|---|---|
| គហបតិវគ្គ | ជីវកសូត្រ | ការចម្រើនមេត្តាព្រហ្មវិហារ................................ | ៨៥ |
| | | ការចម្រើនព្រហ្មវិហារមានករុណាព្រហ្មវិហារជាដើម | ៨៧ |
| | | ឋានៈ ៥ យ៉ាងនៃការសម្លាប់សត្វ .................... | ៨៩ |
| | | ការដល់នូវសរណៈស្មើដោយជីវិត..................... | ៩១ |


## ឧបាលិវាទសូត្រ ទី ៦


| | | | |
|---|---|---|---|
| គហបតិវគ្គ | ឧបាលិវាទសូត្រ | ទណ្ឌៈ ៣ យ៉ាង................................................ | ៩៣ |
| | | កម្ម ៣ យ៉ាង .................................................... | ៩៥ |
| | | ដំណាលអំពីការនិយាយឆ្លើយឆ្លង..................... | ៩៧ |
| | | បំណងនឹងលើកឡើងនូវវាទៈ............................ | ៩៩ |
| | | ឧបាលិគហបតីចូលគាល់ព្រះមានព្រះភាគ......... | ១០៣ |
| | | សំណួរអំពីទណ្ឌៈ............................................. | ១០៥ |
| | | សំណួរតបអំពីប្រស្នាដែលសួរហើយ................. | ១០៧ |
| | | ការដល់នូវសរណៈស្មើដោយជីវិត..................... | ១១១ |

# មាតិកាបត្តានិ

អង្កេ

គហបតិវគ្គស្ស ឧបាលិវាទសុត្តេ មហាបួលាមហាបួលតា.................... ១១៣
និគន្ថានំ ទ្វារាវរណំ....................... ១១៥
សាវកត្តឧបគតតា......................... ១១៧
និគន្ថស្ស ឧបាលិមុបសង្កមនំ........ ១២១
អាវដ្តនិមាយា .............................. ១២៣
ភូតបុព្វវត្ថុ ................................... ១២៧
សាវកត្តប្បកាសនំ ......................... ១៣១

## សត្តមំ កុក្កុរោវាទសុត្តំ

គហបតិវគ្គស្ស កុក្កុរោវាទសុត្តេ កុក្កុរវត្តិកគតិ................................. ១៣៧
គោវត្តិកគតិ .................................. ១៣៩
កតវន្ទប្បសាទប្បកាសនំ............... ១៤១
ចត្តារិ កម្មានិ ................................. ១៤៣
ចាតុម្មាសបរិវាសោ ....................... ១៤៧

# សង្ខេបចង្អុលប្រាប់មាតិកា

លេខទំព័រ


| | | | |
|---|---|---|---|
| គហបតិវគ្គ | ឧបាលិវាទសូត្រ | ភាពនៃទានមានផលច្រើននិងមិនមានផលច្រើន. | ១១៣ |
| | | ការរាំងទ្វារចំពោះពួកនិគ្រន្ថ .............................. | ១១៥ |
| | | ការចូលទៅជាសាវ័ក ....................................... | ១១៧ |
| | | និគន្ថនាដបុត្តចូលទៅរកឧបាលិគហបតី............ | ១២១ |
| | | កិច្ចកលសម្រាប់បោកប្រាស់ .............................. | ១២៣ |
| | | រឿងធ្លាប់មានមកហើយ .................................... | ១២៧ |
| | | ការប្រកាសខ្លួនជាសាវ័ក................................... | ១៣១ |


## *កុក្កុរោវាទសូត្រ ទី ៧*


| | | | |
|---|---|---|---|
| គហបតិវគ្គ | កុក្កុរោវាទសូត្រ | គតិរបស់បុគ្គលអ្នកសមាទានកុក្កុរវត្ត................... | ១៣៧ |
| | | គតិរបស់បុគ្គលអ្នកសមាទានគោវត្ត................... | ១៣៩ |
| | | ការប្រកាសសេចក្តីជ្រះថ្លាចំពោះព្រះមានព្រះភាគ | ១៤១ |
| | | កម្ម ៤ យ៉ាង ...................................................... | ១៤៣ |
| | | បរិវាស ៤ ខែ.................................................... | ១៤៧ |

# មាតិកាបត្តានិ

## អដ្ឋមំ អភយរាជកុមារសុត្តំ

អង្កេ

គហបតិវគ្គស្ស អភយរាជកុមារសុត្តេ ឧភតោកោដិតប្បញ្ហា .................. ១៥១
អមនាបវាចាបញ្ហា......................... ១៥៣
អត្តសញ្ហិតាវាចា........................... ១៥៧
បាណុបេតសរណោគតតា.............. ១៥៩

## នវមំ ពហុវេទនីយសុត្តំ

គហបតិវគ្គស្ស ពហុវេទនីយសុត្តេ វេទនាកថា.................................... ១៦៣
រូបារូបជ្ឈានសុខំ .......................... ១៦៧
សញ្ញាវេទយិតសុខំ........................ ១៦៩

## ទសមំ អបណ្ណកសុត្តំ

គហបតិវគ្គស្ស អបណ្ណកសុត្តេ វិបច្ចនីកវាទោ................................ ១៧៣
ទុស្សមត្តាបណ្ណកោ ....................... ១៧៧
សុសមត្តាបណ្ណកោ....................... ១៧៩
វិបច្ចនីកវាទោ............................... ១៨១

# សន្ទឹកាចង្អុលប្រាប់មាតិកា

## *អភយរាជកុមារសូត្រ ទី ៨*

លេខទំព័រ


| | | | |
|---|---|---|---|
| គហបតិវគ្គ | អភយរាជកុមារសូត្រ | ប្រស្នាប្រកបដោយទីបំផុតទាំងសងខាង....... | ១៥១ |
| | | ប្រស្នាពោលអំពីវាចាដែលមិនជាទីគាប់ចិត្ត... | ១៥៣ |
| | | វាចាប្រកបដោយប្រយោជន៍........................ | ១៥៧ |
| | | ការដល់នូវសរណគមន៍ស្មើដោយជីវិត.......... | ១៥៩ |


## *ពហុវេទនីយសូត្រ ទី ៩*


| | | | |
|---|---|---|---|
| គហបតិវគ្គ | ពហុវេទនីយសូត្រ | ការពោលអំពីវេទនា.................................... | ១៦៣ |
| | | សេចក្តីសុខក្នុងរូបជ្ឈាននិងអរូបជ្ឈាន........... | ១៦៧ |
| | | សេចក្តីសុខក្នុងសញ្ញាវេទយិតនិរោធ............ | ១៦៩ |


## *អបណ្ណកសូត្រ ទី ១០*


| | | | |
|---|---|---|---|
| គហបតិវគ្គ | អបណ្ណកសូត្រ | ការពោលអំពីវាទៈដែលជាសឹកសត្រូវ........... | ១៧៣ |
| | | អបណ្ណកធម៌ដែលបុគ្គលធ្វើមិនពេញលេញ... | ១៧៧ |
| | | អបណ្ណកធម៌ដែលបុគ្គលបានធ្វើពេញលេញល្អ | ១៧៩ |
| | | ការពោលអំពីវាទៈដែលជាសឹកសត្រូវ........... | ១៨១ |

# មាតិកាបត្តានិ

អង្កេ

*គហបតិវគ្គស្ស អបណ្ណកសុត្តេ អរិយបច្ចនីកតា* ................................ ១៨៥
*អរិយាបច្ចនីកតា* ............................... ១៨៧
*វិបច្ចនីកវាទោ* ................................... ១៩១
*ទុស្សមត្តាបណ្ណកោ* ............................ ១៩៥
*អរិយាបច្ចនីកតា* ................................ ១៩៧
*អារុប្បនតត្ថិវាទោ* .............................. ១៩៩
*ភវនិរោធនតត្ថិវាទោ* ........................... ២០១
*ចត្តារោ បុគ្គលា* ................................ ២០៣
*ចតុបុគ្គលវិភជនំ* ................................ ២០៥
*ធម្មទេសនាបសំសា* ........................... ២០៩

# ភិក្ខុវគ្គោ

## បឋមំ ចូឡរាហុលោវាទសុត្តំ

*ភិក្ខុវគ្គស្ស ចូឡរាហុលោវាទសុត្តេ សង្កាមាវចរនាគោបមា* ................ ២១៣
*អាទាសូបមា*...................................... ២១៥

# សង្ខេបចង្អុលប្រាប់មាតិកា

លេខទំព័រ


| | | | |
|---|---|---|---|
| គហបតិវគ្គ | អបណ្ណកសូត្រ | វាចាដែលជាសឹកសត្រូវនឹងព្រះអរិយៈ .............. | ១៨៥ |
| | | វាចាដែលមិនជាសឹកសត្រូវនឹងព្រះអរិយៈ.......... | ១៨៧ |
| | | ការពោលអំពីវាទៈដែលជាសឹកសត្រូវ ............... | ១៩១ |
| | | អបណ្ណកធម៌ដែលបុគ្គលធ្វើមិនពេញលេញ......... | ១៩៥ |
| | | វាចាមិនជាសឹកសត្រូវដល់ព្រះអរិយៈ ................ | ១៩៧ |
| | | ការពោលថាអរូបព្រហ្មមិនមាន ......................... | ១៩៩ |
| | | ការពោលថាការរលត់នៃភពមិនមាន ................. | ២០១ |
| | | បុគ្គល ៤ ពួក ............................................... | ២០៣ |
| | | ការទ្រង់ចែកបុគ្គលជា ៤ ពួក ........................... | ២០៥ |
| | | ការពោលសរសើរព្រះធម្មទេសនា .................... | ២០៩ |


## ភិក្ខុវគ្គ

### *ចូឡរាហុលោវាទសូត្រ ទី ១*


| | | | |
|---|---|---|---|
| ភិក្ខុវគ្គ | ចូឡរាហុលោវាទសូត្រ | ឧបមាដូចដំរីដែលចូលកាន់សង្គ្រាម.................. | ២១៣ |
| | | សេចក្តីប្រៀបដោយកញ្ចក់................................ | ២១៥ |

# មាតិកាបត្តានិ

អង្កេ

ភិក្ខុវគ្គស្ស ចូឡរាហុលោវាទសុត្តេ កាយកម្មំ .................................... ២១៧

វចីកម្មំ ......................................... ២២១

មនោកម្មំ ..................................... ២២៣

កម្មត្តយបរិសោធនំ ...................... ២២៧

## ទុតិយំ មហារាហុលោវាទសុត្តំ

ភិក្ខុវគ្គស្ស មហារាហុលោវាទសុត្តេ បញ្ចសុ បឋមធាតុកថា................ ២៣១

បញ្ចសុ តតិយធាតុកថា ............... ២៣៣

បញ្ចមធាតុកថា............................ ២៣៥

អាបោសមាភាវនា ........................ ២៣៧

អាកាសសមាភាវនា ..................... ២៣៩

អានាបានស្សតិកថា ..................... ២៤១

## តតិយំ ចូឡមាលុង្ក្យោវាទសុត្តំ

ភិក្ខុវគ្គស្ស ចូឡមាលុង្ក្យោវាទសុត្តេ បរិវិតក្កាពោចនំ.............................. ២៤៧

បុច្ឆិតបដិបុច្ឆា.............................. ២៥១

# សង្ខេបចង្អុលប្រាប់មាតិកា

លេខទំព័រ


ភិក្ខុវគ្គ ចូឡរាហុលោវាទសូត្រ កាយកម្ម ........................................................ ២១៧

វចីកម្ម ............................................................ ២២១

មនោកម្ម ........................................................ ២២៣

ការជម្រះកម្មទាំង ៣ ........................................ ២២៧


## មហារាហុលោវាទសូត្រ ទី ២


ភិក្ខុវគ្គ មហារាហុលោវាទសូត្រ ការពោលអំពីធាតុទី ១ ក្នុងពួកធាតុទាំង ៥ ......... ២៣១

ការពោលអំពីធាតុទី ៣ ក្នុងពួកធាតុទាំង ៥......... ២៣៣

ការពោលអំពីធាតុទី ៥ ..................................... ២៣៥

ការចម្រើនភាវនាឲ្យដូចជាទឹក............................. ២៣៧

ការចម្រើនភាវនាឲ្យដូចជាអាកាស....................... ២៣៩

ការពោលអំពីអានាបានស្សតិ............................ ២៤១


## ចូឡមាលុង្ក្យោវាទសូត្រ ទី ៣


ភិក្ខុវគ្គ ចូឡមាលុង្ក្យោវាទសូត្រ ការក្រាបបង្គំទូលអំពីសេចក្តីត្រិះរិះ ..................... ២៤៧

ការទ្រង់សាកសួរប្រស្នាដែលសួររួចហើយ.......... ២៥១

# មាតិកាបត្តានិ

អង្កេ

*ភិក្ខុវគ្គស្ស មហាមាលុង្ក្យោវាទសុត្តេ សល្វវិទ្ធូបមា* ................................ ២៥៣

*ទិដ្ឋិព្យាករណំ* ................................ ២៥៧

*អព្យាកតតា* .................................. ២៥៩

*ព្យាកតតា* ..................................... ២៦១

## ចតុត្ថំ មហាមាលុង្ក្យោវាទសុត្តំ

*ភិក្ខុវគ្គស្ស មហាមាលុង្ក្យោវាទសុត្តេ បញ្ចានុសយា* ........................... ២៦៣

*បញ្ចោរម្ភាគិយសញ្ញោជនំ* ............ ២៦៥

*បញ្ចសញ្ញោជនប្បហានំ* ............... ២៦៧

*សញ្ញោជនប្បហានមគ្គោ* .............. ២៦៩

*ចតុរូបដ្ឋានំ* .................................. ២៧១

*ចត្វារូបដ្ឋានំ* ................................. ២៧៣

*សញ្ញោជនប្បហានមគ្គោ* .............. ២៧៥

# សន្ទឹកចង្អុលប្រាប់មាតិកា

លេខទំព័រ

ភិក្ខុវគ្គ ចូឡមាលុង្ក្យោវាទសូត្រ ឧបមាដូចបុរសដែលមុតសរ.............................. ២៥៣

ការទ្រង់សំដែងទិដ្ឋិ.......................................... ២៥៧

ទិដ្ឋិដែលទ្រង់ព្យាករ ........................................ ២៥៩

ទិដ្ឋិដែលទ្រង់សំដែង ........................................ ២៦១

## មហាមាលុង្ក្យោវាទសូត្រ ទី ៤

ភិក្ខុវគ្គ មហាមាលុង្ក្យោវាទសូត្រ អនុស័យ ៥ យ៉ាង............................................ ២៦៣

ឱរម្ភាគិយសំយោជនៈ ៥ យ៉ាង ........................ ២៦៥

ការលះបង់សំយោជនៈទាំង ៥ .......................... ២៦៧

មគ្គជាគ្រឿងលះបង់នូវសំយោជនៈ.................... ២៦៩

រូបជ្ឈាន ៤ ...................................................... ២៧១

អរូបជ្ឈាន ៤ .................................................... ២៧៣

មគ្គជាគ្រឿងលះបង់សំយោជនៈ........................ ២៧៥

# មាតិកាបត្តានិ

## បញ្ចមំ ភទ្ទាលិសុត្តំ

អង្កេ

ភិក្ខុវគ្គស្ស ភទ្ទាលិសុត្តេ ចីវរកម្មករណំ........................................ ២៧៩
សមយប្បដិវិទ្ធតា.................................. ២៨១
ឧភតោភាគវិមុត្តាទិកោ .......................... ២៨៣
សិក្ខាបរិបូរការិតា.................................. ២៨៥
សិក្ខាបរិបូរិការិតា.................................. ២៨៧
អធិករណូបសមភាវោ ........................... ២៩៣
សទ្ធាមត្តកំ បេមមត្តកំ............................២៩៧
សិក្ខាបទប្បញ្ញាបនំ................................ ២៩៩
អស្សទមកោបមា.................................... ៣០១
ទស ធម្មា................................................ ៣០៣

## ឆដ្ឋំ លដុកិកោបមសុត្តំ

ភិក្ខុវគ្គស្ស លដុកិកោបមសុត្តេ បរិវិតក្កាពោចនំ.................................... ៣០៧
លដុកិកោបមា........................................ ៣១១

# សន្លឹកចង្អុលប្រាប់មាតិកា

## ភទ្ទាលិសូត្រ ទី ៥

លេខទំព័រ


| | | | |
|---|---|---|---|
| ភិក្ខុវគ្គ | ភទ្ទាលិសូត្រ | ការធ្វើចីវរកម្ម.................................................. | ២៧៩ |
| | | ការមិនបានដឹងនូវហេតុ.................................... | ២៨១ |
| | | ភិក្ខុមានឧភតោភាគវិមុត្តភិក្ខុជាដើម.................. | ២៨៣ |
| | | ការមិនបានបំពេញសិក្ខា.................................. | ២៨៥ |
| | | ការបានបំពេញសិក្ខា......................................... | ២៨៧ |
| | | សេចក្តីរម្ងាប់អធិករណ៍...................................... | ២៩៣ |
| | | សទ្ធាស្តួចស្តើងសេចក្តីស្រឡាញ់ស្តួចស្តើង ........ | ២៩៧ |
| | | ហេតុដែលឲ្យទ្រង់បញ្ញត្តសិក្ខាបទ...................... | ២៩៩ |
| | | ឧបមាដូចបុរសជាអ្នកបង្ហាត់សេះ...................... | ៣០១ |
| | | ធម៌ ១០ ប្រការ................................................. | ៣០៣ |


## លដុកិកោបមសូត្រ ទី ៦


| | | | |
|---|---|---|---|
| ភិក្ខុវគ្គ | លដុកិកោបមសូត្រ | ការក្រាបបង្គំទូលអំពីសេចក្តីត្រិះរិះ..................... | ៣០៧ |
| | | ឧបមាដូចសត្វប្រចៀច...................................... | ៣១១ |

# មាតិកាបត្តានិ

អង្កេ

ភិក្ខុវគ្គស្ស លដុកិកោបមសុត្តេ នាគោបមា ........................................ ៣១៣
ទឡ្ហិទ្វូបមា.............................................. ៣១៥
គហបតិគហបតិបុត្តូបមា......................... ៣១៧
ចត្តារោ បុគ្គលា....................................... ៣២១
ចតុត្ថជ្ឈានកថា....................................... ៣២៥
បហានកថា ............................................ ៣២៧

## សត្តមំ ចាតុមសុត្តំ

ភិក្ខុវគ្គស្ស ចាតុមសុត្តេ ឧច្ចាសទ្ទា មហាសទ្ទា .................................... ៣៣១
សក្យានំ ភគវន្តូបសង្កមនំ .......................៣៣៣
ព្រហ្មជ្ឈេសនា ......................................... ៣៣៥
ភិក្ខូនំ ភគវន្តូបសង្កមនំ ..........................៣៣៧
ឧម្មិភយកថា............................................ ៣៣៩
កុម្ភីលភយកថា........................................ ៣៤១
អាវដ្ដភយកថា......................................... ៣៤៣

# សន្លឹកចង្អុលប្រាប់មាតិកា

លេខទំព័រ


| | | | |
|---|---|---|---|
| ភិក្ខុវគ្គ | លដុកិកោបមសូត្រ | ឧបមាដូចដំរី .................................................... | ៣១៣ |
| | | ឧបមាដូចបុរសកំសត់....................................... | ៣១៥ |
| | | ឧបមាដូចគហបតីឬគហបតិបុត្រ........................ | ៣១៧ |
| | | បុគ្គល ៤ ពួក.................................................. | ៣២១ |
| | | ការពោលអំពីឈាន ៤....................................... | ៣២៥ |
| | | ការពោលអំពីការលះ ....................................... | ៣២៧ |


## ចាតុមសូត្រ ទី ៧


| | | | |
|---|---|---|---|
| ភិក្ខុវគ្គ | ចាតុមសូត្រ | សំឡេងគឹកកងសំឡេងអ៊ូអា ............................. | ៣៣១ |
| | | ពួកសក្យចូលគាល់ព្រះមានព្រះភាគ .................. | ៣៣៣ |
| | | ព្រហ្មក្រាបបង្គំទូលអារាធនា .............................. | ៣៣៥ |
| | | ពួកភិក្ខុចូលគាល់ព្រះមានព្រះភាគ ..................... | ៣៣៧ |
| | | ការពោលអំពីភ័យកើតអំពីរលក......................... | ៣៣៩ |
| | | ការពោលអំពីភ័យកើតអំពីក្រពើ.......................... | ៣៤១ |
| | | ការពោលអំពីភ័យកើតអំពីអន្លង់......................... | ៣៤៣ |

# មាតិកាបត្តានិ

អង្គេ

ភិក្ខុវគ្គស្ស ចាតុមសុត្តេ សុសុកាភយកថា .................................. ៣៤៥

## អដ្ឋមំ នឡកបានសុត្តំ

ភិក្ខុវគ្គស្ស នឡកបានសុត្តេ ព្រហ្មចរិយាភិរមកថា ............................. ៣៤៩

អាសវបុច្ឆា............................................ ៣៥៣

ភិក្ខុផាសុវិហារោ..................................... ៣៥៥

ភិក្ខុនីផាសុវិហារោ.................................. ៣៥៩

ឧបាសកផាសុវិហារោ............................ ៣៦១

ឧបាសិកាផាសុវិហារោ .......................... ៣៦៣

## នវមំ គោលិស្សានិសុត្តំ

ភិក្ខុវគ្គស្ស គោលិស្សានិសុត្តេ តតិយារញ្ញកវត្តំ..................................... ៣៦៩

បញ្ចមារញ្ញកវត្តំ...................................... ៣៧១

អដ្ឋមារញ្ញកវត្តំ........................................៣៧៣

ពារសមារញ្ញកវត្តំ ................................. ៣៧៥

# សង្ខេបកចង្អុលទ្រាប់មាតិកា


លេខទំព័រ

ភិក្ខុវគ្គ ចាតុមសូត្រ ការពោលអំពីភ័យកើតអំពីត្រីសាហារ ..................................... ៣៤៥

## នឡកបានសូត្រ ទី ៨

ភិក្ខុវគ្គ នឡកបានសូត្រ ការនិយាយពីសេចក្តីត្រេកអរក្នុងព្រហ្មចារ្យ......... ៣៤៩

ការទ្រង់សាកសួរអំពីអាសវៈ ............................. ៣៥៣

ផាសុវិហារធម៌របស់ភិក្ខុ ................................... ៣៥៥

ផាសុវិហារធម៌របស់ភិក្ខុនី ................................. ៣៥៩

ផាសុវិហារធម៌របស់ឧបាសក ............................ ៣៦១

ផាសុវិហារធម៌របស់ឧបាសិកា........................... ៣៦៣

## គោលិស្សានិសូត្រ ទី ៩

ភិក្ខុវគ្គ គោលិស្សានិសូត្រ អារញ្ញកវត្ត ទី ៣ ............................................. ៣៦៩

អារញ្ញកវត្ត ទី ៥................................................ ៣៧១

អារញ្ញកវត្ត ទី ៨................................................ ៣៧៣

អារញ្ញកវត្ត ទី ១២.............................................. ៣៧៥

# មាតិកាបត្តានិ

អង្កេ

*ភិក្ខុវគ្គស្ស គោលិស្សានិសុត្តេ បណ្ណរសមារញ្ញកវត្តំ.............................. ៣៧៧*

*សត្តរសមារញ្ញកវត្តំ................................ ៣៧៩*

## ឆសមំ កីដាគិរិសុត្តំ

*ភិក្ខុវគ្គស្ស កីដាគិរិសុត្តេ ភគវន្តូបសង្កមនំ.................................... ៣៨៣*

*តិស្សោ វេទនា ....................................... ៣៨៧*

*សុខវេទនាកថា .................................... ៣៨៩*

*ទុក្ខវេទនាកថា....................................... ៣៩១*

*អប្បមាទោ............................................. ៣៩៣*

*សត្តសុ បឋមបុគ្គលោ............................. ៣៩៥*

*សត្តសុ ចតុត្ថបុគ្គលោ.............................. ៣៩៧*

*សត្តសុ ឆដ្ឋបុគ្គលោ ................................ ៣៩៩*

*សត្តសុ សត្តមបុគ្គលោ ........................... ៤០១*

*អញ្ញារាធនា.......................................... ៤០៣*

*ទ្វិប្បលបាដិកង្ខតា................................... ៤០៥*

# សន្លឹកចង្អុលប្រាប់មាតិកា

លេខទំព័រ


ភិក្ខុវគ្គ គោលិស្សានិសូត្រ អារញ្ញកវត្ត ទី ១៥.......................................... ៣៧៧

អារញ្ញកវត្ត ទី ១៧.......................................... ៣៧៩


## *កីដាគិរិសូត្រ ទី ១០*


ភិក្ខុវគ្គ កីដាគិរិសូត្រ ការចូលគាល់ព្រះមានព្រះភាគ.......................... ៣៨៣

វេទនា ៣ ........................................................ ៣៨៧

ការពោលអំពីសុខវេទនា.................................. ៣៨៩

ការពោលអំពីទុក្ខវេទនា.................................. ៣៩១

សេចក្តីមិនប្រមាទ ............................................ ៣៩៣

បុគ្គលទី ១ ក្នុងពួកបុគ្គលទាំង ៧....................... ៣៩៥

បុគ្គលទី ៤ ក្នុងពួកបុគ្គលទាំង ៧....................... ៣៩៧

បុគ្គលទី ៦ ក្នុងពួកបុគ្គលទាំង ៧....................... ៣៩៩

បុគ្គលទី ៧ ក្នុងពួកបុគ្គលទាំង ៧....................... ៤០១

ការត្រេកអរចំពោះអរហត្តផល .......................... ៤០៣

ការបានសម្រេចនូវផលពីរប្រការ....................... ៤០៥